LIBRARY

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



រូបបដិមានៃព្រះបាទជ័យវរ្ម័ន ទី៧ ( បរមសៅគត )

ឆ្នាំទី ៤៩ លេខ ១ ខែ មករា - កុម្ភៈ - មីនា

ព.ស ២៥៣៨ គ.ស ១៩៩៥

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន ៖


ទីប្រឹក្សា : **ហៀន ចណ្ណារក្ខ**

នាយកការផ្សាយ : **ឈន អៀម**

និពន្ធនាយក : **យី ធន់**

និពន្ធនាយករង : **ឱម ខែម**

គណៈកម្មការនិពន្ធ

សម្ដេចព្រះធម្មលិខិត **លាស់ ឡាយ**, ព្រះមហាព្រហ្មមុនី **ហេង លាងហោ**,

លោក **ម៉ែន ប្រាង**, លោក **អាំ ឆន**,

## ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの宗教と文化の発展に貢献できれば幸いです。

## ACKNOWLEDGEMENT

The Kampuja Surya Magazine is specially printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC).

We pray that this magazine would contribute to the Friendship with Cambodian people and their religious and cultural preservation.

## និវេទនកថា

ទស្សនាវដ្ដីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគម្រោងការងារ របស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោកស្ដីពីសាសនានិងសន្តិភាព (WCRP) ហើយនិងគណៈកម្មាធិការជំនួយសូតូស៊ូជប៉ុន (JSRC) ។

យើងខ្ញុំអធិដ្ឋាន សូមឱ្យទស្សនាវដ្ដីនេះ បានជាវិភាគទានរក្សាមិត្តភាពជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិសាសនានិងវប្បធម៌របស់ប្រជាជនកម្ពុជា ។

## មាតិកាអត្ថបទ

I. អក្សរសិល្ប៍ពុទ្ធសាសនា :

- ព្រះធម៌របស់ព្រះពុទ្ធ (ត ចប់) ........................................ ១
- សង្គាយនា ទី៥ ........................................ ១៥
- កោសម្ពិកភិក្ខុ ........................................ ១៩
- បញ្ហាបួស ........................................ ២៧
- ទស្សនវិជ្ជាសេដ្ឋកិច្ចពុទ្ធសាសនា ........................................ ៣៥

II. អក្សរសាស្ត្រទូទៅ :

- កាព្យរំលឹកអំពីអក្សរខ្មែរ ........................................ ៤៥
- ច្បាប់កេរកាលថ្មី ........................................ ៤៨
- លក្ខណៈពិសេសនៃជជនជាតិខ្មែរ (ត) ........................................ ៦២
- ប្រទេសកម្ពុជាតាមរយៈអក្សរសាស្ត្ររបស់ខ្លួន ........................................ ៧៥
- ការស្វែងរកមន្តរំដោះគ្រោះ ........................................ ១០០
- ឈ្មោះបទភ្លេងខ្មែរ ........................................ ១០៦
- គួរយើងទុកវត្ថុខ្លះនៅខាងក្រោយយើង ........................................ ១១១
- រឿងមិត្តសម្លាញ់ ២ នាក់ ........................................ ១១២
- សេចក្ដីជូនដំណឹងអំពីលទ្ធផលនៃចម្លើយប្រស្នាកំណាព្យ ........................................ ១១៥
- ចម្លើយកំណាព្យប្រស្នា ........................................ ១១៧
- អ្នកប្រើជញ្ជីង ........................................ ១២១
- ● កំណាព្យប្រស្នា : ការលុបដីចម្លែក ........................................ ១២៣
- សេចក្ដីអំពាវនាវរបស់ពុទ្ធសាសនបណ្ឌិត្យ ........................................ ១២៤

# ព្រះធម៌របស់ព្រះពុទ្ធ

(តចប់)

ដោយភិក្ខុ Jagdish Kasyapa

បកប្រែដោយ **ឈន អៀម**

## *គ. ទាំងអស់គឺជាទុក្ខៈ ឬ ការឈឺចាប់*

ទុក្ខៈ គឺគ្រាន់តែជាហេតុការណ៍មួយ ដែលជាសំខាន់តែងអន្ទោលតាមសច្ចភាពនៃអនិច្ចៈ និងអនត្តៈ (La vérité de l'impermanence et de l'absence de substancialité) ។ វាគ្មានអចិន្ត្រៃយភាព ឬសារជាតិណាមួយ ដែលអាចត្រូវបានប្រកាន់យកដោយក្ដីសង្ឃឹមថាមានសន្តិសុខ និងការសប្បាយរីករាយនោះទេ ។ ដោយអាស្រ័យទៅតាមតណ្ហារបស់យើង យើងខិតខំស្រវាចាប់តោងពិភពលោក ហើយភ្ជាប់ខ្លួនទៅនឹងពិភពលោកនេះ, ប៉ុន្តែ ពិភពលោកនេះរត់ចេញពីយើងយ៉ាងលឿន, មុនពេលប្រាប់យើងអោយដឹងទៅទៀត, ហើយដោយប្រការនេះ យើងឋិតនៅតែជាមួយសេចក្ដីក្រៀមក្រំ និងការសោកស្ដាយ ។ វាគ្មានកន្លែងណាមួយជាកន្លែងសំរាកទេនៅក្នុងចក្រវាឡនេះ ដែលយើងធ្វើដំណើរទៅហើយឋិតនៅដើម្បីលំហែចិត្តយើងនោះឡើយ ។ អ្វី១ទាំងអស់គឺជាអនិច្ចៈ និងអនត្តៈ ឬអនិច្ចភាព និងគ្មានសារជាតិ ឬគ្មានអត្តៈឋិតថេរទេ ។

ព្រះពុទ្ធទ្រង់មានពុទ្ធដីកាថា : " ទាំងនៅក្នុងអាកាស ទាំងនៅក្នុងជំរៅ នៃមហាសាគរ ទាំងនៅក្នុងរូងភ្នំ, គ្មានកន្លែងណាមួយនៅលើផែនដីនេះ, អ្នកនឹងរកឃើញជំរកមួយ ដែលនៅទីនោះមរណភាពនឹងមិនមកតាមរកអ្នក ហើយផ្ដួលរំលំអ្នកនោះឡើយ ( ធម្មបទ ) " ។

ទុក្ខៈ គឺជាអរិយសច្ចៈទីមួយដែលត្រូវពិព័ណ៌នាយ៉ាងក្បោះក្បាយនៅក្នុង បឋមទេសនា, ធម្មចក្កប្បវត្តនសូត្រ ដែលព្រះពុទ្ធបរមគ្រូទ្រង់បានសំដែងដល់បញ្ច-វគ្គិយភិក្ខុ នៅឥសិបតនៈ ជិតក្រុងប៉េណារ៉េស ។

វាជាការគួរអោយជាប់ចិត្តមួយ ដើម្បីកត់សំគាល់ថា តើទ្រឹស្តីខុសៗគ្នានៃទស្សនវិជ្ជាឥណ្ឌា ពន្យល់បញ្ហានៃទុក្ខៈតាមបែបរៀងៗខ្លួនយ៉ាងណាខ្លះ ហើយថាតើទ្រឹស្តីផ្សេងៗទាំងនោះ ផ្តល់សច្ចភាពដូចម្តេចចំពោះទុក្ខៈ ។

ទស្សនវិជ្ជាវេទន្តៈ បង្ហាញពីភាពផ្ទុយគ្នាស្រឡះពីពុទ្ធលទ្ធិ ៖ ទស្សនវិជ្ជានោះ ប្រកាន់ខ្ជាប់មតិស្តីពី សត - ចិត - អានទៈ ( Sat - Cit - Anada ) ៖ និច្ចៈ ចិត្ត សុខៈ ( permanenence-esprit - bonheur ) ផ្ទុយទៅនឹងទ្រឹស្តីពុទ្ធសាសនា ស្តីពី ៖ អនិច្ចៈ - អនត្តៈ - ទុក្ខៈ ( Impermanence - Absence d'égo-Souffrance ) ។

តាមវេទន្តៈ, ឯកភាពមួយនឹងថ្កល់ ហើយមិតវន្ត គឺមានពិតប្រាកដ ហើយពិភពលោកប្រកបដោយវិវិធភាព ( Le monde de diversité ) មានដំណើរដូចទឹកជោរជាប្រចាំ គឺជាមាយា ឬជាការថ្លើនភ្នែក ។ ចិត្តនិយមកាន់សាសនាតឹងរ៉ឹង ( l' esprit mystique ) គឺពិត, ហើយចិត្តដែលអាងលើពិសោធន៍ ហើយនិង រូប-ធាតុ ( l' esprit empirique et la matière ) គឺជាមាយា ( Illusion ) ។ សុខៈ គឺពិត ហើយទុក្ខៈ គឺជាមាយា ។ ចិត្តនិយមកាន់សាសនាតឹងរ៉ឹងតែមួយនិងរីករាយ មានឈ្មោះថា ព្រហ្មៈ តាមទស្សនវិជ្ជាវេទន្តៈ ហើយទស្សនវិទូតែងធ្វើការដើម្បីចាប់បានធម្មជាតិនេះរបស់ព្រហ្មៈ ។

ទស្សនវិជ្ជា សង្ខ្យា - យោគៈ ៖ មិនដាក់កំហុសពិភពលោក ហើយនិងទុក្ខៈថាជាមាយាទេ, ប៉ុន្តែ អះអាងសច្ចភាពបរត្តវិជ្ជារបស់មាយាទុកដូចសច្ចវិជ្ជមាន ។ ប៉ុន្តែ ក្នុងពេលដដែលនេះ ចំពោះលោកសម្ភារៈ, ទស្សនវិជ្ជា សង្ខ្យា-យោគៈ ជឿលើ

ពហុភាពនៃចិត្តនិយមកាន់សាសនាតឹងរ៉ឹង ( Une pluralité d'esprits mystiques ) ដែលកផ្តុំជាសារៈស្នូលនៃមនុស្ស, សារៈស្នូលនេះ ជាសភាវៈបរិសុទ្ធនៅក្នុងធម្មជាតិរបស់វា, ជាសព្វញ្ញូ ( Omniscient ) និងសេរី ។ គេអោយឈ្មោះ សារៈស្នូលនេះថា បុរុសៈ ។

បុរុសៈទាំងឡាយ, តាមធម្មតា ជាសភាវៈបរិសុទ្ធ, បែបបទដែលបុរុសៈត្រូវសៅហ្មងដោយបាប និងសេចក្ដីទុក្ខនោះ, ត្រូវបានគេពន្យល់តាមរូបភាពមួយដ៏ល្អក្រៃលែង ។

ចំណាំងពន្លឺនៃផ្កាព័ណ៌ក្រហមចោលទៅលើកញ្ចក់ដ៏ថ្លាមួយ ហើយចំណាំងពន្លឺនេះ ក៏មានព័ណ៌ក្រហមនេះដែរ ។ ប្រការនេះ កញ្ចក់ពុំមែនកញ្ចក់ក្លាយទៅជាមានព័ណ៌ក្រហមនោះទេ, ប៉ុន្តែ វាហាក់ដូចជាមានព័ណ៌ក្រហម ពីព្រោះតែវាបានរួមជាមួយផ្កា ។ ដូចគ្នានេះដែរ អនិច្ចភាព ( ភាពប្រែប្រួល ) នៃលោកសម្ភារៈត្រូវចោលពន្លឺទៅលើបុរុសៈ ដោយហេតុនេះ បុរុសៈ ក៏ត្រូវបានគេមើលឃើញតាមភាពល្ងង់ខ្លៅថា អនិច្ចភាព ( ភាពប្រែប្រួល ) គឺជាចរិតលក្ខណៈផ្ទាល់របស់បុរុសៈ ។ តាមការពិត, ចរិតបរិសុទ្ធរបស់បុរុសៈ មិនអាចត្រូវបានធ្វើអោយសៅហ្មងកើតឡើយ ។

ដូច្នេះ សង្ខ្យា បង្ហាញទុក្ខៈ មិនមែនជាមាយា ដូចជាវេទន្តៈ បានបង្ហាញទេ, ប៉ុន្តែ សង្ខ្យា ផ្ដល់អោយទុក្ខៈ នូវស្រមោលតថភាព ។ ទស្សនិជ្ជា សង្ខ្យា មិនពន្យល់ផងទេថា តើអវិជ្ជាដែលធ្វើអន្តរាគមន៍ចូលក្នុងធម្មជាតិបរិសុទ្ធនោះបានធ្វើអោយចំណាំងពន្លឺច្រឡូកច្រឡំជាមួយតថភាពនោះយ៉ាងដូម្ដេចខ្លះ ? នេះគឺមានន័យថា ធម្មជាតិរបស់បុរុសៈ ត្រូវបានសៅហ្មងរួចស្រេចទៅហើយ មុនពេលចំណាំងពន្លឺជះទៅលើខ្លួន ។ ដូច្នេះ ធម្មជាតិរបស់បុរុសៈខ្លួនឯងផ្ទាល់មិនទាន់ត្រូវបានបញ្ជាក់អះអាងទេ ។ ការជំទាស់ជាច្រើនទៀត អាចត្រូវបានគេលើកឡើងប្រឆាំងនឹង

ទស្សនវិជ្ជាសង្ខ្យា ។ សង្ខ្យាពុំអាចឆ្លើយតបទៅនឹងការជំទាស់ទាំងនោះបានតាមទស្សនវិស័យរបស់ខ្លួន ដ៏គួរជាទីពេញចិត្តទេ ។

ទស្សនវិជ្ជា ន្យាយៈ ចាត់ទុកទុក្ខវេទនាដូចជាកេតនភណ្ឌមួយរបស់អាត្មា ហើយទស្សនវិជ្ជាជេន ( Jain ) ចាត់ទុកទុក្ខវេទនាជារបាំងមួយ ឬ " អវណៈ" ( avarna ) លើជីវាដ៏បរិសុទ្ធ ។

ទស្សនវិជ្ជាផ្សេង ៗ គ្នាទាំងអស់នោះ មិនយល់ថាទុក្ខៈ ជាតថភាពមួយទេ ពីព្រោះទស្សនវិជ្ជាទាំងឡាយនោះ មិនអាចរំដោះខ្លួនផុតពីសញ្ញាណល្ងង់ខ្លៅ ថាមានព្រលឹងមួយជាអចិន្ត្រៃយ៍បានទេ ។

យើងបានឃើញថា មានតែនៅក្រោមពន្លឺដ៏ពិតប្រាកដរបស់អនិច្ចៈទេ ទើបអវិជ្ជាស្តីពីព្រលឹង ឬ អាត្មនលុបបំបាត់បាន ហើយគេចាត់ទុកទុក្ខវេទនា តាមសភាវៈជាក់ស្តែងរបស់វាបាន ។

កាលណាមនុស្សមើលឃើញ ទុក្ខៈ ក្នុងសភាវៈជាក់ស្តែងរបស់វា, មនុស្សស្វែងរកការរំដោះខ្លួន អោយផុតពីទុក្ខៈ ។

## II. តើនិរោធៈ ( និព្វាន ) ជាអ្វី ?

ដោយប្រថុយរៀបរាប់ឡើងវិញ នូវចំណុចខ្លះៗដែលបាននិយាយខាងលើរួចហើយ, ចូរយើងអត់ធ្មត់លើកយកចំណុចដដែលៗ មករៀបរាប់អោយបានល្អិតល្អន់ជាថ្មី ។

លោកនេះ ត្រូវបានគ្រប់គ្រងដោយក្រឹត្យក្រមបដិច្ចសមុប្បាទ ឬប្រភពកំណើតអាស្រ័យទាក់ទង ( Des origines dépendantes ) ។ គ្មានអ្វីមួយមានដើមកំណើត ដោយកំណើតនោះមិនអាស្រ័យ ( ពឹងផ្អែក ) អ្វីមួយដែលកើតមានពីមុនដើមកំណើតនោះទេ ។ ហើយវាក៏មិនអាចមានអ្វីមួយ មានដើមកំណើតដែល

មិនផ្តល់កំណើតជាបន្តវេនទៅអោយវត្ថុអ្វីមួយផ្សេងទៀតដែរ ។

## ឧ ទា ហ រ ណ៍

ជាងម៉ាស៊ីនធ្វើអោយឌីណាម៉ូវិល ។ ចលនានេះ បណ្តាលអោយមានការត្រដុសកកិត ( Une friction ) ។ ការត្រដុសកកិតផលិតអគ្គិសនី ។ អគ្គិសនីធ្វើអោយកង្ហារវិល ។

ប្រសិនបើជាងម៉ាស៊ីនមិនធ្វើអ្វីទេ, ឌីណាម៉ូក៏មិនកំរើក ។ បើឌីណាម៉ូមិនកំរើក នោះក៏ពុំមានការត្រដុសកកិត, គ្មានការត្រដុសកកិតនោះ ក៏គ្មានអគ្គិសនីដែរ ហើយបើគ្មានចរន្តអគ្គិសនីទេ, កង្ហារក៏ពុំអាចវិលកើត ។

នៅក្នុងឧទាហរណ៍នៃខ្សែសង្វាក់ហេតុនិងផល, ព្រឹត្តិការណ៍មួយកកើតមានឡើងដោយអាស្រ័យព្រឹត្តិការណ៍មួយទៀតដែលមានមុននេះ ។ អវត្តមាននៃធាតុណាមួយ ក្នុងបណ្តាធាតុទាំងឡាយរបស់ខ្សែសង្វាក់ នឹងត្រូវបញ្ឈប់នូវអ្វីៗទាំងអស់ដែលនឹងកកើតឡើងតាមក្រោយជាបន្តបន្ទាប់ ។ ដោយប្រការយ៉ាងនេះឯង ដែលធម្មជាតិត្រូវបានបញ្ចេដោយក្រឹត្យក្រមបដិច្ចសមុប្បាទនោះ ។

ព្រះពុទ្ធជាម្ចាស់បានអនុវត្តក្រឹត្យក្រមបដិច្ចសមុប្បាទនេះ ក្នុងការពន្យល់ " ទុក្ខៈ, ជាតិ, ជរា, និងសេចក្តីឈឺចាប់ " ។

## តណ្ហានាំអោយកើតមានឧបាទាន

តណ្ហា គឺជាចំណង់ ឬសេចក្តីជាប់ជំពាក់, ឯឧបាទាន គឺជាអ្វីដែលតោងស្អិត ចង់អោយសំរេចបាននូវចំណង់នោះ ។

យើងបានឃើញវត្ថុមួយដ៏ល្អ ហើយយើងរំភើបដោយចំណង់ចង់បានវត្ថុនោះ : ខ្ញុំចង់បានវត្ថុនោះ, វាត្រូវតែបានមកខ្ញុំ ។ ចំណង់នេះរុញច្រានយើង

ទៅរកការប្រឹងប្រែង ទៅរកការប្រយុទ្ធដណ្តើមយកវត្ថុនោះ ។ នេះគឺការភ្ជាប់ខ្លួនទៅនឹងវត្ថុ។

## ឧបាទាននាំអោយកើតមានភព

ភពមានន័យដោយផ្ទាល់ថា អត្ថិភាព ( ភាពកើតមាន ), ក្នុងទីនេះ, វាមានន័យថា អត្ថិភាពនៃអភិក្រមជីវិតរបស់យើង ។ យ៉ាងណាមិញ, គឺដោយប្រការដែលយើងក្រាញតោងភ្ជាប់ខ្លួនយើងទៅនឹងនេះ ឬទៅនឹងនោះហើយ ទើបមានឡើងនូវអត្ថិភាពនៃអភិក្រមជីវិតរបស់យើង ។

តើជីវិតរបស់យើងជាអ្វី, បើមិនមែនជាខ្សែសង្វាក់ជាប្រចាំនៃសេចក្តីជាប់ជំពាក់ចិត្តចង់បានអ្វីដែលយើងខិតខំស្វែងរក ហើយជៀសអោយផុតពីអ្វីដែលធ្វើអោយយើងខកចិត្ត ឬមិនពេញចិត្តនោះ ។

ស៊ី ផឹក ដើរ និងសកម្មភាពដ៏តូចតាចបំផុតរបស់យើង គឺត្រូវបានធ្វើឡើងដើម្បីរ៉ាប់រងអោយយើងមានផាសុកភាពជាអតិបរមា ។ យើងមិនអាចនឹកគិតប្រឌិតឡើងនូវជីវិតណាមួយដែលគ្មានសេចក្តីជាប់ជំពាក់ចិត្តនោះបានឡើយ ។

ដូច្នេះ, អត្ថិភាពនៃអភិក្រមជីវិតរបស់យើងកើតមានអាស្រ័យដោយមានសេចក្តីជាប់ជំពាក់ចិត្តនេះឯង ។

## ភពនាំអោយកើតមានជាតិ ជរា មរណៈ - ល -

កាលណាអភិក្រមនៃជីវិតកើតមានហើយ, វានាំអោយមានជាតិ ជរា មរណៈ ; គេបានជួបនឹងជោគជ័យ និងបរាជ័យ, គេមានសេចក្តីសង្ឃឹម និងសេចក្តីខកចិត្ត ហើយព្រមទាំងសេចក្តីព្រួយបារម្ភជាបន្តបន្ទាប់ ។

*បើយើងអាចយកជំនះលើតណ្ហារបស់យើងបាន, នោះវានឹងពុំមាន*

*ឧបាទានទេ*, ពីព្រោះថា តើសេចក្ដីជាប់ជំពាក់ចិត្តអាចកើតមានដូចម្ដេចបាន កាលណាវាគ្មានចំណង់នោះ ? ព្រះអរហន្តមួយអង្គ បានឃើញវត្ថុដ៏ល្អមួយ, ប៉ុន្តែលោកពុំមានព្រះទ័យរំភើបដោយចំណង់ ឬ សេចក្ដីជាប់ជំពាក់ចិត្តចំពោះវត្ថុនោះទេ ហើយដោយហេតុនេះ លោកគ្មានមនោសញ្ចេតនាបែបណាមួយក្នុងខ្លួនរបស់លោក ដើម្បីតោងស្អិតចង់បានវត្ថុនោះឡើយ ។

*ការគ្មានសេចក្ដីជំពាក់ចិត្ត មានន័យថាបញ្ឈប់អភិក្រមនៃជីវិត ។*

កាលណាអភិក្រមនៃជីវិតត្រូវបានបញ្ឈប់, វាគ្មានកំណើត គ្មានចាស់ជរា គ្មានការឈឺចាប់ ( ទុក្ខៈ ) ទេ ។ ដូចនេះ ទុក្ខៈក៏ត្រូវបានបញ្ឈប់ ។ សេចក្ដីព្រួយកង្វល់គ្រប់យ៉ាងត្រូវបានបន្សាត់បង់ឆ្ងាយ ។

គេអោយឈ្មោះថានិព្វាន នូវការរំលត់ទាំងស្រុងនៃចំណង់គ្រប់ជំពូក : " តស្សាយេវ តណ្ហាយអសេសវិរាគនិរោធោ" ។

## ជីវិតរបស់ព្រះអរហន្ត

ព្រះអរហន្ត បានផ្ដាច់ឫសគល់ចំណង់គ្រប់យ៉ាងហើយ ដោយហេតុនេះ លោកគ្មានសេចក្ដីជាប់ជំពាក់ចិត្តណាមួយទេ ។ គេអាចលើកឡើងជាពាក្យជំទាស់ថា បើព្រះអរហន្តគ្មានសេចក្ដីជាប់ជំពាក់ចិត្តទេ តើអភិក្រមនៃជីវិតរបស់លោកបន្តទៅយ៉ាងម៉េចកើត ? ពីព្រោះថា គឺដោយអាស្រ័យការជាប់ជំពាក់ចិត្តនេះហើយ ទើបអត្ថិភាពនៃអភិក្រមជីវិតកើតឡើងបាន ដូចដែលយើងបានឃើញរួចមកហើយ ។

សំណួរនេះ អាចរកឃើញចំម្លើយតាមការប្រៀបធៀបជីវិតរបស់ព្រះអរហន្តទៅនឹងចលនានៃកង្ហារ ។ កាលណាគេបញ្ឈប់ចរន្តអគ្គិសនី, កង្ហារបន្តវិលមួយរយៈខ្លីដោយមានចរន្តកាត់ផ្ដាច់ហើយ, ដោយយោលទៅតាមល្បឿនដែលនៅសល់ ។ លុះដល់ពេលកំលាំងជំរុញនឹងស្ងួតហើយ កង្ហារត្រូវឈប់ស្ងៀម ។

ព្រះអរហន្តបានធ្វើអោយចំណង់គ្រប់យ៉ាងឈប់មានហើយ ហើយមិនបង្កើតអោយមានសេចក្ដីជាប់ជំពាក់ចិត្តទៀតទេ, ប៉ុន្តែ អភិក្រមនៃជីវិតនៅតែបន្តដោយយោលទៅតាមកំលាំងជំរុញកម្ម តណ្ហារបស់លោក និងសេចក្ដីជាប់ជំពាក់ចិត្តរបស់លោកពីមុន ។ លោកចូលកាន់បរិនិព្វាន កាលណាអភិក្រមនៃជីវិតត្រូវបានបញ្ឈប់ទាំងស្រុងក្រោយការរំលត់រូបកាយរបស់លោក និងកាលណាកំលាំងកម្មមុនៗ ត្រូវរីងស្ងួតអស់ ។

ភ្លើងត្រូវរលត់ ហើយត្រជាក់ឡើងវិញ ៖ សីតភូតោ បរិនិព្វុតោ ។

## សំណួរដ៏ខុសឆ្គងមួយ ( Une question absurde )

ជូនកាលគេសួរថា ៖" ចុះមនុស្សទៅជាយ៉ាងណា ក្រោយគេបរិនិព្វាន ?"

គឺជាសំណួរមិនទំនងមួយ ។ អភិក្រមជីវិតរបស់មនុស្សចេះតែបន្ត ដរាបណាមនុស្សនៅតែកំរើករំភើបដោយ ( animé ) តណ្ហា ។ កាលណាតណ្ហាឈប់, អភិក្រម ក៏ឈប់មាន ។ គ្មានហេតុ, ផលក៏ពុំកើតមាន ។

សំណួរនេះដូចគ្នា សួរថា ៖"តើចលនាកង្ហារទៅជាយ៉ាងណា កាលណាកង្ហារត្រូវឈប់ ?" គេអាចឆ្លើយតបនឹងសំណួរនេះ ដោយនិយាយថា ៖ គ្មានហេតុ, ផលក៏មិនកើតមានដែរ ។

## ការធ្វើអោយសាបសូន្យអត្ត ៖ ( Le Moi )

អ្នកខ្លះអាចនឹងចោទសួរថា តើនិព្វានជាការធ្វើអោយសាបសូន្យអត្តៈ ឬ ?

តាមពុទ្ធសាសនា ពាក្យថា" ឧច្ឆេទ" គឺការធ្វើអោយសាបសូន្យ គឺជាភាវៈមិនអាចធ្វើបាន ។ គ្មានអ្វីអាចត្រូវធ្វើអោយសាបសូន្យបានទេ ។ យើងក៏មិនអាចធ្វើអោយសាបសូន្យ សូម្បីតែតំណក់ទឹកមួយ ឬកំទេចធូលីដ៏តូចបំផុតមួយបានទេ ។

អ្វីដែលមានអត្ថិភាព ពុំអាចត្រូវបានធ្វើអោយគ្មានអត្ថិភាពកើតទេ, ។ តើអត្តៈអាច នឹងត្រូវគេធ្វើអោយសាបសូន្យដូចម្តេចកើត ?

កំហុសដ៏ពិតប្រាកដនៃការសង្ស័យដែលបានពោលហើយនេះ គឺមាននៅក្នុងគំនិតដែលប្រឌិតអំពី "អត្តៈ = Le Moi" ។ ពុទ្ធសាសនាមិនអះអាងអំពីអត្ថិភាពនៃអត្តៈអចិន្ត្រៃយ៍បែបនោះទេ ។

ចលនាកង្វារត្រូវបានបញ្ឈប់ កាលណាចរន្តត្រូវបានកាត់ផ្តាច់ ។ នេះពុំមានន័យថាចលនាត្រូវបានកំទេចសាបសូន្យនោះទេ ។ នេះក៏ពុំមានន័យផងដែរថាវាមានអង្គភាពដដែលមួយនៃចលនា ( Une unité identique du mouvement ), ហើយអង្គភាពនេះ ត្រូវបានធ្វើអោយសាបសូន្យ ។ គេអាចយល់រឿងនេះបានក្រោមពន្លឺនៃអ្វីដែលយើងបាននិយាយជាញឹកញយថា ៖ បើគ្មានហេតុ ផលពុំអាចកើតមានបានទេ ។

ដូច្នេះ និព្វានមានន័យស្មើនឹងការបញ្ឈប់នៃកំណើត ( ជាតិ ) ជរា ..... ដោយការបញ្ឈប់តណ្ហា ។

## និព្វាន គឺជាសភាវៈមួយនិរន្តរ៍ឬទេ ?

អ្នកសួរអាចជជីកសួរថា ៖ ប្រសិនបើនិព្វានពុំមែនជាបរិសូន្យ (Anni hilation) ទេ, តើជាសភាវៈមួយនិរន្តរ៍ឬទេ ?

សំណួរនេះក៏បានសួរខុសឆ្គងដែរ ពីព្រោះវានាំទៅដល់ចុងបំផុត (អច្ចន្តភាព) មួយទៀត នៃសស្សតវាទ ( l' éternalisme ) ។ តាមព្រះធម៌របស់ព្រះពុទ្ធ, វាគ្មានជីវិតណាមួយជានិរន្តរ៍ ឬ ជានិច្ចៈទេ ។ អ្វីៗទាំងអស់ដែលកើតឡើងតាមព្រះពុទ្ធជាម្ចាស់មានព្រះពុទ្ធដីកា , គឺជា អនិច្ចំ និង ទុក្ខំ ពោលគឺមិនឋិតថេរជានិរន្តរ៍ ហើយប្រកបដោយទុក្ខសោក, ទស្សនៈស្តីពីនិរន្តរភាពនៃសុភមង្គល គឺជាអប្បិយ-

ជំនឿ ( Une superstition ) ដែលនាំទៅរកការភ័ន្តច្រឡំ ។

កាលណាគេនិយាយថា គេអាចទៅដល់ព្រះនិព្វាននៅក្នុងជាតិនេះតែម្តង, នេះគឺមិនមែនមានន័យថា ភាវៈដ៏វិករាយបែបណាមួយអាចសំរេចបាននោះទេ, ពីព្រោះ នេះគឺអាចជាជោគជ័យលោកិយ បីដូចជាស្ថាននិព្វានប៉ុណ្ណោះ ។ នេះវាគ្រាន់តែមានន័យថា : មនុស្សសំរេចបញ្ឈប់ទាំងស្រុងនូវតណ្ហាក្នុងជីវិតនេះ ហើយក្លាយខ្លួនជាព្រះអរហន្ត ។

តាមការណ៍ពិត, សំណួរថា " តើនេះជាសភាវៈមួយឬ ? " ក៏មិនអាចត្រូវបានលើកយកមកចោទបានទេ ។ ភាវៈមួយ ( Une état ) ចង្អុលបញ្ជាក់វត្ថុមួយដែលកើតមានដោយភាពអចិន្ត្រៃយ៍ ។ តាមព្រះពុទ្ធសាសនា, គ្មានកត្តាអចិន្ត្រៃយ៍បែបណាមួយនៅក្នុងមនុស្សដែលគេអាចនិយាយថា វាមានអត្ថិភាពនៅក្នុងភាវៈណាមួយក្រោយនិព្វាននោះទេ ។

គ្មានភាវៈណាមួយនៃវត្ថុណាមួយអាចកើតមាននៅទីណាដែលគ្មានជាតិ (ការកើត) គ្មានជរា គ្មានមរណភាពនោះឡើយ ។ ពាក្យស្លោករបស់ពុទ្ធសាសនាគឺ : " Yat sat, tat ksanikam" = អ្វីមួយដែលមានអត្ថិភាព, អ្វីនោះគឺបណ្តោះអាសន្ន ។

ដូច្នេះ និព្វានមិនមែនជាបរិសូន្យ ( Annihilation ) = " ឧច្ឆេទ" ទេ, ហើយក៏ពុំមែនជាស្ថានមួយអនន្តដែរ (សស្សតៈ), ពីព្រោះជំរើសណាមួយក្នុងបណ្តាជំរើសទាំងនេះ គឺសុទ្ធតែមិនអាចពន្យល់កើតដោយខ្លួនឯងតែម្តង ។

ហេតុនេះ បរិនិព្វាន គឺការឈប់មានជាតិ, ឈប់មានជរា ... ដោយការអស់ទៅនៃតណ្ហា - គ្មានផលបណ្តាលមកពីគ្មានហេតុ ។

## តើនិព្វានជាបរមសុខឬ ?

ព្រះបរមគ្រូបានបញ្ជាក់ផ្ទាល់ព្រះអង្គថា" និព្វានំ បរមំ សុខំ " ឬថា និព្វានជាបរមសុខដ៏ក្រៃលែង ។ ប៉ុន្តែ ឃ្លានេះមិនត្រូវយល់ដោយត្រង់ៗ ដើម្បីពោលអះអាងនូវភាវៈបែបណាមួយនៃអត្ថិភាពជាវិជ្ជមានទេ ។ *បរមសុខអាចកើតមានតែនៅក្នុងអាត្ម័នអចិន្ត្រៃយ៍ និងមិនប្រែប្រួលណាមួយ ដែលព្រះពុទ្ធសាសនាបានទាត់ចោលជាដាច់ខាត* ។ ចំពោះព្រះពុទ្ធសាសនា អាត្ម័នបែបនេះ ពុំមានទេ, គឺមានតែអភិក្រមនៃជីវិតដែលជាការប្រែប្រួល និងវិវត្ត ហើយដោយហេតុនេះ គឺជាទុក្ខៈ ។

និព្វាន ត្រូវបានព្រះបរមគ្រូបញ្ជាក់ថាជាបរមសុខ *គ្រាន់តែជាពាក្យសរសើរ* ។

នៅពេលព្រះពុទ្ធមានពុទ្ធដីកាថា" បញ្ញា នរានំ រតនំ " បញ្ញាគឺជារតនវត្ថុរបស់មនុស្សជាតិ, នេះពុំមានន័យថា បញ្ញាគឺជាត្បូង ឬជាកែវផលិក ( ឈ្មោះថ្មកែវវិសេសមួយយ៉ាងមានពណិស ) ទេ ។ គឺគ្រាន់តែជាពាក្យហៅអួតសរសើរចំពោះបញ្ញា, នេះគឺមានន័យយ៉ាងសាមញ្ញថា បញ្ញាគឺជាភាវៈដ៏មានតំលៃបំផុត ដែលមនុស្សមាន ។ គ្មានអ្វីលើសពីនេះទេ ។

ដូចគ្នានេះដែរ, និព្វានគឺជាបរមសុខ, គឺមានន័យថា គឺជាឧត្តមគតិដ៏ខ្ពស់បំផុតដែលគេអាចសំរេចបាន ពីព្រោះវាកើតមាននៅក្នុងការបញ្ឈប់រាល់ទុក្ខវេទនាដោយការអស់ទៅនៃតណ្ហា, ដែលជាមូលហេតុនៃទុក្ខវេទនាទាំងអស់ ។

## III . ចំណោងដប់យ៉ាង

មនុស្សប្រកបដោយគុណធម៌ និងឋាមពលដែលចង់បញ្ចប់ដោយពិតប្រាកដនូវទុក្ខវេទនា ត្រូវជំនះឧបសគ្គផ្លូវចិត្តទាំងអស់ដប់យ៉ាងដែលមានអវិជ្ជាជាទីបំផុត, ដ៏ជាគោលការណ៍ប្រព្រឹត្តទៅក្នុងនៃជីវិតបច្ចុប្បន្ន ។ ឧបសគ្គទាំងនោះ គឺជា

អាកប្បកិរិយាខុសឆ្គង ធ្វើផ្ទុយពីសច្ចធម៌ ដែលដេកត្រាំនៅក្នុងអឡ្សសម្បជញ្ញ : ហើយចាក់ឫសជ្រៅនៅក្នុងទីនោះ, ហើយវាមានយ៉ាងនេះតាំងតែពីកាលដ៏យូរលង់ និងអស់ជាតិជាអសង្ខេយ្យមកហើយ ។

ឧបសគ្គ ឬចំណងទាំងនោះអាចត្រូវជំនះបាន ដោយសារការរស់នៅប្រកបដោយសីលធម៌ខ្ពស់ និងក្រោយពីបានហ្វឹកហ្វឺនចិត្តយ៉ាងត្រឹមត្រូវទៅតាមឈាន និងសមាធិ ។

កាលណាសន្តបុគ្គល ( Un être saint ) ណាមួយបានកំចាត់បង់ចំណង ៣ ខាងដើមគឺ :

១. សក្កាយទិដ្ឋិ ( ទស្សនៈខុសឆ្គង )

២. វិចិកិច្ឆា ( សេចក្តីសង្ស័យលើព្រះធម៌ )

៣. សីលព្វតបរាមាស ( បុណ្យអឺកអធឹក និងពិធីខាងក្រៅដោយមានគំនិតថាបុណ្យ និងពិធីទាំងនោះនាំទៅរកការធ្វើខ្លួនអោយបរិសុទ្ធ ),

សន្តបុគ្គលនោះ បានក្លាយជាសោតាបន្ន ( អ្នកដែលចូលគន្លងនាំទៅរកព្រះនិព្វាន ) ។ យ៉ាងច្រើន, លោកកើតជាថ្មី ៧ ជាតិទៀត, លោកនឹងកំចាត់បានទាំងស្រុងនូវអវិជ្ជា ហើយបញ្ឈប់បាននូវទុក្ខវេទនា ។

កាលណា សន្តបុគ្គលណាមួយបានធ្វើអោយថមថយទាំងស្រុងនូវចំណងពីរយ៉ាងគឺ :

៤. កាមរាគ : ( ចំណង់នៃវិញ្ញាណ )

៥. បដិឃៈ ( បំណងអាក្រក់ ),

សន្តបុគ្គលនោះបានក្លាយទៅជាសកទាគាមិ ( អ្នកដែលកើតឡើងវិញតែម្តង បើសិនជាលោកពុំបានសំរេចអរហត្ត ) ។

កាលណា សន្តបុគ្គលបានកំចាត់ចោលទាំងស្រុង នូវចំណងទាំងពីរនេះ

លោកក្លាយជាអនាគាមិ ( អ្នកដែលមិនត្រឡប់វិញ ) ។

កាលណា សន្តបុគ្គលបន្សាត់បង់ចំណងទាំងប្រាំ ដែលនៅសេសសល់គឺ :

៦. រូបរាគ ( ចំណង់នៃជីវិតក្នុងលោកសម្ភារៈ )

៧. អរូបរាគ ( ចំណង់នៃជីវិតក្នុងអរូបលោក )

៨. មានះ ( អំនួតឆ្មើងឆ្មៃ)

៩. ឧទ្ធច្ចៈ ( ចិត្តងោកងុយ )

១០. អវិជ្ជា ( ល្ងង់ខ្លៅ ),

លោកក្លាយជាព្រះអរហន្ត ។

ព្រះពុទ្ធឃោសៈ នៅក្នុងគម្ពីរវិសុទ្ធិមគ្គ មានពុទ្ធដីកាថា :

« យ៉ាងណាមិញ មនុស្សម្នាក់មិនពេញចិត្តនឹងផ្កា ហើយនិងផ្លែ ដែលឈើមួយដើមផ្តល់អោយ, ចាក់ទំលុះដើមរបស់ឈើនោះ ទាំង ៤ ជ្រុងដោយម្ជុលព្រាំពិសឈ្មោះមណ្ឌុ ហើយនៅពេលនោះ ឈើនោះកាលបើជ័ររបស់វា ត្រូវរីងស្ងួតហើយ ដើមរបស់វាត្រូវបំផ្លាញដោយការចាក់ថ្នាំពិសនោះ នឹងអាចឈានដល់មិនអាចកាន់ផ្លែបាន ហើយនិងមិនអាចផ្តល់ផលបាន, ក៏ដូចគ្នាដែរ កុលបុត្រមិនពេញចិត្តចំពោះអត្ថិភាពនៃខន្ធ, បីដូចមនុស្សដែលចាក់បញ្ចូលថ្នាំពុលទៅក្នុងដើមឈើ ក៏ចាក់បញ្ចូលសមាធិនៃមគ្គបួន ទៅក្នុងចង្កោមនៃខន្ធ ។ ហើយនៅពេលនោះ, ចង្កោមទាំងឡាយ (Les séries) នៃខន្ធ, កាលបើបាបកម្មដ៏ជាហេតុនៃកំណើត ( ជាតិ ) ត្រូវរីងស្ងួតដោយការអនុវត្តមគ្គទាំងបួន, ក៏ប្រែប្រួលទៅជាកម្មរូបបែបណាមួយដែលកត្តិជាអំពើគ្មានផលវិបាក និងឈានដល់សភាពដែលមិននាំអោយមានកំណើតទៀត ហើយមិនអាចកកើតទៀតបាននៅក្នុងជីវិតជាបន្តបន្ទាប់ ។ ដោយការលែងមានមនសិការចុងក្រោយ, មនុស្សនោះគឺដូចជាភ្លើងគ្មានឥន្ធនៈ ឈានចូលកាន់ព្រះនិព្វានគ្មានការជាប់ជំពាក់ចិត្ត » ។

*ព្រះពុទ្ធមានពុទ្ធដីកាថា :*

" ខីណំ បុរាណំ, នវំ នត្ថិ សម្ភវំ,
វិរត្តចិត្តាយតិកេ ភវស្មឹ,
តេ ខីណពីជា អវិរុឡ្ហិឆន្ទា
និព្វន្តិ ធីរា យថាយម្បទីបោ,
ឥទម្បិ សង្ឃេ រតនំ បណីតំ
ឯតេន សច្ចេន សុវត្ថិ ហោតុ ។ »

" កម្មចាស់ ( របស់អរិយបុគ្គលឯណា ) អស់ហើយ , កម្មថ្មីរមែងមិនកើតប្រាកដ,
" អរិយបុគ្គលទាំងឡាយឯណា មានចិត្តនឿយណាយហើយក្នុងភពតទៅ,
" អរិយបុគ្គលទាំងឡាយនោះ មានពូជអស់ហើយ មានឆន្ទៈគឺសេចក្តីប៉ុនប៉ងក្នុងចិត្តមិនដុះចម្រើនឡើយ,
" ជាអ្នកមានប្រាជ្ញា តែងរលត់ទៅ ដូចជាប្រទីបដែលរលត់ទៅនេះ,
" កែវគឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម,
" ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។ »

= ចប់ =

# សង្គាយនាទី ៥

ពុទ្ធសាសនានៅកោះលង្កា បានរីកចំរើនជាងពុទ្ធសាសនានៅតាមតំបន់នានា បន្ទាប់ពីសង្គាយនាទី៣ មក ។ ពេលដែលពុទ្ធសាសនាកំពុងរីកចំរើននេះ ស្រាប់តែមានពួកទមិឡនាំគ្នាធ្វើរដ្ឋប្រហារបង្កអសន្តិសុខ ធ្វើឱ្យពុទ្ធសាសនា និងប្រជារាស្ត្ររងវិនាសកម្ម និងទុក្ខវេទនាយ៉ាងធ្ងន់ធ្ងរ ។ វត្តអារាម វិហារ រមណីយដ្ឋាន ...នៃពុទ្ធសាសនា ត្រូវពួកទមិឡបំផ្លិចបំផ្លាញចោល ។

ចំណេរកាលតមក មានព្រះរាជបុត្រមួយអង្គព្រះនាមវដ្តគាមិនី ចេញទៅបង្កើតរណសិរ្ស វាយរំដោះប្រទេសជាតិពីកណ្តាប់ដៃពួកទមិឡ ហើយបញ្ជាឱ្យស្តារកសាងវត្តអារាម វិហារ រមណីយដ្ឋាន ... នៃពុទ្ធសាសនាឡើងវិញ ។

ជាមួយគ្នានោះ មានព្រះមហាថេរមួយអង្គ ព្រះនាមតិស្សៈ ជាថ្នាក់ដឹកនាំពុទ្ធសាសនា ហើយជាទីសព្វព្រះរាជហឫទ័យ នៃព្រះចៅក្រុងកោះលង្កាផង ប៉ុន្តែមានព្រះសង្ឃមួយភាគ មិនពេញព្រះទ័យនឹងព្រះមហាតិស្សត្ថេរអង្គនេះឡើយ ដោយពិនិត្យឃើញថា លោកប្រកាន់តាមលទ្ធិពួកវិជ្ជីបុត្តកភិក្ខុ ។ ព្រះសង្ឃពុទ្ធសាសនា ពេលនោះត្រូវបែកគ្នាជាពីរពួក ។

នៅចំពោះមុខសភាពការណ៍បែបនេះ ព្រះសង្ឃដែលប្រកបដោយប្រាជ្ញាឈ្លាសវៃ មានការព្រួយបារម្ភយ៉ាងខ្លាំងអំពីអនាគតរបស់ពុទ្ធសាសនា ហើយក៏ប្រជុំគ្នាសំរេចព្រះទ័យជ្រើសរើសព្រះសង្ឃ ដែលទ្រទ្រង់ព្រះត្រៃបិដកចំនួន ១០០០ អង្គ ធ្វើសង្គាយនាព្រះពុទ្ធវចនៈ ចារឹកលាយល័ក្ខអក្សរដាក់ស្លឹករឹតឡើង ។

ក្នុងការធ្វើសង្គាយនានេះ មានព្រះពុទ្ធត្ថេរជាអ្នកសួរ, ព្រះមហាតិស្សត្ថេរជាអ្នកឆ្លើយ, ភិក្ខុ ១០០០ អង្គ ជាការកសង្ឃ, ព្រះបាទវដ្តគាមិនីជាពុទ្ធសាសនូបត្ថម្ភក៏

ធ្វើនៅវត្តមហាវិហារ ក្រុងអនុរាធបុរី កោះលង្កា, ធ្វើអស់ចិរវេលាមួយឆ្នាំទើបចប់, ពុទ្ធបរិនិព្វានកន្លងទៅបាន ៤៣៣ ឆ្នាំ (១) ។ សង្គាយនានេះ ហៅថា បោត្ថការុឡ្ហ-សង្គាយនា ក៏បាន ព្រោះជាសង្គាយនាធម៌វិន័យឡើងកាន់ក្បួន ឬគម្ពីរ ជាគ្រាដំបូងបង្អស់ ក្នុងប្រវត្តិនៃពុទ្ធសាសនា ។

អំណើះកាលតមក មានការធ្វើសង្គាយនារាយរងដែរ នៅកោះលង្កា នៅប្រទេសភូមា នៅប្រទេសសៀម ។ នៅប្រទេសភូមា មានធ្វើសង្គាយនា ហើយចារឹកព្រះពុទ្ធវចនៈជាលាយលក្ខណ៍អក្សរដាក់លើផែនថ្មកែវច្រើនរយផ្ទាំង នៅទីក្រុងមណ្ឌលេ នៅក្រុងប៉េគូ ( ហង្សាវតី ) នៅថាទង ( ស្រុកមាស ដែលជនជាតិមិនយល់ថា ទីនេះហើយជាសុវណ្ណភូមិ ) ។

# សង្គាយនាខ្មែរ

នៅប្រទេសកម្ពុជា តាំងពីព្រេងនាយដែលមានពុទ្ធសាសនា មកប្រតិស្ឋាននៅលើទឹកដីយើង មិនមានប្រវត្តិស្ដីទុកថាបានធ្វើសង្គាយនាព្រះត្រៃបិដកទេ ។ លុះមកដល់រាជ្យព្រះបាទសម្ដេចព្រះស៊ីសុវត្ថិមុនីវង្ស ( ព្រះបរមខត្តិយកោដ្ឋ ) ទើបមានការធ្វើសង្គាយនាព្រះត្រៃបិដកជាពុទ្ធវចនៈនេះឡើងដំបូង ។ ការសង្គាយនាគ្រានេះស៊ីវេលាបីរាជ្យគឺរាជ្យព្រះបាទសម្ដេចព្រះស៊ីសុវត្ថិមុនីវង្ស, រាជ្យព្រះបាទសម្ដេចព្រះនរោត្តម សីហនុ វរ្ម័ន និងរាជ្យព្រះបាទសម្ដេចព្រះនរោត្តម សុរាម្រឹត គឺតាំងពីពុទ្ធសករាជ ២៤៧៣ ( គ.ស ១៩២៩ ) ដល់ពុទ្ធសករាជ ២៥១៣ ( គ.ស ១៩៦៩ ) ស៊ីវេលាអស់ ៤០ ឆ្នាំគត់ ។

(១) ឯកសាររបស់ព្រះភិក្ខុប៉ាងខាត់ ដែលប្រមូលចងក្រងដោយគណៈកម្មាធិការជាតិ នៃខេមរយានកម្ម ថានៅពុទ្ធសករាជ ៥២០ ឆ្នាំ ។

សង្គាយនានៅប្រទេសកម្ពុជានេះ លោកចាត់ទុកជាឆដ្ឋសង្គាយនា (សង្គាយនាទី៦) ឬជាឧត្តមសង្គាយនា ព្រោះមានលក្ខណៈពិសេសមួយ ដែលមិនធ្លាប់កើតមាននៅក្នុងប្រវត្តិពុទ្ធសាសនា គឺការប្រែពុទ្ធវចនៈជាភាសាបាលី ដែលមានរាប់ពាន់ឆ្នាំមកហើយជាភាសាជាតិខ្មែរ គឺទំព័រម្ខាងជាបាលី ម្ខាងទៀតជាខ្មែរ (មាន ១១០ ភាគ គឺ ព្រះវិន័យបិដក ពីភាគទី១ ដល់ភាគទី១៣, ព្រះសុត្តន្តបិដក ពីភាគទី១៤ ដល់ភាគទី៧៧, ព្រះអភិធម្មបិដក ពីភាគទី៧៨ ដល់ភាគទី១១០) ។

*សេចក្តីសន្និដ្ឋាន*

ការសង្គាយនាជាភាសាបាលីដោយមុខបាឋ ( ចាំមាត់ ) ក្តី ដោយចារឹកជាលាយលក្ខណ៍អក្សរក្តី ប្រែជាភាសាជាតិក្តី ឈ្មោះថា" រក្សាព្រះពុទ្ធវចនៈទុកឱ្យគង់នៅបរិសុទ្ធដដែល " ឈ្មោះថា " ញ៉ាំងព្រះពុទ្ធសាសនាឱ្យស្ថិតស្ថេរចិរកាលអង្វែងតទៅ" និងឈ្មោះថា " សាងព្រះសម្ពុទ្ធគ្រប់កាលទាំងពួង" ព្រោះថា បើព្រះពុទ្ធវចនៈគង់វង្សនៅដរាបណា ព្រះសម្ពុទ្ធក៏ឈ្មោះថា ទ្រង់គង់ធរមាននៅដរាបនោះដែរ ។

បច្ឆាពុទ្ធសាសនិកជំនាន់ក្រោយៗសម័យពុទ្ធកាល ទោះបីពុំបានកើតទាន់, ពុំបានអង្គុយត្រងត្រាប់ស្តាប់ព្រះពុទ្ធឱវាទព្រះអង្គផ្ទាល់ក្តី ក៏ឈ្មោះថាបានកើតទាន់, បានឃើញ បានស្តាប់ព្រះធម៌របស់ព្រះពុទ្ធអង្គផ្ទាល់ដែរ ព្រោះបានឃើញ បានក្រេបជញ្ជក់ព្រះពុទ្ធវចនៈរបស់ព្រះអង្គ ដោយសារមានសង្គាយនា ជាបន្តបន្ទាប់នោះឯង ជាមហាកំពែងដ៏រឹងមាំ សំរាប់ការពារពុទ្ធវចនៈឱ្យគង់វង្សនៅរហូតដល់សព្វថ្ងៃ សមដូចពុទ្ធភាសិត ដែលព្រះអង្គបានសំដែងនឹងវក្កលិភិក្ខុថា " យោ ធម្មំ បស្សតិ សោ មំ បស្សតិ ... អ្នកណាឃើញនូវធម៌ អ្នកនោះឈ្មោះថាឃើញនូវតថាគត ...ដែរ " ។

រៀបរៀងដោយ

ម៉ែន ប្រាង, អាំ ឆន

បទកាកគតិ

ពាក្យព្រេងលោកថា លោកនឹងឧបមា ឱយគិតឱយយល់
ពាក្យលោកទំនឹម មិនមានឱយសល់ កូនអើយកុំឆ្ងល់
នឹងពាក្យនេះណា ។

កុំអួតកុំអាង ដើរកុំមើលរាង មើលអង្គអាត្មា
កុំដើរផ្ទះគេ ហួសពេលវេលា កុំទៅផានា
ទ្រព្យគេទាំងឡាយ ។

កុំដេកផ្កាប់មុខ កុំដើរពានថ្លុក ថាឯងសប្បាយ
មានទោសនឹងគេ កុំឱយនិយាយ ដើមគេនឹងក្លាយ
កើតជាទោសធំ ។

ខ្លួនទាបកុំតោង ដៃខ្លីកុំឈោង ស្រវាឱបភ្នំ
ចាស់កោងកាន់ច្រត់ អួតអាងប្រគំ ក្លរអួតផ្លុំ
ប៉ីពកយកខ្យល់ ។

ខ្ទាក់ឆ្នុះកញ្ចក់ ដកកក្លក់ ហាក់ឯងមើលយល់
ខ្ទិនអួតនឹងផ្លោះ រំលងលើគល់ តំពែករកកល
ចង់បានប្រេងលាប ។

ក្លែងចង់រាំ ក្រោកឡើងទន្ទាំ កេងកោងអាបឡាប
ថ្លង់ចង់ស្ដាប់ច្រៀង ផ្អៀងផ្អងទន់ទាប ដៃតូចខ្លួនទាប
ចង់ឈោងចាប់ផ្កាយ ។

កូនអើយចូរស្ដាប់ ពាក្យនេះមហាគាប់ គ្រប់តួទាំងឡាយ
បាគិតរំពឹង ជញ្ជីងឱយឆ្ងាយ កុំធ្វើវាយមាយ
នឹងច្បាប់នេះណា ។

*ដកស្រង់ពីច្បាប់បណ្ដាំបិតា*

# រឿងកោសម្ពិកភិក្ខុ

រឿងនេះ មាននៅក្នុងគម្ពីរវិន័យបិដក (ព្រះត្រៃបិដកជាភាសាបាលី-ខ្មែរ ភាគទី៨) និងគម្ពីរធម្មបទដ្ឋកថា ភាគទី១ ។ លំនាំសង្ខេបនៃរឿងនេះ មានដូចតទៅ :

*កោសម្ពិយំ ហិ ឃោសិតារាមេ ...* សេចក្ដីដំណាលថា មានភិក្ខុពីរអង្គ, មួយអង្គជា*វិន័យធរ* មួយអង្គទៀតជា*ធម្មកថិក,* គង់នៅវត្តឃោសិតារាមជិតក្រុងកោសម្ពី ។ លោកទាំងពីរអង្គ មានភិក្ខុជាសិស្សគណចំនួន ៥០០ អង្គៗដូចគ្នា ។

ថ្ងៃមួយ ភិក្ខុជាធម្មកថិកចូលទៅបន្ទោបង់ឧច្ចារៈ (បត់ជើងធំ) ក្នុងបង្គន់ ហើយមិនបានចាក់ទឹកសំណល់លាងលាមកចោល ។ បន្ទាប់មក ភិក្ខុជាវិន័យធរបានចូលទៅក្រោយ ឃើញទឹកសំណល់នោះ ហើយចេញមកវិញសួរថា «លោកម្ចាស់ទុកទឹកសំណល់ពីលាងលាមកនៅក្នុងបង្គន់ឬ?» ។ ធម្មកថិកតបថា «ករុណា» ។ វិន័យធរបន្តទៀតថា «លោកធ្វើយ៉ាងនេះ មិនដឹងត្រូវអាបត្តិទេឬ ?» ធម្មកថិកតបថា «ខ្ញុំករុណាឥតដឹងទេ, បើខ្ញុំករុណាត្រូវអាបត្តិ ខ្ញុំសូមសំដែងអាបត្តិនោះចេញ» ។ ពេលនោះ វិន័យធរឆ្លើយថា «បើលោកធ្វើដោយគ្មានចិត្តក្លែងទេនោះ លោកក៏ពុំត្រូវអាបត្តិអ្វីដែរ» ។ កាលឮដូច្នេះ ធម្មកថិកក៏ស្ងៀមនៅ ដោយសំគាល់ថា « ខ្លួនឥតត្រូវអាបត្តិអ្វីឡើយ » ។ ក្រោយមក វិន័យធរបាននិយាយប្រាប់សិស្សគណរបស់ខ្លួនថា «ធម្មកថិកប្រព្រឹត្តខុស ត្រូវអាបត្តិហើយ មិនដឹងថាខ្លួនត្រូវអាបត្តិទៀត» ។ សិស្សគណរបស់វិន័យធរ បានយកពាក្យនេះទៅបន្តុះបង្អាប់សិស្សរបស់ធម្មកថិកថា «គ្រូរបស់អ្នកឯងល្ងង់ណាស់ ត្រូវអាបត្តិហើយ មិន

នឹងថាខ្លួនត្រូវអាបត្តិទៀត» ។ សិស្សគណរបស់ធម្មកថិក ក៏នាំពាក្យនេះទៅប្រាប់គ្រូរបស់ខ្លួន ។ ធម្មកថិកក៏ប្រាប់សិស្សរបស់ខ្លួនថា «វិន័យធរជាអ្នកពោលពាក្យមុសាវាទ» ព្រោះពេលមុន លោកនិយាយថា «ខ្ញុំមិនត្រូវអាបត្តិទេ តែឥឡូវនេះបែរជានិយាយថាខ្ញុំត្រូវអាបត្តិទៅវិញ» ។ សិស្សគណរបស់ធម្មកថិក យកពាក្យនេះទៅផ្តុញផ្តាល់សិស្សរបស់វិន័យធរវិញ ។ សិស្សរបស់វិន័យធរ ក៏យកពាក្យនេះទៅប្រាប់គ្រូរបស់ខ្លួន ។ វិន័យធរមានការថ្នាំងថ្នាក់ ក៏ចោទភិក្ខុជាធម្មកថិកថា «ជាអ្នកមានទោស ហើយមិនឱ្យចូលរួមធ្វើសង្ឃកម្មជាមួយ» ។ ទំនាស់រវាងវិន័យធរ និងធម្មកថិក ក៏ចាប់ផ្តើមកើតឡើងខ្លាំងឡើងៗ រហូតដល់បែកគ្នាជា ពីរពួក ។

លំដាប់នោះ មានភិក្ខុមួយអង្គបានចូលទៅក្រាបទូលព្រះសម្ពុទ្ធ អំពីការបែកបាក់គ្នាក្នុងសង្ឃមណ្ឌលនេះ ។ ព្រះសាស្តា កាលបើទ្រង់ជ្រាបហើយ ក៏ផ្តែផ្តាំទៅថា *«ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរកុំទាស់ទែងគ្នាអី ចូរព្រមព្រៀងគ្នាឡើងវិញទៅ»* ។ អស់វារៈបីដង ក៏ពួកភិក្ខុទាំងនោះនៅតែឈ្លោះប្រកែកគ្នាដដែល ។ ព្រះសម្ពុទ្ធក៏ទ្រង់យាងទៅជួបផ្ទាល់នឹងភិក្ខុទាំងនោះ ហើយមានពុទ្ធដីកាថា *«ម្នាលភិក្ខុទាំងឡាយ អ្នកទាំងអស់គ្នាសុទ្ធតែជាអ្នកឥតមានទោសពៃរ៍អ្វីឡើយ ត្រូវតែសាមគ្គីគ្នាឡើងវិញ»* ។ នៅពេលនោះ ព្រះអង្គទ្រង់ពន្យល់ណែនាំអំពីទោសនៃការបែកបាក់គ្នា ឈ្លោះប្រកែកគ្នាជាច្រើនអនេកប្បការឱ្យពួកភិក្ខុទាំងនោះស្តាប់ទៀតផង ប៉ុន្តែអនុគាគមន៍របស់ព្រះសាស្តា គ្មានបានការអ្វីទាំងអស់ គឺភិក្ខុទាំងនោះ រឹតតែប្រទូសរ៉ាយគ្នាខ្លាំងឡើងៗ រហូតដល់ជេរប្រទេច វាយដំគ្នានៅក្នុងវត្ត និងនៅតាមភូមិអ្នកស្រុកទៀតផង ។

គ្រានោះ មានភិក្ខុជាបក្សពួករបស់វិន័យធរ បានចូលទៅក្រាបទូលព្រះសម្ពុទ្ធថា «បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គគង់នៅជាសុខចុះ កុំខ្វល់ខ្វាយព្រះទ័យនឹងខ្ញុំព្រះអង្គអី ដ្បិតខ្ញុំព្រះអង្គមិនអាចបញ្ឈប់ការទាស់ទែងគ្នាបានទេ, ពុំអាច

សាមគ្គីគ្នាបានទេ» ។ ពេលនោះ ព្រះសាស្ដាខិតខំពន្យល់ណែនាំទៀតថា *«ពីអតីត-កាល ព្រះបាទព្រហ្មទត្ត និងទីឃាវុកុមារ ជាស្ដេចសុទ្ធតែមានសស្ត្រាវុធក្នុងដៃដូចគ្នា គេអាចយោគយល់គ្នា ជានាគ្នាបាន ចុះហេតុដូម្ដេចបានជាអ្នកទាំងឡាយ សុទ្ធតែជាអ្នកបានបួសក្នុងធម៌វិន័យយ៉ាងត្រឡាំង បែរជាមិនអាចអត់ឱនឱ្យគ្នា ជានាគ្នា ព្រមព្រៀងគ្នាទៅកើត»* ។ ទោះបីមានការណែនាំម្ដងជាពីរដងក៏ដោយ ភិក្ខុទាំងនោះក៏នៅតែមានះ រឹងរូសឈ្លោះប្រកែកគ្នាតទៅទៀត ។

ដោយទ្រង់ព្រះតម្រិះថា ភិក្ខុទាំងនេះមិនស្ដាប់ព្រះអង្គទេ ព្រះអង្គក៏ទ្រង់យាងទៅជួបនឹងភិក្ខុទាំងអស់ដែលទាស់ទែងគ្នានោះ ហើយទ្រង់មានពុទ្ធដីកាជាចុងក្រោយ ជាអាទិថា :

*បុថុសទ្ទោ សមជនោ ន ពាលោ កោចិ មញ្ញថ ....*
*បរិមុដ្ឋា បណ្ឌិតា ភាសា វាចាគោចរភាណិនោ*
*យា វិច្ឆន្តិ មុខាយាមំ យេន នីតា ន តំ វិទូ*

ជននេះមានសំឡេងខ្លាំងផង ជាជនប្រហែលគ្នាផង (ស្មូម្បី) ជនណាមួយដឹងខ្លួនថាជាបុគ្គលពាលក៏គ្មាន, ពួកជនដែលភ្លេចស្មារតី ហើយធ្វើឫកពាខ្លួនដូចជាអ្នកប្រាជ្ញ មានសំដីជាអារម្មណ៍ ចង់ហាមាត់និយាយប៉ុន្មាន ក៏និយាយប៉ុណ្ណោះទៅ ទុកជាមានគេនាំទៅ (ប្រជល់ឱ្យឈ្លោះគ្នា) ក៏ពុំដឹងសេចក្ដីនោះ (ថាជាការឈ្លោះឡើយ) ជាដើម ។ រួចហើយព្រះសម្ពុទ្ធ ក៏សម្រេចព្រះទ័យចេញពីដែនកោសម្ពី តែមួយព្រះអង្គឯង ទៅគង់ចាំវស្សាក្នុងព្រៃរក្ខិតវ័ន ដែលមានដំរីឈ្មោះបាលិលេយ្យកៈជាអ្នកបំរើនៅទីនោះ ។

ក្រោយពេលដែលព្រះសាស្ដា និមន្តចេញបាត់ពីវត្តឃោសិតារាមទៅ ពួកពុទ្ធបរិស័តខានបានស្ដាប់ធម៌អាថ៌ ក៏នឹកឆ្ងល់ថា *«ចុះព្រះសម្ពុទ្ធយាងទៅណា បានជាពុំដែលឃើញសោះ ?»* លុះបានដឹងថា ព្រះពុទ្ធជាម្ចាស់ទ្រង់ភៀសព្រះអង្គចេញ

បាត់ទៅដោយសារតែពួកភិក្ខុទាស់ទែងគ្នា ធ្វើឱ្យព្រះអង្គលំបាកព្រះទ័យ ; ពួកគេក៏នាំគ្នាថ្កោលទោសលែងគោរព លែងដាក់បាត្រ ដូចពេលសព្វដងទៀត ។ ពួកភិក្ខុទាំងនោះ ក៏រស់នៅយ៉ាងលំបាកដោយខ្វះខាតចតុប្បច្ច័យ ទើបយល់ពីកំហុស របស់ខ្លួន ហើយគិតនាំគ្នាទៅសុំខមាទោសចំពោះព្រះសម្ពុទ្ធ ប៉ុន្តែពេលនោះជួនជាថ្ងៃចូលវស្សាបានចូលមកដល់ ក៏នាំគ្នាទ្រាំចូលវស្សាទាំងលំបាកខ្វះខាតទៅ ។

លុះពេលចេញវស្សាហើយ អនាថបិណ្ឌិកសេដ្ឋី នាងវិសាខា និងភិក្ខុចំនួន៥០០ អង្គ បានសុំឱ្យអានន្ទទៅនិមន្តព្រះសាស្តាពីព្រៃមកកាន់វត្តជេតពន ព្រោះពួកគេខានស្តាប់ធម្មទេសនារបស់ព្រះអង្គជាច្រើនខែកន្លងមកហើយ ។ ព្រះអានន្ទក៏នាំពួកភិក្ខុចំនួន ៥០០ អង្គ ទៅកាន់សំណាក់ព្រះសម្ពុទ្ធ ។ កាលនិមន្តជិតដល់អាស្រម លោកក៏គិតថា « អាត្មាអញនាំពួកភិក្ខុដ៏ច្រើនដូច្នេះទៅជួបព្រះសាស្តាមិនគួរទេ » ។ លោកក៏បញ្ឈប់ពួកភិក្ខុឱ្យនៅខាងក្រៅសិន ហើយចូលទៅតែមួយអង្គឯង ។ គ្រាន់តែចូលទៅដល់ភ្លាម ស្រាប់តែដំរីបាលិលេយ្យកៈ ចាប់ដំបងបំរុងប្រហារព្រះអានន្ទ ប៉ុន្តែព្រះសាស្តាទ្រង់ឃាត់ថា « *កុំ! កុំ! នេះជាពុទ្ធុប្បដ្ឋាកៈរបស់តថាគតទេ* » ។ ដំរីក៏ទម្លាក់ដំបងចោល ។ បន្ទាប់ពីធ្វើអភិវន្ទនកិច្ចហើយ ព្រះសម្ពុទ្ធទ្រង់សួរថា «*ម្នាលអានន្ទ អ្នកមកតែម្នាក់ឯងទេឬ ?*» អានន្ទក៏ក្រាបទូលថា «ទូលបង្គំ មកជាមួយភិក្ខុចំនួន៥០០អង្គ ឥឡូវខ្ញុំព្រះអង្គបញ្ឈប់ឱ្យនៅខាងក្រៅឯណោះ » ។ ព្រះសាស្តាទ្រង់បង្គាប់ឱ្យនាំភិក្ខុទាំងនោះចូលមក ។ ភិក្ខុទាំងអស់នោះ លុះថ្វាយបង្គំព្រះហើយ ក៏ទូលសួរថា " ព្រះអង្គគង់នៅតែមួយអង្គឯងយ៉ាងនេះ ទំនងជាមានការលំបាកណាស់ ព្រោះពុំមានអ្នកណាបម្រើ " ព្រះសាស្តាទ្រង់តបវិញថា « *តថាគតនៅទីនេះមានដំរីបាលិលេយ្យកៈ ជាអ្នកបំរើកិច្ចការគ្រប់យ៉ាង* » ។ ជាមួយនោះ ព្រះសម្ពុទ្ធទ្រង់សំដែងគាថា ថា ៖

*សចេ លភេថ និបកំ សហាយំ*

*សទ្ធិញ្ចរំ សាធុវិហារិធីរំ*
*អភិភុយ្យ សព្វានិ បរិស្សយានិ*
*ចរេយ្យ តេនត្តមនោ សតីមា ។*
*នោ ចេ លភេថ និបកំ សហាយំ*
*សទ្ធិញ្ចរំ សាធុវិហារិធីរំ*
*រាជាវ រដ្ឋំ វិជិតំ បហាយ*
*ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។*
*ឯកស្ស ចរិតំ សេយ្យោ*
*នត្ថិ ពាលេ សហាយតា ។*

បើបុគ្គលបានសម្លាញ់ជាអ្នកមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅសប្បាយ ត្រាច់ទៅជាមួយគ្នា (បុគ្គលនោះ) អាចគ្របសង្កត់នូវសេចក្ដីអន្តរាយទាំងពួងបាន ហើយជាអ្នកមានស្មារតី គប្បីត្រាច់ទៅជាមួយនឹងសម្លាញ់នោះចុះ ។ បើបុគ្គលមិនបាននូវសម្លាញ់ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅសប្បាយ ត្រាច់ទៅជាមួយទេ (បុគ្គលនោះ) គួរត្រាច់ទៅតែម្នាក់ឯង ប្រៀបដូចជាស្ដេចលះបង់ដែនដែលខ្លួនឈ្នះ ហើយត្រាច់ទៅម្នាក់ឯង (ពុំនោះសោត) ប្រៀបដូចដំរីដ៏ប្រសើរ ត្រាច់ទៅម្នាក់ឯងក្នុងព្រៃ ។ ការដែលបុគ្គលត្រាច់ទៅតែម្នាក់ឯង ហៅពេញជាប្រសើរ ព្រោះបុគ្គលពាលគ្មានសហាយតាគុណទេ ។

កាលបើចប់គាថានេះហើយ ពួកភិក្ខុទាំង៥០០អង្គ ក៏បានសំរេចមគ្គផលទាំងអស់អង្គ ។ ឆ្លៀតពេលនោះ ព្រះអានន្ទ ក៏ក្រាបទូលអំពីបំណងរបស់អរិយសាវ័កដ៏ច្រើន មានអនាថបិណ្ឌិកសេដ្ឋីជាដើម ក្នុងការសុំយាងព្រះសាស្ដាទៅវិញ ។ ព្រះសម្ពុទ្ធ គ្រាន់តែទ្រង់ព្រះសណ្ដាប់ភ្លាម ក៏ទ្រង់បញ្ជាឱ្យយកបាត្រ និងចីវរ ហើយ

ចេញពុទ្ធដំណើរឆ្ពោះទៅកាន់វត្តជេតពនភ្លាម ។ គ្រានោះ ព្រះសាស្តាទ្រង់ត្រាស់នឹងដំរីបាលិលេយ្យកៈថា *«ម្នាលបាលិលេយ្យកៈ! ដំណើរនេះ ជាដំណើរមិនត្រឡប់វិញរបស់តថាគត, ឈានក្តី វិបស្សនាក្តី មគ្គក្តី ផលក្តី មិនមានដល់អ្នកក្នុងអត្តភាពនេះទេ, អ្នកចូរស្ថិតនៅចុះ»* ។ គ្រាន់តែឮព្រះបន្ទូលនេះភ្លាម ដំរីយកប្រមោយញាត់ក្នុងមាត់ ស្រែករោទ៍យ៉ាងខ្លាំងដើរតាមក្រោយព្រះសាស្តា ។ កាលបើជិតដល់ភូមិស្រុកហើយ ព្រះសាស្តាទ្រង់មានបន្ទូលទៅកាន់ដំរីថា « *ម្នាលបាលិលេយ្យកៈ ! ចាប់ពីទីនេះទៅ មិនមែនជាទីនៅអាស្រ័យរបស់អ្នកទេ គឺជាទីនៅអាស្រ័យរបស់មនុស្ស, អ្នកចូរឈប់ត្រឹមនេះចុះ* » ។ ដំរី កាលឮពុទ្ធដីកានោះភ្លាម ក៏ឈប់ឈរទ្រឹងស្រែកយ៉ាងខ្លាំង សម្លឹងមើលដំណើរព្រះសាស្តា មិនពព្រិចភ្នែក ។ គ្រាន់តែព្រះសម្ពុទ្ធនិមន្តផុតពីរង្វង់ចក្ខុរបស់ខ្លួន ដំរីនោះក៏បែកទ្រូងស្លាប់ ហើយបានទៅកើតនៅស្ថានត្រៃត្រិង្ស មាននាមថា *បាលិលេយ្យក-ទេវបុត្រ* ។ ព្រះសាស្តាទ្រង់និមន្តដល់វត្តជេតពន ពួកកោសម្ពិកភិក្ខុដឹងហើយក៏ប្រញាប់ប្រញាល់ទៅសុំខមាទោសចំពោះព្រះអង្គ ។ ពេលនោះ ព្រះបាទព្រហ្មទត្តនិងអនាថបិណ្ឌិកសេដ្ឋី បានឮដំណឹងនេះ ក៏ទៅទូលព្រះសម្ពុទ្ធថា « ខ្ញុំព្រះអង្គមិនឱ្យពួកកោសម្ពិកភិក្ខុដែលទាស់ទែងគ្នានោះចូលមកកាន់ក្រុង និងវត្តខ្ញុំព្រះអង្គឡើយ » ។ ព្រះសាស្តាទ្រង់តបទៅវិញថា *«កុំអី ព្រោះភិក្ខុទាំងនោះ ជាអ្នកនៅមានសីល គ្រាន់តែទាស់ទែងគ្នា និងមិនស្តាប់ឱវាទរបស់តថាគតប៉ុណ្ណោះ ឥឡូវគេមកសុំទោសតថាគតហើយ សូមឱ្យពួកគេចូលមកចុះ»* ។ ចំណែកពួកភិក្ខុទាំងឡាយដទៃទៀត ក៏មិនព្រមអង្គុយ ឈរជិត ឬនិយាយរកពួកកោសម្ពិក-ភិក្ខុដែរ ។ មនុស្សទាំងឡាយដែលមកកាន់ទីនោះ ក៏នាំគ្នាចូលទៅសួរព្រះសាស្តាថា « ពួកភិក្ខុដែលទាស់ទែងគ្នានៅឯណា ? » ព្រះសម្ពុទ្ធទ្រង់តបថា « *នុ៎ះ! នុ៎ះ!* » ។ មនុស្សទាំងឡាយក៏ចង្អុលប្រាប់គ្នីគ្នាថា « នុ៎ះតើ ភិក្ខុដែលទាស់ទែងគ្នា ! » ។ ពួក

កោសម្ពិកភិក្ខុ មានការអៀនខ្មាសយ៉ាងខ្លាំង មិនហ៊ានងើបមុខ ក្រាបចុះទៀបព្រះបាទាព្រះសម្ពុទ្ធ សុំឱ្យព្រះសាស្ដាមេត្តាអត់ទោសឱ្យខ្លួន ។ ព្រះសាស្ដាទ្រង់ត្រាស់ថា *« ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយធ្វើអំពើអាក្រក់, តថាគតខំណែនាំឱ្យលះបង់ចោល ប៉ុន្តែអ្នកទាំងឡាយមិនព្រមស្ដាប់សោះ ។ នេះវាផ្ទុយស្រឡះពីអ្នកប្រាជ្ញពីបុរាណ ព្រោះលោកទាំងនោះជឿ គោរព ធ្វើតាម មិនហ៊ានប្រព្រឹត្តកន្លងដំបូន្មានឪពុកម្ដាយរបស់លោកទេ ទោះបីមាតាបិតាលោកអនិច្ចកម្មទៅហើយ ក៏ដោយ»* ។

ពេលនោះ ពួកកោសម្ពិកភិក្ខុ ក៏បានយល់ច្បាស់ពីកំហុសរបស់ខ្លួន ហើយធ្វើសង្ឃសាមគ្គីឧបោសថជានាគ្នា តរៀងទៅ ។

*ភ្លើងឆេះពីសំរាម* ។ រឿងតូចតាចសោះ អាចបណ្ដាលឱ្យជារឿងធំបាន រហូតដល់បែកបាក់ជាបក្ស ជាពួក ប្រឈមមុខដាក់គ្នា ប្រទូសរ៉ាយគ្នា ភ្លេចថាខ្លួនជាអ្នកបួស ជាសមណសក្យបុត្ត ។

ពុទ្ធបរិស័ទ ទាំងបព្វជិត ទាំងគ្រហស្ថ គួរយកធម៌វិន័យជាធំ (ធម្មាធិបតេយ្យ) ដើម្បីរក្សាតម្លៃខ្លួន និងសាសនារបស់ខ្លួន ។ បើឃើញអ្នកណាមួយប្រព្រឹត្តខុសឆ្គង គប្បីជួយដាស់តឿន ក្រើនរំលឹកគ្នាក្នុងន័យស្ថាបនា ក្នុងមនោសញ្ចេតនាសន្ដោស ចង់ឱ្យអ្នកដែលជ្រុលប្រព្រឹត្តខុសនោះ បានភ្ញាក់រលឹក បានកែលំអខ្លួនឡើងវិញ ទាន់ពេលវេលា ។ ប្រសិនបើឃើញសហធម្មិកផងគ្នាត្រូវអាបត្តិ គួរជួយក្រើនរំលឹក ឬបង្កលក្ខណៈងាយស្រួលឱ្យសហធម្មិកនោះ បានសំដែងអាបត្តិនោះផង ចៀសវាងចាំតែចាប់កំហុស បន្ទុះបង្អាប់ សន្សំរឿងហេតុ មើលឃើញកំហុសតូចតាចរបស់គេ ហាក់ប៉ុនភ្នំ ពេលស្រឡាញ់ មើលឃើញសុទ្ធតែត្រូវ សុទ្ធតែល្អ, ពេលស្អប់ មើលឃើញសុទ្ធតែខុស សុទ្ធតែអាក្រក់ទាំងអស់ ។ រីឯអ្នកដែលបានជាប្រព្រឹត្តខុសជ្រុលហើយនោះ ក៏ត្រូវតែចេះវិភាគ ចេះភ្ញាក់រលឹក ខំកែលំអជា

បន្ទាន់ ចៀសវាងអស្មិមានះរឹងរូសយកត្រូវម្នាក់ឯង មិនព្រមទទួលកំហុស ខ្លាចបាក់មុខ និងប៉ះពាល់ដល់កិត្តិយសខ្លួន ។

កន្លងមក តាមការពិនិត្យយើងឃើញថា នៅវត្តខ្លះមានការបែកបាក់សាមគ្គីគ្នារវាងព្រះសង្ឃនិងព្រះសង្ឃ ដោយសារតែរឿង*ដែងលាភសក្ការៈ ដែងមុខមាត់គ្នា* បន្តិចបន្តួច ហើយឆេះរាលដាលទៅជាអធិករណ៍ ក៏មាន ។ អ្នកខ្លះពេញចិត្តគ្រូសូត្រ ស្អប់លោកគ្រូចៅអធិការ ម្លោះហើយខំអួតអាងលើកតម្កើង ឬបន្ទុះបង្អាប់ ចាប់កំហុស កាច់បំបាក់តែម្ខាងៗ លែងមើលឃើញការពិតត្រូវតាមធម៌វិន័យអ្វីទាំងអស់ យូរៗទៅ លោកគ្រូចៅអធិការ និងគ្រូសូត្រ ក៏ហាក់ក្លាយទៅជាមាន់ដែលគេលាបច្បូងមុខឱ្យជល់គ្នា ហើយខិតខំតែពីប្រឹងគន់រំពៃទោស ចាប់កំ-ហុសគ្នា ចោទប្រកាន់ កាច់បំបាក់គ្នា ។ លទ្ធផលចុងក្រោយ បានត្រឹមតែការបែកបាក់ ប្រេះឆាគ្នាជាពីរ ជាបីពួក ហើយវត្តអារាមគ្មានមេ គ្មានកោយពិតប្រាកដ អនា-ធិបតេយ្យ អន្តរាយ គ្មានការរីកចំរើន ខាងផ្លូវព្រះពុទ្ធសាសនា ក៏ដូចជាការងារសង្គមផ្សេងៗ ។

ពុទ្ធបរិស័ទ ពិសេស ព្រះសង្ឃយើង គួរប្រុងប្រយ័ត្នកុំឱ្យរឿងបែបនេះកើតមាននៅក្នុងរង្វង់សាសនាយើង ត្រូវយកចិត្តទុកដាក់ប្រិតប្រៀនក្នុងការប្រតិបត្តិធម៌ និងវិន័យ សំដៅធ្វើឱ្យព្រះពុទ្ធសាសនា រក្សាបានតម្លៃសីលធម៌ និងតួនាទីរបស់ខ្លួនក្នុងសង្គម ក្នុងភាពត្រឹមត្រូវ បរិសុទ្ធ ម៉ត់ចត់ តាមពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត ព្រមទាំងរក្សាបាននូវជំនឿរបស់ប្រជារាស្ត្រ ចំពោះព្រះពុទ្ធសាសនា និងរក្សាបានឋានៈជាសាសនារបស់រដ្ឋ តទៅ ។

ដោយ **ម៉ែន ប្រាជ** និង **អាំ ឆន**

តាមព្រះយោបល់នៃសម្ដេចព្រះសង្ឃរាជគណៈមហានិកាយ

# បព្វជ្ជា

**បព្វជ្ជា** : ពាក្យ បួស ជាពាក្យមានតម្លៃល្អប្រសើរ ។ មនុស្សដែលបានបួសក្នុងព្រះពុទ្ធសាសនា ជាមនុស្សមានតម្លៃល្អប្រសើរជាងអ្នកមិនបានបួស ។ អ្នកកាន់ព្រះពុទ្ធសាសនា គេនិយមថា អ្នកបួស គឺជាមនុស្សល្អ ដឹងខុស ដឹងត្រូវ ដឹងគុណ ដឹងទោស ដឹងបុណ្យ ដឹងបាប ។ ល ។ ឬកែគំនិតមារយាទ និងស្មារតីមនុស្សពីអាក្រក់ ថោកទាប ឱ្យមកជាល្អ ខ្ពង់ខ្ពស់បាន ដោយអាស្រ័យការប្រព្រឹត្តិតាមធម៌វិន័យរបស់ព្រះពុទ្ធក្នុងភេទផ្នួស ។

អត្ថបទ « បួស » នេះខ្លី ប៉ុន្តែបានជាជំនួយស្មារតី សម្រាប់អ្នកបួស ឬអ្នកដែលបម្រុងខ្លួននឹងបួស ។

ខ្ញុំសង្ឃឹមថា លោកអ្នកដែលស្រឡាញ់ផ្នួស ស្រឡាញ់ព្រះពុទ្ធសាសនា មុខជានឹងយកចិត្តទុកដាក់ពិនិត្យមើលអត្ថបទនេះ ហើយអត្ថបទនេះ ប្រាកដជាផ្តល់អត្ថប្រយោជន៍ពិសេសមកវិញ ពុំខាន ។

***

## ដុំរិញបព្វជ្ជា

បព្វជិតភាវោ ទុល្លភោ : ភាពនៃបព្វជិត គេរកបានដោយកម្រ ។

ការបានបួសជាភិក្ខុក្តី ជាសាមណេរក្តី បួសហើយដាច់ចិត្តចេញមកប្រព្រឹត្តប្រតិបត្តិធម៌ សមថកម្មដ្ឋាន ឬវិបស្សនាកម្មដ្ឋានក្តី បានឈ្មោះថាជារបស់រកបានដោយកម្រ ក្នុងជំនាន់ដើម ។

ចំណែកភិក្ខុ-សាមណេរបច្ចុប្បន្ននេះ ដែលបានបួសត្រឹមត្រូវហើយ ខិតខំរៀនសូត្រធម៌វិន័យសិក្ខា ចម្រើនសមថកម្មដ្ឋាន វិបស្សនាកម្មដ្ឋានរឿយៗ ឈ្មោះថាបានជួបប្រទះនឹងរបស់ដែលគេរកបានដោយកម្រណាស់ ។ សូម្បីតែគ្រហស្ថ ដែលបានថ្វាយខ្លួនជាឧបាសក ឧបាសិកា បានបួសកាយ វាចា និងចិត្តរបស់ខ្លួន សុខចិត្តលះនូវសេចក្ដីសុខបន្តិចបន្តួច ត្រឹមតែគ្រួសារប៉ុណ្ណោះ សង្ឃឹមប្ដូរយកសុខធំទូលំទូលាយ ហើយនាំគ្នាមកធ្វើរាងកាយដែលជារបស់បដិកូល គួរខ្ពើមរអើមនេះ ឱ្យទៅជារបស់ស្អាត មានក្លិនក្រអូបដោយសីល សមាធិ បញ្ញា ទៅវិញ សុទ្ធតែរកបានដោយក្រ ។

តាមន័យនេះ អ្នកស្លៀកខ្មៅ ដណ្ដប់ខ្មៅ ស្លៀកស ដណ្ដប់ស ឬ ស្លៀកខ្មៅ ដណ្ដប់ស ពានា-សក្ដិ ក៏ឈ្មោះថាអ្នកនាំគ្នាមកបួសបានដែរ (តាមបែបចេត-នាកម្ម) ឬហៅថាភិក្ខុក៏បាន ព្រោះសំដៅយក " អ្នកឃើញភ័យក្នុងវដ្ដសង្សារ " ។ ដូចពាក្យអដ្ឋកថាចារ្យ ពោលថា :

*យោ ច ឥមំ បដិបត្តឹ បដិបជ្ជតិ*
*សោ ភិក្ខុ នាម ហោតិ*

អ្នកណាប្រតិបត្តិតាមខប្រតិបត្តិនេះ អ្នកនោះឈ្មោះថា" ភិក្ខុ" ។

*បដិបន្នកោ ហិ ទេវោ វា ហោតិ*
*មនុស្សោ វា ភិក្ខូតិ សង្ខ្យំ គច្ឆតិយេវ*

ពិតមែន អ្នកដែលចម្រើនវិបស្សនានោះ ទោះជាទេវតាក្ដី មនុស្សក្ដី បានឈ្មោះថា" ភិក្ខុ" ទាំងអស់ ។

ហេតុនេះ អស់លោកជាឧបាសក ឧបាសិកា គប្បីចូលចិត្តចាំថា បើទុកណាជាយើងនៅមិនទាន់មានឱកាសបួស ស្លៀកដណ្ដប់ពណ៌អម្ពត់ (តាមបែបបញ្ញត្តិ-កម្ម) ក៏ដោយ បើបានប្រតិបត្តិខ្លួនឱ្យចម្រើនដោយគុណធម៌យ៉ាងនេះហើយ ក៏ចាត់ទុកថាបាននៅក្នុងចំណែកនៃការបួស ( តាមបែបចេតនាកម្ម ) ហើយរាប់បានថាជា

របស់រកបានដោយក្រក្រៃលែង ។

ដោយហេតុទៅ ស្ងួម្បីអ្នកបួសបែបគោត្រភូសង្ឃ ព្រះសង្ឃតវង្ស ត្រកូល គឺអ្នកបួសក្នុងសម័យលង្វែកព្រះពុទ្ធសាសនា បួសហើយប្រព្រឹត្តឃ្លៀងឃ្លាតចាកធម៌វិន័យស្ទើរតែទាំងអស់ គ្រាន់តែមានភេទជាអ្នកបួសដោយឥតមានក្លែងក្លាយ ឬ រង្កៀសសង្ស័យឡើយ ។ ស្ងួម្បីនៅត្រឹមតែយកសំពត់ជ្រលក់ពណ៌អម្ចត់មកចងកខ្លះ សៀតនឹងត្រចៀកខ្លះប៉ុណ្ណោះ ដោយបានប្តេជ្ញាសម្គាល់ខ្លួនថាជាអ្នកបួសដោយពិត ឥតមានសង្ស័យ ពីព្រោះ ធ្លាប់បានទទួលផ្នួសអំពីគ្រូអាចារ្យតៗមក, យ៉ាងនេះក៏ហៅថាអ្នកបួសដែរ (បែបចេតនាកម្ម) ។

## បួសមាន ២ ប្រភេទ

### ក. ប្រភេទបួសបែបបញ្ញត្តិកម្ម ៤ យ៉ាងគឺ :

១. បួសចង់ធ្វើឱ្យខ្លួនស្អាតបរិសុទ្ធ ចេញផុតចាកចំណងកាមគុណ ។
២. បួសតាមជំនឿថា មានតែដើរតាមមាគ៌ាព្រះពុទ្ធតែមួយគត់ ទើបរើខ្លួនឱ្យរួចចាកទុក្ខបាន ។
៣. បួសប្រាថ្នាធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ជាទីរួចផុតស្រឡះចាកវដ្តទុក្ខ ។
៤. ដោយភ្ញាក់រលឹកចង់បន្តវង្សព្រះសង្ឃបញ្ញត្តិកម្ម មានយូរអង្វែងគ្រប់ប្រាំពាន់ព្រះវស្សា ។

ប្រភេទបួសបែបបញ្ញត្តិកម្មទាំង ៤ នេះ ត្រូវមានឧបជ្ឈាយ៍ ជាប្រធាន និងគ្រូស្ងួធ្យស្តាំ-ឆ្វេង ព្រមទាំងការកសង្ឃត្រឹមត្រូវផង ។

ប្រភេទបួសបែបបញ្ញត្តិកម្មដែរ ប៉ុន្តែច្រើនប្រព្រឹត្តពាយងាយទុច្ចជាតិកៈ មាន ៤ ពួក :

ក. បួសចាស់គ្រាំគ្រា ទុរន់ទុរា,

ខ. បួសបែបមនុស្សថោកទាប,

គ. បួសបែបបព្វជិត ៦ ពួក,

ឃ. បួសប្រតិបត្តិបំបែកផ្លូវដើរផ្ទុយពីមាគ៌ារបស់ព្រះពុទ្ធ ។

• *បួសចាស់គ្រាំគ្រាទុរន់ទុរា មានទោស ៥ យ៉ាងគឺ :*

១. ទុល្លភោ និបុណោ ក្របានជាមនុស្សល្អិតល្អន់ទន់ភ្លន់,

២. ទុល្លភោ អាកប្បសម្បន្នោ ក្របានជាមនុស្សមានមារយាទត្រឹមត្រូវល្អ

៣. ទុល្លភោ ពហុស្សុតោ ក្របានជាពហុស្សូត អ្នកចេះដឹងច្រើន,

៤. ទុល្លភោ ធម្មកថិកោ ក្របានជាធម្មកថិកជំនាញ,

៥. ទុល្លភោ វិនយធរោ ទ្រទ្រង់វិន័យបានដោយលំបាកពេក ។

• *ហេតុនាំឱ្យអ្នកបួសថោកទាប ៤ យ៉ាងគឺ :*

១. បួសព្រោះក្រទ្រព្យសម្បត្តិ ឬ ខ្លាចអស់ទ្រព្យសម្បត្តិ (បួសសន្សំទ្រព្យ),

២. បួសព្រោះចាស់ជរា-ពិការ ធ្វើការងារអ្វីមិនកើត,

៣. បួសព្រោះអស់ញាតិសន្តាន (ប្រពន្ធស្លាប់ ឬ គេរត់ចោល),

៤. បួសអាស្រ័យការចិញ្ចឹមជីវិតងាយស្រួល ។

• *បួសបែបបព្វជិត ៦ ពួក :*

១. ឧបជីវិកា បួសអាស្រ័យការចិញ្ចឹមជីវិត,

២. ឧបចិណ្ណិកា បួសសន្សំទ្រព្យ,

៣. ឧបកីឡិកា បួសសម្រាប់តែលេងល្បែង,

៤. ឧបទូសិកា បួសសម្រាប់តែប្រទូសរ៉ាយគេ,

៥. ឧបមុយ្ហិកា បួសហើយល្ងិតល្ងង់ គ្មានរៀនសូត្រអ្វី,

៦. ឧបនិស្សរណា បួសប្រាថ្នាវេីរលាស់ខ្លួនចេញចាកវដ្តទុក្ខ ។

បួសទាំង ៦ ពួកនេះ, បួសប្រាថ្នាលាភមក មាន ២ គឺ បួសប្រាថ្នាចិញ្ចឹមជីវិត១, បួសសន្សំទ្រព្យ១ ។ បួសដោយភ្លេចខ្លួន (ប្រមាទ) មាន ៣ គឺ បួសសម្រាប់តែដើរលេង១, គិតតែប្រឡូកប្រឡែងសប្បាយរីករាយគេ១, ល្មិតល្ងង់មិនខិតខំរៀនសូត្យឱ្យចេះដឹង១ ។ បួសដោយភ្ញាក់រលឹកប្រាថ្នារើខ្លួនចេញចាកវដ្តទុក្ខគ្រប់យ៉ាង មានតែ ១ គត់ ដែលកំណត់ថាបួសត្រឹមត្រូវ ។

• *បួសប្រតិបត្តិបំបែកផ្លូវដើរផ្ទុយពីមាគ៌ាព្រះពុទ្ធ*

បព្វជិតរូបណាមួយ ទោះជាភិក្ខុក្តី សាមណេរក្តី បួសហើយប្រព្រឹត្តប្រតិបត្តិ អាស្រ័យដោយលាភសក្ការៈតែម្យ៉ាង ផ្ទុយពីមាគ៌ារបស់ព្រះពុទ្ធហើយ ឥតបានសម្រេចប្រយោជន៍អ្វីក្នុងភេទផ្នួសនោះទេ ។ ព្រះអង្គទ្រង់សម្តែងថា ៖

*អញ្ញា ហិ លាភូបនិសា អញ្ញា និព្វានគាមិនី*
*ឯវមេតំ អភិញ្ញាយ ភិក្ខុ ពុទ្ធស្ស សាវកោ*
*សក្ការំ នាភិនន្ទេយ្យ វិវេកមនុព្រូហយេ*

សេចក្តីប្រតិបត្តិអាស្រ័យលាភ ជាផ្លូវដាច់ដោយឡែក, ទៅព្រះនិព្វាន ជាផ្លូវដាច់ដោយឡែក (ឥតជាប់ពាក់ព័ន្ធគ្នាឡើយ) ភិក្ខុជាសាវ័ករបស់ព្រះពុទ្ធ កាលបើដឹងនូវហេតុការណ៍នេះជាក់ច្បាស់ហើយ មិនគប្បីត្រេកអរនឹងលាភសក្ការៈឡើយ គួរគប្បីស្វះស្វែងចម្រើននូវវិវេក ជាទីស្ងប់ស្ងាត់វិញ ។

## ខ . បួសបែបចេតនាកម្ម

បួសដែលពុំចាំបាច់មានឧបជ្ឈាយ៍ត្រឹមត្រូវ មិនទាក់ទងដោយពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត គឺអាស្រ័យលើចេតនាតែម្យ៉ាង ហៅចេតនាកម្ម មាន ៤ យ៉ាង គឺ ៖

១. បួសរក្សាប្រពៃណី គឺខ្មែរច្រើនមានជំនឿលើប្រពៃណីថា បើមានកូនប្រុស ត្រូវតែឱ្យបួស, អាយុ ១២ ឆ្នាំ បួសជាសាមណេរ ដើម្បីសងគុណមាតា ពីព្រោះមាតាមានគុណ ១២, អាយុ ២១ ឆ្នាំបួសជាភិក្ខុ ដើម្បីសងគុណឪពុក ពីព្រោះ

ឪពុក មានគុណ ២១ ម្ល៉ោះហើយប្រពៃណីនេះគេមិនហ៊ានកន្លងទេ ។ ការបួសនេះទៀតសោត ពុំសូវប្រាកដទេ ជួនកាលជាបញ្ញត្តិកម្ម ជួនកាលជាចេតនាកម្ម ។

២. បួសខ្លាចធ្លាក់ក្នុងនរក គឺខ្មែរយើងខ្លះ ពួកពុទ្ធនិយមមានជំនឿលើសាស្ត្រាបុរាណមួយ ផ្នែកអក្សរសិល្ប៍ ហៅថាសាស្ត្រាសុបិន (រឿងយល់សប្តិ) ។ សាស្ត្រានោះបានចែងថា មានកូនប្រុសចង់បួសសុំលាម្តាយ ម្តាយឃាត់មិនឱ្យបួស ; ទោសព្រោះតែឃាត់កូនមិនឱ្យបួស ទើបយមបាលចាប់ម្តាយទាំងរស់បោះទៅក្នុងខ្ទះដែលមានទឹកកំពុងតែពុះកញ្ជ្រោល ដោយអណ្តាតភ្លើង ។ ល ។

៣. បួសលាបំណន់ បួសប្រភេទនេះកើតឡើងដោយមានភ័យ ឬបំណងអ្វីមួយទើបបន់ លុះបានសម្រេចហើយទើបបួសលា កុំឱ្យចំពាក់បំណន់តទៅទៀត ។

៤. បួសមុខភ្លើង បួសប្រភេទនេះ ក៏នៅក្នុងគំនិតសងគុណដែរ ។ បួសទាំង ៤ ពួកនេះ សុទ្ធតែមានលោកភិក្ខុជាឧបជ្ឈាយ៍បំបួស មានស្បង់ ចីពរ អង្សាក់ វត្តពន្ធ ពណិអម្ចត់ កោរសក់ កោរពុកមាត់ រោមចិញ្ចើម ទទួលត្រៃសរណគមន៍ សមាទានសិក្ខាបទ ១០ ប្រហាក់ប្រហែលបែបបញ្ញត្តិកម្មខ្លះដែរ ប៉ុន្តែគេបួសមិនយូរទេ ខ្លះបានតែមួយភ្លែត បុរាណហៅថា មួយសំកាំងដីរ ខ្លះបួសបាន១.២.៣.៤.៥.៦.៧ ថ្ងៃយ៉ាងយូរ ក៏លាចាកសិក្ខា (សិក) ហើយទៅគ្រប់គ្រងកាមគុណវិញទៅ ពីព្រោះគេគ្មានចេតនាចេញចាកកាម ។

បួសបែបបញ្ញត្តិកម្ម ព្រះសម្មាសម្ពុទ្ធទ្រង់ហាមកុលបុត្រ ៣២ ចំពួក មិនឱ្យចូលបព្វជ្ជាទេ គឺ :

១. *ហត្ថច្ឆិន្ន* មនុស្សកំបុតដៃ

២. *បាទច្ឆិន្ន* មនុស្សកំបុតជើង

៣. *ហត្ថបាទច្ឆិន្ន* មនុស្សកំបុតទាំងដៃ ទាំងជើង

៤. *កណ្ណច្ឆិន្ន* មនុស្សកំបុតត្រចៀក

៥. *នាសច្ឆិន្ន* មនុស្សកំបុតច្រមុះ

៦. *កណ្ណនាសច្ឆិន្ន* មនុស្សកំបុតទាំងត្រចៀក ទាំងច្រមុះ

៧. *អង្គុលិច្ឆិន្ន* មនុស្សកំបុតម្រាមដៃ

៨. *អឡច្ឆិន្ន* មនុស្សកំបុតម្រាមជើង

៩. *កណ្ឌរច្ឆិន្ន* មនុស្សដាច់សរសៃធំ

១០. *ផណហត្ថក* មនុស្សម្រាមដៃជាប់គ្នា

១១. *ខុជ្ជ* មនុស្សគម

១២. *វាមន* មនុស្សតឿ

១៣. *គលគណ្ឌិក* មនុស្សពក-ក

១៤. *លក្ខណាហត* មនុស្សដែលគេបៀតបៀនឱ្យមានស្លាកស្នាម

១៥. *កសាហត* មនុស្សដែលគេវាយដោយរំពាត់

១៦. *លិខិតក* មនុស្សដែលរាជការព្យួរទោសទុក

១៧. *សីបទ* មនុស្សជើងស្ពក់

១៨. *បាបរោគី* មនុស្សមានរោគអាក្រក់

១៩. *បរិសទូសក* មនុស្សប្រទូស្តនឹងបរិស័ទ

២០. *កាណ* មនុស្សទើបនឹងខ្វាក់

២១. *កុណី* មនុស្សក្ញេងដៃ - ជើង

២២. *ខញ្ជ* មនុស្សខ្ចក

២៣. *បក្ខហត* មនុស្សស្លាប់កាយម្ខាង

២៤. *ឆិន្នីរិយាបថ* មនុស្សខ្វិន

២៥. *ជរាទុព្វល* មនុស្សខ្សោយកម្លាំងព្រោះជរា

២៦. *អន្ធ* មនុស្សខ្វាក់

២៧. *មូគ* មនុស្សគ

២៨. *ពធិរ* មនុស្សថ្លង់

២៩. *អន្ធមូគ* មនុស្សទាំងខ្វាក់ ទាំងគ

៣០. *អន្ធពធិរ* មនុស្សទាំងខ្វាក់ ទាំងថ្លង់

៣១. *មូគពធិរ* មនុស្សទាំងគទាំងថ្លង់

៣២. *អន្ធមូគពធិរ* មនុស្សទាំងខ្វាក់ ទាំងគ ទាំងថ្លង់ ។

កុលបុត្រទាំង ៣២ ជំពូកនេះ បើចចេសតែបួស បានឡើងជាសាមណេរដែរ ប៉ុន្តែលោកណាធ្វើឧបជ្ឈាយ៍បំបួស លោកនោះត្រូវអាបត្តិទុក្កដ ។

កាលបើយ៉ាងនេះ សូមឧបជ្ឈាយ៍អ្នកបំបួស និង កុលបុត្រអ្នកសុំបួស ពិនិត្យមើលឱ្យត្រឹមត្រូវផង ។

សម្តេចព្រះមង្គលទេពាចារ្យ

**អ៊ុម - ស៊ុម** ( សង្ឃត្ថេរោ )

*អត្ថបទពិចារណា*

# ទស្សនវិជ្ជាសេដ្ឋកិច្ចពុទ្ធសាសនា

សេដ្ឋកិច្ចវិទ្យា គឺជាមែកធាងនៃចំណេះដែលសិក្សាអំពីការចំរើនលូតលាស់ជារូបវន្ត (រីកចំរើនខាងសម្ភារៈ) របស់មនុស្ស ។ ជាបឋម, ពុទ្ធសាសនា គឺជាទ្រឹស្តីតម្រង់ឆ្ពោះទៅរកការរីកចំរើនខាងស្មារតី ។ ទោះបីស្ថេរភាពសេដ្ឋកិច្ច មានតួនាទីសំខាន់នៅក្នុងជីវភាពប្រចាំថ្ងៃក៏ដោយ, ក៏ពុទ្ធសាសនាមិនបានជំរុញ ឬលើកទឹកចិត្តដល់ការរីកចំរើនខាងសម្ភារៈដែរ ពីព្រោះ ពុទ្ធសាសនាប្រៀនប្រដៅថា អ្វីៗទាំងអស់ ត្រូវទទួលរងការប្រែប្រួល ហើយគ្មានភាពឋិតថេរទេ ។ ដោយសារមានហេតុផលនេះ ទើបមានមនុស្សខ្លះជឿថា ពុទ្ធសាសនា គឺជាសាសនា (Religion) ដែលមិនជួយអោយមានវឌ្ឍនភាពខាងសេដ្ឋកិច្ចទេ ហើយសាបព្រោះវិធីសាស្ត្រទុទិដ្ឋិនិយម ចំពោះការចំរើនលូតលាស់ខាងសម្ភារៈនៃពិភពលោក ។

តទៅនេះ គឺជាទឡ្ហីករណ៍សម្រាប់គាំទ្រទស្សនះរបស់គេ ៖

១ . ពុទ្ធសាសនា គឺជាសាសនាដែលជួយធ្វើអោយជីវិតយើងក្នុងជាតិខាងមុខមានសុភមង្គល ហើយមិនជួយធ្វើអោយជីវិតយើងនៅក្នុងលោកនេះ បានរីកចំរើនទេ ។

២ . ពុទ្ធសាសនាទទួលស្គាល់ថា លោកនេះពោរពេញដោយទុគ្គតភាព និងសេចក្តីទុក្ខព្រួយ ។ ពុទ្ធសាសនា បានប្រៀនប្រដៅទ្រឹស្តី ដែលជួយលុបបំបាត់ *ចំណង់* ដែលនាំទៅរកការធ្វើអោយបានសំរេចនូវវឌ្ឍនភាពលោកិយ៍នេះ ។

៣ . ការប្រៀនប្រដៅអំពី «កម្មៈ» ដែលចែងនៅក្នុងទ្រឹស្តីពុទ្ធសាសនា

គឺជារបាំងរាំងខ្ទប់ *ចំណង់* ដើម្បីសំរេចវឌ្ឍនភាពនៅក្នុងជីវិតនេះ ។

៤ - ពាក្យប្រៀនប្រដៅ ដែលទាក់ទងនឹងការអោយវៀរចាកសេចក្ដីសប្បាយក្នុងលោកីយ៍នេះ និងពាក្យប្រៀនប្រដៅអោយរស់នៅក្នុងជីវិតសាមញ្ញ គឺជាឧបសគ្គដល់វឌ្ឍនភាពខាងសេដ្ឋកិច្ច ។

ដោយហេតុនេះ, មនុស្សភាគច្រើនដែលបានយល់ច្រឡំ ឬយល់ស្រពេចស្រពិលហេតុការណ៍ខ្លះ ដែលមានចែងនៅក្នុងពុទ្ធសាសនា ក៏បានប្រកាសថា គ្មានទស្សនវិជ្ជាខាងសេដ្ឋកិច្ច នៅក្នុងទ្រឹស្ដីពុទ្ធសាសនាទេ ។ ប៉ុន្តែ ពេលដែលទស្សនៈនេះត្រូវបានយើងពិនិត្យមើលទៅ, យើងកើតមានគំនិតផ្ទាល់ខ្លួនថា នៅក្នុងធម៌ដែលព្រះពុទ្ធបានទេសនា មានពាក្យពេចន៍យោងជាច្រើនទាក់ទងដល់ទស្សនវិជ្ជាច្បាស់លាស់ បង្កប់នៅក្នុងពុទ្ធសាសនា ដែលស្ដីពីបុគ្គលនៅក្នុងសេដ្ឋកិច្ចសង្គម ។

គ្មានការអធិប្បាយនៅក្នុងទីណាមួយ ដែលថាគោលការណ៍ល្អៗទាំងអស់ប្រៀនប្រដៅនៅក្នុងពុទ្ធសាសនា ត្រូវបានកំណត់តែក្នុងក្របខណ្ឌ ឬក៏នាំទៅរកគោលដៅ ដែលបញ្ចប់ត្រឹមបានសំរេចលទ្ធផលបរិបូណ៌ក្នុងជាតិក្រោយ តែប៉ុណ្ណោះនោះទេ ។ ការរំដោះផុតពីសង្សារ (ការកើត - ស្លាប់ៗ) ដែលជាគោលដៅទីបំផុតក្នុងពុទ្ធសាសនា អាចត្រូវបានសំរេចនៅក្នុងលោកនេះដោយផ្ទាល់ ប្រសិនបើគេខំព្យាយាមតឹងតែងដើម្បីអោយបានសំរេចនោះ ។ បាលីមួយឃ្លានេះថា « ធម្មចារី សុខំ សេតិ, អស្មិំ លោកេ បរម្ហិ ច » មានន័យថា មនុស្សដែលដឹកនាំជីវិតត្រឹមត្រូវ តែងបានរស់នៅជាសុខនៅក្នុងលោកនេះ ក៏ដូចក្នុងលោកខាងមុខ ។ នេះមានន័យយ៉ាងច្បាស់ទៀតថា សុភមង្គលដែលផ្ដល់អោយក្នុងលោកខាងមុខ អាស្រ័យទាំងស្រុងលើជីវិតត្រឹមត្រូវ និងប្រកបដោយផលល្អកើតមាននៅក្នុងលោកនេះ ។ *ម្យ៉ាងទៀតគ្មានពាក្យប្រៀនប្រដៅណានៅក្នុងទ្រឹស្ដីពុទ្ធសាសនា ដែលចង្អុលប្រាប់ថាបុគ្គលត្រូវរងទុក្ខសោកក្នុងជាតិនេះសិន ដើម្បីអោយបានសោយសុខ និងសេចក្ដី*

*ចំរុងចំរើនក្នុងជាតិក្រោយនោះទេ* ។ ក្នុងបែបដូចគ្នានេះ ព្រះពុទ្ធបានចង្អុលបង្ហាញថា ទុក្ខគ្រប់យ៉ាងនៅក្នុងលោកនេះត្រូវបានកើតមក មិនមែនដោយសារអានុភាពរបស់អាទិទេពណាមួយនោះទេ ប៉ុន្តែ គឺដោយសារផលនៃអំពើរបស់ខ្លួនឯងផ្ទាល់ ។ ម្យ៉ាងទៀត ពុទ្ធសាសនាក៏បានបញ្ជាក់យ៉ាងច្បាស់ថា ដើម្បីអោយអាចឆ្លងផុតពីទុក្ខ និងភាពតានតឹងគ្រប់យ៉ាងក្នុងជីវិត, គេត្រូវបំពេញការងារដោយសេចក្ដីព្យាយាម និងប្រកបដោយឆន្ទៈមោះមុត ។

កាលណានិយាយយោងដល់ កម្មៈ, គេបានចង្អុលប្រាប់ថា នេះមិនមែនជាហេតុផលតែមួយគត់ទេ ដែលជះឥទ្ធិពលមកលើជីវិតមនុស្សលើផែនដីនេះ ។ ប៉ុន្តែ កម្មៈ គ្រាន់តែជាឥទ្ធិពលមួយបែបនោះតែប៉ុណ្ណោះ ។ វាគ្មានចំណុចណាមួយដើម្បីនឹកគិតតែពី កម្មៈ នោះទេ ។ វិរយៈ និងឆន្ទៈ គួរតែត្រូវបានផ្ដល់អាទិភាពខ្ពស់លើសលប់ជាង កម្មៈទៅទៀត ។ នេះគឺជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដល់សាវ័ករបស់ព្រះអង្គក្នុងឱកាសផ្សេងៗ ។

ទស្សនវិជ្ជាស្ដីពីទុក្ខៈ ដែលមានចែងនៅក្នុងទ្រឹស្ដីពុទ្ធសាសនា, កម្មៈ ហើយនិងពាក្យប្រៀនប្រដៅទាក់ទងនឹងលោកខាងមុខ - មិនមែនជារបាំងរាំងរាដល់ *ការអភិវឌ្ឍន៍ខាងសេដ្ឋកិច្ចជាបុគ្គល ឬជាសមូហភាព* នោះទេ ។

ឥឡូវ ចូរយើងពិនិត្យមើលសេដ្ឋសាស្ត្រជាក់ស្ដែង ដែលពុទ្ធសាសនាបានបង្រៀនយើង តាមរយៈទស្សនវិជ្ជារបស់ខ្លួន សម្រាប់ការរស់នៅប្រកបដោយជោគជ័យ ។ *ទស្សនវិជ្ជាស្ដីពីសេដ្ឋកិច្ចរបស់ពុទ្ធសាសនាមិនដូចគោលការណ៍សេដ្ឋកិច្ចបច្ចុប្បន្ននេះ, គឺមិនផ្ដល់សារសំខាន់តែទៅលើការរីកចំរើនខាងមូលដ្ឋានសម្ភារៈ ប៉ុណ្ណោះទេ, ប៉ុន្តែបានផ្ដោតការយកចិត្តទុកដាក់ដល់អជ្ឈត្តិកប្បញ្ញា (the inner intellect) របស់បុគ្គល* ថែមទៀត ។

សេដ្ឋវិទ្យា គឺជាវិទ្យាសាស្ត្រដែលកំណត់បញ្ជាក់ ថាតើសេចក្ដីត្រូវការខាង

រូបកាយរបស់មនុស្ស ត្រូវបានបំពេញយ៉ាងដូចម្តេច ដើម្បីអោយមនុស្សបានសប្បាយរីករាយ ។ ទ្រឹស្តីដ៏ច្បាស់លាស់នៅក្នុងពិភពលោកនេះថា « ធនធានរបស់ពិភពលោក មានកំរិតព្រំដែន, ឯសេចក្តីត្រូវការរបស់មនុស្សពុំមានកំរិតព្រំដែនទេ », ទ្រឹស្តីនេះ ក៏ត្រូវបានចែងនៅក្នុងពុទ្ធសាសនាដែរ ។

នៅក្នុងរត្តបាលសូត្រ នៃមជ្ឈិមនិកាយ មានការនិយាយដល់ហេតុការណ៍ដែលថា មនុស្សទាំងឡាយនៃពិភពលោកនេះ ពុំមានភាពសុក្រឹតទេ, ហើយថាមនុស្សទាំងឡាយនោះ គ្មានសេចក្តីរីករាយទេ ។ គេទាំងឡាយនោះ ក្លាយជាទាសករនៃតណ្ហា ។

សេដ្ឋវិទូលោកខាងលិច ដែលបានលើកយកបញ្ហារវាងធនធានមានកំរិតព្រំដែន ហើយនិងសេចក្តីត្រូវការមិនមានកំរិតព្រំដែន មកបង្ហាញ , ក៏បានឆក់យកឱកាសនេះ ដើម្បីជំរុញអ្នកប្រើប្រាស់អោយបង្កើនការបរិភោគ ការប្រើប្រាស់ច្រើនឡើងថែមទៀត ។ ទោះបីប្រព័ន្ធនេះ មានភាពចាំបាច់សម្រាប់ប្រព័ន្ធសេដ្ឋកិច្ចមូលធនក៏ដោយ, ក៏អ្នកទាំងឡាយដែលមានសេចក្តីត្រូវការបន្តិចបន្តួច យល់ឃើញថាអ្នកទាំងឡាយដែលមានឥទ្ធិពល និងមានឯកសិទ្ធិ កំពុងបំផ្លាញធនធាន បង្កើតអោយមានចំណោទខាងសេដ្ឋកិច្ច កាន់តែច្រើនឡើងៗ ។ ពុទ្ធសាសនា គាំទ្រទស្សនៈដែលថា ជីវភាពសាមញ្ញ នឹងជួយអោយយើងប្រើប្រាស់ធនធាន ដែលមានកំរិតព្រំដែនបានត្រឹមត្រូវ ហើយដោះស្រាយបាននូវបញ្ហាសេដ្ឋកិច្ច ដែលបង្កើតឡើងដោយចំណង់និងតម្រេករបស់យើង ដែលគ្មានកំរិតព្រំដែននោះ ។

ពេលនិយាយអំពីទស្សនវិជ្ជា ស្តីពីសេដ្ឋកិច្ចរបស់ពុទ្ធសាសនា ទស្សនៈទាំងឡាយដែលចែងនៅក្នុងទ្រឹស្តីរបស់ព្រះពុទ្ធទាក់ទងនឹងធនធាន បានក្លាយជាទស្សនៈដ៏មានសារសំខាន់ ។ លក្ខណ៍ការណ៍ ដែលគេអាចប្រើដើម្បីវាយតម្លៃទ្រព្យសម្បត្តិរបស់គេ គឺប្រាក់ ។ ប្រាក់ ត្រូវបានគេប្រើជាមធ្យោបាយទាក់ទង ដើម្បីសំរេចចំណង់

និងតម្រេកខាងសម្ភារៈ ។ ស្របតាមនេះដែរ, ទ្រឹស្តីរបស់ពុទ្ធសាសនា ក៏ទទួលយកទស្សនះដែលថា ដើម្បីរស់នៅអោយបានហាំហួន គេគប្បីប្រមូលអោយបានទ្រព្យសម្បត្តិយ៉ាងច្រើន ។

នៅក្នុងប្តូនដំណាក់កាល, ពុទ្ធសាសនាបាននិយាយដល់ការចំរើនដុះដាលរបស់បុគ្គល ។ ឱកាសមួយបែបនោះ គឺឱកាសបង្កឡើងដើម្បីទទួលសោយសេចក្តីសប្បាយ ដែលថា គេបានប្រមូលទ្រព្យសម្បត្តិបានច្រើន ។ នេះជាហេតុផល ដើម្បីសប្បាយរីករាយ, ព្រះពុទ្ធក៏ទ្រង់បានសម្តែងដែរថា ទ្រព្យសម្បត្តិដែលប្រមូលបានយ៉ាងនេះ, គេគប្បីប្រមូលបានដោយពលកម្មយ៉ាងតឹងតែង, ហើយទ្រព្យសម្បត្តិរកបានដូចនោះ គប្បីត្រូវបានការពារ កុំអោយខ្ជះខ្ជាយ ។ ខ្លឹមសារនេះ មាននិយាយនៅក្នុងព្យគ្ឃបជ្ជសូត្រ និងសិង្គាលោវាទសូត្រ ។ នៅក្នុងទស្សនវិជ្ជា នៃទ្រឹស្តីរបស់ពុទ្ធសាសនា បែបបទដែលទ្រព្យសម្បត្តិគប្បីប្រមូលទុកដាក់ ហើយនិងការចំណាយប្រាក់កាសគប្បីប្រព្រឹត្តទៅយ៉ាងណានោះ ត្រូវបានពន្យល់យ៉ាងច្បាស់នៅក្នុងអត្ថបទពុទ្ធសាសនា ។

យោលតាមសិង្គាលោវាទសូត្រ, ប្រាក់ដែលសន្សំបាន គប្បីចំណាយជាដំបូងបង្អស់សម្រាប់អាហារ, សម្លៀកបំពាក់, លំនៅឋាន, ថ្នាំពេទ្យ . ល . កុំអោយលំបាកវេទនា ។ ក្នុងន័យដូចគ្នាដែរ សេចក្តីសម្បូរសប្បាយរបស់បុគ្គលគឺ ព្រះពុទ្ធទ្រង់បានពិពណ៌នានៅក្នុងពាក្យប្រៀនប្រដៅរបស់ព្រះអង្គហើយ, ហេតុការណ៍ដែលថា បុគ្គលបានចំណាយប្រាក់របស់ខ្លួន ដើម្បីបំពេញសេចក្តីត្រូវការ និងការចាំបាច់របស់ខ្លួន ... គប្បីធ្វើអោយបុគ្គលមានអារម្មណ៍ថា ខ្លួនបានចំណាយប្រាក់ដើម្បីចាប់យកសេចក្តីសុខ, ហើយទ្រព្យសម្បត្តិត្រូវបានប្រើប្រាស់ ដើម្បីបុព្វហេតុដ៏ល្អ ។ នេះគួរតែផ្តល់អោយបុគ្គលនោះ នូវសេចក្តីរីករាយទាំងខាងផ្លូវចិត្ត ទាំងខាងផ្លូវកាយ ។ ក្នុងទីនោះ ព្រះពុទ្ធទ្រង់បានបំភ្លឺហេតុការណ៍ថា ប្រាក់សន្សំបានគប្បីចំណាយសម្រាប់

អត្ថប្រយោជន៍របស់ខ្លួនផ្ទាល់ ក៏ដូចជាសម្រាប់បុគ្គលក្រោមអាណាព្យាបាលរបស់ខ្លួន ហើយនិងអ្នកឯទៀតកំពុងរស់នៅជាមួយផង កុំអោយគេរងការអត់ឃ្លាន ។ បែបបទដែលប្រាក់សន្សំបាន គប្បីចាយវាយយ៉ាងណា គឺនឹងមាននិយាយនៅក្នុងអបុល្លកសូត្រ នៃសំយុត្តនិកាយ ។

តាមទស្សនះនេះ វាពុំមានន័យថា ពុទ្ធសាសនាបន្ទច់បង្អាក់មនុស្សមិនអោយចាយវាយប្រាក់ខំរកបាន សម្រាប់សេចក្តីត្រូវការប្រចាំថ្ងៃនោះទេ ។ ជាជំនួសវិញ ពុទ្ធសាសនាលើកស្ទួយទស្សនះដែលថា ទ្រព្យសម្បត្តិទាំងឡាយ គប្បីប្រើប្រាស់បរិភោគសម្រាប់ជាប្រយោជន៍របស់ខ្លួន ក៏ដូចជាសម្រាប់ប្រយោជន៍ដល់អ្នកដទៃ ។ ដូច្នេះ ទស្សនវិជ្ជាពុទ្ធសាសនា ជួយលើកទឹកចិត្តដល់ផលិតកម្ម ។ ប៉ុន្តែ អ្វីដែលយើងត្រូវចងចាំ គឺថា ពុទ្ធសាសនាមិនយល់ព្រមចំពោះការប្រមូលទ្រព្យសម្បត្តិដោយគ្មានកំណត់ព្រំដែននោះឡើយ ។

បែបបទដែលផលិតកម្ម គប្បីត្រូវបានលើកទឹកចិត្ត មិនគ្រាន់តែតាមរយះការប្រើប្រាស់ប៉ុណ្ណោះទេ ប៉ុន្តែតាមរយះការវិនិយោគទុនផងដែរ ។ ទស្សនះនេះ ត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់ដោយពាក្យយោងថា « ទ្វីហិ កម្មំ បយោជយេ » ដែលមានន័យថា ពីរភាគបួននៃប្រាក់សន្សំបាន គប្បីវិនិយោគ ឬរក្សាទុកសម្រាប់ការប្រើប្រាស់អនាគត ដោយទុកដាក់ក្នុងធនាគារ .ល.។ ថ្វីបើមានមធ្យោបាយជាច្រើន ដែលតាមរយះនេះ ប្រាក់អាចត្រូវបានវិនិយោគក៏ដោយ, ក៏ខ្សែបន្ទាត់នៃគំនិតបច្ចុប្បន្នតែងគាំទ្រទស្សនះលើកឡើងដោយទ្រឹស្តីពុទ្ធសាសនាដែរ ។ ប៉ុន្តែ, ជាការណ៍ជាក់ច្បាស់ណាស់ថា បែបបទពុទ្ធសាសនាចំពោះការវិនិយោគ និងការស្វែងរកទ្រព្យសម្បត្តិ គឺផ្សេងពីបច្ចេកទេស ដែលមានចែងនៅក្នុងសេដ្ឋសាស្ត្រសម័យ ។

កាលណាប្រមូលបានទ្រព្យសម្បត្តិ ឬវិនិយោគប្រាក់លើរបរជំនួញផ្សេងៗ មតិដែលថា តើវិធីដោះស្រាយបញ្ហាត្រូវ ឬខុសយ៉ាងណានោះ, មិនទាន់ត្រូវ

បានបំភ្លឺ ដោយទស្សនវិជ្ជាសេដ្ឋកិច្ចលោកខាងលិចទេ ។ គោលដៅគឺ ការរកចំណេញប៉ុណ្ណោះ ។ ផ្ទុយទៅវិញ, យោងតាមទស្សនវិជ្ជាសេដ្ឋកិច្ចពុទ្ធសាសនា រកប្រាក់បានដោយមិនត្រឹមត្រូវ តាមមធ្យោបាយបោកប្រាស និងដោយវិធីទាំងឡាយដែលបង្ខូចប្រយោជន៍សង្គម មិនត្រូវបានទទួលយកទុកជាមាគ៌ាត្រឹមត្រូវក្នុងការរកប្រាក់ទេ ។ មានពាក្យយោងជាច្រើនទាក់ទងនឹងការស្វែងរកទ្រព្យសម្បត្តិ :

ឧទាហរណ៍ : *ធម្មេន ធម្មលទ្ធា* «ប្រាក់រកបានមកដោយមធ្យោបាយត្រឹមត្រូវ», *សេទា វក្កិតេហិ* «ប្រាក់រកបានមកដោយញើស និងពលកម្ម» - ទស្សនៈនេះ ត្រូវបានព្រះពុទ្ធយល់ព្រម និងគាំទ្រ ។

« ពលកម្ម » គឺជាទិដ្ឋភាពមួយទៀតនៃផលិតកម្ម បើយោងតាមសេដ្ឋ-សាស្ត្រ ។ សូម្បីនៅក្នុងវិធីសេដ្ឋកិច្ចពុទ្ធសាសនា ពលកម្មដើរតួនាទីមួយដ៏លេចធ្លោបំផុត, ហើយវាបានបង្ហាញអោយឃើញថា កាលណាប្រាក់ឈ្នួលខ្ពស់ត្រូវបានផ្តល់អោយទៅពលករ, ផលិតកម្មកាន់តែចំរើនឡើង១៨ឥតឈប់ឈរ ។ ព្រះពុទ្ធទ្រង់បានរិះគន់ជានិច្ចចំពោះមនុស្សទាំងឡាយដែលគិតតែរកចំណេញប៉ុណ្ណោះ ដោយសារការកេងប្រវញ្ចលើពលកម្ម ។ នៅក្នុងសិង្គាលោវាទសូត្រ ព្រះពុទ្ធបានបំភ្លឺយ៉ាងច្បាស់ ថាពលកម្មគប្បីត្រូវបានផ្តល់ប្រាក់បំណាច់អោយយ៉ាងសមស្រប ហើយប្រាក់លើកទឹកចិត្ត (ប្រាក់ទឹកតែ) - ល - ត្រូវផ្តល់អោយក្នុងបែបបទត្រឹមត្រូវដល់ពលករ ។ ការងារប្រគល់អោយពលករធ្វើ ត្រូវតែជាការងារដែលពលករអាចធ្វើ ឬអាចបំពេញបាន ។

កាលណាគេពិចារណា ថ្នាក់ប្រទេស ហើយមិនមែនថ្នាក់បុគ្គល ឬថ្នាក់អង្គការទេ - កត្តាជាច្រើនដែលអាចរួមវិភាគទានជួយអោយបានសំរេច នូវវឌ្ឍនភាពសេដ្ឋកិច្ច ហាក់ដូចជាមានចែងនៅក្នុងទស្សនវិជ្ជាសេដ្ឋកិច្ចពុទ្ធសាសនារួចហើយ ។

ព្រះពុទ្ធចាត់ទុកយ៉ាងសមស្របបំផុតថា ទុគ្គតភាពរបស់ប្រទេស បណ្តាលមកពីការថ្លោះធ្លោយខ្លះ ដែលអាចកើតមានទាក់ទងទៅនឹងការបែងចែកទ្រព្យ-

សម្បត្តិ ។ ប្រសិនបើទ្រព្យសម្បត្តិទាំងអស់ នៅក្នុងប្រទេសមួយ ត្រូវបានក្តោបក្តាប់តែដោយផ្នែកមួយមានកំរិតរបស់សង្គមប៉ុណ្ណោះ, វិធានការកែសម្រួលជាបន្ទាន់ ត្រូវតែបានលើកឡើង ។ ពីព្រោះស្ថានភាពនោះ អាចដឹកនាំប្រទេសទៅកាន់ភាពក្រីក្រ ។

ដូចគ្នានេះដែរ, ព្រះពុទ្ធនៅក្នុងចក្កវត្តិសីហនាទសូត្រ បានសំដែងអំពីប្រធានបទនេះ ហើយទ្រង់បានបញ្ជាក់ថា ករណីយកិច្ចរបស់រដ្ឋាភិបាល គឺត្រូវផ្តល់មូលធនសម្រាប់អោយសហគ្រិន ធ្វើវិនិយោគប្រាក់លើការរកស៊ីរបស់សហគ្រាសនានា ។ រដ្ឋាភិបាល គប្បីផ្តល់ការងាយស្រួលផងដែរ ដូចជា ដី ទៅអោយពួកកសិករ, ឧស្សាហករ . ល . ។ យោងតាមទ្រឹស្តីសេដ្ឋកិច្ច ពន្ធអាករគឺជាប្រភពសំខាន់នៃចំណូលសម្រាប់រដ្ឋាភិបាល ។ រដ្ឋាភិបាលប្រើប្រាស់ចំណូលនោះ សម្រាប់ការងារសុ-ខុមាលភាព និងការអភិវឌ្ឍន៍ ។ ពុទ្ធសាសនា ទន្ទឹមនឹងទទួលយកមនោគមវិជ្ជានេះជាគោលការណ៍, ក៏បានបង្ហាញទស្សនៈមួយរបស់ពុទ្ធសាសនា ស្តីពីប្រធានបទនេះដែរ ។ ព្រះពុទ្ធ នៅពេលព្រះអង្គមានពុទ្ធដីកាយោងដល់ស្តេច « លិច្ឆវី », ទ្រង់បានបញ្ជាក់ថាការប្រមូលពន្ធអាករដោយមិនត្រឹមត្រូវ គឺជាការខុសឆ្គង ហើយថាពន្ធអាករ ត្រូវតែរដ្ឋាភិបាលប្រមូលយកពីប្រជានុរាស្ត្រ ដោយមិនបន្ថែមបន្ទុកលើប្រជារាស្ត្រ ជាមួយបន្ទុកពន្ធអាករ តាមបែបបទដែលឃ្មុំជញ្ជក់យកទឹកឃ្មុំអំពីផ្កា ដោយមិនធ្វើអោយផ្កាខូចខាត ឬអន្តរាយ ។ ព្រះពុទ្ធទ្រង់មានពុទ្ធដីកាផងដែរថា វាជាករណីយកិច្ចរបស់ប្រជានុរាស្ត្រ ដើម្បីបង់ពន្ធអាករទាន់ពេលវេលា ដោយមិនលាក់បំពួនពតិមាន ស្តីពីការបង់ពន្ធអាករ ។ ពាក្យថា «រាជពលី» គឺត្រូវបានប្រើសម្រាប់កត់សំគាល់ពន្ធអាករដែលត្រូវបង់ជូនរដ្ឋ ។

ដូច្នេះ យើងឃើញថា ពុទ្ធសាសនា ដោយសារមានទស្សនវិជ្ជាសេដ្ឋកិច្ចរបស់ខ្លួនច្បាស់លាស់ អាចត្រូវបានគេចាត់ទុកមិនត្រឹមតែជាទ្រឹស្តីមួយ ដែលនិយាយអំពីជីវិតខាងមុខប៉ុណ្ណោះទេ, ប៉ុន្តែ គេចាត់ទុកជាទ្រឹស្តីមួយ, ជាសាសនាមួយ ដែល

និយាយអំពីមាគ៌ា និងមធ្យោបាយសម្រាប់ធ្វើអោយសង្គម និងបុគ្គលបានរីកចំរើនថែមទៀត ។ គម្ពីរព្រះត្រៃបិដក ពោរពេញដោយពាក្យប្រៀនប្រដៅ ដែលជាភស្តុ-តាងបញ្ជាក់ថា ពុទ្ធសាសនាមិនគ្រាន់តែនិយាយអំពីជីវិតខាងមុខប៉ុណ្ណោះទេ, ប៉ុន្តែជួយបុគ្គល និងសង្គមអោយមានជីវិតរស់នៅចំរុងចំរើននៅក្នុងសង្គម ដោយសារទស្សនវិជ្ជាសេដ្ឋកិច្ចច្បាស់លាស់ ដែលមាននៅក្នុងទ្រឹស្តីពុទ្ធសាសនា ទាំងមូល ។

By Bellanwila Wimalaratana

in Buddhism, Society and Environment

បកប្រែ : **ឈន អៀម**

**យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ**
**ឯកាហំ ជីវិតំ សេយ្យោ វីរិយំ អារភតោ ទឡ្ហំ ។**

*បុគ្គលណាខ្ជិលច្រអូស មានសេចក្តីព្យាយាមអន់ថយ ទោះបីរស់នៅមួយរយឆ្នាំ ក៏មិនប្រសើរស្មើនឹងការរស់នៅ សូម្បីមួយថ្ងៃរបស់បុគ្គលអ្នកមានព្យាយាមខ្ជាប់ខ្ជួនឡើយ ។*

( ធម្មបទ )

**អត្តានមេវ បឋមំ បតិរូបេ និវេសយេ**
**អថញ្ញមនុសាសេយ្យ ន កិលិស្សេយ្យ បណ្ឌិតោ ។**

*បុគ្គលគួរតម្កល់ខ្លួនឯងអោយតាំងនៅក្នុងគុណធម៌ដ៏សមគួរជាមុនសិន ចាំប្រដៅអ្នកដទៃជាក្រោយ ទើបមិនលំបាក ។*

( ធម្មបទ )

**ហីនំ ធម្មំ ន សេវេយ្យ បមាទេន ន សំវសេ**
**មិច្ឆាទិដ្ឋឹ ន សេវេយ្យ ន សិយា លោកវឌ្ឍនោ ។**

*បុគ្គលមិនគួរប្រព្រឹត្តអំពើថោកទាប, មិនគួររស់នៅដោយសេចក្តីប្រមាទ, មិនគួរប្រកាន់យកនូវទស្សនៈខុស, មិនគួរជាអ្នករស់នៅអោយគ្រាន់តែចង្អៀតលោកឡើយ ។*

( ធម្មបទ )

# ភាព្យរំលឹកពីអក្សរខ្មែរ

ព្រះរាជនិពន្ធន៍សម្ដេចព្រះសង្ឃរាជ គណៈមហានិកាយ

## បទពាក្យ ៧

## អក្សរខ្មែរ

. អក្សរខ្មែររុងរឿងដោយសារខ្មែរ ពុំហ៊ានបំបែរឱ្យភ្លាត់ខុស
ជនខ្មែរគ្រប់គ្នាទាំងស្រីប្រុស ពុំហ៊ានបង្ហុសឱ្យខូចបង់ ។
. ជនខ្មែរស្រុះគ្នាលើកតម្កើង ដំឡើងពាក្យពេចន៍ដោយផ្ចិតផ្ចង់
ខ្មែរជាគ្រហស្ថខ្មែរជាសង្ឃ ខំប្រឹងតម្រង់អក្សរជាតិ ។
. អក្សរវិបត្តិជាតិវិបត្តិ ខ្ចាយខ្ចាត់រាត់រាយក្លាយឃ្លៀងឃ្លាត
ហេតុនេះខ្មែរយើងកុំរវាត ត្រូវរក្សាជាតិឱ្យរឹងប៉ឹង ។
. បើដឹងមិនដល់កុំធ្វើចេះ ចំណេះតិចតួចស្ដួចស្ដើងស្ដឹង
បើចង់ច្បាស់លាស់ត្រូវខំប្រឹង កុំដេកសម្ងំឱ្យចេះឯង ។
. ចំណេះកើតមានព្រោះការរៀន កម្ជិលអៀនប្រៀនកុំសម្ដែង
ធ្វើឱ្យគេស្ងើចគេកោតក្រែង ស្លាក់ស្លែងទេកុំរិះគន់គេ ។
. ត្រូវរិះគន់ខ្លួនឯងជាមុន កុំឱ្យស៊ើយស៊ុនខុសទទេ
បើឆ្ងល់ពុំយល់ត្រូវសួរគេ ឥតចោកអ្វីទេថ្លៃទេតើ ។
. បុរាណថាថោកអីនឹងដៃ ថ្លៃអីនឹងមាត់ពោលសើរើ
រៀនទៅសួរទៅទើបគ្រាន់បើ អើពើចង់ចេះប្រសើរណាស់ ។

- ចាស់ថាបើល្ងង់កុំធ្វើចេះ
បើមានចំណេះឱ្យជាក់ច្បាស់
បើស្ទើងហើយចង់ឱ្យបានក្រាស់
ត្រូវថៃមកម្រាស់ផ្សំសាច់គ្នា ។
- អបស្ដបប៉ះប៉ុនយកកម្រាស់
កុំចាំងកុំច្រាសហួសមាត្រា
ប៉ះផ្សំផ្គុំភ្ជិតទើបកើតជា
ទោលឬបន្ទារមួនជាមុន ។
- បើចេះអក្សរនិងភាសា
នៃជាតិណា១កុំជ្រួលស៊ុន
ងាប់ស័ព្ទប្រែស្រាយក្លាយជាប់កុន
សុនត្រូនប្រែស្រាយឃ្លាតក្ដីពិត ។
- កាលដែលប្រារព្ធនឹងប្រែស្រាយ
ត្រូវគិតនាយអាយដោយពិនិត្យ
ឱ្យឃើញសេចក្ដីជាខ្មែរពិត
សឹមប្រែកុំផ្ចិតតាមពាក្យគេ ។
- ត្រូវប្រែឱ្យមកជាសេចក្ដី
ដែលខ្មែរប្រុសស្រីអាចរិះរេ
ស្ដាប់យល់មិនឆ្ងល់ទើបហៅប្រែ
ត្រឹមត្រូវតាមរូបសេចក្ដីពិត ។
- អ្នករៀនភាសាជនបរទេស
ទ្វេធ្វេសដោយការឥតបើគិត
កាលខ្លួនកំពុងរៀនប្រឹងប្រិត
ប្រែផ្ចិតឱ្យចំតាមរូបស័ព្ទ ។
- ភ្លេចនឹកគិតមកភាសាខ្លួន
ឱ្យយល់សំនួនដែលងាយស្ដាប់
សម្ដីងសង្កេតតែរូបស័ព្ទ
ក៏ស្រាប់តែប្រែខុសទាំងស្រុង ។
- អ្នករៀនសំស្ក្រឹតឬបាលី
ប្រែខុសសេចក្ដីព្រោះភ័ន្តផុង
យល់ខុសទទេទាំងដើមចុង
ចូលក្នុងរិងស៊ុងខ្មាសអ្នកផង ។
- តិដ្ឋះបាលីប្រែថាឈរ
អ្នករៀនឈ្លក់វរអន់មួង១
ត្រង់មានសេចក្ដីថាស្ងួនត្រង
ប្រែត្តងថាឈរនៅងាប់ស័ព្ទ ។
- បារាំង «ពរ៍តេស្សួរឡាតែត»(១)
ខ្មែរឆ្អេតចិត្តជាប់បែរប្រែប្រាប់
អ្នកដែលមិនចេះឱ្យគ្នាស្ដាប់
បង្គាប់ថាឱ្យកាន់លើក្បាល ។

---

(1) porter sur la tête

- មិនប្រាប់ឱ្យគ្នាដឹងថាទូល
ពាក្យខ្មែរថាទូលក៏លើក្បាល
- តែងកាព្យឱ្យត្រូវតាមសម្ព័ស្ស
កុំចេះតែតែងតាមចិត្តខ្លួន
- ពាក្យអឺយនិងអើយ (១) សូរផ្សេងគ្នា
ស្តាប់បងមិនឮឬសួនភ្ញា
- ព្រះបាទសម្តេចព្រះហរិរក្ស
ក្នុងកាព្យព្រះអង្គដែលមានចួន
- កវីគួរតែយកតម្រាប់
រំលុបបែបនោះមិនត្រាប់ត្រង
- មានអ្នកតែងកាព្យខ្លះប៉ាន់ថា
ប្រើជាកិរិយាស័ព្ទខុសណាស់

នេះហៅស្រមូលពុំត្រកាល
ត្រូវរាលប្រែខុសពីពាក្យខ្លួន ។
តាមកាព្យចាស់ៗដែលមានចួន
ឱ្យកាព្យមានចួនខុសមាត្រា ។
ដូចជាប្អូនអើយ (២) ម្តេចឡើយថា
ធ្វើជាមិនឮព្រោះរឹងខ្លួន ។
ទ្រង់បានបញ្ជាក់ដោយផ្ទួនៗ
សំនួនសម្ព័ស្សឥតមានឆ្គង ។
ពុំគួរប្រញាប់កាត់រំលង
ខុសពីបំណងអ្នកប្រាជ្ញចាស់ ។
ម្តេចមិនវាចាឱ្យជាក់ច្បាស់
គួរផ្លាស់សំដីនេះចោលចេញ ។

ខ.ណ.

* * *

---

១. អានថា អ្ហើយ កុំថាអើយ ឬអឺយ
២. អានថាប្អូនអ្ហើយ ឬប្អូនណើយ កុំថាប្អូនអឺយ

# ច្បាប់ កេរកាលថ្មី [(១)]

នេះបទព្រហ្មប្រាជ្ញប្រាយ ខ្ញុំអធិប្បាយលើកល្បត់ល្បង
ប្រដៅកូនចៅផង ចងជាច្បាប់ខុសនិងត្រូវ ។
កត្តិកខ្មែតគ្មេរគ្មាន់ ក្នុងវស្សន្តរដូវ
ទឹកស្រែជន់លិចស្រូវ នៅសំណល់សំណាបខ្ចី ។
កិរកាលពីព្រេងព្រឹទ្ធ ដើមគំនិតពីសេដ្ឋី
ខ្ញុំលើកកិរកាលថ្មី ចែងសេចក្ដីជាបរមត្ថ ។
ក្នុងថ្ងៃពេញបូណ៌មី ម៉ោង៨ព្រលប់ស្ងាត់
ឆ្នាំចចត្វាក្សត្រ ផាត់សកវាជកន្លងឆ្ងាយ ។
៥ . សាសនាព្រះសមណៈ បានពីរពាន់បូនរយប្លាយ
ហុកសិបកំបាយ ចាត់អធិប្បាយពីខុសត្រូវ ។
កិរកាលដំណាលទុក ជាទំនុកដំណែលនៅ
ដំណាតវៀងទៅ តម្រូវចិត្តជនប្រុសស្រី ។
កូនអើយពាក្យអាពុក ជាទំនុកទំនើបថ្មី
អនិស្រោយរាយបាលី អាពុកស្ដីឱ្យកូនស្ដាប់ ។
គួរស្ដាយកេរ្តិ៍ម៉ែឪ កិរិយាត្រូវឱ្យខំត្រាប់
កិរិយាណាខុសច្បាប់ គួរក្រឡាប់ក្រឡាស់ចោល ។
ម្ដាយអាពុកនឹងកូន បីដូចខ្លួននិងស្រមោល
ឃើញខុសកុំដេញដោល កុំថ្កោលទោសអ្នកមានគុណ ។
១០. ល្វង់ខ្លៅត្រូវតែសួរ ពាក្យឱ្យគួរកុំឱ្យស៊ុន

(១) បុរាណសរសេរ កិរកាល

យកពាក្យផ្អែមជាមុន ទន់លំទោនឱនប្រតិបត្តិ ។
ទោះម៉ែឪស្លូតកាច គួរតែខ្លាចដូចមហាក្សត្រ
ម្តាយជេរពីរបីម៉ាត់ គួរតែស្ងាត់ស្ងៀមឱ្យឈឹង ។
ប្រដៅត្រូវតែស្តាប់ យកតម្រាប់កុំទទឹង
ម្នោម្នះចចេសរឹង នឹងហើយហៅកូនសេសកម្ម ។
ធមិអាថិចេះតែភ្លេច ជេរប្រទេចចេះតែចាំ
អាពុកពត់ទៅស្តាំ អកុសលកម្មទាញទៅឆ្វេង ។
អវជាតបុត្រ ខូចបំផុតតាំងពីក្មេង
ប្រព្រឹត្តព្រើលផ្សេងៗ បើលេងអ្វីស្តីមិនស្តាប់ ។
១៥. មិនស្តាយជាតិកំណើត ល្ងង់ស្លូតស្ងើតដល់ចាស់ស្លាប់
ត្រឹមត្រូវមិនសូវស្តាប់ ព្រួយគេប្រាប់ទាំងយប់ថ្ងៃ ។
ម៉ែឪមានគុណណាស់ មិនសំពះខ្មាស់អៀនដៃ
បើអ្នកក្រៅដទៃ វិស័យសោះសំពះបាន ។
ឆ្លើយបាទចាះចាំខ្ញុំ រាបរមទម្បនឹងសន្តាន
ម៉ែឪឯងក្នុងឋាន ប៉ានឆ្លើយអឺរញូអឺរើ ។
អនុជាតបុត្រ ស្លូតបំផុតស្រណុកប្រើ
ប្រកបការប្រសើរ ដើរតែតាមលំអានឪ ។
ប្រដៅទទួលយក ចេះលៃលកស្តាប់ខុសត្រូវ
ស្រណុកញាក់ផ្លាក់ផ្លូវ មិនសូវភ្លេចដិប្បន្នាន ។
២០. អតិជាតបុត្រ ល្អបរិសុទ្ធស្គាល់សីលទាន
នាំឪទៅនិព្វាន ឈានទៅរកកន្លែងសុខ ។
ចេះលើសគេដរាប ជឿបុណ្យបាបប្រែតនរក

មិនល្មោភនឹងម្ហូបលាមក ភ័យនឹងភក់ភពសង្សារ ។
នេះគឺដើមបាលី បុត្រទាំងពីរបីបែបកិរិយា
ស្រឡាញ់ណាស្អប់ណា តាមសញ្ញាចូលចិត្តចុះ ។
អវធ្លាក់ផ្លូវក្រោម ប្រព្រឹត្តព្រមតែខាងខុស
អតិជាតមារយាទខ្ពស់ អនុនោះយ៉ាងកណ្ដាល ។
អតិ១០០មានមួយ គួរតែស្ទួយដាក់លើក្បាល
អវគឺស្រើបស្រាល ត្រូវអាលយកតែពីរយ៉ាង ។
២៩. អតិជាតិកំណើត គំនិតកើតពីកសាង
កុសលតម្កល់ខាង សំណាងកើតពីគំនិត ។
អនុអានាងអើយ ខ្លួនធំហើយឱ្យចេះគិត
ចេះកាញ់ស្គាល់ឆ្ងាយជិត ប្រព្រឹត្តយកតែខាងត្រូវ ។
រៀនរិះរកទ្រព្យធន យកប្រពន្ធមើលធុនឪ
ធុនចោកជ្រកខុសត្រូវ អ្នកកុំទៅខ្លាចបន្លា ។
ផ្លូវវៀចកុំបោះបង់ ផ្លូវព្រៃត្រង់កុំយាត្រា
ឈានឈរពិចារណា ឆ្ការឱ្យស្អាតសឹមដើរទៅ ។
កុំដើរភ្លើភ្លេចខ្លួន ខ្លាចក្រែងជួនធ្លាក់ជ្រោះជ្រៅ
ជ្រកម្លប់សំណាក់នៅ កុំបោះពៅផ្ទប់គល់ឈើ ។
៣០. ឆេះខ្លោចសំបកក្រោម ស្រពោនព្រួមស្លោកស្លឹកលើ
មានភ្នែកឱ្យចេះមើល កុំល្ងីល្ងើល្ងង់ល្ងិតពេក ។
រៀនដើរឱ្យមើលផ្លូវ ធ្វើស្រែស្រូវឱ្យមើលមេឃ
ម្លប់ធ្លកធ្លាប់ជ្រកដេក ជាដំណេកអ្នកដំណើរ ។
ដំណែលដែលគេដាក់ ជាដំណាក់ទំនួលផ្ញើ

ចំណាំចាំគ្រាន់បើ ដើរក្រោយៗគ្រាន់ជ្រកទៀត ។
ឈើណាទោសសត្រូវ ជុះជិតផ្លូវនាំចង្អៀត
ជិតបប់យប់អគ្រោត្រ ឆ្អៀតកាប់ចេញកុំទុកវា ។
បន្លាគល់ដង្គត់ កន្លែង (១) ផុតតែភ្នែកជា
ដើរយប់ជិតប់ពារ ក្រែងគ្រោះគ្នាអ្នកដើរក្រោយ ។

៣៩. គ្នាមុតកុំចាំផ្ទាន់ ឃើញគួរជាន់កុំបណ្តោយ
បណ្តើរមើលខ្លាំងខ្សោយ ឱ្យពិនិត្យពិចារណា ។
ពាក្យពិតត្រង់ប្រាកដ ត្រូវច្រើនបទច្រើនប្រការ
ប្រកបជាប្រស្នា ប្រាជ្ញាអាប់ស្លាប់នឹងឆ្ងល់ ។
ផ្លូវពិតទាំងជិតឆ្ងាយ សព្វសុសសាយមិនសេសសល់
អ្នកណាប្រាជ្ញាដល់ ដឹងយោបល់ច្រើនកន្លែង ។
កូនអើយការកេរ្តិ៍ឈ្មោះ កុំចង់រស់តែម្នាក់ឯង
គិតអ្វីគិតឱ្យវែង ក្រែងក្រក្រោយស័យគំនិត ។
កំណើតរាល់រូបកាយ ចេញជួញឆ្ងាយស្តាយជួញជិត
ចិញ្ចឹមជន្មជីវិត គិតឱ្យស្រេចទើបបានស្រួល ។

៤០. ធ្វើស្រែចង់បានស្រូវ ដើមរដូវធ្វើស្រែទួល
ស្រែទាបមើលទំនួល លើកទំនប់ឱ្យមាំមួន ។
កូនអើយកេរ្តិ៍មេបា ចាំរក្សាមើលថែថ្នួន
ធុញថប់ថយថោកខ្លួន ជួនជាខ្សត់គេថាខ្សោយ ។
ស្រូវខ្សោយអង្ករថ្លៃ លក់សំចៃទុកឆ្នាំក្រោយ
អ្នកក្ររកញយៗ ឱ្យអ្នកសុំជាងអ្នកខ្ចី ។

---

(១) កន្លង

សប្បុរសពេកថយធន          មុទ្ទជនថយរាសី
ប្រពន្ធល្អច្រើនអាប់ប្តី          ពាក្យអប្រិយចាញ់អាត្មា ។
ឈើផ្លែចាញ់សន្លឹក          ត្រីវរវីកទឹកមិនថ្លា
កំណាញ់ក្រៅតម្រា          សោតសឹងអាប់ប្រយោជន៍យស ។
នឹងឱ្យៗ មើលភាព          ឱ្យអ្នកទាបជាងអ្នកខ្ពស់
៤៩. អ្នកទិញឈប់សិនចុះ          ក្នុងតែរស់មិនស្លាប់ងាយ ។
កំណាញ់ហួសកំណត់          ពាក្យអ្នកខ្សត់ខ្សបនិយាយ
ទេវតាផ្គន្ទាទាយ          រលាយអស់រលស់ឯង ។
សទ្ធាមើលធនធាន          ជាតិអ្នកមានមិនអង្វេង
កំណាញ់ដោយកន្លែង          ក្រែងគ្រោះក្រដល់ឆ្នាំក្រោយ ។
អ្នកក្រខ្ចីនេះកុំ          អ្នកមានសុំនេះគួរឱ្យ
អ្នកប្រាជ្ញអង្គាសញយ          អស់ក៏ដោយឱ្យទៅចុះ ។
អ្នកក្របានជាបាម          ពិបាកតាមទៅឯណោះ
ទាល់ទឹកចូលច្រមុះ          ច្រើនកើតឈ្លោះពីព្រោះយល់ ។
៥០. អ្នកមានគេមានខ្មាស          សងរហ័សមិនអំពល់
ជួនយើងមានរវល់          គេស្គាល់មុខស្រណុកខ្ចី ។
អ្នកក្រៗ ទាំងចិត្ត          ស្រូវឆ្ការល្អិតឱ្យមើលល្អី
វាល់ល្អកន្តាំងបី          ទាន់ស្រូវថ្មីទារឆាប់បាន ។
ជួនក្រែងឯងក្រវិញ          ទោះដូរទិញមើលប្រមាណ
ជៀបុលខ្ចីសន្តាន          កុំប៉ានពារកញ្ជើធំ ។
ខ្លួនក្រកុំចង់ផាត់          កុំងាយមាត់អាងតែសុំ
ជៀខ្ចីល្អក្រមុំ          ស្រូវឯងទុំស្រណុកសង ។

បើជឿខ្ញីគេឱ្យ កុំទៅញយគេឱ្យខ្មង
ឯណេះឯណោះផង កុំច្រើនដងគេមើលងាយ ។

៥៩. ក្រលុយកុំងុយដេក ចូលដំណេកកុំនិយាយ
សំពត់ញាត់សំពាយ រាយរើសរៀបញាត់សំពៀត ។
រៀបដេកសំពះគុណ កុំដេកស៊ុនឱ្យប្រុងស្មៀត
ភ្លើងឆេះយប់អធ្រាត្រ កណ្ដៀតទូលប្រមូលរត់ ។
ខ្លួនរាស្ត្រក្រមាសប្រាក់ ភើចកន្ត្រាក់អាវសំពត់
ទំរាំភ្លើងរលត់ ស្លៀកផ្លង់ផ្គត់សោះខ្មាសគេ ។
កូនអើយគិតឱ្យគ្រប់ រៀងរាល់យប់កុំទំនេរ
ជាងដេកលក់ទទេ យល់សព្ទ (១) ដេរបីសាចក្រៅ ។
ទំលាប់មាត់មមើ ស្រែកថាយើៗ អៅៗ
ចោរខ្លាំងខ្មោចចិត្តខ្មៅ ហៅមេខ្មៃវៃឱ្យខ្ទក ។

៦០. ដេកផ្ទៀងជាងអង្គុយ ល្ងាល្ងាន់ល្ងុយកុំទ្រាំងក់
ពីល្ងាចដេកកុំលក់ មាន់រងាវជក់ស៊ីម្លូស្លា ។
ជាងល្ងីតឥតអំពើ ឥតអ្វីធ្វើស្ងួត្រធមិអាថិ
បើច្បាសវិបស្សនា ស្មាស្មាធិ៍ស្មឹងប្រឹងឱ្យស្មោះ ។
គងខ្មើយដេកកើយស្មុគ្រ គ្របឱ្យសុខស្ងួត្រអម្បោះ
កុំដាក់ដោយគៀនកោះ អស់នឹងសត្វកណ្ដៀរកោរ ។
កណ្ដុរកន្លាតកាត់ ដល់កំណាត់ខានដេរខោ
ជួនកាលមានអាចោរ លលបល្ងួចលីទៅបាត់ ។
កុំដាក់ឆ្ងាយប្រយោល ទុកជាចោលមិនប្រយ័ត្ន

(១) យល់សប្តិ ?

ប្រយោជន៍យប់យាមស្ងាត់ បង្កាត់ភ្លើងបង្គោលគោ ។
៦៩. បង្ការព្រៃងម្ហូសខាំ ត្រូវចំណាំខ្យល់ជំនោរ
បាយកកផ្អកម្ហូបជោរ ឱ្យអាលោស៊ីចាំសេះ ។
កំណើតឆ្កែញីឈ្មោល ដេកចំណោលតែនឹងផេះ
រៀនប្រើមើលចំណេះ រិះចំណាំតាមកិរិយា ។
ទោះប្រើកូនតូចធំ ឬប្រើខ្ញុំឱ្យធ្វើការ
ធ្វើកលយល់ប្រាជ្ញា អាណាប៉ានប្រើទៅឆ្ងាយ ។
អាខ្លាចប្រើតែជិត ឥតគំនិតប្រើរៀងអាយ
ខុសម្តងពុំជេរម្តាយ ពេលដស់បាយកុំនាំឈ្លោះ ។
មនុស្សឃ្លានវាប៉ានឆ្លើយ ស៊ីរួចហើយបន្ទោសចុះ
បានឆ្អែតប៉េងពេញពោះ ស្តីខុសត្រូវមិនស្ងួវខឹង ។
៧០. កូនអើយពាក្យអាពុក ចំណាំទុកពីត្រឹមណឹង
ធ្វើប្រុសឱ្យខំប្រឹង រៀនឱ្យដឹងស្គាល់ពុតស្រី ។
មារយាទនិងមាយា ម្យ៉ាងចិត្តជាចេះថ្មមប្តី
ប្តូរស្លាប់រស់វាហី យកពីរបីនេះមិនបាន ។
កុំលោភច្រើនៗ ព្រួយ យកតែមួយសុខក្សេមក្សាន្ត
ចិត្តស្រីទាំងប៉ុន្មាន ប៉ានប្រមូលម៉ៅមិនខុស ។
មិនខ្វចគ្រប់តែស្រី ល្អពីរបីជឿចាំចុះ
ជាតិស្រីលោភលើប្រុស នោះមិនខុសស្រីណាមួយ ។
ខ្លាំងខ្សោយកុំឱ្យខ្សត់ ទោះនឿយហត់កុំលំអួយ
ធ្វើប្រុសតែងតែព្រួយ ស្រីមិនជួយកុំត្អូញត្អែរ ។
ខ្លួនខ្លាំងកុំគិតខ្លាច ស្រីៗ កាចស្លូតដោយខែ

៧៥. រដូវធ្វើស្រូវស្រែ ចៃប៉ចៃប្រស្ពីលើប្រុស ។
ខែស្ទូងនិងខែច្រូត កាចរហូតដល់ខែបុស្ស
ខែបែនបោករលស់ រលីងអស់អំពីដី ។
ជញ្ជូនដាក់ជង្រុក ពូជពេញទុកស្បៀងពីរបី
ដំណើបប្អូនដប់ល្អី ស្រី១ ស្លូតហើយខែនឹង ។
ស្លូតផុតនៅខែមាឃ ស្ដីធ្ងន់ពាក្យមិនសូវខឹង
បើប្រុស១ មិនដឹង ប្រឹងតែព្រួតស្អប់ស្រី១ ។
ម្យ៉ាងទៀតមារយាខូច មារយាបេះក្រូចមារយាដកខ្ញី
មានប្រុសសាហាយថ្មី រីតថ្នមប្ដីមិនឱ្យអាក់ ។
អីអើតែមាត់ក្រៅ ចិត្តមួម៉ៅគ្មានត្រជាក់
៨០. ត្រីសាច់ល្អល្អចលាក់ ដាក់តែឆ្អឹងឱ្យឯងស៊ី ។
បញ្ចោរចេះបញ្ចើ បញ្ឆោតប្រើឯងរកវី
វវីកព្រួតប្រុសពីរ ស៊ីទាល់ងាប់គាប់សងខាង ។
មួយទៀតផិតកំឡោះ ស្រឡាញ់ស្មោះស្ម័គ្រអស់យ៉ាង
លោមប្ដីលាសំណាង ទាស់ក្អែងក្អាងទារសំបុត្រ ។
បើប្ដីមិនព្រមលែង លបជំទែងជំទយរត់
មួយទៀតខូចបំផុត មត់ឱ្យប្រុសសម្លាប់ប្ដី ។
ម្យ៉ាងទៀតមារយាទជា មានច្រើនគ្នាក្នុងលោកិយ
ប្រាកដពេញជាស្រី ប្រុសពីរបីស្នាលាកម្ម ។
៨៥. ស្លាប់រស់មួយនឹងមួយ មិនចង់ព្រួយយកប្រុសប្រាំ
ប្ដីស្លាប់បួនដប់ឆ្នាំ ចាំសីលទានមិនមានទៀត ។
ធ្វើបុណ្យផ្សងសច្ចា សុំប្រាថ្នាជួបរាល់ជាតិ

អុចធូបដេកឱបផាតុ កណ្តៀតថោកោរកាន់ទុក្ខ ។
និយាយពីពុតប្រុស ចូរចាំចុះជាទំនុក
ដំណាតទៅមុខ អាពុកប្រាប់ឱ្យស្រីចាំ ។
ប្រពន្ធមួយមិនស្កប់ ប្រពន្ធដប់គ្រាន់តែស្កាំ
កាចស្លូតរហូតឆ្នាំ រាំងរាបរាល់រូបា ។
កាចម្យ៉ាងខាងល្ងាចព្រឹក រឿងបាយទឹកថ្នាំម្លូស្លា
កាចម្យ៉ាងរឿងធ្វើការ ម្យ៉ាងទៀតណារឿងប្រចណ្ឌ ។
៩០. ប្រជុំជាតិចិត្តប្រុស ត្រូវនឹងខុសជាកំណាន់
គំនិតល្អសំខាន់ ប្រកាន់មើលឥរិយាបថ ។
ប្រចណ្ឌរាវរាល់ឈ្មោះ ច្រើនកើតឈ្លោះទៅជាខ្សត់
មួយឃើញជាក់ប្រាកដ ប្រកៀកចាប់ធ្វើទោសបាន ។
លក់លែងតែខាងប្រុស ប្រពន្ធខុសបង្អង់ខាន
ខូចម្តងខាតប៉ុន្មាន រាប់អានឱបក្រសោបទៀត ។
មួយលក់លែងទាំងពីរ នៅរកស៊ីដោយសារញាតិ
ស្រីមាយាឥតមារយាទ ស្មាលាជាតិមិនឱ្យជួន ។
ប្រចណ្ឌទាំងបីបទ គួរតួចកត់ទុកក្នុងខ្លួន
លក់ពីរពេញចំនួន គួនគុំទុកយកជាច្បាប់ ។
៩៥. ប្រចណ្ឌហើយយកទៀត ហៅជួជាតិមាយាទអាប់
កូនណាយកតម្រាប់ ស្លាប់នឹងស្រី១ មើលងាយ ។
ទោសតិចកុំទាញផ្សំ ឃើញមិនធំកុំនិយាយ
កុំចាប់ស្ទើររើរវាយ នាំឱ្យរលំអំពល់ចិត្ត ។
ពុតប្រុសនឹងពុតស្រី ចប់សេចក្តីពីក្បត់ផិត

រៀងរើសណាសុខចិត្ត　　គិតសំគាល់រាល់រូបកាយ ។
បើមានកូនក្រមុំ　　គួរតែកុំបណ្តោយឆ្ងាយ
ឱ្យមើលនាយមើលអាយ　　ស្រេចនៅម្តាយរក្សាកូន ។
ប្រយ័ត្នកុំឱ្យឃ្លាត　　ភ្លាត់មារយាទមិនសុទ្ធសូន្យ
កុំទុកចិត្តបងប្អូន　　ជីដូនមួយជួយរក្សា ។
១០០-ក្រមុំមានម្រាក់មិត្រ　　មេមួយគិតនាំកិច្ចការ
កុំជឿចិត្តនរណា　　មើលកិរិយានៃកូនឯង ។
ទោះស្ទូងដកយប់ថ្ងៃ　　ដើរយកដៃដាច់សង្វែង
ប្រុសខូចលួចបន្លែង　　តែទាល់ភ្នែកបែកមេបា ។
ច្រើនណាស់តែសែនខ្មោច　　កេរ្តិ៍អាសោចិ៍ផុតអាសា
នាំកូនឡើងសាលា　　គេថាឱ្យជម្ងឺចិត្ត ។
បើមានកូនប្រុសា　　មិនទាន់ការគួរឱ្យប្រិត
កុំឱ្យបំរើឆ្អិត　　អាណិតវា១ សងគុណ ។
យប់ថ្ងៃចូលប្រតិបត្តិ　　គាតក្រវាត់រត់រែកពុន
អាចនឹងច្រើនជឿមុន　　ស៊ុនអំពីឪពុកម្តាយ ។
១០៥-រក្សាកូនប្រពន្ធ　　រកទ្រព្យធនចង់ធូរចាយ
ជួញជិតគំនិតឆ្ងាយ　　ជួញវៀងអាយរក្សាគុណ ។
អំពើបាបកុំរៀន　　កុំអៀនប្រៀនក្នុងការបុណ្យ
លាងទោសចេញជាមុន　　ទើបធ្វើបុណ្យចំរើនផល ។
បើនឹងចង់គង់ទ្រព្យ　　កុំទំលាប់សាងអកុសល
របិញរបុញវៀចកាចកល់　　ទេវតាផ្តល់ផ្តាច់ធនធាន ។
កុំឈ្នានីសអ្នកខ្សត់　　កុំបំភ្លាត់ទ្រព្យអ្នកមាន

| | |
|---|---|
| បើខ្លួនខ្សត់អត់ឃ្លាន | រៀនតែរកតាមទៀងត្រង់ ។ |
| ជួញខាតកុំឈប់ខាន | បើចង់បានកុំខ្លាចបង់ |
| ខ្លាចបាត់ឱ្យផ្ចិតផ្ចង់ | ប្រុងថែទាំឱ្យមាំមួន ។ |
| ១១០.កុំភ្លើធ្វើជាភ្លេច | ភ្លាត់បន្តិចខ្លាចក្រែងជួន |
| ក្រែងចោរចូលមកពួន | លួនលបលួចយកទ្រព្យទៅ ។ |
| ប្របៃហេសតែងតែបាត់ | ប្រុងប្រយ័ត្នតែងតែនៅ |
| គិតសព្វគ្រប់ដោយផ្លូវ | សូវទ្រាំនឿយកុំទ្រាំក្រ ។ |
| នៅផ្ទះស្រះរបង | របាចងឱ្យជាប់ល្អ |
| ប្រើប្រាស់ខ្ញុំកំដរ | ឱ្យបរិភោគដោយខ្លួនឯង ។ |
| នឹងប្រើទៅហៅមក | កុំគំហកយកកំហែង |
| កុំហាឡើងហាងឯង | ក្រែងកំហាលទល់កំហឹង ។ |
| កុំហួសពាក្យសម្តី | ការអ្វីៗ ឱ្យចេះថ្លឹង |
| កុំប្រើព្រួតលើប្រឹង | ក្រែងកើតខឹងវានាំខាត ។ |
| ១១៥.មនុស្សខឹងច្រើនៗខុស | មនុស្សច្រើនឈ្លោះច្រើនប្រមាថ |
| ការល្អច្រើនត្រូវខ្នាត | យើងចង់ស្អាតកុំខ្លាចយូរ ។ |
| ចង់ប្រាជ្ញឱ្យខំប្រឹង | ចងក្បិនតឹងរកស៊ីធូរ |
| គំនិតមុនគំនូរ | រៀនមានគ្រូមានគេរាប់ ។ |
| បំរើឪពុកម្តាយ | អ្នកនៅឆ្ងាយគេច្រើនគាប់ |
| អ្នកណាបំរើខ្ជាប់ | ធ្លាប់តែខុសមិនដែលត្រូវ ។ |
| ជាតិមនុស្សទោះខ្ពស់ទាប | មិនចោលភាពពីម៉ែឪ |
| ពាក្យមនុស្សវែងជាងផ្លូវ | ស្រូវច្រើនខូបខូចអង្ករ ។ |
| របស់ទ្រព្យថោកថ្លៃ | ទុកសំចៃលៃឱ្យល្អ |

អុងអាងពាងក្រឡ ត្រដរទិញកុំឱ្យខ្វះ ។
១២០.កើតមកខ្លួនជារាស្ត្រ ក្រប្រាក់មាសឱ្យមានខ្នាស
សារពើគ្រឿងប្រើប្រាស់ ឱ្យមានចាស់ឱ្យមានថ្មី ។
ពូថៅដឹងកាំបិត ពន្លាកខ្វិតចបវែងខ្លី
ខ្សែសេះគោក្របី ឬស្បៀផ្តៅកាច់សង្រែក ។
ការងាយកុំឱ្យក្រ អាក្រក់ល្អមានដោយឡែក
ថ្ងៃនេះរបេះបាក់បែក ស្អែកខំរើធ្វើជាឆាប់ ។
ឈ្មោះការប្រើលើដី កុំចាំស្រីតៀនប្រើប្រាប់
ឱ្យមានគ្រប់ប្រដាប់ សំរាប់រាល់ឱ្យសល់ប្រើ ។
កុំខ្ជិលល្ងង់ខ្លៅពេក ឱ្យចេះដេកឱ្យចេះដើរ
ចេះសព្វគាប់ប្រសើរ កុំចង់ហើរហួសភាពខ្លួន ។
ចង់ក្តីឱ្យរៀនច្បាប់ រស់នឹងស្លាប់ឱ្យចេះក្បួន
១២៥.ចេះអ្វីចេះឱ្យមួន កុំបន្លំផ្សំនឹងគេ ។
កុំដេកចាំសំណាង កុំក្អេងក្អាងចាំបុព្វេ
ខំរកកុំទំនេរ រៀនរិះចេះឱ្យគ្រប់ ។
នឹងដើរស្វែងរកផល មិនទាន់ដល់កុំអាលឈប់
ឈានខ្លាំងពេកជំពប់ បើដេកយប់ឱ្យស្គាល់យាម ។
កុំដេកយូរទ្រមឹក លក់ហួសព្រឹកខុសទំនៀម
តែភ្លឺឡើងភ្ញាក់ភ្លាម ព្រហាមឡើងក្រោកធ្វើការ ។
ជាតិមនុស្សទោះប្រុសស្រី រាស្ត្រមន្ត្រីជាធម្មតា
ពេលព្រឹកតែងឧស្សាហ៍ ថ្ងៃក្តៅល្ហោខ្ជិលល្អិតផ្អឹង ។
១៣០.ចង់ធំខំពីតូច បើខ្លាចខូចកុំឆាប់ខឹង

ការអ្វីឱ្យចេះថ្លឹង កុំប្រឹងជុះតាមដីរ ។
កុំចង់ខ្ពស់ស្មើមេឃ កុំឱនពេកអាប់រាសី
ទោះដើរនិយាយស្តី លៃឱ្យល្មមតែគួរសម ។
យល់ឆ្ងាយកុំណាយគិត ទោះយល់ជិតកុំអាលខំ
មិនជាក់មើលឱ្យចំ ក្រែងច្រឡំសជាខ្មៅ ។
ទម្លាប់ធំជាងច្បាប់ បើរៀនត្រាប់កុំត្រាប់ខ្លៅ
ត្រាប់ប្រាជ្ញអាចប្រដៅ ស្តីកូនចៅស្តីឱ្យស្មោះ ។
ស្អឹងស្អីលសិល្ប៍របៀន ឱ្យគេរៀនកុំឱ្យអស់
ស្រឡាញ់កុំញ៉េះញ៉ោះ បើខឹងទាស់កុំឱ្យទាយ ។
១៣៩-ភ្នែកព្រះកុំព្រួយពេក ឃើញភ្នែកដេកកុំមើលងាយ
កំណាប់ដប់សំពាយ កុំនិយាយប្រាប់សំឡាញ់ ។
សំឡឹងមើលឱ្យសព្វ បើនឹងស្អប់កុំអាលបាញ់
ក្តីឈ្នះគេចុះចាញ់ កុំក្នាញ់តាមផ្តន្ទាទៀត ។
បើខឹងកុំរំលោភ បើនឹងល្មោភឱ្យល្មមមាឌ
កុំរមាត់ក្រែងភ្លាត់ស្មៀត វាតហួសវង់ផុតគំនិត ។
កំណើតអាក្រក់ល្អ មាននឹងក្រពីគំនិត
ពីកាលបុព្វពិត ងងឹតពេកមើលមិនយល់ ។
ដាំដូងឱ្យខំថែ ចង់ស៊ីផ្លែឱ្យដុតគល់
បើជួនសំណាងដល់ រវល់តែស៊ីឆ្អាញ់ពិសា ។
១៤០-ប្រាជ្ញប្រិតប្រៀនប្រដៅ ចូរកូនចៅពិចារណា
រំពឹងក្នុងប្រាជ្ញា ស្រាយបញ្ហានេះឱ្យដឹង ។
នេះច្បាប់កេរកាលថ្មី អស់សេចក្តីតែប៉ុណ្ណឹង

កូនប្រុសអ្នកខំប្រឹង សំឡឹងចាំតទៅមុខ ។
ពីឆ្នាំច តទៅ ខំធ្វើស្រូវដាក់ជង្រុក
អាស្រូវពាក្យអាពុក ទុកឱ្យកូនចៅគ្រប់គ្នា ។
អាពុកកាន់តែចាស់ ស្គាយខ្លួនណាស់ចូលជរា
ពាក្យពិតប្រាំរយឃ្លា ជាស្ទូវេចម្ល៉េះឯងហោង ។
អ្នកប្រាជ្ញភិរម្យល្បី លើកច្បាប់ថ្មីអស់ល្បត់ល្បង
ឈ្មោះ **អ៊ូ** ហៅ **ខ៊ុយ** ផង ចងជាច្បាប់សំរាប់ជន ។
១៩៥-ខ្ញុំសូមផ្សងសច្ចា កើតជាតិណាសូមមានបុណ្យ
មូលកូនមូលប្រពន្ធ ធនសម្បត្តិសម្បូរចាយ ។
ស្មាលាក្រលំបាក សូមជៀសចាកចតុរាយបាយ
សូមល្អពង្សរូបកាយ កុំឱ្យឆ្ងាយពីព្រះពុទ្ធ ។
ប្រាជ្ញាកុំទើសទាល់ ចេះអាថិធមិឱ្យមាំមុត
សូមជាប់សីលបរិសុទ្ធ រលត់ទុក្ខសោករោគភ័យ ។
អានិសង្សបុណ្យខ្ញុំបាន សាងប៉ុន្មានក្នុងលោកិយ
សម្បត្តិសួគ៌ាល័យ កុំបីឃ្លាតរវាតវែងឆ្ងាយ ។
១៩៦-ពីជាតិនេះទៅមុខ មូលអាពុកជួបមូលម្ដាយ
បងប្អូនកុំខ្ចាត់ខ្ចាយ អធិប្បាយថៃងចប់ឯវិ ។

អ្នកព្រះភិរម្យភាសា **អ៊ូ** ហៅ **ខ៊ុយ**

# លក្ខណៈពិសេស នៃជនជាតិខ្មែរ

( ក )

ការភៀសខ្លួននៃអំបូរខ្មែរសម័យនោះដែលបែកមកខាងត្បូង គង់នៅសភាពមិនចំរើននៅឡើយ ប៉ុន្តែ បើយើងសិក្សាអំពីវប្បធម៌ « បានឆៀង » ដែលនៅត្រង់អាណាចក្រគោត្របូរពីដើម ក៏ឃើញថាយុគលោហៈនៃអាស៊ីភាគកណ្ដាលត្រង់នេះ បានឡើងកាន់ឋានៈជាអារ្យជនមុនភាគឯទៀតនៃអាស៊ីអាគ្នេយ៍ ព្រោះគេបានជីករកឃើញវប្បធម៌ដ៏ផុត និងដីប៉ាន់លាបពណ៌មានអាយុ ៧០៦៩ - ៦០៧៩ មកហើយ ឃើញថានៅមុំត្រង់នេះអាចមានអំបូរមន-ខ្មែរ មកនៅយូរយារណាស់គឺអាចបានមកពីទិសខាងជើងភ្នំហិមាល័យ មុនជំនាន់ជាតិអរិយកៈមកដេញអំបូរខ្មែរមន អោយចេញពីអាណាបរិវេណទន្លេសិន្ធុ ។

ការភៀសខ្លួនរត់ទៅកាន់អាស៊ីប៉ែកអាគ្នេយ៍ មានបន្តមកច្រើនគ្រានៅសម័យដែលប្រទេសឥណ្ឌាមានប្រវត្តិសាស្ត្រពិតប្រាកដហើយ ។ ការរត់ភៀសខ្លួននៅសម័យនេះ បើពិចារណាតាមលក្ខឋានផ្នែកពុទ្ធសាសនា មានគម្ពីរមហាវង្ស និងមិលិន្ទបញ្ហាជាដើមនេះមួយ, មួយទៀត បើពិចារណាតាមភស្តុតាងជាឯកសាររបស់រាជទូតចិន អ្នកជំនួញជាតិក្រិក និងអារ៉ាប់ ក៏គួរអោយឃើញថា ការភៀសខ្លួននៅសម័យប្រវត្តិសាស្ត្រនេះ មានមូលហេតុ ៣ ប្រការគឺ :

១- មកពីការរកស៊ីចិញ្ចឹមជីវិត,

២- មកពីសង្គ្រាម,

៣- មកពីរឿងសាសនា ។

តទៅនេះ ខ្ញុំសូមទាញរឿងរ៉ាវដែលមាននៅក្នុងប្រវត្តិសាស្ត្រឥណ្ឌាខ្លះមកពិចារណា ដូចតទៅ :

តាមភស្តុតាងដែលបានស្រាវជ្រាវក្នុងគម្ពីរព្រះវេទ គេបានអោយដឹងថា ជនជាតិអរិយកៈ បានផ្សាយឥទ្ធិពលលើផែនដីតាមដងទន្លេសិន្ធុ តាមដងទន្លេគង្គា ហើយបានតាំងអាណាចក្រយ៉ាងសំខាន់ៗច្រើនកន្លែង ដែលសំខាន់ជាងគេគឺ អាណាចក្រមគធរដ្ឋ ។ អាណាចក្រនេះ ជាមជ្ឈមណ្ឌលសំខាន់នៃឥទ្ធិពលជនជាតិអរិយកៈ មានអំណាចផ្សាយទាំងផ្លូវពុទ្ធចក្រ និងអាណាចក្រក្នុងសម័យពុទ្ធកាល ។

តមក សម័យដើមពុទ្ធកាល ប្រទេសអៀរ៉ង់ ( Iran ) ក្នុងសម័យរាជវង្សអាចាមេនីដ (Achaemenid) ក៏បានផ្សាយចូលគ្រប់គ្រងឥណ្ឌាប៉ែកខាងទន្លេសិន្ធុដែរ ជាហេតុនាំអោយមានអ្នកភៀសខ្លួនរត់គេចចេញពីកន្លែងនេះទៅទៀត ។

ក្នុងរយៈសតវត្សទី ៦ មុនគ្រិស្តសករាជ អាណាចក្រគន្ធារៈ ( Gandhāra ) ដែលនៅប៉ែកលើទន្លេសិន្ធុ មានស្រុកឈ្មោះថាប៉េសវារ (Peshawar) និងរ៉ាវ៉ាល់ពិនឌី ( Rawalpindi ) បានអោយរាជទូតនាំសារចូលមកថ្វាយព្រះចៅពិម្ពិសារនៃមគធរដ្ឋ - ក្នុងសំបុត្រនោះមិនប្រាកដថាជាអ្វី ប៉ុន្តែដែលដឹងទូទៅគឺដែនគន្ធាររដ្ឋ បានត្រូវស្តេចវង្សអាចាមេនាន ( Achaemenian ) មកវាយ ។ អាណាចក្របរិវេណឆ្នេរទន្លេសិន្ធុ បានធ្លាក់ទៅក្នុងកណ្តាប់ដៃអៀរ៉ង់ ( Iran ) តាំងពីពី ៥២២ - ៤៨៦ ឆ្នាំ មុនគ.ស ម្ល៉េះ ។

តមក ៣២៧ ឆ្នាំមុនគ.ស ព្រះចៅអាឡិចក្សាន់ដារ ( Alexander ) មហារាជនៃម៉ាសេដូនា ( Macedonia ) បានចូលមកពីហិណ្ឌូគូជ ហើយបានវាយយកអាណាខេត្តតាមដងទន្លេសិន្ធុ ដែលពួកអៀរ៉ង់គ្រប់គ្រងនោះទៅវិញហើយ បានលើកទ័ពឆ្លងទន្លេសិន្ធុឆ្ពោះទៅកាន់ដងទន្លេគង្គា តែពួកសេនាទាហានបានឃាត់ ទើបត្រឡប់ទៅវិញ ។ ពេលនោះ អំបូរមន-ខ្មែរ ដែលនៅទីនោះ ក៏បាននាំគ្នារត់ភៀសខ្លួនពីភ័យសង្គ្រាម ម្តងទៀត ។

ព្រះចៅចន្ទ្រគុប្ត ( ៣២១ - ២៩២ មុន គ.ស ) នៃរាជវង្សមោរិយៈ

ក្រោយដែលអាឡិក្សង់ដារ ( Alexander ) មហារាជទ្រង់សោយទីវង្គតហើយ ឥទ្ធិពលក្រិកនៅខាងលិច ឆៀងខាងជើងនៃប្រទេសឥណ្ឌា ក៏អស់ទៅដែរ ។ ក្នុងឆ្នាំ ៣២១ មុន គ.ស ព្រះចៅចន្ទ្រគុប្តបានប្រាបប្រាមដែនដីនានាប៉ែកខាងជើង នៃឥណ្ឌា បានចាត់តាំងអាណាចក្រធំ មានទីក្រុងឈ្មោះបាតលីបុត្រ ។ ពេលនេះ អំបូរមន-ខ្មែរ ក៏គង់រត់គេចពីរាជភ័យម្តងទៀត ។ តពីសម័យព្រះចៅចន្ទ្រគុប្តមក ព្រះរាជបុត្រទ្រង់ព្រះនាម ពិន្ទុសារ ក៏ទ្រង់សោយរាជ្យត ព្រះអង្គទ្រង់មានព្រះរាជសម្ពន្ធមេត្រីនឹងអាណាចក្រ ប៉ិរសៀ អាណាចក្រនេះ ក៏សុខស្ងប់រហូតមក ។

ប្រមាណ ៣០០ ឆ្នាំមុន គ.ស ព្រះពុទ្ធសាសនាចំរើនរុងរឿងណាស់ នៅប្រទេសឥណ្ឌា ព្រោះមានស្តេចសំខាន់ៗ ដូចជាព្រះចៅអសោកមហារាជនៃមោ-រិយវង្ស ជួយឧបត្ថម្ភទំនុកបំរុង ។

ព្រះចៅអសោក ( ២៧៤ - ២៣៧ ឆ្នាំ មុន គ.ស ) ព្រះចៅអសោកជាព្រះរាជបុត្រព្រះចៅពិន្ទុសារ បានត្រូវគេលើកថាជាក្សត្រីខ្លាំងពូកែមួយព្រះអង្គដែលមិនងាយរកបានក្នុងលោកនេះ ។ ក្នុងរជ្ជសម័យព្រះបាទអសោកនេះ មានធ្វើសឹកសង្គ្រាមជាញឹកញាប់ ដើម្បីផ្សាយរាជអាណាចក្រអោយបានរីកធំទូលាយឡើងទៀត ព្រះអង្គវាយបានដែនដីដែលហៅថា អាហ្វហ្គានិស្ថាន បាលូចិស្ថាន កស្មីរ នេប៉ាល់ សិក្ខិម ហើយនិងដែនដីភាគខាងជើងនៃប្រទេសឥណ្ឌាទាំងអស់ គឺរាប់ចាប់តាំងពីដងទន្លេសិន្ធុទៅ រហូតដល់ឈូងបេងកាល ប៉ែកខាងលិចរហូតទៅដល់ទន្លេកឫស្នា ។

ក្នុងឆ្នាំ ២៦២ មុន គ.ស ព្រះអង្គបានលើកទ័ពទៅប្រាបប្រាមពួកក្លឹង្គក្នុងរដ្ឋអូរិស្សាដែលនៅវាងស្ទឹងមហានទី និងគោទាវរី ។ ពួកក្លឹង្គបានតស៊ូយ៉ាងម៉ឺងម៉ាត់ ប៉ុន្តែត្រូវចាញ់នៅទីបំផុត ។ ការប្រយុទ្ធគ្នាពេលនោះជាហេតុធ្វើអោយស្លាប់បាត់បង់ជីវិតនៃទាហានទាំងពីរផ្នែក អស់ច្រើនណាស់ ។ តាំងពីនោះមក ព្រះបាទ

អសោកទ្រង់មានព្រះទ័យតក់ស្លុតណាស់ ទើបទ្រង់ព្រះតម្រិះយកព្រះពុទ្ធសាសនាជាទីពឹងប្រកាសឈប់ធ្វើសឹកសង្គ្រាមដោយកំលាំងតាំងពីពេលនោះរហូតមក ទ្រង់យកព្រះធម៌ជាធំ ទ្រង់ប្រកាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន ទ្រង់ផ្សាយបរមរាជានុភាពដោយធម្មានុភាពទៅវិញ ។

ក្រោយរជ្ជសម័យព្រះបាទអសោក ប្រទេសឥណ្ឌាបានថយកិត្យានុភាពក្សត្រិ៍អង្គៗមក គ្មានបានសាងថ្វីដៃអ្វីឡើយ មោរិយវង្សក៏អស់អំណាចក្នុងឆ្នាំ ១៨៤ មុន គ.ស ឬប្រមាណ ព.ស ៣៥៦ ។

ក្នុងជំនាន់ព្រះបាទអសោកមហារាជនេះ មានជនជាតិឥណ្ឌាទាំងអំបូរមនខ្មែរ និងពួកឥណ្ឌាដែលហៅថាអរិយកៈ បានភៀសខ្លួនចេញពីប្រទេសឥណ្ឌាច្រើនណាស់ ។ ការចេញពីប្រទេសឥណ្ឌា ទៅនៅទីផ្សេងៗក្រៅប្រទេស គួរអោយសន្និដ្ឋានថា មកពីហេតុ ៤ ប្រការគឺ :

១. មកពីព្រះរាជបំណងរបស់ព្រះបាទអសោក ដែលទ្រង់មានអ្នកប្រាជ្ញរាជបណ្ឌិតទាំងគ្រហស្ថ ទាំងបព្វជិតជួយផ្សាយព្រះពុទ្ធសាសនា ម្ល៉ោះហើយជនជាតិឥណ្ឌាសម័យនោះ ក៏បានចេញទៅកាន់ដែនដីនានាក្រៅប្រទេស ដោយអំណាចរាជានុភាព សុវណ្ណភូមិ ឬអាស៊ីអាគ្នេយ៍ ជាផែនដីមួយដែលពួកឥណ្ឌាទាំងអំបូរមន-ខ្មែរ និងអរិយកៈបានចូលមកនៅ សម័យនេះផ្ទៃដីអាស៊ីអាគ្នេយ៍នៅមិនទាន់គោកសព្វគ្រប់ដូចសព្វថ្ងៃទេ តែនៅលើទីនានានៃផ្ទៃដីគោក ក៏គង់មានអំបូរមន-ខ្មែរ មកនៅពេញរស់ទៅហើយ ។ គួរអោយជឿជាក់ថា ពួកនាគ ឬពួកជនជាតិនាគ ក៏ជាអំបូរខ្មែរមួយក្រុម អាចមកនៅទីនេះមុនគេបង្អស់ ។ ហេតុដែលជឿជាក់ថា នាគជាបុព្វបុរសខ្មែរមួយក្រុមនោះ ពីព្រោះរឿងរ៉ាវនាគនេះ មានទាក់ទងនឹងប្រវត្តិសាស្ត្រយើងជាច្រើនអន្លើ ។ យើងជាអនុជន គួរគប្បីសិក្សាស្រាវជ្រាវរឿងនេះអោយពិតប្រាកដ យើងកំពុងប្រមូលចិត្តយើងក្នុងជំនឿថា « នាគជាសត្វ » តែគួរ

អោយជឿថា មនុស្ស ឬអំបូរមនុស្សដែលទាក់ទងជាកុលសម្ព័ន្ធនឹងយើងទៅវិញ ។ សព្វថ្ងៃពូជមនុស្សនាគនេះ មាននៅក្នុងផ្ទៃដីជ្រោយម៉ាឡាយូ និងព្រំដែនឥណ្ឌាភូមា ។

២. ពួកក្រៅសាសនា បានដល់ជនជាតិអរិយកៈ និងអំបូរមន.ខ្មែរ ដែលធ្លាប់កាន់ព្រហ្មញ្ញសាសនារួចមកហើយ តែលុះព្រះបាទអសោកបែរមកទំនុកបំរុងព្រះពុទ្ធសាសនាវិញនោះ ក៏ជាហេតុនាំអោយពួកសាសនាព្រាហ្មណ៍មិនពេញចិត្ត ទើបរត់ភៀសខ្លួន ព្រមទាំងនាំសាសនាព្រាហ្មណ៍ចូលមកអាស៊ីអាគ្នេយ៍ ដើម្បីបន្តជំនឿរបស់ខ្លួនលើទីនេះតទៅ ដោយពុំចង់អោយមានអ្នកណាមកបៀតបៀនបានទៀតឡើយ ។

៣. រត់ភ័យគេចពីសង្គ្រាម ដែលពេលនោះប្រទេសឥណ្ឌារំជួយដោយសែន្យានុភាពនៃកងទ័ពព្រះបាទអសោក ពួកដែលភៀសខ្លួនមកនៅអាស៊ីអាគ្នេយ៍ពេលនោះ មានជនជាតិគ្រប់ជាន់ គ្រប់អំបូរ គ្រប់ភាគីពីប្រទេសឥណ្ឌា ប៉ុន្តែអាចមានពួកវណ្ណៈជាន់ខ្ពស់ ដូចជាវណ្ណៈក្សត្រិយ៍ ហើយនិងព្រាហ្មណ៍ដែលមិនព្រមនៅក្រោមអំណាចព្រះចៅអសោកនោះ ក៏បាននាំគ្នាមករកកន្លែងថ្មីនៅអាស៊ីអាគ្នេយ៍ដែរ ដើម្បីតាំងជារដ្ឋធានីថ្មីដោយឡែក ។ ក្នុងដំណាលបូរាណ មានដំណាលសុវណ្ណខ្ញុំមខាំជាដើម ក៏បាននិយាយអំពីព្រះវង្សស្តេចដែលមកពីប្រទេសឥណ្ឌានោះ ហើយដែលបានមកធ្វើធំនៅអាស៊ីអាគ្នេយ៍នោះដែរ ។

៤. ពួកអ្នកផ្សងព្រេង បានដល់ជនដែលចង់រកស៊ីមានបាន ព្រោះឮដំណឹងថា ផ្ទៃដីនៃភូមិភាគអាស៊ីអាគ្នេយ៍នោះដែរ សម្បូរសប្បាយរកស៊ីស្រួលងាយណាស់ បានជានាំគ្នាហូរចូលមក ។ រឿងមកលក់ដូរធ្វើចំការដូច្នេះ គង់មានមកតាំងពីមុនសម័យព្រះចៅអសោកមហារាជក៏សឹងបាន បញ្ហានេះសូមអោយមើលក្នុងជាតកនានាផ្នែកពុទ្ធសាសនា មានមហាជនកជាតក សង្ខព្រាហ្មណ៍ជាតក និងសុសន្ធី

ជាតកជាដើម ក៏នឹងឃើញសេចក្តីច្បាស់ ។

ប្រវត្តិសាស្ត្រនៃប្រទេសឥណ្ឌា តាំងពី ព.ស ៥៥០ ចុះមកដល់ ព.ស ១០៥០ ឃើញថាជាសម័យច្របូកច្របល់ណាស់ ខ្ញុំសូមលើកមកជូន ដើម្បីជាប្រ-យោជន៍ក្នុងការស្រាវជ្រាវអំពីអំបូរមន-ខ្មែរ ព្រោះប្រទេសនេះ មានការទាក់ទងនឹងផ្ទៃដើមនៃប្រវត្តិសាស្ត្រជាតិយើងជាច្រើន ។

នៅរយះក្រោយព្រះចៅអសោកមក មានស្តេចច្រើនអង្គដែរ ប៉ុន្តែអំណាចដែលធ្លាប់មានកាលពីជំនាន់ព្រះចៅអសោកនោះ ដល់មកជំនាន់នេះ ក៏ខ្សោយអំណាចអស់ ។ មជ្ឈដ្ឋានអំណាចនៃប្រទេសឥណ្ឌា បានមកប្រាជកនៅពីរកន្លែងគឺ :

• កន្លែងទី ១ នៅភាគខាងពាយព្យប្រទេស ផ្ទៃដីត្រង់នេះធ្លាក់ទៅក្នុងកណ្តាប់ដៃក្រិក តែតមក បាននៅក្នុងអំណាចជនជាតិសីធៀន ( Scythian ) ។

• កន្លែងទី ២ នៅក្នុងភាគកណ្តាលនៃជ្រោយដេកខាន អាណាចក្រដែលរាជវង្សអាន្ធ្រះបានចាត់តាំងឡើង ទុកណានៅរយៈនេះ ឥទ្ធិពលជាតិបរទេសអាចចូលមកឥណ្ឌាពីខាង ( និរតី ) ក៏ដោយ ក៏ប៉ុន្តែ វប្បធម៌ និង ប្រពៃណីបែបទមិឡទៅវិញ ហើយបាននៅក្រោមការគ្រប់គ្រងរាជវង្សអាន្ធ្រះដែលជារាជវង្សរបស់ឥណ្ឌាដើមសុទ្ធ ។ តមក រាជវង្សនេះបានពង្រីកអំណាចកាន់តែធំឡើងទៅលើភូមិភាគដទៃទៀតនៃប្រទេស គឺពីជ្រោយដេកខាន ឡើងទៅដល់រដ្ឋមល្វះ ( Malwa ) និងរដ្ឋមហារាស្ត្រ ( Mahārashtra ) ទាល់តែដល់ឈូងកាំបេយ៍ ( Cambay ) មុខស្រុកបុមបេយ៍ ( Bombay ) ទិសខាងលិច ។ រីឯដែនដីភូមិភាគខាងលិចឆៀងខាងជើង បានផ្ទេរពីដៃក្រិកទៅអោយជនជាតិដែលបុករុកមកថ្មីទៀតគឺ ជនជាតិសកៈ ( Saka ) ។

ជនជាតិ Saka នេះជាពូជជនជាតិសីធៀន ( Scythian ) ដែលកាល

ពីមុនធ្លាប់នៅលើផ្ទៃដីភាគខាងកើតនៃប្រទេសអៀរ៉ង់ ( Iran ) ។ តមក ត្រូវបានជនជាតិពនេចរ គឺយុយ-ចិ ( Youh - chih ) បណ្តេញអោយចូលមកនៅប្រទេសឥណ្ឌា រួមជនជាតិយុយ-ចិ ខ្លួនឯងក៏ត្រូវបានពួក ហ៊ុង-នូ ( Hiong-nu ) ឬហាន់ ( Hun ) បណ្តេញអោយចេញពីដែនដីមុងកុលមួយតំណទៅទៀត ហេតុការណ៍នេះបានឧប្បត្តិឡើងរវាង ព.ស ៤២៥ - ៤៥០ ។ ដោយអាស្រ័យហេតុនេះឯង ទើបពួកជនជាតិយុយចិ បែកបាក់គ្នា បានមកប្រាកដខ្លួននៅពេសពេញលើអាណាបរិវេណដែលធ្លាប់នៅក្រោមឥទ្ធិពលរបស់ជាតិក្រិក និងអៀរ៉ង់កាលពីមុន ។ តមក ពួកយុយចិនេះ មានឥទ្ធិពលកាន់តែខ្លាំងឡើងៗ ទើបបានចូលវាយយកដែនដីដែលហៅថា Bactria និង Seistan អោយនៅក្រោមអាណាព្យាបាលរបស់ខ្លួន ។ ដែនដីទាំងពីរនេះ នៅខាងត្បូងប្រទេសអាហ្វហ្គានិស្ថាន រួមទាំងរដ្ឋគន្ធារៈផង រដ្ឋនេះគឺដែនដីដែលហៅថា ប៉េស្វារ (Peshawar) បច្ចុប្បន្ននេះឯង ។ តមក ក្នុងពុទ្ធសតវត្សទី ៦ - ៧ រដ្ឋនានា ដូចជា បញ្ចាបខាងលិច គឺក្រុងតក្កសិលា រដ្ឋកាបិសៈ ( Kapisa ) គឺអាណាបរិវេណម្តុំរដ្ឋបេគ្រាម ( Begram ) ក្នុងប្រទេសអាហ្វហ្គានីស្ថាន រដ្ឋបញ្ចាបខាងលិច និងរដ្ឋសិន្ធុ ក៏បានធ្លាប់ទៅនៅក្នុងកណ្តាប់ដៃរាជវង្សកុសាណៈ ( Kusāna ) ដែលជាពូជជនជាតិយុយចិដដែលនេះ ។

រាជវង្សកុសាណៈនេះ បានតាំងអាណាចក្រយ៉ាងធំ មានអំណាចតាំងតែពីដងទន្លេអកស៊ស ( Oxus ) ដែលជាដែនដីនៅប៉ែកខាងពាយ័ព្យ នៃប្រទេសឥណ្ឌា រហូតដល់អាណាបរិវេណងទន្លេគង្គា មានក្រុង Bactaria ( បាក់តេរៀ ) និងកាប៊ុល ( Kabul ) ជាមជ្ឈមណ្ឌលទ្រទ្រង់ឥទ្ធិពលនៃរាជវង្សកុសាណៈនេះ ។ អំណាចរាជវង្សនេះ បានផ្សាយទៅដល់រដ្ឋសកឌីយ៉ាណា ( Sogdiana ) ហើយនិងភាគកណ្តាលនៃទ្វីបអាស៊ី ហើយផ្សាយមកជ្រោយឥណ្ឌូចិនផង ព្រោះនៅទីនេះគេបានរកឃើញសិល្បៈបែបអៀរ៉ង់ ( Iran ) លាយឡំជាមួយខ្លះ ។ ក្សត្រិយ៍

រាជវង្សកុសាណៈ ដែលមានព្រះនាមល្បីជាងគេ គឺព្រះចៅកនិសកៈ ( Kaniska ) ដែលជាពុទ្ធសាសនិក ហើយអាចជាអ្នកតាំងមហាសករាជឡើងក្នុង ព.ស. ៦២១ ក៏សឹងបាន ព្រោះឆ្នាំនោះគឺជាឆ្នាំដែលឡើងសោយរាជ្យ ។

ចក្រវត្តិនេះ មានអំណាចរុងរឿងប្រមាណ ១០០ ឆ្នាំ តពីនោះ អំណាចបានត្រូវថយចុះ ព្រោះមហាប្រទេសឥណ្ឌាបានត្រូវបែងជារដ្ឋតូចធំជាច្រើន ដោយមានរាជវង្សសកៈឡើងកាន់អំណាចជំទាស់ ។ អាណាចក្របរិវេណក្បែរក្រុងបុមបេយ៍ក៏បានត្រូវបែងចែក ហើយនៅពេលជាមួយគ្នានោះ អាណាបរិវេណប៉ែកខាងត្បូងនៅក្រោមឥទ្ធិពលរាជវង្សអាន្ធារៈ ក៏ត្រូវបានបែងចែកជា ២ ភាគ ក្នុងពុទ្ធសតវត្ស ទី ៨ ។ តមក រាជវង្សសំខាន់របស់ឥណ្ឌាមួយទៀត គឺរាជវង្សគុប្តៈ ( Gupta ) បានរួបរួមប្រទេសឥណ្ឌាជាថ្មីម្តងទៀត ។

ក្នុងយុគនេះ ប្រទេសឥណ្ឌាបានចំរើនល្អតលាស់ក្នុងវិស័យសេដ្ឋកិច្ច ជាទីបំផុត មានការទាក់ទងតាមផ្លូវពាណិជ្ជជាមួយប្រទេសនានា ដែលនៅខាងលិចនៃទ្វីបអាស៊ី ហើយនិងដែនដីមុំទន្លេមេឌីធែរេនាន ( Mediteranian ) ក្នុងទ្វីបអឺរ៉ុប ។ ក្រៅពីនេះមានការទាក់ទង និងប្រទេសនៅប៉ែកទន្លេភាគខាងត្បូង នៃទ្វីបអាស៊ីផងដែរ ។ ការទាក់ទងដូច្នេះ យើងដឹងមកពីការជីករកឃើញវត្ថុតាងតាមអាណាបរិវេណទូទៅបានយ៉ាងច្រើនលើសលប់ ។ វត្ថុតាងដែលបានរកឃើញនៅក្រុងតក្កសិលា ជាហេតុអោយឃើញច្បាស់អំពីការទាក់ទងរវាងប្រទេសឥណ្ឌានិងប្រទេសមេសូប៉ូតាមី ក្នុងរយៈ ១០០ ឆ្នាំមុនពុទ្ធកាល រហូតដល់សម័យពុទ្ធ-កាល ។ ការទាក់ទងរវាងប្រទេសឥណ្ឌា និងអៀរ៉ង់ ( Iran ) បានមានឡើងតាំងពីពុទ្ធសតវត្សទី១ ហើយនិងការទាក់ទងរវាងប្រទេសក្រិក បានមានឡើងប្រមាណពុទ្ធសតវត្សទី ២ ។ វត្ថុវត្ថុតាងដែលបានរកឃើញត១មក បានជាសាក្សីអោយឃើញច្បាស់នូវការទាក់ទងយ៉ាងទូលំទូលាយផ្នែកពាណិជ្ជក្នុងសម័យនោះ ។ ក្រៅពី

ប្រាក់រៀលរោមន៍ ដែលបានរកឃើញដោយទូទៅក្នុងផ្ទៃប្រទេសឥណ្ឌា ហើយគេបានជីកឃើញវត្ថុគ្រឿងប្រើប្រាស់ ធ្វើដោយដៃពីកំបោរដែលជារបស់ក្រិក-រោមន៍ ឬវត្ថុដែលបានមកពីក្រុងអាឡិកសានដ្រា ( Alexandria ) ប្រទេសអ៊ីហ្ស៊ីប ។ គ្រឿងសិរីទិ្ធក្រិក - រោមន៍ និងគ្រឿងកែវទាំងអស់នេះ គេបានរកឃើញនៅស្រុកកាពិស៊ី (Kapisi) ឬស្រុកបេគ្រាម ដែលជាក្រុងចាស់នៃរដ្ឋកាមិសៈ ។ ស្រុកនេះសព្វថ្ងៃ តាំងនៅក្នុងប្រទេសអាហ្វហ្កានីស្ថានដែលគេបានរកឃើញគ្រឿងប្រើប្រាស់ដែលធ្វើពីខ្លួកជារបស់ចិន ។ ក្រៅពីនេះ នៅមានអំបែងដីដុត និងក្បាលចិញ្ចៀនរោមន៍ជំនាន់ព្រះចៅអគ័សតស (Augustus) ហើយនិងព្រះចៅគ្លូឌិស (Claudis) ក្នុងពុទ្ធសតវត្សទី៦ ។ របស់អស់នេះ បានរកឃើញនៅភាគខាងត្បូងនៃដែនដីប្រទេសឥណ្ឌា ត្រង់ស្រុកដែលមានឈ្មោះថា អរិកៈមេឌុ (Arikamedu) ហើយនិងស្រុកវិរប័តណាំ ( Virapatnam ) ជិតស្រុកប៉នទិឆ្ញេរី ( Pondichery ) ក្រៅពីនេះ នៅកូសាំងស៊ីន ( Cochinchina ) ក្នុងប្រទេសវៀតណាមខាងត្បូង ត្រង់កំពង់ផែខ្មែរបូរាណ ដែលមានឈ្មោះថា អូកែវ ( Oc - Eo ) នោះ គេបានរកឃើញក្បាលចិញ្ចៀនប្រាក់រៀល និងគ្រឿងប្រើប្រាស់រោមន៍ សម័យចក្រព័ត្ររោមន៍ ៧ អង្គ ក្នុងរវាង ព.ស ៦៣៤-៧៣៥ ហើយនិងសិល្បៈបែបអៀរ៉ង់ (Iran) ជំនាន់រាជវង្សសស្សានិត ទៀតផង ។

ហេតុនេះ ទើបឃើញថាក្នុងយុគនេះ ប្រទេសឥណ្ឌាមានការទាក់ទងយ៉ាងទូលំទូលាយរវាងប្រទេសក្រិក អៀរ៉ង់ និងប្រទេសនានានៅអាស៊ីអាគ្នេយ៍ ។

ខ្ញុំសូមសរុបសេចក្តីនៃការប្រែប្រួល បែកញែកយ៉ាងច្របូកច្របល់ នៃប្រទេសឥណ្ឌានេះអោយខ្លីម្តងទៀត ដើម្បីងាយស្រួលក្នុងការស្រាវជ្រាវ ។

ផែនដីឥណ្ឌាប៉ែកខាងលិចឆៀងខាងជើងបន្តិច គឺត្រង់ដែលហៅថា ឬមបេយ៍ រដ្ឋមហារាស្ត្រ រដ្ឋមល្វៈ ជាដើម បានធ្លាក់ទៅក្នុងកណ្តាប់ដៃជនបរទេស

គឺជាតិសិធៀន ( Scythian ) ក្នុងពុទ្ធសតវត្សទី ៥ - ៦ ។ គួរអោយសង្កេតថា រដ្ឋកម្ពោជៈ ដែលជាដែនដីជាតិអំបូរមន-ខ្មែរ បានទៅតាំងនៅក្រោយពីការរត់ភៀសខ្លួនពីរដ្ឋកស្មិរនោះ ក៏បាននៅក្រោមអំណាចជាតិបរទេសដែរ ព្រោះស្រុកនោះនៅខាងត្បូងគន្ធារៈរដ្ឋ នៅឆ្នេរសមុទ្រខាងជើងក្រុងបុមបេយ៏ សព្វថ្ងៃហៅថាគុជរដ្ឋ ។ កាលពីជំនាន់ដើម គុជរដ្ឋនេះ មានឈ្មោះថារដ្ឋវលភី ឬអាណាចក្រវលភី ។ រីឯស្រុកកម្ពោជៈនោះ ព្រះអង្គបានតាំងក្រុមមួយ ឈ្មោះថាទ្វារកៈ ដល់មកជំនាន់សីធៀនមកគ្រប់គ្រង អំបូរមន-ខ្មែរអាចមិនពេញចិត្ត ទើបរត់ភៀសខ្លួនចេញមក ប៉ុន្តែបន្តិចបន្តួចទេ ។ តមក ភាគខាងលិចនេះបានផ្ទេរអំណាចទៅអោយរាជវង្សអន្ធារៈ ដែលមកពីដេកខានទិសខាងត្បូងទៅវិញ ក៏អាចជាហេតុអោយអំបូរមន-ខ្មែរ ដែលនៅត្រង់នេះមានការភិតភ័យម្តងទៀត ប៉ុន្តែអាចមិនជាប៉ុន្មានដែរទេ ។

ភូមិភាគខាងពាយ័ព្យ ត្រង់ដងស្ទឹងសិន្ធុ កស្មិរ បញ្ចាបជាដើមដែលជាកន្លែងអំបូរមន-ខ្មែរ នៅពីជំនាន់ដើមនោះ បានផ្ទេរអំណាចពីកណ្តាប់ដៃក្រិកដែលបានបន្តពូជពីអាឡិកក្សិនដារ ( Alexander ) នោះ អោយមកនៅក្រោមអំណាចជាតិបរទេសថ្មី ដែលមានឈ្មោះថាសកៈទៅវិញ ដែលមានពូជមកពីជាតិសីធៀន ។ ពួកនេះ កាលដើមនៅត្រង់តំបន់ខាងកើត នៃប្រទេសអៀរ៉ង់ តែ តមកត្រូវពួកយុយចិបណ្តេញចេញមក បានមកមានឥទ្ធិពលលើដែនដីអំបូរមន-ខ្មែរ ប៉ែកខាងជើងនោះឯង ។ រីឯពួកយុយចិនេះ ពីដំបូងបានត្រូវពួកហ៊ុន ( Hun ) បណ្តេញចេញពីដែនដីម៉ុងហ្គោល ហើយបានមកជ្រែកនៅពាសពេញលើផ្ទៃដីប្រទេសឥណ្ឌា ។ តមក ពួកនេះមានមហិទ្ធានុភាពកាន់តែខ្លាំងឡើងៗ ទាល់តែមានអំណាចគ្របសង្កត់លើដែនដីនានាដែលនៅជិតខាង គឺរដ្ឋបាក់ទ្រា ( Bactria ) និងសេស្តាន ( Seistan ) ដែលសព្វថ្ងៃនៅក្នុងដែនដីប្រទេសអាហ្វហ្គានិស្ថាន

( Afghanistan ) ។ រដ្ឋគន្ធារៈ, ប៉េសវារ (Peshawar) ក៏បាននៅក្រោមឥទ្ធិ-ពលពួកយុយចិដែរ ។ តមក ដែនដីដងទន្លេសិន្ធុ គឺក្រុងតក្កសិលា ( ដែលធ្លាប់ជាទីក្រុងនៃអំបូរមន-ខ្មែរ ប៉ែកខាងត្បូងភ្នំហិមាល័យខាងត្បូងពីដើម ) រដ្ឋកាបិសៈ ( Kapisa ) រដ្ឋបញ្ចាប, រដ្ឋទាំងអស់នេះ បានធ្លាក់នៅក្រោមកណ្ដាប់ដៃរាជវង្សយុយ-ចិ ដែលមានឈ្មោះថាកុសាណៈ ( Kusāna ) ក្នុងពុទ្ធសតវត្សទី ៦ - ៧ ។

ឥទ្ធិពលនៃរាជវង្សកុសាណៈនេះ មានទូលំទូលាយផ្សាយទៅឆ្ងាយណាស់ រហូតដល់មកជ្រោយឥណ្ឌូចិនយើងនេះ, តែនៅអូកែវ ( Oc - Eo ) ដែលជាកំពង់ផែខ្មែរបូរាណនេះ បើពិចារណាលើវត្ថុដែលគេបានជីកឃើញ ដូចក្បាលចិញ្ចៀន និងវត្ថុគ្រឿងប្រើប្រាស់ឯទៀតៗជាដើម គួរអោយឃើញថាមានការទាក់ទងរវាងដែនដីត្រង់នេះ និងជាតិអៀរ៉ង់ ហើយនិងជាតិរាមន៍ផង រួចគួរអោយជឿថាការទាក់ទងនេះ គង់មានតាំងពីសម័យដើមពុទ្ធកាល រហូតដល់ពុទ្ធសតវត្សទី៨មុននេះ ។

តទៅនេះ ខ្ញុំសូមវិនិច្ឆ័យតាមទស្សនៈផ្ទាល់ខ្លួនសុទ្ធសាធ ដែលខ្ញុំពុំបានចាត់ទុកថាជាការវិនិច្ឆ័យផ្ដាច់ព្រាត់ដោយអោយអស់តែត្រឹមនេះទេ គឺថា អាចមានតុលាការជាន់ខ្ពស់ដែលមានទស្សនៈ, មានភស្តុតាងល្អជាងខ្ញុំរកឃើញ នៅថ្ងៃក្រោយទៀត ។ តុលាការជាន់ខ្ពស់នោះ បានដល់ព្រះតេជព្រះគុណ, អស់លោកនិងប្អូនៗបញ្ញវន្តជំនាន់ក្រោយនោះឯង ដែលបានស្រាវជ្រាវ ហើយបានវិនិច្ឆ័យដោយមានភស្តុតាងល្អជាង, ប្រសើរជាងខ្ញុំក៏បានដែរ គ្រាន់តែធ្វើដូចម្ដេចអោយអស់លោកនិងប្អូនៗ បានបញ្ចេញនូវគំនិតដែលប្រកបដោយជម្រៅនៃអ្នកប្រាជ្ញក្នុងការ-ស្វះស្វែងរកលក្ខឋានអំបូរជាតិយើងអោយបានពិតប្រាកដឡើង ដើម្បីជាប្រយោជន៍ក្នុងការបន្តពូជពង្សរបស់ខ្លួន អោយបានស្ថិតស្ថេរចិរកាលតរៀងទៅ ក្នុងឆាកអន្តរជាតិ ហើយជាកំលាំង ពលំមួយដ៏អស្ចារ្យដល់អនុជនជំនាន់ក្រោយ អោយយល់

ថា អំបូររបស់ខ្លួននោះ ជាអំបូរខ្ពស់ ជាអំបូរធ្លាប់មានមហិទ្ធិឫទ្ធិ សែនឤនុភាព ជាអំបូរដែលប្រវត្តិសាស្ត្រប្រាប់ថា មានអារ្យធម៌ វប្បធម៌ល្អលាស់មុនគេ នៅអាស៊ីអាគ្នេយ៍ ឬអាចនៅអាស៊ីនេះតែម្តង ! ដូចតទៅ ៖

ប្រទេសឥណ្ឌាដែលមានការផ្លាស់ប្តូរ ច្របូកច្របល់ វរវឹកជាញឹកញយនោះ បានធ្វើអោយអំបូរខ្មែរបែកបាក់ រត់ភៀសខ្លួនទៅនៅរាត់រាយតាមកន្លែងនានាតាំងពីផ្ទៃប្រទេសឥណ្ឌា ដងភ្នំ ដងទន្លេ តាមកោះនានា រហូតដល់អាស៊ីអាគ្នេយ៍នេះ ប៉ុន្តែ ល័ក្ខឋានដែលឃើញច្បាស់ជាចុងបង្ហើយនៃការភៀសខ្លួនអំពីប្រទេសឥណ្ឌាមកកាន់អាស៊ីអាគ្នេយ៍ ដូចបានជម្រាបមកតាមលំដាប់អំពីប្រវត្តិសាស្ត្រប្រ-ទេសឥណ្ឌានោះ ក៏ឃើញបានថា នៅសតវត្សទី៦ ទី៧ ទី៨ នៃជំនាន់រាជវង្សកុសាណៈ អំបូរមន-ខ្មែរបានភៀសខ្លួនចេញពីប្រទេសឥណ្ឌា មកតាំងស្រុកទេសនៅលើផ្ទៃដីអាស៊ីអាគ្នេយ៍នេះទាំងអស់ ។

ការភៀសខ្លួនមកនេះ មិនមែនមកតែខ្លួនទេ គឺថា មាននាំអារ្យធម៌ និងវប្បធម៌ដែលខ្លួនធ្លាប់កាន់នោះមកជាមួយផង ហើយបានមកផ្សាយពេញផ្ទៃភូមិភាគអាស៊ីអាគ្នេយ៍យើងនេះ ទាល់តែមើលទៅហាក់ដូចជាប្រទេសឥណ្ឌាទី២ តែម្តង ! ព្រោះហេតុដូច្នេះ អ្នកប្រាជ្ញល្បីឈ្មោះនានា មានលោកសេដេស៍, ហ្វីល្លិបស្តែន និងលោកប៉េលីយ៉ុត ( Pelliot ) ជាដើម បានហៅភូមិភាគអាស៊ីប៉ែកអាគ្នេយ៍ថាអាណាចក្រឥណ្ឌាទៅវិញ ដូចគ្នានឹងប្រជាជនខ្មែរជំនាន់បូរាណរហូតដល់សព្វថ្ងៃខ្លះបានហៅស្ថាបត្យកម្ម បដិមាកម្ម ដែលជាថ្មីដែល្អអស្ចារ្យថា សុទ្ធជាស្នាដៃព្រះឥន្ទ្រទាំងអស់ ( ពាក្យថា « ព្រះឥន្ទ្រ » ដែលយើងហៅតាំងពីបូរាណមកគួរអោយសន្និដ្ឋានថា « គឺជនជាតិឥណ្ឌា » នោះឯង ) ។ រីឯឈ្មោះនគរផ្សេងៗដែលមានឈ្មោះប្រាកដនៅក្នុងដែនដីប្រទេសឥណ្ឌា ដូចជាឥន្ទ្រប្រស្ថ, តក្កសិលា, កម្ពោជៈ, អមរវតី, ចាម៉្បា, ទ្វារវតី, ក្លីង្គ ក៏ត្រូវបានពួកអំបូរមន-ខ្មែរ នាំមកនៅ

តាមកន្លែងនានា ដែលខ្លួនបានមកកសាងឥទ្ធិពលថ្មីដែរ ។

ពួកអំបូរមន-ខ្មែរ ដែលរត់ពីក្រុងឥន្ទ្រប្រស្ថ មកនៅលើដងទន្លេមុនាជិតក្រុងដែល្លីសព្វថ្ងៃនេះ បានមកតាំងក្រុងឥន្ទ្រប្រស្ថលើផ្ទៃដីលាវ ត្រង់ព្រំដែនសព្វ ថ្ងៃ ហៅថាប៉ាកហិនប៊ូរ ឆ្មេរខាងកើតទន្លេមេគង្គ ។ គួរអោយជឿថាកុលសម្ព័ន្ធ នៅក្នុងប្រទេសលាវ គង់មានតំណពីពូជឥន្ទ្រប្រស្ថ ៖

| | | | |
|---|---|---|---|
| ល្វិន | ( Loven ) | ស៊ក | ( Sork ) |
| លាម៉េត | ( Lamet ) | សាពួន | ( Sapuan ) |
| ង៉េះ | ( Ngeh ) | ថាប | ( Thap ) |
| ងុងប៊ូរ | ( Ngung Bo ) | តៅអយ | ( Tou oi ) |
| ញ៉ាហិន | ( Nha Heun ) | ថឺ | ( The ) |
| ពួណយ | ( Pü Noi ) | វ៉ិន | ( Ven ) |

( នៅមានត )

ស្រាវជ្រាវដោយ

**ហៀន ចណ្ណារក្ខ**

*ឯកសារសិក្សា*

# ប្រទេសកម្ពុជា តាមរយៈអក្សរសាស្ត្ររបស់ខ្លួន

មានបែបបទច្រើនយ៉ាង ដើម្បីស្វែងយល់ប្រទេសណាមួយ ។ គេអាចស្គាល់ប្រទេសនោះ តាមបែបសើៗ, តាមរយៈទិដ្ឋភាពទូទៅរបស់ប្រទេសនោះ, តាមរយៈទេសភាពរបស់ប្រទេសនោះ, តាមរយៈទីក្រុងទាំងឡាយរបស់ប្រទេសនោះ តែប៉ុណ្ណោះ, គេអាចស្គាល់ប្រទេសនោះយ៉ាងស៊ីជម្រៅ តាមរយៈប្រវត្តិសាស្ត្ររបស់ប្រទេសនោះ, តាមរយៈការវិវត្តន៍របស់ប្រទេសនោះ នៅក្នុងកាលៈទេសៈ និងព្រឹត្តិការណ៍ទាំងឡាយដែលបន្សល់ទុកស្លាកស្នាមដល់ប្រទេសនោះ ; គេអាចស្គាល់ប្រទេសនោះយ៉ាងស៊ីជម្រៅមួយបែបទៀត តាមរយៈប្រវត្តិសាស្ត្រ, តាមរយៈសិល្បៈ, តាមរយៈប្រាសាទ, តាមរយៈតន្ត្រី ហើយនៅទីបំផុត តាមរយៈភាសារបស់ប្រទេសនោះ, ហើយគឺចំណុចហ្នឹងហើយដែលខ្ញុំជឿថា ជាមធ្យោបាយដើម្បីយល់ដឹងដ៏ផ្ទាល់បំផុត និងដ៏ពេញលេញបំផុតនោះ ។ ពីព្រោះអី ភាសាគឺជាសង្វាក់ផ្ទាល់នៃការគិត ដែលផ្សេងគ្នាពីប្រជាជាតិមួយទៅប្រជាជាតិមួយទៀត ។

ចំពោះប្រទេសកម្ពុជា រហូតមកដល់ពេលនេះ គឺមានតែទិដ្ឋភាពបុរាណវត្ថុវិទ្យារបស់ប្រទេសនេះទេ ដែលជាកម្មវត្ថុដ៏ត្រឹមត្រូវបំផុតនៃការកោតសរសើរដ៏ធំធេងបំផុត និងជាកម្មវត្ថុនៃការស្រាវជ្រាវដ៏ច្រើនបំផុត ។ យើងគ្រាន់តែរំលឹកក្នុងទីនេះ នូវកិត្តិនាមដ៏រុងរឿងនៃអង្គរវត្ត ដែលតាមរយៈនៃសុក្រឹតភាពនៃខ្សែបន្ទាត់របស់ប្រាសាទនោះ (la perfection de ses lignes) បញ្ជាក់ថា គឺជាការប៉ុនប៉ងដ៏គួរអោយរំភើបចិត្តបំផុតរបស់មនុស្សជាតិ ឆ្ពោះទៅរកសោភណភាព ។ គេគ្រាន់តែត្រិះរិះគិតថា អង្គរវត្ត, ប្រសិនបើជាស្នាដៃមិនអាចប្រណាំងប្រជែងបានមែន,

នេះក៏គ្រាន់តែជាឧទាហរណ៍មួយ ក្នុងចំណោមឧទាហរណ៍ដ៏ច្រើនផ្សេងទៀត នៃដំណើររីកស្គុះស្គាយដ៏អស្ចារ្យនៃប្រាសាទសិលា ដែលគ្របដណ្តប់លើផ្ទៃប្រទេសកម្ពុជាទាំងមូល, នៅក្នុងពេលវេលាមួយ ដែលជួនគ្នាជាមួយសម័យកាល ស្ហាលឺម៉ាញ ( l'époque de Charlemagne ) រហូតមកដល់ទីបញ្ចប់នៃសម័យកាលវិសាលវិហារ ( វិហារខាងសាសនាគ្រិស្ត ) របស់បស្ចិមប្រទេសរបស់យើង ( nos cathédrales d'Occident ) ។ គេគ្រាន់តែនឹកគិតក្នុងចិត្តនូវដែនដីនេះ ដែលនៅគ្របទីកន្លែងទាំងអស់សម្បូរដោយព្រះភក្ត្រទេវៈ និងពោរពេញដោយចម្លាក់ ដើម្បីយល់ថាដែនដីនេះ ជាបឋម គឺជាវិស័យដែលបុរាណវត្ថុវិទូតែងស្រមើស្រមៃដល់ ។ ប៉ុន្តែ បើទោះបីការសិក្សាបុរាណវត្ថុវិទ្យា បង្ហាញនិងពន្យល់សិល្បៈខ្មែរអោយយើងដឹងនិងយល់, ក៏ការសិក្សានោះ មិនបានពន្យល់ប្រទេសកម្ពុជាទាំងស្រុង ដល់យើងទេ ហើយជាពិសេស ការសិក្សានោះបានឃ្លាតឆ្ងាយ និងលែងនឹកនាប្រទេសកម្ពុជា ចាប់តាំងពីសតវត្សទី ១៤ ដោយគ្រាន់តែបានផ្តល់អត្ថប្រយោជន៍ ដ៏តិចតួចដល់ប្រទេសនេះ តែប៉ុណ្ណោះ ។

ម្យ៉ាងទៀត ប្រទេសកម្ពុជាមិនសូវត្រូវបានគេសម្លឹងមើលតាមរយៈអក្សរសាស្ត្ររបស់ខ្លួននោះទេ, ដែលនេះហើយគឺជាចរិតលក្ខណៈសំខាន់ ៖ អក្សរសាស្ត្រខ្មែរ *មានចំណាស់ច្រើន* ពីព្រោះអី សិលាចារឹកដំបូងៗជាភាសាខ្មែរ ដែលរកឃើញក្នុងភាគខាងត្បូងនៃប្រទេស មានកាលបរិច្ឆេទតាំងពីសតវត្សទី៧ នៃគ្រិស្តសករាជ មកម្ល៉េះ ។ អក្សរសាស្ត្រខ្មែរ *មានវិវិធភាព* ( ភាពប្លែកៗគ្នា ), ពីព្រោះអក្សរសាស្ត្រនេះ បាននិយាយដល់ស្ទើរតែគ្របវិស័យ ៖ ប្រវត្តិសាស្ត្រ, សាសនា, ល្បោន, កំណាព្យ, ប្រលោមលោក, អក្សរសាស្ត្របច្ចេកទេស, អក្សរសិល្ប៍និទានកថា ។ បើទោះបីអក្សរសាស្ត្រខ្មែរ ជាវប្បធម៌ឥណ្ឌាទាំងស្រុងក៏ដោយ, ក៏អក្សរសាស្ត្រខ្មែរនេះមានរាយដេរដាសដោយប្រធានបទក្នុងស្រុក ហើយជាញឹកញយប្រមូលយកប្រាជ្ញា-

ញាណផុសចេញមកពីចំណេះដឹងរបស់មនុស្សជំនាន់ដើម ដែលមានមកតាំងតែពីពេលមុននៃការហូរចូលអរិយធម៌ឥណ្ឌាម្ល៉េះ ។ ជាទីបញ្ចប់ អក្សរសាស្ត្រខ្មែរមានលក្ខណៈមនុស្សនិយមយ៉ាងជ្រាលជ្រៅ, ពីព្រោះ គឺប្រទេសកម្ពុជាខ្លួនឯង ដែលបានរស់រានឆ្លងកាត់អក្សរសាស្ត្រនោះ តាមបែបបទអនាមិក និងមិនឋិតក្រោមការបកស្រាយរបស់អ្នកមានទេពកោសល្យណាម្នាក់ទេ ; នេះក៏មកតែពីហេតុការណ៍ ដែលអក្សរសាស្ត្រខ្មែរ បានទទួលឥទ្ធិពលរបស់ពុទ្ធសាសនា ដែលជាសត្រូវចំពោះវិញ្ញត្តិ ( ពោលគឺ ការសំដែងគំនិត ឬមនោសញ្ចេតនាដោយវាចា ឬដោយកាយ ) ទាំងអស់ណា ស៊ីពីបុគ្គលភាពរបស់ជនម្នាក់ៗ ។

ចាប់តាំងពីសតវត្សទី ៧ រហូតមកដល់សតវត្សទី ១៤, អក្សរសិលាចារិកជាភាសាខ្មែរចាស់ បានប្រាប់អោយយើងស្គាល់ប្រទេសកម្ពុជា ក្រោមទិដ្ឋភាពប្រវត្តិ-សាស្ត្រ និងសាសនា ។ តពីពេលនោះមក, ពុំមានពតិមានអ្វីទាល់តែសោះ ។ ជាលំដាប់មកទៀត, ដែលគេចាត់ទុកជាចំណងរវាងសម័យបុរាណ ហើយនិងសម័យថ្មី គឺកើតមានឡើង ដោយម្យ៉ាងមានសិលាចារិកសម័យថ្មីអង្គរវត្ត នាសតវត្សទី១២ និងទី១៣ ហើយម្យ៉ាងទៀត មានកំណាព្យខ្មែរដ៏ចម្បងមួយ មានឈ្មោះថា «រាមកេរ្តិ៍», ជាភាសាខ្មែរ ស្មើនឹងសម័យកាលឥណ្ឌានៃរឿងរាមាយណៈ ។ ចំណុចទី ៣ គឺមានផលិតកម្មសម័យថ្មីផ្ទាល់ ។ ផលិតកម្មថ្មីនេះ និយាយយ៉ាងល្អពីប្រភេទ : ល្ខោន, ប្រវត្តិសាស្ត្រ, សាសនា, ច្បាប់, ប៉ុន្តែ ច្រើនគ្របដណ្តប់ដោយចម្រៀង, ប្រលោមលោក និងរឿងនិទាន ។

នៅសម័យបុរាណ, អក្សរសាស្ត្រប្រទេសកម្ពុជា មានអ្វីខ្លះ ?

អក្សរសាស្ត្រនេះត្រូវបានគេធ្វើអោយប្រាកដឡើងក្រោមរូបភាពពីរ : រូបភាពមួយដែលយើងគ្រាន់តែអាចសន្និដ្ឋានប៉ុណ្ណោះ គឺរូបភាពអត្ថបទសរសេរដោយដីស នៅលើស្បែកឆ្អើរអោយខ្មៅ ដែលមិនអាចធន់ទ្រាំនឹងពេលវេលាបាន ;

រូបភាពមួយទៀត គឺការចារិកអក្សរនៅលើផ្ទាំងសិលា ឬសសរថ្ម ហើយដែលមាននិយាយទាំងអំពីសិល្បៈ, ទាំងអំពីប្រវត្តិសាស្ត្រ និងទាំងអំពីអក្សរសាស្ត្រ ។ ក្នុងចំណោមសិលាចារឹកទាំងនោះ, សិលាចារឹកខ្លះ ត្រូវបានគេតែងជាភាសាសំស្ក្រឹត, ដែលជាភាសាអ្នកប្រាជ្ញខាងអរិយធម៌ឥណ្ឌា និងជាពាក្យកាព្យ ។ សិលាចារឹកខ្លះទៀតជាភាសាខ្មែរចាស់ ជាពាក្យរាយ ។ ចំពោះយើង សិលាចារឹកទាំងអស់នោះ គឺជាស្នាដៃអក្សរសាស្ត្រដំបូងគេ គួរអោយជឿទុកចិត្តបានរបស់ប្រទេសកម្ពុជា ។ ស្នាដៃអក្សរសាស្ត្រទាំងនោះ បានប្រាប់អោយយើងដឹងពីរបៀបរៀបចំប្រាសាទ, កាលបរិច្ឆេទនៃការកសាងប្រាសាទ, កាលៈទេសៈនៃការកសាងបដិមា, បញ្ជីទាំងឡាយនៃអ្នកបំរើ និងបញ្ជីវត្ថុទាំងឡាយឧទ្ទិសថ្វាយសរណដ្ឋានពិសិដ្ឋ ( ប្រាសាទ ឬវិហារ ) ។ បញ្ជីទាំងឡាយនោះ ដែលគេសរសេរតែងជាភាសាសំស្ក្រឹត ពោរពេញទៅដោយពាក្យពេចន៍អក្សរសាស្ត្រ ហើយលើកតម្កើងកិត្យានុភាពព្រះមហាក្សត្រខ្មែរ អួតសរសើរពីរីរៈសកម្មភាពរបស់ព្រះអង្គ តាមបែបចម្រៀងសរសើរព្រះអាទិទេពសំខាន់ៗរបស់ឥណ្ឌា ដែលនៅក្នុងចម្រៀងនោះៗ គេបានអួតសរសើរវិរសកម្មភាពរបស់ព្រះអាទិទេព ។

លោក ហ្ស៊ក សីដេស, អតីតចាងហ្វាងសាលាបារាំងសែសចុងបូព៌ា, បានបកប្រែសិលាចារឹកនោះៗទាំងអស់ ហើយបានបង្ហាញអោយដឹងនូវខ្លឹមសារនៃសិលាចារឹកទាំងនោះ ។ បើទោះបីគ្រាន់តែជាការរៀបរាប់យ៉ាងសាមញ្ញខ្លីៗក្តី ឬជាប្រភេទចម្រៀងសរសើរព្រះអាទិទេពជាកំណាព្យក្តី ក៏សិលាចារឹកទាំងនោះ បានបង្ហាញនូវអត្ថប្រយោជន៍ខាងប្រវត្តិសាស្ត្រយ៉ាងសម្បើម ។ សិលាចារឹកទាំងនោះ មិនគ្រាន់តែបាននាំអោយស្គាល់សភាពពីមុននៃភាសាខ្មែរ ព្រមទាំងការវិវត្តន៍នៃតួអក្សរ ប៉ុណ្ណោះទេ, ប៉ុន្តែ វាបានជួយអ្នកប្រាជ្ញបារាំងសែសកសាងជាថ្មី នូវកាលប្បវត្តិនៃរាជ្យ និងកាលប្បវត្តិនៃប្រាសាទថែមទៀត ; វាបានផ្តល់ការបំភ្លឺទៅលើពង្សាវលី ( la géné-

alogie ) នៃរាជត្រកូលទាំងឡាយ និងបានបើកចំហនូវខណិកទស្សន៍ (aperçus) លើគំនិតសាសនារបស់ប្រទេសខ្មែរបុរាណ ។ សង្ខេបសេចក្ដីមក, អក្សរសាស្ត្រថ្មីនេះ បានប្រាប់អោយយើងដឹងពីប្រទេសខ្មែរបុរាណក្រោមទិដ្ឋភាពបីយ៉ាងគឺ ប្រវត្តិ-សាស្ត្រ, សាសនា និងយុទ្ធកថា ( ការពោលរៀបរាប់ពីចម្បាំង ) ។ ជាថ្មីម្ដងទៀត បើនិយាយតាមពិតទៅ, កំណាព្យទាំងអស់នោះជារបស់វប្បធម៌សំស្ក្រឹត ។

ជាដំបូង ចូរយើងពិនិត្យមើលទិដ្ឋភាពប្រវត្តិសាស្ត្រ ៖ ចូរយើងរំលឹកឡើងវិញថា នៅបណ្ដាសតវត្សជាដំបូងៗនៃសករាជរបស់យើង ( គ្រិស្តសករាជ ) មានព្រះរាជាណាចក្រពីរ ដែលទទួលអរិយធម៌ឥណ្ឌាគឺ ហ្វូណន និងចេនឡា ។ ព្រះរាជា-ណាចក្រហ្វូនណន គ្រប់គ្រងភាគខាងត្បូងនៃប្រទេសកម្ពុជា និងដែនដីកូសាំងស៊ីនបច្ចុប្បន្ន ; ព្រះរាជាណាចក្រនេះ វាតទីអំណាចរបស់ខ្លួនទៅលើដែនដីប្រទេសអាណ្ណាមភាគខាងត្បូង, ដែនដីមួយចំណែករបស់ប្រទេសសៀម និង ដែនដីមួយចំណែករបស់ឧបទ្វីបម៉ាឡាយូ ។ ព្រះរាជាណាចក្រចេនឡា រួមមានភាគខាងជើងនៃប្រទេសកម្ពុជា ហើយនិងដែនដីមួយចំណែកនៃប្រទេសឡាវភាគខាងត្បូង ។ គឺនៅទីនោះហើយដែលមានក្សត្រប្រទេសនៃជនជាតិកម្ពុជៈ ( la principauté des Kampujas ) តាំងនៅ ហើយដែលបានផ្ដល់នាមអោយប្រទេសកម្ពុជា ។

ចូរយើងរំលឹកផងដែរថា នៅអំឡុងឆ្នាំ ៥៤០, ព្រះរាជាណាចក្រហ្វូណនត្រូវបានចុះចាញ់ព្រះរាជាណាចក្រចេនឡា ហើយរដ្ឋទាំងពីរបានរួមបញ្ចូលគ្នា ក្រោមរដ្ឋអំណាចតែមួយដូចគ្នា បង្កបង្កើតទៅជាប្រទេសកម្ពុជាមុនសម័យអង្គរ នាសត-វត្សទី ៦ និងទី ៧ ។ នៅលើផ្លូវដ៏សោះកក្រោះឥតជីជាតិនេះ ដែលមានតែសិលាចារឹកបោះទុកជាតម្រុយ, ចូរយើងដើរឆ្លងមកសតវត្សទី ៨ ដែលនៅអំឡុងកាលនោះប្រទេសចេនឡា បានបំបែកចេញជាភូមិភាគពីរគឺ ចេនឡាដី ( ចេនឡាលើ ) ឋិតនៅភាគខាងជើង, និងចេនឡាទឹក ( ចេនឡាក្រោម ) ឋិតនៅភាគខាងត្បូង ។

មកដល់សតវត្សទី ៩ ព្រះបាទជយវរ្ម័នទី ២ បានស្ថាបនាព្រះរាជាណាចក្រអង្គរ ។ សិលាចារឹកមួយបានថែងថា ៖ « ដើម្បីភាពថ្កុំថ្កើងរបស់ប្រជារាស្ត្រ, នៅក្នុងខត្តិយជាតិដ៏បរិសុទ្ធយ៉ាងសុក្រឹតនៃមហាបទុមដែលគ្មានទង វាបានផុសឡើង បីដូចជារដូវផ្កាថ្មី » ។ តាំងពីពេលនោះមក, សិលាចារឹកទាំងឡាយគ្របដណ្តប់ដោយព្រះនាមដ៏រន្ទឺនៃព្រះរាជា, នៃរាជធានី, នៃប្រាសាទថ្មីៗ ។ ព្រះមហាក្សត្រទាំងឡាយនោះទ្រង់ត្រេកត្រអាលនឹងការកសាង ។ ព្រះអង្គជាចរកជន (nomades) ហើយទីក្រុងរបស់ព្រះអង្គ ត្រូវបានផ្លាស់ប្តូរទីតាំង ពីចុងម្ខាងទៅចុងម្ខាងនៃព្រះរាជាណាចក្រ ។ ក្នុងចំណោមទីក្រុងទាំងឡាយ, ចូរយើងរាប់ ៖ ហរិហរាលយបុរៈ នៅភាគអាគ្នេយ៍នៃទីក្រុងសៀមរាប ត្រង់រមណីយដ្ឋានរលួសបច្ចុប្បន្ន . យសោធរបុរៈ កសាងឡើងដោយព្រះបាទយសោវរ្ម័នទី ១ ដោយមានភ្នំបាខែងជាស្នូល . អង្គរធំ ជារាជធានីរបស់ព្រះបាទជយវរ្ម័នទី ៧ ដោយមានប្រាសាទបាយ័នជាមជ្ឈមណ្ឌល ។

ចាប់តាំងពីសតវត្សទី ១២ មក, សិលាចារឹកទាំងឡាយនៅតែនិយាយមិនអស់មិនហើយសរសើរព្រះមហាក្សត្រ និង ការស្ថាបនាដ៏ជាកុសលរបស់ព្រះអង្គ ៖ អង្គរវត្ត សាងសង់ឡើងសម្រាប់ជាទីបញ្ចុះព្រះបរមសពព្រះបាទសុរ្យវរ្ម័នទី ២ ។ ប៉ុន្តែ ជាពិសេស គឺព្រះបាទជយវរ្ម័នទី ៧ ជាស្ថាបនិកដ៏ចម្បងបំផុត ; គឺព្រះអង្គដែលបានស្រោចស្រង់ប្រទេសកម្ពុជា អោយផុតពី « សមុទ្រទុក្ខសោកនៃការរាតត្បាតរបស់ចាមក្នុងឆ្នាំ១១៧៧ ដែលបានជ្រមុជប្រទេសកម្ពុជាទៅក្នុងសមុទ្រទុក្ខនោះ» ។ ព្រះអង្គ មិនគ្រាន់តែបានសាងសង់ប្រាសាទបាយ័ន, បន្ទាយក្តី, តាព្រហ្ម, ព្រះខាន់ប៉ុណ្ណោះទេ, ប៉ុន្តែ ដោយព្រះអង្គជាពុទ្ធសាសនិកដ៏មោះមុតផង ទ្រង់បានបង្កើតមន្ទីរពេទ្យ ១០២ កន្លែង និងសាលាសំណាក់ជាច្រើន សម្រាប់បួជនីយេសក៍ដែលនឿយហត់ ធ្វើដំណើរលើផ្លូវនៃប្រទេសកម្ពុជា ។ បញ្ញត្តិទាំងឡាយ ( les édits ) របស់មន្ទីរពេទ្យ បានផ្តល់ពត៌មានយ៉ាងមានប្រយោជន៍ដល់យើង ស្តីពីការរៀបចំស្ថាប័ន

ដ៏សប្បុរសទាំងនោះ ដែលឋិតក្រោមពាក្យអធិដ្ឋានរបស់ព្រះពុទ្ធព្យាបាលជំងឺ (le Bouddha guérisseur) ដ៏ជា «គ្រូថ្នាំដែលមានរស្មីចែងចាំង ដូចកែវចរណៃ» ។

ក្រោយសម័យកាលទាំងបី នៃប្រវត្តិសាស្ត្រខ្មែរ : សម័យកាលហ្វូណន, សម័យកាលមុនអង្គរ និងសម័យកាលអង្គរ, គំនូសបន្ទាត់កោងឡើង (la courbe ascendante) ដែលទើបតែបានដល់ចំណុចខ្ពស់បំផុតនោះ, ក៏ត្រូវធ្លាក់ចុះមកវិញ។

ប្រវត្តិសាស្ត្រដ៏អស្ចារ្យ នឹងត្រូវធ្លាក់ក្នុងអន្ធការភាព ក្រោមការវាតត្បាតរបស់ជនជាតិថៃ ; ប៉ុន្តែ ទុក្ខវេទនានឹងនៅមានវែងឆ្ងាយទៀត, ពីព្រោះទាល់តែមកដល់ពាក់កណ្ដាលសតវត្សទី ១៥ ទើបព្រះរាជវាំងបានលើកពីអង្គរ ដើម្បីមកតាំងទីនៅឯភ្នំពេញ ។ សៀវភៅជាសិលាចារឹកបុរាណនឹងត្រូវបិទ, ការចារឹកផ្សេងទៀតនឹងត្រូវចារដោយទឹកថ្នាំវិញ, ប៉ុន្តែ ការចារឹកទាំងនោះ នឹងបានជាចំណែកមួយនៃអក្សរសាស្ត្រសម័យ, ហើយមានចរិតលក្ខណៈផ្សេងពីមុន ។

ឥឡូវនេះ, យើងនិយាយពីរ-បីម៉ាត់ អំពីទិដ្ឋភាពសាសនា ដែលអក្សរសាស្ត្រនៅលើថ្មបានប្រាប់អោយយើងដឹង ។ នៅក្នុងប្រទេសកម្ពុជាបុរាណ, មានភាពសាំញ៉ាំណាស់ខាងសាសនា និង មានការលាយចូលគ្នាដ៏គួរអោយឆ្ងល់ រវាងសាសនាផ្សេងៗគ្នា ។ សាសនាឥណ្ឌាពីរគឺ លទ្ធិព្រាហ្មណ៍ និងលទ្ធិព្រះពុទ្ធ ( ពុទ្ធ-សាសនា ) ឋិតនៅបានជាមួយគ្នា ។ នៅក្នុងលទ្ធិព្រាហ្មណ៍, ការគោរពបូជាព្រះសិវៈ និងការគោរពបូជាព្រះវិស្ណុ តែងមានឥទ្ធិពលជាងគ្នាម្តងម្នាក់ ។ ចូរយើងរំលឹកផងដែរនូវនាមបរិហារៈ, ជាតួអង្គរួមផ្សំគ្នា ត្រូវបានគេគោរពយ៉ាងខ្លាំងនៅសម័យកាលហ្វូ-ណន និងសម័យកាលមុនអង្គរ, ដែលជាសហភាពរួមជាអាទិទេពមួយអង្គតែ រវាងព្រះវិស្ណុ និងព្រះសិវៈ ។ ចំពោះពុទ្ធសាសនាវិញ, មាននិកាយពីរ ដែលត្រូវបានគេរាប់អាន ឬលែងរាប់អានជាបន្តបន្ទាប់គឺ និកាយខាងត្បូង ( ទក្ខិណនិកាយ ) ឬហីនយាន ដែលគេបកប្រែថា « យានតូច » និងនិកាយខាងជើង ( ឧត្តរនិកាយ )

ឬមហាយាន ដែលគេបកប្រែថា « យានធំ » ។ នៅក្នុងគាថានមស្សការពុទ្ធសាសនា, ត្រៃសរណគមន៍ គឺមាននាមបី តែងត្រូវបានរំលឹកជាដរាប ៖ ព្រះពុទ្ធ, លោកេស្វរៈដ៏ជាតួអង្គ មានប្រាជ្ញាញាណ និងមេត្តាធម៌, និងប្រាជ្ញាបារមីតា ឬជាតួអង្គតំណាងសម្មាសម្ពោធិ (la Science parfaite) ។ នៅទីបញ្ចប់ ចូរយើងបន្ថែមទិដ្ឋ-ភាពសាសនាមួយទៀត ដែលចម្លែកពីគេនៅក្នុងប្រទេសកម្ពុជាសម័យបូរាណ គឺការគោរពបូជាទេវរាជ (Dieu Roi) ដែលគេប្រាថ្នាចង់អោយព្រះរាជា ក្រោយពីសោយទីវង្គតទៅ បានទៅជាទេព្តា (Dieu) ; ការគោរពបូជានេះ ត្រូវបានព្រះបាទជយវរ្ម័នទី ២ ចាត់តាំងឡើង ។ សាសនារបស់ថ្នាក់ដឹកនាំ មិនដែលមានឯកភាពគ្នាទេ ។ តាមជាក់ស្តែង, លទ្ធិសិវៈក្តី, លទ្ធិវិស្ណុក្តី ឬលទ្ធិព្រះពុទ្ធក្តី សុទ្ធតែជាជំនឿនាំចូលពីក្រៅទាំងអស់, ហើយព្រះរាជាទាំងឡាយ, រាជវាំង និងពួកនាម៉ឺន ( អភិជន ) បានប្រកាន់យកសាសនាទាំងនោះ ទុកដូចជាវប្បធម៌មួយដ៏ប្រណីត ។ សិលាចារឹកបានប្រាប់អោយយើងដឹងម្យ៉ាងទៀតថា អារ្យធម៌អង្គរ គឺឋិតទាំងស្រុងនៅក្នុងកណ្តាប់ដៃនៃរបបអប្បជនាធិបតេយ្យវណ្ណៈអភិជន ( Une oligarchie aristo-cratique, ពោលគឺ ជារបបគ្រប់គ្រងមួយ ដែលអំណាចទាំងអស់ធ្លាក់នៅក្នុងកណ្តាប់ដៃនៃជនភាគតិចជាវណ្ណៈអភិជន ) ; មុខងារជារាជការធំៗទាំងអស់ ត្រូវបានសមាជិកនៃរាជត្រកូលកាន់កាប់ ។ នៅមានគ្រួសារព្រាហ្មណ៍បុរោហិតយ៉ាងច្រើនផងដែរ, ដែលជួនកាលភ្ជាប់ខ្លួនជាមួយវាំង ។ ក្រុមណា ក៏ដូចនៅក្រុមណាដែរ សុទ្ធតែតំណាងវប្បធម៌ហិណ្ឌូ និងតំណាងវរជនជាបញ្ញវន្ត, ហើយសិលាចារឹកបានអោយយើងដឹងទៀតថា មានវរជនសំខាន់ៗខ្លះ មានចំណេះយ៉ាងទូលំទូលាយខាងអក្សរសាស្ត្របូរាណនៃប្រទេសឥណ្ឌា ។

ដោយហេតុនេះ, តាមការក្រឡេកមើលដ៏សង្ខេប នូវអក្សរចារឹកនៅលើថ្មនេះ, យើងបានឃើញលេចឡើងរួចហើយនូវប្រទេសកម្ពុជាមួយមានវណ្ណៈអភិជន

ដែលទទួលយកវប្បធម៌ពិសិដ្ឋពីប្រទេសឥណ្ឌាបុរាណ, នូវប្រទេសកម្ពុជាមួយដែលព្រះរាជាទាំងឡាយតែងប្ដូងសួងអោយមានភាពរុងរឿង និងមហិទ្ធិឫទ្ធិ, នូវប្រទេសកម្ពុជាមួយកាន់សាសនា ដែលរចនាសម្ពន្ធទាំងអស់ ឋិតនៅលើការប្រតិបត្តិ ហើយដែលអំពើទាំងអស់ជាបុគ្គលក្ដី ជាសាធារណៈក្ដី អាស្រ័យលើជំនឿ និងលើពិធីដែលបានបំពេញ, នូវប្រទេសកម្ពុជាមួយអ្នកបង្កើត ( Un Cambodge créateur ) ដែលកសាងសម្រាប់អនាគត និងអនុលោមតាមឧត្តមគតិកាន់សាសនាតឹងរ៉ឹង ហើយដែលប្រាសាទទាំងអស់មានន័យតាមសាសនា, នូវប្រទេសកម្ពុជាមួយសក្តិភូមិ និងធ្វើចម្បាំងដណ្ដើមអំណាច, នៅទីបញ្ចប់ នូវប្រទេសកម្ពុជាមួយដ៏មានអរិយធម៌ល្អលាស់, ដ៏ខ្លាំងពូកែក្នុងគំនូសបន្ទាត់កោងឈានឡើងរបស់ខ្លួន (sa courbe ascendante) ប៉ុន្តែ ឈ្លាសវៃ ហើយរុងរឿងក្នុងការស្រុតចុះរបស់ខ្លួន ។

ដើម្បីប្រើប្រាស់ជាចំណាងរវាងផលិតកម្មបុរាណ និងផលិតកម្មសម័យរបស់ប្រទេសកម្ពុជា, ឥឡូវ ចូរពិនិត្យមើលអក្សរចារឹកលើថ្មម្ដងទៀត ។ ម្ដងនេះគឺសិលាចារឹកសម័យថ្មី នៃអង្គរវត្ត នាសតវត្សទី ១៧ និងទី ១៨ ។ សិលាចារឹកទាំងនោះ ត្រូវបានចារជាភាសាខ្មែរ ហើយឆ្លាក់លើសសរ ។ វាបានឆ្លុះបញ្ចាំងអោយឃើញនូវការប្រែប្រួលកើតមានឡើង នៅក្នុងវប្បធម៌របស់ប្រទេស ។ ដោយហេតុនេះ, ភាសាអ្នកប្រាជ្ញ, លែងមានជាភាសាសំស្រ្កឹតទៀតហើយ ; ឥឡូវនេះ, ភាសាអ្នកប្រាជ្ញ គឺជាភាសាបាលីដែលជាភាសារបស់ពុទ្ធសាសនាខាងទក្ខិណទិស ( ទិសខាងត្បូង ) ។ ចាប់ពីពេលនោះមក គឺនិកាយនេះហើយដែលចេញមកពីប្រទេសសីឡង់ (ស្រីលង្កា) ឆ្លងតាមរយៈប្រទេសសៀម បានមកជំនួសទាំងស្រុងនូវព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ខាងឧត្តរទិស (ទិសខាងជើង) ។ សិលាចារឹកសម័យថ្មីទាំងឡាយនោះ មានលក្ខណៈអក្សរសាស្រ្តច្រើនជាងសិលាចារឹកសម័យបុរាណ ; សិលាចារឹកទាំងនោះ និទានរៀបរាប់ពីបូជនីយសក៍, ពិពណ៌នាអំពីពិធីបុណ្យសាសនា ; សិលា-

ចារឹកទាំងអស់ សឹងពោរពេញដោយពាក្យពេចន៍បញ្ជិតបញ្ជៀងទៅរកព្រះជីវភាពរបស់ព្រះពុទ្ធ ហើយមានភាពក្លៀវក្លាដោយសទ្ធាមោះមុត (ពលវសទ្ធា) ដ៏ពិតប្រាកដ ។ ក្នុងបណ្ដាគុណសម្បត្តិខ្លះៗ, សិលាចារឹកទាំងនោះ មានអត្ថប្រយោជន៍ផងដែរ ក្នុងការផ្ដល់ពត៌មានដល់យើងដ៏ជាក់លាក់បង្គួរ ស្ដីពីវប្បធម៌ អក្សរសាស្ត្ររបស់ប្រទេសកម្ពុជាសម័យថ្មី ។ សិលាចារឹកមួយ, ដែលចុះកាលបរិច្ឆេទឆ្នាំ ១៧០២ គឺជាឧទាហរណ៍ដំបូងគេនៃកំណាព្យខ្មែរ ដែលបានចារឹក ។

ប្រសិនបើផលិតកម្មអក្សរសាស្ត្រសម័យថ្មីចំពួ ហាក់ដូចជាគ្មានចំណងណាមួយភ្ជាប់ទៅនឹងមហាអរិយធម៌ខ្មែរក៏ដោយ, ក៏ផលិតកម្មនោះមិនបានឃ្លាតឆ្ងាយរហូតដល់ថ្នាក់ជាផលិតកម្មដទៃស្រឡះ ពីមហាអរិយធម៌ខ្មែរនោះដែរ គឺដូចជាយុទ្ធកថាខ្មែរ ឈ្មោះរាមកេរ្តិ៍ (១) ។ នៅក្នុងយុទ្ធកថានោះ, គេបានពោលសរសើរពីវីរសកម្មភាពរបស់វីរជន គឺតួអង្គព្រះរាម, ជាអវតារនៃទេវៈគ្រឹស្ណៈ ។ មហេសីដ៏ល្អរបស់ព្រះរាម, ព្រះនាមសីតា ត្រូវបានយក្សដ៏គួរស្មៀមឆក់យកទៅកោះសីឡង់ ។ ក្រោយពីឧប្បត្តិហេតុរាប់មិនអស់ត្រូវបានជំនះ, ព្រះរាមដោយមានព្រះអនុជព្រះនាមព្រះលក្ស្មណ៍ និងទ័ពពានរជួយផង ក៏ដណ្ដើមយកព្រះនាងសីតាបានមកវិញ ។ អត្ថបទនេះ, នៅគ្រប់តែឧបកថា ( épisodes ), ដែលប្រហាក់ប្រហែលនឹងអត្ថបទរាមាយណៈរបស់ឥណ្ឌាដែរ, គឺជាសំណល់អក្សរសាស្ត្រចុងក្រោយគេនៃមហាសម័យកាល នៃអរិយធម៌ប្រទេសកម្ពុជា ។ ប៉ុន្តែ វាមានទិន្នន័យថ្មីៗ ដែលគ្មានសោះនៅក្នុងរាមាយណៈឥណ្ឌា ។ ទិន្នន័យទាំងនោះ ហាក់ដូចជាមានសំណល់ច្រើន ហើយទាក់ទងទៅនឹងអត្ថន័យផ្សេងៗក្រៅពីអត្ថរសសំស្ក្រឹត ។ ដោយពិនិត្យសិក្សារឿងរាមកេរ្តិ៍ទៅ, គេអាចសម្លឹងមើលឃើញយ៉ាងត្រឹមត្រូវ ថាតើត្រឹមកំរិតណាអានុភាពនៃវប្បធម៌សំស្ក្រឹតបានបំប្លែងធាតុដើម ( l'élément primitif ), ហើយរហូត

(១) កិត្តិសព្ទនៃព្រះរាម

ដល់ចំណុចណា ទើបខ្លឹមសារចាស់ប្រជាប្រិយ (les vieux thèmes populaires) ត្រូវបានរលាយរលំ ហើយជាន់លើគ្នានៅក្នុងសាច់រឿង ។ ចម្លាក់ក្រឡោត (les bas-reliefs) នៃប្រាសាទ, រូបភាពប្រជាប្រិយបានបង្ហាញយ៉ាងសម្បូរ នូវប្រវត្តិនៃព្រះរាម ដែលនៅទីកន្លែងខ្លះ គេបានប្រើប្រាស់ជាប្រធានបទសម្រាប់ក្រុមល្ខោនខ្មែរជាច្រើនយកទៅលេង ។ រឿងរាមកេរ្តិ៍ មើលជក់ជាប់ចិត្តណាស់ ពីព្រោះប្រទេសកម្ពុជា ដែលយើងបានឃើញតាមរយៈរឿងរាមកេរ្តិ៍ គឺជា មហាប្រទេសកម្ពុជា ទទួលអរិយធម៌ឥណ្ឌា (le grand Cambodge indianisé) ដ៏ល្បីល្បាញដោយរឿងព្រេង មានវីរបុរសខ្លាំងពូកែ និងពោរពេញដោយអច្ឆរិយហេតុផង, និងជាប្រទេសកម្ពុជាប្រជាប្រិយ, ឈ្លើសឈ្លួលជានិច្ចឡើងទៅរកអត្តរសជីនាន់ដើមផង ។

សម្រង់អត្ថបទមួយចំនួន ដែលរួមផ្តុំក្រោមចំណងជើងថា *ត្រៃភូមិ* រួមទាំង*រឿងរាមកេរ្តិ៍* ផង គឺជា សំណល់អក្សរសាស្ត្រតែមួយគត់នៃប្រទេសកម្ពុជាបូរាណ ។ ចំណែកឯកម្រងផលិតកម្មសម័យវិញ, ផលិតកម្មនោះ មានរួមជាស្នាដៃជាភាសាខ្មែរ និងភាសាបាលី, ជាស្នាដៃសរសេរជាពាក្យរាយ និងមានជាស្នាដៃផ្សេងទៀតសរសេរជាកំណាព្យ ។ ម្យ៉ាងទៀត ជួនកាលក៏មានស្នាដៃដដែលត្រួតគ្នា ដែលមួយសរសេរជាពាក្យរាយ, មួយទៀតសរសេរតែងជាពាក្យកាព្យ ។ អត្ថបទខ្លះត្រូវបានគេចារនៅលើ *ស្លឹករឹត* ចែកចេញជាខ្សែ, អត្ថបទខ្លះទៀតត្រូវបានគេសរសេរដោយដៃនៅលើក្រដាស ដែលគេហៅថា *ក្រាំង*, ដែលបត់ជាផ្នត់ៗ ដូចជាឧបករណ៍ភ្លេងមួយបែប ហៅថា *អាគ័រដេអុង* ។ នៅទីបំផុត ក៏មានសៀវភៅបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ នៅក្រុងភ្នំពេញ ។

អក្សរសាស្ត្រសាសនា បើនិយាយអោយចំទៅ, មិនមែនជាអក្សរសាស្ត្រខ្មែរទេ, ពីព្រោះភាគច្រើននៃអក្សរសាស្ត្រ ត្រូវបានសរសេរជាភាសាបាលី ។ ប៉ុន្តែភាសាបាលីនោះ ត្រូវបានសរសេរនៅក្នុងប្រទេសខ្មែរ ជាអក្សរខ្មែរពិសេសម្យ៉ាង

ដែលគេហៅថា អក្សរមូល ។ ភាសាបាលី, ដែលជាភាសាសាសនារបស់ប្រទេសសិឡុង, សៀម, ភូមា និងលាវ, ត្រូវបានគេចារ ឬសរសេរនៅក្នុងប្រទេសនីមួយៗក្នុងបណ្តាប្រទេសទាំងនោះ ដោយតួអក្សររបស់គេរៀងៗខ្លួន ។ ម្យ៉ាងទៀត ក៏មានសៀវភៅបកប្រែ និងសៀវភៅអត្ថាធិប្បាយជាភាសាខ្មែរ អំពីអត្ថបទទាំងឡាយខ្លះដែលប្រើជាញឹកញយ ។ នៅក្នុងក្រុងភ្នំពេញ ព្រះសង្ឃបានរក្សាទុកអត្ថបទសរសេរដោយដៃនៅក្នុងបណ្តាវត្តសំខាន់ៗ ។ អត្ថបទដែលចាស់ទុំបំផុត ច្រើនតែមានចុះកាលបរិច្ឆេទនៅចុងសតវត្សទី ១៨ ឬក៏ដើមសតវត្សទី ១៩ ។ ផ្នែកទាំងបីនៃគម្ពីរសាសនា ដែលគេហៅថា *ព្រះត្រៃបិដក* ឬ ល្អីបី នោះមាន ៖ ព្រះវិន័យ, ព្រះសូត្រ និងព្រះអភិធម្ម ។ ជាការពិត, កម្រងធម៌សូត្រ ដែលគេនិយមប្រើក្នុងពិធីបុណ្យផ្សេងៗ ត្រូវបានគេបកប្រែជាភាសាខ្មែរយ៉ាងសម្បូរ, ព្រមទាំងអត្ថបទទាក់ទងនឹងវិន័យលោកសង្ឃ ក៏ដូចជាអត្ថបទ*ជាតក*, ឬរឿងនិទានអំពីជាតិពីមុនទាំងឡាយរបស់ព្រះពុទ្ធ ។ អត្ថបទទាំងនោះ ត្រូវបានគេចេះចាំរត់មាត់ ហើយក្លាយទៅជាផ្នែកមួយនៃអក្សរសាស្ត្ររឿងនិទាន និងរឿងប្រជាប្រិយ ។ អត្ថបទទាំងឡាយនោះ ក៏ត្រូវបានចាត់ទុកជាក្របខណ្ឌមួយយ៉ាងសមស្រប សម្រាប់ឃុំគ្រងរតនសម្បត្តិទាំងអស់ នៃប្រពៃណី និងទំនៀមទម្លាប់របស់អ្នកស្រុក, ដែលបានទទួលយក « នូវត្រាសម្គាល់របស់ពុទ្ធសាសនា » បើតាមវោហារស័ព្ទរបស់លោកល្វី ហ្វីណូត៍ ។ អត្ថបទដ៏ល្បីល្បាញបំផុតនៅក្នុងប្រទេសខ្មែរ គឺរឿងវេស្សន្តរ, ជាស្តេចដែលធ្វើទានបរិច្ចាគរហូតដល់អោយជាទាននូវបុត្រ និងមហេសីរបស់ព្រះអង្គ ។ នៅក្នុងអត្ថបទទាំងនោះ, មានការបំផុសគំនិតមហាបរិច្ចាគ ។ ចំណែកសេចក្តីអធិប្បាយជាទ្រឹស្តីវិញ, វាមានភាពត្រឹមត្រូវទៅតាមលទ្ធិដ៏បរិសុទ្ធនៃពុទ្ធសាសនាបូរាណ ដែលមូលដ្ឋាននៃលទ្ធិនេះ ឋិតនៅលើទិន្នន័យ (គោលការណ៍សំខាន់ៗ ) នៃការលុបបំបាត់អោយអស់អាត្មាជាបុគ្គល, លើការស្គាល់អរិសច្ចៈទាំងបួនដែលបង្ហាញនៅក្នុងនេះថា អ្វីៗទាំង

អស់ គឺជាទុក្ខៈ, លើជំនឿចំពោះការជាប់ទាក់ទងគ្នា ចៀសមិនផុតនៃហេតុ និងផល នៅក្នុងខ្សែង្វាក់នៃកំណើតថ្មីជាបន្តបន្ទាប់, និងលើការអះអាងថាការរំដោះផុតពីខ្សែសង្វាក់ជាប់គ្នានេះ មាននៅក្នុងការបំបាត់អោយអស់អាត្មាជាបុគ្គលដែលបង្កើតឡើងដោយតណ្ហា (ចំណង់) ។ បើនិយាយតាមពិតទៅ, ប្រទេសកម្ពុជាជាប្រទេសកាន់ពុទ្ធសាសនា មានអត្ថបទទាំងនោះដ៏សម្បូរហូរហៀរ ។ លទ្ធិដ៏បរិសុទ្ធខាងបញ្ញា, ដែលដំបូងឡើយ គ្រាន់តែជាទស្សនវិជ្ជាសោះ, បានក្លាយទៅជាសាសនាដ៏ពិតប្រាកដមួយទៅវិញ, នៅទីនេះក៏ដូចជានៅទីផ្សេងទៀតដែរ, និងត្រូវបានជិតដាមដោយមនោសញ្ចេតនា ធ្វើអោយព្រះពុទ្ធទៅជាព្រះអាទិទេព សម្រាប់គេបន់ស្រន់ ; លទ្ធិដ៏សុទ្ធសាធនេះ ក៏បានក្លាយទៅជាមានអានុភាពពូកែផងដែរ, ជាវិធីព្យាបាលរោគ ពោលគឺ ជាលទ្ធិទទួលយកនូវអបិយ្យជំនឿ និងក្បួនផ្សំឱសថព្យាបាលជំងឺ។

អក្សរសាស្ត្រខាងច្បាប់ ត្រូវបានបង្ហាញអោយឃើញតាមច្បាប់នានា (codes) ដែលតាមទ្រង់ទ្រាយបច្ចុប្បន្នរបស់ច្បាប់នោះៗ មានចំណាស់មិនហួសពីដើមសតវត្សទី ១៧ ទេ ។ ដំបូងបង្អស់ គឺជាកម្រងនៃព្រះរាជបញ្ញត្តិ ( décisions royales ) ដែលត្រូវបានកែសម្រួលជាថ្មី ដោយព្រះមហាក្សត្របន្តបន្ទាប់, ក្រោយពីបានការយល់ព្រមពីរដ្ឋអំណាចជាន់ខ្ពស់ខាងព្រហ្មទណ្ឌរួចហើយ ។ ដកស្រង់ចេញមកពីច្បាប់បុរាណសំស្ក្រឹត, ច្បាប់ទាំងឡាយនោះ មានរាយប៉ាយដោយដំបូន្មានសីលធម៌ដ៏មានអត្ថន័យខ្ពស់ស្ដីពីចរិយាមារយាទ និងប្រពៃណីនៃជនជាតិខ្មែរ ។ ប្រជាជនមិនចេះច្បាប់ទាំងនោះទេ, ប៉ុន្តែផ្ទុយទៅវិញ, គេបានចេះចាំរត់មាត់នូវវគ្គឃ្លា ជាសុភាសិតមួយចំនួនធំ ដែលមានបង្កប់គោលការណ៍សីលធម៌ធម្មតា និងក្បួនច្បាប់សម្រាប់ជីវភាពរាល់ថ្ងៃ ។ គឺតាមរយៈអក្សរសាស្ត្រជាពាក្យកាព្យ, ផ្ទុកច្រើនដោយពាក្យពេចន៍បូរាណនេះហើយ ដែលឪពុកម្ដាយទាំងឡាយ តែងផ្ដល់បន្តទៅអោយកូនចៅរបស់គេ នូវគតិបណ្ឌិតរបស់ដូនតានោះ ។ ករណីយកិច្ចរបស់កូន ត្រូវគោរព

និងស្រឡាញ់ឪពុកម្ដាយ, ការចេះគួរសមក្នុងសង្គម, ភាពសមរម្យខាងក្រៅ, កាតព្វ-កិច្ចរបស់កូនប្រុសស្រី, រចនាសម្ពន្ធផ្ទៃក្នុងទាំងអស់របស់សង្គមខ្មែរ មានសរសេរនៅក្នុងច្បាប់ទាំងនោះ ក្រោមរូបភាពជាសុភាសិត និងភាសិត ។

អក្សរសាស្ត្របច្ចេកទេស មានជាអត្ថបទតូចៗយ៉ាងសម្បូរហូរហៀរ ទាល់តែជនជាតិខ្មែរជាច្រើនចេះចាំរត់មាត់ស្ដីពីឱសថធម្មតា, តារាសាស្ត្រ, ការទស្សន៍ទាយ, វិធីផ្សំឱសថ, ស្ថាបត្យកម្ម, លោកធាតុវិទ្យា ដែលមានចំណងជើងពីរបីនេះជាភស្តុតាងគឺ : អំពីឱសថ ៨៣ មុខ, អំពីអាយុកាលនៃលោក, អំពីទេវលោក, -ល-។ បន្ថែមទៅលើក្រុមអក្សរសាស្ត្របច្ចេកទេសនេះ, គួររាប់បញ្ចូលអត្ថបទ ស្ដីពីកំណាព្យខ្មែរ, ការពិពណ៌នាពីពិធីបុណ្យប្រចាំឆ្នាំ និងវិធីប្រែសំស្ក្រឹត ជាភាសាខ្មែរ ។

ប្រវត្តិសាស្ត្រ ត្រូវបានគេកត់ត្រាទុកក្នុងពង្សាវតារ ( annales ) របស់គ្រួសារ និងរបស់វត្តអារាម ហើយនិងនៅក្នុងព្រះរាជពង្សាវតារ ដែលស្ទើរតែជានិច្ច-កាល មានភ្ជាប់ជាមួយបញ្ជីនៃព្រះមហាក្សត្រ ; ប៉ុន្តែប្រវត្តិសាស្ត្រដែលពោលក្នុងទីនេះ ពុំដូចប្រវត្តិសាស្ត្រដែលបស្ចិមប្រទេសបានយល់នោះទេ, ពីព្រោះប្រទេសអាស៊ី វាស់ព្រឹត្តិការណ៍ខាងអាណាចក្រទាំងឡាយតាមខ្នាតមួយផ្សេងពីខ្នាតរបស់យើង ( អ្នកបស្ចិមប្រទេស ), ហើយជាញឹកញយ រឿងនិទានដើរតួសំខាន់ផង ។ នៅក្នុងអត្ថបទទាំងឡាយនោះ ពិធី និងបុណ្យទានត្រូវបានគេរៀបរាប់ពង្រីកហួសហេតុ, ចំណែកឯព្រឹត្តិការណ៍នយោបាយវិញ ត្រូវបានគេរៀបរាប់សង្ខេបតែពីរបីបន្ទាត់ប៉ុណ្ណោះ ។ ផ្នែករឿងនិទាន ត្រូវបានគេបញ្ចូលជាលើកទីមួយហើយទៅក្នុងផ្នែកប្រវត្តិសាស្ត្រ ដោយកវីម្នាក់នៅក្នុងវាំងរបស់ព្រះបាទនរោត្តម, ក្នុងខែមីនា ១៨០៣, ហើយប្រវត្តិសាស្ត្រនោះត្រូវបានបន្តមកដល់រាជព្រះបាទស៊ីវត្ថិទៀត ។ នៅក្នុងនេះ, មានរឿងនិពន្ធធ្វើអោយសៀវភៅល្អ ដែលនៅក្នុងសៀវភៅនេះ អាចអោយមើលឃើញអរិយធម៌ខ្មែរទាំងអស់លាយឡំដោយភាពរុងរឿងនិងការក្បៀបសង្កត់, ដោយ

ទុក្ខភាព និងជោគជ័យ, ហើយត្រូវចះត្រួចង់ដោយព្រះភក្ត្ររបស់ព្រះរាជាស្ថាបនិក ទាំងឡាយនោះ ។

ល្ខោនខ្មែរឋិតនៅត្រឹមដំណាក់ជាវិនាដកម្ម មន្តអាគម សាសនា (Drame magico-religieux), ពីព្រោះវាគ្មានអ្វីក្រៅពីការលេងរឿងធ្វើកាយវិការតាមអត្ថបទសម្រាប់សូត្រ ឬច្រៀង ; គឺជារបាំច្រើនជាងរឿងល្ខោន : ស្ត្រីរបាំធ្វើត្រាប់ដោយកាយវិការ, ដោយអនុលោមតាមប្រពៃណីបុរាណនាំយកពីស្រុកសៀម, នូវឧបកថាដកស្រង់ចេញមកស្ទើរតែជានិច្ចកាល ពីរឿងនិទានរបស់ព្រះរាម ឬអំពីរឿងវិនាដកម្មអេណាវ ; រឿងសល់ពីនេះ នៅក្នុងបញ្ជីរឿង គឺជារឿងសៀមសុទ្ធសាធ ។ ប៉ុន្តែ ចាប់តាំងពីប៉ុន្មានឆ្នាំមកនេះ, មានលេចឡើងល្ខោនខ្មែរដ៏ក្មេងខ្ចី, សព្វថ្ងៃកំពុងពេញសន្ទុះ ។ ដោះដៃចេញពីប្រធានបទប្រពៃណី និងពីតួអង្គនឹងថ្កល់, ល្ខោនទំនើបនោះ អនុញ្ញាតអោយអ្នកដើរតួក្មេងពីបីនាក់ សាកល្បងទេពកោសល្យរបស់គេ ។ ម្តងនេះ គេលែងលេងរឿងប្រវត្តិសាស្ត្រទៀតហើយ, ប៉ុន្តែ លេងរឿងជីវិតជាក់ស្តែង ដែលធ្វើអោយអ្នកដើរតួក្នុងរឿងពោរពេញដោយសន្ទុះចិត្ត និងធ្វើអោយស្ថានភាពរឿងមានកំប្លែង ។ ក្នុងវិស័យនេះ ជនជាតិខ្មែរមានការកោតសរសើរយ៉ាងធំធេងចំពោះលោកម៉ូលីយ៉ែរ (Molière) ; ភាគច្រើននៃស្នាដៃរឿងល្ខោនរបស់គេ មានដំណើររឿងប្រហាក់ប្រហែលនឹងរឿងកំប្លែង*របស់យើង* (ជនជាតិបារាំង ) នាមជ្ឈិមសម័យ ហើយគេបានឆ្លៀតប្រើអោយមានប្រយោជន៍នូវអំណោយទានដ៏អស្ចារ្យរបស់គេខាងការសន្ទនា និង ការឆ្លើយតបដោយឥតព្រាងទុកមុន ។

ឥឡូវនេះ ចូរយើងពិនិត្យមើលចម្រៀងដែលមានអត្ថិភាពក្រោមរូបភាពយ៉ាងសាមញ្ញ របស់វាផង និង ក្រោមរូបភាពជាទំនុកច្រៀងឆ្លើយឆ្លងគ្នាផង ។ ចម្រៀងដោយមានដំណើររឿងប្រឌិត គឺជាប្រភេទនិយមចូលចិត្តបំផុតនៅប្រទេស

កម្ពុជា ។ ជនជាតិខ្មែរមិនគ្រាន់តែជាអ្នកស្រឡាញ់ចូលចិត្តភ្លេងប៉ុណ្ណោះទេ, ប៉ុន្តែគេជាអ្នកចេះច្រៀងដោយឥតព្រាងទុកដ៏ចំណាន ហើយចម្រៀងគឺជាក្របខណ្ឌមួយដែលនៅក្នុងក្របខណ្ឌនេះ ជនជាតិខ្មែរអាចសំដែងគំនិតយោបល់របស់ខ្លួនបានដោយសយម្ភូតភាព (ដំណើរកើតមានដោយឯកឯង) ។ រង្វាស់កំណាព្យនៃចម្រៀងគឺជាការងាយបំផុត, សូម្បីអ្នកស្រុកទូទៅ ក៏គ្មានការលំបាកអ្វីនឹងតែងកំណាព្យតាមបែបនេះដែរ ។ ចិត្តពោរពេញដោយមនោសញ្ចេតនា និងទោរទន់ទៅរកការស្រមើស្រមៃនៃប្រជាជនខ្មែរ ត្រូវបានសំដែងចេញមកតាមបែបបទមួយ ដ៏ស្និទ្ធស្នាលក្នុងការពិតដ៏គួរអោយរំភើបចិត្ត ។ មនោសញ្ចេតនាដ៏ជ្រាលជ្រៅមួយ ត្រូវបានសាយភាយចេញមកពីកំណាព្យទាំងអស់ និងពីសំឡេងពិរោះទាំងអស់របស់ប្រជាជននៃប្រទេសនេះ : គឺមនោសញ្ចេតនាស្រងូតស្រងាត់ ។ ប៉ុន្តែ ចរិតលក្ខណៈផ្សេងៗទៀតនៃទឹកចិត្តជនជាតិខ្មែរ ក៏ឃើញមាននៅក្នុងនោះដែរ ដូចជា : ភាពឆោតល្ងង់ជឿឥតសមហេតុផល, ភាពទន់ភ្លន់ដ៏ធំធេងនៃប្រពៃណី, ការជាប់ជំពាក់ចិត្តដ៏ជ្រៅក្នុងទម្លាប់ចាស់ ក្នុងជីវភាពជាអ្នកស្រែ ក្នុងភាពឋិតថេរនៃក្រុមគ្រួសារ, ភាពចូលចិត្តតែលេងឡេះឡោះ ឥតខ្វល់ចំពោះជីវភាពប្រកបដោយភាពអសកម្ម ឬដោយការបណ្តែតបណ្តោយតាមព្រហ្មលិខិត, សេចក្តីត្រេកត្រអាលដ៏ជ្រៅក្នុងកាមគុណ, ចំណូលចិត្តក្នុងភាពសោះអង្គើយ ហើយនិងសង្វាក់ជីវិតឥតស្ទុះស្ទា ។ ចម្រៀងទាំងនោះជាច្រើន គ្មានអ្វីក្រៅពីការកត់សំឡេងជូនរណ្តំធ្វើអោយអណ្តែតអណ្តូងមួយខណៈប៉ុណ្ណោះ, ប៉ុន្តែ នៅក្នុងការកត់សំឡេងរណ្តំដ៏ខ្លីនេះ គេឃើញមានភាពសុខុម និងភាពរម្យទមនៃអតីតមហាអរិយធម៌មួយ ។ ប្រជាជននេះ ចូលចិត្តណាស់ច្រៀងរៀបរាប់ពីសេចក្តីទុក្ខព្រួយរបស់ខ្លួន, សូម្បីតែកាលណាគេមានសេចក្តីស្នេហា ក៏គេច្រៀងសំដែងសេចក្តីឈឺចាប់ពីសេចក្តីស្នេហារបស់គេ, សូម្បីតែពេលគេសប្បាយរីករាយ ក៏គង់មានសំដីបង្អើរយ៉ាងស្រាលអំពីសេចក្តីស្លាយ

ស្រណោះដែរ ។

រឿងប្រលោមលោក ច្រើនតែជារឿងវែងៗ ណាស់ មានជាពាក្យកាព្យ ឬជាពាក្យរាយ ។ រឿងប្រលោមលោកទាំងនោះ រៀបរាប់អំពីអក្សរសាស្ត្រនៃអរិយៈធម៌ និងប្រពៃណីទំនៀមទម្លាប់អ្នកស្រុកឥណ្ឌចិនជាមួយគ្នា ។ គឺជាប្រភេទរឿងប្រលោមលោកផ្សងព្រេង និងស្នេហា ពាក់តែងឡើងក្នុងក្របខណ្ឌប្រវត្តិសាស្ត្រ ឬនិយាយអោយចំ, ក្នុងក្របខណ្ឌរឿងព្រេងដកស្រង់ចេញពីការអន្ទោលជាតិរបស់ព្រះរាម ឬយកលំនាំតាមរឿងជាតក ។ តួអង្គមានលក្ខណៈជាមនុស្សសុទ្ធសាធ វិវត្តទៅក្នុងចំណោមតួអង្គអធិធម្មជាតិ ។ ប៉ុន្តែ ភាពហួសហេតុនៃឧបកថា ត្រូវបានកែលំអដោយសញ្ញាណទស្សនវិជ្ជាមួយ គឺសញ្ញាណទស្សន វិជ្ជាស្តីពី*កម្ម* ពោលគឺមតិដែលថា អ្វីៗទាំងអស់ដែលកើតមាននៅក្នុងជាតិនេះ គឺជាផលវិបាកចេញមកពីអំពើដែលបានប្រព្រឹត្តនៅក្នុងជីវិតកន្លងទៅ, ហើយថា, ម្យ៉ាងទៀត រាល់អំពើដែលបានប្រព្រឹត្តនៅក្នុងជាតិនេះ នឹងមានលទ្ធផលជាក់លាក់មួយទៅក្នុងជីវិតអនាគត ។ នៅក្នុងចំណោមនៃការផ្សងព្រេងទាំងអស់នោះ, កម្មគឺជាខ្សែចម្លងផលតែមួយគត់ ។ អ្វីៗទាំងអស់អាចកើតមាន, អ្វីៗទាំងអស់អាចប្រព្រឹត្តទៅបាន ពីព្រោះជីវិតពីមុនបានសំរេចយ៉ាងនេះ, សមដូចជនជាតិខ្មែរតែងនិយាយនៅពេលណាដែល « ផលនៃកម្មនោះទុំ » ។ នៅកណ្តាលការប្រយុទ្ធទាំងនោះ, កណ្តាលអំពើឆក់ចាប់យកក្សត្រីទាំងនោះ, កណ្តាលគ្រោះមហន្តរាយទាំងនោះ, កណ្តាលអារុធយុទ្ធភ័ណ្ឌទាំងនោះ, កណ្តាលវីរសកម្មភាពទាំងនោះ, កណ្តាលហ្វូងនាគទាំងនោះ, វាកើតឡើងនូវភាពអសកម្មម្យ៉ាង ឬនិយាយអោយចំ គឺភាពព្រមទទួលរងដោយឥតប្រកែកដែលផ្តល់ពណ៌មួយដ៏ពិសេសមួយអោយកម្រងរឿងព្រេងនោះ ។ សញ្ញាណអរូបីនៃរង្វាន់របស់អំពើ កាលបើបញ្ចូលទៅក្នុងរឿងប្រលោមលោកផ្នែកមនោសញ្ចេតនា, តែងមានភាពរណ្តំដោយសេចក្តីស្រឡាញ់ ហើយបង្កើតបានជាតម្លៃមួយ

ថ្មីដល់តណ្ហា ( la passion ) ។ មិនគ្រាន់តែបានជាដំណើរប្រទាក់ឆ្វាក់នៃរឿងនិទានប៉ុណ្ណោះទេ, ប៉ុន្តែ សញ្ញាណអរូបីនេះ កត្តីទៅជាមរតកខាងស្មារតីមួយបែបរបស់តួអង្គភាគច្រើន ។ នេះហើយគឺជាភាពផ្សេងគ្នាជាសារវន្តរវាងរឿងប្រលោមលោកខ្មែរ និងរឿងប្រលោមលោកវីរកថារបស់យើង ( nos romans chevaleresques ) ជាឧទាហរណ៍ ។ ប្រលោមលោកខ្មែរបង្ហាញអោយយើងដឹងពីអាកប្បកិរិយាដោយឡែកនៃតួអង្គមនុស្ស នៅចំពោះមុខអច្ឆរិយហេតុ ក៏ដូចជានៅចំពោះមុខជីវិត និងមរណៈ ។ ប្រលោមលោកខ្មែរ, ជាតំណាងយុទ្ធកថាឥណ្ឌានៅប្រទេសកម្ពុជា, ជាពន្លឺចាំងចេញពីពុទ្ធសាសនា និងចម្រុះដោយវត្ថុធាតុនៃប្រពៃណីនិងទំនៀមទម្លាប់អ្នកស្រុកឥណ្ឌូចិន, នៅក្នុងឋានៈនេះ ប្រលោមលោកខ្មែរបានបង្កអោយមានការចាប់អារម្មណ៍យ៉ាងសម្បើម ។ រឿងប្រលោមលោកដ៏ល្បីល្បាញបំផុតក្នុងចំណោមរឿងប្រលោមលោកទាំងឡាយនោះ គឺ*រឿងវរវង្ស និងសូរ្យវង្ស* ដែលលោក ប៉ាវី (Auguste Pavie) បានសរសេរសង្ខេប ។

ឥឡូវ យើងនិយាយពីរឿងប្រឌិត (le conte) វិញម្តង ដែលគួរតែនិយាយអោយច្រើន ។ ពីព្រោះរឿងប្រឌិតសម្បូរដោយតម្លៃមនុស្ស, មិនមែនដោយសារអត្ថន័យរបស់វាទេ ប៉ុន្តែដោយសារសារសំខាន់ទូទៅរបស់វា ( sa portée générale ) ។ រឿងប្រឌិតសមស្របណាស់ ធ្វើអោយមនុស្សទាំងអស់ជាប់ចិត្តតាំងពីមនុស្សល្ងង់បំផុត រហូតដល់មនុស្សវិវត្តខ្ពស់បំផុត ។ វាបង្ហាញតាមមធ្យោបាយយ៉ាងសាមញ្ញ នូវរូបភាព និងមនោសញ្ចេតនាទាំងឡាយដែលមនុស្សជាតិទាំងមូលធ្លាប់បានប្រព្រឹត្ត និងជួបប្រទះ ។

ក្នុងចំណោមរឿងប្រឌិតទាំងឡាយរបស់ខ្មែរ, មានរឿងមួយចំនួនត្រូវបានចម្លងទាំងស្រុងពីឥណ្ឌា ហើយកន្លែងខ្លះមានប្រធានបទជាច្រើន អារាត់ អារាយឃើញមានទីនេះខ្លះ ទីនោះខ្លះ នៅក្នុងរឿងប្រឌិតផ្សេងៗទៀត ដែលប្រភពរបស់វា

ហាក់ដូចជាខុសៗគ្នា ។

តើន័យរបស់រឿងប្រឌិតទាំងនោះយ៉ាងណា ? រឿងប្រឌិតទាំងនោះ ជាទូទៅ បង្ហាញពីកសិករខ្មែរ, ជីវភាពប្រចាំថ្ងៃរបស់គេ, ការបួសរៀននៅវត្ត, ដំបូន្មានក្រោមរូបភាពជាសុភាសិត ដែលព្រះសង្ឃទាំងឡាយបានផ្តល់អោយគេ មុនពេលគេលាចាកសិក្ខាបទ, អាកប្បកិរិយារបស់គេចំពោះប្រពន្ធរបស់គេ, បែបបទរកស៊ីចិញ្ចឹមជីវិតរបស់គេ, ជំនឿរបស់គេ, ទំនាក់ទំនងរបស់គេជាមួយទេពារក្ស ភូតបិសាច, សេចក្តីអត់ធ្មត់របស់គេចំពោះទុក្ខលំបាក, ការចំអកចំអន់លេងចំពោះអ្នកជិតខាង, ភាពមានចិត្តបរិសុទ្ធ និងភាពឆោតល្ងង់របស់គេនៅចំពោះមុខអ្នកដែលស្វែងរកឆបោក, ការព្រមទទួលដោយឯងៗ ចំពោះមុខភ័ព្វសំណាងដ៏អស្ចារ្យបំផុតដែលអាចផ្តល់សុភមង្គលដល់ខ្លួនគេ ។ ចៅក្រម, ព្រះរាជា និងព្រះរាជិនី, ទេព្តា, ព្រាយ, បិសាច, និងហោរា, មនុស្សស្រុកស្រែ និងមនុស្សទីក្រុង ទាំងអម្បាលម៉ាននេះ ដែលគេបង្ហាញអោយយើងឃើញនៅក្នុងរឿងប្រឌិត ។ ធម្មជាតិមិនត្រូវបានគេពិពណ៌នានៅក្នុងរឿងប្រឌិតទេ, ប៉ុន្តែ ដើមឈើបានដើរតួយ៉ាងសំខាន់ ។ រុក្ខជាតិត្រូវបានគេដាក់ឈ្មោះអោយ ។ ក្របខណ្ឌរឿងត្រូវបានគេចង្អុលប្រាប់ជានិច្ច ដោយលំអិតតែបន្តិចបន្តួច : គេដឹងថា ផ្ទះស្លឹកមានជណ្តើរមួយសម្រាប់ឡើងទៅក្នុងផ្ទះ ហើយមានចោរម្នាក់អាចពួនសំងំនៅពីក្រោមបាន ។ គេដឹងថា ពាងពេញប្រៀបដោយទឹកត្រី ហើយធំល្មមដើម្បីអោយប្រពន្ធអាចលាក់សាហាយរបស់គេបាន, ប្រសិនបើគ្មានទឹក ។ គេដឹងថា លបប្រភេទណា ដែលអ្នកស្រែប្រើសម្រាប់ដាក់យកត្រីបែបណាមួយនោះ ដោយហៅចំឈ្មោះត្រីនោះ ។

នៅក្នុងវិស័យសាសនាវិញ, គ្មានការអធិប្បាយអំពីទ្រឹស្តីនៅក្នុងរឿងប្រឌិតទេ, ប៉ុន្តែ ព្រះពុទ្ធត្រូវបានគេបួងសួងរំលឹកជាញឹកញយ ហើយលើសនេះទៀតគឺគេបួងសួងដល់ទេវតា ។ ព្រះឥន្ទ ជាញឹកញយតែងបើកទិព្វចក្ខុប្រមើលមើល

តួអង្គខ្សត់ខ្សោយនៃរឿង ហើយតែងចុះមកជួយគេ កាលណាគេមានបារមីចាស់ ទុំហើយ ។ ស្ត្រីទុរគតម្នាក់, ប៉ុន្តែប្រកបដោយ *សួស្តី* (១) អាចសង្ឃឹមថាទទួលបានទ្រព្យសម្បត្តិ ។ ជីវភាពរបស់វត្តនៅក្នុងរឿង ត្រូវបានគេបង្ហាញក្រោមទិដ្ឋភាពឧស្សាហ៍ព្យាយាម, ហើយលោកសង្ឃ ត្រូវបានគេបង្ហាញថាជាអ្នកប្រកាន់ខ្ជាប់ នូវរាល់គតិបណ្ឌិត ។ រឿងខ្លះទៀត, តាមពិត, គឺជារឿងកំប្លែងធ្វើអោយអស់សំណើចយ៉ាងខ្លាំង ។ បុណ្យទាន ត្រូវបានចង្អុលប្រាប់ ។ នៅទីបញ្ចប់ អ្នកតា ឬអ្នកតាម្ចាស់ស្រុក តែងឃើញមានជាញឹកញាយណាស់ នៅក្នុងខ្ទមតូចៗ នៅជនបទ ៖ ស្ត្រីម្នាក់ក្សត់ប្តីមកបន់ស្រន់អ្នកតាណាមួយ សន្យាថ្វាយជ្រូកខ្វៃ បើសិនជាអ្នកតានោះកាច់ប្តីរបស់គេបាន ។ ក្មេងម្នាក់ បានធ្វើអោយភ្នែកក្មេងប្រុសកំសត់ម្នាក់មានភ្នែកភ្លឺឡើងវិញ ដែលត្រូវរងគ្រោះដោយសារមិត្តភ័ក្តិកំណាចម្នាក់ ។ រុក្ខទេវតា ប្រាថ្នាដាក់ទណ្ឌកម្មដល់មនុស្សម្នាក់ ដែលប្រុងប្រៀបនឹងកាប់រំលំដើមឈើជាលំនៅស្ថានរបស់ខ្លួន ។ ពុទ្ធសាសនា, ដ៏ជាសំណល់ចុងក្រោយនៃលទ្ធិព្រាហ្មណ៍, និងជំនឿខ្មោចបិសាច ត្រូវបានលាយច្របល់យ៉ាងជិតស្និទ្ធនៅក្នុងទីនេះ ។

ប្រសិនបើនិយាយពីការស្តីដណ្តឹង ឬការរៀបមង្គលការវិញ, រឿងប្រឌិតទាំងឡាយ បានប្រាប់អោយដឹងថា កូនកំឡោះត្រូវមកនៅផ្ទះឪពុក-ម្តាយក្មេក ដើម្បីមកលត់ដំខ្លួន ។ ការរៀបមង្គលការ នឹងមិនអាចប្រព្រឹត្តទៅកើត ដោយគ្មានហោរាមើលកំណត់ថ្ងៃល្អអោយនោះទេ ។ ការកំណត់នេះចង់និយាយដល់ « ការចងដៃ » និងដល់ករណីយកិច្ចប្រចាំថ្ងៃរបស់ស្ត្រីចំពោះប្តីរបស់ខ្លួន ។ ពិធីបុណ្យខ្មោចក៏ត្រូវបានគេរៀបរាប់ដែរ, ឧទាហរណ៍ ការបូជាសព ។

---

(១) ភ័ព្វសំណាង កើតមានដោយសារបុណ្យសន្សំទុកពីជាតិមុន ( សំស្ក្រឹត ៖ សួស្តី )

គ្រូធ្មប់ អាប ជាទូទៅ តែងមានតម្រាមន្តអាគម ហើយគូសសញ្ញា និងរូបទាំងឡាយដែលគេពុំអាចពណ៌នាបាន ។ រឿងប្រឌិតខ្លះទៀត បានផ្តល់គំនិតស្តីពីឱសថសម្រាប់ព្យាបាលជំងឺ, ឬស្តីពីកាយវិការត្រូវធ្វើ ដើម្បីចាប់ត្រីមួយបានភ្លាម ហើយធ្វើអោយត្រីនោះត្រឡប់ទៅវិញផ្ងារពោះឡើងលើ ដោយគ្រាន់តែហុចដៃនៅពីលើផ្ទៃទឹក ។ គ្រូធ្មប់-អាប ស្គាល់គ្រប់ភូតគាម ( plantes ) ហើយដឹងថា ក្នុងទឹកបែបណា ដែលអ្នកក្បាលទំពែកល្បីល្បាញប្អូននាក់ត្រូវត្រាំក្បាលរលីងយង់របស់គេ ដើម្បីមានសក់ឡើងវិញ ។ ប៉ុន្តែ មុខងារជាធម្មតារបស់គ្រូធ្មប់-អាប ទាំងនោះគឺការទស្សន៍ទាយមើលអនាគត, ហើយរឿងប្រឌិតទាំងឡាយ តែងផ្តល់អោយគ្រូធ្មប់-អាប ត្រូវជានិច្ច ។

ការងារប្រចាំគ្រួសាររបស់ជនជាតិខ្មែរ ត្រូវបានគេបញ្ជាក់ ។ ដោយហេតុនេះ យើងដឹងថា អ្វីគេផឹក-ស៊ី អ្វីគេជក់ ចុក និងគេធ្វើដោយដៃគេផ្ទាល់ ។ ម្នាក់ត្បាញកញ្ជើ, ម្នាក់ទៀតទៅរកឈើធ្វើនង្គ័ល, អ្នកទីបីទៅរកត្រី, អ្នកទីបួនយាមស្រូវនៅរដូវស្រូវកំពុងទុំ ។ ម្នាក់ផ្សេងទៀតដេញចាប៉ី, ឬបន់ស្រន់ទេវតា, ឬបររទេះ, ឬដេក ។ បើនិយាយដល់ជនជាតិចិនវិញ គឺច្រើននិយាយពី « ហាងរបស់ឈ្មួញចិន » ។ ប្រសិនបើមនុស្សណាមួយមកពីជ្វា មានវត្តមាននៅក្នុងរឿងប្រឌិត, គេនោះជាអ្នកចិញ្ចឹម « មាន់ប្រជល់ ឬជាព្រានប្រមាញ់ » ។

រដ្ឋមន្ត្រី, នាយទាហ៊ាន និងនាយក្រុមភស្តុភាររបស់វាំង មិនសូវមានមុខនៅក្នុងរឿងទេ ហើយក៏គ្មានគំនិតផ្តើមនិយាយដល់ផង ។ អ្នកទាំងនោះ គឺជាព្រះនេត្រ ព្រះកាណ៌ ( ភ្នែក ត្រចៀក ) របស់ព្រះរាជា, គេស្តាប់, រាយការណ៍ និងដាក់ការព្រមាន ។ ចាំទទួលព្រះរាជបញ្ជា ឬត្រូវបានចាត់អោយទៅដោយរវៀសរវៃជានិច្ច, គេគឺជាឧបករណ៍បំរើព្រះរាជឆន្ទៈរបស់ព្រះមហាក្សត្រ ។

ព្រះមហាក្សត្រ ស្ទើរតែជានិច្ចកាល ត្រូវបានតំណាងជាចៅក្រម ។ ព្រះ

អង្គអារកាត់សេចក្តី ដែលអ្នកកាន់អំណាចតុលាការ (ចៅក្រម) ទាំងឡាយ - តាមធម្មតា និងជាគោលការណ៍ -អស់សមត្ថភាពវិនិច្ឆ័យ ។ ប៉ុន្តែ ព្រះរាជាតែងតែវិនិច្ឆ័យដោះស្រាយបាន ស្ទើរតែក្រោយគេជានិច្ច, វៀរលែងតែពេលព្រះអង្គត្រូវចាញ់ប្រាជ្ញក្មេងខិលធនញ្ជ័យចេញ ។ ដោយសារព្រះប្រាជ្ញាញាណធំធេង, ព្រះអង្គបានរកឃើញចោរលួច, វែកមុខជនមានកំហុស ហើយធ្វើអោយយុត្តិធម៌ឈ្នះបាន, ដូចជានៅក្នុងរឿង *ចៅកំបិតបន្ទោះ*, គេជំនុំជំរះរឿងក្តី ពីជណ្តើរមួយ ដែលគេអូសយកទៅប្តឹងតុលាការ ហើយដែលគេដាក់ខ្នោះឃ្នាងផង ។

ប្រភេទមនុស្សផ្សេងៗ ត្រូវបានគេបង្ហាញនៅក្នុងរឿងប្រឌិត ព្រះរាជា, ព្រះរាជិនី, លោកសង្ឃ, ចៅហ្វាយខេត្ត, ស្ត្រី-ច្រើនបែបទៅតាមឋានៈ ជាស្ត្រីប្រពន្ធអ្នកក្រ ឬប្រពន្ធអ្នកមានទ្រព្យ-សាហាយ, ចោរ, គ្រូធ្មប់ ឬគ្រូទាយ, ហោរាព្រះរាជ-វាំង, អ្នកក្រ, អ្នកមាន, បងប្អូនកំព្រាពីរនាក់, ចាស់ព្រឹទ្ធាចារ្យ, មនុស្សស្រុកស្រែ, ញាតិសន្តាន,-ល- ។ ម្នាក់ៗមានលក្ខណៈដោយឡែកៗ របស់គេ ហើយជួនកាលទៀតក៏មានបុគ្គលភាពច្រើនបែបនៅក្នុងប្រភេទតែមួយដដែល ។

តួអង្គអច្ឆរិយៈ មិនមែនសុទ្ធតែជាទេវៈ និងតួអង្គមានក្នុងទេវកថា ដែលប្រពៃណីឥណ្ឌាបានធ្វើអោយស្គាល់នោះទេ, ប៉ុន្តែ ក៏មានអ្នកតា ពោលគឺ ទេវភូមិគ្រប់ប្រភេទ, ដែលមានទេវភូមិខ្លះ ថែរក្សាសត្វ, ដូចជាក្រពើនៅក្នុងរឿងប្រឌិត «សុកស្លួត និងសុកកាច» ។ ហើយក៏មានរឿងខ្មោច ឬព្រលឹងរបស់អ្នកស្លាប់ទៅ, ដូចខ្មោចក្រមុំ ក្នុងរឿងប្រឌិតដ៏គួរអោយចង់ដឹង " គ្រូប៉ាង និងនន្ទី " (Maître Pang et Nan-ti) ដែលបាននាំប្តីនាងទៅរស់នៅក្នុងគ្រួសារក្មេកខ្មោចរបស់ប្តី ។ ឬក៏មានរឿងមនុស្សចម្លែកទាំងនោះផងដែរ ដែលមាន « ភេទជាមនុស្សស្រី » ឋិតនៅក្នុងខ្នាយ ឬភ្លុក, ដូចជានៅក្នុងខ្នាយស្តេចរមាស និងនៅក្នុងភ្លុកស្តេចដំរី ក្នុងរឿងប្រឌិត « *បងប្អូនពីរនាក់ និងមាន់ផ្ទាក់* » ។ ជារឿងអច្ឆរិយៈផងដែរ គឺមាន់ផ្ទាក់

របស់រឿងប្រឌិតដដែលនេះ ដែលគ្រាន់តែរងារបីដង ធ្វើអោយស្រី១ទាំងអស់នៃព្រះរាជាណាចក្រ មកជាប់ផ្ទាក់គ្មានសល់ ។ ជាតួអង្គអច្ឆរិយៈដែរ គឺកូនរាជសីហ៍ និងសំបកខ្យង ដែលដឹកនាំវីរបុរសនៃរឿងប្រឌិត *ស័ង្ខសិល្ប៍ជ័យ* ។

ចំណែកសត្វវិញ, គេត្រូវធ្វើការសិក្សាដោយឡែក ។ សត្វខ្មែរ ជាសត្វកាន់ពុទ្ធសាសនា ឬគ្រាន់តែជាសត្វឥណ្ឌា ? ទោះជាអ្វីក៏ដោយ, សត្វទាំងនោះ គឺជាបងប្អូនរបស់មនុស្ស ដូចនៅក្នុងរឿងប្រឌិត *ចៅបាយក្តាំង* ដែលឆ្កែ និងឆ្មា នៅទីបំផុតនៃរឿង, ត្រូវបានតែងតាំងជារដ្ឋមន្ត្រី ។

សត្វទាំងអស់ មានចិត្តសាស្ត្រមួយសក្តិសម ត្រូវបានគេយកចិត្តទុកដាក់សិក្សា, ដូចជាចិត្តសាស្ត្រនៃសត្វទាំងឡាយរបស់រឿងខ្លី១ ជាកំណាព្យរបស់យើង ( បារាំងសែស ) ឬរបស់លោកឡាហ្វុង តែន ។ ប៉ុន្តែ សត្វទាំងឡាយ នៅក្នុងរឿងជាតក មានប្រាជ្ញាវាងវៃសម្បូរជាង ។ សត្វទាំងឡាយនៅក្នុងរឿងប្រឌិតធម្មតា បានឆ្លុះបញ្ចាំងចេញអោយឃើញនូវទិដ្ឋភាពនៃធម្មជាតិខ្មែរ និងធម្មជាតិមនុស្សទាំងមូល, ដោយមានបន្ថែមចរិតលក្ខណៈខ្លះ១របស់សត្វ ដែលបញ្ជាក់នូវការស្គាល់សត្វច្បាស់ និងភាតរភាពដ៏ពិតប្រាកដ ដែលកើតមានរវាងសត្វ និងសត្វ និងរវាងសត្វ និងកសិករខ្មែរ ។ អព្ភន្តរញ្ញាណរបស់សត្វ ( L'intuition de l'animal ) មិនមែនចេះតែផ្តល់អោយដល់គ្រប់គ្នាទេ ។ តាមរយៈរឿងប្រឌិត, គេកត់សំគាល់ឃើញ, តាមការស្និទ្ធស្នាលជាធម្មតារបស់មនុស្សជាមួយសត្វ, នូវគំនិតរលាយចូលគ្នាយ៉ាងជិតស្និទ្ធ ដែលថា សត្វទាំងឡាយនោះ គឺជាបងប្អូនរួមព្រេងវាសនារបស់មនុស្ស ហើយឋិតក្នុងល័ក្ខខ័ណ្ឌនៃជីវិត, នៃមរណភាព និងជីវិតថ្មីដូចគ្នា ។ម្យ៉ាងទៀត, សត្វនីមួយ១មានបុគ្គលិកលក្ខណៈផ្ទាល់ ហើយតំណាងគំរូមួយ : មុនគេគឺ ទន្សាយ, ឆ្កែ, ឆ្មា, ខ្លាត្រី, ខ្លា, ដំរី, អណ្តើក, ក្រពើ សុទ្ធតែមានចរិតលក្ខណៈបែបណាមួយផ្ទាល់របស់ខ្លួន ។

នេះគឺជាខ្លឹមសារនៃរឿងប្រឌិត, យ៉ាងហោចណាស់ក៏ជាខ្លឹមសារនៃរឿង

ដែលជាគំរូផ្ទាល់របស់ខ្មែរដែរ ។ មានប្រធានបទជាច្រើន ត្រូវបានគេលើកយកមកបង្ហាញ ។ ប្រធានបទដ៏ជិតបំផុត គឺជាប្រធានបទស្ដីពីការរិះគន់សង្គម តាមរយៈរឿងប្រឌិតខ្មែរ ឬចរិតលក្ខណៈសត្វនៅក្នុងរឿងនិទាននៃស្រុកខ្មែរ ឬអច្ឆរិយហេតុក្នុងរឿងប្រឌិត, ឬធាតុទាំងឡាយនៃអក្សរសាស្ត្រ រឿងនិទានជាសកល និងធាតុប្រជាប្រិយក្នុងស្រុក ។

ប្រសិនបើគេចង់អោយនិយមន័យដល់រឿងប្រឌិតទាំងនោះ ទៅតាមក្រុម, ចូរយើងរាប់រឿងតុលាការ ដូចជាកម្រងអត្ថបទអក្សរសាស្ត្រ កឹងកន្ទ្រែ ដែលមានជាភាសាភូមា, ភាសាឡាវ, ភាសាសៀម, ឬដូចជាប្រវត្តិដ៏ពិរោះរបស់សុភាទន្សាយ ដែលមានខ្លឹមសាររួមនាំអោយនឹកដល់រឿងប្រលោមលោកសត្វកញ្ជ្រោងរបស់យើង ( Notre roman de Renard ) ។ ចូរយើងរាប់រឿងប្រឌិតកំប្លែងដូចជារឿងបុរសទំពែកបួននាក់ ដែលខំស្វះស្វែងគ្រប់ទិសទី នៃព្រះរាជាណាចក្រដើម្បីរកប្រពន្ធ, ហើយក៏ទំនងជាស្វែងរកសក់នៅលើលលាដ៍ក្បាលរបស់ខ្លួនផងដែរ, រឿងធនញ្ជ័យ, ដ៏ជាក្មេងឆ្លាតវាងវៃ មានល្បិចកល, ដែលរឿងកំប្លែងនេះរកឃើញដៃគូរ របស់ខ្លួននៅស្រុកលាវ, ក្នុងរឿងសៀងមៀង, (l'histoire de Xieng Mieng), ហើយនៅស្រុកសៀម ក្នុងរឿងស៊ីថានន់ចៃ (l'histoire de sithanoncai) ។ ចូរយើងរាប់បន្ថែមទៀត រឿងប្រឌិតស្ដីពីសមុដ្ឋានសាស្ត្រ ឬរឿងប្រឌិតពន្យល់, ដូចជា រឿងព្រេងស្ដីពីដើមកំណើតសត្វខ្លា, ដើមកំណើតសត្វមូស ឬរឿងសំឡាញ់ពីរនាក់ ដែលចង់បាចទឹកពង្រីងសមុទ្រ ។ ចូរយើងលើកឡើងផងដែរ នូវរឿងប្រឌិតអច្ឆរិយៈសុទ្ធសាធ ដូចជារឿងនាងកាកី, ជាក្សត្រីត្រូវសត្វគ្រុឌឆក់យកទៅ, រឿងប្រឌិតស្ដីពីអ្នកជនបទ ដូចជារឿងតា និងយាយ ចេញទៅបរបាញ់សត្វ ... ។ ប៉ុន្តែ វានៅមានច្រើនណាស់ ដែលទាល់តែមានពេលមួយឆ្នាំពេញទើបនិយាយរៀបរាប់រឿងទាំងនោះអស់ ។

តាំងពីសម័យកាលហ្វូណនដ៏យូរលង់ និងអាថិកំបាំង រហូតមកដល់សម័យកម្ពុជាបច្ចុប្បន្ន, នេះគឺជាការចង្អុលបង្ហាញប្រាប់ដោយសង្ខេបៗ នូវដំណាក់ផ្សេងៗនៃផ្លូវ ដែលព្រះរាជាណាចក្រខ្មែរបានដើរតាម, និងទិដ្ឋភាពប្លែកៗ ដែលអក្សរសាស្ត្រចារលើថ្ម, ចារលើស្លឹករឹត ឬយ៉ាងសាមញ្ញបំផុត ចារលើបបូរមាត់អ្នកនិទានរឿង និងអ្នកចម្រៀង បានបន្សល់ទុកអោយយើងដឹង ។ អក្សរសាស្ត្រនេះបានឆ្លុះបញ្ចាំងនូវរឿងសំខាន់ៗ ៖ ជោគជ័យកន្លងទៅដ៏ត្រចះត្រចង់ ដោយសារសិល្បៈរបស់ខ្លួន និងដំណើររីកសាយកិត្តិសព្ទនៃព្រះរាជាទាំងឡាយរបស់ខ្លួន ។ បន្ទាប់មក ក៏កើតមានភាពស្ងប់ស្ងាត់ បាត់ឈ្មោះ បាត់សំឡេងដ៏អណោចអធម្ម អស់ច្រើនសតវត្ស ដែលនៅក្នុងអំឡុងកាលនេះ ជនជាតិនេះបានរត់ពីកន្លែងមួយទៅកន្លែងមួយ នៅក្នុងព្រះរាជាណាចក្ររបស់ខ្លួនដែលចុះចាញ់គេ, ចំណែកឯប្រាសាទរបស់គេ បានកប់ខ្លួនបាត់នៅក្នុងព្រៃ ។ ហើយនៅទីបំផុត ក៏កើតមានស្មារតីនឹកឃើញដ៏រំភើបនូវអនុស្សាវរីយ៍ចាស់, ការនឹកឃើញដ៏សោះអង្គើយ ដំណើរចិត្តព្រឺលស្រវាំងនៅឡើយ, ហើយដែលបង្ក្រប់នៅក្នុងសុបិនរបស់ខ្លួន ដែលបានក្លាយទៅជាប្រពៃណី ។ ស្មារតីនឹកឃើញ ដែលហាក់ដូចជាផ្ទុកជ្រុល, ធ្ងន់ជ្រុលដោយទស្សនៈ ដើម្បីអាចបង្កើតទស្សនៈថ្មីបាន ។ អនាគតនឹងប្រាប់អោយយើងដឹងថា តើអក្សរសាស្ត្រដ៏ក្មេងខ្ចីមួយនេះអាចស្រូបយកវប្បធម៌លោកខាងលិចភ្ជាប់ទៅនឹងវប្បធម៌បុរាណផណ្ឌា និងចំណេះ ឬសមត្ថភាពរបស់បុព្វបុរសបានឬទេ ។

Solange Bernard

in France-Asie-Numéro special 37-38

Consacré au Cambodge - 1949

បកប្រែដោយ **ឈន អៀម**

# ការសូត្រមន្តរំដោះគ្រោះ

បុរាណាចារ្យខ្មែរយើង, បើមានមនុស្សឈឺ គេព្យាបាលដោយវិធីយ៉ាងនេះយ៉ាងនោះ នៅតែមិនជាសះស្បើយ គេក៏រកឱ្យគ្រូហោរទស្សន៍ទាយមើល ថាតើវាបណ្ដាលពីអ្វី ? ត្រូវធ្វើដូចម្ដេច ? កាលណាហោរទស្សន៍ទាយទៅ ថាអ្នកជំងឺនោះត្រូវមានគ្រោះ គេតែងនិមន្តព្រះសង្ឃសូត្រមន្តរំដោះគ្រោះ ។ ម្យ៉ាងទៀត មនុស្សខ្លះ ទោះបីមិនទាន់មានឈឺថ្កាត់អ្វីក៏ដោយ ប៉ុន្តែគេបានអោយហោរទស្សន៍ទាយមើលថាឆ្នាំនេះមាន ឬគ្មានគ្រោះ ។ កាលបើហោរទស្សន៍ទាយថា ក្នុងឆ្នាំនេះគេមានគ្រោះថ្នាក់ណាមួយនោះ គេក៏តែងនិមន្តព្រះសង្ឃមកសូត្រមន្តរំដោះគ្រោះនោះដែរ ។ អាចារ្យខ្លះ ហៅការសូត្រមន្តបែបនេះថា សូត្រមន្តកាត់គ្រោះទេវិញ ។

## I - ពេលវេលាសូត្ររំដោះគ្រោះ

ការសូត្រមន្តរំដោះគ្រោះ គេកំណត់យកពេលវេលាតាមក្បួនតម្រាសម្ដោកគ្រោះ គឺគិតតាមថ្ងៃ . ខែ . ឆ្នាំ និងអន្សាកំណើតរបស់អ្នកមានគ្រោះ ។ បើកើត :

| | | | |
|---|---|---|---|
| - ឆ្នាំជូត | ឱ្យសូត្រមន្ត | ថ្ងៃអាទិត្យ | ធមិកស្សបសូត្រ |
| - ឆ្នាំឆ្លូវ | ឱ្យសូត្រមន្ត | ថ្ងៃចន្ទ | មោគ្គល្លានសូត្រ |
| - ឆ្នាំខាល | ឱ្យសូត្រមន្ត | ថ្ងៃអង្គារ | ជីវិតទានបរិត្តសូត្រ |
| - ឆ្នាំថោះ | ឱ្យសូត្រមន្ត | ថ្ងៃពុធ | ចុន្ទបរិត្តសូត្រ |
| - ឆ្នាំរោង | ឱ្យសូត្រមន្ត | ថ្ងៃព្រហស្បតិ៍ | មេត្តិយសូត្រ |
| - ឆ្នាំម្សាញ់ | ឱ្យសូត្រមន្ត | ថ្ងៃសុក្រ | ធម្មចក្កប្បវត្តនសូត្រ |
| - ឆ្នាំមមី | ឱ្យសូត្រមន្ត | ថ្ងៃសៅរ៍ | មហាសមយសូត្រ |
| - ឆ្នាំមមែ | ឱ្យសូត្រមន្ត | ថ្ងៃអាទិត្យ | ឥសីគិលិសូត្រ |

| | | | |
|---|---|---|---|
| - ឆ្នាំវក | ឱ្យសូត្រមន្ត | ថ្ងៃចន្ទ | អាដានាដិយសូត្រ |
| - ឆ្នាំរកា | ឱ្យសូត្រមន្ត | ថ្ងៃអង្គារ | ធជគ្គសូត្រ |
| - ឆ្នាំច | ឱ្យសូត្រមន្ត | ថ្ងៃពុធ | អភិណ្ហប្បច្ចវេក្ខណៈ |
| - ឆ្នាំកុរ | ឱ្យសូត្រមន្ត | ថ្ងៃព្រហស្បតិ៍ | គិរិមានន្ទសូត្រ |

មតិអាចារ្យខ្លះទៀត និយមយកពេលសូត្រមន្តរំដោះគ្រោះបែបនេះទៅវិញគឺ បើកើត :

| | | | | |
|---|---|---|---|---|
| - ឆ្នាំជូត | ឱ្យសូត្រមន្ត ថ្ងៃព្រហស្បតិ៍ | | - ឆ្នាំមមី | ឱ្យសូត្រមន្ត ថ្ងៃពុធ |
| - ឆ្នាំឆ្លូវ | ឱ្យសូត្រមន្ត ថ្ងៃសុក្រ | | - ឆ្នាំមមែ | ឱ្យសូត្រមន្ត ថ្ងៃព្រហស្បតិ៍ |
| - ឆ្នាំខាល | ឱ្យសូត្រមន្ត ថ្ងៃសៅរ៍ | | - ឆ្នាំវក | ឱ្យសូត្រមន្ត ថ្ងៃសុក្រ |
| - ឆ្នាំថោះ | ឱ្យសូត្រមន្ត ថ្ងៃអាទិត្យ | | - ឆ្នាំរកា | ឱ្យសូត្រមន្ត ថ្ងៃសៅរ៍ |
| - ឆ្នាំរោង | ឱ្យសូត្រមន្ត ថ្ងៃចន្ទ | | - ឆ្នាំច | ឱ្យសូត្រមន្ត ថ្ងៃអាទិត្យ |
| - ឆ្នាំម្សាញ់ | ឱ្យសូត្រមន្ត ថ្ងៃអង្គារ | | - ឆ្នាំកុរ | ឱ្យសូត្រមន្ត ថ្ងៃចន្ទ ។ |

ចំពោះមតិទាំងពីរ, មតិទី១ កំណត់យកថ្ងៃអន្សា មតិទី២ កំណត់យកថ្ងៃសិទ្ធិរបស់អ្នកមានគ្រោះ ជាថ្ងៃសូត្ររំដោះគ្រោះ ឬកាត់គ្រោះ ។

## II . របៀបរណ្តាប់សូត្រមន្តរំដោះគ្រោះ

របៀបរៀបចំពិធីសូត្រមន្តរំដោះគ្រោះ ច្រើនប្រព្រឹត្តទៅនៅពេលល្ងាច, គេនិមន្តព្រះសង្ឃមួយអង្គ ឬច្រើនអង្គ, អញ្ជើញអាចារ្យម្នាក់, រៀបទៀន ៥ ធូប ៥ ផ្កា ៥ ស្លាធ៌រកូនចេក ១, ទឹកអប់ពីក្រមួនសុទ្ធមួយផ្តិល និងស្ពាន់ ១ (បច្ចុប្បន្នគេចាក់ទឹកអប់លាយជាមួយទឹកក្នុងផ្តិល), កំណាត់សប្រវែង ៥ ហត្ថរបស់អ្នកមានគ្រោះ, វាល់អង្កររនឹងកូនផ្តិលបណ្តែត ឬនឹងកូនចាន ឬក៏ពែងឱ្យលើសពីអាយុអ្នកមានគ្រោះ (បើអ្នកមានគ្រោះ អាយុ ៣០ ឆ្នាំ ត្រូវវាល់អង្ករ ៣៣ កូនផ្តិល, គឺត្រូវវាល់ឱ្យលើសពីអាយុអ្នកមានគ្រោះ ហើយចំនួនដែលលើសនោះ ជាចំនួនសេស), ពែមួយ, មាន

រូបស្នងរុំដោយកំណាត់ដាក់ក្នុងពៃនោះមានបង្អែមចំអាប, ស្លាធ័រប្រាំបីដោតជុំវិញផ្ទះគ្រប់ទិស ។ អង្ករដែលបានវាល់នោះ ត្រូវដាក់ទៅលើកំណាត់ស ៥ ហត្ថ រួចគូសវាសជារាងមនុស្ស ហើយខ្ទប់ ទើបឱ្យអ្នកមានគ្រោះអង្គុយលើ ។ តមកទៀត អាចារ្យព័ទ្ធសីមាដោយអំបោះស ឬចេសមួយសរសៃជុំវិញអ្នកមានគ្រោះ ដោយដាក់ចុងអំបោះ ឬចេសនោះ ទៅខាងព្រះភក្ត្រព្រះសង្ឃ ។

កាលបើរៀបចំសព្វគ្រប់តាមទម្លាប់ហើយ អាចារ្យចាប់ផ្ដើមដុតទៀនធូប នមស្សការព្រះរតនត្រ័យ សមាទានសីល ប្រកាសអញ្ជើញពួកទេព្តា ។ បន្ទាប់មកព្រះសង្ឃចំរើនព្រះបរិត្ត ប្រោះទឹកមន្តទៅលើអ្នកមានគ្រោះ ដែលកំពុងក្រាបសំពះ ។ លុះព្រះសង្ឃសូត្រមន្តចប់ហើយ អាចារ្យក៏ធ្វើពិធីសែនព្រេនជូនពៃថា ឧមះគ្រោះចរ, ឧមះគ្រោះមរណ៍ គ្រោះជោគ គ្រោះជាំ គ្រោះខែ គ្រោះឆ្នាំ គ្រោះលក្ខណា អន្សាកំណើតអ្នកនោះឯងហោង អំពីម្ចាស់ទេវរាជឱ្យថ្កាត់ ប្រសិទ្ធិសក្តិ ព្រះពុទ្ធមន្តា ទើបអញ្ជើញស្ដេចទេវរាជទាំងឡាយ ដែលគង់នៅក្នុងទិសឦសាន - បូពិ - អាគ្នេយ៍ទក្សិណ - នីរតី - បស្ចិម - ពាយព្យ - ឧត្តរ, អញ្ជើញស្ដេចមកយកក្រយាបូជា ទោះថ្កាត់នានា រោគាឱ្យបាត់ កុំឱ្យឈឺក្បាល ឈឺត្បូង ឈឺទ្រូង ឈឺស្មា ឈឺជើង ឈឺដៃសរសៃរោគា សូមទោស សូមលា អ្នកកុំប្រកួត ទោះឈឺចាក់ ឈឺច្បាក់សាច់ សូតដោតរមួលរមួត សូមពឹងរំដោះឱ្យជា ទោះថ្កាត់នានា រោគាឱ្យបាត់ ចូរពឹងចេញថ្វាត់កាន់ឋានលំនៅទីទៃវិញហោង ឧមះ នមោ ពុទ្ធស្ស នមោ ធម្មស្ស នមោ សង្ឃស្សសេយ្យជីទំ ហុលោ ហុលោ ស្វាហាយះ ។

លុះចប់ពិធីសូត្រព្រះបរិត្ត និងពិធីសែនព្រេននេះហើយ, អាចារ្យចាប់សរសៃអំបោះ ឬចេសសីមា មូរសន្សឹមៗរុំផ្ចិត្ត រួចដុតនឹងភ្លើងទៀនដាក់ក្នុងពៃ ហើយឧបកិច្ចឱ្យរូបស្នងទទួលយកគ្រោះទាំងអម្បាលម៉ាន រួចឱ្យយកពៃនោះទៅដាក់នៅក្រៅផ្ទះ តាមទិសដែលអាចារ្យបានកំណត់ ។

## III - ប្រភពសូត្រមន្តរំដោះគ្រោះ

ក្នុងគម្ពីធម្មបទដ្ឋកថា ភាគ ៤ និងសុត្តន្តបិដក ភាគទី ៥២ មាននិយាយអំពីពិធីរំដោះគ្រោះ និងចម្រើនអាយុដែរ ។ និទានដែលនិយាយពីរឿងនេះ មានលំនាំដូចតទៅ :

សេចក្ដីដំណាលថា មានព្រាហ្មណ៍ជាសម្លាញ់នឹងគ្នាពីរនាក់ នៅក្នុងក្រុងឈ្មោះ ទីឃលម្ពិកៈ ។ ព្រាហ្មណ៍ទាំងពីរនាក់នេះ បានចេញទៅបួសជាបព្វជិតក្រៅពុទ្ធសាសនា (តាបសឥសី) ប្រព្រឹត្តតបធម៌អស់រយៈកាល ៤៨ ឆ្នាំ ។ ក្រោយមកតាបសម្នាក់ នឿយណាយនឹងភេទរបស់ខ្លួន ក៏បានលាចាកបព្វជិតភេទ ហើយយកបរិក្ខាររបស់ខ្លួនទៅលក់ឱ្យអ្នកដទៃ យកប្រាក់ទៅដណ្ដឹងប្រពន្ធ, ទិញគោបាន ១០០ ក្បាល និងទ្រព្យសម្បត្តិមួយចំនួន ហើយនៅសល់ប្រាក់ ១០០ កហាបណៈទៀត ។

គ្រាក្រោយមក ភរិយារបស់ព្រាហ្មណ៍នោះ ប្រសូតបានកូនប្រុសមួយ ។ រីឯតាបសឥសីជាសម្លាញ់ដែលប្រព្រឹត្តតបធម៌នៅក្នុងព្រៃនោះ មានការនឹករលឹក ភូមិស្រុកកំណើត ក៏ត្រឡប់ចូលមកក្រុងវិញ, ព្រាហ្មណ៍ប្ដីប្រពន្ធបានដឹងដំណឹងនេះ ក៏នាំកូនទៅថ្វាយបង្គំសួរសុខទុក្ខតាបសឥសីជាសម្លាញ់របស់ខ្លួន ដែលខានបានជួបគ្នាជាយូរមកហើយនោះ ។ ពេលដែលព្រាហ្មណ៍ប្ដីប្រពន្ធថ្វាយបង្គំតាបស។ បានឱ្យពរសព្ទសាធុការថា « ទីឃាយុកា ហោថ សូមឱ្យអ្នកមានអាយុវែង » ។ លុះពេលឱ្យទារកថ្វាយបង្គំ តាបសនេះបែរជានៅស្ងៀមស្ងាត់មិននិយាយអ្វីទាំងអស់ ព្រាហ្មណ៍ប្ដីប្រពន្ធកើតមានសេចក្ដីសង្ស័យណាស់ ក៏សួរថា បពិត្រលោកម្ចាស់ ដ៏ចម្រើន ! ចុះហេតុអ្វីបានជាពេលដែលខ្ញុំព្រះករុណាឱ្យកូនថ្វាយបង្គំ ព្រះអង្គមិនមាននិយាយអ្វីមួយម៉ាត់សោះ ? តាបសតបថា ម្នាលព្រាហ្មណ៍, កូនអ្នកនឹងមានគ្រោះមួយកើតឡើងយ៉ាងពិតប្រាកដ ។ ព្រាហ្មណ៍ប្ដីប្រពន្ធសួរថា តើគ្រោះនោះនឹងកើតឡើងនៅពេលណា ? តើមានពិធីអ្វីសម្រាប់ការពារ ឬបញ្ចៀសគ្រោះនេះបាន ឬទេ ? តាបសតប

ថា ខ្ញុំមិនដឹងទេ ។ បើអ្នកចង់ដឹងរឿងនេះ អ្នកចូរទៅសួរព្រះសមណគោតមចុះ នោះអ្នកនឹងបានដឹងជាពុំខាន ។ ព្រាហ្មណ៍ប្រកែកថា ខ្ញុំពុំហ៊ានទៅសួរព្រះសមណ-គោតមទេ ព្រោះខ្លាចដាច់តបធម៌ដែលបានប្រព្រឹត្តរួចមកហើយ ។ តាបសជំរុញថា បើអ្នកស្រឡាញ់កូនពិតប្រាកដ អ្នកត្រូវតែហ៊ានលះបង់អ្វីៗទាំងអស់ ហើយទៅសាកសួរព្រះសមណគោតម ឱ្យខាងតែបាន ។

កាលបើឮដូច្នេះហើយ ព្រាហ្មណ៍ប្តីប្រពន្ធ ក៏ដាច់ចិត្តនាំកូនទៅថ្វាយបង្គំព្រះសាស្តា ។ ពេលដែលប្តីប្រពន្ធថ្វាយបង្គំ ព្រះសម្ពុទ្ធទ្រង់មានព្រះបន្ទូលថា «ទីឃា-យុកា ហោថ អ្នកចូរមានអាយុវែង» ។ ប៉ុន្តែ ពេលដែលឱ្យកូនថ្វាយបង្គំ ព្រះសាស្តានៃយើង ព្រះអង្គទ្រង់គង់នៅស្ងៀម ដូចជាតាបសដែរ ។ ព្រាហ្មណ៍ប្តីប្រពន្ធ ក៏រឹតតែមានសេចក្តីសង្ស័យទ្វេឡើងទៀត ហើយសួរព្រះសាស្តាថា បពិត្រព្រះសមណ-គោតមដ៏ចម្រើន តើមានពិធីអ្វីសម្រាប់ការពារគ្រោះ ដែលបំរុងនឹងកើតមានដល់កូនខ្ញុំព្រះអង្គ ឬទេ ? ព្រះសម្ពុទ្ធទ្រង់មានព្រះបន្ទូលថា ម្នាលព្រាហ្មណ៍ វិធីការពារមាន, គឺអ្នកត្រូវធ្វើមណ្ឌប (រោង) នៅក្បែរទ្វារផ្ទះ, ធ្វើតាំងដាក់កណ្តាលរោង ផ្តេកកូនលើតាំង ហើយក្រាលអាសនៈចំនួន ៨ ឬ ១៦ នៅជុំវិញកូននោះ រួចនិមន្តសាវ័កតថាគតឱ្យគង់សូត្រព្រះបរិត្តចំនួន ៧ ថ្ងៃ ៧ យប់ ជាប់គ្នា ។ កាលធ្វើបែបនេះ ទើបអាចបញ្ចៀសគ្រោះនោះបាន ។ ព្រាហ្មណ៍ទូលថា បពិត្រព្រះសមណគោតម ដ៏ចម្រើនខ្ញុំព្រះអង្គអាចធ្វើកិច្ចនេះបាន ប៉ុន្តែ ធ្វើម្តេចនឹងនិមន្តសាវ័ករបស់ព្រះអង្គបាន ? ព្រះសាស្តាទ្រង់ត្រាស់ថា ចូរអ្នកចាត់ចែងធ្វើកិច្ចការនោះចុះ ចាំតថាគតបញ្ជូនសាវ័កឱ្យទៅកាន់ទីនោះ ។

ពេលមុនប្រារព្ធពិធី ព្រាហ្មណ៍បានផ្តេកកូនលើតាំងកណ្តាលចំណោមភិក្ខុសង្ឃ ហើយព្រះសង្ឃក៏ចាប់សូត្រព្រះបរិត្តអស់រយៈ ៦ ថ្ងៃ លុះដល់ថ្ងៃជាគម្រប់ ៧ ព្រះសាស្តា ក៏ទ្រង់យាងចូលរួមក្នុងពិធីនោះដែរ ។ និយាយពីពួកទេវតាក្នុងចក្រវាឡ

ទាំងអសុរិញ ក៏បានមកជួបជុំគ្នានៅទីនោះ ក្នុងពេលដែលព្រះសាស្តាយាងទៅដល់ ។ ពួកទេវតាសក្តិធំៗ ចូលមកអង្គុយជិតជុំកន្លែងធ្វើពិធី រីឯទេវតាសក្តិតូចៗ ប្រច្រៀតគ្នាពីក្រោយកម្រាស់ ១២ យោជន៍ រីឯអវរុទ្ធកយក្ស បាននៅបម្រើស្តេចវេស្សវណ្ណ (ស្តេចយក្ស) អស់រយៈពេល ១២ ឆ្នាំ បានទទួលពរឱ្យមកស៊ីកូនព្រាហ្មណ៍ក្នុងថ្ងៃទី ៧ អំពីថ្ងៃដែលកូននោះកើត ក៏ពុំមានឱកាសចូលទៅចាប់ស៊ីតាមបំណងបាន ហើយចៀសចេញបាត់ទៅ ។

លុះដល់ថ្ងៃទី ៨, គ្រាន់តែព្រះអរុណរះឡើងភ្លាម ព្រាហ្មណ៍ប្តីប្រពន្ធ ក៏យកកូនទៅថ្វាយបង្គំព្រះសាស្តា ; ព្រះអង្គទ្រង់មានព្រះបន្ទូលថា « ទីឃាយុកោ ហោហិ ចូរឱ្យអ្នកមានអាយុវែង » ។ ព្រាហ្មណ៍សួរព្រះសម្ពុទ្ធទៀតថា បពិត្រព្រះគោតម តើកូនរបស់ខ្ញុំព្រះអង្គ នឹងមានអាយុតទៅប៉ុន្មានឆ្នាំ ? ព្រះសម្ពុទ្ធទ្រង់មានបន្ទូលថា កូនរបស់អ្នកនឹងមានអាយុដល់ ១២០ ឆ្នាំ ទើបស្លាប់ ។ ចាប់ពីពេលនោះ, ព្រាហ្មណ៍ប្តីប្រពន្ធ បានដាក់ឈ្មោះឱ្យកូនរបស់ខ្លួននោះថា « អាយុវឌ្ឍនកុមារ » តរៀងមក ។

ពិនិត្យទៅលើផ្ទៃរឿងដែលរៀបរាប់មកនេះ ឃើញថា ទស្សនៈស្តីពីពិធីរំដោះគ្រោះតាមបែបបុរាណាចារ្យរបស់ខ្មែរយើង និងតាមបែបដែលមានក្នុងគម្ពីរពុទ្ធសាសនា មានចំណុចជាមូលដ្ឋានស្របគ្នា ប៉ុន្តែ វិធីរំដោះគ្រោះតាមបែបខ្មែរ មានលក្ខណៈល្អិតម៉ត់ចត់ជាង ។

រៀបរៀងដោយ

**ម៉ែន ប្រាជ្ញ** និង **អាំ ឆន**

# ឈ្មោះបទភ្លេងខ្មែរ

ស្រាវជ្រាវដោយ **យី ធន់**

ខ្មែរជាជាតិសាសន៍មួយ ដែលមានទេពកោសល្យខ្ពស់ខាងសិល្បៈ តាំងពីរាប់ពាន់ឆ្នាំមកហើយ នៅភូមិភាគអាស៊ីអាគ្នេយ៍នេះ ។ ដូនតាយើងបានបន្សល់ទុកនូវស្នាដៃខាងសិល្បៈ វប្បធម៌ដ៏ល្បីល្បាញគ្រប់ផ្នែក ដែលប្រជាជាតិទាំងឡាយនៅលើសកលលោកកោតស្ញប់ស្ញែង ពិសេសគឺ សិល្បៈស្ថាបត្យកម្ម និងសិល្បៈនាដសាស្ត្រ ។ សិល្បៈនាដសាស្ត្ររបស់ខ្មែរ ជាសិល្បៈដ៏បរមបុរាណមួយដែលមានក្បាច់របាំរាប់ពាន់ មានចំណាស់រាប់ពាន់ឆ្នាំ និងមានកេរ្តិ៍ឈ្មោះល្បីរន្ទឺសុះសាយនៅលើសកលលោក ។ ជនបរទេស តែងតែកោតស្ញប់ស្ញែងចំពោះសិល្បៈធំៗ របស់ខ្មែរទាំងពីរនេះគ្រប់ៗ គ្នា ។ ប្រាសាទអង្គរវត្ត គឺជានិមិត្តរូបនៃប្រទេសខ្មែរ ។ ប៉ុន្តែ ខ្មែរមិនមែនមានតែប្រាសាទអង្គរវត្តប៉ុណ្ណោះទេ យើងនៅមានប្រាសាទសិលា ដែលមានសម្រស់ល្អ មិនអន់ជាងប្រាសាទអង្គរវត្ត រាប់រយប្រាសាទទៀតនៅពាសពេញលើផ្ទៃប្រទេសកម្ពុជាបច្ចុប្បន្ន និងនៅលើទឹកដី នៃប្រទេសជិតខាងខ្លះ ដែលពីបុរាណជាទឹកដីរបស់ព្រះរាជាណាចក្រ កម្ពុជា ។

ខ្មែរយើង នៅមានសំណង់សិល្បៈមួយទៀតដ៏ធំសម្បើម ដែលជនបរទេសមិនសូវស្គាល់ ប៉ុន្តែ ចំពោះប្រជារាស្ត្រខ្មែរ គឺជាសិល្បៈដែលមានលក្ខណៈប្រជាប្រិយបំផុតនោះគឺ សិល្បៈតន្ត្រី ។ សិល្បៈតន្ត្រីមានចំណែកមួយមិនអាចខ្វះបានក្នុងជីវភាពប្រចាំថ្ងៃ របស់មនុស្សខ្មែរ ។ តាំងពីកើតរហូតដល់ស្លាប់ ខ្មែរមានពិធីបុណ្យផ្សេងៗ ជាច្រើន ដោយមិនរាប់អំពីការកំសាន្តសប្បាយធម្មតាឡើយ ដែលសុទ្ធតែមានភ្លេងរបាំកំដរជានិច្ច ។ ព្រោះហេតុនេះបានជាខ្មែរ បង្កើតវង់ភ្លេងជា

ច្រើនក្រុមដើម្បីតម្រូវទៅតាមពិធីផ្សេងៗទាំងនោះ ។ រីឯឧបករណ៍ភ្លេង ក៏គេច្នៃប្រឌិតបានយ៉ាងសម្បូរបែបដែរ ។ បើរាប់តែក្រុមភ្លេងវង់ធំៗ ខ្មែរមានវង់ពិណពាទ្យ វង់ភ្លេងការ ភ្លេងអារក្ស វង់មហោរី វង់យីកេ វង់ភ្លេងកំដរល្ខោនបាសាក់ ឆៃយ៉ាំ ទ្រាំមីង ។ ល ។ វង់នីមួយៗ មានឧបករណ៍ដោយឡែក ទោះបីឧបករណ៍ខ្លះមានរូបរាង ឈ្មោះដូចគ្នា តែសូរសំឡេងនៃឧបករណ៍ក្នុងវង់នីមួយៗ មានលក្ខណៈដោយឡែកពិសេសរបស់ខ្លួន ។

គឺអាស្រ័យដោយសារសិល្បៈតន្ត្រីខ្មែរ មានលក្ខណៈប្រជាប្រិយម្យ៉ាង និង ម្យ៉ាងទៀតមានទ្រង់ទ្រាយប្លែកច្រើនក្រុម ច្រើនសណ្ឋានយ៉ាងនេះ ទើបគេបង្កើតបទភ្លេង និងទំនុកច្រើនសម្បូរបែបដែរ ។

បទភ្លេងដែលដូចខ្មែរបាននិពន្ធទុកមករាប់រយ រាប់ពាន់ សម្រាប់ប្រើទៅតាមក្រុម និងវង់ភ្លេងផង ទៅតាមពិធីផ្សេងៗផង ។ ប៉ុន្តែ គួរអោយស្តាយត្រង់ភ្លេង និងទំនុកច្រៀងទាំងឡាយនោះ បានរសាត់បាត់ទៅជាបន្តបន្ទាប់ ទៅតាមពេលវេលាដែលកន្លងទៅរាប់ពាន់ឆ្នាំ ដោយសារពុំបានកត់ត្រាទុកខ្លះផង និងដោយសារការវិនាសអន្តរាយ ដែលបណ្តាយមកពីសង្គ្រាមស៊ីវិលក្នុងស្រុកជាហូរហែរមកផង ។

ប៉ុន្តែទោះជាយ៉ាងណា ក៏យើងបានដឹងថា ដូនតាខ្មែរយើងបានបន្សល់ទុកឱ្យយើងនូវបទភ្លេងទាំងចាស់ ទាំងថ្មី សារុបទាំងអស់ជាងមួយពាន់បទ ដែលក្នុងនោះមានទាំងបទភ្លេងក្នុងវង់ភ្លេងការ វង់ពិណពាទ្យ វង់យីកេ វង់បាសាក់ វង់អារក្ស វង់មហោរី ។ល។

ខាងក្រោមនេះ គឺជាបញ្ជីឈ្មោះភ្លេងខ្មែរពីបុរាណ ដែលអ្នកស្រាវជ្រាវ ( មិនស្គាល់ឈ្មោះ ) បានចងក្រងទុកមកបានជាង ២០០ បទ ដែលយើងខ្ញុំនឹងចុះផ្សាយជាបន្តបន្ទាប់ ។ ខ្ញុំសូមឆ្លៀតឱកាសនេះជម្រាបលោកអ្នកអាន និងអស់លោកអ្នកជំនាញខាងវិជ្ជាតន្ត្រីថា បញ្ជីឈ្មោះភ្លេងខ្មែរនេះជាសំណៅដៃ ដែល

ខ្ញុំរើសបានពីគំនរសំរាម តាមដងមហាវិថីព្រះមុនីវង្ស នៅក្នុងឆ្នាំ ១៩៧៩ បន្ទាប់ពីទីក្រុងភ្នំពេញ ត្រូវបានរំដោះ ។

ខ្ញុំយល់ឃើញថា ឈ្មោះបទទាំងអស់នេះ មានសារសំខាន់សំរាប់ការសិក្សាស្រាវជ្រាវខាងប្រវត្តតន្ត្រី ប៉ុន្តែប្រការដែលគួរអោយបារម្ភ ហើយត្រូវយកចិត្តទុកដាក់នោះ គឺឈ្មោះបទភ្លេងទាំងបុរាណ ទាំងឈ្មោះថ្មី ដែលអ្នកស្រាវជ្រាវបានចងក្រងទុកមកនោះ មិនឃើញមានបញ្ជាក់ថា បានធ្វើការផ្ទៀងផ្ទាត់ ឬបញ្ជាក់ថាពិតជាត្រឹមត្រូវ ពីគណៈកម្មការជំនាញណាមួយឡើយ ។

អាស្រ័យហេតុនេះ យើងខ្ញុំសូមអំពាវនាវចំពោះសិល្បៈករ តន្ត្រីករ និងលោកអ្នកប្រាជ្ញខាងតន្ត្រីទាំងអស់ជួយកែតម្រូវ និងបំពេញបន្ថែមដើម្បីអោយឯកសារនេះ មានតម្លៃជាផ្លូវការតទៅ សំរាប់កូនចៅខ្មែរជំនាន់ក្រោយៗ រៀនសូត្រ ។

## ឈ្មោះបទភ្លេង

| ឈ្មោះថ្មី ឬឈ្មោះហៅ តាមភាសាខ្មែរទំនើប | | ឈ្មោះចាស់ ឬឈ្មោះហៅ តាមភាសាបរទេស |
|---|---|---|
| ១. ខ្មែរព្រះបន្ទំ | : | - ខ្មែនប៉ាក់បន្ទំ |
| ២. ខ្មែរច្រូតស្រូវ | : | - ខ្មែនកៀវខាវ |
| ៣. ខ្មែរដម្បាញ | : | - ខ្មែនប៉ាក់ថង |
| ៤. ខ្មែរបំពេរកូន | : | - ខ្មែនក្រមល្វក |
| ៥. ខ្មែរយោលទោង | : | - ខ្មែនសៃយោក (ប្រៃយោក) |
| ៦. កម្រងភ្លេងខ្មែរ | : | - ខ្មែនភ្លង |
| ៧. ខ្មែរផ្លុំស្លឹក | : | - ខ្មែនភីកែវ |

៨. ដំណើរខ្មែរ : - ដាំនើនខ្មែន

៩. ខ្មែរពោធិ៍សាត់ : - ខ្មែនពូនសាត់

១០. ខ្មែរគ្រួសារ : - ខ្មែនគ្រួសារ

១១. ចិនលក់ថ្នាំ (ចិនសែ) : - ជិនប៉ាយយ៉ា

១២. ចិនបង (ចិនចម្បង) : - ជិនភី, អាប៉ា

១៣. ចិនចាស់ : - ជិនប៉ិ, អាប៉ិ

១៤. ចិនចុងស្រុក : - ជិនខ្វាងទុង

១៥. ចិនធ្វើឆ្នាំង : - ជិនតយម៉ុរ

១៦. ចិនបើកវាំងនន : - ជិនប៉ុតម៉ាន

១៧. ចិនចុះទូក : - ជិនឡុងរឿ

១៨. ចិនទ្រកែវ : - ជិនប៉ាក់គួយ (ឈ្មោះជនជាតិចិនមួយក្រុម)

១៩. ចិនឈរមុខទូក : - ជិនណារឿ

២០. វាំផ្លិត : - វាំផាត់

២១. ដំណើរយឺត : - ឆា

២២. ដំណើររហ័ស : - រ៉េវ

២៣. បេះបុប្ផា : - កេបប៉ុប្ផា

២៤. ស្មារតីទន់ : - ខ្វាន់អន

២៥. ចិនបាំងតាំងយូ : - ជិនប៉ាងឡាង

២៦. ចិនបេះស្លឹកឈើ : - ជិនកេបប៉ាយម៉ាយ

២៧. ដំណើរចិន : - ដើតជិន

២៨. បេក្ខជន : - បេក្ខឆុន

២៩. ក្លួយកងឡេង : - ក្លួយកងឡេង

| | | |
|---|---|---|
| ៣០. រាំមន | : | . រ៉ាំម៉ន |
| ៣១. មនចុះទូក | : | . ម៉នឡុងរឿ |
| ៣២. ភ្លេងមន | : | . ម៉នភ្លេង |
| ៣៣. មនយោលដាវ | : | . ម៉នយោនដាប |
| ៣៤. ផ្គាស្រុកមនពីរនាក់ | : | . ខែកមនពីរជាន់ |
| ៣៥. ផ្គាស្រុកមនបីជាន់ | : | . ខែកមនបីជាន់ |
| ៣៦. ផ្គាទ្រមាក់ដឹរី | : | . ខែកមនបាំងឆាង |
| ៣៧. ផ្គាភោក្គា | : | . ខែកស្វូក |
| ៣៨. ផ្គារាំផ្លិត | : | . ខែករាំផាត់ |
| ៣៩. ផ្គាភ្នែកខ្លា | : | . ខែកតាសឿ |
| ៤០. ផ្គាឡើងរោង | : | . ខែកជីនចាវ |
| ៤១. ផ្គាស្រាវយុថ្កា | : | . ខែកថតសាម៉រ |
| ៤២. ផ្គាដើរទេស | : | . ខែកសាវ៉ាយ |
| ៤៣. ផ្គាដើរភូមិ | : | . ខែកចូវ៉ាន់បាយបូ |
| ៤៤. ផ្គារាជបូរី | : | . ខែករាជបូរី |
| ៤៥. ផ្គានពបូរី | : | . ខែកនពបូរី |
| ៤៦. ផ្គាស្រុកចៅសិន | : | . ខែកចៅស៊ិន |
| ៤៧. ផ្គាខ្សឹកខ្សួល | : | . ខែកសាអ៊ីន |

( នៅមានត )

# គួរយើងទុកវត្ថុខ្លះ នៅខាងក្រោយយើង

គេមិនសុំឱ្យយើងបង្កើតនូវអច្ឆរិយវត្ថុនោះទេ តែសុំឱ្យយើងទុកវត្ថុខ្លះពេលដែលយើងលាចាកភពផែនដីនេះទៅ ។ ភាសិតឥណ្ឌាមួយ បានពោលថា « នរណាបានដាំដើមឈើមួយដើម មុននឹងអនិច្ចកម្មទៅ នរនោះកើតមកនៅក្នុងលោកមិនឥតប្រយោជន៍ទេ », អ្នកនោះយ៉ាងហោចណាស់ ក៏បានបន្ថែមនូវវត្ថុខ្លះដល់មនុស្សជាតិ ។

ដើមឈើមួយដើម គ្រឿងឧបករណ៍មួយមុខ វត្ថុសិល្បៈមួយ ផ្លូវថ្នល់មួយ មន្ទីរពេទ្យមួយ សួនច្បារមួយ ស្រះទឹកមួយ អគារសិក្សាមួយ រោងចក្រមួយ ការរកឃើញនូវវិទ្យាសាស្ត្រមួយមុខ ។ ល ។ និង ។ ល ។ នេះហើយដែលយើងម្នាក់ៗ អាចបន្ថែមទៅលើរតនវត្ថុរួមគ្នា ។

បុព្វបុរសរបស់យើង បានទុកកេរដំណែលយ៉ាងប្រណីតៗដល់យើង គួរយើងរក្សាថែទាំនូវកេរដំណែលដ៏កម្រនេះ សំរាប់កូនចៅយើង និង សំរាប់មនុស្សជាតិនៅលើផែនពសុធានេះ ។

ប្រសិនបើគ្មានរបបប៉ុលពតទេនោះ យើងមុខជាសប្បាយជាងដូនតាយើង ដូច្នេះគួរតែយើងធ្វើឱ្យមនុស្សជំនាន់ក្រោយយើងចេះដឹងជាងយើង មានសមត្ថភាពជាងយើង សម្បូរជាងយើង ។

ប្រែ និងរៀបរៀងដោយ

**ហៀន ចណ្ឌារ័ក្ខ**

រឿងព្រេងបារាំង

# រឿងមិត្តសម្លាញ់ពីរនាក់

កាលពីព្រេងនាយ មានដំណាលថា មានបុរសពីរនាក់បានចងមិត្តនឹងគ្នា ជាសម្លាញ់ស្លាប់រស់ជាមួយគ្នា ។ គ្រប់ពេលវេលា ទោះជាកន្លែងណា ឬទីណាក៏ដោយ ក៏គេតែងឃើញបុរសទាំងពីរនៅជាមួយគ្នាជានិច្ច មិនដែលឃើញម្នាក់បាត់ម្នាក់ណាឡើយ ។ លើសពីនេះទៀត បុរសទាំងពីរនេះគោរពស្រឡាញ់គ្នា មិនខុសពីបងប្អូនបង្កើតឡើយ ។

មានយប់មួយនោះ គេទាំងពីរនាក់ទៅលេងផ្ទះមិត្តស្រីរបស់គេ នៅពេលត្រឡប់មកវិញ គេបានសន្យានឹងគ្នាថា យើងទាំងពីរនាក់ជាសម្លាញ់ស្លាប់រស់នឹងគ្នា យើងសន្យាថា ទោះបីយើងស្លាប់ ឬរស់ យើងនឹងអញ្ជើញគ្នាទៅចូលរួមក្នុងពិធីរៀបការរបស់យើងរៀង១ខ្លួន ។

ពេលវេលាចេះតែកន្លងទៅ ជាភព្វអាក្រក់ បុរសម្នាក់ក្នុងចំណោមសម្លាញ់ទាំងពីរនាក់ បានធ្វើមរណកាលទៅ ។ រីឯបុរសម្នាក់ទៀតដែលនៅរស់ ក៏កើតទុក្ខ សោកសៅក្រៃលែង មិនអាចពណ៌នាបានចំពោះមរណភាពរបស់មិត្តខ្លួននេះ ។ ប៉ុន្តែ ដោយសារខ្លួនមានអាយុកាន់តែច្រើន បុរសនោះក៏សម្រេចកសាងគ្រួសារ ។ គេបានទៅស្ដីដណ្ដឹងនារីជាទីស្រឡាញ់គេ ព្រមទាំងកំណត់ថ្ងៃរៀបការជាស្រេច ។ ដោយគោរពតាមពាក្យសន្យារបស់ខ្លួន បុរសនោះបានទៅឯទីប៉ាឆា កន្លែងដែលគេកប់ខ្មោចមិត្តរបស់ខ្លួន ។ នៅពេលទៅដល់ បុរសនោះបានអង្គុយនៅចំពោះមុខផ្នូរ រួចស្រែកហៅសម្លាញ់របស់គេ ហើយនិយាយថា ៖ «សម្លាញ់អើយ ! ខ្ញុំនឹងរៀបការក្នុងថ្ងៃខាងមុខនេះហើយ យើងបានសន្យានឹងគ្នាថា ទោះជាស្លាប់ ឬរស់ យើងនឹងអញ្ជើញគ្នាទៅចូលរួមក្នុងពេលរៀបមង្គលការរៀង១ខ្លួន ឥឡូវខ្ញុំត្រូវរៀប

ចំការហើយ ខ្ញុំមកនេះ គឺដើម្បីមកអញ្ជើញសម្លាញ់ទៅចូលរួមក្នុងពិធីរៀបអាពាហ៍-ពិពាហ៍របស់ខ្ញុំ សូមសម្លាញ់អញ្ជើញទៅកុំខាន» ។

រំពេចនោះ សម្លាញ់ដែលស្លាប់ទៅហើយនោះ បានបង្ហាញខ្លួននៅចំពោះមុខមិត្តរបស់ខ្លួន ដោយមានរូបរាងដូចកាលពីនៅរស់ដូច្នោះ ។ បុរសដែលស្លាប់ទៅហើយនោះ បាននិយាយតបវិញថាខ្លួននឹងទៅកំដរមិត្តខ្លួនក្នុងពិធីរៀបការនោះ ដើម្បីនាំកូនក្រមុំទៅព្រះវិហារ ។

ថ្ងៃរៀបការបានមកដល់ បុរសដែលស្លាប់ទៅហើយនោះ ក៏ធ្វើដំណើរទៅចូលរួមតាមពាក្យសន្យា ប៉ុន្តែក្នុងចំណោមមនុស្សនៅទីនោះ មានតែកូនកំលោះនិងកូនក្រមុំទេ ដែលមើលឃើញបុរសដែលស្លាប់ទៅហើយនោះ ។ ភ្ញៀវទាំងឡាយនាំគ្នាចម្លែកក្នុងចិត្តពេកណាស់ ដោយឃើញពិធីអាពាហ៍ពិពាហ៍នេះប្លែកពីធម្មតា ព្រោះពុំឃើញមានអ្នកកំដរកូនកំលោះមកនាំកូនក្រមុំ ដូចសព្វដងឡើយ ។ អាពាហ៍-ពិពាហ៍បានប្រព្រឹត្តទៅយ៉ាងអឺកអធឹក និងសប្បាយរីករាយទាំងអស់គ្នា ។ នៅពេលភ្ញៀវទាំងឡាយត្រឡប់ទៅផ្ទះវិញអស់ បុរសអ្នកកំដរកូនកំលោះនោះ ក៏លាសម្លាញ់វិលទៅស្រុកខ្មោចវិញដែរ តែមុននឹងទៅ បុរសនោះបានប្រាប់សម្លាញ់របស់ខ្លួនថានៅពេលណាខ្លួនរៀបការនោះ ខ្លួននឹងមកអញ្ជើញទៅចូលរួមក្នុងពិធីរៀបការ នៅស្រុកខ្មោចវិញម្តង ។

ក្រោយពេលនោះបន្តិចមក បុរសនៅស្រុកខ្មោចក៏មកប្រាប់សម្លាញ់ខ្លួនឱ្យទៅចូលរួមក្នុងពិធីរៀបការខ្លួន តាមទម្លាប់របស់អ្នកស្រុកខ្មោចមែន ។

បុរសនៅស្រុកខ្មោច ប្រាប់ឱ្យសម្លាញ់ខ្លួនទៅចាំនៅផ្លូវកាច់ជ្រុង ជិតទីប៉ាឆា នៅម៉ោងពេល ថ្ងៃ ខែ ដែលបុរសអ្នកស្រុកខ្មោចកំណត់ឱ្យ ។ ពេលវេលាបានមកដល់ បុរសដែលនៅរស់បានលាប្រពន្ធខ្លួនទៅហូបការសម្លាញ់ខ្លួន នៅស្រុកខ្មោច ។ គេបានដើរតម្រង់ទៅរកកាច់ជ្រុងផ្លូវនៃទីប៉ាឆាកប់ខ្មោច ។ លុះទៅដល់

កន្លែងដែលបុរសនៅស្រុកខ្មោចប្រាប់អោយទៅនោះ បុរសនៅស្ថានមនុស្សបាន ឃើញសេះឈ្មោលតូចមួយក្បាល រោមសក្បុះ មានចងអាន ចងកែបយ៉ាងស្អាត ឈរចាំជាស្រេច ។ បុរសនោះ ក៏ផែលលើខ្នងសេះនោះភ្លាម ។ រំពេចនោះ កូនសេះ សក៏ស្ទុះផាយលឿនដូចព្រួញ នាំបុរសជាមនុស្សនោះឆ្លងកាត់ភូមិ ស្រុកដ៏ចម្លែកៗ យ៉ាងឆ្ងាយដាច់សង្វែង រួចហើយទៅឈប់នៅកន្លែងមួយ ដោយមាត់ដង្ហក់យ៉ាងខ្លាំង ញើសហូរជោគខ្លួនដូចគេងូតទឹក ។

បុរសនៅស្រុកខ្មោច បានឈរចាំទទួលសម្លាញ់របស់គេនៅទីនោះជា ស្រេច ។ រំពេចនោះដែរ ពិធីរៀបការក៏ចាប់ផ្តើមឡើង រួចអូសបន្លាយអស់ពេល បីថ្ងៃ ទើបចប់ ។ លុះចប់ពិធី បុរសជាមនុស្សបានលាប្តីប្រពន្ធដែលទើបរៀបការថ្មី វិលមកលំនៅខ្លួនវិញ ។ បុរសនោះឡើងជិះសេះសតូចល្អិតដដែលនោះ ធ្វើដំណើរ ត្រឡប់មកវិញយ៉ាងលឿន ឆ្លងកាត់ភូមិ ស្រុកចម្លែកៗតាមផ្លូវដែលខ្លួនបានធ្វើ ដំណើរទៅ ។ ប៉ុន្តែ នៅពេលដែលគាត់ត្រឡប់មកដល់ភូមិកំណើតគាត់វិញនោះ អ្វីៗ បានផ្លាស់ប្តូរអស់រលីងទៅហើយ ។ ដើមគគីរដែលកាលពីថ្ងៃគាត់ចេញទៅទើបប៉ុន កដៃសោះ ឥឡូវស្រាប់តែចាស់រហូតដល់ពុកគល់រលំបាត់ទៅហើយ ។ បុរសនោះខំ រកញាតិសន្តានរបស់ខ្លួន តែគ្មានស្គាល់នរណាម្នាក់សោះឡើយ ។ ប្រពន្ធគាត់ មិត្តភ័ក្តិ គាត់ ឪពុកម្តាយគាត់ បានស្លាប់អស់តាំងពីយូរយារណាស់ទៅហើយ ។

រយៈពេលបីរយឆ្នាំ បានកន្លងទៅមុខហើយ បើគិតពីថ្ងៃដែលបុរសនោះ ចេញទៅហូបការសម្លាញ់គាត់នៅស្រុកខ្មោច មកដល់ថ្ងៃដែលគាត់ត្រឡប់មកវិញ នេះ ។

ប្រែសម្រួលពីប្រជុំរឿងព្រេងបារាំង

ដោយ **កុសល**

# សេចក្តីជូនដំណឹង
# អំពីលទ្ធផល នៃចម្លើយ « កំណាព្យប្រស្នា »
# ដែលបានចុះក្នុងទស្សនាវដ្តីកម្ពុជសុរិយា លេខ៣
# ឆ្នាំ ១៩៩៤

គណៈកម្មការនិពន្ធ នៃទស្សនាវដ្តីកម្ពុជសុរិយា មានកិត្តិយសសូមប្រគេន និងជូនដំណឹងចំពោះព្រះតេជព្រះគុណ និងចំពោះអស់លោក អ្នកនាងកញ្ញា ព្រមទាំងមិត្តអ្នកអានទស្សនាវដ្តីកម្ពុជសុរិយា ជាទីគោរពថា គណៈកម្មការនិពន្ធបានទទួលលិខិតរបស់ព្រះតេជព្រះគុណ និងលោកអ្នកអានចំនួន ២៩ ច្បាប់ ដែលសុទ្ធជា " កំណាព្យ " ឆ្លើយតបទៅនឹងប្រស្នាដែលបានចុះផ្សាយក្នុងទស្សនាវដ្តីកម្ពុជសុរិយា លេខ ៣ ឆ្នាំ ១៩៩៤ ។ ប៉ុន្តែ ក្នុងចំណោមលិខិតទាំងនោះ ពុំមានលិខិតណាមួយឆ្លើយត្រូវនឹងកំណាព្យប្រស្នានោះឡើយ ។ ព្រះតេជព្រះគុណ និងលោកអ្នកអានភាគច្រើនឆ្លើយថា ជាល្បែងខ្លាឃ្លោក រីឯលោកអ្នកអានមួយចំនួនទៀតឆ្លើយថា ផ្លែល្វា ។

ដោយគ្មានអ្នកឆ្លើយត្រូវយ៉ាងនេះ គណៈកម្មការនិពន្ធសម្រេចរក្សាប្រាក់រង្វាន់នៃទស្សនាវដ្តីលេខ ៣ នេះ ទុកជូនជ័យលាភីដែលឆ្លើយត្រូវនឹងចំណោទប្រស្នានៃទស្សនាវដ្តីលេខ ១ ឆ្នាំ ១៩៩៥ វិញ ។

ជាមួយគ្នានេះដែរ គណៈកម្មការនិពន្ធមានសេចក្តីរីករាយនឹងចុះផ្សាយ " កំណាព្យចម្លើយ " របស់ម្ចាស់សំណួរ ដើម្បីជូនលោកអ្នកអានយកទៅផ្ទៀងផ្ទាត់នឹងសំណួរដែលម្ចាស់ប្រស្នាបានចោទផង និងដើម្បីជូនលោកអ្នកម្ចាស់ចម្លើយបានផ្ទៀងផ្ទាត់នឹងចម្លើយរបស់ខ្លួនផង ។

នៅក្នុងទស្សនាវដ្ដីលេខ ១ ឆ្នាំ ១៩៩៥ នេះដែរ គណៈកម្មការនិពន្ធ និង ឯកឧត្ដម វណ្ណ ស៊ុនហេង បានសម្រេចយក " កំណាព្យប្រស្នា " របស់លោក គង់ វេទ ធ្វើការនៅក្រសួងធម្មការ និងសាសនា មកចុះផ្សាយជំនួស ដោយគណៈកម្មការនិពន្ធបានពិនិត្យឃើញថា " កំណាព្យប្រស្នា " របស់លោក គង់ វេទ មានខ្លឹមសារសមល្មមអាចចុះផ្សាយបាន ។ ចំពោះរង្វាន់ផ្សេងៗ គណៈកម្មការនិពន្ធនៅរក្សាដូចលើកមុនៗដដែល គឺអាស្រ័យដោយឯកឧត្ដម វណ្ណ ស៊ុនហេង ជាអ្នកឧបត្ថម្ភ ។

ដោយឡែក ដើម្បីជាការលើកទឹកចិត្តចំពោះលោក គង់ វេទ ដែលបានឆ្លើយនឹងកំណាព្យប្រស្នារបស់ទស្សនាវដ្ដីកម្ពុជសុរិយា លេខ ៣ ឆ្នាំ ១៩៩៤ ព្រមទាំងបានផ្ដល់ " កំណាព្យប្រស្នា " មួយថែមទៀតនោះ គណៈកម្មការនិពន្ធសម្រេចចុះផ្សាយកំណាព្យចម្លើយរបស់លោក គង់ វេទ ក្នុងទស្សនាវដ្ដីលេខ ១ ឆ្នាំ ១៩៩៥ នេះ ទោះបីកំណាព្យនេះមិនបានឆ្លើយត្រូវនឹងសំណួរ ក៏ដោយ ។

**កម្ពុជសុរិយា**

# ចម្លើយកំណាព្យប្រស្នា

កម្ពុជសុរិយា លេខ ៣ (បទពុំនោល)

* ពុំនោលពោលពីប្រស្នា កម្ពុជសុរិយា ចារជាចំណោទចោទឆ្លើយ ។
. ពីរលើកបានចេញរួចហើយ ទីបីនៅឡើយ សូមឆ្លើយឱ្យអស់សង្ស័យ ។
. ប្រស្នាការប្រឌិតឆ្នៃ ខិតខំកែខៃ និស្ស័យកិច្ចកលកំសាន្ត ។
. ចំលើយឆ្លើយជូនសន្តាន មិនឱ្យខកខាន ពីរឿងពងសត្វចម្លែក ។
* ពងមួយញាស់ច្រើនអនេក ខ្ញុំសូមបំបែក ចែកជូនទៅតាមគំនិត ។
. ពាក្យពងជាពាក្យប្រឌិត មិនមែនពងពិត គឺជាតួអក្សរ **ឆ** ។
. សូមទោសព្រោះប្រស្នាភ សត្វអក្សរ **ឆ** ប្រមូលបានដប់ប្រាំបី ។
. ដំបូងរាប់សត្វបក្សី មានហើរដើរដី ចំនួនប្រាំបួននោះណា ។
* មួយសត្វទទាបក្សា ហើរលើវេហា ទីពីរគឺទាស្រុកព្រៃ ។
. ទីទុយរាប់បានគ្រប់បី បួនទុងស៊ីត្រី ប្រាំទៀវពណ៌ខៀវស្រអាប់ ។
. ប្រាំមួយសត្វទោមស្គាល់ស្រាប់ ប្រាំពីរខ្ញុំប្រាប់ សត្វទងកន្ទ្រែនោះឯង ។
. ប្រាំបីទុកទ្រូស្លាថ្លែង ប្រាំបួនចារចែង ចំទ្រមាក់ខ្លាបក្សី ។
* ប្រាំទៀតជាសត្វដើរដី នឹងពោងឈើព្រៃ កវីរៀបរាប់បន្ត ។
. មួយទ្រាយទ្រើសទ្រង់បវរ ពីរទន្សោងចរ ស៊ីល្បះព្រិចខ្ចីព្រៃភ្នំ ។
. ទីបីទន្សាយប្រាជ្ញព្រហ្ម ទីបួនទោចយំ ទីប្រាំគឺសត្វទន្សង ។
* ពីរទៀតជាមច្ឆាផង ទីពោតែម្តង នឹងត្រីទ្រនាលនោះមិញ ។
* រីឯខាងសត្វលូនវិញ មានពីរបំពេញ គឺពស់ទងព្រៅនិងទាក ។

* តួ ៩ ប្រស្នាពោលពាក្យ ជាពងបែងភាគ ញាស់បានសត្វដប់ប្រាំបី ។
- ល្បោយល្បិចកលកិច្ចករី ពាក្យពុំគប្បី ខន្តីសេន្ទាសប្រោសប្រាណ ។
- គំនិតគិតឃើញប៉ុន្មាន ផ្ញើជូនសន្តាន កំសាន្តសប្បាយប៉ុណ្ណោះ ។
- ទោះបីសេចក្តីត្រូវខុស លើកទ្បាត់កាត់ចុះ ជាប់គ្នាជាមិត្តរៀងរើយ ។

ថ្ងៃទី២២ ខែមករា ឆ្នាំ ១៩៩៥

**ខណ្ឌ ស៊ុនហេខ**

# ឆ្លើយប្រស្នា ជាកំណាព្យ

( បទរលកជួបច្រាំង )

សូមអភិវន្ទទន់សំពះម្ចាស់ប្រស្នា ដែលបានចារជាចំណោងក្រងកវី
ឱ្យរស់មិត្តគិតរិះរេផ្ទេរអត្ថន័យ ស្រាយសេចក្ដីន័យចំណោទចោទបញ្ហា ។
• " មានពងសត្វមួយចម្លែកប្លែកពីគេ ពងមួយទេទ្វេញាស់បានប្រាណត្រៀបត្រា
ជាបក្សីជាទ្រីតីជាមច្ឆា ឱរង្គ " ណា ត្រាដើមដងប៉ងឱ្យស្រាយ ។
• ខ្ញុំគិតអស់ច្រោះចម្រាញ់កាញ់សាកល្បង គ្មានតែម្ដងពងក្នុងលោកបួកបរិយាយ
ពងតែឯកប្លែកបង្អស់ញាស់កើតកាយ រសវីកសាយដល់ទៅបួនកូនខុសគ្នា ។
• តាមន័យបើក (១) លើករូបជាក់ធ្លាក់ចំណែក " ពងមួយប្លែក" បែកបានកូនបួនអង្គា
តែន័យបិទ (២) ផ្ចិតយករសនោះឃើញទ្វារ អាចពណ៌នាជាសម្រាយស្រាយចេញបាន ។
" ពងចម្លែក "ប្លែកនិមល "គល់សាសនា ព្រះសាស្ដា " ថ្នាវិស័យថ្លៃកល្យាណ"
ពងចម្លែក "ប្លែកមរតក " បិដកថ្កាន" ព្រះទ្រង់បានប្រាណប្រាយប្រាប់ច្បាប់អប់រំ ។
• " ពងចម្លែក "ប្លែកវិស័យថ្លៃអន័ឃ្យ មួប់ត្រជាក់ខ្ជាក់រស់ទុក្ខសុខឧត្ដម
នេះ,ន័យ "ពង" ល្បងបកស្រាយផ្សាយផ្សំផ្សំ ពោលឱ្យចំក្រមក្រឹត្យស្នាមតាមយល់ដឹង ។
* _ វិចំណែកចែកចំនួន" កូនទាំងបួន " ជាតិដោយខ្លួនមិនស្ទួនគ្នាគ្រានេះហ្នឹង
តាមតម្រិះរិះដើមដានបានដំណឹង ភេទផ្សឹង៧សត្វទាំងបួនជូនន័យថា : ។
* បរិស័ទចាត់ជិតកូលឈ្មោកពិសី ចាំរង្សីនៃសួរ្យសែងចែងសុរិយា
កើតសទ្ធាជាក្រសៃប្រែជ្រះថ្លា តាំងប្ដេជ្ញាប្រគល់កាយថ្វាយត្រៃរតន៍ ។
* បួសជាភិក្ខុភិក្ខុនីក្រើកម្ចាត់ កិលេសខ្ជាត់បាត់សៅហ្មងប៉ងរម្ងត់
បានជាសង្ឃអង្គសាវ័កជាក់ប្រាកដ សូមកំណត់កូនដំបូងយោងទីពីរ ។

* អ្នកមិនបួសព្រោះជិនាប់ជាប់ជំពាក់
គេទទួលស្រួលស្រស់ស្រាន្តបានត្រឹមទី
* នេះ, ជាល្បាប់រាប់ឈ្មោះកូន ទីបីប្អូន
ញាស់កូនប្អូនជូនគម្រប់ឈប់ចរចា
• ព្រះទ្រង់ឫទ្ធិជិតនិព្វានមានឥតម្រាស់
ជាបរិស័ទចាត់សាវ័កថ្នាក់ថ្នាថ្លៃ

កិលេសធ្លាក់ស្រាក់ជីវិតរីតជីវី
ថ្វាយជីវីជាបាសកបាសិកា ។
ថែមបន្ទន់ជូនសណ្ដាប់ប្រាប់អស់អាថិ
គឺបរិវារព្រះចមម្កុដផុតភពព្រៃ ។
បញ្ជាក់ច្បាស់ថាអ្នកស្នំត្រជាក់និស្ស័យ
ឧត្តមក្រៃគឺបុត្រស្ងួនប្អូននេះឯង ៕

ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត, ថ្ងៃទី ១៣ ធ្នូ ១៩៩៤

**គង់ ខេង**

---

១. អត្តានុរូប
២. អត្តប្បដិរូប

## សូមបន្ថែមដើម្បីលើកទឹកចិត្ត
## ដល់ កម្ពុជសុរិយា

# អ្នកប្រើជញ្ជីង

( បទកាកគតិ )

នៅក្នុងប្រទេស ខ្មែរយើងពិសេស ចេះច្នៃប្រឌិត
តាមខ្ញុំចំណាំ នៅក្នុងគំនិត សង្កេតពិតៗ
ឥតភាន់ច្រឡំ ។

ជញ្ជីងអ្នកធ្វើ ល្អមួយអន្លើ ពុំក្លែងបន្លំ
ត្រឹមត្រូវឥតខ្ចោះ ឥតទាស់ភ្នែកខ្ញុំ ល្អឈ្មោះត្រសុំ
ត្រសាយថ្លៃថ្លា ។

ជញ្ជីងអ្នកប្រើ កែច្នៃបណ្ដើរ អោយខុសក្រឡា
ចំណេញដល់ខ្លួន ក្រាស់ក្រៃអស្ចារ្យ ពុំតាមតម្រា
ជញ្ជីញដើមឡើយ ។

ជញ្ជីងថ្លឹងចូល គេយកទៅបូល រួមថែមកូនហើយ
ដើម្បីអោយបាន ទម្ងន់កើនកើយ រួចមិនកន្តើយ
ចាប់ថ្លឹងតទៅ ។

ជញ្ជីងលក់ចេញ ឆាបកូនទៅវិញ ដើម្បីតម្រូវ
ទៅតាមប្រាថ្នា អោយស៊ីជម្រៅ រួចទើបថ្លឹងទៅ
បានដូចបំណង ។

ជញ្ជីងមានច្រើន សម្បុរកើតកើន ពេកពន់កន្លង
តែពុំដូចគ្នា អ្វីសោះតែម្តង ហើយអ្នកប្រើផង
ក៏ពុំដូចដែរ ។

ជញ្ជីងគ្រប់មុខ មានទូទាំងស្រុក សម្រាប់រាស្ត្រខ្មែរ
មានច្រើនប្រភេទ ត្រូវរក្សាថៃ សូមលោកកុំកែ
ច្នៃជញ្ជីងបោង ។

ភិក្ខុ **ពិន ពេញ** ( សទ្ធា សោភនោ )
សមណសិស្ស ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត
គង់នៅកុដិចាស់ វត្តបទុមវតី ភ្នំពេញ

## កំណាព្យប្រស្នា

# ការលុបដ៏ចម្លែក

- នៅលើការលុបគ្រប់ប្រការ យើងតែងដឹងថា " លុបបំបាត់ "
 គឺលុបក្តីព្រាងលាងកម្ចាត់ ធ្វើឱ្យរសាត់ខ្ចាត់រូបតាង ។
- ប៉ុន្តែ, ការលុប ១ ចម្លែក ជាល្បែបយ៉ាងឯកប្លែកដោយយ៉ាង
 គេបានលុបពិត " រីតច្បាប់តាង " គំនូរ - រូបសាងលេចត្រដែត ។
- តើលុបលើអ្វីលែដោះសា សូមមិត្តពិចារណ៍ស្មាររកហេតុ
 លុបរួច, ចេញរូបច្បាស់ក្រឡែត អណ្តែតឃើញស្រាប់ច្បាប់ប្រើការ ។
- យកល្អ, សូមមិត្តធ្លាប់ឆ្លងកាត់ កិច្ចការលំបាត់ស្ទាត់តម្រា
 ប្រាប់ឱ្យសព្វគ្រប់ " ភពលក្ខណា វត្ថុ-កិច្ចការ " ស្មារមកផង ! ។
- ល្បែងល្បងស្រួចស្រស់ដោះប្រស្នា នាំឱ្យបានក្លាថ្លាបំណាង
 មិត្តអើយរីករាយគិតឆ្លើយឆ្លង នាំគ្នាផ្សូរផ្សងល្បងប្រាជ្ញា ! ។

វិទ្យាល័យព្រះសុរាម្រឹត, ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ១៩៩៥

**គង់ វេង**

# សេចក្តីអំពាវនាវ
# របស់ពុទ្ធសាសនបណ្ឌិត្យ

ឆ្នាំ ១៩៩៥ នេះ ជាឆ្នាំខួបទី ១៣០ នៃកំណើតរបស់កវីអ្នកព្រះភិរម្យភាសាអ៊ូ ហៅ ង៉ុយ ។ នៅក្នុងឱកាសដ៏មហោឡារិកនេះ ពុទ្ធសាសនបណ្ឌិត្យ និងទស្សនាវដ្ដីកម្ពុជ-សុរិយា នឹងបោះផ្សាយកម្រងស្នាដៃរបស់អ្នកព្រះភិរម្យភាសាអ៊ូ ឡើងវិញទាំងស្រុង ដើម្បីជាកិត្តិយសចំពោះអ្នកកវីប្រជាប្រិយដ៏ឆ្នើមនេះ ។ ស្នាដៃរបស់លោក ដែលពុទ្ធសាសនបណ្ឌិត្យបានចងក្រង និងបោះពុម្ពកន្លងមក មានតែ ៤ ច្បាប់ ប៉ុណ្ណោះ ។ ពុទ្ធសាសនបណ្ឌិត្យ មានជំនឿថា ស្នាដៃជាពាក្យកាព្យ - ជាច្បាប់ទូន្មាន - ជារឿងកំប្លុកកំប្លែង របស់លោកអ្នកកវីប្រជាប្រិយដែឯកនេះ នៅមានសល់ច្រើនទៀត ដែលដក់ជាប់ដោយការចងចាំតៗគ្នា ក្នុងចំណោមបងប្អូនប្រជាជនយើង ដែលស្រឡាញ់កំណាព្យ និងសំនួនវោហាររបស់លោក ។

អាស្រ័យហេតុនេះ ពុទ្ធសាសនបណ្ឌិត្យ សូមអំពាវនាវចំពោះអស់លោកអ្នកនាង ដែលបានចេះចាំកំណាព្យរបស់កវីអ្នកព្រះភិរម្យភាសាអ៊ូ ហៅង៉ុយ សូមមេត្តាផ្ញើអត្ថបទកំណាព្យទាំងឡាយនោះ ទៅពុទ្ធសាសនបណ្ឌិត្យ ( ក្រសួងធម្មការ និងសាសនា ) ដែលមានទីស្នាក់ការនៅវត្តឧណ្ណាលោម ដើម្បីពុទ្ធសាសនបណ្ឌិត្យ ចាត់ចែងបោះពុម្ពផ្សាយបន្ថែមពីលើអត្ថបទកំណាព្យ ដែលបានបោះពុម្ពរួចហើយពីមុនមក ។

ដើម្បីជាគុណប្រយោជន៍ដល់សេចក្តីរុងរឿងនៃអក្សរសិល្បខ្មែរ ពុទ្ធសាសន-បណ្ឌិត្យមានសេចក្តីសង្ឃឹមថា អស់លោកអ្នកនាង ប្រាកដជានឹងឆ្លើយតបចំពោះសេចក្តីអំពាវនាវនេះ ជាមិនខាន ។

សូមអរគុណ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ




ឆ្នាំទី ៤៩ លេខ ២ ខែ មេសា - ឧសភា - មិថុនា

ព.ស ២៥៣៩ គ.ស ១៩៩៥

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :


ទីប្រឹក្សា : **ហៀន ចណ្ឌារក្ខ**

នាយកការផ្សាយ : **ឈន អៀម**

និពន្ធនាយក : **យី ធន់**

និពន្ធនាយករង : **ឱម ខែម**

គណៈកម្មការនិពន្ធ

សម្ដេចព្រះធម្មលិខិត **លាស់ ឡ្យាយ**, ព្រះមហាព្រហ្មមុនី **ហេង លាងហោ**,

លោក **ម៉ែន ប្រាង**, លោក **អាំ ឆន**,

## ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの宗教と文化の発展に貢献できれば幸いです。

## ACKNOWLEDGEMENT

The Kampuja Surya Magazine is specially printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC).

We pray that this magazine would contribute to the Friendship with Cambodian people and their religious and cultural preservation.

## និវេទនកថា

ទស្សនាវដ្ដីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគម្រោងការងារ របស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោកស្ដីពីសាសនានិងសន្តិភាព (WCRP) ហើយនិងគណៈកម្មាធិការជំនួយសូតូស៊ូជប៉ុន (JSRC) ។

យើងខ្ញុំអធិដ្ឋាន សូមឱ្យទស្សនាវដ្ដីនេះ បានជាវិភាគមានរក្សាមិត្តភាពជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិសាសនានិងវប្បធម៌របស់ប្រជាជនកម្ពុជា ។

# មាតិកាអត្ថបទ

## I. អក្សរសិល្ប៍ពុទ្ធសាសនា


- ពុទ្ធសាសនា និងសង្គម (ព្រះតេជព្រះគុណវិមលរតនៈ) ១
- បែបបទដើម្បីមើលឃើញព្រះពុទ្ធ (ព្រះតេជព្រះគុណវិមលរតនៈ) ១០
- អំពីភិក្ខុ ឬភិក្ខុសង្ឃ (ឈេន អៀម) ១៥
- ការចាំវស្សារបស់ព្រះសង្ឃ (ម៉ែន ប្រាង និង រអាំ ឆន) ៤៣
- ការចេញវស្សារបស់ព្រះសង្ឃ (ម៉ែន ប្រាង និង រអាំ ឆន) ៥៥
- កឋិនទាន (ម៉ែន ប្រាង និង រអាំ ឆន) ៦៥


## II. អក្សរសាស្ត្រទូទៅ


- សិលាចារឹកជាប្រភពនៃការសិក្សាអក្សរសាស្ត្រ និងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា (បណ្ឌិត ឡុង សៀម) ៧៩
- ច្បាប់ល្បើកថ្មី (ព្រះភិរម្យភាសា អ៊ូ ហៅ ង៉ុយ) ៩៦
- បញ្ជីឈ្មោះបទភ្លេងខ្មែរ (ត) (ស្រាវជ្រាវដោយ យី ធន់) ១៣០
- គួរគ្រាប់ដើមត្នោត (កវី អ៊ូ ចុង) ១៣៦
- ការប្រព្រឹត្តិនាំអោយថោកពុទ្ធសាសនា (វ៉ាយ វិបុល) ១៣៨
- គំនិតស្វែងយល់ពីអ្នកជក់បារី (វេជ្ជ. យុន ង៉ែត និង ហៀន វណ្ណរត្ន) ១៤២
- សេចក្តីជូនដំណឹងអំពីលទ្ធផលនៃចម្លើយប្រស្នាកំណាព្យ ១៤៥
- ចម្លើយកំណាព្យប្រស្នា (តឹក ប៊ុន ឈឿន) ១៤៧
- * កំណាព្យប្រស្នា (វណ្ណ ស៊ុនហេង) ១៤៩
- គម្ពីរព្រះត្រៃបិដកប្រែរបស់ខ្មែរ ត្រូវបានបោះពុម្ពជាថ្មី (ឱម ខែម) ១៥០

# អត្ថបទពិចារណា

# ពុទ្ធសាសនា និង សង្គម

ពុទ្ធសាសនា ពុំគ្រាន់តែជាទស្សនវិជ្ជា សំរាប់ពួកបញ្ញវន្តយកទៅពិភាក្សាវែកញែកនៅក្នុងមជ្ឈដ្ឋានអ្នកចេះដឹងប៉ុណ្ណោះទេ, ប៉ុន្តែ ជាមាគ៌ាជាក់ស្តែងមួយសម្រាប់ការរស់នៅ ដែលដើរតួសំខាន់ក្នុងជីវភាពប្រចាំថ្ងៃ ។

ក្នុងសង្គមមុនការកើតមានពុទ្ធសាសនា, ការបែងចែកសង្គមជាស្រទាប់ក្នុងទ្រង់ទ្រាយជាថ្នាក់ និងជាប្រព័ន្ធវណ្ណៈ បានលេចឡើងជាទិដ្ឋភាពមួយគ្របដណ្តប់នៅក្នុងលំដាប់ថ្នាក់សង្គម ។ មានថ្នាក់ (Classes) សំខាន់បួន ដែលក្រោយមកក្លាយជាវណ្ណៈ *យោលទៅតាមការចាំបាច់នៃសង្គម* ។ ពួកព្រាហ្មណ៍ ទទួលបន្ទុកខាងទិដ្ឋភាពនៃការសិក្សា និងបញ្ញាស្មារតីរបស់សង្គម ។ ពួកអ្នកបិតក្នុងថ្នាក់អ្នកច្បាំង គឺជាអ្នកគ្រប់គ្រងប្រទេស និងជាអ្នកប្រយុទ្ធ ។ ពួកអ្នកដែលមានទីលំនៅជាប់លាប់ហើយចិញ្ចឹមជីវិតដោយការធ្វើស្រែ ចំការ និងរបរជំនួញ ហើយដែលតាមពិតទៅ គឺជាអ្នកផលិតភោគទ្រព្យរបស់ប្រទេស ត្រូវបានគេស្គាល់ថា វៃស្យៈ ពោលគឺជាពួកកសិករ និងឈ្មួញ ។ ថ្នាក់ក្រោយគេ, គឺពួក ស្ទូទ្រៈ ដែលជាពលករ ឬវណ្ណៈពលករ ។ តាមគម្ពីរព្រាហ្មណ៍ និយាយថា ព្រាហ្មណ៍ ឬព្រះព្រហ្ម ពោលគឺព្រះអាទិទេព បានបង្កើតថ្នាក់ ឬវណ្ណៈបួន តាមគំរូសង្គមទេវៈ ។ ដំបូងឡើយ មានតែពួកព្រាហ្មណ៍ទេត្រូវបានបង្កើតឡើងតាមគំរូនៃព្រាហ្មណ៍ ប៉ុន្តែ ព្រាហ្មណ៍ បានយល់ឃើញថា ពួកព្រាហ្មណ៍តែឯងមិនអាចបំពេញករណីយកិច្ចចាំបាច់នៅលើផែនដីបានទេ ។ ដូច្នេះលោកក៏បានបង្កើតពួកអ្នកច្បាំងថែមទៀតតាមគំរូទេវៈ ឥន្ទ្រៈ និងវរុណៈ, បង្កើតពួកកសិករ និងឈ្មួញ តាមគំរូទេវៈ វសុ និងមារុតៈ ហើយបង្កើតវណ្ណៈពលករ តាមគំរូ

របស់បុស័ន ។ ការលេចឡើងនៃការបែងចែកបែបនេះនៅក្នុងសង្គមមនុស្ស ត្រូវបានកើតមាន ដើម្បីអោយប្រហាក់ប្រហែលទៅនឹងសង្គមទេវៈ ។ ប៉ុន្តែថា ព្រាហ្មណ៍នៅតែមិនទាន់គាប់ព្រះទ័យជាមួយនឹងការបង្កើតរបស់លោកនេះទេ ពីព្រោះលោកបានយល់ឃើញថា អំណាចដើម្បីតែងតាំងព្រះរាជា ឬអ្នកគ្រប់គ្រងដ៏ខ្លាំងពូកែ នៅមិនទាន់មាន ។ ដូច្នេះ លោកក៏បានបង្កើតធម៌ៈ ឬសច្ចៈនេះឡើង ដែលផ្តល់អោយដល់មនុស្សណាមួយ ដែលទន់ខ្សោយខាងកំឡាំងកាយ (ឬក៏ផ្តល់អោយដល់សង្គម) នូវអំណាច ដើម្បីគ្រប់គ្រងលើអ្នកឯទៀត ដែលអាចមានកំឡាំងកាយខ្លាំងជាង, ដរាបណានៅមានសច្ចៈប្រព្រឹត្តទៅក្នុងពិភពលោកនោះ ។ បន្ទាប់មក, កំឡាំងកាយ (កាយពល) របស់អ្នកគ្រប់គ្រង ទើបត្រូវបានគេធ្វើអោយទៅជាអរូបីយ (immaterial) ។ នៅក្នុងសង្គមឥណ្ឌា ការបែងចែកបែបនេះ បានក្លាយទៅជាតំណមរតក, វណ្ណៈនីមួយៗ មានករណីយកិច្ចរបស់ខ្លួនជាប់មកពីកំណើត ។ នៅសម័យកាលនៃព្រះពុទ្ធអង្គ, ពួកព្រាហ្មណ៍ បានទទួលលក្ខន្តិកៈសង្គម ជាវណ្ណៈមានឯកសិទ្ធិ ចំណែកពួកអ្នកគ្រប់គ្រង និងពួកអ្នកច្បាំង ត្រូវបានយកចេញមកពីវណ្ណៈក្សត្រិយៈ ។

ព្រះពុទ្ធបានព្យាយាមកែប្រែតម្លៃសង្គម ដែលបានរៀបចំហើយនេះ, ពីព្រោះ ព្រះអង្គពុំយល់ស្របតាមមុខការនៃធម៌ៈ ឬសច្ចៈ ដែលផ្តល់ទៅអោយបុគ្គលខាងក្រៅខ្លួនណាមួយនោះទេ ។ គឺព្រះពុទ្ធអង្គឯង ដែលជាលើកដំបូងនៅក្នុងប្រវត្តិសាស្ត្រ ទ្រង់បានប្រកាសដ៏មហោឡារិកថា តាមការពិចារណារឿងហេតុទាំងឡាយប្រកបដោយវិចារណញ្ញាណ, អាទិភាព គប្បីផ្តល់ទៅអោយបញ្ញា (គតិបណ្ឌិត) ជាជាងផ្តល់ទៅអោយជំនឿ ឬលទ្ធិសាសនា ក្នុងការដោះស្រាយបញ្ហាណាមួយដែលជាបញ្ហាប្រចាំថ្ងៃ ។ វឌ្ឍនភាព ឬការធ្លាក់ខ្លួន ឬក៏ការចុះរាសីរបស់មនុស្សនៅក្នុងជីវិតនេះមិនផ្អែកទៅលើអ្វី ដូចដែលជំនឿរបស់ទស្សនវិទូខ្លះ នាសម័យកាលនោះបានយល់ដូចតទៅនេះ នោះទេ :

(១) រិទ្ធិ ដែលបានកើតឡើង គឺស្របទៅតាមអំពើដែលគេបានប្រព្រឹត្ត ធ្វើនៅក្នុងជាតិមុន ដែលគេអោយឈ្មោះថា «បុព្វេកតហេតុវាទ»

(២) ជីវិតរបស់មនុស្សនៅលើផែនដីនេះ ប្រព្រឹត្តទៅស្របទៅតាមឆន្ទៈរបស់ព្រះអាទិទេព ឬរបស់ឧត្តមានុភាពប្រភេទណាមួយ ដែលគេហៅថា «ឥស្សរនិម្មានវាទ»

(៣) គ្មានហេតុផល ឬការពន្យល់ដោយឡែកណាមួយអាចត្រូវបានផ្តល់អោយសម្រាប់យកមកពន្យល់ ឬដើម្បីយល់អំពីសុភមង្គល ឬទុក្ខសោក ដែលមនុស្សបានទទួលនោះទេ ដែលមានឈ្មោះថា «អហេតុ-អប្បច្ចយវាទ» ។

ព្រះពុទ្ធអង្គ បានបដិសេធទស្សនៈទាំងឡាយនោះ ហើយចង្អុលប្រាប់យ៉ាងច្បាស់លាស់ថា គ្មានមនុស្សណាម្នាក់បានភាពឧត្តុង្គឧត្តម ដោយសារកំណើតរបស់ខ្លួននោះទេ ។ មនុស្សម្នាក់ នៅក្នុងវណ្ណៈដែលគេហៅថាវណ្ណៈថោកទាប ក៏តង់កើតចេញមកតាមគន្លងតែមួយដូចគ្នា មិនខុសពីកំណើតរបស់មនុស្សណាមួយ នៅក្នុងវណ្ណៈខ្ពង់ខ្ពស់នោះទេ ពោលគឺ ចេញមកពីផ្ទៃម្តាយដូចគ្នា ។ ព្រះពុទ្ធបានចង្អុលប្រាប់នៅក្នុងអគ្គញ្ញ សូត្រថា ការស្ថាបនាអោយមានជាឋានៈ និងកម្រិតផ្សេងៗគ្នារបស់មនុស្សកំពុងរស់នៅក្នុងសង្គម គឺបណ្តាលមកតែពីការចាំបាច់របស់សង្គមនោះ តែប៉ុណ្ណោះ ។ វាមានករណីយកិច្ចខ្លះ ដែលគេទាមទារអោយក្រុម ឬវណ្ណៈនីមួយៗត្រូវបំពេញ, ប៉ុន្តែ គ្មានក្រុមណាមួយមានឯកសិទ្ធិជាងក្រុមដទៃ ដោយសារកំណើត នោះទេ ។ ព្រះពុទ្ធទ្រង់មានពុទ្ធដីកាថា សង្គម ឬសហគមន៍នោះ ផ្អែកទៅលើធម៌ៈ ឬសច្ចៈ ។ នៅក្នុងចក្កវត្តិសីហនាទសូត្រ ព្រះអង្គទ្រង់ចង្អុលប្រាប់ថា លក្ខណសម្បត្តិដ៏ប្រសើររបស់សង្គមមួយ នឹងរីកចំរើនទៅបាន ប្រសិនបើ*សង្គមនោះក្លាយជាសង្គមរឹងមាំខាងសេដ្ឋកិច្ច* ។ នៅក្នុងប្រទេសរួបរិតដោយទុគ្គតភាព, ប្រជាជនពិបាក

និងមានពេលវេលាដើម្បីយកចិត្តទុកដាក់ធ្វើអោយរីកចំរើន នូវលក្ខណសម្បត្តិដ៏ល្អៗ ដោយហេតុនេះ ពលានុភាពសេដ្ឋកិច្ចរបស់ប្រទេសមួយ មានសារសំខាន់ខ្លាំងណាស់ ដើម្បីអោយប្រជាជនអាចទទួលសោយផលអំពើល្អ ដែលមិតនៅក្នុងក្រអៅបេះដូងរបស់គេ ។

សូម្បីតែព្រះរាជា ឬអ្នកគ្រប់គ្រងប្រទេស ដែលមានសមត្ថភាពការពារប្រជាពលរដ្ឋរបស់ខ្លួនបាន, ប៉ុន្តែ មិនបានបើកច្រកណាមួយសម្រាប់បង្កើតភោគ-ទ្រព្យ, បើកផ្លូវ និងផ្តល់មធ្យោបាយទាំងឡាយបែបណាមួយ សម្រាប់អោយប្រជា-ជនចិញ្ចឹមជីវិតដោយសុចរិតផងទេ, វាច្បាស់ជាចៀសមិនផុតពីភាពក្រីក្រ ដែលជាផលវិបាក បង្កើតអោយមានច្រើនឡើងនូវអំពើលួច . ប្លន់ និងភាពទុច្ចរិតផ្សេងៗ ។ ព្រះពុទ្ធទ្រង់និទានរៀបរាប់នៅក្នុងព្រះសូត្រខាងលើ អំពីព្រះរាជាបែបនោះថា ព្រះរាជាទ្រង់មានព្រះតំរិះថា បើព្រះអង្គប្រទានប្រាក់អោយដល់អ្នកក្រីក្រ, ដែលត្រូវមានទោសព្រោះការលួច និងអំពើទុច្ចរិតផ្សេងៗ, អ្នកក្រីក្រទាំងនោះ អាចចាប់ផ្តើមកសាងជីវភាពជាថ្មី ហើយមានមធ្យោបាយសម្រាប់រស់នៅបាន ។ ប៉ុន្តែ កាយវិការរបស់ព្រះរាជាបែបនេះ មិនអាចជួយដោះស្រាយបញ្ហាទាំងស្រុងបានទេ ពីព្រោះអំពើលួច . ប្លន់ មិនបានបញ្ចប់ ហើយបន្ទាប់មក ព្រះរាជាអង្គនោះបញ្ជាអោយដាក់ទោសប្រហារជីវិតទៅលើជនទាំងឡាយណា ដែលត្រូវបានជាប់ពិរុទ្ធចំពោះបទល្មើសទាំងនោះ ។ វិធានការនេះ ក៏ពុំមែនជាដំណោះស្រាយបញ្ហាដែរ ពីព្រោះអំពើលួច-ប្លន់ ឧក្រិដ្ឋកម្ម និងឃាតកម្ម ក៏កាន់តែកើតមានពាសពេញលើផ្ទៃប្រទេសទាំងមូល ។ ហេតុការណ៍ ដែលព្រះរាជាចេញបញ្ជាអោយដាក់ទោសប្រហារជីវិត ទៅលើប្រជា-រាស្ត្ររបស់ព្រះអង្គ មានន័យថា ព្រះអង្គគ្មានការគោរពជីវិតមនុស្សទៀតឡើយ ។ កាលបើប្រជារាស្ត្របានដឹងរឿងនេះហើយ គេត្រូវតែចេះនិយាយកុហក ដើម្បីការពារជីវិតរបស់ខ្លួន កាលណាគេត្រូវបានចាប់ខ្លួននាំទៅតុលាការកាត់ទោស ។ នេះជា

ហេតុនាំអោយមានការនិយាយកុហក, ការនិយាយបង្កាច់ និងការនិយាយបរិហារកេរ្តិ៍នៅក្នុងសង្គម ។ ដោយសារមានការប្រព្រឹត្តវៀចវេរយ៉ាងនេះ, ទឹកចិត្ត ក៏ដូចជារូបកាយរបស់ប្រជាជន ប្រែក្លាយទៅជាមន្ទិលសៅហ្មង ។ ប្រជាជននោះក្លាយទៅជាមនុស្សមិនត្រូវបានគេរាប់រក ទាំងខាងផ្នែកទំនាក់ទំនងផ្លូវកាយ ក៏ដូចជាខាងទំនាក់ទំនងផ្នែកផ្លូវចិត្ត ។ ស្ត្រីទាំងឡាយ ចាប់ផ្តើមស្អប់ខ្ពើមមនុស្សប្រុសអាក្រក់ ហើយបន្ទាប់មក ក៏កើតមានអំពើស្អប់ខ្ពើម និងប្រណែនឈ្នានីសចំពោះស្វាមីរបស់ស្ត្រីដែលមានរូបស្អាត ។ អំពើនេះ បង្កអោយមានអតិចរិយា ( គឺអំពើផិតក្បត់ប្តី ឬប្រពន្ធ ) និងអំពើរំលោភសេពកាម ដែលក្លាយទៅជាបុព្វហេតុនៃពាក្យទ្រគោះបោះបោក និងការនិយាយដើមគ្នា ។ អ្នកទាំងឡាយណា ដែលបានធ្លាក់ខ្លួនក្នុងស្ថានភាពបែបនេះ មិនអាចមានគំនិតជាមនុស្សឧត្តុង្គឧត្តម និងពុំមានលក្ខណសម្បត្តិល្អប្រពៃក្នុងជីវិតបានទេ ។

នៅក្នុងសង្គមបែបនេះ, ព្រះពុទ្ធទ្រង់ទេសនាថា ចំណង់ដើម្បីបាននូវអ្វីៗដែលមិនប្រពៃ, តណ្ហាខ្លាំងក្លាដើម្បីបានសេចក្តីសប្បាយផ្ទាល់ខ្លួន, ហើយនិងមិច្ឆាទិដ្ឋិ ចាប់ផ្តើមកើតឡើង ។ ពុំមានតម្លៃណាមួយសេសសល់នៅក្នុងសង្គមទេ, គ្មានការគោរពចំពោះរៀមច្បង ហើយគ្មានការគោរពមនុស្សដទៃសោះឡើយ ។ ដោយប្រជារាស្ត្រមានចិត្តពោរពេញដោយគំនិតអាក្រក់ដូច្នេះ, គេក៏ចាប់ផ្តើមវាយប្រហារគ្នា, ហើយច្បាំងគ្នាក្នុងចំណោមជនជាតិខ្លួនឯង ។ សភាពការណ៍នេះ នឹងនាំទៅកាន់សេចក្តីអន្តរាយនៃវប្បធម៌ ហើយតាមពិតទៅ វប្បធម៌ផ្នែកខ្លះ ត្រូវបានបំផ្លាញទាំងស្រុងទៅហើយ ។ ក្នុងចំណោមប្រជារាស្ត្រទាំងនោះ, មានមនុស្សខ្លះមិនយល់ព្រមបណ្តោយអោយវប្បធម៌របស់ខ្លួន ត្រូវគេបំផ្លាញឡើយ, ដូច្នេះហើយគេក៏ចាប់ផ្តើមកសាងជីវភាពរបស់គេតាមសម្មាអាជីវៈ ហើយកសាងសង្គមមួយដែលឋិតនៅលើគ្រឹះធម៌ៈ ពោលគឺ ជាទ្រង់ទ្រាយមួយនៃសង្គម ដែលបំពេញ

សំណូមពររបស់ប្រជាជន ។

រឿងនេះ ផ្តល់ឧទាហរណ៍ថា ប្រភពដើម, ការរីករាលដាល និងការស្រុតចុះនៃអរិយធម៌ណាមួយ ពឹងផ្អែក ឬអាស្រ័យលើគោលការណ៍នៃហេតុ និងផល ។ សង្គម គឺជាស្ថាប័នមួយប្រែប្រួល ផ្លាស់ប្តូរជាប្រក្រតី ហើយការប្រែប្រួលផ្លាស់ប្តូរនេះ គឺជាដំណើរប្រព្រឹត្តទៅជានិរន្តរ៍ ។ សង្គម ឬពិភពលោកជាទូទៅ ប្រឈមមុខនឹងទិដ្ឋភាពនៃជីវិតប្រាំបីយ៉ាង (អដ្ឋលោកធម៌) គឺឈ្នះ និងចាញ់, អាប់ឱន និងល្បីល្បាញ, ស្តីបន្ទោស និងសរសើរ, សុភមង្គល និងទុក្ខ ។ ការដើរតាមផ្លូវត្រូវ មានសារសំខាន់ដល់ដំណើររីកចំរើននៃសង្គម ។ អំពើទាំងឡាយរបស់មនុស្ស ដែលឋិតនៅលើផ្លូវត្រូវ ត្រូវបានគេអោយឈ្មោះថាជាចរិយារបស់កតញ្ញូជន ។ អំពើទាំងនោះត្រូវបានគេហៅថា កុសលចរិយា ឬបុញ្ញកិរិយា (អំពើជាកុសល) ។ ជីវិតនៅក្នុងលោកនេះ ក្លាយទៅជាជីវិតសប្បាយរីករាយបាន ប្រសិនបើគេរស់នៅស្របតាមផ្លូវត្រូវ ហើយគេនឹងទទួលបាននូវជីវិតដ៏ល្អប្រសើរក្នុងពិភពលោកដ៏មនោរម្យ ក្នុងជាតិបន្ទាប់ ។ ប្រសិនបើនៅក្នុងជីវិតរបស់យើងនេះ យើងខិតខំអោយអស់លទ្ធភាពដើម្បីយល់ខ្លួនយើង ហើយនិងទីជុំវិញយើង (បរិដ្ឋាន) វានឹងជួយអោយយើងរស់នៅក្នុងជីវិតមួយគ្មានឧបសគ្គ ហើយយើងអាចប្រតិបត្តិតាមព្រះធម៌ដ៏ឧត្តុង្គឧត្តមនៃមេត្តា, ករុណា, មុទិតា, ឧបេក្ខា ។

បើតាមព្រះពុទ្ធអង្គថា, ភាគច្រើននៃបញ្ហាដែលបានកើតមានឡើងនៅក្នុងសង្គម គឺច្រើនតែជាបញ្ហាផ្លូវចិត្ត, ប៉ុន្តែ បរិដ្ឋានក៏បានដើរតួរដ៏សំខាន់ផងដែរ ។ ព្រះពុទ្ធពុំបានកំណត់ព្រំដែនដល់ជីវភាពរបស់មនុស្ស អោយនៅតែក្នុងក្របខណ្ឌសម្ភារៈ និងសេដ្ឋកិច្ច ប៉ុណ្ណោះទេ ។ សូម្បីតែនៅក្នុងការពិភាក្សារបស់ព្រះអង្គ ស្តីពីជំងឺ ក៏ព្រះអង្គបានចែកជំងឺទាំងនោះ ជាជំងឺផ្លូវកាយ និងជំងឺផ្លូវចិត្តដែរ ។ ព្រះអង្គមានពុទ្ធដីកាថា សង្គមក៏ទទួលរងទុក្ខវេទនាអំពីវិបត្តិបីយ៉ាង មានជាអាទិ៍ លោភៈ

(ចំណង់ខ្លាំង) ទុរ្ភិក្ស និងជរាគ្រាំគ្រា ។ យើងត្រូវទទួលរងនូវអារម្មណ៍ទាំងឡាយ ដែលជាលទ្ធផលចេញមកពីវិបត្តិទាំងនោះ ។ ដោយហេតុនេះ យើងត្រូវតែឃ្លាំមើល ដោយប្រុងប្រយ័ត្ននូវចិត្ត និងអំពើទាំងឡាយរបស់យើង ។ ចិត្តដែលនឹងធឹង ហើយ ស្ងប់ស្ងាត់ មានសារសំខាន់ណាស់ក្នុងគ្រប់សកម្មភាពប្រចាំថ្ងៃរបស់យើង ។ យើង ត្រូវការអោយមានស្វ័យគ្រប់គ្រងចិត្ត ភាពស្ងប់ចិត្ត និងខន្តី ហើយហ្វឹកហ្វឺនខ្លួនយើង មិនអោយលុះទៅក្នុងចំណង់, មហិច្ឆតារបស់យើងគ្រប់យ៉ាង . ល ., ប្រសិនបើ យើងប្រាថ្នារស់នៅប្រកបដោយសេចក្ដីថ្លៃថ្នូរនៅក្នុងសង្គម ។ ព្រះពុទ្ធទ្រង់ទូន្មាន យើងអំពីសារប្រយោជន៍របស់គុណសម្បត្តិទាំងនោះ ។ ប្រសិនបើប្រជាជននៅក្នុង សង្គមបានអភិវឌ្ឍគុណសម្បត្តិដ៏ល្អទាំងនោះ, ពេលនោះ វិបត្តិភ័យផងទាំងឡាយ ដែលមនុស្សត្រូវប្រឈមមុខ នឹងថយចុះនៅសល់ដ៏តិចតួច ។ តាមពិត សង្គមដែល ព្រះពុទ្ធទ្រង់យោងដល់ គឺពុំមែនតែសង្គមមនុស្សប៉ុណ្ណោះទេ, ប៉ុន្តែ រួមបញ្ចូលសង្គម សត្វទាំងអស់ផងដែរ ។ ព្រះអង្គទ្រង់មានជំនឿថា សត្វរាល់រូបត្រូវប្រព្រឹត្តក្នុងគន្លង បែបណា ដែលវាមិនបណ្ដាលអោយកើតមានអំពើអាក្រក់ដល់ខ្លួនផ្ទាល់ ឬដល់អ្នក ដទៃផងឡើយ ។

ចក្កវត្តិសីហានាទសូត្រ និយាយបន្តទៀតថា វាជាករណីយកិច្ចរបស់អ្នក គ្រប់គ្រងដែលត្រូវការពារ មិនមែនតែមនុស្ស និងសត្វប៉ុណ្ណោះទេ ។ ប៉ុន្តែ អ្នកគ្រប់ គ្រងគប្បីរក្សាអាកាស និងបរិដ្ឋានអោយផុតពីភាពកខ្វក់ផងដែរ ។ ពាក្យប្រៀន ប្រដៅរបស់ព្រះពុទ្ធ មិនត្រូវបានកំណត់អោយប្រើប្រាស់បានចំពោះពេលវេលា ឬ ទីឋានដោយឡែកណាមួយប៉ុណ្ណោះទេ ប៉ុន្តែ ពាក្យប្រៀនប្រដៅនោះ អនុវត្តបាន ចំពោះមនុស្សគ្រប់រូប គ្រប់ទីកន្លែង និងគ្រប់ពេលវេលា ហើយអាចត្រូវបានសង្គម ណាមួយប្រតិបត្តិតាម សម្រាប់សុខុមាលភាពផ្ទាល់របស់សង្គមនោះ ។ ការប្រតិបត្តិ បីយ៉ាងគឺ ទាន សីល និងភាវនា ក៏មានសារសំខាន់ណាស់ សម្រាប់មនុស្សគ្រប់រូប

ដើម្បីធ្វើអោយជីវិតរស់នៅរបស់ខ្លួនមានតម្លៃ ។ ប្រសិនបើគេប្រព្រឹត្តសប្បុរសធម៌ គេបង្កើតបាននូវសេចក្តីស្រឡាញ់រាប់អាន និងសមភាព ហើយគេក្លាយជាមនុស្ស មានចិត្តទូលាយ អាចចែករំលែកអ្វីដែលគេមាន ជាមួយអ្នកឯទៀតបាន ។ នេះជាហេតុការណ៍ដ៏មានសារសំខាន់ណាស់ក្នុងការព្យាយាមរក្សាតុល្យភាព ក្នុងពិភពលោក ។ សព្វថ្ងៃនេះ ពិភពលោកមិនមានតុល្យភាពសោះឡើយ ។ នៅលើចុងម្ខាងនៃជញ្ជីងមានទម្ងន់លើស ដោយមានការរីកចំរើនខ្លាំង ចំណែកឯចុងម្ខាងវិញគ្មានការរីកចំរើនស្ទើរតែទាំងស្រុង ។ នេះគឺចង់និយាយថា ភាគមួយនៃពិភពលោកទទួលបាននូវឯកសិទ្ធិគ្រប់យ៉ាង ដែលជីវិតអាចផ្តល់អោយ ចំណែកឯមួយភាគទៀតលិចលង់នៅក្នុងភាពក្រខ្សត់ ។ វិសមភាពដ៏ច្បាស់លាស់នោះ គឺជាភស្តុតាងមិនអាចបដិសេធ បាន នៅពេលប្រាក់រាប់លានដុល្លារ ត្រូវបានគេចំណាយសម្រាប់ការសប្បាយ និងប្រណីតភាពផ្សេងៗ ដោយមនុស្សខ្លះ ឬមនុស្សមួយក្រុម, ចំណែកប្រជាជនពិភពលោកពាក់កណ្តាលរងគ្រោះទុរ្ភិក្ស ដាច់ពោះស្លាប់ ។ ប្រសិនបើគេអនុវត្តតាមពុទ្ធឱវាទ ហើយសម្រួលការរស់នៅរបស់គេ អោយស្របទៅនឹងពាក្យប្រៀនប្រដៅនេះ, វិសមភាពបែបនោះ នឹងត្រូវបានលុបបំបាត់ ។ ព្រោះហេតុនោះហើយ ការប្រព្រឹត្តសប្បុរសធម៌ក្នុងបែបបទសមស្រប មានសារសំខាន់ក្នុងការធ្វើអោយពិភពលោក បានជាលំនៅឋានដ៏ប្រសើរសម្រាប់ជីវិតរស់នៅ ។ សីលធម៌គឺមិនមែនជាក្រម ឬជាបទបញ្ញត្តិសម្រាប់ដាក់ទណ្ឌកម្មទេ, ប៉ុន្តែ គឺជាកម្រងនៃគោលការណ៍ណែនាំ អោយកើតមានវឌ្ឍនភាពខាងសម្ភារៈ ក៏ដូចជាខាងស្មារតី ។ យើងត្រូវការអោយមានទម្រង់បែបណាមួយនៃគោលការណ៍ណែនាំ ដើម្បីគ្រប់គ្រងខ្លួនយើងអោយធ្វើដំណើរទៅមុខ ឆ្ពោះទៅកាន់វឌ្ឍនភាពនោះ និងដើម្បីការពារខ្លួនយើង កុំអោយឃ្លាតចេញពីគន្លងល្អ ឬនិយាយមួយបែបទៀត គឺដើម្បីការពារខ្លួនយើង អោយផុតពីការប្រព្រឹត្ត (ចរិយា) ដ៏ព្រៃផ្សៃ និងភ្លូកវង្វេង ។ សមាធិ ជួយយើង

អោយយល់ដឹងពីខ្លួនយើង ក៏ដូចជាយល់ដឹងពីអ្នកដទៃ ព្រមជាមួយនឹងការយល់ដឹងពីអ្វីៗនៅជុំវិញខ្លួនយើង (បរិដ្ឋាន) ផងដែរ ។ គោលការណ៍ទាំងឡាយនេះ នឹងជួយយើងអោយផ្តល់វិភាគទានមួយចំណែកធំ ដល់ការកសាងសង្គមមួយស្អាតស្អំ និងរីកចំរើន ទាំងខាងសម្ភារៈ ទាំងខាងផ្លូវចិត្ត ។ ប្រសិនបើយើងព្យាយាមដឹកនាំជីវភាពបែបនេះ យើងបានក្លាយជាអ្នកប្រតិបត្តិតាមមាគ៌ារបស់ព្រះពុទ្ធ ដែលនាំយើងអោយសម្រេចបាន *សុភមង្គលដ៏ឧត្តុង្គឧត្តម* ។

By Bellanwila Wimalaratana
in Buddhism, Society and Environment

បកប្រែ : **ឈន វៀម**

## អត្ថបទពិចារណា

# បែបបទដើម្បីមើលឃើញព្រះពុទ្ធ

នៅថ្ងៃពេញបូណ៌មី ខែពិសាខ យើងតែងធ្វើបុណ្យរំលឹកថ្ងៃប្រសូត ថ្ងៃត្រាស់ដឹង និងថ្ងៃបរិនិព្វានរបស់ព្រះពុទ្ធ ។ ថ្វីបើមានពុទ្ធបរិស័ទជាច្រើនរៀបចំពិធីបុណ្យពិសាខបូជា ដោយតុបតែងរូបបដិមា រូបគំនូរធំៗ ហើយតែងភ្លើងលំអរូបបដិមា រូបគំនូរទាំងនោះដោយពន្លឺភ្លើងចំរុះពណ៌, ប៉ុន្តែ មានមនុស្សតិចតួចណាស់មើលឃើញព្រះពុទ្ធពិតប្រាកដ ។ កាលណាយើងនិយាយអំពីពុទ្ធចរិត ខ្ញុំតែងនឹកឃើញពាក្យពេចន៍របស់លោកគុរុលុគោមី ( Gurulugomi ) ដែលជាអ្នកប្រាជ្ញ ដ៏ចំណានម្នាក់អំពីពុទ្ធវិទ្យា នៅក្នុងសៀវភៅរិជ្ជាសមោធានរបស់លោក ស្តីពីព្រះធម៌របស់ព្រះពុទ្ធ ដែលមានឈ្មោះថា ធម៌ប្រទីបកា ។ លោកនិយាយថា : " ព្រះពុទ្ធជាតួអង្គមិនអាចប្រឌិតបាន, មិនអាចប្រៀបធៀបបាន, មិនអាចគិតយល់បាន ទាំងខាងពហិលក្ខណៈ ( លក្ខណៈខាងក្រៅ ) ទាំងខាងព្រះបញ្ញាញាណ " ។ នេះចង្អុលបង្ហាញថា គេមិនអាចឈានដល់សេចក្តីសន្និដ្ឋានតាមការគិត, តាមការប្រៀបផ្ទឹម ឬតាមការយល់អំពីគុណសម្បត្តិជាមនុស្សរបស់ព្រះអង្គ ក៏ដូចជា សមិទ្ធផលខាងបញ្ញាស្មារតីរបស់ព្រះអង្គនោះទេ ។ ការបកស្រាយបែបនេះ បាននាំទៅរកការតាំងបង្ហាញចំរុះពណ៌ដោយពន្លើសបំផ្លើសចរិតលក្ខណៈអធិមនុស្សរបស់ព្រះអង្គ និងក្នុងដំណើរមើលរំលងគុណសម្បត្តិជាមនុស្សរបស់ព្រះអង្គ ។ ប៉ុន្តែថា, ការពន្យល់របស់លោកគុរុលុគោមី មានលក្ខណៈសមស្របណាស់ ទៅនឹងការបកស្រាយផ្ទាល់របស់ព្រះពុទ្ធដែលថាព្រះអង្គជា *អច្ឆរិយមនុស្ស* ។ " ម្នាលភិក្ខុទាំងឡាយ, បុគ្គលមួយរូបកើតមកក្នុងលោកនេះ គឺជាមនុស្សអស្ចារ្យម្នាក់, តើមនុស្សណា ? គឺ តថាគត ដែលជា

ព្រះអរហន្ត, ជាព្រះសព្វញ្ញុពុទ្ធ" ។ យោងតាមអត្ថបទទាំងឡាយ, ព្រះពុទ្ធជាមនុស្សមួយរូប ដែលបានសំរេចសុក្រិតភាពក្នុងគ្រប់វិស័យ ។

ព្រះអង្គបានបដិសន្ធិឡើងនៅកណ្តាលសង្គមមួយ ដែលពោរពេញដោយសង្ឃ័ដ ( ការប៉ះទង្គិច ), ដូចជាភាពក្រីក្រ, ព្យសនកម្ម ( ការខូចប្រយោជន៍ ) ខាងជាតិសាសន៍, ការរើសអើងខាងវណ្ណៈ, - ល - ។ បើទោះបីជាមានល័ក្ខខ័ណ្ឌមិនជាទីពេញចិត្តទាំងអស់នេះក្តី, ព្រះអង្គម្ចាស់សិទ្ធថ៌ ត្រូវបានចិញ្ចឹមបីបាច់ដោយមានផាសុកភាពគ្រប់យ៉ាងដ៏ប្រណីត ដែលមនុស្សធម្មតាមិនធ្លាប់ដែលបានទទួល ។ ព្រះពុទ្ធទ្រង់បានពិពណ៌នាអំពីផាសុកភាពនោះ ដូចតទៅនេះថា " ម្នាលភិក្ខុទាំងឡាយ, តថាគតត្រូវបានគេចិញ្ចឹមបីបាច់យ៉ាងម៉ត់ចត់, ចិញ្ចឹមបីបាច់យ៉ាងម៉ត់ចត់លើសលប់, ចិញ្ចឹមបីបាច់យ៉ាងម៉ត់ចត់ហួសហេតុ ។ ជាឧទាហរណ៍, នៅក្នុងវិមានរបស់បិតានៃតថាគត មានស្រះបោក្ខរណី ( ស្រះមានឈូក ) ទាំងឡាយ ត្រូវបានគេសាងឡើងដូច្នេះ ស្រះបោក្ខរណីមួយមានឈូកពណ៌ខៀវ, មួយទៀតមានឈូកពណ៌ក្រហម, មួយផ្សេងទៀតមានឈូកពណ៌ស, គ្រាន់តែសម្រាប់អត្ថប្រយោជន៍តថាគត ។ គ្មានកំទេចខ្លឹមចន្ទក្រឹស្នាណាដែលតថាគតបានប្រើ មិនមកពីកាសីទេ, ឆ្នូតព្រះកេសារបស់តថាគតធ្វើពីសម្ពត់កាសី, អាវខ្លីរបស់តថាគត ក៏ធ្វើពីសម្ពត់កាសី, អាវវែង និងអាវធំពាក់ក្រៅ ក៏ធ្វើពីសម្ពត់កាសី ។ ពេលយប់ក៏ដូចពេលថ្ងៃ បាំងពណ៌សចងត្រដាងពីលើតថាគត ខ្លាចត្រជាក់ ឬកំដៅ, ធូលី ឬកំទេច ឬសន្សើមអាចប៉ះពាល់តថាគត ។ ជាងនេះទៀត, ម្នាលភិក្ខុទាំងឡាយ, តថាគតមានប្រាសាទបី, ប្រាសាទមួយសម្រាប់រដូវរងារ, មួយសម្រាប់រដូវក្តៅ, មួយទៀតសម្រាប់រដូវភ្លៀង ។ ក្នុងពេលបួនខែ នៃរដូវភ្លៀង តថាគតត្រូវបានពួកអ្នករបាំបំរើ, ទាំងអស់សុទ្ធតែស្ត្រី ។ តថាគតមិនដែលចុះពីប្រាសាទទេ ក្នុងខែនោះៗ " ។

ជាទូទៅ, មនុស្សណាមួយ ដែលធ្លាប់សោយសុខជីវិតដ៏ប្រណីតហើយ

រមែងតែខិតខំទទួលយកជាអតិបរមានូវសេចក្ដីសប្បាយអំពីជីវិតនោះ ។ ព្រះអង្គម្ចាស់សិទ្ធត្ថវិញ តែងចាប់ផ្ដើមពិចារណាលើប្រណីតភាពទាំងអម្បាលម៉ាននោះ ក្នុងបែបបទមួយផ្សេង ។ តើនេះជាតថភាពនៃជីវិតឬទេ ? តើយើងអាចធ្វើអោយជីវិតរបស់យើងមានសុភមង្គលក្នុងគ្រប់ទិដ្ឋភាព តាមរយៈផាសុកភាពទាំងនោះឬទេ? តើនេះជាន័យនៃជីវិតឬទេ ? គ្មាននរណាម្នាក់អាចប្រមាទ ( ធ្វេសប្រហែស ) ហេតុការណ៍ទាំងឡាយធម្មតានៃជីវិត ដូចជា រោគា ជរា និងមរណភាពបានទេ ។ បែបបទត្រិះរិះនេះ បាននាំព្រះអង្គទៅដល់ការបោះបង់ចោលផាសុកភាពដ៏ប្រណីតទាំងឡាយនោះ ។ នេះគឺជាជំហានដ៏អង់អាចមួយ សម្រាប់មនុស្សម្នាក់ដើម្បីប្រកាន់យក ។

ព្រះពុទ្ធតែងបានពន្យល់ដល់អ្នកឯទៀត អំពីគ្រោះថ្នាក់មិនអាចគេចផុតទាំងនោះ នៅក្នុងឱកាសដ៏ច្រើន ។ យោងតាមអត្ថបទទាំងឡាយ, គ្រោះថ្នាក់ទាំងនោះ គឺភេរវកម្មបីយ៉ាងដែលបំបែកម្ដាយពីកូន ( អមតបុត្តិកភ័យ ) ។ គេទទួលស្គាល់ជាទូទៅថា កាលណាមានភ្លើងដ៏ធំឆាបឆេះឡើង, កាលណាមានភ្លៀងដ៏ខ្លាំងបង្អុរចុះ, កាលណាមានការប្រកាសអាសន្នអំពីហ្វូងចោរព្រៃ, ម្ដាយមិនអាចចាប់យកកូនខ្លួន ហើយកូនក៏មិនអាចតោងម្ដាយខ្លួនបាន ។ ទោះបីជាឧប្បត្តិហេតុទាំងឡាយនេះ អាចត្រូវបានគេហៅថា " ភេរវកម្ម " ដែលបំបែកម្ដាយពីកូនក៏ដោយ, ក៏វាអាចមានពេលខ្លះនាំអោយម្ដាយ និងកូនយោងចាប់គ្នាទៅវិញទៅមកបាន សូម្បីតែឋិតក្រោមកាលៈទេសៈដ៏តឹងតែងយ៉ាងណាក្ដី ។ ប៉ុន្តែ យោងតាមព្រះពុទ្ធវិញ ភេរវកម្មដ៏ពិតដែលបំបែកម្ដាយ និងកូន គឺរោគា ជរា និងមរណភាព ។ កាលណាជួបប្រទះភេរវកម្មទាំងនោះ ម្ដាយមិនអាចជួយកូនរបស់ខ្លួន ហើយកូនក៏មិនអាចជួយម្ដាយខ្លួនបានដែរ ។

ព្រះពុទ្ធ គឺជាមនុស្សទីមួយ ដែលបានបំពេញវីរិយភាពដ៏ត្រឹមត្រូវ ដើម្បី

វិដោះផុតពិភេទវកម្មដ៏ជាក់ស្តែងទាំងនោះនៃជីវិត ។ យើងត្រូវមើលឃើញមហន្ត-ភាព ( greatness ) របស់ព្រះពុទ្ធ លើមូលដ្ឋាននៃហេតុការណ៍ខាងលើ ដែលបង្ហាញភស្តុតាងថា ព្រះអង្គជាតួអង្គអច្ឆរិយៈ យ៉ាងពិតប្រាកដ ។ រស់នៅក្នុងជីវិតដ៏ប្រណិត, ហ៊ុំជុំជិតដោយផាសុកភាពចាំបាច់សព្វយ៉ាង, តែព្រះអង្គនៅតែមិនគាប់ព្រះ-ទ័យ ហើយព្រះអង្គបានយាងចាកចោលអ្វីៗទាំងអស់ ដើម្បីប្រយោជន៍មនុស្សច្រើនគ្នា និងដើម្បីសុភមង្គលមនុស្សច្រើនគ្នា ។ លទ្ធផលនៃសេចក្តីព្យាយាមឥតនឿយហត់នេះ គឺការសំរេចបាននូវការយល់ដឹងសច្ចធម៌នៃអ្វីៗ ដូចដែលមានជាក់ស្តែង ។ គ្មានមនុស្សណាផ្សេងពីមុនដែលអាចប្រកាសថា គេបានយល់ដឹងអ្វីៗទាំងអស់ក្នុងឋានៈជាមនុស្សម្នាក់, ដូចជាព្រះពុទ្ធបានប្រកាសនោះទេ ។

ដោយហេតុនេះ ព្រះអង្គត្រូវបានគេថ្វាយនាមថា *អច្ឆរិយមនុស្ស* ។ ក្នុងទំនាក់ទំនងទៅនឹងអ្វីៗទាំងអស់, ព្រះពុទ្ធទ្រង់ត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ, តថាគតនឹងប្រៀនប្រដៅ នូវសព្វធម៌ ( the all ) ដល់អ្នក ។ ចូរស្តាប់សព្វធម៌នោះចុះ ។ ចុះអ្វីទៅ, ម្នាលភិក្ខុទាំងឡាយ, ជាសព្វធម៌ ? នោះគឺ ភ្នែកនិងវត្ថុ, ត្រចៀកនិងសំឡេង, ច្រមុះនិងក្លិន, អណ្តាតនិងរសជាតិ, កាយនិងវត្ថុប៉ះពាល់បាន, ចិត្តនិងចេតសិក ។ ម្នាលភិក្ខុទាំងឡាយ, នោះហើយហៅថា " សព្វធម៌ (the all) " ។ ម្នាលភិក្ខុទាំងឡាយ, តើអ្នកណាអាចនិយាយថា : " ផាត់ចោលសព្វធម៌នេះ អាត្មាអញនឹងប្រកាសសព្វធម៌មួយទៀត, វាគ្រាន់តែជាការនិយាយទទេរបស់មនុស្សនោះ, ហើយនៅពេលចោទសួរ មនុស្សនោះមិនអាចដោះសាពាក្យអួតអាងរបស់គេបាន, ហើយជាងនេះទៀត, មិនអាចរកច្រកចេញរួច ។ ព្រោះហេតុអ្វីបានជាដូច្នោះ ? ពីព្រោះ, ម្នាលភិក្ខុទាំងឡាយ, វាហួសពីសមត្ថភាពរបស់គេ ដើម្បីធ្វើបាន " ។

ប្រសិនបើគេពិនិត្យយ៉ាងយកចិត្តទុកដាក់ នូវពុទ្ធដីការបស់ព្រះពុទ្ធខាងលើ, គេយល់ថា គ្មានអ្វីមួយមិនបានបញ្ចូល ឬសេសសល់ខាងក្រៅ នៅក្នុងការ

ពន្យល់របស់ព្រះអង្គអំពីអ្វី១ទាំងអស់ក្នុងលោកឡើយ ។ ព្រះពុទ្ធបានឈ្វេងយល់អ្វី១ទាំងអស់ ជាមួយនឹងចរិតលក្ខណៈជាប់ជាមួយរបស់វា ហើយព្រះអង្គបានមានបន្ទូលថា អ្វី១ទាំងអស់ជាអនិច្ចៈ និងថា បើអ្វី១ទាំងអស់ជាអនិច្ចៈ អីចឹងអ្វី១ទាំងអស់នោះ ត្រូវរងការប្រែប្រួល ហើយក៏គ្មានអង្គភាពជាអចិន្ត្រៃយ៍ ( និច្ចៈ ) ណាមួយដែលមានឈ្មោះហៅថា អត្តៈ, ឬអាត្មានោះដែរ ។ តាមគន្លងនេះ យើងអាចអះអាងថា ព្រះពុទ្ធ គឺជាមនុស្សអស្ចារ្យម្នាក់ដែលបានយល់ និងបានបង្ហាញអោយឃើញនូវតថភាព នៃអ្វី១ទាំងអស់ក្នុងលោក ។

ដើម្បីមើលឃើញព្រះពុទ្ធ ដែលទ្រង់បានយល់អ្វី១ទាំងអស់, គេត្រូវមើលអោយឃើញព្រះធម៌ ។ នេះគឺជាហេតុការណ៍មួយ ដែលព្រះពុទ្ធព្រះអង្គឯងបានសំដែងនៅក្នុងឱកាសដ៏ច្រើន ។ ម្តងនោះ សាវ័កមួយអង្គព្រះនាម វក្កលិ ដែលជាអ្នកមានភក្តីច្រើនបំផុតចំពោះព្រះបរមគ្រូ តែងតាមសម្លឹងគយគន់ព្រះរូបកាយរបស់ព្រះអង្គ ។ ព្រះពុទ្ធបានថ្កោលទោសចំពោះអំពើនេះ ហើយទ្រង់ត្រាស់ទៅកាន់វក្កលិថា « ម្នាលវក្កលិ តើមានប្រយោជន៍អ្វីនឹងតាមសម្លឹងមើលរូបកាយដ៏គ្មានខ្លឹមសារនេះ, អ្នកដែលឃើញព្រះធម៌, ឃើញតថាគត, អ្នកដែលឃើញតថាគត ឃើញព្រះធម៌ » ។ ក្នុងឱកាសមួយផ្សេងទៀត នៅក្នុងចុល្លហត្ថិបាទោបមាសូត្រ ព្រះពុទ្ធទ្រង់បានអធិប្បាយថា ការប្រតិបត្តិតាមព្រះធម៌ គឺជាមាគ៌ាដើម្បីយល់ព្រះពុទ្ធ ។ ពុទ្ធដីកានេះបង្ហាញអោយយើងឃើញថា បញ្ញា ( Wisdom ) មានសារសំខាន់ជាងជំនឿ ( Faith ) ដើម្បីស្គាល់ព្រះពុទ្ធច្បាស់លាស់ ។ អ្នកបន្តពិនិត្យពិចារណាព្រះធម៌យ៉ាងល្អិតល្អន់កាន់តែខ្លាំង, អ្នកនឹងឃើញមហន្តភាព ( the greatness ) របស់ព្រះពុទ្ធកាន់តែធំធេងឡើង១ ។

by B. Wimalaratana
in Buddhism, Society and
Environment

បកប្រែ : **ឈួន អៀម**

# អំពីភិក្ខុ ឬ ភិក្ខុសង្ឃ

រៀបរៀងដោយ : **ឈន រៀម**

ចាប់តាំងពីលេខ១ ឆ្នាំ ១៩៩៤ ជាបន្តបន្ទាប់ មកដល់លេខ១ ឆ្នាំ ១៩៩៥ នេះ យើងបានចុះផ្សាយអត្ថបទមួយក្រោមចំណងជើងថា *ព្រះធម៌របស់ព្រះពុទ្ធ* ដែលនៅក្នុងអត្ថបទនោះ យើងបានរៀបរាប់អំពីព្រះពុទ្ធ និងព្រះធម៌ ដ៏ជាទ្រឹស្តីមូលដ្ឋាននៃពុទ្ធសាសនា ។ ឥឡូវនេះ យើងនឹងរៀបរាប់អំពី*ភិក្ខុសង្ឃ* ឬ *សង្ឃ* ដែលជារតនៈមួយនៃត្រ័យរតនៈគឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដើម្បីជាជំនួយដល់ចំណេះដឹងរបស់លោកអ្នកអានបន្តទៀត ។

ជាដំបូង យើងគប្បីពិនិត្យសិក្សាស័ព្ទ «ភិក្ខុ» សិន ។ ភិក្ខុ គឺជាអ្នកបួសកិរិតខ្ពស់ (ឧបសម្បទា) ក្នុងពុទ្ធសាសនា ។ តាមដើមកំណើតរបស់វា ពាក្យនេះក្លាយចេញមកពីឫសសំស្ក្រឹត «ភជ» ដែលមានន័យថា «ចង់ចែករំលែក» ឬ «ចូលរួម, រួមចំណែក» ។ ដូច្នេះ ភិក្ខុ មានន័យថា អ្នកដែលសុំសម្រាប់សេចក្ដីត្រូវការរបស់ខ្លួន, ជាពិសេស សុំអំណោយ, អំពីអ្នកដទៃ, ឬនិយាយម្យ៉ាងទៀត គឺជាស្មូមកាន់សាសនា (ភិក្ខតីតិ > ភិក្ខុ) ។

នៅក្នុងប្រទេសឥណ្ឌានាសម័យពុទ្ធកាល មានតាបសគោចរច្រើនបែបណាស់ ដែលនិយមហៅដោយរួមថា «បរិព្វាជក» ។ បរិព្វាជកនេះ ត្រូវបានគេនិយាយយោងដល់ជាញឹកញយនៅក្នុងបិដក, ហើយជាញឹកញយណាស់នោះ ក្រោមពាក្យទូទៅមួយគឺ «សមណព្រាហ្មណ៍» ។ មនុស្សទាំងឡាយជាបុរស ឬស្ត្រី, ដែលបានប្រកាន់យកជីវភាពជាតាបសនេះ, បានលះបង់ផ្ទះសម្បែង គ្រួសារ និងទ្រព្យធន ហើយបានកាន់យកនូវជីវិតរស់នៅយ៉ាងសាមញ្ញ បំផុត ។ ដោយរស់នៅក្រៅសង្គម

ចាត់តាំង, សមណព្រាហ្មណ៍ទាំងនោះបានរស់នៅជាជីវភាពឥសី ។ សេចក្តីត្រូវការដ៏សាមញ្ញរបស់គេ ត្រូវបានបំពេញដោយការសុំទាន ។ ជួនកាល គេក៏រស់នៅជាក្រុម (គណៈ), នៅក្នុងករណីនេះ គេឋិតនៅក្រោមការគ្រប់គ្រងរបស់មេម្នាក់ ។ ចរិតលក្ខណៈដ៏ចម្បងៗរបស់ពួកគេគឺ ទុគ្គតភាព, ភាពនៅលីវ និងជីវភាពរស់នៅជាតាបស ។ គឺក្រុមតាបស និងតាបសជាបុគ្គលម្នាក់ៗទាំងនេះហើយ ដែលបានត្រួសត្រាយផ្លូវ សម្រាប់ស្ថាបនាឡើងនូវអង្គការមានការចាត់តាំងមួយរបស់ពុទ្ធិកយាចក ដែលហៅថា «ភិក្ខុសង្ឃ» នេះឯង ។

ទិដ្ឋភាពមួយទៀតនៃសង្គមឥណ្ឌា នាសម័យកាលដែលព្រះពុទ្ធទ្រង់បានប្រសូត ហើយដែលមានសារសំខាន់នៅក្នុងទំនាក់ទំនងនេះគឺ *ទ្រឹស្តីអាស្រម* របស់ពួកព្រាហ្មណ៍ ។ យោងតាមទ្រឹស្តីនេះ ជីវិតរបស់ព្រាហ្មណ៍ម្នាក់ត្រូវបានចែកជាបួនដំណាក់កាល ៖ ជាបុគ្គលមួយរូបដែលបំពេញការសិក្សាដ៏ពិសិដ្ឋ ជានិស្សិតនៅលីវប្រកាន់ខ្ជាប់ភាពបរិសុទ្ធ (ព្រហ្មចារិន), ជាមេផ្ទះកំពុងអនុវត្តករណីយកិច្ចជាម្ចាស់ផ្ទះ និងជាឪពុកនៃគ្រួសារមួយ (គ្រឹហស្ថ), ជាឫសីម្នាក់ដែលលះបង់គ្រួសារ និងផ្ទះរបស់គេ សម្រាប់ជីវភាពជាតាបសរស់នៅក្នុងព្រៃ (វានប្រស្ថ), និងជាសាសនិកយាចកដែលលះបង់កង្វល់លោកីយគ្រប់យ៉ាង ហើយឧទ្ទិសខ្លួនចំពោះសមាធិ (សន្យាសិន) ។ ដោយមិនចាំបាច់ជជែកវែកញែកថា តើស្ថាប័ននេះកើតមានមុន ឬក្រោយព្រះពុទ្ធនោះទេ, យើងអាចទទួលយកដោយឥតរអែងថា មតិនេះបានចាក់ឫសរឹងមាំរួចហើយនាសម័យកាលនៃព្រះពុទ្ធ, ពីព្រោះមតិនេះត្រូវបានគេឃើញថា ឧត្តមគតិស្តីពីតាបសដែលនិយាយយោងពីខាងដើម ត្រូវបានជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយ នឹង*ទ្រឹស្តីអាស្រម* ។ គួរកត់សម្គាល់ថា សមាជិកនៃក្រុមទី ៤ គឺ «សន្យាសិន» មានភាពប្រហាក់ប្រហែលគ្នាយ៉ាងច្រើនទៅនឹងភិក្ខុក្នុងពុទ្ធ-សាសនា ។ តាមពិត ស័ព្ទ « ភិក្សុ » នេះ ត្រូវបានគេប្រើសម្រាប់សម្គាល់

*សន្យាសិន* នៅក្នុងធម៌សូត្រ ។ នេះប្រហែលជាអាចនិយាយថា ដំណាក់កាល *សន្យាសិន* គឺជាការធ្វើព្រាហ្មណូបនិយកម្មនៃការប្រតិបត្តិផ្សេងណាមួយ មិនមែនរបស់ព្រាហ្មណ៍ ដែលបានក្លាយទៅជាប្រជាប្រិយហើយនោះ ។ ប៉ុន្តែថា, ផ្នែកទីមួយ និងទីបួន (ពោលគឺ ព្រហ្មចារិន និងសន្យាសិន) មានផ្ទុកអត្ថន័យខ្លះចំពោះគំនិតស្តីពីភិក្ខុពុទ្ធសាសនិក, ពីព្រោះ ដូចនៅក្នុងករណីអ្នកបួសក្នុងពុទ្ធសាសនា សមាជិកទាំងឡាយរបស់ផ្នែកទាំងពីរនេះ ត្រូវបានគេសង្ឃឹមថាប្រកាន់យកយ៉ាងម៉ត់ចត់នូវភាពនៅលីវ ។ *ព្រហ្មចារិន* មានលក្ខណៈប្រហាក់ប្រហែលនឹង *សាមណេរ* ពុទ្ធសាសនិក, ហើយ *សន្យាសិន* ប្រហាក់ប្រហែលនឹង *ភិក្ខុ* ។ ជាភាគមួយនៃជីវិតរស់នៅដោយការលះបង់, សន្យាសិនត្រូវពឹងពាក់អាស្រ័យលើការសុំទាន (ភិក្សា) ដើម្បីចិញ្ចឹមជីវិត ។ គេត្រូវបដិសេធផាសុកភាពនៃជីវិតដ៏ច្រើនផ្សេងទៀតផងដែរ, ហើយសម្លៀកបំពាក់របស់គេ គឺជាសម្បកឈើ ឬជាសំពត់ជ្រលក់ពណ៌ ។ ដូច្នេះយើងឃើញថា ប្រសិនបើដំណាក់កាល *គ្រឹហស្ថ* និង *វានប្រស្ថ* ត្រូវបានព្រាហ្មណ៍ម្នាក់រំលងចោល យើងនឹងបានរូបភាពប្រហាក់ប្រហែលនឹងភិក្ខុពុទ្ធសាសនិកដែរ ។ ប្រសិនបើមនុស្សបែបនេះ ត្រូវបានទទួលការបំបួសត្រឹមត្រូវ ហើយទុកព្រះនិព្វានជាគោលដៅនោះ ការឆ្លងកាត់របស់គេទៅកាន់ស្ថានភាពជាភិក្ខុពុទ្ធសាសនិកនោះ ស្ទើរតែមានលក្ខណៈពេញលេញទៅហើយ ។

គឺនៅក្នុងប្រវត្តិបែបនេះហើយដែលព្រះពុទ្ធបានស្ថាបនា *ភិក្ខុសង្ឃ* ។ យើងមិនអាចអះអាងអំពីហេតុ-ផលដែលនាំអោយព្រះពុទ្ធអង្គជ្រើសរើសស័ព្ទដ៏ពិសេសនេះ ទុកជាការសម្គាល់ធម្មតាសម្រាប់សាវ័ករបស់ព្រះអង្គបានឡើយ ។ ថ្វីបើពាក្យ *សាមណេរ* ត្រូវបានប្រើជាញឹកញយនៅក្នុងគម្ពីរព្រះត្រៃបិដក ហើយព្រះពុទ្ធអង្គឯង ក៏ត្រូវបានគេនិយាយយោងដល់ជាញឹកញយណាស់ថា *សមណោគោតមោ* ឬ *សមណគោតម* ដោយពួកជនមិនមែនជាពុទ្ធសាសនិក នាសម័យកាល

របស់ព្រះអង្គផងដែរក៏ដោយ ក៏ស័ព្ទ *ភិក្ខុ* ហាក់ដូចជាបានជំនួសស័ព្ទផ្សេងទៀត ។ នេះក៏គេគប្បីយល់ផងដែរ ពីព្រោះព្រះពុទ្ធអង្គឯងហាក់ដូចជាគាប់ព្រះទ័យស័ព្ទ *ភិក្ខុ* ជាងស័ព្ទឯទៀតៗ ។ គំនិតនេះបញ្ជាក់អោយឃើញ ដោយហេតុថា រាល់ពេលដែលព្រះអង្គមានព្រះពុទ្ធដីកាទៅកាន់អង្គប្រជុំបព្វជិត ព្រះអង្គតែងប្រើពាក្យ *ភិក្ខុ* ក្នុងទម្រង់អាលបនៈពហុវចនៈថា *ភិក្ខវេ* (ម្នាលភិក្ខុទាំងឡាយ) ។ គឺជាមួយនឹងពាក្យដដែលនេះទៀត ដែលព្រះអង្គមានព្រះពុទ្ធដីកាទៅកាន់សាវ័កទាំងប្រាំអង្គដំបូងរបស់ព្រះអង្គ ។ នៅក្នុងរូបមន្តបំបួសដែលព្រះពុទ្ធបានប្រើដោយផ្ទាល់ព្រះអង្គឯង ក៏ដូចគ្នាដែរ កាលណាព្រះអង្គទ្រង់យល់ព្រមទទួលយកជនណាមួយអោយចូលក្នុងគណៈសង្ឃរបស់ព្រះអង្គនោះ គឺពាក្យ *ភិក្ខុ* នេះហើយដែលព្រះអង្គបានប្រើ « .... *ឯថ ភិក្ខវោ'តិ* » ។ វាអាចមានន័យថា ដោយការប្រើពាក្យនេះ ព្រះពុទ្ធទ្រង់បានឈ្វេងយល់ដល់ការធ្វើអោយឮរណ្តំនៅក្នុងត្រចៀករបស់ជនទាំងឡាយនោះ នូវគំនិតអំពី *នេក្ខម្មៈ* (Renunciation) ដែលបង្កប់នៅក្នុងពាក្យនេះ ។ នៅក្នុងពេលកន្លងទៅ ការប្រើស័ព្ទ *ភិក្ខុ* នេះ បានក្លាយទៅស្ទើរតែជាស្វ័យប្រវត្តិទៅហើយ ។

ការចាប់ផ្តើមនៃភិក្ខុសង្ឃក្នុងពុទ្ធសាសនា បានកើតមានដំណាលគ្នានឹងការចាប់ផ្តើមនៃសកម្មភាពរបស់ព្រះពុទ្ធ ក្នុងព្រះឋានៈព្រះអង្គជាគ្រូ និងជាអ្នកទេសនាប្រៀនប្រដៅ ។ នេះក៏ប្រហែលជាការរីកចំរើនខាងប្រវត្តិសាស្ត្រមួយ ដែលកាលៈទេសៈបានតម្រូវអោយ ។ កាលដែលព្រះពុទ្ធទ្រង់សំដែងបឋមទេសនារបស់ព្រះអង្គនៅឥសីបតនៈ ក្នុងក្រុងបេណារ៉េស ចំពោះតាបសព្រាហ្មណ៍ទាំងប្រាំរូប (បញ្ចវគ្គិយ), តាបសព្រាហ្មណ៍ទាំងនោះ បានក្លាយទៅជាអ្នកផ្លាស់សាសនាដ៏ត្រឹមត្រូវ ហើយជាអ្នកមុនគេចូលក្នុង *សង្ឃ* ។ ចាប់ពីពេលនោះមក លោកទាំងនោះរួមផ្តុំជាស្ថាបនិកដើមនៃ*ភិក្ខុសង្ឃ* ហើយគឺរូបមន្ត «*ឯហិភិក្ខុ*» ដែលព្រះពុទ្ធបានប្រើសម្រាប់ការអនុញ្ញាតផ្នួសដល់លោកទាំងនោះ ។ បន្ទាប់ពីផ្នួសរបស់បញ្ចវគ្គិយភិក្ខុ,

យសៈ, ឪពុកម្ដាយ និងមិត្រទាំងឡាយរបស់គេក៏បានចូលបួសដែរ រួមទាំងអស់មានហុកសិបអង្គជាភិក្ខុ ហើយទាំងអស់គ្នាបានក្លាយជាព្រះអរហន្ត ក្រោយការចូលកាន់ពុទ្ធសាសនា ដោយមានរួមទាំងឧបសម្បទាថ្នាក់ខ្ពស់ ទាំងឧបសម្បទាថ្នាក់ទាប ។ សាវ័កទាំងហុកសិបអង្គនេះ បានទៅជាស្នូលនៃភិក្ខុ-សង្ឃ ។

ដោយសាវ័កទាំងនោះសុទ្ធតែជាព្រះអរហន្ត, នោះពុំទាន់ត្រូវការអោយមានវិនយបញ្ញត្តិ ដូចជាប្រភេទវិនយបញ្ញត្តិដែលយើងមាន នាកាលខាងក្រោយមកទេ ។ ជាងនេះទៀត, លោកក៏ពុំចាំបាច់ចាត់តាំងរៀបចំខ្លួនលោកអោយទៅជាគណៈដែរ ។ បទបញ្ញត្តិ និងការចាត់តាំង ត្រូវបានរៀបចំឡើងខាងក្រោយនេះទេ គឺនៅពេលដែលភិក្ខុមិនមែនជាអរហន្តកាន់តែមានចំនួនកើនឡើង ។ ពុទ្ធដីកាដែលព្រះពុទ្ធមានបន្ទូលទៅកាន់ភិក្ខុទាំងឡាយនោះ បង្ហាញអោយឃើញនូវបេសកកម្មយ៉ាងដែលព្រះអង្គមានបាថ្វន៍យចង់បានពីភិក្ខុទាំងនោះ ។ ព្រះអង្គបានហៅលោកទាំងឡាយនោះថា «ភិក្ខុៗ» ហើយទ្រង់ប្រើអោយនិមន្តទៅកាន់ទិសផ្សេងៗ ដើម្បីផ្សព្វផ្សាយព្រះធម៌ សម្រាប់សុខុមាលភាពរបស់មនុស្ស ។ នេះបង្ហាញថា អ្វីដែលព្រះអង្គមានសេចក្ដីសង្ឃឹមចង់បានពីភិក្ខុមួយរូបៗ, នៅពេលដែលភិក្ខុអង្គនោះ បានសម្រេចការត្រាស់ដឹង និងការរំដោះរួចហើយ, នោះគឺដើម្បីអោយភិក្ខុនោះបានទៅជាបេសកជនដ៏មានភក្ដីភាព និងជាគ្រូប្រដៅសាសនាមួយអង្គ ។ រីឯសេចក្ដីកង្វល់ចំពោះមុខរបស់ភិក្ខុមួយអង្គៗវិញ គប្បីជាការខិតខំសំរេចអោយបានសុក្រឹតភាពផ្ទាល់ខ្លួន និងការរំដោះសម្រាប់ខ្លួន ហើយកាលណាគុណធម៌នេះបានសម្រេចហើយ ភិក្ខុនោះគប្បីបំពេញការងារ «ដើម្បីជាគុណប្រយោជន៍ និងសេចក្ដីសុខដល់មនុស្សដ៏ច្រើន» ។

ក្រោយការបញ្ជូនសាវ័កទាំងហុកសិបអង្គ ជាមួយនឹងដំបូន្មានអោយផ្សព្វផ្សាយព្រះធម៌, មានព្រឹត្តការណ៍ដ៏សំខាន់មួយបានកើតមានឡើង នៅក្នុងការរីក

ចំរើននៃទស្សនភិក្ខុ ។ នោះគឺការអនុញ្ញាតរបស់ព្រះពុទ្ធអោយភិក្ខុជាថេរៈ (មានវស្សាផ្នូសច្រើន) បំបួសសមណបេក្ខៈថ្មីៗបាន ។ សាវ័កទាំងហុកសិបអង្គ បានត្រឡប់មកវិញ ដោយនាំមកជាមួយនូវសមណបេក្ខៈជាច្រើន សម្រាប់បំបួសបញ្ចូលទៅក្នុងគណៈ ហើយព្រះពុទ្ធទ្រង់ឈ្វេងយល់ថា ជាការជាក់ស្តែង ព្រះអង្គពុំអាចបំបួសសមណបេក្ខៈទាំងនោះដោយផ្ទាល់ព្រះអង្គឯងបានឡើយ ។ សមណបេក្ខៈថ្មីៗទាំងឡាយ ក្រោយពេលបានកោរសក់ កោរពុកមាត់ ពុកចង្កា និងស្លៀកដណ្តប់សំពត់ពណ៌លឿងរួចហើយ ត្រូវទៅថ្វាយបង្គំព្រះភិក្ខុជាថេរៈ, ហើយដោយមានដៃសំពះផង ត្រូវសូត្របីដងនូវត្រៃសរណគមន៍ ថ្វាយខ្លួនក្នុងព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។ ដូចជានៅក្នុងករណីនៃរូបមន្ត «ឯហិភិក្ខុ» ដែលរួមមានទាំងការបួសថ្នាក់ទាប និងទាំងការបួសថ្នាក់ខ្ពស់, ក្នុងទីនេះ ការថ្វាយខ្លួននេះ ក៏រួមមានទាំងការបួសថ្នាក់ទាប និងការបួសថ្នាក់ខ្ពស់ដែរ (*តីហិ សរណគមនេហិ បព្វជ្ជំ ឧបសម្បទន្តិ* : វិន័យបិដក) ។

ព្រឹត្តិការណ៍នេះ គួសបញ្ជាក់នូវដំណាក់ដ៏សំខាន់មួយក្នុងការរីកចំរើននៃការយល់អំពី «ភិក្ខុ» ។ នៅក្នុងករណីបព្វជ្ជាផ្ទាល់ យើងឃើញថា តើភាពរលាំគ្នានៃពិធីត្រូវបានបញ្ចូលមកយ៉ាងណា ហើយថាតើទ្រង់ទ្រាយខាងក្រៅនៃភិក្ខុ ចាប់ផ្តើមចេញជារូបរាងយ៉ាងណាដែរ ។ ក្នុងករណីនៃភិក្ខុទាំងឡាយនោះ ដែលបានក្លាយទៅជាព្រះអរហន្ត ក្រោយពេលបានបួសរួចហើយបន្តិចមក, នោះពុំចាំបាច់មានបទវិន័យប្បញ្ញត្តិ ឬបែបបទផ្សេងណាមួយទេ ។ លោកទាំងឡាយនោះបានឈ្នះចម្បាំងហើយ ហើយពុំចាំបាច់មានការប្រយុទ្ធខាងបញ្ញាស្មារតីវែងឆ្ងាយណាមួយទេ ។ ករណីយកិច្ចរបស់លោកទាំងនោះ ក្នុងឋានៈជាភិក្ខុ គឺបំពេញការងារសម្រាប់សុខុមាលភាពរបស់អ្នកដទៃ ។ ប៉ុន្តែ វាមានករណីផ្សេងចំពោះភិក្ខុទាំងឡាយដែលមិនទាន់បានសំរេចឋានៈនេះនៅឡើយ ។ នៅពេលដែលចំនួនភិក្ខុមិនមែនជា

អរហន្តកាន់តែកើនឡើង, ការចាំបាច់ត្រូវមានក្រឹត្យវិន័យ ដើម្បីចង្អុលផ្លូវដល់ភិក្ខុទាំងនោះ ហើយចាត់តាំងភិក្ខុទាំងនោះទៅជាគណៈមួយ ក៏កើតមានឡើងដែរ ។ ការប្រែប្រួលវែងឆ្ងាយនៅក្នុងពិធីបព្វជ្ជា ក៏កើតមានដែរ, ដែលនៅក្នុងនេះ ការអនុញ្ញាតអោយបំបួស ក៏ត្រូវបានធ្លាក់មកលើសង្ឃទាំងមូល ។ ជាការច្បាស់ណាស់ថា មនុស្សម្នាក់ចូលបួសក្នុងពុទ្ធសាសនាជាភិក្ខុ ត្រូវខិតខំប្រព្រឹត្តដើម្បីគោលបំណងដ៏ឧត្តមមួយ, ដែលត្រូវរស់នៅក្នុងភាពបរិសុទ្ធ និងត្រូវបញ្ចប់ទាំងស្រុងនូវទុក្ខៈ *(ចរថ ព្រហ្មចរិយំ សម្មា ទុក្ខស្ស អន្តកិរិយាយ* : វិន័យបិដក) ។ នេះហើយជាអ្វីដែលព្រះពុទ្ធទ្រង់ប្រាថ្នាចង់បានអំពីសាវ័កទាំងឡាយរបស់ព្រះអង្គ ដ៏ជាករណីយកិច្ចដំបូងរបស់សាវ័កទាំងនោះ ។

សង្ឃត្រូវបានរីកធំធាត់យ៉ាងឆាប់ ដោយមានចំនួនភិក្ខុកើនឡើងជារៀងរាល់ថ្ងៃ ។ មិនមែនបព្វជ្ជា និងឧបសម្បទារបស់ភិក្ខុ ត្រូវបានធ្វើពិធីដោយឡែក១ពីគ្នា ប៉ុណ្ណោះនោះទេ, ប៉ុន្តែ បព្វជ្ជា និងឧបសម្បទា តាមពិតទៅ ត្រូវបានក្លាយទៅជាដំណាក់កាលពីរនៃជីវភាពរបស់ភិក្ខុ ។ បព្វជ្ជា ជាលក្ខណ៍ការណ៍សម្រាប់បំបួសកុលបុត្រជាសាមណេរ, ចំណែកឯឧបសម្បទា ជាលក្ខណ៍ការណ៍សម្រាប់បំបួសកុលបុត្រ អោយចូលក្នុងល័ក្ខខ័ណ្ឌពេញលេញជាភិក្ខុ ។ ក្នុងទីនេះ គេគប្បីបញ្ជាក់ថា រាល់ពេលដែលព្រះពុទ្ធបរមគ្រូអនុញ្ញាតទទួលយកបុគ្គលមួយចំនួនណានោះ អោយចូលក្នុងជួរសង្ឃ, ព្រះអង្គតែងប្រើជានិច្ចរូបមន្ត *ឯហិ ភិក្ខុ* (ម្នាលភិក្ខុ, ចូរមក) ដោយពុំមានការបែងចែករវាងការបួសថ្នាក់ខ្ពស់ និងការបួសថ្នាក់ទាបទេ ។ នៅពេលដែលការអនុញ្ញាតអោយបំបួស ត្រូវបានប្រគល់ទៅអោយពួកសាវ័កជាថេរៈ ដើម្បីបំបួសនវភិក្ខុហើយ, នោះរូបមន្ត *ឯហិ ភិក្ខុ* ក៏ត្រូវបានជំនួសដោយរូបមន្តថ្មី គឺការប្រកាន់យកត្រៃសរណគមន៍ (សរណាគមនៈ) វិញ ។ វិធីទីមួយដែលត្រូវបានប្រើដោយផ្ទាល់មុខសម្រាប់តែព្រះពុទ្ធ, គឺជាការអញ្ជើញ ឬការ

ហៅរក, ចំណែកឯវិធីទីពីរ គឺជាការប្រកាសជំនឿរបស់ខ្លួនដោយអ្នកសុំផ្នួស ។ ការផ្ដាច់បព្វជ្ជាចេញពីឧបសម្បទា ហាក់ដូចជាត្រូវបានគេប្រកាន់យក កាលណាការបំបួសនវភិក្ខុបានក្លាយជាអំពើរបស់សង្ឃ ហៅថា *សង្ឃកម្ម* ។ ពីព្រោះ ឧបសម្បទា, ភិក្ខុត្រូវមានអាយុមិនតិចជាងម្ភៃឆ្នាំឡើយ ។ ការបំបួស មិនត្រូវបានធ្វើដោយមិនបែងចែកនោះឡើយ ។ ដើម្បីចៀសវាងការធ្វើខុសឆ្គង និងហាមឃាត់អ្នកមិនជាទីប្រាថ្នាចង់បានចូលមកក្នុងគណៈ, កុលបុត្រត្រូវបំពេញល័ក្ខខ័ណ្ឌមួយចំនួនមុនបានអនុញ្ញាតអោយបួស (សូមអាន បព្វជ្ជាវិធី ដើម្បីយល់ដឹងបានល្អិតល្អន់) ។ ភិក្ខុមួយចំនួន ក្នុងចំណោមភិក្ខុទាំងឡាយដែលបានចូលបួសមិតនៅក្នុងគណៈសង្ឃ គឺជាបុគ្គលមានគុណសម្បត្តិខាងបញ្ញាស្មារតីរអន់ខ្សោយជាងសមាជិកទាំងឡាយនៃគណៈសង្ឃ កាលពីដើមទីដែលបានសំរេចអរហត្តផលក្នុងរយៈពេលមួយដ៏ខ្លី ។ ដោយហេតុនេះ ភិក្ខុមួយចំនួនណានោះ ត្រូវការទទួលយកការហ្វឹកហ្វឺនយ៉ាងច្រើន, ហើយនៅពេលដែលចំនួនកាន់តែកើនឡើង, ក្បួនច្បាប់ និងបទបញ្ញត្តិផ្សេងៗ រឹងរឹតតែជាការចាំបាច់សម្រាប់ការគោរពប្រតិបត្តិរបស់ភិក្ខុទាំងនោះផ្ទាល់ ។ ការបំបួសនេះទៀត ក៏គប្បីតែត្រូវបានគេត្រួតពិនិត្យដោយម៉ត់ចត់ដែរ ។ កិត្យានុភាព និងការគោរពរាប់អានរបស់ភិក្ខុ ត្រូវតែបានរក្សាការពារ ។ មុនពេលបានបួសជាសាមណេរ កុលបុត្រត្រូវបានការអនុញ្ញាតយល់ព្រមពីឪពុកម្ដាយ, ហើយត្រូវមានអាយុមិនតិចជាង[១] ១៥ ឆ្នាំ និងពុំមានកាយពិការបែបណាមួយឡើយ ។ វិន័យបញ្ញត្តិទាំងឡាយ ដែលទាក់ទងនឹងការអនុញ្ញាតផ្នួសបញ្ចូលទៅក្នុងគណៈសង្ឃ គឺមានអត្ថន័យដើម្បីធានាថា គឺមានតែអ្នកដែលមានសម្បទាសមស្រប ទាំងខាង

(១) នៅប្រទេសស្រីលង្កា គេកំណត់ដូច្នេះ ។ នៅកម្ពុជា ពុំមានការកំណត់ដូចនេះទេ ។ អ្នកខ្លះបានអះអាងថា កុលបុត្រអាចបួសជាសាមណេរបាន បើគេអាចចោលបង្អើលក្អែកបាន ។

រូបកាយ ទាំងខាងបញ្ញាស្មារតីប៉ុណ្ណោះទេ ទើបអាចចូលក្នុងគណៈសង្ឃបាន ។ មានតែអ្នកទាំងឡាយណាដែលមានហឫទ័យញាប់ញ័រ ដោយមូលហេតុសមស្រប ប៉ុណ្ណោះទេ ទើបអាចសង្ឃឹមទៅជាភិក្ខុដ៏ផូរផង់បាន និងមានតែអ្នកទាំងឡាយណាដែលមានខ្លួនទូន្មានបានយ៉ាងត្រឹមត្រូវប៉ុណ្ណោះទេ, ទើបអាចឋិតនៅក្នុងគណៈសង្ឃបាន ។

បន្តិចម្តងៗ គណៈនៃភិក្ខុបានក្លាយទៅជាអង្គការមួយគ្រប់គ្រងដោយវិន័យបញ្ញត្តិ, ដោយហេតុថា ភិក្ខុទាំងឡាយនោះត្រូវទទួលការហ្វឹកហ្វឺនយ៉ាងច្រើន, ហើយអ្នករំលោភបំពានលើក្រឹត្យវិន័យ ត្រូវទទួលទោសតាមបែបបទផ្សេងៗ ។ ក្រឹត្យវិន័យត្រូវបានបញ្ញត្តឡើង មិនមែនធ្វើម្តងទាំងអស់នោះទេ ប៉ុន្តែធ្វើឡើងទៅតាមឱកាសទាមទារ ។ ក្រឹត្យវិន័យខ្លះ ត្រូវបានបញ្ញត្តឡើងដោយមិនគិតដល់សាធារណមតិផងទេ ។ ជាផលវិបាក, ទើបមានការបន្ថែម និងការកែប្រែនៃក្រឹត្យវិន័យធ្វើឡើងជាបន្តបន្ទាប់អស់ពេលយ៉ាងវែង ។ ស្នូលដើមនៃក្រឹត្យវិន័យនោះ ត្រូវបានសល់ទុកមកដល់យើងក្នុងទ្រង់ទ្រាយចាស់បំផុត ក្រោមឈ្មោះថា *បាតិមោក្ខ* ដែលមាននៅក្នុងផ្នែកសុត្តវិភង្គៈ នៃវិន័យបិដក ។ ទោះបីជាឋិតក្នុងទ្រង់ទ្រាយថ្មីក្តី, ក៏សិក្ខាបទមានមិនតិចជាង ២២៧ ដែរ, ហើយតាមខ្លឹមសារយ៉ាងហោចណាស់ក៏ប្រជុំនៃសិក្ខាបទទាំងនោះ មានអត្ថរសដូចនៅក្នុងសម័យកាលព្រះពុទ្ធផ្ទាល់ដែរ ។

ភិក្ខុទាំងឡាយរស់នៅក្នុងតំបន់ដោយឡែកមួយហៅថា *សីមា* ត្រូវសូធ្យបាតិមោក្ខរៀងរាល់កន្លះខែម្តង ទុកដូចជារូបមន្តនៃការសារភាពទោស ដែលគេនិយមហៅនៅប្រទេសយើងនេះថា *សំដែងអាបត្តិ* ។ សិក្ខាបទទាំងឡាយ ត្រូវបានរៀបចំឡើងជាប្រាំបីថ្នាក់ទៅតាមកំរិតនៃទម្ងន់ទោសគឺ : បារាជិក ៤ ; សង្ឃាទិសេស ១៣ ; អនិយតៈ ២ ; និស្សគ្គិយបាចិត្តិយៈ ៣០ ; បាចិត្តិយៈ ៩២ ; បដិទេសនីយៈ ៤ ; សេក្ខិយៈ ៧៥ និងអធិករណសមថៈ ៧ ។ ភិក្ខុល្អត្រូវរក្សា

សិក្ខាបទទាំងនេះ ដរាបណាភិក្ខុនោះនៅទទួលការហ្វឹកហ្វឺន និងដរាបណាភិក្ខុនោះនៅជាសេក្ខបុគ្គល (អ្នករៀន) ។

ទោសបញ្ញត្តិ ត្រូវបានកំណត់សម្រាប់ការបំពារបំពានលើសិក្ខាបទទាំងឡាយត្រង់ប្រការណាមួយ ។

ដើម្បីយល់បានទូលំទូលាយ សូមអាន សុត្តវិភង្គៈ នៃវិន័យបិដក ។ ខាងក្រោមនេះ គឺគ្រាន់តែជាសេចក្តីសង្ខេបដ៏ខ្លីប៉ុណ្ណោះ ។

វិន័យដ៏សំខាន់បំផុតក្នុងបណ្តាសិក្ខាបទទាំង ២២៧ នោះគឺ បារាជិកបួន ។ ការប្រព្រឹត្តបំពានលើសិក្ខាបទទាំង ៤ នេះ ត្រង់ប្រការណាមួយ នឹងត្រូវបណ្តេញចេញជារៀងរហូតពីគណៈសង្ឃ ។ សិក្ខាបទទាំង ៤ នោះគឺ : ភិក្ខុមិនត្រូវប្រព្រឹត្តខុសឆ្គងក្នុងទ្រង់ទ្រាយបែបណានៃការសេពមេថុនធម្ម, មិនត្រូវប្រព្រឹត្តខុសក្នុងការលួច, មិនត្រូវផ្តាច់ផ្តិល ឬញុំាងអោយគេផ្តាច់ផ្តិលជីវិតមនុស្ស និងមិនត្រូវអួតអាង ឬតាំងខ្លួនថាខ្លួនមានឫទ្ធានុភាពអធិ-មនុស្ស ។ សិក្ខាបទនៃសង្ឃាទិ-សេសទាំង ១៣ នោះគឺ កំហុសទាំងឡាយអាចនាំទៅដល់ការធ្វើបរិវាសកម្មមួយរយៈកាល ហើយត្រូវបានបញ្ចូលទៅក្នុងសហាគមន៍សង្ឃវិញដោយគណៈសង្ឃ ។ សិក្ខាបទប្រាំខាងដើម ទាក់ទងនឹងកំហុសក្នុងកាមគុណតូចតាច ដូចជាស្ទាបអង្អែលស្រី, និយាយឆ្លើយឆ្លងទៅកាន់ស្ត្រីដោយពាក្យសំរើបកាមគុណ, ឬតាំងខ្លួនជាអន្តរ-ការី (មេអណ្តើក) ណែនាំបុរស និងស្ត្រីអោយត្រូវរ៉ូវគ្នា ។ ភិក្ខុដ៏ប្រពៃ មិនត្រូវប្រឌិតការចោទប្រកាន់ចំពោះភិក្ខុដទៃ ឬបំបាក់បំបែកការព្រមព្រៀងនៅក្នុងជួរសង្ឃឡើយ ។ ប្រសិនបើភិក្ខុប្រព្រឹត្តកំហុស ភិក្ខុនោះមិនគប្បីប្រកែកទទួលទណ្ឌកម្ម ឬកែតម្រូវខ្លួននោះឡើយ ។ សិក្ខាបទអនិយតៈពីរ ក៏ទាក់ទងទៅនឹងកំហុសផ្លូវកាមគុណដែរ ។ សិក្ខាបទនិស្សគ្គិយបាចិត្តិយៈទាំងសាមសិប ទាក់ទងនឹងកំហុសដែលទាមទារអោយមានការលាងទោស ឬការទទួលទណ្ឌកម្មលាងទោស ។

សិក្ខាបទនេះ ចែកចេញជាបីផ្នែក, ផ្នែកនិមួយៗមានដប់មាត្រា ។ ក្រុមទីមួយ (ចីវរវគ្គ) ចែងអំពីចីវរ, ក្រុមទីពីរ (កោសេយ្យវគ្គ) ស្តីពីសម្ភារៈសម្រាប់ធ្វើជាកម្រាល និងការប្រើប្រាស់ប្រាក់ ហើយក្រុមទីបី (បត្តវគ្គ) ចែងអំពីបាត្រ, ថ្នាំកែរោគ និងចីវរ ។ ការចាំបាច់ជាមូលដ្ឋានរបស់ភិក្ខុ ជាទូទៅត្រូវបានគេចាត់ជាបួនយ៉ាងគឺ គ្រឿងស្លៀកដណ្តប់ (*ចីវរ*, ដែលមួយសម្រាប់មានសំពត់បី : ស្បង់, ចីពរ, សង្ឃាដិ), អាហារ (បិណ្ឌបាត), ជម្រក (សេនាសនៈ) និងថ្នាំកែរោគ (គិលានបច្ច័យ), ហើយវិន័យប្បញ្ញត្តិក្នុងផ្នែកនេះ មានន័យថាចង់ឃើញ ចង់បានថាវត្ថុទាំងឡាយនោះបានមក និងប្រើប្រាស់ទៅវិញអោយបានត្រឹមត្រូវ ។

សិក្ខាបទបាចិត្តិយៈ ៩២ ក៏ជាសិក្ខាបទទាមទារអោយមានការលាងទោសកំហុសដែរ ។ សិក្ខាបទទាំងនោះ ទាក់ទងនឹងក្បួនច្បាប់សីលធម៌ ដូចជា ការពោលពាក្យកុហក, ការប្រើភាសាប្រមាថមើលងាយ ការនិយាយបង្កាច់បង្ខូចកេរ្តិ៍, ការមានទំនាក់ទំនងមិនសមស្របជាមួយស្ត្រី, ការបំផ្លាញរូបភាពជីវិតបែបណាមួយ រួមទាំងជីវិតភូតគាមផង, និងសិក្ខាបទដទៃទៀត ស្តីពីរបៀបរបបរស់នៅក្នុងវត្តអារាម (វិហារ) ។ ទាំងនេះ រួមមានសិក្ខាបទផ្សេងៗសម្រាប់ឃុំគ្រងចលនារបស់ភិក្ខុក្នុងចំណោមមនុស្សទាំងឡាយ ។ ក្នុងឋានៈជាបុគ្គលម្នាក់ ភិក្ខុគ្មានសិទ្ធិបណ្តេញភិក្ខុជាសហធម្មិករបស់ខ្លួនអោយចេញពីវត្តអារាមទេ ។ ការទាក់ទងរវាងភិក្ខុ និងភិក្ខុនីត្រូវប្រព្រឹត្តទៅបានតាមវិនយប្បញ្ញត្តិ ។ គឺជាកំហុស កាលភិក្ខុចូលរួមក្នុងកីឡាក្នុងទឹក, អាន់ទឹកដែលសត្វមានជីវិតរស់នៅ ឬក៏ជះទឹកបែបនេះទៅលើស្មៅ ។ ភិក្ខុមិនគប្បីដុតភ្លើង ដើម្បីអាំងកំដៅខ្លួនឡើយ, វៀរលែងតែភិក្ខុនោះមានអាពាធ ។ ការលួចលាក់ស្តាប់ការសន្ទនារបស់គេ និងការវាយប្រហារទៅលើភិក្ខុផងគ្នា ត្រូវបានហាមឃាត់ ។ សិក្ខាបទយ៉ាងល្អិតល្អន់ ត្រូវបានបញ្ញត្តឡើងទាក់ទងទៅនឹងចីវរ និងកម្រាលគ្រែ ហើយនិងការប្រើប្រាស់សម្ភារៈទាំងនោះ ។ សិក្ខាបទបាដិទេសនីយៈ

បួន មានចែងអំពីកំហុសទាំងឡាយដែលត្រូវតែសំដែងលាទោស, សិក្ខាបទទាំងនោះទាក់ទងនឹងអាហារ ។ សេខិយសិក្ខាបទទាំងចិតសិបប្រាំ មានចែងយ៉ាងសំខាន់អំពីការហ្វឹកហ្វឺនភិក្ខុ ។ សិក្ខាបទទាំងនោះ មានន័យសំដៅគ្រប់គ្រងឥរិយាបថរបស់ភិក្ខុក្នុងជីវភាពប្រចាំថ្ងៃ និងមានន័យទាក់ទងនឹងទិដ្ឋភាពនៃការប្រព្រឹត្ត ដូចជាការស្លៀកដណ្តប់យ៉ាងសមស្រប, ការប្រកាន់ខ្ជាប់នូវបទបញ្ញត្តិផ្សេងៗ ស្តីពីចរិយាធម៌នៅពេលកំពុងបិណ្ឌបាត និងសុជីវធម៌នៃអាកប្បកិរិយា ។ មានសិក្ខាបទកំណត់ល័ក្ខខ័ណ្ឌ ត្រូវសំដែងធម៌ដល់ជនជាគ្រហស្ថផងដែរ ។ អាកប្បកិរិយាត្រឹមត្រូវសូម្បីក្នុងទំនាក់ទំនងជាមួយអំពើខាងផ្លូវកាយ ក៏ត្រូវបញ្ញត្តទុកដែរ ។ សិក្ខាបទអធិ-ករណសមថៈទាំងប្រាំពីរ គឺជាការចាត់ថ្នាក់នៃបែបបទផ្សេងៗ ដែលទាក់ទងនឹងរឿងហេតុទាំងឡាយ កើតឡើងនៅក្រោមសិក្ខាបទទាំងឡាយនោះប៉ុណ្ណោះ ។

ក្រៅពីសិក្ខាបទទាំងឡាយ ដែលសំដៅគ្រប់គ្រងជីវភាពប្រចាំថ្ងៃរបស់ភិក្ខុមួយរូបៗ, នៅមានសិក្ខាបទទាំងឡាយផ្សេងទៀត ទាក់ទងនឹងការចាត់តាំងនៃគណៈសង្ឃ ។ សិក្ខាបទទាំងពីរផ្នែកនេះ មានន័យសំដៅរក្សាភិក្ខុអោយឋិតនៅក្នុងក្រឹត្យវិន័យ ។ សិក្ខាបទទាំងពីរក្រុមនេះ មាននិយាយនៅក្នុងផ្នែកទីពីរនៃវិន័យបិដកដែលមានឈ្មោះថា ខន្ធកៈ ដែលត្រូវបានចងក្រងឡើងទុកដូចជាសេចក្តីបន្ថែមទៅនឹងអត្ថបទសុត្តវិភង្គៈ ។ ខន្ធកៈ រួមមានទាំងបទបញ្ញត្តិសម្រាប់ការបំបួសចូលក្នុងគណៈសង្ឃ, បទបញ្ញត្តិសម្រាប់ឧបោសថកម្ម, សម្រាប់ការចូលវស្សា, បទបញ្ញត្តិសម្រាប់ការប្រើទ្រនាប់ជើង, ថ្នាំកែរោគ, ចីវរ និងវិធីរំងាប់អធិករណ៍ និងការដឹកនាំនីតិវិធី ។

ជាទូទៅ វិនយប្បញ្ញត្តិ សំដៅគ្រប់គ្រងជីវភាពខាងក្រៅរបស់ភិក្ខុ ។ បើគ្មានការហ្វឹកហ្វឺនបែបនេះទេ, វាប្រាកដជាមិនអាចធ្វើអោយរីកចំរើនជីវភាពផ្ទៃក្នុងបានឡើយ ។ ផ្តាច់ខ្លួនចេញពីជីវភាពសង្គម និងពីជីវភាពគ្រួសារ, ភិក្ខុក្លាយទៅជា

មនុស្សសេរី, ជាបុត្ររបស់ព្រះពុទ្ធ រស់នៅដើម្បីគោលបំណងដ៏ឧត្តុង្គឧត្តម, ពោលគឺ បញ្ចប់នូវទុក្ខសោកទាំងពួង (ទុក្ខស្ស អន្តកិរិយាយ) ។ ភិក្ខុខាងថេរវាទ ជាពិសេស ត្រូវបានគេសង្ឃឹមទុកថា នឹងប្រតិបត្តិធម៌ដោយរស់នៅដាច់ពីគេពីឯងរហូតដល់សំរេចបាននូវការរំដោះ ។ តាមប្រភពដើម ភិក្ខុទាំងឡាយរស់នៅតែក្រោមដើមឈើទាំងឡាយទេ វៀរលែងតែក្នុងរដូវវស្សា, ប៉ុន្តែ ដោយមានការផ្ដល់អោយលំនៅឋាន ដែលហៅថាវិហារ, ផ្ដើមឡើងជាដំបូងដោយព្រះបាទពិម្ពិសារដោយព្រះអង្គបានថ្វាយវត្តវេឡុវនដល់ព្រះសម្មាសម្ពុទ្ធ, ភិក្ខុទាំងឡាយក៏អាចរស់នៅក្នុងវត្តអារាម ដោយគ្មានការលំបាកផ្ទាល់ខ្លួនបែបណាមួយឡើយ ។ បទបញ្ញត្តិយ៉ាងល្អិតល្អន់ ត្រូវបានកំណត់ឡើងសម្រាប់ការកសាង, ការថែរក្សា និងការបំពាក់សម្ភារៈដល់វិហារទាំងឡាយ ។

ស្ថាប័នមួយដូចជា គណៈភិក្ខុសង្ឃពុទ្ធសាសនិក មិនត្រូវបានគេស្គាល់ទេនៅក្នុងប្រទេសឥណ្ឌាមុនសម័យកាលនៃព្រះពុទ្ធគោតម ។ មានពួកតាបសជាបុគ្គលម្នាក់ៗ ឬពួកតាបសជាក្រុមៗ ប៉ុន្តែពុំមានជាគណៈចាត់តាំងទេ ។ ប្រហែលជាព្រះពុទ្ធអង្គឯងក៏ពុំមានព្រះបំណងគិតទុកមុន ដើម្បីស្ថាបនាគណៈសង្ឃ ដូចដែលបានស្ថាបនាឡើងនៅពេលខាងក្រោយមកដែរ ។ ប៉ុន្តែ នៅពេលដែលភាពចាំបាច់ដើម្បីអោយមានការចាត់តាំងមួយបែបនេះបានកើតឡើង, ព្រះអង្គក៏ទ្រង់យកព្រះទ័យគិតគូរស្ថាបនាគណៈសង្ឃនេះឡើង នៅលើគ្រឹះមួយដ៏រឹងមាំ ។ ហើយនៅពេលណាដែលគណៈសង្ឃត្រូវបានស្ថាបនាហើយនោះ ព្រះអង្គប្រាថ្នាអោយភិក្ខុរាល់រូបបានទៅជាតួអង្គគំរូមួយ, ត្រឹមត្រូវ ផូរផង់ទាំងខាងក្នុង ទាំងខាងក្រៅ ។ ក្រឹត្យវិន័យទាំងឡាយត្រូវបានបញ្ញត្តឡើង ជាសំខាន់នោះគឺសំដៅគ្រប់គ្រងជីវភាពខាងក្រៅរបស់ភិក្ខុ, ហើយនៅក្នុងរូបមន្តនៃក្រឹត្យវិន័យទាំងនោះ ព្រះពុទ្ធតែងយកព្រះទ័យទុកដាក់ជានិច្ចថា ភិក្ខុទាំងឡាយមិនត្រូវទើសទាល់ ឬចង្អៀតចង្អល់ដ៏ឥតចាំបាច់

ដោយសារការកាន់ក្រឹត្យវិន័យទាំងនោះទេ ។ ភិក្ខុទាំងឡាយ អាចទទួលបាននូវតម្រូវការជាមូលដ្ឋានទាំងឡាយរបស់ខ្លួននៅក្នុងការរស់នៅ ដោយគ្មានក្រឹត្យវិន័យទាំងនេះ ។ ការបង្អិតបង្អំផ្សេងៗលើអាហារភោជន, លើសំលៀកបំពាក់, លើជម្រកអាស្រ័យ, ទំនាក់ទំនងរបស់ភិក្ខុជាមួយមនុស្សឯទៀត, សេចក្ដីត្រូវការខាងរូបកាយ, . ល . ទាំងអស់សុទ្ធតែមានន័យសំដៅធ្វើអោយមានដំណើរជឿនលឿនខាងបញ្ញាស្មារតីរបស់ភិក្ខុ, ដែលជាគោលដៅនៃការចូលបួសក្នុងគណៈសង្ឃ ។ សូម្បីតែការប្រព្រឹត្តជាធម្មតាក្នុងការបិណ្ឌបាតចង្ហាន់ ក៏ត្រូវបានបន្ធូរបន្ថយ ដោយអនុញ្ញាតអោយទទួលការនិមន្តន៍អំពីគ្រហស្ថ ឬអោយទទួលយកអាហារដែលចែកអោយតាមសលាកប័ត្រ ។ នៅក្នុងរយៈពេលកន្លងទៅ មានការបន្ធូរបន្ថយវែងឆ្ងាយទៀត ហើយយើងបានដឹងបានឮអំពីការតម្កល់រក្សាទុកចំណីអាហារ (កប្បិយភូមិ) ដែលទៅឆ្ងាយហួសពីព្រំដែននៃវត្តអារាមទៅទៀត ។ នវកម្មទាំងអស់នេះក្លាយទៅជាការចាំបាច់ ពិព្រោះដោយសារមានយថាភាពដែលបានលេចឡើង ហើយការអនុញ្ញាតក៏ត្រូវផ្ដល់អោយ ប៉ុន្តែត្រូវឋិតនៅក្នុងព្រំដែនណាមួយ ។ ភិក្ខុក៏ត្រូវបានអនុញ្ញាត អោយទទួលអត្ថប្រយោជន៍យ៉ាងពេញលេញតាមវេជ្ជវិទ្យាសាស្ត្រ ប៉ុន្តែដោយមានការទូន្មានប្រឆាំងនឹងការរំលោភបំពាន ក្រោមលេសនៃជំងឺ ។ ការរំលោភបំពានលើការងាយស្រួលបែបនេះ ហាក់ដូចជាមានជាទូទៅ, ហើយភិក្ខុទាំងឡាយ ត្រូវបានក្រើនរំលឹកប្រឆាំងនឹងចរិយាបែបនេះ ។

នៅពេលដែលជីវភាពជាទូទៅរបស់ភិក្ខុ ត្រូវបានគ្រប់គ្រងដោយគោលការណ៍សីលធម៌ និងក្រឹត្យវិន័យរបស់ព្រះពុទ្ធ, វាកើតមានឱកាសដ៏សំខាន់ខ្លះៗ នៅក្នុងជីវភាពរបស់ភិក្ខុ ដែលទាមទារអោយមានការប្រតិបត្តិដ៏ពិសេស ។ គោលការណ៍ពីរដំបូងគេ គឺ *បព្វជ្ជា* និង *ឧបសម្បទា* ។ ការប្រជុំរបស់ភិក្ខុទាំងឡាយកន្លះខែម្ដង ដែលគេស្គាល់ថាធ្វើឧបោសថនោះ ក៏ជាឱកាសសំខាន់មួយទៀត ។ ការណ៍

នេះទាមទារអោយភិក្ខុទាំងអស់ដែលរស់នៅក្នុងព័ទ្ធសីមាជាមួយគ្នា ត្រូវមករួមប្រជុំ, ហើយសូម្បីភិក្ខុមានអាពាធ (ជំងឺ) ក៏ត្រូវតែអោយគេតំណាងខ្លួនដែរ ។ គោលបំណងដ៏ចម្បងនៃការប្រជុំ គឺការសូធ្យបាតិមោក្ខ ដែលនៅក្នុងអំឡុងនៃការសូធ្យនេះ ភិក្ខុមួយអង្គៗត្រូវទទួលសារភាពនូវការប្រព្រឹត្តខុសឆ្គងនៃក្រឹត្យវិន័យ ដែលបានកើតមានក្នុងអំឡុងពីរសប្តាហ៍កន្លងទៅ ។ ការដាក់ទណ្ឌកម្ម ត្រូវអោយមានសមាមាត្រទៅនឹងទម្ងន់នៃទោស ។ បាតិមោក្ខ មានសារសំខាន់ណាស់ក្នុងការរក្សាភិក្ខុទាំងឡាយអោយឋិតនៅក្នុងក្រឹត្យវិន័យល្អ ។ វាជួយបោសសំអាតផ្ទៃក្នុងសង្ឃ ដោយបណ្តេញចេញអ្នកប្រព្រឹត្តកំហុសធ្ងន់ធ្ងរ និងដោយផ្តល់ឱកាសអោយអ្នកមានកំហុសតូចតាច បានកែលំអខ្លួនឡើងវិញ ។ ចំពោះភិក្ខុក្រៅពីនេះ ការប្រជុំឧបោសថ គឺជាការរំលឹកជាប្រចាំអំពីការទទួលខុសត្រូវរបស់ខ្លួន ។ ឱកាសដ៏សំខាន់មួយទៀតនៅក្នុងជីវិតរបស់ភិក្ខុ គឺការចូលវស្សាក្នុងវស្សានរដូវ (វស្សាវាស) ។ នៅក្នុងរយៈពេលនេះ ភិក្ខុត្រូវបានគេរំពឹងថានឹងស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងវត្តអារាម ហើយពឹងផ្អែកលើការឧបត្ថម្ភរបស់ឧបាសក-ឧបាសិកាដែលនៅជុំវិញវត្តអារាម សម្រាប់ការរស់នៅរបស់ខ្លួន ។ នៅពេលបញ្ចប់ការកាន់វស្សា (បវារណា) ភិក្ខុទាំងឡាយតែងជួបប្រជុំគ្នា ហើយប្រកាសសារភាពទោសកំហុសរបស់ខ្លួន (សំដែងអាបត្តិ), ប្រសិនបើលោកទាំងឡាយនោះ បានប្រព្រឹត្តខុសឆ្គងត្រង់ប្រការណាមួយ ។

សេចក្តីរៀបរាប់ខាងដើម បង្ហាញថាភិក្ខុទាំងឡាយរួមទាំងបណ្តាសាមណេរផង កផ្តិកើតបានជាគណៈសង្ឃដែលព្រះពុទ្ធបានស្ថាបនាឡើង ។ ស្លៀកដណ្តប់សំពត់ពណ៌លឿង និងមានព្រះកេសកោរ ភិក្ខុ-សាមណេរទាំងឡាយរស់នៅក្នុងវត្តអារាមនានា ជាក្រុមៗ ឬជាបុគ្គលម្នាក់ឯង, ប្រតិបត្តិតាមព្រះធម៌ ហើយខ្មីឃ្មាតជានិច្ច ដើម្បីសំរេចគោលដៅរបស់ខ្លួន ។ នៅពេលជាមួយគ្នានេះ, ភិក្ខុ

សាមណេរទាំងឡាយ តែងប្រព្រឹត្តធ្វើខ្លួនជាមគ្គុទ្ទេសក៍ ឬជាអ្នកអោយដំបូន្មានដល់គ្រហស្ថ ហើយបង្រៀនគេអោយចិញ្ចឹមជីវិតប្រកបដោយគុណធម៌ ។ ភិក្ខុ សាម-ណេរទាំងនោះត្រូវតាំងខ្លួនជាគំរូក្នុងការរស់នៅទៅតាមមាគ៌ាចិញ្ចឹមជីវិតរបស់ព្រះពុទ្ធ ។ លោកទាំងឡាយនោះ មិនតាំងខ្លួនជាអន្តរការីរវាងអទិស្សមានានុភាពខ្លះ (some unseen power) និងមនុស្សលោកទេ, ហើយក៏មិនតាំងខ្លួនជាអ្នកមានអានុភាពអាថ៌កំបាំងដែរ, ដោយសារអានុភាពនេះ លោកអាចកែប្រែព្រេងវាសនារបស់មនុស្សណាមួយបាន ។ ដោយបានបោះបង់ចោលរាល់ការជាប់ជំពាក់ចិត្តចំពោះអារម្មណ៍ស្រើបស្រាលទាំងឡាយ, លោកទាំងឡាយនោះ បានដឹកនាំជីវិតរបស់លោកតាមមាគ៌ាចិញ្ចឹមជីវិតរបស់ព្រះពុទ្ធ, ជាជីវិតដ៏បរិសុទ្ធ (ព្រហ្មចរិយ-ធម៌) ។ តាមរយៈភាពបរិសុទ្ធខាងចរិយា (សីល), លោកចាប់យកបាននូវភាពសុខស្ងប់នៃចិត្ត (សមាធិ) ដែលបន្តវេននាំទៅរកគតិបណ្ឌិត (បញ្ញា), កើតចេញពីផលគឺការបំពេញនូវសំណូមពរស្វែងរករបស់លោក ក្នុងការចាប់យកនូវការផុតរំលត់ទុក្ខ (វិមុត្តិ) ។ មាគ៌ាចិញ្ចឹមជីវិតរបស់ភិក្ខុ អាចជាមាគ៌ាតាបស, ប៉ុន្តែតាបសនិយមនេះត្រូវតែជាស្វ័យវិន័យ, មិនមែនជាអត្តកិលមថានុយោគ (self-mortification) ទេ ។ ហេតុការណ៍ដែលថាសូម្បីតែទំហំ និងសម្ភារៈនៃកុដិ ឬអាស្រម, ស្បង់ចីពរ, បាត្រ, គ្រែ, កម្រាលគ្រែ និងព្រំ សុទ្ធតែត្រូវបានកំណត់ច្បាស់លាស់, នេះបង្ហាញ អោយឃើញនូវកំរិតដែលភិក្ខុគប្បីទទួលយកបាននូវផាសុកភាពខាងសម្ភារៈ ។ សូម្បីតែសំណើង (ដំណេក) របស់ភិក្ខុ ក៏ត្រូវបានកំណត់ព្រំដែនដែរ ។ លោកចាប់ផ្ដើមទិវារបស់លោក ដោយដំបូងត្រូវបំពេញករណីយកិច្ចពេលព្រឹក (ថ្វាយបង្គំព្រះ, សូធ្យធម៌, បោសសំអាតវត្តអារាម ... ), ហើយបន្ទាប់មក ចេញទៅបិណ្ឌបាតចង្ហាន់ ដែលលោកត្រូវឆាន់មុនថ្ងៃត្រង់ ។

នេះគឺជាអាហារតែមួយពេលរបស់លោកប្រចាំថ្ងៃ ។ តាមមធ្យោបាយ

បែបណា ដែលភិក្ខុរកបាននូវអាហាររបស់លោក, ទោះជាតាមការសុំបិណ្ឌបាត ឬតាមការនិមន្តន៍ទៅកាន់ផ្ទះរបស់គ្រហស្ថ, លោកត្រូវតែគាប់ព្រះទ័យជាមួយអ្វីដែលគេបានប្រគេន ។ បើគ្មានហេតុផលពិតប្រាកដទេ, ភិក្ខុមិនត្រូវស្នាក់នៅក្នុងចំណោមមនុស្សជាគ្រហស្ថទេ ។ ក្រោយពេលឆាន់ចង្ហាន់រួច ឬក្នុងពេលរាត្រី,ករណីយកិច្ចរបស់ភិក្ខុ គឺត្រូវរៀនធម៌ និងត្រូវហ្វឹកហ្វឺនខាងផ្លូវស្មារតី (ចិត្ត) សម្រាប់ខ្លួន ។ លោកត្រូវធ្វើខ្លួនអោយបានជាប្រយោជន៍ដល់ជនជាគ្រហស្ថ កាលណាគ្រហស្ថស្នើសុំយោបល់ ឬត្រូវការដំបូន្មានរបស់លោក ។

យើងបានពន្យល់នៅខាងដើមរួចហើយថា ស័ព្ទ «ភិក្ខុ» មានន័យដោយត្រង់ថា អ្នកដែលសុំទានពីមនុស្សឯទៀត ឬពឹងផ្អែកលើអ្នកឯទៀត សម្រាប់សេចក្តីត្រូវការដ៏សាមញ្ញ ដើម្បីចិញ្ចឹមជីវិតរបស់លោក, ហើយថាស័ព្ទនេះ បានប្រើនៅក្នុងអក្សរសាស្ត្រពុទ្ធសាសនា សំដៅសំគាល់សាវ័កដ៏ពិតប្រាកដរបស់ព្រះពុទ្ធដែលហៅថា *អរិយសាវ័ក* ។ យើងគួររំលឹកក្នុងទីនេះថា គឺស័ព្ទ «ភិក្ខុ» នេះហើយដែលព្រះពុទ្ធបានប្រើដើម្បីមានបន្ទូលទៅកាន់ព្រះអរហន្តដំបូងគេ នៅពេលព្រះអង្គទ្រង់ត្រាស់បញ្ជាអោយព្រះអរហន្តទាំងឡាយនោះ និមន្តទៅផ្សព្វផ្សាយព្រះធម៌ (ចរថ ភិក្ខវេ) ។

មាននិយមន័យច្រើន ត្រូវបានគេផ្តល់អោយនៅក្នុងអក្សរសាស្ត្រអធិប្បាយអំពីស័ព្ទ *«ភិក្ខុ»*, និយមន័យខ្លះ ក្នុងចំណោមនិយមន័យទាំងនោះ គឺជានិយមន័យឡែបខាយពេកណាស់ ។ ជាឧទាហរណ៍, មាននិយមន័យមួយមានន័យទូលំទូលាយល្អណាស់អំពីស័ព្ទ *ភិក្ខុ* នៅក្នុង *អដ្ឋកថាវិភង្គ* ដែលនៅក្នុងនោះ គេបានផ្តល់ការកត់សំគាល់ផ្សេងៗអំពីស័ព្ទនេះ តាំងពីន័យសាមញ្ញបំផុតរហូតដល់ន័យពិសេសបំផុត ។ គេឃើញមាននិយមន័យមិនតិចជាង ១៧ និយមន័យឡើយ, ដែលរៀបរាប់ការប្រើប្រាស់ពាក្យ «ភិក្ខុ» អំពីជ្រុងជ្រោយទាំងអស់ ។ និយមន័យពីរ

ដំបូង បង្ហាញនូវការប្រើដ៏សាមញ្ញបំផុតនៃស័ព្ទ តាមដូចដែលគេធ្លាប់យល់ជាទូទៅ (សាមញ្ញាយ), ពោលគឺ អ្នកដែលប្រជាជនអោយឈ្មោះថា ភិក្ខុ ឬអ្នកដែលហៅខ្លួនឯងថា ភិក្ខុ (បដិញ្ញាយ) ។ បន្ទាប់មក មានការលេងពីដើមកំណើតពាក្យផ្សេងៗ ។ ដោយហេតុនេះ ភិក្ខុត្រូវបានគេហៅដូច្នេះ ពីព្រោះលោកដើរសុំអាហារ (ភិក្ខតី'តិ ភិក្ខុ) ។ និយមន័យបន្ទាប់មក ពង្រីកលើប្រធានបទដដែល ហើយបង្ហាញអោយឃើញជាពាក្យពណ៌នាទូលំទូលាយអំពីការប្រព្រឹត្តដើរសុំអាហារ ជាការប្រព្រឹត្តធ្វើខ្លួនជាភិក្ខុ ។ ទោះបីជាភិក្ខុដើរសុំអាហារសំរាប់រស់ ពិព្រោះនេះជាការប្រព្រឹត្តរបស់ព្រះពុទ្ធទាំងឡាយពីមុន ឬពីព្រោះនេះជាសញ្ញានៃភាពជាភិក្ខុ ឬក៏ពីព្រោះភិក្ខុជាអ្នកពឹងផ្អែកលើអ្នកដទៃដើម្បីចិញ្ចឹមជីវិតរបស់ខ្លួន ឬក៏ពីព្រោះលោកប្រព្រឹត្តជាភិក្ខុភាវៈដើម្បីជាគុណប្រយោជន៍នៃដុំបាយ (អាហារ) ដែលលោកបានទទួលដោយសារការប្រព្រឹត្តនេះ, ទោះជាអ្វីក៏ដោយ ហេតុផលគឺថា លោកត្រូវបានគេហៅថា *ភិក្ខុ* ពីព្រោះលោកបានប្រកាន់យកនូវការប្រព្រឹត្តនេះ ។ តមក ក៏មានការពន្យល់កាន់តែទ្បែបខាយពាក្យសំដីឡើង ទៅតាមអ្វីដែលគេបានក្លាយទៅជាភិក្ខុ ពីព្រោះគេស្លៀកពាក់សំពត់បំណាស់, *(ភិន្នបដធរោ'តិ ភិក្ខុ)* ។ សេចក្ដីរៀបរាប់ដ៏វែង ត្រូវបានធ្វើឡើងអំពីអ្វីដែលគេហៅថា សំពត់បំណាស់នោះ ។ និយមន័យបន្ទាប់ទៀត មានអត្ថន័យជាទ្រឹស្ដី ។ ភិក្ខុ គឺជាបុគ្គលដែលបានកាត់ផ្ដាច់និន្នាការអកុសលរបស់គេទាំងអស់ *(ភិន្ទតិ បាបកេ អកុសលេ ធម្មេ'តិ ភិក្ខុ)* ។ និយមន័យនេះ និយាយយោងដល់ព្រះអរិយពុទ្ធសាសនិកជន ដែលបានរីកចំរើនក្នុងដំណាក់ទាំងឡាយ រហូតបានដល់ភាពជាព្រះអរហន្ត ។ ក្នុងដំណាក់និមួយៗ នៃដំណាក់ទាំងបួនរបស់អរិយបុគ្គល, ចាប់ផ្ដើមតាំងពីសោតាបត្តិទៅ, អរិយបុគ្គលបោះបង់ចោលនូវអំពើសៅហ្មងបែបណាមួយ រហូតដល់លោកមានភាពបរិសុទ្ធទាំងស្រុង នៅក្នុងដំណាក់ចុងក្រោយបង្អស់នៃអរហត្តផល ។ នេះគឺជាគំរូនៃការប្រើស័ព្ទ ភិក្ខុ ដើម្បីសំគាល់សាវ័ករបស់

ព្រះពុទ្ធនៅក្នុងដំណាក់កាលណាមួយនៃអរិយភាព តាំងពីភាវៈជាភិក្ខុធម្មតា រហូតដល់ភាវៈជាព្រះអរហន្ត ។ និយមន័យពីរបន្ទាប់មកទៀត ក៏ទាក់ទងនឹងប្រធានបទដដែលនៃការបំផ្លាញអំពើសៅហ្មងទាំងឡាយ អំពីជ្រុងមួយផ្សេងទៀតដែរ ។ និយមន័យពីរខាងក្រោយ ធ្វើអោយឃើញផ្សេងពីគ្នារវាងព្រះអរហន្ត និងអ្នកមិនមែនព្រះអរហន្ត (សេក្ខ និងអសេក្ខ), ហើយប្រើស័ព្ទ ភិក្ខុ សំគាល់បុគ្គលទាំងពីរពួក ។ អ្នកទាំងឡាយណា ដែលមិនចាត់ចូលក្នុងផ្នែកណាមួយនៃបណ្ដាផ្នែកទាំងនេះ, ហើយដែលមិនបានព្យាយាមដាក់កំហិតវិន័យខ្លួនឯងសោះទេ ដោយគ្រាន់តែរស់នៅក្នុងជីវភាពកិរិតខ្ពង់ខ្ពស់ (ព្រហ្មចរិយ), អ្នកទាំងឡាយនោះ ត្រូវបានចាត់ទុកជាភិក្ខុប្រភេទធម្មតា (បុថុជ្ជនភិក្ខុ) ។ ភិក្ខុមួយរូប ត្រូវបានគេហៅថា *អគ្គៈ*, ពីព្រោះលោកបានសំរេចជោគជ័យទាំងស្រុង ដែលទាក់ទងនឹង *សីល សមាធិ បញ្ញា* និង *វិមុត្តិ* ។ លោកជាភទ្របុគ្គល, ពីព្រោះលោកបានរំដោះខ្លួនអោយផុតពីទំនោរទៅរកអំពើអាក្រក់ទាំងអស់ដែលចងភ្ជាក់ខ្លួនលោក ។ លោកជាមណ្ឌៈ (ប្រសើរ), ជាបសន្នៈ (សុខស្ងប់) និងជាអនាវិលបុគ្គល (បុគ្គលឥតមានកំហុស) ។

ហេតុការណ៍មួយ ដែលលេចចេញច្បាស់ពីនិយមន័យទាំងឡាយខាងលើនោះ គឺថា ការប្រើស័ព្ទ ភិក្ខុ ត្រូវបានគេយកទៅប្រើយ៉ាងទូលំទូលាយ ។ ដំបូងបំផុត, បុគ្គលណាមួយដែលបានបំពេញល័ក្ខខ័ណ្ឌចាំបាច់ទាំងឡាយ បានក្លាយទៅជាភិក្ខុ ។ ប៉ុន្តែ ដូចជាបានសង្ខេបនៅខាងចុងនៃអត្ថបទខាងលើ ក្នុងអដ្ឋកថាវិភង្គៈ, ស័ព្ទ ភិក្ខុ ត្រូវបានប្រើដ៏ទូលំទូលាយនៅក្នុងការផ្ដល់ទស្សនទ្រឹស្ដី ។ គេអាចប្រើស័ព្ទនេះ ដើម្បីកត់សម្គាល់អរិយបុគ្គលណាមួយ ក្នុងបណ្ដាអរិយបុគ្គលទាំងប្រាំពីរ (សត្តសេក្ខា) ដែលបានសំរេចមគ្គៈបីដំបូង និងបានសំរេចផលនៃមគ្គទាំងបីនេះ (ពោលគឺ សោតាបត្តិមគ្គ និង សោតាបត្តិផល, សកទាគាមិមគ្គ និង សកទាគាមិ-ផល, អនាគាមិមគ្គ និង អនាគាមិផល) ព្រមទាំងបានសំរេចមគ្គៈនៃព្រះអរហន្ត តែ

ប៉ុណ្ណោះ (អរហត្តមគ្គៈ) ។ ប៉ុន្តែ, បន្ទាប់មកក៏មានការសំដែងថា អ្នកទាំងឡាយដែលបានសំរេចផលនៃដំណាក់ចុងក្រោយរួចហើយ (អរហត្តផល), ហើយដោយហេតុនេះ លោកបានជាព្រះអរហន្តបរិបូររួចហើយ, ក៏គេនៅតែប្រើពាក្យ *ភិក្ខុ* នេះ ដើម្បីហៅលោកដែរ ។

មាននិយមន័យ *ភិក្ខុ* ច្រើនផ្សេងទៀតនៅក្នុងមហានិទ្ទេស ។ និយម.ន័យទាំងនោះ ស្ទើរតែទាក់ទងនឹងចរិយាធម៌ និងទ្រឹស្តីទាំងស្រុង ។ អ្នកដែលគេហៅថា សន្តបុគ្គល ពីព្រោះគេបានបន្សាត់បង់នូវទំនោរចិត្តអកុសលរបស់គេ ។ សភាវៈអកុសលនៃចិត្តបែបនេះ ត្រូវបានរៀបរាប់នៅក្នុងបញ្ជីមួយយ៉ាងវែង ។ ភិក្ខុដ៏ពិត បានឈ្មោះមិនមែនតែសភាវៈអកុសលនៃចិត្តទាំងអស់នេះប៉ុណ្ណោះទេ, ប៉ុន្តែលោកបានឈ្មោះសភាវៈសៅហ្មង និងក្តៅក្រហាយទាំងអស់ (កិលេស និងសន្តាបៈ) ។ យោងតាមនិយមន័យខាងក្រោយនេះ, ភិក្ខុ ត្រូវបានគេហៅថាដូច្នេះពីព្រោះលោកបានកាច់បំបាក់ធម្មជាតិទាំងប្រាំពីរយ៉ាង ដែលចាត់ទុកជាច្រវាក់ខ្នោះឃ្នាង (សំយោជនៈ) ។ ដោយលោកបានបំបាក់ច្រវាក់ ខ្នោះឃ្នាងទាំងនោះ លោកគឺជាព្រះអរហន្ត, លោកជាអ្នករលត់ទាំងស្រុងហើយ (អភិនិព្វុតៈ) ។ ភិក្ខុដ៏ពិត មិនមែនជាមនុស្សអួតអាងសោះឡើយ (អកថី), លោកក៏ពុំមែនជាអ្នកបង្អួតសោះដែរ (វិកថី) ។ អត្ថបទបានរៀបរាប់បញ្ជីវត្ថុយ៉ាងវែង ដែលភិក្ខុបោកប្រាសផ្តាច់បានអួតអាង ។

គ្រប់គ្រងបាននូវអង្គវិញ្ញាណទាំងឡាយ គឺជាការងារមូលដ្ឋានមួយនៃចរិតល្អ, ហើយនេះគឺជាផែនគ្រឹះ ដែលនៅលើផែនគ្រឹះនេះ ការហ្វឹកហាត់ចិត្តរបស់ភិក្ខុដ៏ពិតត្រូវពឹងផ្អែក ។ ក្នុងការពិពណ៌នានូវទិដ្ឋភាពនេះនៃជីវភាពរបស់ភិក្ខុ មហា.និទ្ទេសបានកំណត់និយមន័យនៃភិក្ខុថា ជាបុគ្គលរស់នៅដោយមានវិញ្ញាណទាំងឡាយគ្រប់គ្រង, ហើយវិសេសស័ព្ទ «បដិលីនចរ» ត្រូវបានគេយកមកប្រើ ដើម្បី

សំគាល់ន័យនេះ ។ ចំណែកព្រះអរហន្តវិញ ត្រូវបានគេពិពណ៌នាថា ជាបុគ្គលដែលបានគ្រប់គ្រងល្អហើយ នូវវិញ្ញាណទាំងឡាយរបស់លោក (បរិលីនៈ) ។ បុគ្គលណាមានចិត្តរបស់គេឋិតនៅក្រោមការគ្រប់គ្រងល្អ, បុគ្គលនោះ នឹងមានវិញ្ញាណទាំងឡាយដទៃទៀតរបស់គេ ងាយស្រួលគ្រប់គ្រង ។ ដោយហេតុនេះ សាវ័កដ៏ពេញទោះឋិតនៅក្នុងការងារអ្វីក៏ដោយ នឹងមិនអនុញ្ញាតអោយចិត្តរបស់លោកជាប់ជំពាក់លើវត្ថុមិនសមគ្រប់ទាំងឡាយឡើយ, លោកតែងរក្សាចិត្តរបស់លោក មិនអោយសាត់ព្រាត់ឡើយ (តតោ តតោ ចិត្តំ បរិលីយន្តិ តេន ការណេន បរិលីនចរា វុច្ចន្តិ តត្តសេក្ខា) ។ ទោះបីឋិតនៅក្នុងឋានៈណាក៏ដោយ លោកតែងរក្សាជានិច្ចនូវចិត្តរបស់លោក ប្រឆាំងនឹងចំនោរទៅរកអំពើអាក្រក់ហើយ, ដោះដៃអោយផុតពីធម្មជាតិសៅហ្មងរបស់លោកទាំងអស់ (កិលេស), លោកក្លាយទៅជាភិក្ខុក្នុងន័យពិតរបស់វា (សព្វតោ ភិន្ន-កិលេសត្តា បរតត្ថតោ ភិក្ខុ នាម) ។ ដូច្នេះ ភិក្ខុសង្ឃមានក្រុមបុគ្គលដ៏ប្រសើរប្រាំបី ប្រកបដោយទស្សនៈ, សីលធម៌ត្រឹមត្រូវ និងមានគុណសម្បត្តិផ្សេងទៀតខាងចរិយា និងចិត្ត (ភិក្ខុសង្ឃន្តិ ទិដ្ឋិ សីល សាមញ្ញេន សង្ហតំ អដ្ឋអរិយបុគ្គលសមូហំ) ។ ចិត្តរបស់ភិក្ខុដ៏ពិត រមែងស្ងប់ជានិច្ច ហើយមិនរំភើបញាប់ញ័រឡើយ ។ តម្រិះរបស់លោកច្បាស់លាស់គ្មានសៅហ្មង (អនាវិល - សង្កប្បៈ) ។ គ្មានគំនិតអកុសលណាមួយចូលក្នុងចិត្តរបស់លោកបានទេ (កិលេស - កាលុស្សិយាភាវ) ។

គំនិតទាំងមូលអំពីភិក្ខុពុទ្ធសាសនិក ទាំងទិដ្ឋភាពខាងផ្លូវសីលធម៌ ទាំងទិដ្ឋភាពខាងផ្លូវចិត្ត ត្រូវបានគេសង្ខេបយ៉ាងខ្លីនៅក្នុង *ភិក្ខុវគ្គ* នៃ *គម្ពីរធម្មបទ* ។ ខ្លឹមសារនៃអត្ថបទនោះ គឺសង្កត់លើស្វ័យវិន័យ, បើគ្មាននេះទេ នោះវឌ្ឍនភាព និងវិមុត្តិ មិនអាចកើតមានទេ ។ ភិក្ខុដ៏ពិត ត្រូវរក្សាទ្វារនៃវិញ្ញាណរបស់ខ្លួនអោយល្អជានិច្ច, គឺភិក្ខុនេះហើយដែលទទួលជោគជ័យរំដោះផុតពីទុក្ខទាំងពួង (សព្វត្ថសំវុតោ

ភិក្ខុ សព្វទុក្ខា បមុញ្ចតិ) ។ លោកតែងត្រេកអរក្នុងការប្រឹកឃាត់ចិត្តរបស់លោក ជានិច្ច ។ ចេះដឹងព្រះធម៌ច្បាស់លាស់, លោកតែងពោលតែពាក្យពិរោះ និងប្រកប ដោយគតិបណ្ឌិតជានិច្ច ។ សេចក្តីសប្បាយរបស់លោក គឺធម៌, លោករកឃើញ សេចក្តីរីករាយក្នុងធម៌, អារម្មណ៍របស់លោកថិតនៅក្នុងធម៌, ដោយហេតុនេះ លោកមិនដែលឃ្លាតឆ្ងាយពីធម៌ឡើយ ។ ដោយលោករស់នៅក្នុងភាពរីករាយ ទាំងស្រុង ហើយមិនឈ្នានីសអ្នកដទៃ និងក្នុងភាពបរិសុទ្ធដ៏សុក្រិត, លោក សូម្បី តែទេព្តាក៏សរសើរដែរ ។ ដោយបានយល់ច្បាស់ថា ជីវិតគឺជាការផ្សុំផ្គុំនៃខន្ធទាំង ឡាយ, លោកបានលះបង់នូវគំនិតអំពីអាត្មា (អត្តៈ) ហើយនៅពេលដែលជីវិតនេះ ត្រូវបែកធ្លាយ, លោកក៏មិនសោកសៅ ។ គឺមានតែបុគ្គលបែបនេះទេ ទើបអាច ឈានដល់ស្ថានភាពរីករាយ ដែលជាស្ថានភាពអចិន្ត្រៃយ៍ ។ រូបកាយមនុស្ស ប្រៀប ដូចជាទូកមួយផ្ទុកពេញដោយទឹកនៃជំនឿខុស និងសភាវៈសៅហ្មង (កិលេស), ហើយភិក្ខុ ត្រូវបានគេសុំអោយស្តារទូកនោះឡើង ដើម្បីអោយទូកអាចធ្វើដំណើរ ទៅយ៉ាងស្រាល ឆ្ពោះទៅកាន់*និព្វាន* ។ តាមទស្សនៈមួយផ្សេងទៀត, លោកត្រូវ បានគេសុំអោយត្រាច់ទៅតាមមាគ៌ានៃព្រះអរហន្ត ដោយត្រូវកាត់ផ្តាច់នូវចំណង ដប់យ៉ាង (សំយោជនៈ) ហើយពង្រីកសទ្ធា, ភាវៈជាមនុស្ស, សីល, សមាធិ និង បញ្ញា ។ ភិក្ខុដែលធ្វេសប្រហែសចំពោះករណីយកិច្ចរបស់ខ្លួន ត្រូវប្រឈមមុខ ចំពោះទុក្ខ ។ មិនធ្វើសមាធិ, ភិក្ខុមិនអាចទទួលបានបញ្ញាទេ (បញ្ញា នត្ថិ អឈាយ-តោ) ។ ភិក្ខុដែលផ្ចង់អារម្មណ៍ក្នុងខ្លួន និងដោយមានឋាមថ៌ាមនឹងន ហើយប្រមើល មើលខ្លួនឯងដោយអជ្ឈត្តិកញ្ញាណ ត្រូវបានគេចាត់ទុកជាអ្នកសោយបីតិប្រាមោទ្យ នៃអច្ឆរិយមនុស្ស ដោយសារលទ្ធផលនៃការយល់ដឹង ។ ដំបូន្មានផ្តល់អោយចំពោះ ភិក្ខុទាំងឡាយនោះ ដែលមានបញ្ញាខ្សោយ ហើយឃើញដំបូន្មាននោះពិបាកប្រតិបត្តិ តាមព្រះធម៌នោះគឺ ភិក្ខុតាំងសេចក្តីព្យាយាម ហើយពិនិត្យខ្លួនឯង រួចចាត់វិធានការ

កែលំអ សម្រាប់ការខ្វះខាតរបស់ខ្លួន ។

ក្នុងការពន្យល់ថា តើមនុស្សបែបណាជាមនុស្សមានសីល, ព្រះពុទ្ធឃោ-សាចារ្យ, នៅខាងដើមសៀវភៅវិសុទ្ធិមគ្គរបស់លោក, ប្រដូចមនុស្សបែបនោះ ជាមួយនឹងភិក្ខុដ៏ពិត ។ មនុស្សមានសីល គឺជាបុគ្គលដែលក្រោយពីបានតាំងខ្លួននៅក្នុងគុណធម៌រួចហើយ, តែងពង្រីកបញ្ញា និងញាណរបស់លោកដោយសេចក្ដីស្ទិតស្វាញ និងដោយសុខុមញ្ញាណ (អាតាបី និបកោ ភិក្ខុ) ។ នេះគឺជាភិក្ខុដ៏ពិតដែលព្យាយាមស្ទិតស្វាញ ដើម្បីបញ្ចប់ទុក្ខ ។ នៅក្នុងបរិបទដោយឡែកនេះ វាហាក់ដូចជាពុំគួរគប្បីលើកយកព្រះពុទ្ធឃោសាចារ្យចេញពីបរិបទ ហើយនិយាយថាលោកពន្យល់ស័ព្ទ *ភិក្ខុ* ដោយគ្រាន់តែទុកដូចជាបុគ្គលដែលឃើញភ័យនៅក្នុងសង្សារ (សំសារេ ភយំ ឥក្ខតីតិ ភិក្ខុ) ។ តាមឫសនៃស័ព្ទ ក៏ដូចជាតាមស្វរស័ទ្ទវិទ្យា, វាហាក់ដូចជាមិនត្រឹមត្រូវទេ, ប៉ុន្តែ តាមទស្សនៈស្ដីពីការប្រែប្រួលរីកចំរើននៃន័យរបស់ស័ព្ទថា តើអ្នកណាទៅវិញជាភិក្ខុនោះ បើមិនមែនបុគ្គលដែលឃើញភ័យក្នុងសង្សារ ហើយខិតខំឆ្លងអោយផុតពីសង្សារនេះ ? វាអាចជាថា ព្រះពុទ្ធឃោសា-ចារ្យ បានភ្លេចន័យដើមនៃ «សូម» (begging) ដែលភ្ជាប់ជាមួយនឹងពាក្យ, ហើយលោកចង់ឃើញន័យជ្រៅជាងនៅក្នុងពាក្យនោះ ។

នៅក្នុងបិដក, ឃ្លាដែលពិពណ៌នាពីការ «ត្រាច់រង្គាត់» របស់ភិក្ខុអាចត្រូវបានបកស្រាយថា «បានត្រាច់ចរទៅមុខ ចេញពីផ្ទះទៅកាន់ភាពគ្មានផ្ទះ» (អគារស្មា អនាគារិយំ បព្វជិតា) ។ ក្រោយពេលបានឆ្លងកាត់ការបួសថ្នាក់ទាប និងថ្នាក់ខ្ពស់រួចហើយ, ក្រោយពីបានបំពេញល័ក្ខខ័ណ្ឌផ្សេងៗចាំបាច់ សម្រាប់ដំណាក់នីមួយៗ ក្រោមក្រឹត្យវិន័យរបស់បាតិមោក្ខរួចហើយ (បាតិមោក្ខសំវរសំវុតោ), គេក្លាយជានវភិក្ខុមួយរូប ហើយឋិតនៅយ៉ាងនេះអស់ពេលប្រាំឆ្នាំ ក្រោយបានឧបសម្បទា ; ចាប់ពីប្រាំទៅដប់ឆ្នាំ លោកបានជាមជ្ឈិមភិក្ខុ, រួចចាប់ពីដប់ឆ្នាំឡើង

ទៅ, លោកបានជាថេរភិក្ខុ, នេះប្រសិនណាលោកចេះតែមានសេចក្ដីរីកចំរើនឆ្ពោះទៅរកគោលដៅរបស់លោក ។

ការបន្តពាសនារបស់ព្រះពុទ្ធ ពឹងផ្អែកជាសំខាន់ទៅលើកិច្ចការដែលព្រះអង្គបានតាំងតាំងគណៈសង្ឃ ដែលគោលបំណងរបស់លោក គឺបញ្ចប់នូវទុក្ខ ។ វាគ្មានការចាំបាច់អ្វីសម្រាប់ភិក្ខុមួយរូប ដើម្បីខិតខំយ៉ាងខ្លាំងសម្រេចគោលដៅដែលមិនសមស្របនោះទេ ។ ការរំដោះនៃហាឫទ័យ និងស្មារតី ហើយនិងការសន្សំនៃសេចក្ដីស្រឡាញ់ និងវិជ្ជា ត្រូវតែជាគោលដៅរបស់ភិក្ខុនោះ ។ ការដឹកនាំជីវិតរបស់ភិក្ខុដ៏ពិតមួយអង្គ ពុំមែនជាការងាយស្រួលទេ ។ វាពុំមែនជាតបនិយមសុទ្ធសាធ (mere ascetism) ដែលតាមការប្រៀបធៀបមានភាពងាយស្រួល បើផ្ទួរផ្ទឹមទៅនឹងធម្មជាតិពិតនៃសមិទ្ធផលជាវិជ្ជមាន ដែលគេសង្ឃឹមទទួលបានពីភិក្ខុពុទ្ធ-សាសនិកមួយអង្គ ។ មនុស្សដែលប្រព្រឹត្តតាមបែបតាបសសុទ្ធសាធ ត្រូវបានប្រជាជនគាប់ញ្ញតាត់ទុកដូចជាអ្នកមានសីល ។ នេះហើយជាហេតុនាំអោយទេវទត្ត និងអ្នកដទៃទៀត ស្នើសុំអោយព្រះពុទ្ធបង្កើនភាពម៉ឺងម៉ាត់នៃវិន័យរបស់ព្រះអង្គ ។ ព្រះពុទ្ធមិនគ្រាន់តែបដិសេធសំណូមពរប៉ុណ្ណោះទេ ប៉ុន្តែប្រកែកមិនព្រមចាត់ទុកការប្រព្រឹត្តជាតាបស ដែលគេហៅថា ធុតង្គនោះ ថាជាកាតព្វកិច្ចទៀតផង ។ ការចាត់ចោលតបនិយមខុសឆ្គង (សីលព្វតបរាមាស) ដែលជាសំយោជនៈមួយ គឺជាល័ក្ខខ័ណ្ឌចាំបាច់ដំបូងមួយរបស់ភិក្ខុ ។ ព្រះពុទ្ធពុំដែលមានព្រះទ័យចង់អោយភិក្ខុទាំងឡាយរបស់ព្រះអង្គ ប្រព្រឹត្តតាមតបនិយមឥតន័យម្ដងណាឡើយ ។ មិនដូចពួកជេន និងពួកកាន់សាសនាដទៃទៀត ដែលត្រាច់ទៅស្រាតឥតស្លៀកដណ្ដប់សោះនោះទេ, ព្រះអង្គប្រាថ្នាអោយភិក្ខុរបស់ព្រះអង្គស្លៀកដណ្ដប់ជិតរាងកាយ និងប្រកបដោយបរិមណ្ឌល ។ ភិក្ខុទាំងឡាយនោះ ត្រូវប្រើបាត្រដ៏ធម្មតាមួយ ដើម្បីសុំអាហារ ដោយមិនទទួលអាហារផ្ទាល់នឹងដៃខ្លួនឡើយ ។ សូម្បីតែពណ៌នៃសម្ពត់

ដែលបោកផាតយើររបួត (កាតការះ) ក៏មិនត្រូវអោយមានពណ៌ផេតសម្រាប់លំររ នោះឡើយ ។ ព្រាហ្មណ៍ប្រតិបត្តិតាមវេទ ស្វែងរកការរំដោះតាមរយៈការធ្វើពិធីបូជា (យោគៈ), តាបសពុំមែនជាពុទ្ធសាសនិក ស្វែងរកការរំដោះតាមរយៈការធ្វើតបនិយម ប៉ុន្តែព្រះពុទ្ធ និងសាវ័កទាំងឡាយរបស់ព្រះអង្គ ស្វែងរកការរំដោះតាមរយៈវិជ្ជា, ការសំរេចបាននូវវិជ្ជា គឺជាគោលដៅរបស់ភិក្ខុ ។ ភិក្ខុសង្ឃ គឺជាក្រុមបុរសអ្នកកាន់សាសនា ដែលជឿថាជីវភាពដ៏ខ្ពង់ខ្ពស់ មិនអាចបិតនៅក្នុងកណ្ដាប់ដៃពួកអ្នកគ្រប់គ្រងផ្ទះ (គ្រហស្ថ) ទេ, ហើយដោយហេតុនេះ ត្រូវផ្សំគ្នាបង្កើតទៅជាគណៈមួយ «ដែលនៅក្នុងគណៈនេះ ភិក្ខុទាំងឡាយបានធូរស្បើយពីកង្វល់រកអាហារ និងសម្លៀកបំពាក់, អាចមិននឹកនាដល់ថ្ងៃស្អែក និងកិច្ចការលោកិយដទៃទៀត ... ។ ភិក្ខុទាំងឡាយ ពុំមែនជាអង្គការរបស់អ្នកបួសព្រាហ្មណ៍ ឬគ្រីស្ដ (priests) ទេ, ហើយពុំមានគោលបំណងនយោបាយដែរ ។ មនុស្សសេរីណាក៏ដោយ, វៀរលែងតែឪពុកម្ដាយ ឬរដ្ឋ ទាមទារលើរូបគេ និងវៀរលែងតែមនុស្សនោះកើតមានជំងឺខ្លះចេញ, អាចអនុញ្ញាតអោយបួស និងចូលរួមក្នុងគណៈសង្ឃបាន» ។ អ្នកណាក៏ដោយ ដែលមិនសប្បាយនៅក្នុងផ្នួសទេ, អាចត្រឡប់ទៅកាន់ជីវភាពជាគ្រហស្ថវិញបានដោយសេរី នៅពេលណាក៏បាន ។

ចិដ្ឋភាពដ៏សំខាន់មួយទៀត ទាក់ទងនឹងភិក្ខុសង្ឃនោះគឺ ការអនុញ្ញាតអោយចូលរួមក្នុងសង្ឃ មិនត្រូវបានហាមឃាត់ដោយសារបាំងវណ្ណៈឡើយ ។ ចំណែកឯការបែងចែកវណ្ណៈ មានមុខងារសំខាន់នៅក្នុងជីវភាពសាសនារបស់ពួកព្រាហ្មណ៍, នៅក្នុងពុទ្ធសាសនា ឋានៈរបស់បុគ្គលម្នាក់, ទោះជាភិក្ខុ ឬគ្រហស្ថ ត្រូវបានសំរេចមិនមែនដោយសារជាតិកំណើតទេ ប៉ុន្តែ ដោយសារតម្លៃគុណធម៌ ។ ភិក្ខុមួយរូប ក្នុងឋានៈជាសមាជិករបស់គណៈសង្ឃ ក្លាយទៅជាអង្គតែមួយជាមួយភិក្ខុឯទៀត, បីដូចជាទឹកនៃទន្លេស្ទឹងទាំងឡាយដែលហូរចុះទៅក្នុងសមុទ្រដូច្នោះ ។

ភិក្ខុនោះបាត់ភាពផ្សេងៗ នៃសង្គមរបស់ខ្លួនទាំងអស់ ក្នុងខណៈដែលគេចូលរួមក្នុងគណៈសង្ឃ, ហើយព្រះធម៌ និងវិន័យ គឺជាគ្រូអាចារ្យដ៏ពិតរបស់គេ ។ ភិក្ខុនោះត្រូវសំដែងការគោរពចំពោះថ្នាក់លើរបស់ខ្លួន ហើយទទួលយកដំបូន្មានរបស់លោកទាំងនោះ, ប៉ុន្តែការរំដោះសង្គ្រោះខ្លួន ពឹងផ្អែកលើការសិក្សាស្វែងយល់ដោយខ្លួនឯង, ហើយភិក្ខុនោះជាអ្នកទទួលផលវិបាកណាមួយដោយខ្លួនឯង ។ ភិក្ខុ, មិនដូចព្រាហ្មណ៍ទេ, គឺពុំមែនជាអ្នកបួសព្រាហ្មណ៍ ឬគ្រីស្ត (priest) ទេ, ភិក្ខុត្រូវបានប្រឌិតធ្វើឡើង, ចំណែកឯព្រាហ្មណ៍ គឺកើតមកជាព្រាហ្មណ៍ពីកំណើត ។ ព្រាហ្មណ៍ គឺជាព្រាហ្មណ៍ជានិច្ច, ប៉ុន្តែ ភិក្ខុអាចលែងជាភិក្ខុវិញបានយ៉ាងងាយ ប្រសិនបើការប្រព្រឹត្ត ឬចរិយារបស់គេបានធ្វើអោយគេអស់តម្លៃគុណធម៌ដើម្បីឋិតនៅជាភិក្ខុ ។ មានតែកាលណាភិក្ខុនោះ ឋិតនៅក្នុងផ្លូវរីកចំរើន និងបរិសុទ្ធប៉ុណ្ណោះទេ, ទើបគេបានក្លាយទៅជាមនុស្សស័ក្តិសមនឹងដឹកនាំមនុស្សឯទៀត ។ ដោយហេតុនេះ ទោះបីជាគេរស់នៅក្រៅសង្គមចាត់តាំងក៏ដោយ, ក៏គេនៅតែរស់នៅពីលើសង្គមនោះដែរ ហើយមានតែយ៉ាងនេះទេ ទើបគេមើលឃើញការប៉ះទង្គិច (សង្ស័ដ) និងទុក្ខសោកទាំងឡាយ ដែលមនុស្សផងទាំងឡាយទទួលរង, ហើយដោយសារការយល់ដឹងនេះ ភិក្ខុនោះបានក្លាយជាមគ្គុទ្ទេសក៍ដ៏សុក្រិតសម្រាប់មនុស្សឯទៀត ។ ភិក្ខុបែបនេះ អាចដឹកនាំជីវិត ហើយគួរតែដឹកនាំជីវិតដើម្បីបំរើមនុស្សឯទៀត, ដែលមានបញ្ញាបារមី និងវិន័យតិច ។ ក្នុងន័យនេះ ភិក្ខុមិនមែនជាអ្នកដកខ្លួនចេញពីពិភពលោកនេះទេ ។ លោកមិនគប្បីព្រងើយកន្តើយចំពោះសត្រូវរបស់មនុស្សជាតិទេ ។ ការបំរើរបស់លោក ត្រូវប្រព្រឹត្តទៅតាមរយៈអំណោយនៃព្រះធម៌ (ធម្មទាន) ដែលត្រូវបានគេចាត់ទុកថាប្រសើរលើសទានទាំងឡាយឯទៀត ។

មានបញ្ហាមួយក្នុងចំណោមបញ្ហាទ្វេមុខ (ឧភតោ កោដិកបញ្ហា) នៅក្នុង

មិលិន្ទប្បញ្ហា ថាតើវាជាការត្រឹមត្រូវឬទេ សម្រាប់សោតាបន្នបុគ្គលជាគ្រហស្ថ សំដែងការគោរពចំពោះសាមណេរ ឬចំពោះភិក្ខុពុំមែនជាសោតាបន្នៈ (បុថុជ្ជន-ភិក្ខុ) ។ ក្នុងចម្លើយតបបញ្ហានេះ ព្រះនាគសេនបានផ្តល់គុណសម្បត្តិម្ភៃយ៉ាង (ទាំងអស់ជាសីលធម៌) និងចរិតលក្ខណៈខាងក្រៅពីរ (ពោលគឺ សម្តត់ពណ៌លឿង និងការកោរសក់) ដែលធ្វើអោយទៅជាភិក្ខុ និងបានផ្តល់ហេតុផលមួយចំនួនផងដែរ ថាព្រោះហេតុអ្វី ការប្រព្រឹត្តរបស់គ្រហស្ថបែបនោះ ក្នុងការមិនសំដែងការគោរព មិនមែនជាអំពើខុសឆ្គង ។ ក្នុងទីនេះ, ទស្សនៈអំពីភិក្ខុតាមការយល់ឃើញរបស់ព្រះនាគសេន គឺប្រហាក់ប្រហែលនឹងទស្សនៈរបស់ព្រះអរហន្ត ឬយ៉ាងហោចណាស់របស់អ្នកដែលឋិតនៅក្នុងផ្លូវត្រូវ ដើម្បីក្លាយទៅជាព្រះអរហន្ត ។ ប៉ុន្តែថា សេចក្តីសន្និដ្ឋាននៃទឡ្ហីករណ៍របស់ព្រះនាគសេន គឺជាសេចក្តីសន្និដ្ឋានគួរអោយយកចិត្តទុកដាក់ ក្នុងន័យដែលលោកបានពោលថា បើគ្រហស្ថអាចនឹងក្លាយទៅជាព្រះអរហន្ត, គ្រហស្ថនោះគួរតែ ឬមួយក្លាយទៅជាភិក្ខុភ្លាម, ឬបើពុំនោះសោតទេ គ្រហស្ថនោះនឹងទទួលមរណភាព ។

នៅទីអវសាននេះ, យើងគួរបន្ថែមថា នៅក្នុងពុទ្ធសាសនាមហាយានសារសំខាន់របស់ភិក្ខុ ហាក់ដូចជាត្រូវកាត់បន្ថយដោយឧត្តមគតិពោធិសត្វ ដែលជំរុញអោយមនុស្សម្នាក់ៗ ក្លាយទៅជាព្រះពុទ្ធ ។ នេះប្រហែលជាប្រតិកម្មមួយចំពោះជីវភាពរស់នៅឃ្លាតឆ្ងាយពីសង្គមរបស់ភិក្ខុខាងពុទ្ធសាសនាថេរវាទ ដែលត្រូវបានគេចោទប្រកាន់ថា ជាប្រភេទអត្តទត្តភាពខាងបញ្ញាស្មារតី ។ ទោះជាយ៉ាងនេះក្តី អ្វីដែលជាឧត្តមគតិពិតរបស់ភិក្ខុ ត្រូវបានគេពន្យល់នៅក្នុងឃ្លានៃគម្ពីរធម្មបទដូចតទៅនេះ :

> អ្នកដែលស្លៀកដណ្តប់សំពត់ពណ៌លឿង
> ក្នុងពេលដែលតណ្ហាលោកិយមិនទាន់គ្រប់គ្រងបាន

មិនស័ក្តិសមនឹងសម្ពត់របស់ខ្លួនទេ ។

ប៉ុន្តែ អ្នកដែលបន្សាត់បង់រស់ហើយ នូវគ្រឿងសៅហ្មងទាំងអស់ ជាអ្នកតាំងនៅរឹងមាំក្នុងកុសល

នេះ អ្នកនេះទើបជាអ្នកស័ក្តិសមនឹងសម្ពត់ពណ៌លឿង ។

ភាគច្រើននៃអ្វីដែលបាននិយាយមកហើយក្នុងទីនេះ ក៏អនុវត្តបាន ទោះបីតិច ឬច្រើន ចំពោះភិក្ខុនី ឬសាមណេរីផងដែរ ។

* * *

# ការចាំវស្សារបស់ព្រះសង្ឃ

ការចូលវស្សា ឬចាំវស្សា ជាប្រពៃណីរបស់ព្រះសង្ឃពុទ្ធសាសនិក មានតាំងពីជំនាន់ពុទ្ធកាលរៀងមក ។ រឿងនេះ មានសំដែងទុកក្នុងគម្ពីរព្រះត្រៃបិដក ភាគទី ៧ ផ្នែកព្រះវិន័យ ។

I . មូលហេតុនៃការចូលវស្សា

សម័យនោះ ព្រះមានព្រះភាគទ្រង់គង់នៅវត្តវេឡុវ័ន ទៀបក្រុងរាជគ្រឹះ។ គ្រានោះឯង ការចាំវស្សា ព្រះមានព្រះភាគមិនទាន់បានអនុញ្ញាត និងបញ្ញត្តដល់ភិក្ខុទាំងឡាយនៅឡើយទេ ។ ភិក្ខុទាំងនោះ ក៏ចេញដើរទៅកាន់ចារិក [១] ផ្សេងៗ អស់ហេមន្តរដូវខ្លះ អស់គិម្ហរដូវខ្លះ អស់វស្សានរដូវខ្លះ ។ មនុស្សទាំងឡាយក៏ពោលទោសតិះដៀលបន្តុះបង្អាប់ថា ពួកសមណៈជាសាក្យបុត្ត មិនសមបើនឹងដើរ ( ខុសរដូវកាល ) ជាន់ស្មៅស្រស់ ជាន់សត្វល្អិតៗ ឱ្យវិនាសសោះ ។ សូម្បីពួកបរិព្វាជកមានលទ្ធិដទៃ ជាអ្នកពោលធមិអាក្រក់ ម្តេចគង់នឹងសំងំឈប់សំរាកចាំវស្សា ឬសូម្បីពួកសត្វស្លាបទៀតសោត ក៏គង់តែធ្វើសំបុកលើចុងឈើ ហើយសំងំឈប់សំរាកចាំវស្សាដែរ ។ ពេលមនុស្សទាំងឡាយកំពុងលើកទោសបែបនេះ ពួកភិក្ខុទាំងនោះ ក៏បានឮច្បាស់នឹងត្រចៀកផ្ទាល់ ហើយក៏នាំសេចក្តីនោះទៅក្រាបទូលព្រះសម្ពុទ្ធ ។ ព្រះសាស្តាទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកអនុញ្ញ ាតថា *«អនុជានាមិ ភិក្ខវេ វស្សំ ឧបគន្តុំ* = ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុចូលវស្សា ។

II . កាលបរិច្ឆេទនៃការចូលវស្សា

វស្សាមានពីរ គឺ *បុរិមិកាវស្សា* ( វស្សាខាងដើម ) ១ *បច្ឆិមិកាវស្សា* ( វស្សាខាងចុង ) ១ ។ ការចូលបុរិមិកាវស្សា នៅថ្ងៃ ១ រោច ខែអាសាឍ ហើយ

(១) ទីដែលជាទីត្រាច់ទៅ ឬជាទីត្រាច់មក ។

ចេញនៅថ្ងៃពេញបូរមី ខែអស្សុជ ( បើឆ្នាំណាមានអធិកមាស ត្រូវចូលនៅថ្ងៃ ១ រោច ខែទុតិយាសាឍ ព្រោះមានពុទ្ធានុញ្ញាតថា « *អនុជានាមិ ភិក្ខវេ រាជូនំ អនុវត្តិតុំ* = ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុចូលវស្សា ទៅតាមការអនុ-វត្តលើកខែរបស់ព្រះរាជាចុះ » ។ ការចូលបច្ឆិមិកាវស្សា នៅថ្ងៃ ១ រោច ខែស្រាពណ៍ ហើយចេញនៅថ្ងៃពេញបូរមី ខែកត្តិក ។

ប្រសិនបើភិក្ខុណាមានធុរៈ មិនបានប្ដេជ្ញាអធិដ្ឋានបាលីចូលបុរិមិកាវស្សាទេ ភិក្ខុនោះអាចប្ដេជ្ញាអធិដ្ឋានបាលីចូលបច្ឆិមិកាវស្សាក៏បានដែរ ប៉ុន្តែភិក្ខុពុំអាចគេចវេះមិនចូលវស្សាណាមួយជាដាច់ខាត ដូចមានពុទ្ធបញ្ញត្តិថា « *ន ភិក្ខវេ វស្សំ ន ឧបគន្តព្វំ យោ ន ឧបគច្ឆេយ្យ អាបត្តិ ទុក្កដស្ស* = ម្នាលភិក្ខុទាំងឡាយ ភិក្ខុកុំមិនចូលវស្សាឡើយ គឺត្រូវតែចូលវស្សា ភិក្ខុណាមិនចូលវស្សា ភិក្ខុនោះត្រូវអាបត្តិទុក្កដ » ។

III . សត្តាហករណីយ

ភិក្ខុ កាលបើបានប្ដេជ្ញាអធិដ្ឋានចូលវស្សាក្នុងអាវាសណាមួយហើយ ត្រូវស្ថិតនៅក្នុងបរិវេណអាវាសនោះគ្រប់បីខែ គឺមិនត្រូវចេញក្រៅអាវាសនោះឱ្យកន្លងរាត្រីណាមួយឡើយ ដូចមានពុទ្ធបញ្ញត្តិថា « *ន ភិក្ខវេ វស្សំ ឧបគន្ត្វា បុរិមំ វា តេមាសំ បច្ឆិមំ វា តេមាសំ អវសិត្វា ចារិកា បក្កមិតព្វា យោ បក្កមេយ្យ អាបត្តិ ទុក្កដស្ស* = ម្នាលភិក្ខុទាំងឡាយ ភិក្ខុចូលវស្សាហើយ មិននៅចាំបុរិមិកាវស្សាអស់ខែបី ឬបច្ឆិមិកាវស្សាអស់ខែបីទេ មិនត្រូវចៀសចេញទៅកាន់ចារិកឡើយ, ភិក្ខុណាចៀសចេញទៅត្រូវអាបត្តិទុក្កដ » ។ ប៉ុន្តែ បើភិក្ខុមានធុរៈចាំបាច់ អាចលើកសត្តាហៈ ( សុំច្បាប់ព្រះ ) ជាមុនហើយទើបចេញបាន តែត្រូវត្រឡប់មកអាវាសវិញឱ្យទាន់ចន្លោះថ្ងៃ ៧ យ៉ាងយូរបំផុត ។

ឯធុរៈចាំបាច់ដែលភិក្ខុលើកយកមកធ្វើជាមូលហេតុដើម្បីលើកសត្តាហៈ

នោះគឺ ៖

. ភិក្ខុ ភិក្ខុនី សិក្ខមានា (១) សាមណេរ សាមណេរី ឧបាសក ឧបាសិកា ចង់ធ្វើទាន ចង់ស្តាប់ធម៌ ចង់ឃើញ ហើយគេបញ្ជូនបំរើមក ភិក្ខុអាចលើកសត្តាហៈបាន ។

. ភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ សាមណេរី មាតាបិតា បងប្អូនប្រុស មានជំងឺ ឬ ក៏មានសង្ឃកិច្ចត្រូវបំពេញ ភិក្ខុអាចលើកសត្តាហៈបាន ។

. បងប្អូនស្រី ញាតិ អ្នកធ្វើការឈ្នួល ( វេយ្យាវច្ចៈ ) មានជំងឺ ហើយគេបញ្ជូនបំរើមក ភិក្ខុអាចលើកសត្តាហៈទៅបាន ។

ឯវិធីលើកសត្តាហៈនោះគឺ ភិក្ខុត្រូវគ្រងចីវរឆៀងស្មាម្ខាងចូលទៅថ្វាយបង្គំព្រះ ( ព្រះពុទ្ធរូប ) អធិដ្ឋានបាលីលើកសត្តាហៈថា « *សចេ មេ អន្តរាយោ នត្ថិ សត្តាហព្ភន្តរេ បុន និវត្តិស្សាមិ* = ប្រសិនគ្មានអន្តរាយកើតមានដល់ខ្ញុំព្រះអង្គទេ ខ្ញុំព្រះអង្គនឹងវិលត្រឡប់មកអាវាសនេះវិញក្នុងចន្លោះនៃថ្ងៃ ៧ » ( សូត្របីដង ) ។ បើភិក្ខុបានលើកសត្តាហៈបែបនេះហើយចេញទៅ ស្រាប់តែមានឧបសគ្គតាមផ្លូវធ្វើឱ្យភិក្ខុមិនអាចត្រឡប់មកអាវាសវិញក្នុងចន្លោះនៃថ្ងៃ ៧ ទេ ភិក្ខុនោះឈ្មោះថាដាច់វស្សា តែមិនត្រូវអាបត្តិ ( ទោស ) ឡើយ ។

នៅមានអន្តរាយមួយចំនួនទៀត ដែលធ្វើឱ្យភិក្ខុត្រូវចេញចាកអាវាស ( រត់ចោលវស្សា ) តែមិនត្រូវអាបត្តិទេ គឺគ្រាន់តែដាច់វស្សាប៉ុណ្ណោះ ។ អន្តរាយទាំងនោះដូចជា ៖ សត្វសាហាវបៀតបៀន, សត្វមានពិសបៀតបៀន, ភ្លើងឆេះស្រុក និងសេនាសនៈ, ទឹកជន់លិចស្រុក, ចោរមកតាំងនៅក្នុងស្រុក, ពួកទាយកជាច្រើនឥតមានសទ្ធាជ្រះថ្លា, ខ្វះចង្ហាន់បិណ្ឌបាត, គ្មានឧបដ្ឋាកដ៏សមគួរ, ស្រីប្រលោមភិក្ខុ ស្រីផ្កាមាសប្រលោមភិក្ខុ, នាងថុល្លកុមារី (២) ប្រលោមភិក្ខុ, មនុស្ស

(១) អ្នកកំពុងសិក្សាត្រៀមបួស ។ (២) ក្មេងស្រីធាត់ ឬស្ត្រីនៅលីវ ( ប៉ុន្តែពេញវ័យ )

ខ្មោយប្រលោមភិក្ខុ, ញាតិប្រលោមភិក្ខុ, ស្តេចប្រលោមភិក្ខុ, ពួកចោរប្រលោមភិក្ខុ, អ្នកលេងប្រលោមភិក្ខុ, ភិក្ខុឃើញកំណប់ទ្រព្យ, ភិក្ខុសង្ឃបែកគ្នា ។

IV . ទីកន្លែងនៃការចាំវស្សា

ក្នុងជំនាន់ពុទ្ធកាល ស្រុកភូមិណាដែលស្ថិតនៅឆ្ងាយដាច់ស្រយាល គ្មានវត្តអារាមនៅជិត គេតែងនាំគ្នារៀបចំធ្វើជាសាលានៅកន្លែងណាមួយក្បែរនោះ ហើយនិមន្តភិក្ខុសង្ឃតិច ឬច្រើនអង្គតាមសទ្ធាឱ្យគង់ចាំវស្សា ដើម្បីងាយស្រួលក្នុងការធ្វើបុណ្យសុន្ទរ៍ទានផ្សេងៗ ។ ភិក្ខុមុននឹងសំរេចចិត្តទទួលនិមន្តន៍ចូលវស្សានៅកន្លែងណាមួយ ត្រូវពិនិត្យមើលកន្លែងនោះឱ្យបានម៉ត់ចត់ជាមុនសិន សឹមទទួលនិមន្តន៍ ។ បើពិនិត្យឃើញថា កន្លែងដែលគេនិមន្តឱ្យនៅចាំវស្សានោះសមរម្យ គ្មានចង្រៃតទេ ភិក្ខុគប្បីទទួលនិមន្តន៍ចុះ ។ ទីកន្លែងដែលព្រះសម្ពុទ្ធទ្រង់ហាមមិនឱ្យចូលវស្សានោះគឺ ក្នុងរូងឈើ, លើប្រគាបឈើ, ក្នុងទីវាល, គ្មានសេនាសនៈ, ក្នុងខ្ទមអ្នកតា, ក្រោមឆត្រ, ក្នុងអាងទឹក ( និងទីកន្លែងមានរង្កៀស ) ។

V . ទិដ្ឋភាពនៃការចូលវស្សា

ក្នុងការចូលវស្សារបស់ភិក្ខុសង្ឃដែលព្រះសម្ពុទ្ធទ្រង់អនុញ្ញាត និងបញ្ញត្តទុកតមកនោះ ពុំមានពិធីអ្វីអមរួមផ្សំច្រើនទេ គឺបើកាលណាតិថីចូលវស្សាមកដល់ហើយ ភិក្ខុគ្រាន់តែអធិដ្ឋានបាលីចូលវស្សាប៉ុណ្ណោះជាការស្រេច ប៉ុន្តែ ក្នុងការចូលវស្សារបស់ភិក្ខុសង្ឃកម្ពុជា គេសង្កេតឃើញមានសកម្មភាព និងពិធីអមគួបផ្សំមួយចំនួន កើតមាននៅពេលជាមួយគ្នានោះដែរ :

- ភិក្ខុ សាមណេរ ដែលស្នាក់នៅរៀនសូត្រឆ្ងាយពីស្រុកកំណើតត្រូវបានឈប់សំរាកចំនួនពីរសប្តាហ៍មុនថ្ងៃចូលវស្សា ដើម្បីទៅសួរសុខទុក្ខញាតិញោម និងបិណ្ឌបាតចតុប្បច្ច័យត្រៀមទុកប្រើប្រាស់ក្នុងឱកាសចូលវស្សាអស់ខែបី ។

- មុនថ្ងៃចូលវស្សាមកដល់ អាចារ្យ គណៈកម្មការវត្ត តែងដើរប្រកូក

ប្រកាសដំណឹងអំពីថ្ងៃចូលវស្សា និងសុំឱ្យឧបាសក ឧបាសិកា ទាយក ទាយិកាចំណុះជើងវត្តជួយបរិច្ចាគចតុប្បច្ច័យតាមកំលាំងសទ្ធា ដើម្បីឧបត្ថម្ភព្រះសង្ឃដែលនឹងគង់ចាំវស្សាក្នុងវត្តរបស់ខ្លួននាឆ្នាំនេះ ។

. ជិតដល់ថ្ងៃចូលវស្សា ឧបាសក ឧបាសិកា តែងមកកាន់វត្តច្រើនកុះករ ប្លែកពីធម្មតា ដើម្បីសមាទានសីល ប្រគេនចង្ហាន់ព្រះសង្ឃ បោសច្រាសវត្តអារាម សិតទៀនវស្សា ចាត់ចែងសាដកប្រគេនព្រះសង្ឃ ។ តាមឯកសារនានា បានបញ្ជាក់ថា ព្រះអតីតមហាក្សត្រខ្មែរ ទ្រង់មានព្រះរាជសទ្ធាជ្រះថ្លាបំពេញព្រះរាជកុសលក្នុងឱកាសព្រះសង្ឃចូលវស្សានេះដែរ ដូចជាទ្រង់ឱ្យធ្វើពិធីខ្វាន់នាគ ពិធីសិតទៀនវស្សា និងពិធីនិមន្តទេវរូបចូលវស្សាជាដើម ។

. នៅល្ងាចថ្ងៃ ១៥ កើត ខែអាសាឍ គេឃើញឧបាសក ឧបាសិកា មកជួបជុំគ្នាក្នុងវត្ត ហែទៀនវស្សា ហែសាដក និងគ្រឿងសក្ការៈប្រទក្សិណព្រះវិហារ និមន្តព្រះសង្ឃចំរើនព្រះបរិត្ត បវារណាព្រះសង្ឃចូលព្រះវស្សា វេរទៀនវស្សា សាដក ប្រគេនព្រះសង្ឃ ។ លុះព្រឹកឡើង មានការប្រគេនភត្តាហារចំពោះព្រះសង្ឃទៀត ។

. នៅល្ងាចថ្ងៃ ១ រោច ខែអាសាឍ គេឃើញព្រះសង្ឃនិមន្តជួបជុំនៅក្នុងព្រះវិហារ ។ ព្រះសង្ឃជាមហាថេរ បានប្រកាសអំពីការចូលវស្សា និងធ្វើការក្រើនរំលឹកអំពីក្រឹត្យវិន័យដែលទាក់ទងដល់ការចូលវស្សាឱ្យព្រះសង្ឃគ្រប់រូបបានជ្រាប ។ បន្ទាប់មក ព្រះភិក្ខុសង្ឃ ក៏អធិដ្ឋានបាលីចូលវស្សាថា « *ឥមស្មឹ អាវាសេ ឥមំ តេមាសំ វស្សំ ឧបេមិ ។ ទុតិយម្បិ ឥមស្មឹ .... វស្សំ ឧបេមិ, តតិយម្បិ ឥមស្មឹ .... វស្សំ ឧបេមិ* = ខ្ញុំ សូមនៅចាំវស្សាអស់ខែបីក្នុងអាវាសនេះអស់វារៈពីរដងផង អស់វារៈបីដងផង » ជាកិច្ចបញ្ចប់នៃពិធីចូលវស្សា ។

*១. អំពីទៀនវស្សា* ៖ ទៀនវស្សានេះ ឧបាសក ឧបាសិកា ធ្វើដើម្បីព្រះ

សង្ឃអុជថ្វាយព្រះរតនត្រ័យអស់ខែបី ទៀនវស្សានេះមានទទឹងមាត់មួយតឹក និង កំពស់ពីរហត្ថ ធ្វើដោយក្រមួនឃ្មុំ ឬក្រមួនចំបក់, នៅគល់ទៀនខាងក្រោមមានជើង ទ្រ ធ្វើដោយឈើ មានក្បាច់ត្របកឈូក, តែនៅមាត់ខាងលើ គេច្រើនធ្វើឡតដែក ចាក់ប្រេងដូង ឬប្រេងសណ្ដែកដាក់ប្រឆេះអុជ គឺមិនអុជទៀនផ្ទាល់ទេ ព្រោះក្រែង ទៀននោះឆេះឆាបអស់មុនពេលចេញវស្សា ។ អ្នកខ្លះយកផ្កាមាសធ្វើដោយស្ពាន់ ក្រាប់ [១] ទៅបិទជាលម្អលើតួទៀន ក៏មាន ។ របៀបធ្វើទៀនវស្សានេះ មានរចនា ច្រើនបែបណាស់តាមការនិយមរបស់អ្នកស្រុក ។ បច្ចុប្បន្ន គេនិយមប្រើចង្កៀង ប្រេងកាត សំរាប់អុជថ្វាយព្រះរតនត្រ័យ គឺមិនសិតទៀនដោយក្រមួនឃ្មុំ ឬក្រមួន ចំបក់ដូចជំនាន់មុនទេ ប៉ុន្តែត្រូវអុជឱ្យឆេះរហូតគ្រប់ខែបី មិនឱ្យរលត់ក្នុងខណៈណា មួយឡើយ ។ ទំនៀមធ្វើទៀនវស្សាបូជាព្រះក្នុងរយៈពេលចូលវស្សានេះ ពុំមាន និយាយក្នុងគម្ពីរព្រះពុទ្ធសាសនា ( ព្រះត្រៃបិដក ) ទេ ប៉ុន្តែមាននិយាយនៅក្នុង សាស្ត្រាអានិសង្សទៀនវស្សា ដែលខ្មែរយើងនិយមសំដែងនៅពេលចូលវស្សានេះ ឯង ។ គម្ពីរនេះ ពុំមានដាក់ឈ្មោះអ្នកតែង ហើយមិនដឹងជាតែងឡើងក្នុងរាជ្យណា ដែរ ។ ឯសេចក្ដីក្នុងសាស្ត្រានេះ ដំណាលថា កាលព្រះសម្មាសម្ពុទ្ធទ្រង់គង់ធរមាន នៅឡើយ មានបុរសកំសត់ម្នាក់រកស៊ីកាប់អុសលក់ជាមុខរបរប្រចាំថ្ងៃ ។ គាត់តែង សង្កេតឃើញខ្លាឃ្មុំមួយធំ លោតចេញពីរូងថ្មមួយរៀងរាល់ថ្ងៃ ។ ពេលដែលខ្លាឃ្មុំ នោះលោតចេញផុតទៅ គាត់ក៏ដើរទៅមើលឃើញសុទ្ធតែអាចម៍ខ្លាឃ្មុំ ហើយក៏វេច យកមកបង្ហាញអ្នកជិតខាងឱ្យជួយមើល ។ អ្នកជិតខាងប្រាប់ថា « អាចម៍ខ្លាឃ្មុំនេះ គេតែងយកមកស្ងោរធ្វើក្រមួន ធ្វើទៀនអុជ, ចូរអ្នកទៅយកឱ្យច្រើនមក » ។

បុរសកំសត់នោះ នឹកគិតថា « ចុះបើអាចម៍ខ្លាឃ្មុំនេះ គេអាចយកមកធ្វើ ជាទៀនអុជបាន តើគេអាចយកទៀននោះទៅអុជជាគ្រឿងសក្ការបូជាចំពោះព្រះពុទ្ធ

(១) ធាតុផ្សំមានបន្ទះស្តើងស្រួយ សម្បុរផ្លេក សម្រាប់ដាក់ជាក្បាច់រំលេចបិទក្ដារមឈូស ជាដើម ។

អង្គបានឬទេ ? ឬមួយជាការមិនសមគួរគប្បី ព្រោះទៀននេះធ្វើអំពីសំណល់មិនស្អាត ( អាចម៍ ) បែបនេះ ? ពេលដែលបុរសនោះកំពុងតែនឹកសង្ស័យមិនដាច់ស្រេចក្នុងចិត្តបែបនេះ ស្រាប់តែឃើញព្រះមហាមោគ្គល្លានត្ថេរនិមន្តមកដល់ ក៏ទូលសួរលោកតាមដំណើរ ។ ព្រះមហាមោគ្គល្លានត្ថេរមានពុទ្ធដីកាថា « ជាការប្រសើរណាស់ » ។ លុះបុរសនោះធ្វើបានជាទៀនច្រើនហើយ ក៏នាំយកទៅថ្វាយព្រះមានបុណ្យ ។ ព្រះមហាមោគ្គល្លានត្ថេរដែលជាអ្នកដឹកនាំទៅនោះ បានទូលព្រះអង្គថា « បពិត្រព្រះអង្គដ៏ចម្រើន បុរសនោះបានទៅយកអាចម៍ខ្លាឃ្មុំមកស្ងោរយកក្រមួនលញ់ជាទៀនយកមកអុជបូជាព្រះអង្គ ហើយសង្ស័យថា ក្រែងពុំបានផលានិសង្សអ្វីទេដឹង ទើបខ្ញុំព្រះអង្គនាំគាត់ចូលមកនេះ » ។ ព្រះដ៏មានបុណ្យទ្រង់ត្រាស់ថា «ម្នាលអាវុសោអើយ ! បុរសនេះនឹងត្រូវបានទទួលផលានិសង្សច្រើនប្រការ, ប្រាថ្នាអ្វីសឹងបានដូចបំណងទាំងអស់» ។ បុរសនោះស្តាប់ហើយ ត្រេកអរក្រៃលែង ។

នៅពេលដែលបុរសយកទៀនទៅថ្វាយព្រះពុទ្ធអង្គនោះ អានិសង្សបុណ្យកុសលនេះ បានបណ្តាលឱ្យក្តៅក្រហាយដល់ព្រះឥន្ទ្រាធិរាជ ។ ព្រះឥន្ទ្រាធិរាជទ្រង់បើកទិព្វចក្ខុមើលមក ឃើញបុរសកំសត់កំពុងប្រាថ្នាកុំឱ្យក្រលំបាក និងកុំឱ្យកំព្រីកំព្រាដូចជាតិនេះទៀត ក៏ប្រើព្រះវិស្សកម្មទេវបុត្រឱ្យទៅជប់ជាប្រាសាទមាស ប្រាសាទប្រាក់ ឃ្លាំងមាស ឃ្លាំងប្រាក់ ព្រមទាំងសួនប្រកបដោយដើមឈើពេញទៅដោយផ្កាផ្លែគ្រប់ពណ៌យ៉ាងល្អ មានទាំងអ្នកគាល់បំរើច្រើនត្រៀបត្រា ពុំមានខ្វះកន្លះអ្វីឡើយ ។

លុះបុរសត្រឡប់ពីវត្តជេតពន រកខ្ទមស្លឹកមិនឃើញ ហើយបែរជាឃើញឯប្រាសាទភ្លឺរន្ទាលឆ្អិនឆ្អៅទៅវិញ ក៏ភ័យណាស់រត់ទៅទូលព្រះមហាមោគ្គល្លានត្ថេរ ។ ព្រះថេរៈមានពុទ្ធដីកាថា « ចូរអ្នកឡើងទៅនៅចុះ ព្រោះជាលទ្ធផលនៃបុញ្ញកម្មរបស់អ្នកហើយ » ។

ដោយសារមានរឿងនិទានដូចនេះហើយបានជាខ្មែរយើងនិយមសិតទៀនវស្សាបូជាព្រះ នៅពេលព្រះសង្ឃចូលវស្សា ។ ក្នុងគម្ពីរពុទ្ធសាសនា គ្មាននិយាយទាក់ទងដល់ទៀនវស្សាទេ ប៉ុន្តែ មាននិយាយពីប្រទីប ។ ប្រទីប ចាត់ទុកជាសក្ការបូជាមួយដែរ សំរាប់បូជាព្រះរតនត្រ័យ ។ តាមការសន្និដ្ឋានរបស់អ្នកប្រាជ្ញខ្លះថា ការធ្វើទៀនវស្សាបូជាព្រះរតនត្រ័យនេះ ទំនងជាមានទំនៀមជាប់មកពីព្រហ្មញ្ញ សាសនា ព្រោះពួកព្រាហ្មណ៍ពេលប្រារព្ធធ្វើពិធីផ្សេងៗ តែងយកការអុជភ្លើងជាធំ ។ ពេលប្រារព្ធពិធី គេប្រុងប្រយ័ត្នណាស់មិនឱ្យរលត់ទេ ព្រោះយល់ថា បើទៀន ឬភ្លើងរលត់ក្នុងពេលមិនទាន់ចប់ពិធីវាជាប្រផ្នូលអាក្រក់មួយ ។ ឯការអុជទៀនវស្សានេះក៏មានការប្រុងប្រយ័ត្នដែរ បើទៀនរលត់ក្នុងវស្សា គេយល់ថាជាការដាច់វស្សាហើយ ។

អ្នកប្រាជ្ញខ្លះសន្និដ្ឋានថា ការប្រុងប្រយ័ត្នមិនឱ្យរលត់ទៀនវស្សានេះ ជាប្រស្នាមួយពញ្ញ ាក់ស្មារតីភិក្ខុសង្ឃឱ្យខិតខំអនុវត្តតាមពុទ្ធប្បញ្ញ ត្តិ កុំឱ្យមានការផ្លាស់ផ្លោយដាច់វស្សា ព្រោះវស្សាងាយដាច់ណាស់ ប្រៀបដូចជាភ្លើងទៀនដែរ បើយើងមិនប្រយ័ត្នប្រាកដជាដាច់ពុំខាន ។ អ្នកខ្លះទៀត សន្និដ្ឋានថា ទៀនវស្សានេះជានិមិត្ត-រូបនៃព្រះប្រាជ្ញាញាណព្រះមហាករុណាធិគុណរបស់ព្រះពុទ្ធអង្គ ដែលតែងតែភ្លឺស្វាង និងមានជានិច្ចចំពោះសព្វសត្វ ឥតមានពេលណាអាក់ខាន ឬរលត់ឡើយ ។

*២. អំពីសាដក* ៖ រឿងដែលឧបាសក ឧបាសិកា និយមធ្វើសាដកប្រគេនសង្ឃសំរាប់ស្រង់ទឹកនោះ មានសម្តែងទុកនៅក្នុងគម្ពីរព្រះត្រៃបិដក ភាគទី ៨ ( វិន័យបិដក ) ផង និងមាននិយាយក្នុងសាស្ត្រាអានិសង្សសាដកផង ។

ក / គម្ពីរព្រះត្រៃបិដក ៖ បានឮថា ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទៀបក្រុងសាវត្ថី ។ វេលានោះ នាងវិសាខាក្រាបបង្គំទូលព្រះសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់មេត្តាទទួលភត្តរបស់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែក ជាមួយ

និងភិក្ខុសង្ឃ ។ ព្រះមានព្រះភាគទ្រង់ទទួលនិមន្តន៍ដោយតុណ្ហិភាព ។ នាងវិសាខា ក៏ក្រាបថ្វាយបង្គំលាព្រះសាស្តាចេញទៅ ។ លុះរាត្រីកន្លងទៅ មានភ្លៀងធំធ្លាក់ចុះសព្វទ្វីបទាំងបួន ។ គ្រានោះពួកភិក្ខុនាំគ្នាស្រាតងូតទឹក ។

ជួនពេលនោះ នាងវិសាខា បានប្រើទាសីឱ្យទៅនិមន្តព្រះពុទ្ធ និងភិក្ខុសង្ឃ ដើម្បីទទួលភត្ត ។ នាងទាសី ក៏ធ្វើដំណើរទៅដល់វត្តជេតពន រកមើលមិនឃើញពួកភិក្ខុសោះ ឃើញតែមនុស្សកំពុងងូតទឹកស្រាត ក៏គិតថា ក្នុងអារាមនេះគ្មានពួកភិក្ខុទេ មានតែពួកអាជីវកកំពុងងូតទឹកជម្រះកាយ រួចក៏ត្រឡប់មកកាន់សំណាក់នាងវិសាខាវិញ ហើយជម្រាបថា « បពិត្រអ្នកម្ចាស់ ! ក្នុងអារាមគ្មានពួកភិក្ខុទេ មានសុទ្ធតែពួកអាជីវក កំពុងងូតទឹកភ្លៀងជម្រះកាយ » ។ នាងវិសាខាជាស្ត្រីឈ្លាសវៃ ក៏យល់ភ្លាមថា « ច្បាស់ជាលោកម្ចាស់ទាំងឡាយដាក់ចីវរចេញ ហើយនាំគ្នាងូតទឹកភ្លៀងជម្រះកាយ តែទាសីនេះសម្គាល់ថា ពួកអាជីវកទៅវិញ » ។ នាងវិសាខា ក៏ប្រើនាងទាសីនោះជាលើកទីពីរទៀត ។ នាងទាសី ក៏ទៅដល់វត្តហើយ រកមើលភិក្ខុទាំងឡាយមិនឃើញសោះ រួចត្រឡប់មកវិញ ជម្រាបនាងវិសាខាថា « បពិត្រអ្នកម្ចាស់ ក្នុងអារាមនេះគ្មានពួកភិក្ខុសោះ មានតែអារាមទទេ » ។ នាងវិសាខា រិះគិតថា « ច្បាស់ជាលោកម្ចាស់ទាំងឡាយងូតទឹក ហើយចូលទៅលំនៅវិញដូចដែល បានជានាងទាសីនេះមិនឃើញ » ។ នាងវិសាខា ក៏ប្រើទៅជាលើកទីបី នាងទាសីនេះ ក៏ទទួលបង្គាប់ ហើយធ្វើដំណើរទៅវត្តជេតពនទៀត ។ តាប់ជួនដល់វេលាភត្តកាលហើយ ព្រះសាស្តាក៏ទ្រង់ត្រាស់ឱ្យពួកភិក្ខុរៀបចំចេញដំណើរទៅផ្ទះនាងវិសាខា ដើម្បីទទួលភត្តតាមការនិមន្តន៍ ។

លុះព្រះមានព្រះភាគ និងភិក្ខុសង្ឃគ្រាន់តែឆាន់រួចភ្លាម នាងវិសាខាក៏ក្រាបទូលថា « បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមពរប្រាំបីប្រការអំពីព្រះអង្គ » ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា « ម្នាលនាងវិសាខា ធម្មតាព្រះតថាគតទាំងឡាយគ្មាន

ពរទេ » ។ នាងវិសាខាក្រាបទូលថា « បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមតែពរណាដែលគួរ និងពរណាដែលឥតទោស » ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា « ម្នាលនាងវិសាខា ចូរនាងនិយាយមកចុះ » ។ នាងវិសាខា ក៏ក្រាបទូលថា « បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចង់ប្រគេន ៖

១. វស្សិកសាដក ( សំពត់សំរាប់ងូតទឹកភ្លៀង )

២. អាគន្តុកភត្ត ( ភត្តសំរាប់ភិក្ខុមកដល់ថ្មី )

៣. គមិកភត្ត ( ភត្តសំរាប់ភិក្ខុមានដំណើរចេញទៅឆ្ងាយ )

៤. គិលានភត្ត ( ភត្តសំរាប់ភិក្ខុមានជំងឺ )

៥. គិលានុបដ្ឋាកភត្ត ( ភត្តសំរាប់ភិក្ខុអ្នកបំរើជំងឺ )

៦. គិលានភេសជ្ជៈ ( ថ្នាំសំរាប់ភិក្ខុមានជំងឺ )

៧. ធុវយាគូ ( បបរសំរាប់ភិក្ខុឆាន់ជានិច្ច )

៨. ឧទកសាដិកា ( សំពត់ងូត ) សម្រាប់ភិក្ខុនី

ព្រះសាស្តាទ្រង់ត្រាស់ថា « ម្នាលនាងវិសាខា ល្អហើយ ! ល្អហើយ ! នាងបានសូមពរប្រាំបីប្រការអំពីតថាគត ជាការប្រពៃពិត, ម្នាលនាងវិសាខា បើដូច្នេះតថាគតអនុញ្ញាតពរប្រាំបីប្រការដល់នាង » ។ ព្រោះមានដំណើរដើមដានបែបនេះហើយ ទើបពុទ្ធសាសនិកខ្មែរនិយមធ្វើសាដកសំរាប់ប្រគេនភិក្ខុសង្ឃសំរាប់ស្រង់ទឹកជៀសវាងស្រង់ទឹកអាក្រាតកាយ, រហូតមកដល់បច្ចុប្បន្ននេះ ។

· ខ / សាស្ត្រាអានិសង្សសាដក ៖ សេចក្តីដំណាលថា មានទាសា ទាសី ប្តីប្រពន្ធពីរនាក់ ។ គាត់មានកូនក្រមុំម្នាក់ឈ្មោះ « នាងអមយ្យទាសី ។ ក្រោយមកឪពុកនាងក៏ទទួលមរណភាពទៅ ។ នាងក៏រស់នៅជាមួយម្តាយ ហើយធ្វើជាទាសីគេទាំងពីរនាក់ម្តាយកូនតទៅទៀត ។ ថ្ងៃមួយ នៅពេលចូលវស្សា នាងអមយ្យទាសីបានឃើញអ្នកស្រុកនាំគ្នាយកសាដកទៅប្រគេនព្រះភិក្ខុសង្ឃ ក៏កើតមានសេចក្តីជ្រះ

ផ្កាក្រៃលែង ប៉ុន្តែនាងគ្មានលទ្ធភាពរកលុយកាក់ ដើម្បីយកទៅទិញសាដកដូចអ្នកស្រុកឯទៀត ព្រោះនាងទ័លក្រពេកណាស់ ។ នាងគិតមិនលេចសោះ ក្នុងការស្វែងរកលុយកាក់សំរាប់ធ្វើសាដក, នាង និងម្តាយ ក៏សំរេចចិត្តចុងក្រោយទៅសំពះម្ចាស់ ( ថៅកែ ) សុំបន្ថែមថ្លៃឈ្នួលខ្លួន តែម្ចាស់ប្រាក់ក៏ពុំព្រមថែមឱ្យ ព្រោះនាងជំពាក់គេក្រៃលណាស់ទៅហើយ ។ នាងអស់តម្រិះ ក៏ថយមកគិតទៀតថា « ឱអញអើយ ! កើតមកជាអ្នកទ័លក្រ លំបាកវេទនា ឃើញការកុសលនៅនឹងមុខហើយឈោងចាប់យកដូចគេពុំបាន តើកាលណាឡើយនឹងបានធ្វើបុណ្យនឹងគេ, បើអញស្លាប់អំពីជាតិនេះទៅ ទៅចាប់កំណើតថ្មីមុខជានៅតែបំរើគេពុំឃ្លាតឡើយ, ណ្ហើយចុះ ដើម្បីកុំឱ្យសល់ខានធ្វើបុណ្យដែលអញមានសេចក្តីជ្រះថ្លាទាំងម្ល៉េះ អញសុខចិត្តខ្លាស់ ( ខ្មាស់ ) ស្លឹកឈើស្លៀក » ។ លុះនាងគិតហើយ ក៏ផ្លាស់សំពត់អំពីខ្លួនយកទៅបោកគក់ឱ្យជ្រះក្អែល ជ្រះក្លិនឆ្អេះឆ្អាប យកទៅជ្រលក់ទឹកអម្ចត់ រួចយកទៅប្រគេនព្រះសង្ឃតាមចិត្តជ្រះថ្លា ហើយតាំងចិត្តអធិដ្ឋានថា « សេចក្តីជ្រះថ្លាដែលញ៉ាំងចិត្តខ្ញុំឱ្យនាំមកបូជានូវសំពត់សាដកក្នុងគ្រានេះ, លុះអនាគតជាតិទៅ សូមកុំឱ្យខ្ញុំស្គាល់ការខ្វះខាត ដូចជាតិនេះទៀតឡើយ » ។ ក្រោយមក ដោយអំណាចផលានិសង្សដែលនាងបានកសាងសំពត់សាដកនេះ នាងក៏បានទៅជាឯកអគ្គមហេសី នៃព្រះរាជាមួយព្រះអង្គ ។ ដោយសារមាននិទាននេះហើយ ទើបខ្មែរយើងនិយមធ្វើសំពត់សាដកប្រគេនព្រះសង្ឃ ជាទំនៀមមកដល់សព្វថ្ងៃ ។

គ / តំណមក្នុងឱកាសវស្សា : ក្នុងរយៈពេលបីខែនេះ ប្រជារាស្ត្រខ្មែរជាពុទ្ធសាសនិក មានទំនៀមតំណមផ្សេង១ ដូចជាតំណមរៀបមង្គលការកូនចៅ តំណមសង់ផ្ទះសម្បែង ដោយចាត់ទុកថា « ជាថ្ងៃឃ្លប » ។ ចំពោះតំណមនេះ អ្នកប្រាជ្ញខ្លះសន្និដ្ឋានថា « តំណមហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍កូនចៅនោះ ព្រោះបុរាណាចារ្យយើងយល់ថា ខែវស្សាជាខែដែលភ្លៀងធ្លាក់ប៉ប៉ុចប៉ប៉ាច់ និងជាខែដែល

យើងមមាញឹកបង្កបង្កើនផល » ។ ឯតំណាមបាមមិនឱ្យសង់ផ្ទះសម្បែងនោះ ព្រោះលោកយល់ថា ខែវស្សាធ្វើឱ្យដីជ្រាយ និងធ្វើឱ្យឈើសើម ឬរីក ជាហេតុមិនអាចធ្វើផ្ទះសម្បែងបានល្អទេ ។

សេចក្ដីសន្និដ្ឋាន :

ថិរវេលានៃការចាំវស្សាបីខែនេះ ជារយៈពេលមួយមានតម្លៃពិសេស ព្រោះវាជាសញ្ញាដាស់ស្មារតីបព្វជិតពុទ្ធសាសនិក ឱ្យបង្កើនសេចក្ដីព្យាយាមបំពេញគន្ថធុរៈក្ដី វិបស្សនាធុរៈក្ដី ឱ្យបានខ្លាំងក្លាជាងពេលណាៗទាំងអស់ ។ រីឯឧបាសកឧបាសិកា ក៏បានមើលឃើញច្បាស់អំពីខ្លឹមសារនៃការចាំវស្សារបស់ភិក្ខុសង្ឃដែរ ។ ដូច្នេះហើយបានជាគេខិតខំឧបត្ថម្ភចតុប្បច្ច័យផ្សេងៗ ចំពោះលោកយ៉ាងខ្លាំងប្លែកពីធម្មតា ដូចជាទៀនវស្សា ( ប្រេង ), សាដក, ដាក់បិណ្ឌ, ភ្ជុំបិណ្ឌ ..... ដើម្បីសំដែងនូវសមានចិត្ត, ចូលរួមអបអរសាទរ, រំលែកនូវការលំបាកខ្វះខាត និងដើម្បីជាផលានិសង្សសំរាប់ខ្លួនផង ។

រៀបរៀងដោយ
**រ៉ែម៉ន ប្រាជ និង អាំ ឆន**
ពិនិត្យសំរួលដោយ **ឱម ខែម**

# ការចេញវស្សារបស់ព្រះសង្ឃ

ភិក្ខុសង្ឃកាលបើបានចូលវស្សា និងបាននៅចាំវស្សាអស់ត្រីមាសហើយ ត្រូវធ្វើកិច្ចការចេញចាកការចាំវស្សារបស់ខ្លួន ហៅថា " *បវារណា* " ។ បវារណា ជាវេទិការិះគន់គ្នា ដើម្បីការរីកចម្រើន គឺភិក្ខុមួយរូបៗ ប្រកាសដាក់ខ្លួនដាក់កាយ អោយសង្ឃ ឬអោយបុគ្គលគ្នាឯងជួយរិះគន់ ជួយពិនិត្យរកមើលកំហុសរបស់ខ្លួន ក្រែងបានប្រព្រឹត្តឆ្គាំឆ្គងល្មើសលើបទបញ្ញត្តិណាមួយ ក្នុងថិរវេលានៃការចាំវស្សា នោះ ទោះបានឃើញក្តី បានឮក្តី មានការរង្កៀសក្តី ក៏សូមអោយលើកឡើងបង្ហាញ អោយបានច្បាស់ដើម្បីបានដឹង ហើយធ្វើការកែប្រែអោយល្អឡើងវិញ ។

I . មូលហេតុនៃការបវារណា

មូលហេតុដែលនាំអោយភិក្ខុសង្ឃពុទ្ធសាសនិក បវារណាចេញវស្សា នោះមានដូចតទៅ ៖

សម័យមួយ ព្រះមានជោគទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់ អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះមានភិក្ខុច្រើនរូបជាមិត្ត ទើបបានជួប គ្នាថ្មី ( សន្ទិដ្ឋមិត្ត ) ជាមិត្តស្និទ្ធស្នាលមាំមួន ( សម្ភត្តមិត្ត ) បានចូលវស្សាក្នុងអាវាស មួយក្នុងកោសលជនបទ ។ ភិក្ខុទាំងនោះ មានសេចក្តីត្រិះរិះថា តើយើងមានឧបាយ ដូចម្តេចដើម្បីនឹងបានជាអ្នកព្រមព្រៀងគ្នា ស្មោះស មិនវិវាទគ្នា នៅចាំវស្សាអោយ បានស្រួលផង មិនលំបាកដោយអាហារបិណ្ឌបាតផង ? ភិក្ខុទាំងនោះក៏មានគំនិតឯក ភាពថា « បើយើងមិននិយាយគ្នា មិនចរចាគ្នាទៅវិញទៅមក, បើយើងត្រូវការពឹង គ្នាត្រូវប្រើកាយវិការជាសញ្ញា តែមិនត្រូវប្រើវាចាឡើយ ទើបយើងឈ្មោះថាជាអ្នក ព្រមព្រៀងគ្នា ស្មោះស មិនវិវាទគ្នា នៅចាំវស្សាក៏ស្រួលផង មិនលំបាកដោយ អាហារបិណ្ឌបាតផង » ។ ពួកភិក្ខុទាំងនោះព្រមព្រៀងគ្នាដូច្នេះហើយ ក៏លែងស្តី .

ហៅរក - ឆ្លើយឆ្លងគ្នារហូតគ្រប់ខែបី ។

លុះចេញវស្សាហើយ ភិក្ខុទាំងនោះក៏រៀបចំទុកដាក់សេនាសនៈ ប្រដាប់ដោយបាត្រ និងចីវរចេញដំណើរទៅកាន់ក្រុងសាវត្ថី ដើម្បីចូលទៅគាល់ព្រះមានព្រះភាគក្នុងវត្តជេតពន ។ ព្រះសាស្តាទ្រង់ត្រាស់ថា « ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយល្មមអត់ធន់សេចក្តីទុក្ខបានឬទេ ? ល្មមអោយឥរិយាបថប្រព្រឹត្តទៅស្រួលបានឬទេ ? អ្នកទាំងឡាយជាបុគ្គលព្រមព្រៀងគ្នា ស្រុះស្រួលគ្នា មិនទាស់ទែងគ្នា នៅចាំវស្សាដោយសប្បាយហើយឬ ? មួយទៀត អ្នកទាំងឡាយមិនលំបាកដោយបិណ្ឌបាតទេឬ ? ភិក្ខុទាំងនោះ ក៏ក្រាបទូលថា យើងខ្ញុំនៅចាំវស្សាដោយសប្បាយ ព្រោះយើងខ្ញុំមានគំនិតឯកភាពគ្នា « យើងខ្ញុំ មិនគប្បីហៅរកគ្នា មិនគប្បីចរចារកគ្នាទៅវិញទៅមក នោះទើបឈ្មោះថាជាអ្នកព្រមព្រៀងគ្នា ស្រុះស្រួលគ្នា មិនទាស់ទែងគ្នានៅចាំវស្សាដោយសប្បាយ » ។ ព្រះមានព្រះភាគទ្រង់ព្រះសណ្តាប់ពាក្យនេះហើយក៏ទ្រង់មានព្រះបន្ទូលថា « ម្នាលភិក្ខុទាំងឡាយ អ្នកនៅចាំវស្សាមិនសប្បាយទេ ប៉ុន្តែប្តេជ្ញាថាខ្លួនជាអ្នកនៅចាំវស្សាដោយសប្បាយ, អ្នកនៅចាំវស្សាដូចជាការរស់នៅរបស់បសុសត្វ ( សត្វចិញ្ចឹម ) ឬដូចជាការរស់នៅរបស់សត្វពពែ ឬក៏ដូចជាការរស់នៅរបស់បុគ្គលប្រមាទតែប្តេជ្ញាខ្លួនថា ជាអ្នករស់នៅដោយសប្បាយ ។ ម្នាលមោឃ-បុរស អ្នកមិនសមបើនឹងសមាទាននូវមូគវត្ត ( វត្តរបស់មនុស្សគ ) ដែលជាតិត្ថិយ-សមាទាន ( សមាទានរបស់តិរ្ថិយ ) ទេ, អំពើនេះ មិនមែននាំឱ្យគេជ្រះថ្លាទេ ។

ព្រះសម្ពុទ្ធទ្រង់បន្ទោសភិក្ខុទាំងនោះយ៉ាងនេះហើយ ក៏ទ្រង់ធ្វើធម្មីកថាថា « ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសមាទាននូវមូគវត្ត ដែលជាតិត្ថិយសមាទានទេ ភិក្ខុណាសមាទាន ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតអោយភិក្ខុទាំងឡាយដែលនៅចាំវស្សារួចហើយបវារណាដោយស្ថានបីយ៉ាងគឺ ដោយឃើញក្តី ដោយឮក្តី ដោយរង្កៀសក្តី = *អនុជានាមិ ភិក្ខវេ វស្សំ វុត្ថានំ ភិក្ខូនំ តីហិ*

*ឋានេ ហិបវារេត្ថុំ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា ។*

II . កិច្ចបវារណាចេញវស្សា

ជាទូទៅ នៅល្ងាច ឬយប់ថ្ងៃ ១៥ កើតខែអស្សុជ ព្រះសង្ឃដែលបានគង់ចាំបុរិមិការវស្សាអស់ខែបីនៅក្នុងអាវាសណាមួយនោះ ត្រូវជួបជុំគ្នានៅក្នុងព្រះវិហារ នមស្សការព្រះរតនត្រ័យ និងសំដែងអាបត្តិ ។ បើមានភិក្ខុចាប់ពី ៥ អង្គឡើងទៅនៅចាំវស្សាក្នុងអាវាសមួយ ត្រូវបវារណាយ៉ាងនេះគឺ ជាបឋម សង្ឃត្រូវចាត់តាំងភិក្ខុដែលឈ្លាសប្រតិពលអោយប្រកាសក្នុងជំនុំសង្ឃថា « *សុណាតុ មេ ភន្តេ សង្ឃោ អជ្ជ បវារណា ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ បវារេយ្យ* = បពិត្រព្រះសង្ឃដ៏ចំរើនសូមព្រះសង្ឃស្តាប់ខ្ញុំ ថ្ងៃនេះជាថ្ងៃបវារណា ។ បើបវារណាកម្ម មានកាលគួរដល់សង្ឃហើយ គួរសង្ឃបវារណា » ។ ភិក្ខុជាថេរៈ ត្រូវអង្គុយច្រហោងផ្គងអញ្ជលីហើយនិយាយយ៉ាងនេះនឹងសង្ឃថា « *សង្ឃំ អាវុសោ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ ។ ទុតិយម្បិ អាវុសោ សង្ឃំ បវារេមិ .... បដិករិស្សាមិ, តតិយម្បិ អាវុសោ សង្ឃំ បវារេមិ .... បដិករិស្សាមិ* = ម្នាលអាវុសោ ខ្ញុំសូមបវារណានឹងសង្ឃ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកមានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះហើយពោល ( ដាស់តឿន ) ចំពោះខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម, ម្នាលអាវុសោខ្ញុំសូមបវារណា នឹងសង្ឃ ជាគម្រប់ពីរដងផង .... នឹងធ្វើតាម, ម្នាលអាវុសោ ខ្ញុំសូមបវារណានឹងសង្ឃ ជាគម្រប់បីដងផង .... នឹងធ្វើតាម ។ ភិក្ខុដែលមានវស្សាខ្ចីបន្តបន្ទាប់ត្រូវអង្គុយច្រហោងផ្គងអញ្ជលីឡើង ហើយនិយាយយ៉ាងនេះនឹងសង្ឃថា « *សង្ឃំ ភន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ ។ ទុតិយម្បិ ភន្តេ សង្ឃំ បវារេមិ .... បដិករិស្សាមិ, តតិយម្បិ ភន្តេ សង្ឃំ បវារេមិ ....*

*បដិករិស្សាមិ* = បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមបវារណានឹងសង្ឃ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកម្ចាស់មានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះ ហើយពោល ( ដាស់តឿន ) ចំពោះខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម, បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមបវារណានឹងសង្ឃអស់វារៈពីរដងផង ..... នឹងធ្វើតាម, បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមបវារណានឹងសង្ឃអស់វារៈបីដងផង ..... នឹងធ្វើតាម ។ ត្រូវបវារណាបែបនេះតាមលំដាប់ វស្សាមួយអង្គម្តង ៗ រហូតគ្រប់អង្គ ។

បើមានភិក្ខុ ៤ អង្គក្តី ៣ អង្គក្តី នៅចាំវស្សាក្នុងអាវាសមួយ លុះពេលចេញវស្សា ត្រូវធ្វើបវារណាដល់គ្នានឹងគ្នាយ៉ាងនេះ : ត្រូវភិក្ខុដែលឈ្លាសប្រតិពលប្រកាសអោយភិក្ខុទាំងឡាយដឹងថា « *សុណន្តុ មេ អាយស្មន្តោ អជ្ជ បវារណា* ។ *យទាយ ស្មន្តានំ បត្តកល្លំ មយំ អញ្ញមញ្ញំ បវារេយ្យាម* = សូមលោកមានអាយុទាំងឡាយស្តាប់ខ្ញុំ ថ្ងៃនេះជាថ្ងៃបវារណា ។ បើបវារណា មានកាលគួរដល់លោកមានអាយុទាំងឡាយហើយ ត្រូវយើងទាំងឡាយបវារណាដល់គ្នានឹងគ្នា ។ បន្ទាប់មក ត្រូវភិក្ខុជាថេរៈ គ្រងចីពរ អង្គុយច្រហោង ផ្គងអញ្ជលីរួចនិយាយយ៉ាងនេះថា « *អហំ អាវុសោ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ* ។ *ទុតិយម្បិ អាវុសោ អាយស្មន្តេ បវារេមិ .... បដិករិស្សាមិ, តតិយម្បិ អាវុសោ អាយស្មន្តេ បវារេមិ .... បដិករិស្សាមិ* = ម្នាលអាវុសោ ខ្ញុំសូមបវារណានឹងលោកមានអាយុទាំងឡាយ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកមានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ ( ដាស់តឿន ) ចំពោះខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម, ម្នាលអាវុសោ ខ្ញុំសូមបវារណានឹងលោកមានអាយុទាំងឡាយជាគម្រប់ពីរដងផង .... នឹងធ្វើតាម, ម្នាលអាវុសោ ខ្ញុំសូមបវារណានឹងលោកមានអាយុទាំងឡាយជាគម្រប់បីដងផង .... នឹងធ្វើតាម ។ រួចមក ភិក្ខុខ្ចីវស្សាបន្តបន្ទាប់ ត្រូវនិយាយមួយអង្គម្តង១

រហូតដល់គ្រប់អង្គយ៉ាងនេះថា « *អហំ ភន្តេ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ ។ ទុតិយម្បិ ភន្តេ អាយស្មន្តេ បវារេមិ .... បដិករិស្សាមិ តតិយម្បិ ភន្តេ អាយស្មន្តេ បវារេមិ ..... បដិករិស្សាមិ* = បពិត្រលោកដ៏ចំរើន ខ្ញុំសូមបវារណានឹងលោកមានអាយុទាំងឡាយ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកមានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ ( ដាស់តឿន ) ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម, បពិត្រលោកដ៏ចំរើន ខ្ញុំសូមបវារណានឹងលោកមានអាយុទាំងឡាយជា គម្រប់ពីរដងផង ... នឹងធ្វើតាម, បពិត្រលោកដ៏ចំរើន ខ្ញុំសូមបវារណានឹងលោកមានអាយុទាំងឡាយជាគម្រប់បីដងផង .... នឹងធ្វើតាម ។

បើមានភិក្ខុពីរអង្គ នៅចាំវស្សាក្នុងអាវាសមួយជាមួយគ្នា លុះពេលចេញវស្សា ត្រូវបវារណាយ៉ាងនេះ គឺភិក្ខុដែលមានវស្សាចាស់ជាង ត្រូវគ្រងចីវរអង្គុយច្រហោង ផ្គងអញ្ជលីហើយនិយាយនឹងភិក្ខុខ្ចីវស្សាជាងថា « *អហំ អាវុសោ អាយស្មន្តំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទតុ មំ អាយស្មា អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ ។ ទុតិយម្បិ អាវុសោ អាយស្មន្តំ បវារេមិ ..... បដិករិស្សាមិ, តតិយម្បិ អាវុសោ អាយស្មន្តំ បវារេមិ .... បដិករិស្សាមិ* = ម្នាលអាវុសោ ខ្ញុំសូមបវារណានឹងលោកមានអាយុ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកមានអាយុ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ ( ដាស់តឿន ) ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម, ម្នាលអាវុសោ ខ្ញុំសូមបវារណានឹងលោកមានអាយុជាគម្រប់ពីរដងផង .... នឹងធ្វើតាម, ម្នាលអាវុសោ ខ្ញុំសូមបវារណានឹងលោកដ៏មានអាយុជាគម្រប់បីដងផង .... នឹងធ្វើតាម ។ រួចហើយ ភិក្ខុខ្ចីវស្សាត្រូវនិយាយនឹងភិក្ខុចាស់វស្សាថា « *អហំ ភន្តេ អាយស្មន្តំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទតុ មំ អាយស្មា អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ*។

*ទុតិយម្បិ ភន្តេ អាយស្មន្តំ បវារេមិ ... បដិករិស្សាមិ តតិយម្បិ ភន្តេ អាយស្មន្តំ បវារេមិ .... បដិករិស្សាមិ* = បពិត្រលោក ដ៏ចំរើន ខ្ញុំសូមបវារណា នឹងលោកដ៏ចំរើនដោយឃើញ ឮក្តី រង្កៀសក្តី សូមលោកមានអាយុ អាស្រ័យនូវសេចក្តីអនុគ្រោះនិយាយ ( ដាស់តឿន ) ខ្ញុំ កាលបើខ្ញុំឃើញនឹងធ្វើតាម, បពិត្រលោកដ៏ចំរើន ខ្ញុំសូមបវារណានឹងលោកមានអាយុជាគម្រប់ពីរដងផង ..... នឹងធ្វើតាម, បពិត្រលោកដ៏ចំរើន ខ្ញុំសូមបវារណានឹងលោកមានអាយុជាគម្រប់បីដងផង .... នឹងធ្វើតាម, ។

បើមានភិក្ខុតែមួយអង្គគត់ គង់ចាំវស្សាក្នុងអាវាសមួយ លុះដល់ថ្ងៃត្រូវបវារណាចេញវស្សា ត្រូវធ្វើយ៉ាងនេះ គឺបោសច្រាសសំអាតទីកន្លែងដែលខ្លួននៅចាំវស្សានោះ អោយស្អាតបាត ដងទឹកតម្កល់ទុក ក្រាលអាសនៈ អុជប្រទីបអង្គុយរង់ចាំមើល ក្រែងមានភិក្ខុពីអាវាសដទៃមកបវារណាជាមួយ ប៉ុន្តែបើរង់ចាំទៅហើយឃើញថាគ្មានទេ ត្រូវអធិដ្ឋានថា « អជ្ជ មេ បវារណា = ថ្ងៃនេះ ជាថ្ងៃបវារណារបស់អញ » តែប៉ុណ្ណេះជាការស្រេច ។ បើមិនបានអធិដ្ឋានបែបនេះទេ ត្រូវអាបត្តិទុក្កដ = នោ ចេ អធិដ្ឋហេយ្យ អាបត្តិ ទុក្កដស្ស ។

ពុទ្ធបំណងនៃការបវារណា គឺដើម្បីឱ្យព្រះសង្ឃស្រឡាញ់រាប់អានគ្នា ។ កាលបើអ្នកណាមួយបានឃើញ បានឮ ឬរង្កៀស អំពីការប្រព្រឹត្តខុសឆ្គងរបស់គ្នា ត្រូវរំឭកដាស់តឿនគ្នា ដើម្បីអោយប្រព្រឹត្តល្អស្មើគ្នា ជាព្រះសង្ឃដ៏ល្អនៅជាសុខរួមគ្នារហូតទៅ មិនត្រូវមើលបំណាំចាំតែចាប់ទោសកំហុសគ្នា ហើយបែរមុខចេញ មិនសេពគប់រាប់រកគ្នានោះឡើយ ព្រោះអាការដែលមើលបំណាំគ្នា ថ្កោលទោសគ្នាយ៉ាងនោះ ជាហេតុអោយព្រះសង្ឃមិនសាមគ្គីគ្នា ដែលមិនជាទីជ្រះថ្លាដល់ពួកពុទ្ធបរិស័ទជាហេតុធ្វើអោយពុទ្ធសាសនាថយចុះរោយរៀវផង ។

III . ពិធីផ្សេងៗ ក្នុងឱកាសចេញវស្សា

ថ្ងៃបវារណា ជាថ្ងៃបញ្ចប់កិច្ចនៅចាំវស្សារបស់ភិក្ខុសង្ឃ ដែលលោកអត់ទ្រាំមិនត្រាច់ទៅកាន់ទីឆ្ងាយ ខិតខំរៀនសូត្រស្វាធ្យាយធម៌វិន័យក្នុងគន្ថធុរៈ និងចំរើនមេត្តា ភាវនា ក្នុងវិបស្សនាធុរៈ ចំនួនបីខែកន្លងទៅ ។ ហេតុនេះហើយបានជាឧបាសក ឧបាសិកាជ្រះថ្លាខ្លាំងក្លានាំគ្នាធ្វើបុណ្យសុន្ទរ៍មានផ្សេងៗ ទុកដូចជាពិធីសម្ពោធឆ្លងបុណ្យចាំវស្សារបស់ព្រះសង្ឃ ។

តាមទំនៀម ពេលព្រឹក អ្នកស្រុកនាំគ្នាទៅវត្តដោយមានយកចង្ហាន់ទៅប្រគេនព្រះសង្ឃ ឧទ្ទិសកុសលជូនទៅលោកអ្នកមានគុណមានមាតាបិតាជាដើម ។ នៅតំបន់ខ្លះ ពុទ្ធបរិស័ទខ្មែរយើងបានប្រារព្ធពិធីមួយចំនួន ដើម្បីអបអរក្នុងឱកាសព្រះសង្ឃចេញវស្សាដែរ ដូចជា ៖

*១/ ពិធីទេសនាមហាជាតក៍* ៖ នៅថ្ងៃចេញវស្សានោះ, តាមទំនៀមប្រជារាស្ត្រអ្នកស្រុកដោយច្រើនធ្លាប់និមន្តលោកទេសនាគម្ពីរមហាជាតក គឺរឿងព្រះពោធិសត្វ កើតជាព្រះបាទវេស្សន្តរ ។ គេនាំគ្នាចាប់ស្លាកកាន់អង្គ តាំងពីថ្ងៃភ្ជុំបិណ្ឌមកម្ល៉េះ បើនរណាចាប់បានស្លាកឈ្មោះអង្គណា គេសំគាល់ព្រះសង្ឃអង្គនោះថាជាបដិគ្គាហកៈរបស់គេ ហើយម្នាក់ៗ ( ក្រុមវេន ឬភូមិនីមួយៗ ) ចាត់ចែងរណ្តាប់កាន់អង្គបំរុងចាំប្រគេន បដិគ្គាហកៈមួយអង្គៗនោះ ដោយទេយ្យទានយ៉ាងក្រាសក្រៃលប្លែកៗ ។ ចំណែក ព្រះធម្មកថិក ១៣ អង្គ អ្នកទេសនាមហាជាតក៍ ១៣ កណ្ឌតែងបានទទួលនូវទេយ្យទានជារណ្តាប់កាន់អង្គដោយឡែកៗ ពីគ្នា ។ ការចាប់ស្លាកកាន់អង្គធម្មកថិកទេសន៍មហាជាតក៍ដែលបានរៀបចំគ្រោងទុកជាមុននោះ គឺដើម្បីអោយធម្មកថិកដែលត្រូវទេសន៍កណ្ឌណាមួយ បានយកកណ្ឌនោះទៅហាត់ទេសន៍ទាល់តែស្ទាត់រត់មាត់ល្អ ទាំងបាលី ទាំងសំរាយ, ដល់ពេលឡើងទេសន៍អោយអាចទេសន៍បានស្រួលល្អ មិនរអាក់រអួលជាការស្រួលស្តាប់ផង អាចឱ្យចប់ទាំង ១៣ កណ្ឌ ក្នុង ១ ថ្ងៃ មុនថ្ងៃលិចផង ។ ឯព្រះមហាក្សត្រខ្មែរ ក៏ទ្រង់សព្វព្រះរាជហឫទ័យ

តែងនិមន្តធម្មកថិកមួយអង្គ ទេសនាគម្ពីរគាថាពាន់ គឺគម្ពីរមហាជាតក៍ភាសាបាលីដែលមានមួយពាន់គាថា ចែងអំពីរឿងព្រះវេស្សន្តរ មានលំនាំប្រហែលគ្នានឹងការទេសនាមហាជាតក៍របស់ប្រជារាស្ត្រដែរ គ្រាន់តែខាងព្រះរាជាទេសន៍ជាភាសាបាលី ( គឺគាថាទាំងមួយពាន់ក្នុងរឿងមហាវេស្សន្តរ ) មានសេចក្តីសង្ខេប ហៅថា « គាថា-ពាន់ » ។ ឯខាងរាស្ត្រទេសន៍ជាសម្រាយ ( មានលាយបាលីខ្លះៗ ) មានសេចក្តីពិស្តារ ហៅថា « មហាជាតក៍ » ប៉ុណ្ណោះ ។ ការទេសនាមហាជាតក៍ ជាការកុសលចេញមុខមាត់របស់ពុទ្ធបរិស័ទប្រកបដោយបរិយាកាសដ៏រីករាយ ក្នុងសម័យបុរាណ ។

*២/ ពិធីអុំទូក* : វត្តណានៅជិតមាត់ទន្លេ ស្ទឹង បឹង ព្រែក ដែលមានទូកង ឬទូកម្ហូងសំរាប់វត្តនោះ អ្នកស្រុកតែងតែធ្វើពិធីចែវ អុំប្រណាំងជាមួយនឹងទូកង ទូកម្ហូងវត្តក្បែរគ្នាក៏មាន, ចែវ អុំ ប្រណាំងតែគ្នាឯងក៏មាន ឬ ចែវ អុំកំសាន្តសប្បាយក៏មាន ។ ពិធីប្រណាំងទូកនេះ អ្នកស្រុកនិយមធ្វើនៅថ្ងៃ ១៥ កើត ខែ-អស្សុជដែលជាថ្ងៃព្រះសង្ឃត្រូវបវារណាចេញវស្សានោះដែរ ។

*៣/ ពិធីប្រណ្តែតប្រទីប* [១] : លុះដល់ម៉ោង ១៩ ឬ ម៉ោង ២០ គឺម៉ោង ៧ ឬ ម៉ោង ៨ យប់ បន្ទាប់ពេលព្រះសង្ឃសូត្របាលីបវារណាចប់ហើយ ឧបាសក ឧបាសិកា តែងរៀបពិធីបណ្តែតប្រទីបធ្វើពីដើមចេកធំៗដោតភ្ជាប់គ្នា មានសណ្ឋានដូចក្បូន មានទំហំជាងមួយម៉ែត្របួនជ្រុង ដែលយកឫស្សីធ្វើរាងជាចេតិយមានទ្វារបួន ស្រួចត្រង់កំពូលមានរាងជាកន្ទ្រាមតាឱ [២] បិទក្រដាសយ៉ាងស្អាត ។ ប្រទីបនេះ អ្នកស្រុកជើងវត្តរៀបចំធ្វើទុកស្រេចពីថ្ងៃមុន លុះដល់វេលាយប់ទើបគេនាំគ្នាសែងទៅដាក់ក្នុងទន្លេ ឬស្ទឹង បឹង ព្រែក ។ កាលណាដាក់ប្រទីបហើយ គេតែងដាក់នំអន្សម នំគម និងផ្លែឈើផ្សេងៗលើប្រទីបនោះ ហើយនាំគ្នា

(១) ពិធីបណ្តែតប្រទីបមាននិយាយពិស្តារក្នុងសៀវភៅរាជពិធីទ្វាទសមាសភាគទី៣ បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ។ (២) ភ្នំយោងមួយប្រភេទ មានកំពូលជាកន្ទ្រាម ប្រហាក់ប្រហែលនឹងសម្បុកតាឱ ។

អុជទៀនធូប អធិដ្ឋានថា « ខ្ញុំសូមបូជាប្រទីបនេះ ចំពោះព្រះចង្កូមកែវនៃព្រះសម្មាសម្ពុទ្ធ ដែលប្រតិស្ឋាននៅនាគពិភព និងស្នាមព្រះពុទ្ធបាទ ដែលប្រតិស្ឋាននៅទីទាំងប្រាំ មានស្ទឹងនម្មទា និងភ្នំសុមនកូដ នៅលង្កាទ្វីបជាដើម », ចំណែកអ្នកខ្លះទៀតតែងនិយាយសុំស្មាលាទោសនឹងព្រះគង្គា នឹងព្រះធរណី ..... តាមទម្លាប់របស់គេ ។ ចំពោះរបៀបធ្វើ និងរបៀបបណ្តែតប្រទីបនេះ មានលក្ខណៈប្លែកៗគ្នាទៅតាមការនិយមរបស់អ្នកស្រុក ។

- ស្រុកខ្លះ ចងគាបទូកធំៗភ្ជាប់គ្នា ក្រាលក្តារ ពីលើប្រក់បារាំ តែងតាំងព្រះពុទ្ធរូបក្នុងបារាំនោះ ដោយមានគ្រឿងសក្ការបូជាយ៉ាងឱឡារិក ប្រហែលគ្នានឹងរបៀបបុណ្យពុទ្ធាភិសេកដែរ សន្មតគ្រឿងទាំងអស់នោះជា « ប្រទីប » ដង្ហែទៅតាមទន្លេ ស្ទឹង បឹង ព្រែក ។

- ស្រុកខ្លះ យកទូកធំមួយសណ្តោងប្រទីបដើមចេកមួយធំ ដង្ហែទៅតាមទន្លេ ស្ទឹង បឹង ព្រែក ដែលមានទេសភាពគួរធ្វើបាន ។

ទោះបីចងគាបទូកធ្វើជាប្រទីបក្តី សណ្តោងប្រទីបដើមចេកដោយទូកក្តីក៏របៀបចាត់ការក្នុងពិធីបុណ្យបណ្តែតប្រទីបទាំងនោះមិនប្លែកគ្នាទេ គឺចំណែកបព្វជិតគង់លើទូកឃ្នាប ឬទូកសណ្តោងនោះ សូត្រធម៌ផ្សេងៗ មានធម៌សរសើរព្រះបាទឆ្វេង ស្តាំ និងធម៌ « ពហុំ ទេវា » ជាដើម, ចំណែកគ្រហស្ថ សូត្រធម៌ផ្សេងៗមានធម៌នមស្សការព្រះរតនត្រ័យជាដើម លើទូកនោះដែរ ។ ទីបំផុត គេសូត្រធម៌ « យំ កិញ្ចិ » ឧទ្ទិសផល ។

តាមទំនៀមអ្នកស្រុកដែលសណ្តោងប្រទីបដើមចេកដោយទូក, លុះសណ្តោងច្រាសទឹកទៅដល់ទីដៅហើយ គេតែងបណ្តែតប្រទីបដ៏មានពន្លឺព្រោងព្រាតនោះលើខ្សែទឹកហូរវិញៗ ក្រោមរស្មីព្រះចន្ទពេញវង់ ដែលមើលទៅឃើញមូលក្រឡង់សក្បុសលើរលកទឹក ហាក់ដូចព្រះចន្ទចុះមកថតយកប្រទីបនោះទុកជា

អនុស្សាវរីយ៍ ឬមកទទួលអនុមោទនាការកុសលនោះដោយរីករាយ ។

តាមទម្លាប់អ្នកស្រុកដែលសណ្ដែងប្រទីបដើមចេកដោយទូក, គេតែងធ្វើប្រទីបធំៗ មានរាងដូចចេតិយ ច្រើនថ្នាក់ និងធ្វើប្រទីបតូចៗ ជាច្រើនដោយស្រទបចេកអុជទៀនធូប ឬបញ្ឆេះប្រេងដូង បណ្ដែតជាបរិវារប្រទីបធំ មើលទៅឃើញព្រាតព្រោងលើផ្ទៃគង្គា គួរជាទីរីករាយជ្រះថ្លាក្រៃលែង ។

ពិធីអុំទូកនិងបណ្ដែតប្រទីបនោះ ចំពោះប្រជារាស្ត្រពុទ្ធបរិស័ទគ្រប់វត្តអារាមទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលមានលទ្ធភាពអាចធ្វើបាន តែងនិយមប្រព្រឹត្តទៅនៅវេលាថ្ងៃ និងវេលាយប់នៃថ្ងៃ ១៥ កើត ខែអស្សុជ ដែលជាថ្ងៃចេញវស្សា ។ ចំណែកខាងព្រះរាជា និង រាជរដ្ឋាភិបាល តែងនិយមប្រព្រឹត្តធ្វើពិធីអុំទូក បណ្ដែតប្រទីបចំនួនបីថ្ងៃ បីយប់ គឺនៅថ្ងៃ ១៤ . ១៥ កើត និងថ្ងៃ ១ រោចខែកត្តិក រួមជាមួយនឹងព្រះរាជពិធីសំពះព្រះខែ ។

ចំពោះទំនៀមអុំទូក បណ្ដែតប្រទីប ដែលប្រជារាស្ត្រពុទ្ធបរិស័ទក្នុងជំនាន់មុនៗ ធ្លាប់និយមប្រព្រឹត្តធ្វើនៅពេលព្រះសង្ឃចេញវស្សានោះ ឥឡូវបានសាបរលាបស្ទើរតែបាត់អស់ទៅហើយ គឺនៅសល់តែព្រះរាជពិធីអុំទូក បណ្ដែតប្រទីប និងអកអំបុក សំពះព្រះខែ ដែលជាបុណ្យប្រពៃណីផ្លូវការរបស់ជាតិយើងប៉ុណ្ណោះ ។

រៀបរៀងដោយ

**ម៉ែន ប្រាថ អាំ ឆន**

ពិនិត្យសំរួលដោយ **ឱម ខែម**

# កឋិនទាន

កឋិនទាន ជាផ្នែកមួយរបស់ចីវរទាន ប៉ុន្តែទាននេះមានលក្ខណៈពិសេសប្លែកពីចីវរទានធម្មតា ព្រោះអ្នកធ្វើនិងអ្នកទទួល ត្រូវគោរពឱ្យបានត្រឹមត្រូវតាមលក្ខខ័ណ្ឌមួយចំនួនដែលមានចែងក្នុងព្រះវិន័យ ។

## I. ប្រភពកឋិនទាន :

សម័យពុទ្ធកាល ពេលដែលព្រះសម្ពុទ្ធទើបបានត្រាស់ដឹងថ្មីៗ ទ្រង់អនុញ្ញាតឱ្យភិក្ខុសង្ឃប្រើប្រាស់តែសំពត់បង្សុកូល គឺសំពត់ឥតម្ចាស់ ដែលភិក្ខុរកបានពីព្រៃស្មសាន ឬពីគំនរសម្រាម ប៉ុន្តែក្រោយមកទើបទ្រង់អនុញ្ញាតឱ្យភិក្ខុអាចប្រើប្រាស់គហបតិចីវរ គឺសំពត់មានម្ចាស់ ដែលភិក្ខុបានមកដោយសារគេប្រគេន ។ ចាប់ពីពេលនេះហើយ ដែលកឋិនទានចាប់ផ្តើមមានកំណើតឡើង ។ ឯរឿងរ៉ាវដែលទាក់ទងដល់បញ្ហានេះ មានដំណើរសង្ខេបដូចតទៅ :

សម័យនោះ ព្រះដ៏មានព្រះភាគគង់ក្នុងវត្តជេតពន ជាអារាមរបស់អនាថ.បិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះ ពួកភិក្ខុនៅក្នុងដែនបាឋេយ្យ ប្រមាណ ៣០ រូប សុទ្ធតែជាអ្នកប្រព្រឹត្តនៅក្នុងព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រើប្រាស់សំពត់បង្សុកូល ជាអ្នកប្រព្រឹត្តប្រើតែចីវរ ៣ នាំគ្នាទៅកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះមានព្រះភាគ, កាលបើតិថីចូលវស្សាជិតណាស់មកហើយ ក៏មិនអាចនឹងទៅឱ្យទាន់ចូលវស្សា ក្នុងក្រុងសាវត្ថីបានឡើយ ហើយក៏នាំគ្នាចូលទៅចាំវស្សាក្នុងក្រុងសាកេត នាកណ្តាលផ្លូវ ។ ភិក្ខុទាំងនោះ នៅចាំវស្សាទាំងមានសេចក្តីអផ្សុកយ៉ាងខ្លាំង ព្រោះគិតថា ព្រះមានព្រះភាគគង់នៅក្នុងទីជិតយើងទាំងឡាយ ចម្ងាយ ៦ យោជន៍អំពីទីនេះ តែយើងទាំងឡាយមិនសមបើមិនបានទៅគាល់ព្រះអង្គសោះ ។

លុះភិក្ខុទាំងឡាយ នៅចាំវស្សាគ្រប់បីខែហើយ ក៏នាំគ្នាធ្វើបវារណាចេញវស្សា រួចធ្វើដំណើរតម្រង់ទៅកាន់ក្រុងសាវត្ថី ។ ដោយរដូវនោះ នៅមានភ្លៀងធ្លាក់ជោគជាំ មានទឹកភក់រអិលនៅឡើយ, ភិក្ខុទាំងនោះក៏មានចីវរទទឹកជោគ មានការលំបាក ប៉ុន្តែ តស៊ូធ្វើដំណើររហូតដល់វត្តជេតពន ដែលព្រះមានព្រះភាគគង់នៅ ។ ពេលចូលទៅដល់ ពួកភិក្ខុទាំងនោះក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លំដាប់នោះ ព្រះសាស្ដាមានព្រះបន្ទូលថា « ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នាល្មមអត់ទ្រាំបានទេឬ, អ្នករាល់គ្នាល្មមប្រព្រឹត្តទៅបានស្រួលទេឬ, អ្នកទាំងឡាយមានសាមគ្គីស្មោះសរ មិនវិវាទទាស់ទែងគ្នា នៅចាំវស្សាស្រួលបួល មិនលំបាកដោយអាហារបិណ្ឌបាតទេឬ ? ភិក្ខុទាំងនោះ ក៏ក្រាបទូលរៀបរាប់អំពីដំណើរដើមដានដែលខកមកចូលវស្សានៅក្នុងក្រុងសាវត្ថីជាមួយព្រះអង្គ និងពីសុខទុក្ខរបស់ខ្លួនក្នុងការនៅចាំវស្សាពាក់កណ្ដាលផ្លូវនោះ ព្រមទាំងទូលពីការលំបាកក្នុងការធ្វើដំណើរមកគាល់ព្រះអង្គនៅទីនេះ ។ ព្រះសាស្ដា លុះទ្រង់ព្រះសណ្ដាប់ហើយ ក៏ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយឱ្យមកជួបជុំគ្នា ហើយទ្រង់អនុញ្ញាតថា « *អនុជានាមិ ភិក្ខវេ វស្សំ វុត្ថានំ ភិក្ខូនំ កឋិនំ អត្ថរិតុំ ។ អត្ថតកឋិនានំ វោ ភិក្ខវេ បញ្ច កប្បិស្សន្តិ អនាមន្តចារោ អសមាទានចារោ គណភោជនំ យាវទត្ថចីវរំ យោ ច តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ* = ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុដែលបាននៅចាំវស្សារួចហើយក្រាលកឋិនបាន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយបានក្រាលកឋិន (១) ហើយ នឹងសំរេចអានិសង្ស ៥ យ៉ាងគឺ ត្រាច់ទៅណាមិនបាច់លាភិក្ខុផងគ្នា ១ ត្រាច់ទៅណាមិនបាច់យកត្រៃចីវរគ្រប់ប្រដាប់ ១ ឆាន់គណភោជនបាន ១ ទុកដាក់អតិរេកចីវរបានតាមត្រូវការ ១ ចីវរណា

(១) ក្រាលកឋិន = ប្រកាសអោយសង្ឃ ឲ្យគ្រប់រូបថាយកចីវរណា ( ស្បង់ចីពរ ឬសង្ឃាដី ) ជាកឋិន ។

ដែលកើតឡើងក្នុងអាវាសនោះ ចីវរនោះនឹងមានដល់ភិក្ខុទាំងនោះ ១ ។

ដោយសារមានពុទ្ធានុញ្ញាតនោះហើយ ទើបពុទ្ធបរិស័ទនាំគ្នាចាត់ចែងសំពត់ ឬចីវរ យកទៅវេរប្រគេនចំពោះសង្ឃដែលបានគង់ចាំវស្សាម៉ត់ចត់មិនដាច់ ដើម្បីអនុគ្រោះឱ្យព្រះសង្ឃមានចីវរប្រើប្រាស់ផង ដើម្បីឱ្យព្រះសង្ឃបានអានិ-សង្ស ៥ ប្រការផង ដើម្បីជាការកុសលផ្ទាល់ខ្លួនផង ។

## II . លក្ខខ័ណ្ឌបុណ្យកឋិនទាន

ដោយកឋិនជាទានពិសេសប្លែកពីទាននានា ឬ ចីវរទានធម្មតានោះ អ្នកធ្វើនិងភិក្ខុសង្ឃអ្នកទទួល ត្រូវគោរពដាច់ខាត និងម៉ឺងម៉ាត់បំផុតតាមលក្ខខ័ណ្ឌដែលមានចែងនៅក្នុងវិនយបញ្ញត្តិ ដូចតទៅ :

១- លក្ខខ័ណ្ឌសំរាប់អ្នកធ្វើ : អ្នកណាក៏អាចធ្វើកឋិនបាន ទោះជាមនុស្សក្តី ទេពតាក្តី អ្នកបួសក្តី គ្រហស្ថក្តី កាលណាដល់កឋិនកាល គឺរដូវកឋិនដែលមានរយៈកាល ២៩ ថ្ងៃ ដោយគិតពីថ្ងៃ ១ រោចខែអស្សុជដល់ ១៥ កើតខែកត្តិកហើយ អាចយកសំពត់ដែលល្មមកាត់ដេរធ្វើជាស្បង់ ឬចីពរ ឬក៏សង្ឃាដីបានទៅវេរចំពោះព្រះភិក្ខុសង្ឃដែលបានគង់ចាំវស្សាអស់ត្រីមាស ដោយពាក្យថា « *ឥមំ ទុស្សំ កឋិនំ សង្ឃស្ស ទេម* = យើងខ្ញុំសូមវេរសំពត់នេះ ចំពោះព្រះសង្ឃដើម្បីក្រាលកឋិន ប៉ុណ្ណេះជាការស្រេច ។ ប្រសិនបើ អ្នកចេះកាត់ដេរជ្រលក់ធ្វើជាស្បង់ ឬចីពរ ឬសង្ឃាដីឱ្យស្រេច ទើបយកទៅវេរចំពោះភិក្ខុសង្ឃដែលបានគង់ចាំវស្សាគ្រប់ត្រីមាសក្នុងវត្តណាមួយនោះដោយបញ្ចេញវាចាថា *ឥមំ កឋិនចីវរំ សង្ឃស្ស ទេម* = យើងខ្ញុំសូមវេរកឋិនចីវរនេះ ចំពោះព្រះសង្ឃ » ប៉ុណ្ណេះ ជាការស្រេច អ្នកនោះឈ្មោះថាបានធ្វើកឋិនហើយ ។

២- លក្ខខ័ណ្ឌសំរាប់អ្នកទទួល : ព្រះសង្ឃ ឬភិក្ខុ ជាអ្នកទទួល ឬជាអ្នកក្រាលកឋិន ត្រូវអនុវត្តឱ្យបានម៉ត់ចត់តាមលក្ខខ័ណ្ឌដែលមានចែងក្នុងវិនយបញ្ញត្តិ

ជាអាទិ៍ :

- សង្ឃអាចទទួលកឋិនបានតែក្នុងរដូវកឋិនកាល ។

- ភិក្ខុអ្នកបាននៅចាំវស្សាអស់ត្រីមាស ។

- សង្ឃអ្នកទទួល ត្រូវមានភិក្ខុចាប់ពី ៥ រូបឡើងទៅ ។

- បើគេប្រគេនជាសាច់សំពត់សុទ្ធ សង្ឃត្រូវយកទៅធ្វើឱ្យកើតជាស្បង់ ឬចីពរ ឬជាសង្ឃាដីត្រឹមត្រូវ ទើបយកទៅក្រាល ។

- ត្រូវធ្វើពិធីក្រាលកឋិនឱ្យចប់ក្នុងថ្ងៃដែលគេវេរប្រគេន គឺមិនត្រូវបង្អង់ពេល ឬពន្យារពេលឱ្យកន្លងរាត្រីបានឡើយ ។

- ភិក្ខុអ្នកក្រាលត្រូវចេះអានិសង្ស ៥ មាតិកា ៨ បលិពោធ ២ អនន្តាការៈ ២៤ អត្ថាការៈ ១៧ ។

- ភិក្ខុអ្នកក្រាលមានសិទ្ធិយកតែស្បង់ ១ ឬចីពរ ១ ឬសង្ឃាដី ១ ប៉ុណ្ណោះជាសំពត់អង្គកឋិន ( បរិក្ខារក្រៅពីនេះអាចទទួលបាន ប៉ុន្តែត្រូវចាត់ទុកជាអានិសង្សលាភ ឬជាបរិក្ខារបន្ទាប់បន្សំរបស់កឋិន ) ។

## III. កឋិនទាននៅកម្ពុជា

កឋិនទានក្នុងជំនាន់ពុទ្ធកាល ហាក់ដូចជាងាយនឹងធ្វើសោះ ទោះបីជនក្រីក្រ ខ្វះខាត ថ្នាក់ទាបបំផុតក៏ដោយ ឱ្យតែមានស្បង់ ១ ឬចីពរ ១ ឬសង្ឃាដី ១ ឬមានសំពត់ត្រឹមតែពីរ ឬបីម៉ែត្រ ក៏អាចយកទៅវេរចំពោះព្រះសង្ឃដែលគង់ចាំវស្សាអស់ត្រីមាសក្នុងវត្តណាមួយ ក៏ឈ្មោះថាជាអ្នកបានធ្វើកឋិនហើយ ប៉ុន្តែ បុណ្យកឋិនទាននៅកម្ពុជា លុះណាតែអ្នកមានស្តុកស្តម្ភ ឬគ្នាច្រើនទើបអាចធ្វើកឋិនកើត ព្រោះកឋិននៅកម្ពុជា ពុំមែនមានត្រឹមតែស្បង់ ១ ឬចីពរ ១ ឬសង្ឃាដី ១ ប៉ុណ្ណោះទេ គឺត្រូវមានបរិក្ខារដ៏ច្រើនផ្សេងៗទៀត ជាពិសេស បច្ច័យសង្កត់ព្រៃសំរាប់កសាងវត្តអារាម និងសមិទ្ធិសាធារណៈ មានសាលារៀន មន្ទីរពេទ្យ ជាដើម ។

១- គម្រោងបុណ្យកឋិនទាន ៖ កាលណាថ្ងៃបវារណាចេញវស្សារបស់ព្រះសង្ឃជិតមកដល់ ពុទ្ធបរិស័ទគ្រប់ជើងវត្តនានាក្នុងប្រទេសកម្ពុជាទាំងមូល តែងតែពិភាក្សាគ្នា ដើម្បីធ្វើកឋិនទានប្រគេនព្រះសង្ឃគ្រប់វត្តអារាមតាមស្ម័គ្ររៀងខ្លួន ដោយមានជំនឿជាប់មកជាទំនៀមថា កឋិនទាន ជាកាលទាន មានផលានិសង្សច្រើនជាងទានទាំងពួង គឺអ្នកធ្វើក៏បានអានិសង្ស អ្នកទទួលក៏បានអានិសង្ស ។ ជំនឿនេះបានចាក់ឫសជាប់នៅក្នុងចិត្តថ្លើមរបស់ពុទ្ធសាសនិកជនទូទាំងប្រទេស រហូតដល់សំគាល់វត្តដែលដល់រដូវកឋិនហើយ គ្មាននរណាហែកឋិនចូលជាវត្តមិនស្មើមុខនឹងវត្តដែលមាន ។ ដូច្នេះហើយបានជាវត្តណា ដែលគ្មានពុទ្ធបរិស័ទក្រៅជើងវត្តហែកឋិនចូល ពុទ្ធបរិស័ទជាចំណុះជើងវត្តនោះ តែងស្ទុះស្ទា អង្គាសគ្នាធ្វើទាល់តែកើតជាអង្គកឋិនទានឡើង មិនទុកឱ្យទំនេរឡើយ ។ បុណ្យកឋិននេះ មិនមែនត្រឹមតែជាទំនៀមទំលាប់របស់ប្រជារាស្ត្រប៉ុណ្ណោះទេ សូម្បីតែព្រះរាជា ព្រះរាជរដ្ឋាភិបាលកម្ពុជា ក៏តែងតែទ្រង់ធ្វើ និងចូលរួមពុំដែលអាក់ខានឆ្នាំណាឡើយ ។

អ្នកមានធនធានច្រើន ដែលមានបំណងនឹងធ្វើកឋិនដង្ហែទៅវេរប្រគេនព្រះសង្ឃក្នុងវត្តណាមួយ តែងតែសុំ ឬឱ្យដំណឹងទៅព្រះសង្ឃ ឬអាចារ្យវត្តនោះដឹងជាមុន ជាពិសេសតាំងពីក្នុងវស្សាម្ល៉េះ ថាខ្លួនហែកឋិនទានមកកាន់វត្តនោះនៅថ្ងៃនេះ ឬថ្ងៃនោះ ពុំខាន ។ ឯពុទ្ធបរិស័ទ ចំណុះជើងវត្តនីមួយៗ ក៏តែងតែទន្ទឹងរង់ចាំដំណឹងតាំងពីក្នុងវស្សាដែរ ថាតើវត្តរបស់ខ្លួនមានភ័ព្វវាសនា នឹងបានទទួលកឋិនទានរបស់លោកអ្នកណា ? កឋិនទាននោះឱឡារិក ធំដុំ ឬក៏តូចតាចល្មមទេ ?

២- រណ្តាប់កឋិនទាន ៖ បន្ទាប់ពីបានសំរេចថា នឹងរៀបចំធ្វើជាអង្គកឋិនហើយ អ្នកសាមីដើមទានតែងតែខ្វល់ខ្វាយពឹងពាក់លោកអាចារ្យ ឬព្រឹទ្ធាចារ្យ ដែលធ្លាប់យល់ដឹង ឬធ្លាប់មានពិសោធន៍ ក្នុងការរៀបគ្រឿងរណ្តាប់កឋិន ឱ្យជួយចាត់ចែងរៀបចំឱ្យបានត្រឹមត្រូវតាមទម្លាប់ និងក្រឹត្យក្រមព្រះវិន័យ ។

ទំនៀមរបស់ប្រជារាស្ត្រកម្ពុជា ក្នុងការរៀបរណ្តាប់អង្គកឋិនទានមាន ដូចខាងក្រោម ៖

. *រណ្តាប់អង្គកឋិន ១ សំរាប់ ៖* សំរាប់ប្រគេនព្រះថេរៈ ១ អង្គ ដែលក្រាលគ្រង គឺ ស្បង់ ១ ចីពរ ១ សង្ឃាដី ១ អង្សៈ ១ វត្តពន្ធចង្កេះ ១ វត្តពន្ធទ្រូង ១ និសីទនៈ ១ ឆ័ត្រ ១ បាត្រ ១ កំសៀវទឹក ១ កន្ទេល ១ ខ្នើយ ១ មុង ១ ភួយ ១ គ្រែ ១ ផ្នាំង ចាន ស្លាបព្រា ..... ។

. *រណ្តាប់ញត្តិ ឬរណ្តាប់សូត្រឆ្វេង . ស្តាំ ២ សំរាប់ ៖* សំរាប់ប្រគេនព្រះថេរៈ ២ អង្គ ដែលសូត្រញត្តិ គឺមានចីវរ ១ ល្បៀង ( ស្បង់ ១ ចីពរ ១ ) និងបរិក្ខារមួយចំនួនទៀត ..... ។

*រណ្តាប់បរិក្ខារច្រើនសំរាប់ ៖* សំរាប់ប្រគេនព្រះភិក្ខុសង្ឃបរិស័ទ ដែលគង់ហត្ថបាសអនុមោទនាកឋិន ។ រណ្តាប់នេះ គេនិយមរៀបធ្វើជាកញ្ចប់ ហើយក្នុងកញ្ចប់នេះមានជាអាទិ៍ ៖ ស្បង់ ឬសាដក ១ ទៀន ធូប តែ ស្ករ បារី ឈើគូស ច្រាសថ្នាំដុសធ្មេញ ថ្នាំពេទ្យ សាប៊ូ សៀវភៅ ប៊ិច ខ្មៅដៃ ( ប្រាក់ ) ... ។ រណ្តាប់នេះ គេអាចធ្វើឱ្យមានចំនួនច្រើន សំរាប់ប្រគេនសាមណេរផង ប្រសិនបើវត្តនោះមានសាមណេរ ។ ក្រៅពីរណ្តាប់ទាំងបីផ្នែកនេះ អ្នកសាមីដើមទាន តែងប្រកាសបវារ-ណានូវប្រាក់មួយចំនួនសំរាប់ប្រគេនព្រះសង្ឃផ្ទាល់ និងមួយចំនួនធំសំរាប់កសាងសមិទ្ធិផ្សេងៗ ដូចជា កុដិ វិហារ ស្រះ ខ្លោងទ្វារ របងវត្ត សាលារៀន មន្ទីរពេទ្យ .... ។ បណ្តាបរិក្ខារទាំងអស់នៃកឋិនទាន និយាយសរុបមានតែពីរយ៉ាង គឺស្បង់ ១ ឬចីពរ ១ ឬសង្ឃាដី ១ ប៉ុណ្ណោះ ជាកឋិនចីវរ គឺចីវរដែលភិក្ខុត្រូវក្រាល និងបរិក្ខារក្រៅពីនេះហៅថា អានិសង្សលាភ ។

*កម្មវិធីកឋិន ៖* បណ្តា ២៩ ថ្ងៃ គឺពីថ្ងៃ ១ រោច ខែអស្សុជ ដល់ថ្ងៃ ១៥ កើត ខែកត្តិក បើអ្នកសាមីដើមទានស្ម័គ្រថ្ងៃណាមួយហើយ គេតែងតែបោះជា

កម្មវិធីផ្សព្វផ្សាយចែកចាយដល់ញាតិ មិត្ត ជិតឆ្ងាយ ដើម្បីឱ្យចូលរួមក្នុងពិធីបុណ្យកឋិនរបស់គេ ។ សម័យបច្ចុប្បន្ន គេចូលចិត្តកំណត់កម្មវិធីនេះឱ្យត្រូវលើថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ គឺសូត្រមន្តថ្ងៃសៅរ៍ ដង្ហែថ្ងៃអាទិត្យ ។

ក/ ថ្ងៃសូត្រមន្ត ៖ ថ្ងៃសូត្រមន្តជាថ្ងៃទី ១ នៃពិធីបុណ្យកឋិនទាន ដែលគេនិយមធ្វើនៅវេលាល្ងាច ។ ល្ងាចនោះ នៅគេហដ្ឋានអ្នកសាមីដើមកឋិនទាន គេសង្កេតឃើញមាន ៖

. ពិធីទទួលបដិសណ្ឋារៈយ៉ាងអធិកអធមដោយភោជនាហារយ៉ាងពោរ-ពាស ចំពោះភ្ញៀវជិតឆ្ងាយ ដែលអញ្ជើញមកចូលបច្ច័យចាប់កុសលជាមួយ ។

. ពិធីចំរើនព្រះបរិត្ត និងសំដែងធម៌ទេសនា ។

. ជូនកាលមានសំដែងសិល្បៈ ជូនភ្ញៀវកំសាន្តផង ។

. នៅក្នុងវត្តដែលទទួលអង្គកឋិនទាន ក៏មានពិធីសូត្រមន្ត ទេសនាដែរ

ខ/ ថ្ងៃដង្ហែ ឬថ្ងៃចត ៖ ជាថ្ងៃទី ២ នៃកឋិនទាន ដែលគេនិយមធ្វើនៅពេលព្រឹក ។ ព្រឹកនេះ គេសង្កេតឃើញ ៖

. ការជួបជុំគ្នានៅផ្ទះអ្នកសាមីដើមទានឡើងរថយន្តចូលរួមដង្ហែអង្គកឋិនទានឆ្ពោះទៅកាន់វត្តដែលបានគ្រោងទុក ។

. ពេលដង្ហែ គេសង្កេតឃើញនៅជាប់នឹងមុខរថយន្ត នៃអង្គកឋិនមានចងបដាអក្សរធំៗ ថា « កឋិនទានដង្ហែទៅកាន់វត្ត ..... » ។

. នៅលើរថយន្ត មានក្រុមភ្លេងយ៉ាំ ឡកលេង ប្រគំកំដរ លាន់ឮរំពង រហូតដល់វត្ត ។

. នៅឯវត្តអារាមវិញ គេបានរៀបចំបោសច្រាសយ៉ាងស្អាតតុបតែងលំអដោយទង់ជ្វាលា ទង់ជាតិ ទង់សាសនា រំយោលផ្កាភ្ញីយ៉ាងល្អល្អះព្រោងព្រាត ។

. បន្ទាប់ពីប្រគេនភត្តាហារ និងពិធីទទួលអង្គកឋិន និងជូនភោជនាហារ

ចំពោះភ្ញៀវមកមានពិធីដង្ហែអង្គកឋិនប្រទក្សិណព្រះវិហារជាទក្ខិណាវ័តិ ( បត់ពីឆ្វេងទៅស្តាំ ) ដោយមានក្រុមផែយ៉ាំប្រគំឡកលេងរាំយោងមុខយ៉ាងក្រមិច ក្រមើមគួរសប្បាយរីករាយជ្រះថ្លា, បន្ទាប់មក មានលោកអាចារ្យនាំមុខអ្នកដើមទានទូលថ្មៃត្រធំ វណ្ឌាប់ស្ពូត្រឆ្វេង . ស្តាំ និងកាន់វណ្ឌាប់បរិក្ខារផ្សេងៗ ។ រួចហើយចូលទៅតំកល់ក្នុងកណ្តាលព្រះវិហារ ចំពោះព្រះភក្ត្រព្រះពុទ្ធបដិមា និងព្រះភិក្ខុសង្ឃ ។ ពេលនោះ មានពិធីនមស្សការព្រះរតនត្រ័យ សមាទានសីល ប្រកាសបច្ច័យសង្កត់ព្រៃវេរអង្គកឋិនចំពោះព្រះសង្ឃ ពិធីក្រាលកឋិន ព្រះសង្ឃស្វូត្រធម៌អនុមោទនាឱ្យពរសាធុការដល់សាមីដើមទាន និងសប្បុរសជនទាំងអស់ ។

៤–វិធីវេរអង្គកឋិន ៖ តាមទម្លាប់របស់លោកអាចារ្យដែលជាអ្នកតំណាងម្ចាស់កឋិន តែងវេរអង្គកឋិនចំពោះព្រះសង្ឃតាមវិធីពីរយ៉ាង ស្រេចហើយលើការចូលចិត្តរបស់ខ្លួន ៖

. *វិធីវេរបែបទី ១ :* បើគេយកសាច់សំពត់សុទ្ធមកវេរចំពោះព្រះសង្ឃដើម្បីក្រាលកឋិននោះ លោកអាចារ្យតែងវេរថា : « *នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ( បីចប់ )។ ឥមំ ទុស្សំ កឋិនំ សង្ឃស្ស ទេម, ទុតិយម្បិ ឥមំ .... ទេម, តតិយម្បិ ឥមំ .... ទេមំ* = យើងខ្ញុំទាំងឡាយ សូមវេរនូវសំពត់នេះដើម្បីកឋិនចំពោះព្រះសង្ឃ, អស់វារៈពីរដងផង អស់វារៈបីដងផង ។

. បើគេយកចីវរធ្វើស្រេចមកវេរចំពោះព្រះសង្ឃ ដើម្បីក្រាលកឋិននោះ លោកអាចារ្យតែងវេរថា : « *នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (បីចប់) ឥមំ កឋិនចីវរំ សង្ឃស្ស ទេម, ទុតិយម្បិ ឥមំ ... ទេម, តតិយម្បិ ឥមំ ... ទេម,* = យើងខ្ញុំទាំងឡាយ សូមវេរនូវកឋិនចីវរនេះចំពោះព្រះសង្ឃ អស់វារៈពីរដងផង អស់វារៈបីដងផង ។

. ប្រសិនបើមានបរិក្ខារផ្សេងៗ ក្រៅពីសំពត់កឋិន ឬកឋិនចីវរផងដែល

ហៅថាអានិសង្សលាភនោះ លោកអាចារ្យតែងវេរបន្ថែមទៀតថា « *យេនម្ហាកំ កឋិនំ គហិតំ កឋិនានិសំសានិ តស្សេវ ទេម, ទុតិយម្បិ យេនម្ហាកំ .... ទេម, តតិយម្បិ យេនម្ហាកំ .... ទេម* = រីកឋិននៃយើងខ្ញុំទាំងឡាយ គឺលោកម្ចាស់អង្គណាទទួលកាន់យក យើងខ្ញុំទាំងឡាយសូមវេរនូវបរិក្ខារទាំងឡាយជាអានិសង្សលាភ នៃកឋិនចំពោះលោកម្ចាស់អង្គនោះឯង ។ អស់វារៈពីរដងផង ។ អស់វារៈបីដងផង ។

. វិធីវេរបែបទី ២ : សម័យបច្ចុប្បន្ន លោកអាចារ្យគ្រប់វត្តនិយមវេរស្ទើរតែទូទៅថា : *នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (បីចប់) ។ មយំ ភន្តេ ឥមំ កឋិនចីវរំ សានិសំសំ សង្ឃស្ស ទេម កឋិនំ អត្ថរិតុំ សាធុ ភន្តេ សង្ឃោ ឥមំ កឋិនចីវរំ សានិសំសំ បដិគ្គណ្ហតុ កឋិនំ អត្ថរិតុំ មាតាបិតាទីនំ គុណវន្តានញ្ច អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ, ទុតិយម្បិ មយំ ភន្តេ .... ហិតាយ សុខាយ, តតិយម្បិ មយំ ភន្តេ .... ហិតាយ សុខាយ* = បពិត្រព្រះសង្ឃដ៏ចំរើន យើងខ្ញុំទាំងឡាយសូមវេរនូវកឋិនចីវរព្រមទាំងអានិសង្សលាភនេះចំពោះព្រះសង្ឃដើម្បីក្រាលកឋិន, បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃមេត្តាទទួលនូវកឋិនចីវរ ព្រមទាំងអានិសង្សលាភនេះ ដើម្បីក្រាលកឋិន, ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់លោកអ្នកមានគុណទាំងឡាយ មានមាតាបិតាជាដើម អស់កាលជាយូរអង្វែងទៅហោង អស់វារៈពីរដងផង អស់វារៈបីដងផង ។

៥- វិធីក្រាលកឋិន : ចំណែកព្រះសង្ឃ កាលបើបានទទួលកឋិនចីវរនោះដោយពិនិត្យពិច័យឃើញថាត្រឹមត្រូវតាមវិន័យសព្វគ្រប់ហើយ ក៏អប[១] លោកឱ្យភិក្ខុ ១ រូប ដែលជំនុំសង្ឃយល់ថាគួរក្រាលកឋិនបាន, រួចចាត់ភិក្ខុ ២ រូបសូត្រ

(១) អានថា = អៈ ប៉ះ ឡោក មានន័យថា " ប្រការពាក្យសុំសេចក្តីយល់ព្រមអំពីជំនុំ សង្ឃ ឬពីក្រុមជំនុំ ដើម្បីបង្វែរ ឬប្រគល់អ្វី១ អោយដល់អ្នកណាមួយ ។

ញត្តិជាភាសាបាលីប្រគល់ចីវរនោះ ដែលមានលំដាប់លំដោយដូចតទៅ :

. ដំបូង ភិក្ខុ ១ រូបដែលហៅថា « សូត្រឆ្វេង » ចាប់ផ្ដើមក្រើនកឋិន ដោយពាក្យថា « ភន្តេ បពិត្រព្រះគម្ដែងសង្ឃដ៏ចំរើន វិរអង្គកឋិនទាននេះ ជារបស់លោក ( ... ) និង ( ... ) សុទ្ធសឹងជាពុទ្ធមាមកជនប្រកបដោយបសាទស្បទ្ធា និងកុសលចេតនា ជាអសង្ខារិក ជ្រះថ្លាចំពោះគុណព្រះរតនត្រ័យ បានបំពេញនូវបុញ្ញកិរិយាវត្ថុចេះលៃលកយកធនធានដែលគ្មានខ្លឹមសារ ធ្វើឱ្យជារបស់មានខ្លឹមសារកប់ទុកក្នុងព្រះពុទ្ធសាសនា ដើម្បីជាទ្រព្យមតិកសំរាប់ប្រើប្រាស់ទៅក្នុងភពខាងមុខទៀត បានស្រុះស្រួលបបួលគ្នាផ្ដួចផ្ដើមបង្កើតជាអង្គកឋិនទាននេះឡើង ដើម្បីយកមកវេរថ្វាយភិក្ខុសង្ឃដែលគង់ចាំវស្សាអស់ត្រីមាសក្នុងទីវត្ត ( .... ) នេះ ។ ដូច្នេះសំពត់កឋិននេះហាក់ដូចជាសំពត់ទិព្វកោសេយ្យពស្ត្រ អណ្ដែតត្រសែតឰដ៏អាកាសវេហាស៍នភាល័យ ហើយធ្លាក់ចុះមកក្នុងកណ្ដាលជំនុំសង្ឃ ជាសង្ឃទានដ៏ស្មោះឥតចំពោះព្រះករុណាអង្គណាមួយឡើយ ។ ហេតុនេះហើយ បើព្រះករុណាអង្គណាមានត្រៃចីវរទុព្វលភាពដាច់ដាចមិនអាចប្រើប្រាស់បាន ហើយចេះនូវអានិសង្ស ៥[១] មាតិកា៨ បលិពោធ២ អនន្តរាការៈ ២៤ អត្ថតាការៈ ១៧ អាចញ៉ាំងសង្ឃឱ្យក្រែកអរដោយកឋិនត្ថារកិច្ចបាន ក៏សូមមានព្រះពុទ្ធដីកាឆ្លើយមកចុះ ព្រះសង្ឃនឹងអបលោកសំពត់កឋិននេះ ដល់ព្រះករុណាអង្គនោះដោយញត្តិទុតិយកម្មវាចាក្រាលគ្រងតទៅ ។ ( ពេលដែលភិក្ខុរូបនេះ ប្រកាសចប់ ត្រូវឈប់បង្អង់ ២ ឬ ៣ នាទី ដើម្បីរង់ចាំមើលក្រែងមានភិក្ខុរូបណាដែលមានចីវរដាច់ដាច ឆ្លើយថាខ្លួនចង់ក្រាលកឋិននេះ ) ។

. បើគ្មានភិក្ខុរូបណាមួយ ឆ្លើយថាខ្លួនសុំក្រាលកឋិននេះទេ ភិក្ខុ ១ រូបទៀតដែលហៅថា « សូត្រស្ដាំ » ត្រូវប្រកាសក្រើនកឋិនដោយពាក្យថា « ភន្តេ បពិត្រព្រះគម្ដែងសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាជាអ្នកតំណាងសង្ឃគ្រប់អង្គ ក្នុងឱកាស

(១) មាននិយាយពិស្ដារនៅក្នុងវិន័យបិដកភាគទី ៨

នេះ សូមពិតព្រះពុទ្ធដីកាចំពោះព្រះសង្ឃគ្រប់អង្គ សូមទានជ្រាប ។ យើងខ្ញុំទាំងអស់សុទ្ធសឹងតែមានចីវរល្មមគ្រប់គ្រាន់ប្រើប្រាស់ហើយ ប៉ុន្តែតាមយោបល់របស់ខ្ញុំព្រះករុណាយល់ឃើញថា មានតែព្រះតេជគុណ ( .... ) អង្គនេះ ទើបសមគួរនឹងក្រាលគ្រងនូវសំពត់កឋិននេះ ព្រោះលោកជាអ្នកចេះនូវអានិសង្ស ៥ ចាំនូវមាតិកា៨ បលិ-ពោធ ២ អនន្តាការៈ ២៤ អត្ថាការៈ ១៧ ហើយឆ្លៀវឆ្លាសក្នុងកឋិនត្ថារកិច្ចអាចញុំាងសង្ឃឱ្យត្រេកអរបាន ។ ហេតុនេះ បើព្រះសង្ឃគ្រប់អង្គយល់ឃើញថាសមគួរដូចជាបកាសនវាចា ដែលខ្ញុំព្រះករុណាបានថ្លែងមកនេះ ក៏សូមបញ្ចេញនូវសញ្ញាថា សាធុ ឱ្យព្រមៗ គ្រប់អង្គទៅហោង ។ ( ពេលនោះ ជំនុំសង្ឃក៏ទទួលព្រមៗគ្នាថា « សាធុ » ។

- បន្ទាប់មក លោកអ្នកសូត្រទាំងពីររូប អង្គុយច្រហោងទឹមគ្នាលើកដៃប្រណម្យឆ្ពោះទៅរកភិក្ខុដែលត្រូវក្រាលគ្រង ដោយសូត្របាលី ញត្តិទុតិយកម្មវាចាថា «[(១)] *សុណាតុ មេ ភន្តេ សង្ឃោ ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥមំ កឋិនទុស្សំ ( ឥត្ថន្នាមស្ស )*[(២)] *ភិក្ខុនោ ទទេយ្យ កឋិនំ អត្ថរិតុំ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ ។ សង្ឃោ ឥមំ កឋិនទុស្សំ (ឥត្ថន្នាមស្ស) ភិក្ខុនោ ទេតិ កឋិនំ អត្ថរិតុំ ។ យស្សាយស្មតោ ខមតិ ឥមស្ស កឋិនទុស្សស្ស ( ឥត្ថន្នាមស្ស ) ភិក្ខុនោ ទានំ កឋិនំ អត្ថរិតុំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នំ ឥទំ សង្ឃេន កឋិនទុស្សំ ( ឥត្ថន្នាមស្ស ) ភិក្ខុនោ កឋិនំ អត្ថរិតុំ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ* = បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ដ្បិតសំពត់កឋិននេះកើតឡើងដល់សង្ឃហើយ ។ បើកម្មមានកាល

(១) វិន័យបិដកភាគទី ៨ ទំព័រ ៤

(២) គ្រប់បទថា ( ឥត្ថន្នាមស្ស ) ត្រូវដាក់ឈ្មោះភិក្ខុអ្នកក្រាលកឋិន

គួរដល់សង្ឃហើយ គួរសង្ឃឱ្យសំពត់កឋិននេះដល់ភិក្ខុ ( ឈ្មោះនេះ ) ដើម្បីនឹងក្រាលកឋិន ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ ដ្បិតសំពត់កឋិននេះកើតឡើងដល់សង្ឃហើយ ។ ឥឡូវ សង្ឃឱ្យសំពត់កឋិននេះដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីនឹងក្រាលកឋិន ។ការឱ្យសំពត់កឋិននេះដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីនឹងក្រាលកឋិន បើគួរដល់លោកមានអាយុអង្គណា ត្រូវលោកមានអាយុអង្គនោះស្ងៀម បើមិនគួរដល់លោកមានអាយុអង្គណាទេ ត្រូវលោកមានអាយុអង្គនោះនិយាយឡើង ។ សំពត់កឋិននេះ សង្ឃឱ្យដល់ភិក្ខុឈ្មោះនេះ ដើម្បីនឹងក្រាលកឋិនហើយ ។ ការឱ្យសំពត់កឋិននេះគួរដល់សង្ឃហើយ ព្រោះហេតុនេះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវការនេះដោយអាការៈស្ងៀមនៅយ៉ាងនេះ ។

- ភិក្ខុអ្នកក្រាល ត្រូវសូត្របាលីដកសង្ឃាដី ចីពរ ស្បង់ចាស់ចេញថា « *ឥមំ សង្ឃាដឹ បច្ចុទ្ធរាមិ* = អាត្មាអញដកនូវសង្ឃាដីនេះ ។ *ឥមំ ឧត្តរាសង្គំ បច្ចុទ្ធរាមិ* = អាត្មាអញដកនូវចីពរនេះ ។ *ឥមំ អន្តរវាសកំ បច្ចុទ្ធរាមិ* = អាត្មាអញដកនូវស្បង់នេះ » ។

- ភិក្ខុអ្នកក្រាល ត្រូវយកខ្មៅដៃធ្វើកប្បពិន្ទុត្រង់មុមចីវរ ដែលបំរុងក្រាល ( គឺធ្វើជាចំណុចមួយមូលដូចជារាងកូនឃ្លី ) ដោយបាលីថា « *ឥមំ ពិន្ទុកប្បំ ករោមិ* = អាត្មាអញធ្វើនូវពិន្ទុកប្បនេះ » ។

- ភិក្ខុអ្នកក្រាលត្រូវអធិដ្ឋានចីវរថ្មីថា « *ឥមំ អន្តរវាសកំ អធិដ្ឋាមិ ។ ទុតិយម្បិ ... តតិយម្បិ ...* = អាត្មាអញអធិដ្ឋាននូវស្បង់នេះ អស់វារៈពីដងផង, អស់វារៈបីដងផង ។ *ឥមំ ឧត្តរាសង្គំ អធិដ្ឋាមិ, ទុតិយម្បិ ..., តតិយម្បិ ...* អាត្មាអញអធិដ្ឋាននូវចីវរនេះ អស់វារៈពីរដងផង, អស់វារៈបីដងផង ។ *ឥមំ សង្ឃាដឹ អធិដ្ឋាមិ ទុតិយម្បិ ... តតិយម្បិ ...* = អាត្មាអញអធិដ្ឋាននូវសង្ឃាដីនេះអស់វារៈពីរដងផងអស់វារៈបីដងផង ។

- ភិក្ខុអ្នកក្រាល ត្រូវដោះសង្ឃដីចាស់ ចីពរចាស់ ស្បង់ចាស់ចេញ ហើយទ្រង់[១] ស្បង់ថ្មី ចីពរថ្មី សង្ឃាដីថ្មី រួចគង់បត់ព្រះបាទលើកព្រះហស្តសំពះជំនុំសង្ឃ១ សំពះតបវិញ ហើយប្រកាសប្រាប់ជំនុំសង្ឃថា « *ឥមាយ សង្ឃាដិយា កឋិនំ អត្ថរាមិ* = ខ្ញុំក្រាលកឋិនដោយសង្ឃាដីនេះ (បើចង់យកសង្ឃាដីជាសំពត់កឋិន) ។ *ឥមិនា ឧត្តរាសង្គេន កឋិនំ អត្ថរាមិ* = ខ្ញុំក្រាលកឋិនដោយចីពរនេះ (បើចង់យកចីពរជាសំពត់កឋិន ) ។ *ឥមិនា អន្តរវាសកេន កឋិនំ អត្ថរាមិ* = ខ្ញុំក្រាលកឋិនដោយស្បង់នេះ ( បើចង់យកស្បង់ជាសំពត់កឋិន ) ។

- ភិក្ខុអ្នកក្រាលត្រូវអង្គុយច្រហោង ប្រណម្យអញ្ជលីឆ្ពោះទៅរកសង្ឃ ឬគណៈ ឬបុគ្គល ( ដែលបានគង់ចាំវស្សាជាមួយគ្នា ) ហើយពោលថា « *អត្ថតំ អាវុសោ*[២] *សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទថ (អនុមោទាហិ)* ម្នាលអាវុសោ កឋិនរបស់សង្ឃ ខ្ញុំក្រាលហើយ ការក្រាលកឋិន ( នេះ ) ប្រកបដោយធម៌ សូមលោកទាំងឡាយអនុមោទនាចុះ ។

- ភិក្ខុអ្នកអនុមោទនា ត្រូវអង្គុយច្រហោង ប្រណម្យអញ្ជលីពោលថា « អត្ថតំ ភន្តេ សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទាម បពិត្រលោកម្ចាស់ដ៏ចំរើន កឋិនរបស់សង្ឃ លោកក្រាលរួចហើយ, ការក្រាលកឋិន ( នេះ ) ប្រកបដោយធម៌ យើងសូមអនុមោទនា » ។

លុះចប់ពិធីក្រាលនេះហើយ ព្រះសង្ឃក៏សូត្រធម៌ប្រសិទ្ធិពរជូនសាមីដើមទាន និងសប្បុរសជនទាំងអស់ ។ លោកអាចារ្យ ក៏នាំសូត្រធម៌ យំ កិញ្ចិ ..... ឧទ្ទិសកុសលជូនចំពោះបុព្វការីជន ដែលបានធ្វើមរណកាលទៅហើយ ជាកិច្ចបញ្ចប់ពិធីបុណ្យកឋិនទានរបស់ខ្លួន ក្នុងបរិយាកាសសប្បាយរីករាយ និងមនោសញ្ចេតនា

(១) ស្លៀកពាក់

(២) បើមានអ្នកអនុមោទនាចាស់វស្សាជាង ភិក្ខុអ្នកក្រាលត្រូវពោលថា « ភន្តេ » វិញ ។

ជ្រះថ្លាឥតឧបមា ។

## IV . សេចក្តីសន្និដ្ឋាន

កឋិន ជាពិធីជូនរង្វាន់ ឬផ្តល់សិទ្ធិពិសេស លើកទឹកចិត្តចំពោះភិក្ខុសង្ឃ ដែលបានខិតខំយកចិត្តទុកដាក់រៀនសូត្រប្រតិបត្តិធម៌វិន័យ ទ្រាំទ្រការលំបាកផ្សេងៗ អស់ថេរវេលាបីខែក្នុងរដូវវស្សា ។ ភិក្ខុសង្ឃដែលបានសំរេចទិសដៅគ្រប់ផែនការ នៃការចាំវស្សា អាចមានសិទ្ធិក្រាលកឋិន និងអនុមោទនាកឋិនបាន ។ កាលបើបាន ទទួលកឋិនហើយ នឹងបានអានិសង្ស គឺសិទ្ធិ ឬផលប្រយោជន៍ ៥ យ៉ាងអស់រយៈ កាល ៤ ខែ គឺពីថ្ងៃទទួលកឋិន រហូតដល់ថ្ងៃ ១៥ កើត ខែផល្គុណ ។ ដោយឡែក កឋិនទាននេះ ពុំមែនជាចលនាសកម្មស្ថិតនៅតែក្នុងក្របខ័ណ្ឌ និងបំរើតែផល ប្រយោជន៍ខាងផ្នែកពុទ្ធសាសនាប៉ុណ្ណោះទេ តាមពិត កឋិនទានបានក្លាយជាចលនា សកម្មរបស់សង្គមកម្ពុជាទាំងមូល និងបំរើសំណូមពរធំធេងជាក់ស្តែងរបស់ប្រជា-រាស្ត្រកម្ពុជាទូទាំងប្រទេសចូលជ្រៅក្នុងកិច្ចកសាង និងអភិវឌ្ឍន៍ប្រទេសជាតិតាំងពី បុរាណកាល រហូតមកដល់បច្ចុប្បន្នកាលនេះ ។

រៀបរៀងដោយ

**ម៉ែន ប្រាជ្ញ អាំ ឆន**

ពិនិត្យសម្រួលដោយ **ឱម ខែម**

# សិលាចារឹក ជាប្រភពនៃការសិក្សាអក្សរសាស្ត្រ និង ប្រវត្តិសាស្ត្រ នៃប្រទេសកម្ពុជា

តាមចំនួន និងបរិមាណ សិលាចារឹកប្រទេសកម្ពុជាជាមរតកនៃសិលាចារឹកសំខាន់និងប្រកបដោយសំបូរភាពជាងគេមួយនៅលើពិភពលោក ប្រសិនបើប្រៀបធៀបសិលាចារឹកកម្ពុជាទៅនឹងបណ្តាឯកសារសិលាចារឹកនៃប្រទេសដទៃទៀត ។

នៅក្នុងបញ្ជិកាដ៏ធំមួយ រៀបចំដោយសាស្ត្រាចារ្យ ហ្សកឺ សឺដេស ( Georges Coedès, Inscriptions du Cambodge, Vol. XVIII, Paris 1966, Pages 73 - 255 ) គេប្រទះឃើញមានសិលាចារឹកកម្ពុជាទាំងអស់ចំនួន ១.00៥ ។ នៅឆ្នាំ ១៩៧១ លោកសាស្ត្រាចារ្យ ក្លូដហ្សាក់ ( បន្តពីលោក ហ្សកឺ សឺដេស ) ដែលជាអ្នកស្រាវជ្រាវសិលាចារឹកកម្ពុជាមួយរូប បានចុះផ្សាយក្នុងអត្ថបទរបស់លោកថា គេបានរកឃើញសិលាចារឹកចំនួន ៩៥ ទៀត ( Claude Jacques, Supplément au tome VIII des Inscriptions, Cambodge BEFEO, t.LVIII, 1971 ) ហើយនៅឆ្នាំ ១៩៨៨ លោកបានបញ្ជាក់បន្ថែមក្នុងអត្ថបទថ្មីមួយទៀតថា សិលាចារឹកប្រទេសកម្ពុជា មានចំនួនទាំងអស់ ១១៥០ ( Claude Jacques, enrevue « Dossiers, Histoire et Archéologie » , No 125, Paris 1988 ) ។ ជាលើកទីមួយ អ្នកប្រាជ្ញជាតិហុឡង់មួយរូបនាម ហេនរិច គែន ( Heinrich Kern ) បានបោះពុម្ពផ្សាយអំពីអត្ថបទសិលាចារឹកខ្លះស្តីពីកម្ពុជា នៅឆ្នាំ ១៨៧៣ ។ បន្ទាប់ពីការបោះពុម្ពផ្សាយសិលាចារឹកកម្ពុជា ដោយអ្នកប្រាជ្ញបារាំងខាងភាសាសំស្ក្រឹត នាម អូហ្គូស្ត បាថ ( Auguste Bath ) និង

អាបែល ប៊ែរហ្គេញ ( Abel Bergaigne ) និងដោយលោក អៃម៉ូនីយេរ ( M. Aymonier ) ដោយលោក ដឺឡាហ្សុងគីយែរ ( Lunet de Lajonquière, Inventaire descriptif des monuments du Cambodge, 3Vol, Paris 1902-1911 ) ព្រមទាំងដោយសារការប្រឹងប្រែងឥតសំចៃកម្លាំងពីសំណាក់សាលាបារាំងខាងចុងបូព៌ា (Ecole Française d'Extrême-Orient) ចំនួនសិលាចារឹកប្រទេសកម្ពុជា ដែលគេបានរកឃើញ និងបោះពុម្ពផ្សាយ ក៏កាន់តែល្ហូតលាស់ជាអចិន្ត្រៃយ៍ រហូតមកដល់សព្វថ្ងៃ ។ នាសម័យបច្ចុប្បន្ន ការងារស្រាវជ្រាវ និង បោះពុម្ពផ្សាយសិលាចារឹក ដែលគេបានរកឃើញថ្មីៗ កំពុងប្រព្រឹត្តទៅនៅប្រទេសកម្ពុជា ប្រទេសបារាំង ប្រទេសថៃឡង់ ។

សម័យកាលនៃបុរាណសិលាចារឹកកម្ពុជា គឺលាតសន្ធឹងតាំងពីសតវត្សទី៦ ដល់ទី ១៤ នៃ គ.ស បានសេចក្ដីថា ចាប់ផ្ដើមតាំងពីសម័យកាលនៃរាជាណាចក្រនគរភ្នំ ឬ ហ្វូណន ( គឺជាឈ្មោះដើមនៃប្រទេសកម្ពុជា ) រហូតដល់សម័យកាលខាងចុងនៃចក្រភព « កម្ពុជទេស » ( Kambujadeça ) ។

សិលាចារឹកចាស់ជាងគេ សរសេរជាភាសាខ្មែរ គឺសិលាចារឹកអង្គរបូរិ ( K600 ) ដែលមានដាក់កាលបរិច្ឆេទឆ្នាំ ៥៣៣ ស័ករាជត្រូវគ្នានឹង ឆ្នាំ ៦១១ គ.ស ។ ក្រៅពីនេះ សិលាចារឹកមួយចំនួននៅអង្គរបូរិ ដូចជាសិលាចារឹកវត្តថ្លែង (ក្រូសាំងស៊ីន ) K1, សិលាចារឹកវត្តពោធិវង្សលើ ( កូសាំងស៊ីន ) K11, សិលាចារឹកអង្គរបូរិ K25, សិលាចារឹកព្រះវិហារធំ ( កំពង់ចាម ) K520, សិលាចារឹកទួលវត្តគំនូរ ( តាកែវ ) K557, សិលាចារឹកទួលអង្គ ( តាកែវ ) K559 ដែលបានបាត់កាលបរិច្ឆេទ មានអក្ខរាវិរុទ្ធចាស់បុរាណជាងសិលាចារឹក K600 ទៅទៀត ។ គឺនៅលើមូលដ្ឋាននៃអក្ខរាវិរុទ្ធនេះហើយ ដែលគេអាចសន្និដ្ឋានបានថា សិលាចារឹកជាភាសាខ្មែរ បានត្រូវចារឡើងនៅសតវត្សទី ៦ ។

តាមគំនូសផែនទីផ្សេងៗ រៀបចំឡើងដោយលោក ហង់រី ប៉ារម៉ង់ទីយេរ ( Henri Parmentier, - " Cartes de l'Empire Khmer d' après la situation des inscriptions datées " BEFEO, t. XVI, 3, 1916 ) ដែលមានឈ្មោះថា « ផែនទីនៃចក្រភពខ្មែរ រៀបចំឡើងតាមទីកន្លែងនៃសិលាចារឹកមានកាលបរិច្ឆេទ » ។ គេអាចឃើញថា ទឹកដីគ្របដណ្តប់ដោយសិលាចារឹក សរសេរជាភាសាខ្មែរ និងសំស្ក្រឹត មានទំហំធំធេង ។ ទឹកដីនេះលាតសន្ធឹងលើប្រទេសកម្ពុជាបច្ចុប្បន្នលើកូសាំងស៊ីន លើប្រទេសសៀមប៉ែកបូព៌ា លើប្រទេសឡាវ ប៉ែកខាងទក្សិណាគឺជាទឹកដីដែលបានមានឯកភាពខាងនយោបាយ និងវប្បធម៌ ។ គ្រាន់តែនៅសម័យសតវត្សទី ៧ គឺសម័យកាលខាងក្រោយនៃនគរភ្នំ សិលាចារឹកចំនួន ២៣០ បានត្រូវគេរកឃើញនៅប្រទេសកម្ពុជា ហើយសិលាចារឹកចំនួន ៥៥ បានត្រូវគេរកឃើញនៅប្រទេសជិតខាងទាំងបី ។ គ្រាន់តែនៅប្រទេសសៀម សិលាចារឹកកម្ពុជានាសតវត្សទី ៧ បានត្រូវគេរកឃើញនៅទីក្រុង និងខេត្តឆ្ងាយៗ ដូចជាខេត្តពិស្ណុ-លោក ស៊ីទេព អាយុធ្យា ជាដើម ។ តាមភស្តុតាងនៃសិលាចារឹកនាសតវត្សទី ៧ ដែលគេបានរកឃើញទាំងនៅប្រទេសកម្ពុជា ទាំងនៅប្រទេសដទៃ ដូចជានៅខេត្តប្រាចិនបុរី នៅប្រទេសថៃឡង់ ( K506 ) នៅខេត្តសាដែក ក្នុងដែនកូសាំងស៊ីន ( K9 ), គេអាចយល់ថា នៅសតវត្សទី ៧ ភាសាខ្មែរត្រូវបានប្រើប្រាស់ក្នុងលក្ខណៈនៃភាសា សរសេរនៅលើទឹកដីដ៏ទូលំទូលាយដោយអ្នកស្រុកផង ដោយមជ្ឈដ្ឋានរាជការផង ។

សិលាចារឹកទាំងឡាយ គឺជាអត្ថបទមានលក្ខណៈប្រវត្តិកថា ( historiographiques ) ឧទ្ទិសកថា ( commémoratifs ) ពណ៌នាកថា ( narratifs ) ឬ មានលក្ខណៈជាអត្ថបទរដ្ឋការ ( administratifs ) ជាអត្ថបទបញ្ជីកាស្តីអំពីនរនាម និង ស្ថាននាម ( répertores des anthroponymes et topo-

nymes ), គឺជាអត្ថបទដែលគេចារនៅតាមសរសរស្តម្ភដាក់នៅចំពីមុខព្រះវិហារ ឬ ប្រាសាទ លើទ្វារចូល លើជញ្ជាំងថ្ម លើសិលាស្តម្ភ ។ គឺជាសិលាចារឹកសរសេរជាភាសាខ្មែរ ឬ ជាភាសាសំស្ក្រឹត ឬ មួយសរសេរជាភាសាទាំងពីរតែម្តង ។ ប៉ុន្តែ ទោះបីដូចនេះក្តី មិនមែនមានន័យថា ជាសិលាចារឹកទ្វេភាសាទេ ព្រោះថាអត្ថបទជាភាសាសំស្ក្រឹត និងភាសាខ្មែររៀបរាប់អំពីបញ្ហាខុសៗគ្នា ឬ ក៏បំពេញន័យដែលមានការខ្វះខាតនៅក្នុងអត្ថបទមួយទៀត ។ អក្ខរវិធីដែលគេប្រើប្រាស់សំរាប់សរសេរអត្ថបទសិលាចារឹកជាភាសាខ្មែរ គ្មានលក្ខណៈខុសគ្នាអ្វីពីសិលាចារឹកជាភាសាសំស្ក្រឹតនោះឡើយ ។ គឺជាអក្ខរវិធី មានកំណើតពីប្រព័ន្ធអក្សរព្រហ្មី ( brahmi ) ដែលមានន័យថា « អក្សរបង្កើតដោយព្រះព្រហ្ម » ។ មានសិលាចារឹកខ្លះជាពិសេសនាសម័យអង្គរ ត្រូវបានគេចារតាមអក្ខរវិធីពីររបៀប ( digraphiques ) គឺអត្ថបទមួយប្រើអក្សរព្រហ្មី តាមបែបខ្មែរ និង អត្ថបទដដែលមួយទៀតប្រើអក្សរទេវនាគរី ( Devanāgarī ) ។

ជាងមួយសតវត្សមកហើយ សិលាចារឹកកម្ពុជាមួយចំនួនធំ សរសេរជាភាសាសំស្ក្រឹត និងជាភាសាខ្មែរបានត្រូវបកប្រែជាភាសាបារាំង ហើយបោះពុម្ពផ្សាយដោយលោក ល្វីស ហ្វីណូត៍ ( Louis Finot ) នៅក្នុងទស្សនាវដ្តីនានា មានទស្សនាវដ្តី អាស៊ីយ៉ាទីក ( Journal Asiatique ) នៅក្នុងព្រឹត្តិប័ត្រនៃសាលាបារាំងចុងបូព៌ា (Bulletins de l'Ecole Française d'Extrême Orient) នៅក្នុងសៀវភៅកម្រងអត្ថបទសិលាចារឹកប្រទេសសៀម ( Recueil des inscriptions du Siam ) ។ ល ។ នៅសម័យបច្ចុប្បន្ន សិលាចារឹកកម្ពុជាដែលគេមិនបានបោះពុម្ពនៅពេលមុន ឬ ដែលគេទើបនឹងរកឃើញនៅពេលថ្មីៗ បានត្រូវបោះពុម្ពផ្សាយដោយលោកស្រី សាវរស - ពៅ និងដោយលោក ក្លូដ ហ្សាក់ ព្រមទាំងដោយក្រុមអ្នកសិក្សាសិលាចារឹកនៃប្រទេសថៃឡង់ ។

ក្រៅពីការបោះពុម្ពផ្សាយ ដូចបានពណ៌នាខាងលើ សិលាចារឹកកម្ពុជា បានទទួលការបោះពុម្ពផ្សាយដ៏សំខាន់ៗ នៅក្នុងសៀវភៅដូចតទៅ ៖

១. « សិលាចារឹកកម្ពុជា បោះពុម្ពផ្សាយក្រោមការឧបត្ថម្ភរបស់បណ្ឌិត្យសភាសិលាចារឹក និងអក្សរសាស្ត្រ » ប៉ារីស, គ.ស ១៩២៦-១៩៣៧ ។ ទាំងអស់គឺមាន ៦ ភាគ ដែលនៅក្នុងនេះ មានផ្ទាំង និងរូបថតសិលាចារឹកដើមចំនួន ២៨៧ ។ គឺជាឯកសារសិលាចារឹកដើមដ៏សំខាន់ដែលគេអាចធ្វើការសិក្សាប្រវត្តិនៃអក្សរខ្មែរសម័យអង្គរ និងក្រោយអង្គរ ។ ( Inscriptions du Cambodge, publiées sous les auspices de l'Academie des Inscriptions et Belles Lettres, " Paris 1926 - 1937, ( 6 tomes ) )

២. « សិលាចារឹកកម្ពុជា » បោះពុម្ពដោយសាលាបារាំងខាងបូពា៌, ប៉ារីស ហាណូយ គ.ស ១៩៣៧ - ១៩៦៦ ។ ទាំងអស់គឺមានសៀវភៅ ៨ ក្បាល ។ គឺជាកម្រងសិលាចារឹកជាភាសាខ្មែរ និងសំស្រ្កឹតសរសេរជាអក្សរឡាតាំង (translitté-ration indianiste ) ដែលមានការបកប្រែ និងអត្ថាធិប្បាយជាភាសាបារាំងដោយលោក ហ្សក សឺដេស ។ នៅក្នុងសៀវភៅក្បាលទី ៨ មានបទានុក្រមនៃនរនាម ទេវនាម ស្ថាននាម ព្រមទាំងបញ្ជីកាទូទៅនៃសិលាចារឹកកម្ពុជា ។ ( G. Cœdès, " Inscriptions du Cambodge " , publiées par l' Ecole Française d' Extrême - Orient, Paris, Hanoï, 1937 - 1966 ) ; 8 tomes ។

៣. « សិលាចារឹកកម្ពុជា », កាល់គុត្តា ( ឥណ្ឌា ), គ.ស. ១៩៥៣ ។ គឺជាកម្រងអត្ថបទសិលាចារឹកភាសាសំស្រ្កឹត បោះពុម្ពផ្សាយតាមអក្សរទេវនាគរីដោយសាស្ត្រាចារ្យ ម៉ាស៊ុំដារ ។ គ្មានការបកប្រែ ប៉ុន្តែមានអត្ថាធិប្បាយចំពោះសិលា-ចារឹកសំខាន់ៗ ។ ( Majumdar R.C, Inscriptions of Kambuja, Calcutta

1953 ) ។ សិលាចារឹកទាំងឡាយបោះពុម្ពផ្សាយទាំងបីបែបខាងលើ អាចចាត់បានថា ជាប្រភពឯកសារសិលាចារឹកដ៏សំខាន់មួយ៉ាងសំរាប់ការសិក្សាស្រាវជ្រាវវប្បធម៌ និង អរិយធម៌ខ្មែរបុរាណ ។ ប៉ុន្តែគំនរឯកសារសិលាចារឹកមួយ៉ាងទៀត ដែលជាឯកសារ ដើម ហើយពុំទាន់ទទួលការបោះពុម្ពផ្សាយ គឺស្ថិតនៅក្នុងបណ្ណាល័យរបស់សាលា បារាំងចុងបូព៌ា និងនៅបណ្ណាល័យជាតិ ទីក្រុងប៉ារីសនៃប្រទេសបារាំងតែប៉ុណ្ណោះ ។ នៅបណ្ណាល័យសាលាបារាំងចុងបូព៌ា នៅទីក្រុងប៉ារីស មានអត្ថបទដើម ( estam pages ) នៃសិលាចារឹកកម្ពុជា នាសម័យអង្គរ សម័យមុនអង្គរ និងសម័យក្រោយ អង្គរ សឹងគ្រប់សព្វទាំងអស់ ។

អំពីខ្លឹមសារនៃសិលាចារឹកជាភាសាសំស្ក្រឹត និងជាភាសាខ្មែរ សិលាចារឹក ជាភាសាសំស្ក្រឹត មានចំនួនទាំងអស់ ៥០៣ អត្ថបទ ( តាមការបូកសរុបរបស់លោក ហ្វីលីប . ហ្សេន្នែរ ) ។ ជាសិលាចារឹកសរសេរឡើងជាកំណាព្យ ( កាវ្យ ) ហើយជា ទូទៅ មានការពណ៌នាអំពីស្ថាបនកម្មខាងសាសនា (ព្រហ្មញ្ញសាសនា និងពុទ្ធសាសនា) ។ ជារឿយៗ សិលាចារឹកជាភាសាសំស្ក្រឹត ចាប់ផ្តើមប្រារព្ធដោយការបួងសួងដល់ ទេវៈមួយអង្គ ឬ ច្រើនអង្គនៃព្រហ្មញ្ញសាសនាតាមកំណាព្យកាព្យឃ្លោង ពោរពេញ ដោយទស្សនៈទេវនិយម និងទស្សនវិជ្ជា ស្រង់ចេញមកពីគម្ពីរវេទ តាមកំណាព្យស្តុតិ សរសើរដល់ព្រះមហាក្សត្រសោយរាជ្យ ដោយរៀបរាប់អំពីប្រវត្តិ នៃរាជវង្សានុវង្ស អំពីបុព្វកិច្ចនៅក្នុងសមរភូមិប្រឆាំងពួកខ្មាំងសត្រូវ ពីប្រទេសជិតខាង អំពីការកោត សរសើរដល់ព្រះកិត្តិនាម និងប្រាជ្ញាល្បីខ្ចរខ្ចារ ដល់សម័យកាលនៃរាជសម្បត្តិដែល បានផ្តល់ភាពចំរើនរុងរឿង និងមហិទ្ធិឫទ្ធិ ដល់ព្រះនគរកម្ពុជទេស ។ មានកំណាព្យខ្លះ ពណ៌នាសរសើរដល់ឥស្សរជនជាន់ខ្ពស់ ជាបព្វជិត ឬ ជាគ្រហស្ថ ដែលមានសន្តាន ចិត្តជ្រះថ្លាចំពោះសាសនា ដោយការកសាងប្រាសាទ វត្តអារាម ស្រុកភូមិ សួនឧទ្យាន បារាយណ៍ និងទំនប់ទឹក ។ ភាគច្រើននៃសិលាចារឹកពណ៌នាបញ្ជាក់អំពីនាមស្ថាបនករ

ប្រាសាទ ព្រះវិហារ រូបបដិមា ព្រមទាំងកាលបរិច្ឆេទនៃស្ថាបនកម្ម ។ កំណាព្យខ្លះទៀត រៀបរាប់ព្រឹត្តិការណ៍តាមបែបប្រវត្តិសាស្ត្រស្តីអំពីការប្រយុទ្ធស្លាប់រស់រវាង មេទ័ពប្រឆាំង និង មេទ័ពមានភក្តីភាពចំពោះរាជនិយម ។ មានកំណាព្យប្រកបដោយសោកនាដ្យកម្មដែលសរសេរអំពីពិធីបួងសួង ធ្វើភាវនាធម៌ជារៀងរាល់ថ្ងៃរបស់ព្រះនាងឥន្ទ្រទេវី ដើម្បីជ័យជំនះរបស់ព្រះស្វាមី គឺព្រះបាទជ័យវរ្ម័នទី ៧ ដែលបានធ្វើចម្បាំងប្រឆាំងប្រទេសចម្ប៉ា ។ មានអត្ថបទកំណាព្យពីរដ៏វែងមួយ និងនិទានអំពីព្រំប្រទល់កម្ពុជទេស សម័យអង្គរ ( ខាងឧត្តរទល់ប្រទេសចិនខាងបស្ចិមទល់សមុទ្រ ) និងសន្តិវង្សព្រះបាទរាជេន្ទ្រវរ្ម័នមួយទៀតធ្វើអត្ថាធិប្បាយអំពីទ្រឹស្តីពុទ្ធនិយម និង ពិធីសក្ការបូជា ក្នុងជំនឿលើពុទ្ធសាសនា ។

នៅក្នុងសៀវភៅស្តីពីការស្រាវជ្រាវវចនស័ព្ទភាសាសំស្ក្រឹត តាមសិលាចារឹកនៃប្រទេសកម្ពុជា លោកភត្តចារយៈ បានមានប្រសាសន៍ថា « ភាសាសំស្ក្រឹតប្រើប្រាស់ក្នុងសិលាចារឹកកម្ពុជា មានលក្ខណៈត្រឹមត្រូវល្អ » ( K. Bhattacharya, Recherches sur le vocabulaire des inscriptions sanscrites du Cambodge, Paris, 1964 ) ។

កំណាព្យសំស្ក្រឹតតាមសិលាចារឹក បានត្រូវចងក្រងឡើង តាមរចនាបថដ៏ខ្ពង់ខ្ពស់ គគ្រឹកគគ្រេង ពោរពេញដោយពាក្យប្រៀបធៀបសំនួនវោហារ បុគ្គលាធិដ្ឋាន ( Paraboles ) និង រូបបារម្មណ៍ ដ៏រស់រវើក ។ តាមរបៀបរៀបចំសង្វាក់ចាប់ចុងចួន តាមលក្ខណៈវណ្ណពុទ្ធដ៏ពិរោះ កំណាព្យជាភាសាសំស្ក្រឹត បានត្រូវសរសេរឡើង ដើម្បីសូត្រដូចជាធម៌ស្មូត្រ ឬ ដើម្បីច្រៀងជាបទចំរៀងស្តុតីកោតសរសើរដល់អាទិទេពនានា ( មានព្រះឥសូរ ព្រះពិស្ណុ ព្រះព្រហ្ម ) ដល់ព្រះពុទ្ធព្រះពោធិសត្វ និងដល់ព្រះមហាក្សត្រ ដោយមានរបាំ របៀបរបាំព្រះរាជទ្រព្យនិង ក្រុមដូរ្យតន្ត្រី ប្រគំកំដរជាប្រក្រតី ។ ប្រសិនបើយោងទៅតាមប្រភេទនៃ

ព្រឹត្តិការណ៍ដែលចោទឡើង និងជីវប្រវត្តិ ព្រមទាំងគោរម្យងាររបស់កវី បណ្ឌិត គេអាចសន្និដ្ឋានបានថា កវី បណ្ឌិតទាំងនោះ គឺជាអ្នកប្រាជ្ញខាងភាសាសំស្ក្រឹត ដែលមានដើមកំណើតជាជនជាតិកម្ពុជា ហើយមិនមែនជាកវីមកពីប្រទេសឥណ្ឌា ដូចជាពាក្យពោលរបស់លោក ក្លូដ ហ្សាក់ ឡើយ ។ កវីបណ្ឌិតទាំងអម្បាលម៉ាននោះ រមែងធ្វើជារាជគ្រូនៃព្រះមហាក្សត្រ ជាព្រាហ្មណ៍បុរោហិត ជាចតុរាចារ្យ ជាសេនា-មាត្យនៅបរមរាជវាំង ហើយដែលបានរៀនសូត្រគម្ពីរវេទទាំងឡាយខាងព្រហ្មណ-សាសនា ឬ គម្ពីរខាងពុទ្ធសាសនាមហាយានជាភាសាជាសំស្ក្រឹត ។ នេះជាទឡ្ហីករណ៍ដ៏សំខាន់បំផុត ដើម្បីអោយគេអាចធ្វើការសន្និដ្ឋានបានថា កំណាព្យជាភាសាសំស្ក្រឹតតាមសិលាចារឹកកម្ពុជា គឺពិតជាវណ្ណកម្ម ឬ និម្មាបនកម្មនៃអក្សរសាស្ត្របុរាណ នៃប្រទេសកម្ពុជា ពីសតវត្សទី ៥ ឬ ទី ៦ ដល់សតវត្ស ទី ១៤ នៃគ្រិស្តសករាជ ។ ពិតមែនហើយនាសម័យបច្ចុប្បន្ន គេអាចពិនិត្យឃើញថា ប្រជាជនកម្ពុជា ពុំទាន់ដែលបានក្រេបជញ្ជក់នូវរស់ជាតិ និងសោភណភាពដ៏ស្រស់បំព្រងនៃអក្សរសាស្ត្របុរាណរបស់ខ្លួនជាភាសាខ្មែរនៅឡើយ ដោយហេតុថា កំណាព្យសំស្ក្រឹតតាមសិលាចារឹកទាំងប៉ុន្មាន ពុំដែលបានទៅជាកម្មវត្ថុនៃការបកប្រែមកជាកំណាព្យជាភាសាជាតិ នៅឡើយ ។

សិលាចារឹកជាភាសាខ្មែរ មានចំនួនទាំងអស់ ៦១៩ អត្ថបទ ហើយនៅក្នុងចំនួននេះ មានសិលាចារឹកសម័យមុនអង្គរ ( គឺពីសតវត្សទី៦ ដល់សតវត្សទី៨ ) ចំនួន ១៦៤ អត្ថបទ ។ សិលាចារឹកសម័យអង្គរ ( គឺពីសតវត្សទី ៩ ដល់សតវត្សទី១៤ ) ចំនួន ៤៥៥ អត្ថបទ ។

ខុសពីសិលាចារឹកភាសាសំស្ក្រឹត សិលាចារឹកជាភាសាខ្មែរទាំងអស់ត្រូវបានរៀបរៀងឡើងជាពាក្យសម្រាយប្រកបដោយរចនាបថធម្មតា ច្បាស់លាស់ គ្មានលក្ខណៈអច្ឆរិយភាព ។ គឺជាអត្ថបទប្រកបដោយតថភាព ដែលគេបានចារឡើង

សំរាប់សំរួលដល់ការយល់ដឹងនៃបណ្ដាជនភាគច្រើន ដែលគ្មានចំណេះដឹងខាងភាសាសំស្ក្រឹត ។ ក្រៅពីអត្ថបទមួយចំនួនដែលទាក់ទងទៅនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ អត្ថបទសិលាចារឹកខ្មែរភាគច្រើនអាចចាត់ទុកបានថាជាឯកសាររដ្ឋការ តុលាការ និងពតិមាន ។ អក្ខរាវិរុទ្ធ និងវចនស័ព្ទប្រើប្រាស់នៅក្នុងសិលាចារឹកជាភាសាខ្មែរ ដែលគេបានរកឃើញនៅលើដែនដីកម្ពុជទេសដ៏ឆ្ងាយដាច់ស្រយាលក្ដី ក៏រមែងមានឯកភាពក្នុងការសរសេរប្រកបដោយលក្ខណៈត្រឹមត្រូវ ជាពិសេសអក្ខរាវិរុទ្ធនៃពាក្យកម្ចីពីភាសាសំស្ក្រឹត ឃើញថាអ្នកនិពន្ធសិលាចារឹកខាងភាសាខ្មែរមានការអប់រំខាងភាសាប្រហាក់ប្រហែលគ្នា ហើយមានចំណេះច្បាស់លាស់ទាំងខាងភាសាសំស្ក្រឹតទៀតផង ។

ការអានអត្ថបទសិលាចារឹកជាភាសារខ្មែរ អាចអោយយើងទទួលចំណេះដឹង និងពតិមានអំពីទម្រង់ និងរបបគ្រប់គ្រងនៃសង្គមខ្មែរ តាមបញ្ហានានា ដូចតទៅៈ គឺស្ថាបនកម្មប្រាសាទ និង ព្រះវិហារ ស្រុកភូមិស្ថាននៅលើដែនដីថ្មី១ សកម្មភាពខាងសាសនា និងខាងសង្គមកិច្ច ពីសំណាក់វណ្ណៈអភិជន និងព្រាហ្មណាចារ្យ ព្រះសង្ឃគ្រប់ជាន់ថ្នាក់ក្នុងកិច្ចការអភិវឌ្ឍន៍ស្រុកទេស និង ក្នុងកិច្ចការរដ្ឋបាល អំ-ណោយទានដ៏ធំធេង មានតាំងពីដីធ្លី ច្បារដំណាំ ស្រែចំការ ទាសាទាសី សត្វពាហនៈ គ្រឿងបូជាធ្វើពីមាសប្រាក់ ដល់វត្តអារាម និងអាទិទេពនៃពិធីសក្ការបូជាទេវរាជ ព្រះរាជអាជ្ញា និង ព្រះសាសនៈ ជាលាយលក្ខណ៍អក្សរ ផ្ញើតាមរយៈព្រះគ្រូ ឬ ព្រាហ្មណាចារ្យ ដល់ប្រធានតុលាការ ដល់ខ្លោញពលខេត្ត ( វិស័យ ) ឬដល់បុរសប្រធាន និងប្រធានស្រុកនានា ដើម្បីការអនុវត្តកិច្ចការរាជការគ្រប់បែបយ៉ាង មានជាពិសេស ការកាប់គាស់ដីថ្មី ដើម្បីចាត់ស្រុក សាងវត្ត ជីកស្រះ ត្រពាំង សង់ទំនប់ទឹក សំរាប់ជាទីតាំងលំនៅនៃបណ្ដាជនគ្រប់ជាន់ថ្នាក់ ចាប់តាំងពីអភិជន ដល់សាមញ្ញជន និង ពលក្ញុំ ដែលបំពេញងារតាមចំណោប់ពេលវេលាខាងរនោច ឬ ខាងខ្នើត ។ ការ

ប្រព្រឹត្តទៅនៃទំនាក់ទំនងខាងពាណិជ្ជកម្ម មិនមែនដោយសារតែការប្រើមាស ប្រាក់ ប៉ុណ្ណោះ តែដោយសារការប្រើគ្រឿងវត្ថុ ផលដំណាំ គ្រប់ជំពូក ( មានកប្បាស ស្រូវ ) ព្រមទាំងសត្វពាហនៈ ដីធ្លី និង ទាសាទាសីទៀតផង ។

លក្ខណៈពិសេសនៃអត្ថបទជាភាសាខ្មែរ ដែលគេអាចប្រទះឃើញនៅសឹងគ្រប់សិលាចារឹកសម័យអង្គរ និង មុនអង្គរ គឺការពណ៌នាអំពីការកំណត់ព្រំប្រទល់ស្រុក ភូមិស្ថាន និង ស្រែចំការរបស់វត្តអារាម និង របស់វណ្ណៈអភិជន ដែលបានមកពីព្រះរាជអំណោយ និងអំពីនរនាម ( គឺនាមឈ្មោះមនុស្ស ) ដែលបំពេញសេវាកម្មគ្រប់បែបយ៉ាងនៅក្នុងប្រាសាទ ឬ វត្តអារាមនីមួយៗ ។ ហេតុនេះហើយបានជា តាមសិលាចារឹកជាភាសាខ្មែរ យើងអាចស្រង់បាននរនាម ( anthroponymes ) ចំនួនប្រហែល ៥.០០០ ហើយស្ថាននាម ( toponymes ) ចំនួនប្រហែលជា ១.៥០០ ។ តាមសិលាចារឹកកម្ពុជា គេអាចឃើញថាប្រាសាទ ឬ វត្តអារាម គឺជាមជ្ឈមណ្ឌលខាងសេដ្ឋកិច្ច និង វប្បធម៌ និងជាទីពំនឹងដ៏ធំនៃប្រជាជន ។ ទីណាមានវត្តអារាម គឺទីនោះមានស្រុក និងភូមិឋាន មានស្រូវអង្ករ ។ ជាឧទាហរណ៍ តាមសិលាចារឹកវត្តអង្គរបូរី K600 នាឆ្នាំ ៦១១ មានពណ៌នាអំពីឈ្មោះនៃស្រែចំការ ច្បារដំណាំ បឹងបួរ ដែលជាកសិដ្ឋាន ផលិតគ្រឿងបរិភោគរបស់វត្ត មានការពណ៌នាអំពីនាមឈ្មោះរបស់បំនួស ឬ អាចារ្យ មានឈ្មោះអ្នកប្រគំដូរ្យតន្ត្រី នាដការី របាំ សិល្បការិនី ចំរៀង កសិករ អ្នកត្បាញរវៃ ។ល។

មានអត្ថបទសិលាចារឹកមួយចំនួន ដែលគេចាត់ទុកថាជាអត្ថបទប្រកបដោយលក្ខណៈប្រវត្តិសាស្ត្រ ឧទាហរណ៍ សិលាចារឹកស្តុកកក់ធំ K235 ឆ្នាំ ១០៥២ អធិប្បាយដ៏ល្អិតល្អន់អំពីសន្តិវង្សនៃវង្សត្រកូលមួយដែលសមាជិកបំពេញមុខងារជាព្រាហ្មណ៍បុរោហិត នៃពិធីសក្ការបូជា ទេវរាជា សំរាប់ព្រះមហាក្សត្រ សម័យអង្គរជាច្រើនអង្គ អស់រយៈពេលពីររយឆ្នាំ ។ សិលាចារឹកវត្តសំរោង ( ព្រៃវែង )

K956 ដែលរៀបរាប់អំពីកល្យាណពិធី លើមហេន្ទ្របពិត ( ភ្នំគូលែន ) ដើម្បីអភិសេកព្រះបាទជ័យវរ្ម័នទី ២ ( ៨០២ . ៨៥០ A.D ) ជាមហាក្សត្រចក្រពត្តិ ( empereur ) នៃកម្ពុជទេសឯករាជ្យ ។ សិលាចារឹកភិមានអាកាស (សៀមរាប) K 292 សរសេរអំពីពិធីធ្វើសម្បថ សម្តែងស្វាមីភក្តិដល់ព្រះបាទស្រីសូរ្យវរ្ម័នទី ១ ដោយពាក្យសន្យាមិនរត់ចោលព្រះចំបាំងប្រឆាំងសត្រូវពីសំណាក់នៃតម្រួតកងទ័ពប្រមាណជាង ២០០ នាក់ ។ សិលាចារឹកកំពង់ធំ K444 បញ្ជាក់អំពីរាជក្រឹត្យបង្កើតក្រុមមន្ត្រីជាន់ខ្ពស់ថ្មីៗ របស់ព្រះមហាក្សត្រ ។

តាមអត្ថាធិប្បាយអំពីខ្លឹមសារជាគោល ដែលដក់នៅក្នុងអត្ថបទសិលាចារឹកទាំងឡាយ យើងមានគោលបំណងដើម្បីបញ្ជាក់ថា តាមទស្សនៈទូទៅ លក្ខណៈអក្សរសិល្ប៍ នៃសិលាចារឹកខ្មែរ សម័យមុនអង្គរ និងអង្គរ បានលេចឡើងច្បាស់លាស់ លើមូលដ្ឋាននៃរូបភាពជាក់ស្តែង ប្រកបដោយសច្ចភាព នៃជីវិតដ៏រស់រវើកដ៏តឹងតែង និង ពោរពេញដោយជំនឿដ៏ខ្ជាប់ខ្ជួនលើសាសនារបស់ប្រជាជនកម្ពុជា នាសម័យទាំងពីរ ។

ការសិក្សាសិលាចារឹកកម្ពុជា បោះពុម្ពផ្សាយតាំងពីដើមសតវត្សទី ២០ ជាពិសេស ដោយលោកល្វី ហ្វីណូត៍, លោកហ្សក សឺដេស, និងលោកអ្នកប្រាជ្ញដទៃទៀត បានធ្វើអោយយើងយល់ថា ការស្រាវជ្រាវរកសិលាចារឹកកម្ពុជា បានទាមទារអោយមានកិច្ចការរៀបចំការងារស្រាវជ្រាវតាមក្រុម តាមដំណាក់កាលដែលស្ថិតក្នុងបរិយាកាស ប្រកបដោយក្តីព្យាយាម និង អង់អាចទៀតផង ដោយហេតុថា សិលាចារឹកភាគច្រើន បានត្រូវរកឃើញនៅក្នុងប្រាសាទនៅក្នុងព្រៃ នៅក្នុងទីដ៏ឆ្ងាយដាច់ស្រយាល ។

សិលាចារឹកទាំងអស់បានត្រូវគេផ្តិតយកនឹងក្រដាសក្រាស់ធ្វើជាអេស្តំប៉ាស ( estampages ) រួចតម្រូវអោយមានការសិក្សាតាមការអាន តមកត្រូវ

បានសរសេរជាអក្សរឡាតាំង ( translittération indianiste ) រួចបកប្រែ និង ពន្យល់គ្រប់បែបយ៉ាង ហើយបោះពុម្ពផ្សាយជាភាសាបារាំង ។ នៅលើមូលដ្ឋាននៃ សិលាចារឹកបោះពុម្ពផ្សាយ អ្នកស្រាវជ្រាវនៃប្រទេសនានា ( មានប្រទេសបារាំងជា អាទិ៍ ) បានចងក្រងសៀវភៅមួយចំនួនធំ ស្ដីពីប្រវត្តិសាស្ត្រខាងនយោបាយខាង សេដ្ឋកិច្ច ខាងសង្គមកិច្ចនៃប្រទេសកម្ពុជា នាសម័យបុរាណ ។ គឺដោយសារសិលា ចារឹក គេអាចរៀបចំកាលប្បវត្តិ ( Chronologie ) នៃរាជសម្បត្តិមហាក្សត្រ សម័យអង្គរ និងមុនអង្គរ ស្គាល់ច្បាស់អំពីកាលបរិច្ឆេទនៃស្ថាបនកម្ម និងអត្ថន័យ នៃប្រាសាទធំៗ ស្គាល់នូវជំនឿផ្សេងៗ ប្រកាន់ដោយប្រជាជនចំពោះទេវៈ និង អាទិទេពទាំងឡាយនៃព្រាហ្មណ៍ សាសនា និង ពុទ្ធសាសនាយល់នូវស្រទាប់និងការ លូតលាស់នៃសង្គមខ្មែរ ព្រមទាំងរបបគ្រប់គ្រងដែលយោងទៅតាមពិធីសក្ការបូជា ទេវរាជា ។

ទោះបីមានការបោះពុម្ពស្នាដៃខាងប្រវត្តិសាស្ត្រ មានច្រើនក្ដី ក៏ពតិមាន ខាងវិទ្យាសាស្ត្រ ដែលមានដក់នៅក្នុងសិលាចារឹកនៅមិនទាន់រឹងស្ងួត ។ សិលាចារឹកគឺ ជានិម្មាបនកម្មខាងអក្សរសាស្ត្រ ដែលអាចអោយយើងយល់ដល់ទម្រង់ និង ស្ថានភាពនៃភាសាខ្មែរបុរាណ ។ ការសិក្សាសិលាចារឹកជាភាសាខ្មែរ ក៏មិនមែនជា កិច្ចការងាយស្រួលសិក្សាជាងភាសាសំស្ក្រឹតប៉ុន្មានដែរ ដោយហេតុថា ភាសា សំស្ក្រឹតជាភាសាក្លាស៊ិកបុរាណ ដែលត្រូវបានអ្នកប្រាជ្ញបរទេសជាច្រើនចងក្រងជា វចនានុក្រមច្រើនបែបយ៉ាង ចំណែកភាសាខ្មែរបុរាណ គឺជាភាសារអមតៈ មានអំបូរពី ភាសាមន - ខ្មែរ ហើយមានការវិវត្តមកជាភាសាខ្មែរ នៃមធ្យមសម័យ និងបច្ចុប្បន្ន-សម័យ ដោយមានការប្រែប្រួលខាងអក្ខរាវិរុទ្ធ វចនស័ព្ទ និង វេយ្យាករណ៍ ។

នៅពេលដំបូង ការសិក្សាភាសាខ្មែរតាមសិលាចារឹក ពុំទាន់មានចលនា ទៅមុខលឿនដូចជា ការសិក្សាប្រវត្តិវិទ្យា និង ស្ថាបត្យកម្ម ក៏ប៉ុន្តែបន្ទាប់ពីពេល

បោះពុម្ពផ្សាយសៀវភៅ « សិលាចារឹកកម្ពុជា » ៨ ក្បាលរបស់ ហ្សក សឺដេស មក ( ១៩៣៧ . ១៩៦៦ ) ឃើញថា សន្ទុះនៃការសិក្សាស្រាវជ្រាវភាសាខ្មែរតាមសិលាចារឹកបានបោះជំហានទៅមុខយ៉ាងលឿន ដោយសារការបោះពុម្ពផ្សាយអត្ថបទ សៀវភៅ និងវចនានុក្រម ។ ការសិក្សាភាសាខ្មែរតាមសិលាចារឹក បានប្រព្រឹត្តទៅនៅប្រទេសបារាំង ( ដោយលោក អូ ឈៀង, អ្នកស្រី សាវរស ពៅ, លោក ក្លូដ ហ្សាក់ ) នៅប្រទេសអង់គ្លេស ( ដោយលោកស្រី ហ្យូឌីត ហ្សាកុប ) នៅសហរដ្ឋអាមេរិក ( ដោយលោក ហ្វីលីប ហ្សេណ្ណែរ និងអ្នកស្រី សក្តិ . ហាំប្រ៊ី ) នៅសហព័ន្ធរុស្ស៊ី ( ដោយលោក ឡុង សៀម ) នៅប្រទេសជប៉ុន ( ដោយលោក សាកូម៉ូតូ យ៉ាស៊ូយូគី ) នៅប្រទេសកម្ពុជា ( ដោយភិក្ខុ ប៉ាង ខាត់ និង នៅសាកលវិទ្យាល័យភ្នំពេញ ) នៅប្រទេសថៃឡង់ ( ដោយគណៈកម្មាធិការសិលាចារឹកនៃក្រសួងវប្បធម៌ ) ។ ការសិក្សាភាសាសំស្ក្រឹតតាមសិលាចារឹកកម្ពុជា បានប្រព្រឹត្តទៅនៅប្រទេសបារាំង និង ប្រទេសឥណ្ឌា ។ នាសម័យបច្ចុប្បន្ន សិលាចារឹកកម្ពុជា និងភាសាមន-ខ្មែរបានទៅជាកម្មវត្ថុមួយ ក្នុងរបៀបវារៈនៃសន្និសីទអន្តរជាតិ នៅទីក្រុងបាងកក ដែលគេតែងបើកធ្វើឡើង ក្នុងរវាងពីរ បីឆ្នាំម្តង ។

អ្នកប្រាជ្ញដែលមានកិត្តិនាមល្បីល្បាញជាងគេក្នុងការសិក្សាសិលាចារឹកកម្ពុជា គឺលោកសាស្ត្រាចារ្យ ហ្សក សឺដេស (គ.ស ១៨៨៦-១៩៦៩) ។ ក្នុងជីវិតរបស់លោក, លោកបានចំណាយពេលជាងហុកសិបឆ្នាំ ដើម្បីស្វែងរកស្រាវជ្រាវសិក្សាពន្យល់បកប្រែ និង បោះពុម្ពផ្សាយអត្ថបទសិលាចារឹកកម្ពុជា ។ សៀវភៅ និងអត្ថបទបោះពុម្ពផ្សាយរបស់លោកមានចំនួនដល់ទៅបីរយ ។ ក្នុងបណ្តាស្នាដៃទាំងអស់របស់លោក ហ្សក សឺដេស មានស្នាដៃមួយភាគធំ ដែលគេអាចទុកបានថាជាឯកសារមូលដ្ឋានសំរាប់ការសិក្សាប្រវត្តិសាស្ត្រប្រទេសកម្ពុជា និង ភាសាខ្មែរ ។ លោកជាអ្នកផ្តើមគំនិតមួយរូបក្នុងការរៀបចំបោះពុម្ពផ្សាយវចនានុក្រមខ្មែរ ( និពន្ធ

ដោយសម្តេចសង្ឃរាជ ជួន ណាត ) និង សិលាចារឹកនគរវត្តនាសម័យមធ្យម ( សត.វត្សទី ១៦ - ១៨ ) ។ សិលាចារឹកនគរវត្តបានត្រូវបោះពុម្ពផ្សាយម្តងទៀតជាអក្សរឡាតាំង និងជាភាសាបារាំងដោយអ្នកស្រី សាវរស ពៅ នៅក្នុងព្រឹត្តិប័ត្រសាលាចុងបូព៌ាបារាំង ( Textes en Khmer moyen. Inscriptions modernes d'Angkor Vat, -BEFEO, Paris, 1970 ) ។

តាមមតិ និងពាក្យទូន្មានជាច្រើនដែលលោក ហ៊្សក សឺដេស បានសរសេរក្នុងអត្ថបទរបស់លោក មួយចំនួនទាក់ទងនឹងបញ្ហាសិក្សាអក្សរសាស្ត្រ និងភាសានានានៅឥណ្ឌូចិន និងតាមការអានអត្ថបទសិលាចារឹកជាភាសាខ្មែរ.មន និងថៃ យើងអាចទាញយោបល់យល់ថា សិលាចារឹកសរសេរជាភាសាទាំងបី មានចំនួនច្រើនបរិបូរ ហើយគេអាចសន្មតបានថា ជាប្រភពដើមនៃឯកសារប្រវត្តិសាស្ត្រ ដ៏គ្រប់គ្រាន់សំរាប់ការសិក្សាប្រៀបធៀបជាប្រព័ន្ធខាងប្រវត្តិនៃវចនវិទ្យារវាងភាសាទាំងបីមានជាឧបករណ៍ វចនស័ព្ទដូចគ្នាក្នុងភាសាខ្មែរបុរាណ និងភាសាមនបុរាណ វចនស័ព្ទកម្ចីដោយភាសាសៀមបុរាណពីភាសាខ្មែរបុរាណ ។ ល ។ ចំពោះមតិខាងក្រោយនេះ លោក ហ៊្សក សឺដេស បានសរសេរថា នៅសតវត្សទី ១៣ ភាសាថៃបានខ្ចីពាក្យមួយចំនួនធំពីភាសាខ្មែរ ។

ក្នុងក្របខ័ណ្ឌនៃការសិក្សាប្រវត្តិសាស្ត្រខ្មែរ សិលាចារឹកជាភាសាខ្មែរអាចត្រូវចាត់ទុកបានជាឯកសារប្រកបដោយសារសំខាន់ដ៏ខ្ពស់ ព្រោះជាអត្ថបទពិតត្រឹមត្រូវគ្មានកែតម្រូវតាមការចម្លង ឬ បោះពុម្ពនៅពេលក្រោយៗ ជាបន្តមក ។ តាមសិលាចារឹក គេអាចធ្វើការសិក្សាស្រាវជ្រាវជាមូលដ្ឋាននៃភាសាខ្មែរ នាសម័យអង្គរ និងមុនអង្គរនៅលើវិស័យនានា នៃភាសាវិទ្យា ដែលមានជាអាទិ៍ គឺវចនវិទ្យា ( មានជាពិសេសគឺ កំណើតវាក្យស័ព្ទ ឥទ្ធិពលនៃភាសាសំស្ក្រឹត ទម្រង់នៃឋានន្តរនាម.នាសម័យអង្គរ នរនាមវិទ្យា ស្ថាននាមវិទ្យា ទម្រង់នៃភាសាខ្មែរសម័យរាជាណាចក្រ

នគរភ្នំ ( ពី ស.វ ទី១ ដល់ ទី៥ ) បុរាណអក្ខរៈវិទ្យា ( paléographie ) សូរស័ព្ទវិទ្យា វេយ្យាករណ៍ វាក្យសម្ព័ន្ធ ។ នៅពេលអនាគតដ៏ខ្លី កាលណាលទ្ធផលលេចចេញពីការស្រាវជ្រាវភាសាខ្មែរបុរាណ ត្រូវបានបោះពុម្ពផ្សាយនោះ គេអាចគិតគូរធ្វើគំរោងនៃវចនានុក្រមនិរុត្តិវិទ្យា ( dictionnarire étymologique ) ប្រវត្តិវេយ្យាករណ៍ និងប្រវត្តិសូរស័ព្ទ នៃភាសាខ្មែរ ។

រហូតមកដល់ពេលបច្ចុប្បន្ន ការសិក្សាប្រៀបធៀប នឹងចាត់ថ្នាក់បញ្ជាមន . ខ្មែរ ជាអំបូរ ជាក្រុមផ្សេងៗ បានត្រូវធ្វើឡើងតែដោយសារស្ថិតិខាងវចនស័ព្ទតាមវិធីក្លូត្តូក្រូណូឡូសិក ( glottochronologique ) តែប៉ុណ្ណោះ ។ វិធីនេះត្រូវបានបង្កើតឡើងដោយលោក ស្វាដេស ( Swadesh ) ដើម្បីសិក្សារកអំបូរ និងក្រុមភាសាទាំងឡាយណាដែលគ្មានប្រពៃណីប្រើអក្សរ ។ ប៉ុន្តែនៅក្នុងអំបូរភាសាមន.ខ្មែរ គឺមានភាសាខ្មែរបុរាណ មានភាសាមនបុរាណ ដែលជាភាសារបស់រដ្ឋ ប្រកបដោយប្រពៃណីសរសេរតាមសិលាចារឹក តាំងពីសម័យសតវត្សទី ៦ ។ នៅក្នុងសម័យភាសាបុរាណខ្មែរ និងមន បានត្រូវប្រើប្រាស់ដោយបណ្តាជនទាំងឡាយដែលរស់នៅលើទឹកដីដ៏ធំធេង នៃឧបទ្វីបឥណ្ឌូចិន និងឧបទ្វីបម៉ាឡាក្កា ( នៅប្រទេសម៉ាឡេស៊ី ) ហើយប្រហែលជានៅក្នុងសម័យនគរធំ អ្នកនិយាយភាសាខ្មែរ និងមនអាចយល់គ្នាបាន ។ តាមការសិក្សារបស់អ្នកនិពន្ធអត្ថបទពី « ទំនាក់ទំនងខាងក្រៅនៃភាសាមន.ខ្មែរ « Long Seam,- Contacts externes des langues Mon - Khmer, - in BEFEO, tome LXX, 1981, pages 195-230 ) ដែលបោះពុម្ពផ្សាយក្នុងព្រឹត្តប័ត្រសាលាបារាំងនៃចុងបូព៌ា នាឆ្នាំ១៩៨១ នៅក្នុងអំបូរភាសាមន . ខ្មែរ មានភាសា និង គ្រាមភាសាទាំងអស់ ចំនួនកៅសិប ( ៩០ ) និយាយដោយជនជាតិទាំងឡាយដែលរស់នៅប្រទេសកម្ពុជា ប្រទេសសៀម ប្រទេសឡាវ ប្រទេសវៀតណាម ប្រទេសម៉ាឡេស៊ី ប្រទេសភូមា

ប្រទេសឥណ្ឌា ប្រទេសចិន ។ ល ។

ការសិក្សាប្រៀបធៀបវចនស័ព្ទនៃភាសាខ្មែរ និងមនបុរាណ ជាមួយភាសាមន - ខ្មែរ ទាំង ៩០ នឹងអាចអោយគេរកឃើញនូវភាសា និងត្រកូលភាសាប្រើប្រាស់ដោយជនជាតិមន - ខ្មែរ ទាំងឡាយដែលបានបែកចេញ ឬ បែកខ្ញែកចេញពីភាសាខ្មែរ និងមនបុរាណ តាំងពីសម័យគនរភ្នំដោយសារចម្បាំង ឬ ដោយសារព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដទៃទៀត ។

វចនស័ព្ទនៃភាសាមនបុរាណ បានត្រូវចងក្រងឡើងជាវចនានុក្រមដោយលោក ស័រតូ ( H.L. Shorto ) និងលោក ហ្សេរ៉ា ឌីផ្លូត ( G.Diffloth ) ។ រីឯវចនស័ព្ទជាភាសាខ្មែរ នៃសិលាចារឹកផ្ទាល់ខ្មែរបុរាណ បានត្រូវចងក្រងជាវចនានុ-ក្រមមានជាពិសេសដោយអ្នកនិពន្ធអត្ថបទ ក្រោមចំណងជើងថា « វចនានុក្រមភាសាខ្មែរបុរាណ » ពី ស.វ ទី ១៣ ដល់ទី ១៤ ។ គឺជាវចនានុក្រមដែលមាន ២៤៥០ ទំព័រ ( អង្គុលីលេខ ) រៀបរៀងដោយកិច្ចឧបត្ថម្ភរបស់វិជ្ជាស្ថានបូព៌ាសាស្ត្រនៃបណ្ឌិត្យសភាសហពន្ធរុស្ស៊ី ។ វចនានុក្រមនោះមានមេពាក្យចំនួនជាងមួយម៉ឺន ។ មេពាក្យនីមួយៗ បានត្រូវបកប្រែជាភាសាបារាំង និង រុស្ស៊ី ហើយមានសេចក្តីពន្យល់ដោយឧទាហរណ៍នានាស្រង់ចេញពីអត្ថបទសិលាចារឹក ដោយមានចំណាត់ថ្នាក់តាមកាលបរិច្ឆេទចាប់តាំងពីសតវត្សទី ៦ រហូតដល់ចុងសតវត្សទី ១៤ ។ វចនានុក្រមបានត្រូវរៀបចំឡើងដើម្បីអោយទៅជាគ្រឿងឧបករណ៍វិទ្យាសាស្ត្រ សំរាប់អ្នកស្រាវជ្រាវ និង និស្សិតដែលសិក្សាវប្បធម៌ និងអរិយធម៌នៃប្រទេសកម្ពុជា ។

អត្ថបទផ្សេងៗនៅក្នុងសៀវភៅដែលមានឈ្មោះថា ការសិក្សាស្រាវជ្រាវខាងវចនវិទ្យា និងវេយ្យាករណ៍ នៃភាសាខ្មែរបុរាណតាមសិលាចារឹកកម្ពុជា បានត្រូវនិពន្ធលើមូលដ្ឋាននៃវចនានុក្រមដែលបានពណ៌នាមកហើយ ។ លទ្ធផលនៃការងារនេះ គឺគ្រាន់តែជាភាគតូចមួយប៉ុណ្ណោះនៃចំណេះដឹងដ៏ធំធេង អំពីអតីតភាពនៃ

ប្រទេសកម្ពុជា ដែលជិតជាប់នៅក្នុងមរតកនៃសិលាចារឹកបុរាណខ្មែរ ។

បណ្ឌិត **ឆ្សុង សៀម**
វិទ្យាស្ថានបូពិសាស្ត្រ នៃបណ្ឌិត្យសភា
វិទ្យាសាស្ត្រសហព័ន្ធរុស្សី

# ច្បាប់ល្បើកថ្មី

អ្នកព្រះភិរម្យ ភាសាអ៊ីខ្ញុំ បង្គំនឹកគុណ
ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃជាមុន គុណគាប់មហាធ្ងន់
មាតាបិតា ។

ឧបជ្ឈាយ៍ជាធំ កាលចាប់ដៃខ្ញុំ ឱ្យធម៌កេសា
អនុសាវន ព្រះកម្មវាចា គុណគួរអក្ខរា
ទាំងសាមសិបបី ។

ខែចេត្រឆ្នាំច ចត្វាស័កក កគិតកាព្យថ្មី
លើកច្បាប់ប្រដៅ កូនចៅប្រុសស្រី តូចក្តីធំក្តី
ចូរស្តាប់គ្រប់គ្នា ។

ដ្បិតមនុស្សឥឡូវ យកខុសជាត្រូវ យកឆ្គួតធ្វើជា
អំពើអាក្រក់ ឡិកឡក់លើលោ ព្រហើនពានពារ
អាងមាសអាងប្រាក់ ។

៥. អាងព្រើលអាងប្រាជ្ញ អាងកោងអាងកាច អាងកាប់អាងចាក់
អាងជើងអាងដៃ អាងវាយអាងធាក់ អាងគុកច្រវាក់
អាងម៉ាស៊ីនកាត់ក ។

អាងសុទ្ធតែខុស កូនអើយចាំចុះ អាងនោះមិនល្អ
អ្នកគិតឱ្យល្អិត ដ្បិតស្រុកលោកក្រ ប្រមាណតំណ
តទៀតទៅមុខ ។

សាសនានៅឆ្ងាយ លែងបានសប្បាយ មានតែកើតទុក្ខ

| | | |
|---|---|---|
| កើតទាន់លោកិយ | ឲ្យតែចំនុក | ដំណែលរអាពុក |
| | ចូរចាំគ្រប់គ្នា ។ | |
| អ្នកជឿពាក្យចាស់ | ជឿចាំឱ្យណាស់ | កុំធ្វើបំពារ |
| អ្នកបានស្បែកជាច | អ្នកខ្លាចស្បែកជា | មនុស្សចោរប៉ោបៀ |
| | កុំយកខ្លួនបៀត ។ | |
| ឃើញឫកគេល្អ | ទោះបីមានក្រ | យកគេជាញាតិ |
| គួររាប់អ្នកក្រៅ | ផៅអ្នកឯទៀត | រាប់រើសមារយាទ |
| | សុចរិតត្រឹមត្រូវ ។ | |
| ១០. រៀនបទរៀនបាទ | កុំកោងហួសខ្នាត | កុំភ្លាត់ហួសផ្លូវ |
| កុំភ្លើនភ្លេចម៉ែ | កុំប្រែហួសឪ | ឃើញចាស់សក់ស្កូវ |
| | កុំស្ងួរមើលងាយ ។ | |
| បន្ទន់អាត្មា | ខ្លាចមេខ្លាចបា | ខ្លាចតាខ្លាចយាយ |
| បំរើមហាក្សត្រ | ប្រយ័ត្នស្តេចទាយ | ពាក្យពិតទំនាយ |
| | រលាយកេរ្តិ៍ឈ្មោះ ។ | |
| ពាក្យស្តេចពាក្យគ្រូ | មានប្រែមានជូរ | កម្រពីរោះ |
| ជួនទាយឱ្យទាប | ជួនទាយឱ្យខ្ពស់ | ទាយឱ្យសក្តិយស |
| | ទាយចុះកុំខឹង ។ | |
| បម្រើមើលភេទ | ចំណាំព្រះនេត្រ | ហេតុខ្លួនឱ្យដឹង |
| ខ្លួនខ្ជិលហៃព្រើល | លោកមើលសំឡឹង | សំឡក់ឱ្យប្រឹង |
| | ខំប្រិតស្វ្រូត្ររៀន ។ | |
| បម្រើមើលពុត | ប្រាជ្ញាឱ្យមុត | ស្មារតីឱ្យមាន |
| បើខ្លៅឱ្យប្រាជ្ញ | បើខ្លាចឱ្យហ៊ាន | ចង់បានរបៀន |

កុំអៀនកុំខ្មាស ។

១៩. ពុតលោកជាធំ ជ្រងោប៉ុនភ្នំ ឯងមើលមិនច្បាស់
បម្រើលោកណា លោកហ្នឹងជាម្ចាស់ លោកស្អប់អ្វីណាស់
ប្រាសចោលឱ្យឆ្ងាយ ។

កុំឈមឈរជិត កុំយកធ្វើមិត្រ ភ្លាត់ខ្លួនអន្តរាយ
បើប្រពន្ធកូន បងប្អូនចៅហ្វាយ អាពុកឬម្ដាយ
ឱនកាយប្រតិបត្តិ ។

អ្នកកុំមើលងាយ ឃើញគេរីករាយ ប្រញាប់ខ្លួនប្រយ័ត្ន
ត្រកូលញាតិផៅ កូនចៅមហាក្សត្រ ស្មើធ្លើមប្រមាត់
ប្រមាថមិនបាន ។

ទោះអ្នកដទៃ អ្នកព្រៃអ្នកព្រៃ ដែលលោករាប់អាន
កុំថាតែមនុស្ស ទោះសត្វតិរច្ឆាន ឯងស្អប់ប៉ុន្មាន
កុំហ៊ានប្រមាថ ។

របស់ឬទ្រព្យ ដែលជាសំអប់ កុំបាច់សំអាត
ទ្រព្យណាសំឡាញ់ អស់អញ្ញឱបាត ចូរចៅសង្វាត
ជួយថែរក្សា ។

២០. កុំជិះកុំជាន់ ស្មៅផ្ដីអាចម៍មាន់ ពាក្យចាស់ឧបមា
បុរាណបោរាណ្ណ ពីរបីប្រការ កុំស៊ីត្រង់ណា
ជុះដាក់ត្រង់ហ្នឹង ។

សាច់សាលោហិត កុំផ្ដូលផ្ដេកផ្ចិត ផ្ដួចទោសកើតប្ដឹង
អាពុកផ្ដែផ្ដាំ ចូរចាំចេះថ្លឹង សាច់ធ្លើមស្ងួតឆ្អឹង
និងស្បែកខាងក្រៅ ។

សាច់ស្ងួតក្នុងខ្លួន ទុកស្មើបងប្អូន ប្រពន្ធកូនចៅ
សរសៃនិងស្បែក ចែកជាញាតិផៅ ខ្ញុំស្រីខាងក្រៅ
ជាស្មៅរាចម៏មាន់ ។

ស្រីខ្ញុំកំដរ បើឃើញរូបល្អ កុំលលូកលាន់
កុំលួចលបលេង ក្រែងម្ចាស់គេទាន់ កុំភប់កុំភាន់
អាប់អន់អាត្មា ។

បើអ្នកមានយស មានសក្តិខ្ពង់ខ្ពស់ គាប់នឹងរាជការ
ធ្វើធំធ្វើថី មន្ត្រីមានត្រា ព្រះហ្លួងឧកញ៉ា
សាលាកុង្សីយ៍ ។

២១. ចេះច្បាប់បារាំង កុំភ្លេចសថ្ងំ កញ្ញ ខន្តី
កុំឆ្មើងឬសមាឌ ភ្លេចញាតិប្រុសស្រី ជំនុំកាត់ក្តី
យកឧបេក្ខា ។

កុំកាន់សីហាលោ កុំកាន់លោភោ ទោសោមោហោ
កុំជក់អាភៀន កុំឃ្លានផឹកស្រា កុំស្អប់ខាងណា
សច្ចាយកត្រង់ ។

ល្បែងលោមពិសោធ កុំឆបញ្ឆោត បញ្ចូលឱ្យបង់
ឱ្យបែកឱ្យបាក់ ពាក្យសត្យពាក្យសង្ឃ កូនអើយផ្ចិតផ្ចង់
តម្រង់ស្មារតី ។

កុំភ្លើនឃើញប្រាក់ កុំភ្លើភ្លាត់សក្តិ ធ្លាក់ទៅអវិចី
កាន់ធមិទសពិធ រឹតឡើងរាសី គាប់ពីលោកិយ
ដល់បរលោកនាយ ។

អ្នកក្តីជាភ្លើង កុំកាត់កាន់ជើង អ្នកម្ខាងមើលងាយ

ចៅក្រមជាទឹក រំឭករំលាយ កុំជេរកុំវាយ
បង្ខំនាំខុស ។

៣០. ចោរខូចល្បួចប្លន់ រីចោរស្ម័គ្រស្មន់ តណ្ហាស្រីប្រុស
កុំស្អប់ខាងណោះ បញ្ចោះខាងណោះ ល្បួងលោមបញ្ចុះ
បញ្ចូលចិត្តក្ដី ។

កុំដុតឱ្យក្ដៅ បើឃើញគ្នាខ្លៅ ប្រាជ្ញាគ្នាខ្លី
កុំឃ្លានប្រាក់ប្រុស បន្ទុះខាងស្រី បើកាន់ច្បាប់ថ្មី
កុំចោលច្បាប់ចាស់ ។

កុំដៀលអ្នកស្រែ ត្រកូលឯងខ្មែរ កុំប្រែក្រឡាស់
ក្រឡេកឃើញគុណ ទន់ខ្លួនសំពះ កុំធ្វើអ្នកណាស់
កុំឆ្មះអ្នកក្រ ។

អ្នកកុំភ្លេចគុណ គ្រូលេខនព្វន្ត គ្រូស្ទូត្រអក្សរ
កុំចាប់ដៃទាញ គំនាប់ងក់ក កុំជដៃកត
ស្មើមិត្រសំឡាញ់ ។

វាស្ទួរត់ចូលជ្រក ស្ទួរសោកទៅមក កុំអើឯងអញ
ពាក្យពុំពីរោះ គេកើតមួក្នាញ់ គេដៀលផ្ដាលផ្ដាញ់
អន្តរាយកេរ្តិ៍ឈ្មោះ ។

៣៥. កុំឆ្មើងអាងបុណ្យ ស្រដីឱ្យទន់ ពោលពាក្យពីរោះ
ខ្លួនអ្នកនឹងថ្កើង នឹងឡើងសក្ដិយស កុំឆ្មៀតនាំឈ្មោះ
ញុះញង់អ្នកធំ ។

កុំស្អប់អ្នកតូច បើឃើញគ្នាខូច គួរគិតប្រមុំ
ទោសគ្នាតិចតួច ផ្ដួចឡើងជាធំ ផ្សេងពួតជាដុំ

ផ្ទុំឆេះជាភ្លើង ។

កុំភ្លើនភ្លេចខ្លួន ចេះសាសន៍ចិនយួន កុំចោលខ្មែរយើង
កុំធ្វើក្រអឺត កុំពើតកុំពើង កុំពាក់ស្បែកជើង

ចូលវត្តលោកសង្ឃ ។

ដោះមួកដាក់ឆត្រ ឱនកាយប្រតិបត្តិ លំអុតឱនអង្គ
កុំស៊ីពាមឃ្លាន កុំហ៊ានពាមចង់ កាន់ច្បាប់ស្រុកប្រហង្ស៍

កុំបង់សាសនា ។

កុំចង់ថ្កើងពេក កុំលើកដំណេក ហួសមេហួសបា
តែងខ្លួនឱ្យល្មម មើលពូជពង្សា សង្វេបនិដ្ឋិតា

រឿងផ្ដាប់បុណ្យសក្តិ ។

៤០. បើទៅជារាស្ត្រ ប្រាជ្ញាវៃឈ្លាស គួរវាសឆ្លកឆ្លាក់
ឱ្យឆ្លៀតរកពុន បើធូន់សុំដាក់ ខំរកមាសប្រាក់

ឱ្យគ្រាន់ទាន់ចាយ ។

រាជ្យបារាំងសែស កូនកុំប្រហែស កុំថ្មមរូបកាយ
ដើរតិតដេកតិត ជួញជិតជួញឆ្ងាយ បើចង់សប្បាយ

ស្រេចនៅមានទ្រព្យ ។

រាជ្យហ្លួងពីមុន រកស៊ីរកពុន មានក្រុពាមភ័ព្វ
រាជ្យលោកឥឡូវ ត្រូវខំឱ្យញាប់ តែខ្ជិលច្រើនជាប់

ខ្នោះជើងខ្នោះដៃ ។

តាំងពីឆ្នាំច ចាំជាដំណា(១) ទំនិញឡើងថ្លៃ
ចងក្បិនឱ្យតឹង ប្រឹងកុំសំចៃ សញ្ញើងយប់ថ្ងៃ

(១) . តំណា

កុំឱ្យក្រខ្សត់ ។

បើចង់ស្រាលខ្លួន រៀនសូត្រឱ្យមួន ឱ្យមាំឱ្យស្ទាត់
កុំចេះស្ទាក់ស្ទើរ ល្ងើល្ងើឥតបទ បើចេះប្រាកដ
ប្រាក់រត់តាមហៅ ។

៤៩. កុំថ្នមកម្លាំង កាប់ជីកចូកចាំង កុំថារងាក្តៅ
រៀនអ្វីឱ្យផ្ចិន កុំឱ្យខ្លោចឆៅ កុំដេកតែខ្លៅ
ក្រក្រៅសណ្តាប់ ។

បើល្ងង់ឱ្យចេះ រករៀនតម្រិះ រិះរកតម្រាប់
ផន្ទើយឆ្វេងស្តាំ កុំចាំគេប្រាប់ រៀនស្តីរៀនស្តាប់
រៀនមើលឱ្យស្លែង ។

កើតមកជាមនុស្ស ទាំងស្រីទាំងប្រុស មិនដែលចេះឯង
បើក្រឱ្យមាន វិញ្ញាណចេះព្រែង គិតគ្រប់កន្លែង
កុំដេកតែក្រ ។

កុំប្លន់កុំលួច កុំខ្ជិលកុំខូច កុហកឆ្កួតឆ
បោកប្រាសយកប្រាក់ ច្រវាក់ជាប់ក កាន់មារយាទល្អ
សុចរិតត្រឹមត្រូវ ។

កូនអើយរកស៊ី កកាយធរណី ធ្វើស្រែយកស្រូវ
កុំតាមអ្នកណា បាតាមតែឪ លើកភ្លឺជិតផ្លូវ
កុំស្រោស់បន្លា ។

៥០. គេដើរយប់ថ្ងៃ មុតជើងមុតដៃ ដឹងចៀសទៅណា
ចៀសចុះជាន់ស្រូវ ហើយជេរផ្តាសា កូនម្តាយអាណា
ស្រោស់ដើរមិនរួច ។

កុំយកគល់ឈើ ទៅដាក់ពីលើ ទោះធំទោះតូច
ជំពប់ជើងគេ គេថាឯងខូច ជេរដៀលដល់ពូជ
ប្រដូចមេបា ។

លើកភ្លឺឱ្យធំ បង្ហាប់ឱ្យមាំ គាប់ភ្នែកទេវតា
ស្មើបានសង់ស្ពាន នឹងមានផលា កើតសាធុការ
អាយុយឺនវែង ។

កូនអើយធរណី បើតាមគម្ពីរ ដែលលោកសម្ដែង
កុំចង់បានធំ ប្រមុំឆ្មៀលឆ្វេង កុំលើកដីឯង
លបដាក់ស្រែគេ ។

អំពើអាក្រក់ មួយចំរៀកសក់ ធ្លាក់ទៅនិរយេ
បច្ចុប្បន្នលោកិយ កើតក្ដីវាយជេរ មិនដែលសុខទេ
ព្រោះដីមួយហត្ថ ។

៩៥. កុំជួញចង់ទាស់ ខូចខាតរបស់ អស់ទ្រព្យសម្បត្តិ
ចង់គង់ប្រយោជន៍ ឱ្យចេះប្រយ័ត្ន ពាក្យឪមួយម៉ាត់
ឱ្យគិតមួយម៉ោង ។

សំអាតផ្ចិតផ្ចង់ លើកភ្លឺឱ្យត្រង់ កុំលើកឱ្យកោង
អ្នកកុំប្រហែស ក្រែងមានប្រហោង លើកមើលទំនង
ទំនាបទឹកហូរ ។

ចំនួនទឹកស្ទឹង ទឹកព្រែកទឹកបឹង ទឹកវាលទឹកអូរ
អ្នកលើលិចស្រូវ ត្រូវបើកបង្ហូរ អ្នកក្រោមកុំថ្នូរ
បន្ទូរហួសទៅ ។

រាំងរឹងថ្ងៃយប់ ឆាប់លើកឆាប់ទប់ កុំឱ្យបាក់ជ្រោ

កត្តិកចេញខ្យល់ ឥម្តល់ទឹកនៅ បើចង់បានស្រូវ
ស្រេចនៅត្រឹមថៃ ។
កុំយកគ្រាប់ត្នោត ទៅដាំទៅដោត ពីលើភ្លឺស្រែ
ចិត្តគិតប្រមាណ ចង់បានផ្កាផ្លែ ដាំដុះបង្ហែ
បង្ហិនខ្លួនឯង ។
៦០. ដល់ត្នោតឡើងគល់ ឡើងកើតនាំខ្វល់ ផាងល្វេតឡើងវែង
ភ្លួរវាស់ជាប់នឹម ក្របីជាប់ស្នែង ទទើសទទែង
ភ្លួរឆ្វេងមិនត្រូវ ។
ដល់ត្នោតវាធំ មានស្លឹកវាទុំ វាជ្រុះក្នុងស្រូវ
ស្រែឆ្ងាយពីផ្ទះ ឃ្លាតណាស់ពីផ្លូវ ទំរាំតែទៅ
រលួយស្រូវអស់ ។
កូនអើយកុំធោត បើចង់បានត្នោត ដាំដោយកៀនកោះ
ដីទួលចំការ ឯណាចន្លោះ ដាំជារបោះ
ជាយជួររបង ។
របៀបចំការ ថៃទាំរក្សា យូរ ៗ ស្រាស់ម្តង
ស្រាស់ឱ្យត្រូវជួរ មើលគួរសមផង កុំបើកមុជឆ្លង
ទៅស្រាស់ខាងក្រៅ ។
មិនគាប់ប្រសើរ របងវាដើរ អ្នកម្ខាងវាក្តៅ
កើតក្តីកើតក្តាំ អស់ខោរអស់អាវ ខឹងអស់ញាតិផៅ
ពីព្រោះចំការ ។
៦៥. មួយទៀតរបង ជិតផ្លូវអ្នកផង គេទៅណា ៗ

ធ្វើឱ្យទូលាយ កុំវាយបន្លា កាប់ឆ្អើស[១] ទាត់ឆ្ការ
ឱ្យឆ្ងាយពីផ្លូវ ។

កុំធ្វើចង្អៀត ព្រៃងយប់អគ្រោត្រ ខ្លះមកខ្លះទៅ
ចៀសគ្នាមិនរួច បើកបរកាត់ស្រូវ ដើរម្ដាយតាមផ្លូវ
រហូតដល់ផ្ទះ ។

កូនអើយអ្នកចាំ អ្នកកុំចងកម្ម មានពៀរច្រើនណាស់
ជាតិក្រោយខ្វាក់ខ្វិន កខ្វេះកខ្វាស ស្អូវចោលដីខ្លះ
មិនខាតប៉ុន្មាន ។

កុំខ្លាចពៃក្រ ធ្វើឫកមិនល្អ ច្រើនកើតរឱស្ថាន
រអែករអោក បាត់ញាតិសន្ដាន ឥតគេរាប់អាន
មានតែគេស្អប់ ។

កាន់ឫកឱ្យខ្ពស់ ឱ្យខ្ពើមពាក្យឈ្មោះ ទើបបានជាគាប់
យកឆោតដាក់ខ្លួន ច្រើនមានគេរាប់ បើខ្លួនឥតទ្រព្យ
កុំផ្លាប់ហ៊ានខ្ចី ។

៧០. គ្រប់ការសារពើ ចង្អេរកញ្ជើ កន្ត្រាំងតៅល្អី
រនាស់រទេះ គោសេះក្របី បើបានជាខ្ចី
ខ្ចីប្រាក់គេទិញ ។

យកមករកស៊ី ខែមួយខែពីរ សងប្រាក់គេវិញ
របស់បានយើង ជាជើងជួញចេញ ឯទ្រព្យនោះទិញ
ពេញជាទ្រព្យឯង ។

កុំខ្ចីគេប្រើ តែមួយដំណើរ មិនយូរអង្វែង

(១) ឆ្អឹះ

ជូនជាបាក់បែក ជជែកចាស់ទែង សងគេមិនលែង
ចាស់ផ្លាស់ជាថ្មី ។

កើតមកជាប្រុស គិតឱ្យសព្វសុស កុំឱ្យសល់អ្វី
បួសរៀនធម៌អាថ៌ សាស្ត្រាបាលី បរលោកលោកិយ
កុំបីចន្លោះ ។

សឹកមករកស៊ី កកាយធរណី ធ្វើជាគ្រហស្ថ
កុំហាកជឿបុល បំណុលរុំកោះ ច្រើនគេដាក់ខ្នោះ
អស់ស្រែចំការ ។

៧៥. ធ្វើរាស្ត្ររកស៊ី ចិញ្ចឹមគោញី ថែទាំព្យាបាល
ក្របោតុពីខ្ជិល មានដ្បិតឧស្សាហ៍ អ្នកមានប្រាជ្ញា
មិនស្មើគំនិត ។

កំណើតសំណាង សំណូមសូមសាង កកើតពិគិត
ពីកាលជាតិមុន បុណ្យព្រេងអតីត កើតរូបគំនិត
ទើបកើតសំណាង ។

ឯមនុស្សសំណល់ ល្ងង់ល្ងើងឿងឆ្ងល់ ចាស់ទែងក្មេងក្លាង
ដប់ឆ្នាំនេះហើយ ប្រកាន់មយ៉ាង១ ខ្លះអួតសំណាង
ខ្លះអាងគំនិត ។

កូនចៅប្រុសស្រី រកប្រពន្ធប្តី ឱ្យរកស្រុកជិត
បើរកស្រុកឆ្ងាយ ឱ្យម្តាយពិនិត្យ ឱ្យត្រឹមត្រូវពិត
ពូជពង្សាវតារ ។

កូនអើយអ្នកចាំ កុំជឿខែឆ្នាំ កុំជឿតម្រា
ពាក្យក្បួនតម្រាយ កើតពីមនុស្សចារ ពីដូនពីតា

ចារតាមសម្គាល់ ។

៨០. អ្នកជឿតែពួជ អម្បូរធ្លាប់ខូច វាខូចរៀងរាល់
ពូជមានវាមាន ពូជទាល់វាទាល់ កុសលអកុសល
យើងមើលមិនជាក់ ។

ប្រពន្ធនិងប្ដី អាយុវែងខ្លី យើងមើលឃើញច្បាស់
កុំយកពូជល្បែង ពូជភ្លេងអារក្ខ បើម្ដៃបង់ប្រាក់
រកអាយុវែង ។

អម្បូរពង្សពូជ ត្រកូលធ្លាប់ខូច វាខូចមិនលែង
ពូជចោរស្រីៗ យកប្ដីចិត្តឯង មិនគិតកោតក្រែង
ខ្លាចចិត្តមេបា ។

កូនចៅស្រីៗ បើនឹងយកប្ដី ឱ្យមើលកិរិយា
មួយភ្លេងអារក្ខ មួយអ្នកបាណា មួយអ្នកផឹកស្រា
មួយអ្នកចង់ស្រី ។

មួយអ្នកក្រមាច់ លេងផោមលេងអាចម៍ អាយុច្រើនខ្លី
ប្រកាច់ដាច់លក្ខណ៍ ជាន់អារក្ខព្រៃ មួយគឺមន្ត្រី
ធ្វើក្រមជិទប់ ។

៨៥. ជិទយតែដើរ មេស្រុកគេប្រើ ទាំងថ្ងៃទាំងយប់
មានមួកខ្វះឆ័ត្រ កម្រមានគ្រប់ មួយទៀតកុំភប់
ជួញប្រាំប្រការ ។

ប្រាកដជាខុស លក់សត្វទាំងរស់ មិនចេះអនិច្ចា
សព្វសត្វអ្វីៗ បក្សីបក្សា ព្រាត់មេព្រាត់បា
ទេវតាលោកលក់ ។

លោកិយនេះខ្សត់ យម្ភបាលគេកត់ នៅស្ថាននរក
មួយហួយអាប៉ោង ប៉ោបៀគ្រប់មុខ កូនអើយចាំទុក
ក្រគ្រប់ប្រាំបី ។

ឯអ្នកទាំងអស់ រកស៊ីម៉េះម៉ស់ ច្រើនជាងស្រី ៗ
ប្រាជ្ញានោះវែង គំនិតនោះខ្លី ប្រពន្ធជេរស្តី
អាងឈ្លោះបំពាន ។

នេះពួជអ្នកក្រ រស់ទាំងត្រដរ ទាំងអត់ទាំងឃ្លាន
ធ្វើគុណនឹងគេ រកគេសងគ្មាន ហេតុនេះកុំរៀន
ទាំងប្រាំបីផ្លូវ ។

៩០. យ៉ាងអ្នកនេសាទ មិនដែលសង្វាត ធ្វើស្រែបានស្រូវ
ប្រព្រឹត្តសាងកម្ម ប្រចាំរដូវ វង្វេងខុសត្រូវ
ព្យាយាមសម្លាប់ ។

អន្ទាក់ជង់កុក អង្រុតឈ្នាងឆ្នក់[១] គ្រប់គ្រឿងប្រដាប់
ថ្លុកបៀត្រពាំង ទប់បាំងបាចចាប់ ចោលស្រូវកណ្តាប់
កណ្តៀវកាត់អស់ ។

កំពប់ខ្លាត់ខ្លាយ ខ្ជូចខាតអន្តរាយ មិនស្តាយស្រណោះ
យប់រវល់ប្របក់ ចង់បានត្រីរស់ ខែភ្លឺរវល់ឆ្លុះ
ដើរដេញសំពោច ។

វក់តែសប្បាយ ដើរដេញទន្សាយ ដើរចងសន្ទូច
អំពើអស់នោះ ច្រើនខ្វះស្រូវពូជ ធ្វើបានតិចតួច
អាងជឿគេស៊ី ។

---

(១) វចនានុក្រមខ្មែរថា ឈ្នក់

កូនអើយបំណុល ចងការជឿបុល មួយឡើងជាពីរ
អ្នកភ្លេងអារក្ខ ច្រើនទឹមគោញី ធ្វើស្រែមួយពីរ
ធ្វើសោះតែខាន ។

៩៩. ថ្ងៃដេកក្រភាក់ យប់លៀងអារក្ខ ឈឺផ្អាលសន្ដាន
គេស្ទីគេពឹង នឹងឈប់ពុំបាន គេរករាប់អាន
កាលមានធុរៈ ។

ផ្ដីប៉ុក្ខពទ្រ ស្រែកច្រៀងវាយស្គរ មិនបានលុយកាក់
ឯងពឹងគេវិញ គេគ្មានជំពាក់ ពឹងបានម្នាក់ៗ
ដោយសារឱ្យថ្លៃ ។

ឡើងខ្ពោតភ្លូវស្រែ កម្រទាន់គេ ដ្បិតដេកដល់ថ្ងៃ
ច្រូតកាត់ចង់នាប់ ជួលគេពេញថ្លៃ ចំណេះចង្រៃ
នាំខាតធ្វើការ ។

ឯខ្មោចអារក្ខ ស្លាប់ដប់រស់ម្នាក់ ថ្វាយចេកថ្វាយស្រា
សុំពះនឹកគុណ ខ្មោចប្រេតជូនពា មិនដែលអ្នកណា
នឹកគុណអ្នកភ្លេង ។

ឯអ្នកប្រមឹក ប្រមូលកនផឹក ធ្វើរឿននឹងក្មេង
សំដីច្រើនពឹង ស្រវឹងវង្វេង ជិះហោអួតក្អេង
មិនចេះក្រខ្សត់ ។

១០០. អួតទាំងបំពាន ផឹកម៉្ញលុយមាន ផឹកម៉្ញលុយអត់
ឯងចេះតែកិន មិនចេះតែកត់ ផឹកដល់កំណត់
យកស្រែបញ្ចាំ ។

សល់ថ្នាលមួយពីរ វាយគោស្ទោរស៊ី មិនគិតខ្លាចកម្ម

ផឹកជ្រុលហួសល្បត់ អត់បាយរាប់ឆ្នាំ អស់ស្រែបញ្ចាំ
បញ្ចាំកូនទៀត ។
កំណើតផឹកស្រា ផឹកផុតមេត្តា ផឹកជ្រុលហួសមាឌ
អ្នកមួយផឹកស្ទើរ ល្ងីល្ងើចេះឆ្លៀត ម្យ៉ាងផឹកផុតមារយាទ
ច្រើននៅខ្ញុំចិន ។
រែកទឹកពុះខស វាទុញវាតុះ ចាក់កែវផឹកសិន
ស៊ូរែកខំអត់ សំពត់ខៀចក្បិន ទំរាំបាយឆ្អិន
ចិនដួសហៅស៊ី ។
ឆ្ងាញ់តែម្នាក់ឯង ឆ្អែតហើយខំស្វែង ខំលើកខំលី
ដងទឹកស្រោចគ្រប់ ស្រោចខ្ចីមម្ទេសជីរ ខ្ញុំចិនម៉្ងៃពីរ
វិលទៅរាំងផ្ទះ ។
១០៥. ឯអ្នកចង់ស្រី ប្រពន្ធពីរបី ថាឯងអ្នកណាស់
គន់ឯសំពត់ តែមួយបន្លាស់ ពាក់អាវបំណាស់
កម្រមានថ្មី ។
ផ្ទះលេចវាលល្វឹង ជញ្ជាំងចងហ៊ឹង ស្លាធំរបាយសិ
ខ្ជិចប្រែងក្រមួន មួស្លាបារី កំឡោះពីរបី
ចោមរោមរៀនស្នេហ៍ ។
រៀនស្នាលរៀនស្និទ្ធ កើតក្តីពិពិត ព្រួយចិត្តឪម៉ែ
កូនរើយប្រពន្ធ អាងមន្តពួកែ ត្រូវគុកជប់ខែ
អស់ស្រែត្រពាំង ។
ធម្មតាប្រពន្ធ បានដោយសិល្បមន្ត ដោយស្វាត់កំបាំង
រកស៊ីលៀនភ្នែក បានរែកខ្វះឆ្នាំង បានល្អឹកន្ដាំង

នៅខ្វះចង្អេរ ។

បាននេះខ្វះនោះ ក្រហេតុពីព្រោះ អាពុកម្ដាយជេរ

បើចូលជំនុំ មិនរមូរដូចគេ អង្គុយវេះវេរ

មិនហ៊ានហាលមុខ ។

១១០. នេះពុតអ្នកក្រ ចាំជាតំណ តជាទំនុក

ប្រយ័ត្នជំនៀល គេដៀលអាពុក កូនអើយចាំទុក

ចាំតកូនចៅ ។

រក្សាពូជពង្ស បើខ្លួនល្ងីតល្ងង់ ស្ដាប់ចាស់ប្រដៅ

កុំស្អប់អ្នកប្រាជ្ញ កុំខ្លាចអ្នកខ្លៅ បើមនុស្សឆោតឆៅ

កូនឯងកុំភប់ ។

កុំភ័យខ្លាចអត់ មើលឱ្យប្រាកដ គួរយកគួរឈប់

គួរឈានគួរឈោង តោងមើលឱ្យគ្រប់ កុំចេះតែងប់

មិនស្ដាប់ឪម៉ែ ។

រកប្ដីប្រពន្ធ ឱ្យគិតឱ្យគន់ ឱ្យមើលថ្នូនថៃ

ត្រកូលក្រខ្សត់ ប្រាកដតាមខ្សែ បីដូចឈើផ្លែ

មិនដែលចេះក្លាយ ។

ជួរផ្អែមធំតូច ដើមក្រូចផ្លែក្រូច ដើមស្វាយផ្លែស្វាយ

ពូជស្រីចោរក្បត់ មិនអត់សាហាយ ពូជស្រីមេម៉ាយ

ពីម្ដាយដល់កូន ។

១១៥. រើសពូជមិនខុស ពូជសាំងនឹងប្រុស ទាំងអស់បងប្អូន

ពូជសែនមេបា ពីតាដល់ដូន ពូជល្អសុទ្ធសូន្យ

ពីដូនដល់ចៅ ។

រក្សរូបមិនក្រ អាក្រក់ហើយស មារយាទល្អហើយខ្មៅ
ស្រីក្មេងមានខ្លាស ចាស់ចង់ប្រដៅ ប្រដូចតាមផៅ
មិនសូវខុសខាន ។

ពាក្យចាស់លោកថា ធ្វើស្រែចំការ ស្តាប់មហាសង្ក្រាន្ត
ធ្វើម្តងខុសខាត ធ្វើម្តងទៀតបាន ធ្វើតាមប្រមាណ
ប្រមើលទឹកភ្លៀង ។

រកប្តីប្រពន្ធ ឱ្យគយឱ្យគន់ រើសរករូបរាង
ពូជថ្លៃល្អមយក ពូជថោកល្អមវាង រូបល្អឫកល្អៀង
នាងកុំប្រសព្វ ។

ជាតិស្រីនិងប្រុស បើបានជាខុស ខុសទាល់ចាស់ងាប់
បើបានរូបល្អ កម្រមានភ័ព្វ មានខុសមានគាប់
ដូចស្រែចំការ ។

១២០. មួយទៀតអ្នកចាំ អាពុកចំណាំ ទុកជាតម្រា
កុំយកតម្រាប់ កុំស្តាប់អាចារ្យ បើនឹងរៀបការ
កុំការប្រធូន ។

ប្រជែងវេលា ឮសួរឆ្លើយគ្នា ប្រទប់ប្រទូន
ស្រុកជិតភូមិផង របងដោយខ្លួន អាចារ្យអាងក្បួន
ថាសុខសប្បាយ ។

កូនអើយអ្នកចាំ យូរណាស់៤ឆ្នាំ ព្រាត់ប្រាសអន្តរាយ
ច្រើនស្លាប់ពានាក់ រស់ម្នាក់មេម៉ាយ កូនឃើញតែម្តាយ
មិនឃើញអាពុក ។

មានកាលស្លាប់ស្រី ស្លាប់ចោលកូនខ្ចី ប្តីនៅរងទុក្ខ

យកប្រពន្ធទៀត កម្រពេញមុខ កូននិងអាពុក
បែកគ្នាខ្ចាត់ខ្ចាយ ។
កូនចៅស្រីៗ បើនឹងយកប្តី កុំយកពោះម៉ាយ
សូវនៅម្នាក់ឯង បន្ទោងនឹងម្តាយ អាណិតរូបកាយ
ស្តាយខ្លួនក្រមុំ ។
១២៩. ហៅប្រុសអភ័ព្វ ប្រពន្ធដើមស្លាប់ មានកូនតូចធំ
យកឯងជាចុង បំរុងតែយំ ច្រើនឈ្មោះជំនុំ
ព្រួយចិត្តម៉ែឪ ។
ហៅប្រុសចិត្តពីរ ពិបាករកស៊ី រញ៉ាំរញ៉ូវ
ឯងនឿយស្ទើរស្លាប់ ផ្គាប់ចិត្តមិនត្រូវ បីបួនរដូវ
ខ្លួនឯងស្លាប់ទៀត ។
ចង្រៃខាងប្រុស កូនអើយចាំចុះ កុំយកខ្លួនបៀត
ស្រីណាខំយក ស្រីនោះបង់មារយាទ ប្រុសព្រួយខ្ចប់ធាតុ
ខ្ចប់គ្រប់ជាបី ។
យកទៀតជាប្អូន គ្រោះដល់ស្លាប់ខ្លួន មេម៉ាយខាងស្រី
ប្រាកដមិនខុស ប្រុសក្នុងលោកិយ ស៊ូនៅអត់ប្តី
ស្លាប់រស់រូបមួយ ។
បើខ្លួនកំព្រា រំពឹងមីងមា រកស៊ីមិនព្រួយ
កាន់មារយាទល្អ មិនក្រគេជួយ បងប្អូនកូនក្មួយ
រត់ចូលឱ្យប្រើ ។
១៣០. ពោះម៉ាយមានបី កុំយកធ្វើប្តី មិនគាប់ប្រសើរ
អាមួយស្រីលែង ស្រីគេគ្រាន់បើ ពោះម៉ាយក្លាយដើរ

អាងលែងប្រពន្ធ ។

ពោះម៉ាយទាំងអស់ កុំយកឱ្យសោះ ហៅប្រុសទូរជន[១]
ទូរជាតិ[២] អប្រិយ ស្រីកើតទុក្ខធ្ងន់ ហៅមួយជំនាន់
ចំណាំមិនខុស ។

កំឡោះចាស់យូរ ចាស់ទុំគេប្ដូរ ល្មមព្រមយកចុះ
រកស៊ីមានបាន សុខសាន្តឥតឈ្លោះ ចំរើនរូបរស់
អាយុយឺនយូរ ។

កុំយកប្ដីប្អូន ថោកវាសីខ្លួន រកស៊ីមិនធូរ
គេហៅឯងធំ សមហៅគេពូ ច្រើនខ្ជិលមូរទូ
ម៉េះម៉ស់នឹងល្បែង ។

វាច្រើនមើលងាយ ហៅស្ដីនិយាយ ហៅហាងហៅឯង
ខ្លួនយើងជាស្រី ស្រដីឥតក្រែង យល់គេប្អូនឯង
ឯងមើលងាយជេរ ។

១៣៥- ពាក្យចាស់លោកចង ប្ដីទុកស្មើបង ប្រពន្ធស្មើម៉ែ
មើលងាយរាល់ថ្ងៃ ចង្រៃរាល់ខែ រកស៊ីធ្វើស្រែ
ច្រើនខាតគ្រាប់ស្រូវ ។

គួរយកប្ដីបង ពាក្យចាស់លោកចង ទុកប្ដីស្មើឪ
ខ្លួនឯងប្រមាថ ប្រតិបត្តិឱ្យត្រូវ វាសីគង់នៅ
ទេព្រក្សរក្សា ។

ប្រពន្ធនិងប្ដី ធំស្រេចនឹងស្រី គត់គង់កិរិយា
ឈ្លោះហើយច្រើនខ្សត់ ស្រីអត់លក្ខណា ប្ដីខ្ជិលឧស្សាហ៍

(១) ទុរជន, (២) ទុរជាតិ

ព្រោះឫកប្រពន្ធ ។

ជាតិស្រីមានលក្ខណ៍ ទេវតាពំនាក់ កបកើតទ្រព្យធន
ប្រទេចជេរវាយ ចង្រៃទូវជន ជួជាតិលើសលន់
លើសលុបលើប្រុស ។

យោកាឡកិណី វាយកូនជេរប្ដី មិនដឹងត្រូវខុស
បើមានភ្ញៀវមក រឹតរករឿងឈ្លោះ អសោចសាយសុស
រង្គោះធនធាន ។

១៤០. រកស្រីមារយាទខ្ពស់ ចេះខ្ទើមពាក្យឈ្លោះ ចេះទ្រាំអត់ឃ្លាន
ចេះស្លូតចេះកាច ចេះខ្លាចចេះហ៊ាន ចេះខ្មាសចេះរៀន
កាចមានប្រាជ្ញា ។

កូនចៅស្រីប្រុស ចំណាំទុកចុះ ទុកជាតម្រា
គួរយកតម្រាប់ គួរស្ដាប់ពុទ្ធដីកា ព្រះអង្គទេសនា
គាថាបួនបទ ។

រៀនត្រាប់អ្នកប្រាជ្ញ បើចង់ឈ្នះកាច យកស្លូតសង្កត់
ចង់ឈ្នះមនុស្សខឹង ឱ្យប្រឹងខំអត់ វាជេរវាហត់
វាស្បថលែងខឹង ។

ចង់ឈ្នះអសុរោះ ស្ដីលេងឡេះឡោះ កុំធ្វើជាដឹង
យើងស្ដីត្រង់ណា ឱ្យចំត្រង់ណឹង ឃើញឫកយើងរឹង
ខ្លាចយើងខាងក្រោយ ។

ចង់ឈ្នះកំណាញ់ ក្រដេក្រដាញ់ សុំអ្វីមិនឱ្យ
បើបានចំណី ហុចវាញយៗ តិចដោយច្រើនដោយ
ក្នុងតែវាដឹង ។

១៤៩. នេះមន្តព្រះពុទ្ធ ប្រាជ្ញាឱ្យមុត ឱ្យគិតថ្លែងថ្លឹង

កុំកាចខុសខ្នាត កើតខាតដ្បិតខឹង កូនអើយខំប្រឹង

កាន់ច្បាប់ទាំងបួន ។

កុំជួញរវល់ កុំតបតទល់ កើតទាស់គុំគួន

កូនណាកាន់បាន កូននោះសុខខ្លួន ទោសទាស់លែងជួន

លែងជួបមួយជាតិ ។

បើមនុស្សវែកទូល មកនៅចំណូល ញ៉េះញ៉ស់ធ្វើញាតិ

ឱ្យមើលលៃលក កុំយកខ្លួនបៀត វាទូលទៅទៀត

អសារឥតការ ។

ចំណីចំណុក បើឱ្យស៊ីចុក ឱ្យដោយមេត្តា

កុំឱ្យជឿខ្ចី ក្រែងខុសសន្យា កើតទាស់កាលណា

រើរែករត់បាត់ ។

មនុស្សគ្មានកន្លែង ខុសពីមារយាទឯង មិនប្រុងប្រយ័ត្ន

តាមទាន់តឹងទារ វាខឹងក្តៅក្តាត់ គុំគួនដោយស្ទាត់

បំភ្លាត់ឯងបាន ។

១៥០. ហេតុនេះគួរគិត គួរកូនពិនិត្យ ច្បាស់សុំរាប់អាន

គួរឱ្យសុំឱ្យ គួរខានឱ្យខាន ដ្បិតពាក្យបុរាណ

មានពីរចំណែក ។

ចងទុកជាក្បួន ចិត្តល្អក្រខ្លួន នេះពាក្យមួយប៉ែក

មួយទៀតចិត្តល្អ មិនក្រយួរពេក ឆ្នាំនេះឆ្នាំភ្នែក[១]

ក្នុងតែនឹងមាន ។

(១) ស្មែក ?

ចិត្តល្អក្រខ្លួន ចាំទុកជាក្បួន ជាក្បាលនិទាន
ឃើញអ្នកទូរគត កំសត់អត់ឃ្លាន មិនស្គាល់ពោះវៀន
ហ៊ានឱ្យជឿខ្ចី ។

ទៅទារមិនឱ្យ តឹងតឿនញយៗ ខឹងប្តឹងកើតក្តី
ខាតទាំងទ្រព្យចាស់ អស់ទាំងទ្រព្យថ្មី ស្តមគោក្របី
រវល់ក្តីខានថៃ ។

ចិត្តល្អមួយទៀត មេត្រីជាញាតិ សំដីខ្ចីស្រែ
បានស្រូវស៊ីស្កប់ ត្រឡប់កាច់កែ រំលងឆ្នាំខែ
ដកហូតមិនបាន ។

១៥៥. ឯងប្តីឯវា.ត ក្តីទាល់តែក្រ អស់ឆ្នាំងអស់ចាន
របស់ក៏ខាត របរក៏ខាន ដីងអស់ប៉ុន្មាន
ទំរាំចាញ់ឈ្នះ ។

ទ្រព្យធនអ្វីៗ ចងការជឿខ្ចី មើលមុខឱ្យច្បាស់
កុំចោលច្បាប់ខ្មែរ កុំភ្លេចច្បាប់ព្រះ ពាមតែប្រទះ
ប្រទាញសងខាង ។

ចាំចិត្តកណ្តាល បើនឹងឈឺឆ្អាល សប្បុរសមើលយ៉ាង
រៀនស្លូតរៀនប្រាជ្ញ កាចកុំក្អេងក្អាង ក្រែងគ្រោះសំណាង
ខ្មោចខាងវាស្អប់ ។

ល្អមិនក្រយូរ ស្វែងរៀនរកគ្រូ ស៊ូកុំស្តាយទ្រព្យ
គ្រូវាយកុំខឹង ឱ្យប្រឹងខំផ្ចាប់ ចេះមន្តសាយសព្វ
ត្រឡប់ជាមាន ។

ធម្មតាអ្នកចេះ អ្នកស្វែងចំណេះ ចេះឆ្បិតខំរៀន

ធ្លាក់គួរក្បួរក្បាច់ សាច់សិល្ប៍របៀន អ្នកខ្សត់អត់ឃ្លាន
ព្រោះចិត្តអាក្រក់ ។

១៦០. ខូចខិលល្ងង់ខ្លៅ ត្រូជេរប្រដៅ ខឹងលបសំឡក់
របញ្ជរបុញ ភូតភរកុហក ស៊ូប្លន់លួចឆក់
មិនខំធ្វើស្រែ ។

អ្នកប្លន់អ្នកលួច ឆក់បានតិចតួច បានគ្រាន់បើដែរ
ដល់គេឃើញមុខ ត្រូវគុកច្រើនខែ អាក្រក់ដល់មែ
ខូចកេរ្តិ៍ដល់ឪ ។

ចង់ខ្ពស់បានទាប ចចើងចង់លាភ វែងបាត់ធនទៅ
ពាក្យពីបូរាណ លោកអានតំរូវ ឬកមនុស្សឥឡូវ
ត្រូវតាមតម្រាយ ។

អ្នកលួចអ្នកប្លន់ ចង់បានប្រពន្ធ ចេញជួញស្រុកឆ្ងាយ
ទិញងារមេស្រុក ស្ងូកធ្វើចៅហ្វាយ ចង់ធ្វើងសប្បាយ
ចាយប្រាក់រាជការ ។

ឆបាំងបំបាត់ លួចបានដោយស្ងាត់ អាងមានប្រាជ្ញា
ក្រឡេចថ្នាំងដៃ កាឡៃបោះត្រា ទាស់ភ្នែកទេវតា
រក្សាផែនដី ។

១៦៥. មួយទៀតទូរជន ធ្វើបាបបានបុណ្យ គឺបុណ្យមន្ត្រី
ទោសទៅចងចាប់ កាប់ឥតប្រណី បានបុណ្យមន្ត្រី
ព្រោះបុណ្យធ្វើបាប ។

អំពើទាំងអស់ កុំសាងឱ្យសោះ ចៀសវាងដរាប
កាន់សីលព្រះពុទ្ធ ឱនលុតលួនក្រាប បើក្រដុនដាប

មានទេវតាជួយ ។

ក្មួនអើយទេវតា ស្ថិតសព្វព្រឹក្សា រងោករង្គួយ
មនុស្សទ្រុស្តឫស្យា ឯណានីមួយ ទេវតាពុំជួយ
ចំណាំស្គាល់មុខ ។

មិនដែលកំបាំង រាជការបារាំង គេចាប់ដាក់គុក
ដល់ខ្លួនស្លាប់ទៅ នៅរងសោយទុក្ខ សោយទោសនរក
ទាំងពីរកន្លែង ។

នរកបារាំង មានខ្សោយមានខ្លាំង មានខ្លីមានវែង
នរកយមបាល គេផ្ដាលឥតក្រែង ព្រះអង្គសំដែង
ថាលានកោដិឆ្នាំ ។

១៧០. ហេតុនេះគួរវាង គួរចាលគួរវាង គួរចងគួរចាំ
គួរកុំធ្វើបាប ដរាបខ្លាចកម្ម គួរកាន់សីលប្រាំ
បណ្ដាំសាសនា ។

ហៃក្មួនចៅអើយ ក្រឡាប់អស់ហើយ មិនដូចដូនតា
ភ្លៀងជន់ខែប្រាំង រាំងខែវស្សា ឆ្នាំវករកា
ត្រីស័កនេះឯង ។

រនោចផល្គុន រកាពីមុន ឯកស័កដាក់ស្នែង
ក្នុងខ្មែតផល្គុន ជន់គ្រប់កន្លែង ទាំងគេទាំងឯង
ធ្វើស្រែបានផល ។

ឆ្នាំរោងឆស័ក វិសាខភ្លៀងធ្លាក់ ពីររោចសំគាល់
យប់ថ្ងៃអាទិត្យ ងងឹតព្យុះខ្យល់ ភ្លៀងជន់ពេញថ្នល់
ពេញវាលតូចធំ ។

ពេញអូរពេញជ្រោះ ដើមឈើទាបខ្ពស់ រលុះរលំ
ឫស្សីស្រុកយើង រលើងទាំងគុម្ព ទើបគ្រាប់វាផ្ដុំ
ផ្ដួចដុះជាថ្មី ។

១៧៥. ឆ្នាំចកុរជូត រាំងរីងរហូត គ្រប់ឆ្នាំទាំងបី
កើតទាំងជម្ងឺ ស្លាប់មនុស្សប្រុសស្រី ខាលថោះអស់ភ័យ
ធ្វើស្រែស្រូវបាន ។

ភ្លៀងឆ្នាំម្សាញ់ រលីងក្បាលក្រាញ់ ត្រូវតាមបុរាណ
កត្តិកជន់វាល វាលសព្វស្មសាន អ្នកស្ទឹងប៉ុន្មាន
រលួយស្រូវអស់ ។

ដាច់ថ្នល់ខានដើរ រាជការគេប្រើ ទាំងចាស់កំឡោះ
មមែរងកម្ម បញ្ចាំកេរ្តិ៍កោះ គ្មានអ្វីស៊ីសោះ
ដាច់ពោះក្សិណក្ស័យ ។

ខែចេត្រឆ្នាំវក ស្រឡះពពក កើតមានសម័យ
ជាហេតុអស្ចារ្យ សុរិយាល្ងាចថ្ងៃ ឧត្បាតចង្រៃ
ឃើញសត្វអ្វីហោះ ។

ពីជើងទៅត្បូង ចាស់ក្មេងមើលច្រូង បានឃើញទាំងអស់
មើលមិនស្គាល់ជាក់ ធ្លាក់ចំចន្លោះ បាត់ឈឹងសូន្យសោះ
មិនដឹងទៅឯណា ។

១៨០. កាលមុននោះមក ខែបុស្សឆ្នាំវក លែងមានប្រាជ្ញា (១)
មានតែមេស្រុក វាស់បែងក្រឡា ដីមួយហិតា
ត្រូវសែសិបចាំង ។

(១) .ក.ក.ន ចាស់បុរាណថា អាជ្ញា គឺអាជ្ញាហ្លួងអ្នកដើរកត់ពន្ធស្រូវ

រង្វាន់មេស្រុក ត្រូវហូតមួយទុក ដប់ជូនបារាំង
ទៅដល់ប៉ុយប៉ូ បង្ខូរដាក់ឃ្លាំង ពូជពីរកន្លាំង
ក៏ជាប់ពន្ធដែរ ។

គ្មានធូរគ្មានតឹង កូនអើយខំប្រឹង ជាតិឯងជាខ្មែរ
ក្មេងប្រុសជិតទង់ នៅក្នុងឪម៉ែ រាជការប្រិតប្រែ
ថាឱ្យបង់ប្រាក់ ។

កូនចៅប្រុសស្រី កើតមកលើដី ខំរកលុយកាក់
បានហើយប្រឹងខំ ផ្សំគ្នាទុកដាក់ គ្រាន់ទិញស្លៀកពាក់
បង់ថ្លៃរាជការ ។

ភាទ្របទឆ្នាំច ចាប់គោខ្មៅស ដុតដែកបោះត្រា
ដល់កុរជូតឆ្លូវ ដំរូវយ៉ាងណា នឹងកើតអស្ចារ្យ
រហូតរាល់ឆ្នាំ ។

១៨៥. នគរថ្កើងប្លែក សប្បាយតែភ្នែក ក្នុងចិត្តរងកម្ម
កូនប្រុសបណ្ដាច់ កុំភ្លេចបណ្ដាំ កប្បាសស្វព្រថ្នាំ
ត្រីម៉ាំលែងថោក ។

ដូងស្លាអំពៅ អំបិលស្ករស្រូវ មានទៅមានមក
មានចុះមានឡើង រាស្ត្រយើងល្អមរក ល្មមរៃលៃលក
គួរយកគួរខាន ។

កប្បាសនិងថ្នាំ គួរដាស់ដីដាំ ធ្វើដៃឯងបាន
កុំអាងខ្ជិលពេក កុំដេកឈប់ខាន កុំចោលបូរាណ
ម៉ែឪដូនតា ។

ដីកុរគរគោក កុំអាងខ្ជិលដោក ទៅឈ្មោកចិនផ្សារ

កូនចៅស្រីៗ ខំរៀនធ្វើការ បើគ្មានប្រាជ្ញា
មានមាត់ចេះស្តី ។
ឱ្យស្ងួរចាស់ៗ រៀនបោះកប្បាស ផ្ចិតម្ជុរសំឡី
រៀនក្ងួតរៀនការ ត្រសាររពាត់រវៃ ហួលគោមគាតក្តី
កុំបីចន្លោះ ។
១៩០. រៀនផ្ការរៀនត្បាញ ឱ្យចាស់បង្ហាញ បង្ហាត់ទាំងអស់
សំពត់បែបងាយ លាយស្ងួត្រអម្បោះ កុំទិញគេសោះ
ឈ្មោះការជាស្រី ។
ទិញផ្ទូរតែលាក់ អញ្ចូលចេសចាក់ ព្រហ្វូតជាបី
ធ្មេញឈើឈ្មាន់ផ្សំ ក្តារម្ងួរក្តារកី ត្រល់ខ្នារឫស្សី
មុខប្តីជាប្រុស ។
តាំងពីឆ្នាំច ការអ្វីក្រៗ ខំរៀនទៅចុះ
ទាន់មានចាស់នៅ ស្គាល់ត្រូវស្គាល់ខុស ចាស់ស្លាប់រលស់
គ្មានមនុស្សចេះដឹង ។
រកស៊ីឱ្យញឹក ដេកយប់រលឹក រីតក្បិនឱ្យតឹង
បើភ្ញាក់កាលណា កាន់ការកាលនឹង កូនអើយខំប្រឹង
ទាំងប្រុសទាំងស្រី ។
រមៀតស្លឹកគ្រៃ ជីរម្ទេសខ្ទឹមខ្ញី មានដីដាំចុះ
ដាំដើមអ្វីៗ ចំណីគ្រប់ឈ្មោះ គ្រឿងស៊ីឆ្អែតពោះ
ជុះចោលទទេ ។
១៩៥. ជុះទិសខាងជើង ជុះដាក់ដីយើង កុំជុះដីគេ
កុំជុះដាក់ផ្លូវ ត្រូវមាក់ក្មេងជេរ ដីសល់ទំនេរ

ល្អមរមាត់ជុះទៅ ។

សក់មួយជាដប់ ជ្រៀកសិតឱ្យសព្វ កុំឱ្យសល់នៅ
បើប្រាជ្ញារាក់ ចាក់ចិត្តឱ្យជ្រៅ ដាំចេកអំពៅ
ដូរស្រូវអង្ករ ។

កើតមកជាមនុស្ស មួយព្រួយចង់រស់ មួយព្រួយចង់ល្អ
ពីរនេះជាធំ វានាំឱ្យក្រ ចាំជាតំណ
តជាទំនុក ។

មនុស្សមារយាទមិនប៉ិន កូននៅខ្ញុំចិន ព្រោះម្តាយឪពុក
ធ្វើស្រែមិនត្រូវ គ្មានស្រូវជង្រុក កូនអើយចាំទុក
នេះមុខមេក្រ ។

មេ ១ ជាធំ កំឡោះក្រមុំ ស្លៀកពាក់ចង់ល្អ
បើបានបែបខ្មៅ ថានៅបែបស ទើបគ្រាន់អន់ក្រ
ត្រដរចង់ថ្កើង ។

២០០. ក្រឡាប់នគរ រីងរីតកើតចោរ ច្រើនឡើងច្រើនឡើង
ពាលរីងក្រអើត ចើតម៉ើតចើតម៉ើង ក្រដាសយ៉ាងស្តើង
ចាយរហែកនៅដៃ ។

ប្រាក់ចាយអស់ទៅ ព្រោះមនុស្សឥឡូវ ឧត្បាតចង្រៃ
ជាតិខ្មែរប្រែភេទ ក្រឡៃតក្រឡៃ ក្រឡាស់សាសន៍សៃយ
សព្វសត្វនានា ។

ជាតិខ្មែរប្រែខុស ស្រីក្លែងធ្វើប្រុស ប្រុសក្លែងធ្វើផ្កា
យកប្តីប្រពន្ធ មិនស្គាល់មីងមា បុណ្យមានការងារ
កាប់គ្នាឥតក្រែង ។

ល្ងង់ឫកធ្វើចេះ គោចងត្រដោកសេះ ប្រុស១ ដុះស្មែង
ស្រីពាក់អាវខ្លី ប្រុសពាក់អាវវែង សារុងហៀវកែង
ធ្វើឯងអ្នកគ្រាន់ ។

កាន់ចិត្តសីហលោ សេះទឹមនឹងគោ ចាក់ហ៊ោលាន់១
រកស៊ីមួយថ្ងៃ ចង់បានមួយពាន់ បរគោជល់មាន់
ចាក់កាប់ជាប់គុក ។

២០៩. វិវល្បែងបៀប៉ោ ច្រើនទៅជាចោរ ប្រកាសហាមទុក
ចូរកូនប្រយ័ត្ន ប្រយោជន៍ទៅមុខ ចាំជាទំនុក
តំណកូនចៅ ។

អ្នកកុំប្រហែស រាជការនិរទេស កំចាត់ចេញទៅ
រាជការអាណិត ខំប្រិតប្រដៅ កុំលោភល្ងង់ខ្លៅ
ថោកថៅត្រកូល ។

ប្រយ័ត្នក្រែងក្រ ផ្លូវច្បាប់ល្អ១ អ្នកខំប្រមូល
ផ្លូវវៀចអាក្រក់ អ្នកកុំដើរចូល ហៅផ្លូវមិនស្រួល
លង់ផុតតំនិត ។

ដើរផ្លូវកណ្ដាល ស្រឡាញ់សិទ្ធស្មាល ឈើឆ្កាលដោយពិត
មគ្គផលសីលទាន ឈានចូលឱ្យជិត យកធមិជាមិត្ត
មិនឥតអំពើ ។

មនុស្សម្នាក់ច្រើនឆោត ច្រើនគ្មានគេកោត ឈើគ្មានគេមើល
ស្លាប់ឥតគេព្រួយ គេជួយទាំងស្ទើរ មិនដែលឡើងលើ
ច្រមុះចុះក្រោម ។

២១០. កូនចៅស្រី១ ក្រមុំសាវខ្ចី រៀនឆោតឱ្យល្មម

ប្រុសស្មើម៉ែឪ ឆ្ងរឆប្រលោម មើលរូបមើលឆោម
កុំព្រមដោយងាយ ។
កុំក្អិចក្អក់ក្អាញ់ បើចិត្តស្រឡាញ់ កុំចេញនិយាយ
បើស្អប់កុំប្តឹង បើខឹងកុំធ្លាយ កុំរោះកុំរាយ
កុំងាយធ្វើស្និទ្ធ ។
កុំដើរប្រាប់គេ កុំអាងអួតជេរ ក្រែងប្រុសឈឺចិត្ត
នៅឱ្យតែនឹង កុំរវល់ធ្វើស្និទ្ធ ប្រុសនឹងអាណិត
គិតចូលដណ្តឹង ។
បើម៉ែឪឱ្យ មើលមុខមើលក្រោយ អាក្រក់ខ្មៅភ្លឹង
ប្រកែកដោយស្វាត់ កុំខ្លាចម្តាយខឹង កើតកូនមកតឹង
ពិបាកចាយណាស់ ។
កុំឃ្លានចំណី កុំខ្លាចអត់ប្តី កុំភ័យខ្លាចចាស់
មើលមុខឯងផង កុំរើសឥតខ្មាស ខ្លួនល្អស្រឡះ
មិនខ្វះគេស្តី ។
២១៥. បើបានជាខូច ទាន់ផើមនៅតូច ខែពីរខែបី
រវៀសឆ្លើយប្រញាប់ ប្រាប់គ្នាស្រីៗ កុំលាក់ធ្វើអ្វី
ក្នុងតែគេដឹង ។
កុំមាយាបេះក្រូច មារយាទចេះតែខូច មាត់ចេះតែខឹង
គេថាត្រង់ណា ជេរគេត្រង់ហ្នឹង ជេរហើយខំប្រឹង
យកថ្មសង្កត់ ។
រំលាយរំលូត អាក្រក់តែគូទ អួតល្អតែមាត់
មានគេឃើញច្បាស់ ម្នះរឹងប៉ានស្បថ ទោសនេះនឹងភ្លាត់

ធ្លាក់ទៅអវិចី ។

ចោរកាចល្ងង់ខ្លៅ ប្រាជ្ញប្រាមប្រដៅ ហៅបារាជិកស្រី
មេបាកាច់គេ ស្លាប់ពីរស្លាប់បី រំលូតកូនខ្ចី
ស្មើរំលោយព្រះ ។

មានកាលមិនក្ស័យ ខ្វិនជើងខ្វិនដៃ កខ្វេះកខ្វាស
ខ្វាក់ភ្នែកអន្ធការ អនិច្ចារូបណាស់ អាក្រក់កេរ្តិ៍ខ្មាស
តកូនតចៅ ។

២២០. អសោចិ៍សុសសាយ សុសសព្វដល់ម្តាយ ដល់ពូជពង្សផៅ
ស្លាប់ទៅរងទុក្ខ នរកឋានក្រៅ គេស្រុសទឹកក្តៅ
ស្លាប់ទៅរស់ទៀត ។

ស៊ីខ្លួនឈាមឯង ព្រះអង្គសម្តែង ថាម៉ឺនសែនជាតិ
ឡើងមកជាប្រេត ហេតុកម្មមិនឃ្លាត អត់ឃ្លានគ្មានញាតិ
ហែកកូនឯងស៊ី ។

ព្រះពុទ្ធលែងប្រោស ធមិលែងសន្តោស សោយទុក្ខវេរី
ហេតុចិត្តឫស្យា មិច្ឆាទិដ្ឋិ កើតជាជ្រូកញី
គេគ្រៀវគេចាក់ ។

អសង្ខេយ្យឆ្នាំ ហេតុផលសេសកម្ម កើតជាមនុស្សខ្វាក់
មនុស្សខ្វិនទ្រែមទ្រម ជាគមជាគាក់ ខ្ចីយខ្លួតអបលក្ខណ៍
ជាអ្នកឥតប្តី ។

បើម្តាយជួយព្រួត ជួយជាន់រំលូត រំលោយកូនខ្ចី
នរកប្រេតព្រមគ្នា មិនឃើញរស្មី ដ្បិតចិត្តតិរិយ
ទាំងម្តាយទាំងកូន ។

២២៩. ហេតុនេះគួរខ្លាច ធម្មតាចោរកាច មិនដែលស្ងាត់ស្ងូន្យ
អសោចិ៍កេរ្តិ៍ឈ្មោះ ទាំងអស់បងប្អូន មេបាតាដូន
កាត់កាល់លែងរាប់ ។
គួរប្រុងឥរិយា កើតទាន់សាសនា ហៅមហាមានភ័ព្វ
ទាំងប្រុសទាំងស្រី កុំបីឱ្យធ្លាប់ គួរខំរៀនផ្ចាប់
បរលោកលោកិយ ។
ឯខុសនិងគាប់ បើនឹងរៀបរាប់ រាល់រូបប្រុសស្រី
គាប់ខុសនៅចិត្ត ខុសគាប់នៅស្តី គំរប់ជាបី
ខុសត្រូវនៅកាយ ។
កូនប្រុងប្រព្រឹត្ត ការកេរ្តិ៍ឱ្យជិត គំនិតឱ្យឆ្ងាយ
កើតមកជាខ្មែរ កុំប្រែក្លែងក្លាយ ធម្មតាសប្បាយ
វាតែងឱ្យទុក្ខ ។
ឱ្យទោសទាស់ទែង ទាស់តែម្នាក់ឯង ដល់ម្តាយឪពុក
រឹងរឿងទោស មានតែពីរមុខ មួយទៅនរក
មួយនាលោកិយ ។
២៣០.លោភៈទោសោ កើតពីមោហោ រាល់រូបប្រុសស្រី
គួរកាន់មេត្តា កតញ្ញូខន្តី នេះគឺបាលី
ទៅកាន់បរលោក ។
ពាក្យពិតប្រដៅ ឱ្យអស់កូនចៅ ប្រព្រឹត្តរៀនយក
កូនណាមិនរៀន កូននឹងមារយាទថោក នឹងធ្លាក់ជ្រុលជ្រក
ក្នុងចតុរាបាយ ។
ធំស្រេចនៅស្លូត សុខខ្លួនរហូត ដរាបវែងឆ្ងាយ

ខន្តីអំណត់ សង្កត់ក្នុងកាយ ជាតិជនទាំងឡាយ
កម្រកាន់បាន ។
ចេះហើយមិនដឹង ចិត្តនៅម្នះរឹង ប្រឹងរកកម្មដ្ឋាន
រកធម៌មិនយល់ ខ្ជិលខ្វល់ឈប់ខាន បន្ទោសបុរាណ
ថាគ្មាននិស្ស័យ ។
វិបាបនិងបុណ្យ មានចិត្តជាមុន មាត់ជាបច្ច័យ
នាំចុះនាំឡើង ពីជើងពីដៃ សន្សំសព្វថ្ងៃ
ឈ្មោះហៅសំណាង ។

២៣៩-កើតក្នុងលោកិយ រាល់រូបប្រុសស្រី មានចិត្តជាអាង
កុសលអកុសល ប្រទាញសងខាង រូបនៅតែងតាង
តែងតាមទៅមក ។
មគ្គផលសីលទាន បើល្ងង់ឱ្យរៀន បើគ្មានឱ្យរក
យល់ល្អសាងស្អាត សង្វាតជ្រៀតជ្រក ជ្រើសរើសរៀនយក
រក្សារូបកាយ ។
នេះគឺហៅច្បាប់ ជាទីសណ្ដាប់ សន្តានទាំងឡាយ
កូនចៅប្រុសស្រី កុំបីនៀយណាយ សង្ខេបបរិយាយ
និដ្ឋិតំចែងចប់ ។
អ្នកព្រះភិរម្យ អាចារ្យជុំយខ្ញុំ បង្គំប្រាមដប់
លើសលស់ឆ្នាំឆ្កង រំលងពុំគាប់ ពុំគួរសមសព្វ
សុសសាយសេចក្ដី ។
កាយកម្មវចីកម្ម ឈ្មោះច្បាប់បណ្ដាំ កូនចៅប្រុសស្រី
ជាបរមត្ថក្រៅ មិនហៅបាលី បរលោកលោកិយ

ទាំងពីរកន្លែង ។

២៤០. បើលោកឯណា ចេះចាំធមិអាចិ ប្រាកដជាក់ស្ដែង
យើញខុសត្រង់ណា កុំថាជាល្បែង ដ្បិតពាក្យខ្ញុំតែង
ឱ្យក្មេងវាភ័យ ។
មិនមែនភរភូត កុំថាខ្ញុំអួត ប្រាជ្ញាខ្ញុំវៃ
យើញមនុស្សវង្វេង ខ្ញុំតែងច្បាប់ថ្មី អស់អាចិសេចក្ដី
ឯវិចប់ហោង ។

អ្នកព្រះភិរម្យភាសា **អ៊ូ** ហៅ **ឪយ**

# បញ្ជីឈ្មោះបទភ្លេងខ្មែរ

( ត )

ស្រាវជ្រាវដោយ **យី ធន់**

| ឈ្មោះថ្មី ឬឈ្មោះហៅ តាមភាសាខ្មែរទំនើប | | ឈ្មោះចាស់ ឬឈ្មោះហៅ តាមភាសាបរទេស |
|---|---|---|
| ៤៨. របាំផ្កា | : | . របាំផ្កា |
| ៤៩. ភ្លេងផ្កា | : | . ភ្លេងផ្កា |
| ៥០. ទេពប្រាវត្ត | : | . ទេពប្រាវត្ត |
| ៥១. ទេពរំជួល | : | . ទេពរំជួល |
| ៥២. ទេព្ដាផ្ទី | : | . ទេពបន្ទំ |
| ៥៣. ទេព្ដានិម្មិត | : | . ទេពនិម្មិត |
| ៥៤. ស្រីស្នំបំពេរ | : | . ភិរម្យស្វ៉ាង |
| ៥៥. សិង្ហធំជជាន់ | : | . សឹងធំជជាន់ |
| ៥៦. សរសើរផ្កាយ | : | . ឆ្មុំដាវ |
| ៥៧. ផ្កាយមាស | : | . ដាវថង |
| ៥៨. រស្មីផ្កាយ | : | . ដាវឃិប |
| ៥៩. ផ្កាយអណ្ដែត | : | . ដាវឡយ |
| ៦០. រស្មីជោគជ័យ | : | . រស្មីជោគជ័យ |
| ៦១. និរផ្លែង | : | . និរផ្លែង |
| ៦២. ពន្លឺពេជ្រ | : | . ភេតណាយ |

| | | |
|---|---|---|
| ៦៣. ព្រះចន្ទរនោច | : | - ចន្ទរ៉ែម |
| ៦៤. រង់ព្រះចន្ទ | : | - ដួងចន្ទ |
| ៦៥. ព្រះចន្ទល្អ | : | - ព្រះចន្ទង៉ាម |
| ៦៦. សំឡឹងព្រះចន្ទ | : | - សំឡឹងព្រះចន្ទ |
| ៦៧. អស្ចារ្យព្រះចន្ទ | : | - អស្ចារ្យព្រះចន្ទ |
| ៦៨. រស្មីស្រទន់ | : | - ខ្វាន់អន |
| ៦៩. រស្មីព្រះចន្ទ | : | - ព្រះចន្ទចៅខា |
| ៧០. សត្វសេដាយស់ | : | - សេដាយុង |
| ៧១. ភ្លេងសេតាយស់ | : | - សេដាយង់ផ្លែង |
| ៧២. សិង្ហតោ ៣ ជាន់ | : | - សិនត្វ ៣ ជាន់ |
| ៧៣. សិង្ហតោភ្លេង | : | - សិនត្វផ្លែង |
| ៧៤. ស្វាបាក់ | : | - លឹងលោត |
| ៧៥. ព្រះសំនៀង | : | - ផរះសំនៀង |
| ៧៦. សំនៀងស្រីក្រមុំ | : | - សំនៀងមរឆន (ស្រីក្រមុំ) |
| ៧៧. សំអាងកេសរ | : | - កេសនសំអាង |
| ៧៨. នៅនៃបនិត | : | - យូឈិត |
| ៧៩. ក្លើទាំង ៤ | : | - ស៊ីក្លី |
| ៨០. ក្រមុំដោះចិញ្ចៀន | : | - សាវថតវ៉ែន |
| ៨១. ព្រាហ្មរើសចិញ្ចៀន | : | - ព្រាហ្មកិបវ៉ែន |
| ៨២. ចៅព្រាហ្ម | : | - ចៅព្រាហ្ម |
| ៨៣. ព្រាហ្មដើរព្រៃ | : | - ព្រាហ្មដីនដុង |
| ៨៤. ព្រាហ្មដេញសាដៀវ | : | - ព្រាហ្មឱតណាពៅ |

| | | |
|---|---|---|
| ៨៥. នាងស្រីសំរើបចិត្ត | : | . ណាងគ្រួន |
| ៨៦. មន្ត្រីសំរើបចិត្ត | : | . ផ្សាំគ្រួន |
| ៨៧. មន្ត្រីសមសក្តិ | : | . ផ្សាំស្ងួត |
| ៨៨. ទោចយំ | : | . ឆនីរ៉ងហាយ |
| ៨៩. មន្ត្រីថ្កើងសក្តិ | : | . ផ្សារ៉ីងហាយ |
| ៩០. ដើមឈើង | : | . ដើមឈើង |
| ៩១. ស្រីក្រមុំ៣ នាក់ | : | . សាមសាវ |
| ៩២. ផ្កាពុទ្ធជាតិ | : | . វិឡាន់តា |
| ៩៣. របាំរាំដាវ | : | . កាបីលីឡា |
| ៩៤. យាត្រាត្រឡប់ | : | . លីឡាកាធំ |
| ៩៥. របាំជប៉ុន | : | . ជប៉ុនឆាអន |
| ៩៦. កម្រងផ្កាថ្កុល | : | . ភីតុនក្រុង |
| ៩៧. ភួងផ្កា | : | . បួឡាន |
| ៩៨. ភួងផ្កាម្លិះរួត | : | . ឆុកមួយ (ភ្លេងផ្តើមប្រដាល់) |
| ៩៩. ក្រពើកន្ទុយវែង | : | . តាខេហាងវយ៉ាវ |
| ១០០. ខ្យល់បក់រំភើយ | : | . ផាប់ឆាត់ឆា |
| ១០១. ខ្យល់បក់ជាយភ្នំ | : | . លំផាត់ឆាវឆា |
| ១០២. ខ្យល់បក់រំភើយ | : | . លំហួន |
| ១០៣. រំភើយគិរី | : | . រំភើយគិរីន |
| ១០៤. ក្លិនផ្កាម្លិះ | : | . ម្លិះហួន |
| ១០៥. ស្រឡាញ់ផុតចិត្ត | : | . សិតសាងួន |
| ១០៦. ភ្លេងផ្កាំផ្គរ | : | . ភីរុណសាងហ្វា |

| | | |
|---|---|---|
| ១០៧- ផ្គរដើមឆ្នាំ | : | - ហ្វាខាណង |
| ១០៨- ស្រងាកស្តាប់ផ្គរ | : | - ស្រងាកស្តាប់ផ្គរ |
| ១០៩- សន្ធឹកផ្គរគ្រាំ | : | - សន្ធឹកផ្គរគ្រាំ |
| ១១០- នួនស្រី | : | - នួនស្រី |
| ១១១- ស្រីបុកស្រូវ | : | - ស្រីបុកស្រូវ |
| ១១២- ក្រសាំងទាប | : | - ក្រសាំងទាប |
| ១១៣- ត្រពាំងពាយ | : | - ត្រពាំងពាយ |
| ១១៤- ផ្កាក្រង | : | - ផ្កាក្រង |
| ១១៥- ឱរាសាគរ | : | - ឧកថាឡៀ |
| ១១៦- រលកបែកផ្កាព្រែង | : | - ថាឡៀបា |
| ១១៧- សែនស្រណោះ | : | - សែនស្រណោះ |
| ១១៨- សែនស្លុតចិត្ត | : | - សែនស្លុតចិត្ត |
| ១១៩- វាចាផ្អែម | : | - ខាំវ៉ាន |
| ១២០- មាសទឹកដប់ | : | - ថងយ៉ត |
| ១២១- សិង្ហមាស | : | - សាក់មិញថង |
| ១២២- ប្រាសាទមាស | : | - ប្រាសាទថង |
| ១២៣- រូបចាបមាស | : | - ក្រូចកថង |
| ១២៤- ផ្កាចំប៉ាមាស | : | - ចំប៉ាថងដេត |
| ១២៥- ដំណើរសេះ | : | - ម៉ាយ៉ោង |
| ១២៦- ភូមាប៉ោ | : | - ភូម៉ាហេ |
| ១២៧- កម្រងភួងផ្កា | : | - ភួងម៉ាឡៃភិត |
| ១២៨- កម្រងភួងម្ហូល | : | - ភួងម៉ាឡៃពា |

| | | |
|---|---|---|
| ១២៩. កម្រងភ្លួងមាស | : | . ភ្លួងម៉ាឡៃថង |
| ១៣០. រិទ្ធិតេជះ | : | . ដេតរិត |
| ១៣១. មហាឫក្ស | : | . មហារឹក |
| ១៣២. មហាជ័យ | : | . មហាឆៃ |
| ១៣៣. មនសម័យ | : | . ម៉ន់ម៉ៃ |
| ១៣៤. ស្ងួមចិត្ត | : | . ផាឡុំប៉ង |
| ១៣៥. បើកព្រះកោដិ | : | . ប៊ុតព្រះកោដិ |
| ១៣៦. រើសព្រះអដ្ឋិ | : | . ដួងព្រះថោន |
| ១៣៧. ផ្ទៃត្រង់ក្រលួច | : | . តាវ៉ាន់ឆៀង |
| ១៣៨. វិស្សកម្ម | : | . វិស្សកម្ម |
| ១៣៩. ហង្សមាស | : | . ហុងថង |
| ១៤០. អណ្តើកស៊ុត្រកួន | : | . តៅគិនផាក់ប៊ុង |
| ១៤១. ត្រីមាស | : | . ប្លាថង |
| ១៤២. ទន្សាយលេងខែ | : | . ឆាយឆុំដៀន ( កះតាយឆុំដៀង ) |
| ១៤៣. លាវពាក្យក្រអូប | : | . ឡាវខាំហាម |
| ១៤៤. ស្រីលាវតូចចិត្ត | : | . ឡាវឡឹក |
| ១៤៥. កម្រងភ្លួងមាស | : | . ភ្លួងម៉ាឡៃថង |
| ១៤៦. លាវអន្ទ្រងមាន់ | : | . ឡាវកែ |
| ១៤៧. លាវឡើងច្រាំង | : | . ឡាវតយតាឡឹង |
| ១៤៨. លាវទាក់លលក | : | . ឡាវតណុក |
| ១៤៩. លាវដើរព្រៃ | : | . ឡាវដីនដុង |
| ១៥០. លាវសរសើរព្រះចន្ទ | : | . ឡាវឆុំចន្ទ |

| | | |
|---|---|---|
| ១៥១. លាវផ្សេងទៀន | : | - ឡាវសៀនធៀន |
| ១៥២. ទឹកហូរកាត់ខ្សាច់ | : | - ណាមឡុតតសាយ |
| ១៥៣. តាមប្រើសមាស | : | - តាមគ |
| ១៥៤. ស៊ីថាកណ្តាល | : | - ស៊ីថាក្លាង |
| ១៥៥. ៤បទ | : | - ស៊ីប៊ុត |
| ១៥៦. ៦បទ | : | - ហុកប៊ុត |
| ១៥៧. ៨បទ | : | - ប៉ែតប៊ុត |
| ១៥៨. ឡើងព្រះពន្លា | : | - ឃីនផ្លាក់ផ្លា |
| ១៥៩. ឃីមតូច | : | - ឃីមឡេក |
| ១៦០. ឃីមធំ | : | - ឃីមយ៉ៃ |
| ១៦១. ចុងឃីម | : | - ចុងឃីម |
| ១៦២. រង្វង់ | : | - ស៊ុម |
| ១៦៣. ចាកបន្ទាយ | : | - ឡាក់ខៃ |
| ១៦៤. សារះបូរី | : | - សារ៉ាក់បូរី |
| ១៦៥. ដើរបំព្រំ | : | - តាលិនតិន |
| ១៦៦. ...................... | : | - មេលិម |
| ១៦៧. ...................... | : | - បាវលុត |
| ១៦៨. ...................... | : | - សារក់ចូរុង |
| ១៦៩. ព្រះថោង | : | - ព្រះថោង |
| ១៧០. នាងនាគ | : | - នាងនាគ |
| ១៧១. ៤ភាសា | : | - សយសុន |

( នៅមានត )

ច្បាប់ទូន្មាន កវី អ៊ុំ ចុង

# គួរត្រាប់ដើមត្នោត

មនុស្សខ្លះចិត្តកាចខូច លោកប្រដូចមនុស្សក្រូចឆ្មារ
មិនដែលផ្អែមពិសា ជូរយ៉ាងណាជូរទាល់ងាប់ ។
មនុស្សខ្លះដូចននោង ខ្ចីដំបូងប្រសើរគាប់
ដល់ចាស់ស្វិតស្រទាប់ គេលែងរាប់ស្អប់លែងស្ល ។
ឯស្វាយខ្ចីជូរណាស់ តែដល់ចាស់ទុំផ្អែមល្អ
មនុស្សយើងទោះខ្មៅស កម្របានផ្អែមដូចស្វាយ ។
គួរត្រាប់ដូងនិងត្នោត ដែលគួរកោតហួសបរិយាយ
ដ៏មានប្រយោជន៍ឆ្ងាយ ជនទាំងឡាយប្រើគ្រប់ប្រាណ ។
គ្រាប់ត្នោតទុំក្រៀមក្រោះ គេបង់បោះលែងរាប់អាន
ដល់ដុះប្រយោជន៍បាន ធំប៉ុន្មានប្រាក់ប៉ុណ្ណឹង ។
ប្រយោជន៍ជាតិដូចត្នោត អ្នកណាឆោតគិតមិនដឹង
គេកាប់មិនចេះខឹង ចេះតែប្រឹងលូតលាស់ថ្មី ។
មិនឥតអំពើឡើយ ត្រូវណាស់ហើយពោលខ្លីៗ
ដុះខ្ពស់ឃ្លាតពីដី ស្លឹកខ្ចីៗ គេធ្វើផ្លិត ។
ត្បាញស្មុគចាក់កន្ទំ គេចេះផ្សំប្រើតាមចិត្ត
អ្នកណាប្រាជ្ញាល្អិត ប្រើហើយប្រឹតបានប្រាក់ពាន់ ។
ធាងតូចធ្វើចំណាង ទាល់ម្តងៗរក្សូសរាន់
រកនេះនោះមិនទាន់ ម្តេចក៏គ្រាន់តាមប្រញាប់ ។
ខាងពោះចងរបង ប៉ែកខាងខ្នងចងកណ្តាប់

កណ្ដាលហាលថ្ងៃស្លាប់ ក្របែលកាប់ដុតដាំបាយ
ត្នោតម្ដើម [១] លៃលុយកាក់ ប្ដូកជាប្រាក់ច្រើនពាន់ប្លាយ
មនុស្សរស់រាល់រូបកាយ បានប្រាក់ចាយដោយសារត្នោត ។
ស្រទបធាងនិងស្លឹក ផ្កាមានទឹកធ្វើស្ករជ៉ោត
ស្ករផែនសែនលានកោដិ ក្បាបវាសោតគេដោតត្រី ។
ផ្លែចាស់ល្មមលក់ដូរ ស្លកក្ដួរផ្លែខ្ចីៗ
ផ្លែទុំជ្រុះដល់ដី មនុស្សប្រុសស្រីរើសធ្វើនំ ។
ចោលគ្រាប់ដុះកំពីង គាស់ល្ងងក្មេងកុំឱ្យយំ
ជក់ [២] ចាស់សរសៃធំ ចងប្រមុំធ្វើជាប្រៃង [៣] ។
ជក់ល្អិតសរសៃខ្ចី វេញខ្សែខ្លី ឬខ្សែវែង
ប្រយោជន៍ច្រើនកន្លែង មនុស្សណាឯងអាចត្រាប់បាន ។

ដកស្រង់ចេញពី

ច្បាប់ទូន្មានរបស់កវី **អ៊ូ ចុង**

---

(១) ម្ដើម : មួយដើម

(២) ជក់ : សរសៃដែលគេយកបានពីស្រទបធាងត្នោតសាវៗ

(៣) ប្រៃង : អំបោសធ្វើអំពីជក់ត្នោតសរសៃធំ សម្រាប់សិតសរសៃអំបោះ ឬអោយបាយអំបោះក្នុងកិច្ចការតម្បាញ ។

# ការប្រព្រឹត្តិនាំឱ្យថោកពុទ្ធសាសនា

(បទព្រហ្មគីតិ)

បពិត្រលោកអាចារ្យ មានធម៌អាថ៌នៅក្នុងប្រាណ
ជាពង្សវង្សសន្តាន ជនកល្យាណគឺបណ្ឌិត ។
ជាអ្នកប្រព្រឹត្តធម៌ ស្អាតបវរសសុចរិត
គួរលោកកុំមានចិត្ត ខ្មៅទុច្ចរិតងងឹតក្នុង ។
អាក្រក់កាយវាចា និងចិត្តណាមោហៈស្លុង
វង្វេងភ្លេចដើមចុង ផុងលិចភក់ព្រោះជក់លោភ ។
រៀងរាល់វត្តអារាម ច្រើនជិតដាមមិនសុភាព
ពើតពើងមិនស្ងប់រាប គ្មានរបៀបឈ្លោះទាស់គ្នា ។
ឈ្លោះពីរឿងលុយកាក់ បច្ច័យប្រាក់កឋិនផ្កា
ចៅវត្តនិងអាចារ្យ ឈ្លោះទាស់គ្នារឿងសាងសង់ ។
ព្រះចៅអធិការវត្ត អាងប្រាកដភេទផ្នូរផង់
អាងរូបលោកជាសង្ឃ ទ្រង់មិនស្តាប់លោកអាចារ្យ ។
សង្ឃបួសជិនាន់ថ្មី ខ្លះចេះខ្លីរឿងធម៌អាថ៌
វិន័យត្រៃសិក្ខា លោកសិក្សាពុំបានឆ្ងាយ ។
ចេះត្រឹមបច្ចវេក្ខណ៍ ធម៌អជ្ជះសងថ្លៃបាយ
យថាបង្សុកូលអាយ ស្វូត្រមន្តផ្លាយដល់ទេសនា ។
ធម៌ទេសន៍ចេះច្រើនណាស់ ពាសដេរដាសព្រោះងាយថា
អធិប្បាយលើសមាត្រា ដែលភគវាទ្រង់សំដែង ។

ផ្សំផ្គុំឱ្យទំនង ការខុសឆ្គងពុំរវែង
យាយតាសាធុស្តែង ស្តាប់សូរស័ព្ទចាប់ចិន្តា ។
សរសើរថាព្រះអង្គ ទេសន៍ត្រឹមត្រង់ត្រូវណាស់ណា
ធម្មកថិកាចារ្យ ឮយាយតាសរសើរប្រាណ ។
ក៏រីកចិត្តចិន្តា បែកប្រាជ្ញថាហួសប្រមាណ
ខុសច្បាប់ព្រះទ្រង់ញាណ ដូចកបិលមច្ឆៈ ។
លង់ឈ្លក់នឹងបច្ច័យ ច្រើនក្រាស់ក្រៃយ៉ាងអនត្ថ
កើតលោភៈទោសៈ និងមោហៈក្នុងព្រះទ័យ ។
បច្ច័យសម្បូណ៌ច្រើន ធម៌ពុំកើនពុំកើតអី
ឃ្លាងឃ្លាតច្បាប់វិន័យ សីលប្រពៃគ្មានសូន្យសោះ ។
គិតពៃស្លូត្រមន្តដារ(១) និងទេសនាឱ្យក្បាយក្បោះ
កើតលាភកើនទំនាស់ ឈ្មោះទើសទាស់បែកសាមគ្គា ។
មានលោកម្ចាស់អង្គខ្លះ ខំខ្លាំងណាស់ខាងគាថា
ឧបរវាមយន្តចងចារ ប្រាថ្នាលាភក្នុងលោកិយ
រិកិច្ចសង្ឃកុសល មិនខ្វាយខ្វល់សីលវិន័យ
សង្រួមឱ្យប្រពៃ ទាំងផ្លូវកាយវាចាចិត្ត ។
ព្រោះផ្លូវនៃអ្នកបួស មិនលើសហួសមានបីពិត
ដែលសង្ឃត្រូវពិនិត្យ គឺសីលស្មាធិបញ្ញា ។
រឿងកិច្ចការសាងសង់ សាងសំណង់កុដិសាលា

(១) ដារ (ដំណើរឆ្លង, ការឆ្លង) ឈ្មោះបុណ្យតូចម្យ៉ាងក្នុងពុទ្ធសាសនា ជាបុណ្យទក្ខិណានុប្បទាន, ទាយកនិមន្តភិក្ខុសង្ឃសូត្រសត្តប្បករណាភិធម្ម និងតិរោកុឌ្ឌសូត្រ ហើយគេរាប់បាត្រ រួចឧទ្ទិសចំណែកបុណ្យជូនទៅបុព្វបេតបុគ្គល ដែលចែកឋានទៅកាន់បរលោកហើយ ៖ ធ្វើបុណ្យដារ, និមន្តលោកដារ ។

ជានាទីជនា គេជ្រះថ្លាសាងវេរថ្វាយ ។
ព្រោះឃើញសិលព្រះសង្ឃ ស្អាតផូរផង់សង្ឃទាំងឡាយ
មិនអាចទប់ចិត្តកាយ សទ្ធាដុះផុសព្រោងព្រាត ។
សង្ឃយ៉ាប់ព្រោះអាប់សីល បរិស័ទខ្ពីលលែងជិតបៀត
លែងចេញចូលញោមញាតិ សទ្ធាឃ្លាតរួញរារអស់ ។
អាចារ្យអាងចំណេះ សង្ឃមិនចេះអាងភេទខ្ពស់
ម្ល៉ោះហើយកើតទំនាស់ ព្រោះជញ្ជីងមិនស្មើគ្នា ។
អាចារ្យខ្លះឥឡូវ បែកច្រើនផ្លូវច្រើនប្រការ
ពេលបុណ្យទាននានា មានបញ្ហាខ្មៅសៅហ្មង ។
វេរអង្គាសបច្ច័យ រៀងរាល់ថ្ងៃច្រើនឆ្នាំឆ្លង
តាមត្រូបតៀមផ្សារផង នាំថោកទាបពុទ្ធសាសនា ។
រឿងបុណ្យមិនថ្វីទេ តែគ្មាន់គ្នេរឱ្យថ្លៃថ្លា
កុំដើរស្រែកឡូឡា ចូលក្នុងផ្សារគ្រប់កៀនកោះ ។
ធ្វើឫកឱ្យទំនង កុំឱ្យឆ្គងឫកសប្បុរស
កុំចាំស្ទុះលោតផ្លោះ ដើរដូចហោះព្រោះចង់បាន ។
បើសទ្ធាគេមាន គេធ្វើទានតាមលំអាន
ពាក្យបង្គាប់ត្រូវខាន ពាក្យបង្ខំសុំដកទុក ។
ពាក្យពោលណាទើសទាល់ គួរកុំពាល់ត្រូវស្ដើងមុខ
បានលុយកុំលាក់ទុក ខុសទំនុកទំនងផ្លូវ ។
វេរបច្ច័យខ្លួនឯង លុះចាត់ចែងចំណែកទៅ
គ្មានអ្នកឯណាក្រៅ គឺលៃចែកយកខ្លួនឯង ។
គិតតែបុណ្យពលកម្ម ខុសបណ្ដាំព្រះសំដែង

រឿងបុណ្យពិតច្បាស់ទែង មិនមែនស្ថិតលើបច្ច័យ ។
គឺស្ថិតនៅលើចិត្ត ប្រាកដពិតកុំសង្ស័យ
ទោះបានមិនបានក្តី តាមសម្ភារអាជីវោ ។
មុននឹងធ្វើអាចារ្យ ត្រូវឧស្សាហ៍រកភោគោ
រកទ្រព្យឱ្យបរិបូណ៌ ផ្គត់ផ្គង់ជុំក្រុមគ្រួសារ ។
បើគ្មានទ្រព្យធនធាន គួរតែមានចិត្តជ្រះថ្លា
កុំយកលុយបុញ្ញា ខូចសាសនាព្រះពុទ្ធអង្គ ។
បើបរិស័ទទាំងឡាយ ឃើញចិត្តកាយយើងផូរផង់
គេជូនដោយស្មោះត្រង់ តាមភាគច្រើនគួរយកចុះ ។
នេះហៅធម្មិកោ ធម្មលទ្ធោពិតមិនខុស
ប្រកបដោយធម៌ស្មោះ បានមកក៏ដោយធម៌ថ្លៃ ។
មានលោកអាចារ្យខ្លះ ធ្វើផ្តេសផ្តាសខុសណាស់នៃ
យករូបព្រះពុទ្ធថ្លៃ ដើរអង្គាសពាសពេញផ្សារ ។
ថ្លៃជាវមួយម៉ឺនទេ ដើរវែរវេរពោលឃោសនា
សទ្ធាជនខេមរា ចូលអាចារ្យបានមួយសែន ។
ដឹកដានព្រះដល់វត្ត គាត់យកហ្មត់កាន់ទុកណែន
ទាំងដើមចុងមួយសែន គាត់លាក់មែនលុយដប់ម៉ឺន ។
នេះហៅជំនួញព្រះ គិតឱ្យណាស់កុំភ្លើតភ្លើន
លុយព្រះទាំងដប់ម៉ឺន លាក់លៀមចាយវាយខ្ទេចខ្ទី ។

ខែ មករា ឆ្នាំ ១៩៩៥

**ង៉ាយ ទិបុល**

# គំនិតស្វែងយល់ពីអ្នកជក់បារី

ដោយវេជ្ជបណ្ឌិត ឃុន ង៉ែត និង
ហៀន វណ្ណារត្ន

ជាការពិតណាស់ដែលថា ការហូបស្រាត្រឹមមួយឆ្នាំញ៉ាំបាយ វាបានផ្តល់មក ដល់អ្នកផឹក នូវសុខភាពល្អ ពោលគឺបាយបាន សំរានលក់ ស្រួលខ្លួនមែន ។

ចុះការងារជក់បារីវិញ តើមានផលប្រយោជន៍ និងទំនាស់អ្វីខ្លះដល់មនុស្ស លោកយើងនេះ ?

តាមការស្រាវជ្រាវប្រកបលក្ខណៈជាវិទ្យាសាស្ត្រផងនោះ គេបានឃើញ ថា បារីបង្កអោយមានទំនាស់ច្រើនណាស់ដល់សរីរាង្គមនុស្ស ។ គេតែងហាម អ្នកលើសសម្ពាធឈាមមិនអោយជក់បារី ព្រោះវានាំអោយអ្នកជក់កាន់តែលើស សម្ពាធឈាមថែមទៀត ។ គេតែងហាមមិនអោយជក់បារី ព្រោះវានឹងបណ្តាល អោយមានជំងឺមហារីកសួត ឬរបេងសួត ដោយសារជាតិពុលនីកូទីន និងផ្សែងពុល បារី ។ គេតែងហាមមិនអោយជក់បារីចំពោះមាតាដែលមានផ្ទៃពោះ ពិសេសក្នុង ពេលមានទម្ងន់ក្នុង ៣ ខែដំបូង ព្រោះវាអាចប៉ះពាល់ដល់រាងកាយរបស់ទារកក្នុង ផ្ទៃម្តាយ ។ គេរកឃើញថា ១០ ភាគរយ នៃអ្នកបំរើភ្ញៀវក្នុងភោជនីយដ្ឋានដែលមាន អ្នកជក់បារី ក៏ទទួលរងនូវគ្រោះថ្នាក់ដូចគ្នានឹងអ្នកជក់បារីផងដែរ ។

ទន្ទឹមនឹងនេះ បារីអាចបង្កគ្រោះមហន្តរាយដល់ព្រៃឈើអោយឆេះបាន នៅរដូវក្តៅហែង ដោយសារអ្នកជក់បារីធ្វើដំណើរឆ្លងកាត់ព្រៃ ហើយបោះចោល កន្ទុយបារីកំពុងឆេះ ។ បារីអាចបង្កអោយឆេះអាវ ឆេះខោ ឆេះមុង ឆេះកន្ទេល

ឆេះខ្មៀយ កំរាលព្រូករបស់អ្នកជក់ ឬរបស់អ្នកជិតខាងក្បែរខ្លួន ឬក៏រហូតបណ្តាល អោយឆេះផ្ទះសម្បែងរបស់ខ្លួនអ្នកជក់ក៏សឹងមាន ។ នៅក្នុងបន្ទប់មួយបិទជិតមាន សមាជិកបួននាក់, បីនាក់ជាអ្នកជក់បារី, ម្នាក់ទៀតមិនជក់ក៏ដោយ ក៏ទទួលលទ្ធផល ដូចគ្នានឹងអ្នកជក់ដែរ ។ ដូច្នេះ សូមពិចារណាអោយបានហ្មត់ចត់ ។ អ្នកជក់បារីមាន ទឹកមុខឆាប់ចាស់ជាងអ្នកអត់ជក់បារី ។

មួយវិញទៀត ការជក់បារីនាំអោយខ្ជះខ្ជាយលុយ ចំណាយប្រាក់កាស ឥតប្រយោជន៍ ។

បើបារីនាំមកនូវផលវិបាកអាក្រក់ច្រើនយ៉ាងនេះ ហេតុម្តេចក៏រោងចក្រ នៅតែផលិតបារី, ហេតុដូចម្តេចក៏អ្នកដាំនៅតែដាំថ្នាំជាបន្តទៅទៀត, ហើយហេតុអ្វី អ្នកជក់នៅតែជក់បន្តយ៉ាងនេះ ?

ភាគច្រើនអ្នកជក់បារីតែងនិយាយថា នៅពេលអផ្សុក តប់ប្រមល់ គិត ការមិនលេច បើគេបានជក់បារីអស់តែ ១ ដើម នោះអ្វីៗហាក់ដូចជារសាយអស់ ឬ យ៉ាងហោចណាស់ក៏ធ្វើអោយគេមានអារម្មណ៍រីករាយជាងមុនបន្តិច ។ អ្នកដឹកនាំ ដែលជក់បារី ភាគច្រើនតែងនិយាយថា នៅពេលមានសំណួរពីអ្នកកាសែត ហើយ នៅប្រការណាមួយដែលគេរកវិធីឆ្លើយដោះស្រាយសំណួរមិនទាន់ នោះការជក់បារី តាមរយៈការចាប់កាន់ និងការអុជបារី បានពន្យារពេលអោយគាត់បានចំណេញយ៉ាង ហោចណាស់ក៏ ១៥ វិនាទីដែរ ហើយក៏ជាឱកាសទុកអោយគាត់នឹករកចម្លើយដោះ ជាបណ្តើរៗ បាន ។ អ្នកស្រុក អ្នកស្រែខ្មែរ នៅតាមជនបទចុងកាត់មាត់ញកនិយាយ ថា ចោរមិនហ៊ានលួចគោនៅក្រោមផ្ទះឡើយ កាលណាវាមើលពីចម្ងាយនៅពេល យប់ឃើញម្ចាស់ផ្ទះកំពុងជក់បារីនោះ ។ ហើយនៅពេលចូលព្រៃ សត្វពស់ក៏មិនហ៊ាន ចឹកដែរ ព្រោះវាខ្លាចភ្លើងបារី ហើយសត្វខ្លាក៏មិនហ៊ានមកជិតដែរ ព្រោះខ្លាចភ្លើង បារីដូចគ្នា ។

ប្រការល្អរបស់បារីមួយទៀត គឺគេអាចស្គាល់គ្នាតាមរយៈការហុចបារីអោយគ្នាទៅវិញទៅមក ។ ការហុចបារី ក៏ជាវិធីផ្ដើមនៃការចងមិត្តភាពរវាងមនុស្ស ២ នាក់ដែលមិនធ្លាប់ស្គាល់គ្នាពីមុនមកសោះ ។

ដូនតានៅស្រុកស្រែចំការយើង ច្រើននិយមជក់ថ្នាំមូរជាមួយនឹងស្លឹកសង្កែ ។ រហូតមកដល់ពេលនេះ ក៏មិនទាន់ឃើញអង្គការណាមួយស្រាវជ្រាវអំពីរបៀបជក់ថ្នាំមូរស្លឹកសង្កែនេះនៅឡើយ ។ បារីដែលផលិតនាំចូលមកពីបរទេសសុទ្ធតែមានលាយជាតិគ្រឿងញៀន រីឯបារីថ្នាំខ្មែរមូរស្លឹកសង្កែ ជាថ្នាំធម្មជាតិមិនមានលាយជាតិគ្រឿងញៀនឡើយ ឬមិនមានលាយជាតិគីមីណាទៀតឡើយ ។ ដូចនេះ គេសង្កេតឃើញថា អ្នកជក់ថ្នាំខ្មែរមានសុខភាពប្រសើរជាងអ្នកជក់បារីនាំចូលមកពីបរទេស ។

គេបានរកឃើញការជក់បារី ជាមួយខ្សៀវាប្រសើរជាងការជក់បារីដែលមានត្រឹមតម្រងកន្ទុយស្មោ ។ ម្យ៉ាងទៀត គេសង្កេតឃើញថា អ្នកជក់បារីដែលមានវ័យចំណាស់លើសពីអាយុ ៥៥ ឆ្នាំឡើងទៅ ច្រើនស៊ាំទៅនឹងបារី ហើយមិនសូវឃើញមានកើតជំងឺរបេងសួត ឬកើតជំងឺមហារីកឡើយ ។

ប្រការទាំងឡាយដូចបានរៀបរាប់ខាងលើ គ្រាន់តែជាគំនិតតូចមួយសំរាប់យើងចូលរួមចំណែកពិចារណា ថាតើអ្នកជក់បារីត្រូវបន្ថយការជក់ ឬក៏ត្រឹមជក់ក្នុងពេលមានការចាំបាច់ខានមិនបាន ។ អ្នកដែលធ្លាប់ញៀននឹងបារី ១ ចំនួន បានលះបង់ឈប់ជក់បារីតទៅទៀតបានហើយ ហើយគាត់បានពោលថា មិនមានការលំបាកក្នុងការផ្ដាច់ឈប់ជក់បារីឡើយ ប្រសិនបើចិត្តអ្នកជក់ចង់ឈប់ជក់ភ្លាមនោះ ។ ប្រការមួយទៀត ចំពោះអ្នកដែលដឹងថាមិនអាចឈប់ជក់ភ្លាមបាន គេគួរសាកល្បងបន្ថយការជក់ ១ ថ្ងៃ ១ ដើម រហូតឈប់ជក់បានជាស្ថាពរ ក្នុងអំឡុងពី ១ ទៅ ៣ ខែ ។

# សេចក្តីជូនដំណឹង

អំពីលទ្ធផលនៃចម្លើយ " កំណាព្យប្រស្នា "

ដែលបានចុះក្នុងទស្សនាវដ្តីកម្ពុជសុរិយា លេខ ១ ឆ្នាំ ១៩៩៥

គណៈកម្មការនិពន្ធ នៃទស្សនាវដ្តីកម្ពុជសុរិយា មានកិត្តិយសសូមប្រគេន និងជូនដំណឹងចំពោះព្រះតេជព្រះគុណ និងចំពោះអស់លោក អ្នកនាងកញ្ញា ព្រមទាំងមិត្តអ្នកអានជាទីគោរពថា គណៈកម្មការបានទទួលលិខិតជាច្រើនដែលបានរួមចំណែកដល់ការឆ្លើយប្រស្នា ។ នៅក្នុងចំណោមលិខិតទាំងនោះ មានលិខិតចំនួន ៦ បានឆ្លើយត្រូវ ។ គណៈកម្មការបានសំរេចជូនរង្វាន់ដល់អ្នកឆ្លើយត្រូវទាំងអស់ ដោយធ្វើការជ្រើសរើស និងរៀបចំណាត់ថ្នាក់ ជាបីរង្វាន់ គឺ :

*ក / រង្វាន់លេខ ១* . ត្រូវបានប្រាក់ ចំនួន ៤០.០០០ ៛ ០០ មានមួយរង្វាន់ ត្រូវប្រគល់ជូនទៅលោក តឹក ប៊ុនឈឿន និស្សិតមហាវិទ្យាល័យ វេជ្ជសាស្ត្រ ឱសថសាស្ត្រ និងទន្តសាស្ត្រ ។

*ខ / រង្វាន់លេខ ២* . ត្រូវបានប្រាក់ចំនួន ៣៥.០០០ ៛ ០០ មានពីររង្វាន់ ត្រូវប្រគល់ជូនជ័យលាភី ដូចខាងក្រោម :

១ . ភិក្ខុ ប៉ាត សុផល សមណសិស្សពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ឆ្នាំទី៣ (ខ) ។

២ . ភិក្ខុ សាន សុម៉ែន រតនសុវណ្ណោ សមណសិស្សពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹតឆ្នាំទី៣ គង់នៅកុដិលេខ ១១ វត្តឧណ្ណាលោម ភ្នំពេញ ។

*គ / រង្វាន់លេខ ៣* . ត្រូវបានប្រាក់ចំនួន ៣០.០០០ ៛ ០០ មានបីរង្វាន់ ដែលត្រូវប្រគល់ជូនជ័យលាភី ដូចខាងក្រោម :

១ . ភិក្ខុ ព្រហ្ម សុជាតិ អគ្គចិត្តោ គង់នៅវត្តអង្គរយាប ខេត្តកំពង់ស្ពឺ ។

២ . ភិក្ខុ កង ព្រំ គង់នៅវត្តរដ្ឋសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។

៣ . លោក ចាន់ យ៉ាន ប្រធានការិយាល័យធម្មការ និងសាសនា ស្រុកឫស្សីកែវ ភ្នំពេញ ។

គណៈកម្មការនិពន្ធ សូមនិមន្ត និងអញ្ជើញជ័យលាភីទាំងប៉ុន្មាន ដូចមានរាយព្រះនាម និងឈ្មោះខាងលើមកបើករង្វាន់នៅផ្នែកទស្សនាវដ្ដី នៃពុទ្ធសាសនបណ្ឌិត្យ ដែលមានទីស្នាក់ការបណ្ដោះអាសន្ននៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ នៅរាល់ម៉ោងធ្វើការ ។

ទន្ទឹមនឹងនេះដែរ គណៈកម្មការសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្ដម វណ្ណ ស៊ុនហេង អ្នកតំណាងរាស្ដ្រមណ្ឌលព្រៃវែង ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន សំរាប់ឧបត្ថម្ភចំពោះជ័យលាភីទាំងអស់ ដែលបានឆ្លើយត្រូវប្រស្នាលើកនេះ ។

**កម្ពុជសុរិយា**

# ចម្លើយកំណាព្យប្រស្នា

នេះនឹងថ្លាថ្លែងចែងសេចក្តី ឆ្លើយលលកលៃន័យបុច្ឆា
ដោះស្រាយតិចតួចតាមប្រាជ្ញា ខុសត្រូវម្តេចម្តាមេត្តាផង ។
ធម្មតាការលុបមានច្រើនយ៉ាង លុបបាត់រូបតាងរាងដើមទង
តែនេះចម្លែកប្លែកតែម្តង លុបហើយច្បាស់ផងចងប្រើការ ។
ខ្ញុំសូមរិះជូននាលោះរំលែក លុបយ៉ាងចម្លែកប្លែកអស្ចារ្យ
គឺលុបស្លឹករឹតផ្ចិតអក្ខរា លុបហើយកាលណាអក្ខរាច្បាស់ ។
លុបណាស់ឃើញណាស់ច្បាស់នេត្រា ចងជាតម្រាសព្វសិល្ប៍សាស្ត្រ
ខ្ញុំសូមរ៉ាយរ៉ាប់ប្រាប់ខ្លះៗ ទោះលើសឬខ្វះសូមខមា ។
ស្លឹករឹតចារហើយខ្វះតែគ្រឿង យកធ្យូងម្រេងភ្លើងជ័រទឹកថ្លា
កូរលាយឱ្យសព្វជាមួយគ្នា រួចស្រេចក្លាយជាទឹកខ្មៅពិត ។
យកក្រណាត់ជ្រលក់ទឹកខ្មៅ រួចហើយយកទៅលាបស្លឹករឹត
ជូតវាសហើយស្រេចរកខ្សាច់ល្អិត បាចលើស្លឹករឹតឡើងក្រាស់ឃ្មឹក ។
ដៃម្ខាងទ្រាប់កាន់ទប់ឱ្យជាប់ ដៃម្ខាងជូតលុបស្អាតជ័រទឹក
អក្ខរាចេញច្បាស់ល្អពន្លឹក ហាលរួចរៀបស្លឹកតាមលេខក្រិត ។
ឈូសខាត់ឱ្យស្អាតទើបទីបមាស ខ្សែចងក្រងក្រាស់សោតសឹងស្ទិត
ដោតចាក់ដាក់ក្របជាគម្ពីរពិត ល្អស្រស់វិចិត្រចាំងថ្លាថ្លៃ ។
នេះជាការឆ្លើយទាំងប្រថុយ ដឹងចំឬខុយសូមខន្តី
សូមចប់សង្ខេបបែបបទខ្លី សូមជូនពរជ័យថ្លៃបរិសុទ្ធ ។

ខ្ញុំសូមបួងសួងសព្វទេវតា សូមជួយរក្សាសាសនាពុទ្ធ
ទាំងព្រះបិតាខេមរាបុត្រ ឆ្លងចាកភ័យផុតភាពអន្ធការ ។
សូមផុតទុរ្ភិក្សរោគយាយី សូមខ្មែរសាមគ្គីកុំប្រេះឆា
សូមជាតិស្អាតស្អំឈ្មោះបច្ចា អង្គរខេមរាសុខទៅអើយ ។

**គីភ ប៊ុនឈឿន**
និស្សិតមហាវិទ្យាល័យ វេជ្ជសាស្ត្រ ឱសថសាស្ត្រ និងទន្តសាស្ត្រ

# កំណាព្យប្រស្នា

បទពាក្យ ប្រាំបី

* ផ្កាខ្ញីស្វាម៉ាលីគ្មានពីរក្លិនក្លែប ក្រអូបក្រអែបពិដោរឈ្ងុយឈ្ងប់
លោកអ្នកធីហើយសរសើរមិនឈប់ ចូលចិត្តជឿស៊ប់ពូជស្រូវប្រពៃ ។
* តែស្រូវម្យ៉ាងទៀតមានពីបុរ្វេ ក្រអូបលើសគេពូជស្រូវដទៃ
មានបីកន្លាំងថែងចាំងរស្មី មនុស្សលើផែនដីបានធីច្រើនគ្នា ។
* បើបានបរិភោគស្រូវនោះហើយណា កាយចិត្តខ្លាំងក្លាសះស្បើយរោគា
មនុស្សខ្វាក់បានភ្លឺអ្នកឈឺបានជា ចេះស្រឡាញ់គ្នាសាមគ្គាមាំមួន ។
* ស្រូវនោះឈ្មោះអ្វីសូមស្តីបញ្ជាក់ តាក់តែងតាមវគ្គពាក្យកាព្យចុងជួន
អស់លោកអ្នកប្រាជ្ញអាចដឹងចំនួន ព្រោះលោកចេះក្បួនរាប់គ្រាប់ស្រូវបាន ។

**ខណ្ឌ ស៊ុនហេង**

# គម្ពីរព្រះត្រៃបិដកប្រែរបស់ខ្មែរ ត្រូវបានបោះពុម្ពជាថ្មី

នៅក្នុងប្រវត្តិសាស្ត្រនាពេលថ្មីៗនេះ ព្រះរាជាណាចក្រកម្ពុជា បានជួបប្រទះនូវវិបត្តិយ៉ាងធ្ងន់ធ្ងរ នៅក្នុងអត្ថិភាពរបស់ខ្លួន ពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ។ នៅក្នុងពេលតែជាង ៤ ឆ្នាំប៉ុណ្ណោះ ប្រភពធនធានវប្បធម៌ស្ទើរតែទាំងអស់ ត្រូវទទួលរងការបំផ្លិចបំផ្លាញទាំងស្រុង ។ នៅក្នុងចំណោមធនធានទាំងនោះ ពុទ្ធសាសនាដែលជាមូលដ្ឋានគ្រឹះនៃវប្បធម៌របស់ជនជាតិខ្មែរ ក៏ទទួលរងគ្រោះមហន្តរាយ យ៉ាងធ្ងន់ធ្ងរដែរ ។ ព្រះសង្ឃមានចំនួនដល់ទៅជាង ៦០.០០០ អង្គ ត្រូវចាប់បង្ខំអោយចាកសិក្ខាបទ ធ្វើគត ឬសុគតដោយជំងឺ និងដាច់ពោះដោយអត់មានអាហារឆាន់ ។ វត្តអារាមជាង ៣០០០ ត្រូវបានកំទេចអោយបាក់បែកខ្ទេចខ្ទី ។ គម្ពីរ ដីកា និងសាស្ត្រាសៀវភៅផ្សេងៗ ត្រូវបានគេដុតអោយទៅជាផេះផង់ ។

តែទោះបីយ៉ាងណា ក៏ប្រជាជនកម្ពុជាបានចាប់ផ្តើមកសាងជាតិរបស់ខ្លួនឡើងវិញគ្រប់វិស័យ រួមទាំងវិស័យពុទ្ធសាសនាផង ដោយអង់អាច ចាប់តាំងពីឆ្នាំ ១៩៧៩ ដោយមានតែបាតដៃទទេ ។ រហូតមកដល់សព្វថ្ងៃ ចំនួនព្រះសង្ឃបានកើនឡើងដល់ ៤០.២១៨ អង្គ ប្រហាក់ប្រហែលនឹង ៦៤% នៃចំនួនព្រះសង្ឃពីសម័យមុន ។ នៅក្នុងការខិតខំប្រឹងប្រែងស្តារវិស័យពុទ្ធសាសនានេះ, វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យបានបំពេញតួនាទីជាស្នូលមួយ ចាប់តាំងពីវិជ្ជាស្ថាននេះ ត្រូវបានរៀបចំអោយដំណើរការឡើងវិញ នៅក្នុងឆ្នាំ១៩៩២ គឺការប្រមូលចងក្រង ទុកដាក់ឯកសារសៀវភៅធម៌អាថ៌ និងកាបោះពុម្ពឡើងវិញនូវសៀវភៅចាំបាច់ និងបន្ទាន់ សំរាប់បំរើសេចក្តីត្រូវការចំពោះមុខរបស់ព្រះសង្ឃ និងពុទ្ធបរិស័ទ ។ ចាប់ពីពេលនោះមក ដោយបានទទួលការឧបត្ថម្ភដ៏ឧត្តុង្គឧត្តមពីអង្គការជំនួយសូត្តូស្ហ៊ូជប៉ុន និងជំនួយ

សប្បុរសធមិដទៃទៀត ពីប្រទេសជប៉ុន និងអាល្លឺម៉ង់, វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពឡើងវិញនូវសៀវភៅពុទ្ធសាសនាបានជាង ៦ សែនក្បាល និងបានចែកចាយសៀវភៅទាំងឡាយនោះទៅតាមវត្តអារាម និងសាលាពុទ្ធិកសិក្សានានា ។ ការចេញផ្សាយឡើងវិញនូវទស្សនាវដ្ដីកម្ពុជសុរិយា ដែលក្បាលទីមួយនៃទស្សនាវដ្ដីនេះត្រូវបានគេបោះផ្សាយតាំងពីឆ្នាំ ១៩២៦ នោះ បានរួមវិភាគទានយ៉ាងធំធេងដល់ការស្រោចស្រង់អោយរស់ឡើងវិញនូវសហាគមន៍ពុទ្ធសាសនិកនៅកម្ពុជា ។

ជាមួយនឹងការបោះពុម្ពសៀវភៅខាងលើនេះ, គម្ពីរព្រះត្រៃបិដកទាំង ១១០ ភាគ ក៏ត្រូវបានបោះពុម្ពឡើងវិញជាជំហានដំបូង ចំនួន ១២០០ ចប់ផងដែរ ។

ការបោះពុម្ពឡើងវិញនៃគម្ពីរព្រះត្រៃបិដកខ្មែរ គឺជាចម្លើយតបទៅនឹងសេចក្ដីត្រូវការចាំបាច់ចំពោះមុខនៃព្រះសង្ឃ និងវត្តអារាមដែលមានបរិមាណកាន់តែច្រើនឡើងៗរៀងរាល់ឆ្នាំនេះម្យ៉ាង ម្យ៉ាងទៀត គម្ពីរព្រះត្រៃបិដក គឺជាមូលដ្ឋានគ្រឹះនៃព្រះពុទ្ធសាសនា ដែលជាគម្ពីរចាំបាច់ ពុំអាចខ្វះបាន ។

ក្រោយឆ្នាំ ១៩៧៩, គម្ពីរព្រះត្រៃបិដកទាំង ១១០ ភាគនេះ នៅសេសសល់យ៉ាងតិចតួចបំផុត ហើយដែលគេប្រមូលបានពីរ-បីចប់នោះ ស្ទើរតែរកមួយចប់ណាដែលមានគុណភាពល្អ សំរាប់ថតចម្លងបោះពុម្ពឡើងវិញផង ។

ដោយសង្កេតឃើញសេចក្ដីខ្វះខាតដ៏គួរអោយខ្លោចផ្សារ និងសេចក្ដីត្រូវការបន្ទាន់របស់ព្រះសង្ឃ ក៏ដូចជារបស់ពុទ្ធសាសនិកជន, ទើបពុទ្ធសាសនបណ្ឌិត្យបានជួបប្រាស្រ័យជាមួយអង្គការសាសនាទាំងឡាយរបស់ជប៉ុន ដើម្បីស្នើសុំការឧបត្ថម្ភដល់ការជួយបោះពុម្ពឡើងវិញនូវគម្ពីរព្រះត្រៃបិដក ដើម្បីបំពេញសេចក្ដីខ្វះខាត និងបំពេញសំណូមពរទាំងនោះ ។ សេចក្ដីស្នើសុំការឧបត្ថម្ភឡើងវិញរបស់ពុទ្ធ-សាសនបណ្ឌិត្យ ត្រូវបានអង្គការសាសនាជប៉ុន ដែលមានព្រះតេជព្រះគុណ សីក្យមូចាគូ ទទួលយកទៅពិចារណា, ហើយទីបំផុត សំរេចជួយផ្ដល់ការឧបត្ថម្ភបោះពុម្ព

ឡើងវិញ ចំនួន ១២០០ ចប់ ។ ក្នុងការបោះពុម្ពឡើងវិញនេះ គណៈកម្មការបោះពុម្ពព្រះត្រៃបិដកជប៉ុន បានស្រាវជ្រាវរកសៀវភៅគំរូដើមបានចំនួនពាក់កណ្ដាល នៅប្រទេសជប៉ុន និងពាក់កណ្ដាលទៀត យកពីប្រទេសកម្ពុជា ហើយចាប់ផ្ដើមការងារដ៏សម្បើមនេះ តាំងពីពាក់កណ្ដាលឆ្នាំ ១៩៩៤ រហូតដល់ខែមេសា ១៩៩៥ ទើបបោះពុម្ពឡើងវិញចប់សព្វគ្រប់ ។ គម្ពីរព្រះត្រៃបិដក ទាំង ១២០០ ចប់នេះ ត្រូវបានបញ្ជូនតាមកប៉ាល់ពីប្រទេសជប៉ុន មកកម្ពុជា តាមរយៈកំពង់ផែកំពង់សោម ហើយមកដល់រាជធានី ភ្នំពេញ នៅថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ១៩៩៥ ដោយសុវត្ថិភាព ។

ពិធីប្រគល់គម្ពីរព្រះត្រៃបិដក បានប្រព្រឹត្តទៅក្រោមព្រះបរមរាជាធិបតីភាព ដ៏ខ្ពង់ខ្ពស់នៃព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង និងសម្ដេចព្រះមហេសី ពីថ្ងៃទី ២០ មិថុនា ១៩៩៥ នោះ ព្រះតេជព្រះគុណ សឹក្យ ម្ចចាគូ ប្រធានគណៈកម្មការបោះពុម្ពព្រះត្រៃបិដកឡើងវិញ និងទាយកសប្បុរសជនជប៉ុន ដែលបានឧបត្ថម្ភការបោះពុម្ពព្រះត្រៃបិដកឡើងវិញ ទាំងព្រះសង្ឃ ទាំងគ្រហស្ថ ចំនួន ៧៨ រូប បាននិមន្ត-អញ្ជើញចូលរួមផងដែរ ។ នៅក្នុងឱកាសដ៏មហោឡារិកនោះ ព្រះតេជព្រះគុណ សឹក្យ ម្ចចាគូ បានមានពុទ្ធដីកាថា ៖

« អាត្មាភាព ខ្ញុំព្រះករុណា យើងខ្ញុំ មានមហាកិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយបានចូលរួមក្នុងពិធីប្រគល់គម្ពីរព្រះត្រៃបិដករបស់ខ្មែរ ទាំង ១២០០ ចប់ ដែលមាន ១១០ ភាគ ក្នុងមួយចប់ ហើយមានចំនួនសរុបទាំងអស់ ១៣២.០០០ ច្បាប់ ។ គម្ពីរព្រះត្រៃបិដករបស់ខ្មែរ ត្រូវបានពុទ្ធសាសនបណ្ឌិត្យនៅភ្នំពេញ ខិតខំបកប្រែ រៀបរៀង និងចងក្រងអស់រយៈពេល ៤០ ឆ្នាំគត់ ចាប់តាំងពីឆ្នាំ ១៩២៩ ដល់ឆ្នាំ ១៩៦៨ ។

គម្ពីរព្រះត្រៃបិដកខ្មែរ គឺជាសម្បត្តិវប្បធម៌ដ៏មានតម្លៃបំផុតយ៉ាងពិតប្រាកដរបស់ពុទ្ធសាសនាខ្មែរ ព្រមទាំងជារបស់ផ្សព្វផ្សាយវប្បធម៌ខ្មែរផងដែរ ។

ពុទ្ធសាសនិកស្ម័គ្រចិត្តជប៉ុន បានបោះពុម្ពគម្ពីរព្រះត្រៃបិដកខ្មែរឡើងវិញ ហើយនៅពេលនេះ ក៏បានយកគម្ពីរទាំងនេះ មកប្រគល់ថ្វាយ-ប្រគេន-ជូន ដោយស្មោះស្ម័គ្រ ដើម្បីស្តារ និងស្រោចស្រង់អោយរស់ឡើងវិញនូវធនធានវប្បធម៌ពុទ្ធ-សាសនានៅកម្ពុជា ។

អស់រយៈពេលជាង ៥០ ឆ្នាំកន្លងមកហើយ កាលនៅសម័យសង្គ្រាមលោកលើកទី ២ អាត្មាភាព ខ្ញុំព្រះករុណា យើងខ្ញុំ ដែលជាពុទ្ធសាសនិកជប៉ុន បានប្រព្រឹត្តខុសជាច្រើន ។ អាត្មាភាព ខ្ញុំព្រះករុណា យើងខ្ញុំ បានអោយឈ្មោះការលុកលុយរបស់ជប៉ុន ដែលជាបទឧក្រិដ្ឋនោះថាជា «សង្គ្រាមដ៏បរិសុទ្ធទៅវិញ ហើយក៏អនុញ្ញាតអោយពលរដ្ឋដែលជាសង្ឃដ៏ចក្នា ចូលរួមប្រយុទ្ធនៅសមរភូមិ» ។

អាត្មាភាព ខ្ញុំព្រះករុណា យើងខ្ញុំ មិនគ្រាន់តែមិនទើសទាល់នឹងការបញ្ឈប់សង្គ្រាមនោះប៉ុណ្ណោះទេ តែថែមទាំងជួយធ្វើសង្គ្រាមថែមទៀត ។

ពុទ្ធសាសនិកជប៉ុន មិនបានខិតខំទូន្មានប្រជាពលរដ្ឋជប៉ុន អោយគោរពតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធបរមគ្រូ អំពីសន្តិភាពដ៏បរិបូណ៌ ការមិនចូលបំរើក្នុងជួរទ័ព និងការបោះបង់ចោលនូវសង្គ្រាមដោយការប្តូរផ្តាច់នឹងជីវិតរបស់ខ្លួនទេ ។ នេះគឺជាពិរុទ្ធភាពរបស់ពុទ្ធសាសនិកជប៉ុន ។

ជាលទ្ធផលដែលបានមក គឺអាត្មាភាព ខ្ញុំព្រះករុណា យើងខ្ញុំ បានជួយដល់បទឧក្រិដ្ឋនៃជាតិយើងខ្ញុំ ដែលធ្វើអោយប្រទេសទាំងឡាយនៅអាស៊ីធ្លាក់ក្នុងចំបាំង ។

ដោយពុទ្ធសាសនិកជប៉ុនទទួលនូវទោសកំហុសទាំងនេះ ទើបអាត្មាភាព ខ្ញុំព្រះករុណា យើងខ្ញុំ សូមលន់តួនូវពិរុទ្ធភាពរបស់ពុទ្ធសាសនិកជប៉ុន នៅចំពោះព្រះភក្ត្រព្រះពុទ្ធបរមគ្រូ មុនអ្វីៗទាំងអស់ ។

ដោយទទួលនូវការសោកស្តាយទាំងនេះ អាត្មាភាព ខ្ញុំព្រះករុណា យើង

ខ្ញុំ ក៏បានសួរទៅពុទ្ធសាសនិកខ្មែរ ថាតើមានអ្វីអាចអោយអាត្មាភាព ខ្ញុំព្រះករុណា យើងខ្ញុំ ជួយដល់ប្រទេសកម្ពុជាបានទេ ក្នុងឋានៈជាពុទ្ធសាសនិក ? ។»

ព្រះតេជព្រះគុណ មូចាតូ បានបន្តទៀតថា " អ្នកដឹកនាំខាងពុទ្ធសាសនា ទាំងព្រះសង្ឃ ទាំងគ្រហស្ថ បានឆ្លើយតបមកអាត្មាភាព ខ្ញុំព្រះករុណា យើងខ្ញុំ នូវចម្លើយដូចគ្នា គឺ (បោះពុម្ពគម្ពីរព្រះត្រៃបិដកឡើងវិញ ។ បើគ្មានគម្ពីរព្រះត្រៃបិដកទេ នោះក៏នឹងមិនមានការស្តារពុទ្ធសាសនាខ្មែរឡើងវិញដែរ)" ។

ព្រះតេជព្រះគុណ មូចាតូ បានបញ្ចប់សុន្ទរកថារបស់លោកថា :

«អាត្មាភាព ខ្ញុំព្រះករុណា យើងខ្ញុំ សូមប្រកាសនៅក្នុងឱកាសនេះថា អាត្មាភាព ខ្ញុំព្រះករុណា យើងខ្ញុំ នឹងខិតខំប្រឹងប្រែងបញ្ឈប់សង្គ្រាម ហើយនាំគ្នាធ្វើដំណើរឆ្ពោះទៅរកសតវត្សទី ២១ គឺសតវត្សដ៏សន្តិភាពមួយតាមស្មារតីនៃពុទ្ធ-សាសនា មិនប្រព្រឹត្តកំហុសពីអតីតកាលឡើងវិញ ដោយបន្តការអំពាវនាវដល់ពុទ្ធ-សាសនិកទាំងអស់នៅលើសកលលោក ព្រមទាំងប្រជាពលរដ្ឋទាំងអស់នៅលើលោកនេះអោយសាមគ្គីគ្នា ដើម្បីសុខសន្តិភាពពិភពលោក» ។

ពិតមែនតែចំនួនគម្ពីរព្រះត្រៃបិដកដែលយើងបានទទួល មិនទាន់ឆ្លើយតបបានគ្រប់គ្រាន់ទៅតាមសំណូមពររបស់វត្តអារាមខ្មែរយើងក៏ដោយ ក៏យើងយល់ថា នេះជាវិភាគទានមួយយ៉ាងធំធេង ចំពោះការស្តារពុទ្ធសាសនានៅកម្ពុជា ចំពោះការប្រមូលចងក្រងឯកសារ និងការបោះពុម្ពឡើងវិញ នៃសមិទ្ធិខាងព្រលឹង ដែលបុព្វបុរសយើង និងពុទ្ធសាសនបណ្ឌិត្យ បានកសាងទុកអោយកូនចៅខ្មែរយើងសិក្សារៀនសូត្រ តាំងពីសម័យបុរាណរហូតដល់សព្វថ្ងៃនេះ ។

**ឱម ខែម**

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



ព្រះវិហារវត្តពិភិទ្ធារាម ក្រុងបាត់ដំបង

ឆ្នាំទី ៤៩ លេខ ៣ ខែ កក្កដា - សីហា - កញ្ញា

ព.ស ២៥៣៩ គ.ស ១៩៩៥

ភ្នំពេញ



# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ


ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន ៖

ទីប្រឹក្សា : **ហៀន ចណ្ណរត្ន**

នាយកការផ្សាយ : **ឈន អៀម**

និពន្ធនាយក : **យី ធន់**

និពន្ធនាយករង : **ឱម ខែម**

គណៈកម្មការនិពន្ធ

សម្ដេចព្រះធម្មលិខិត **លាស់ ឡាយ**, ព្រះមហាព្រហ្មមុនី **ហេង លាងហោ**,

លោក **ម៉ែន ប្រាង**, លោក **អាំ ឆន**,

## ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの宗教と文化の発展に貢献できれば幸いです。

## ACKNOWLEDGEMENT

The Kampuja Surya Magazine is specially printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC).

We pray that this magazine would contribute to the Friendship with Cambodian people and their religious and cultural preservation.

## និវេទនកថា

ទស្សនាវដ្ដីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគម្រោងការងារ របស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោកស្ដីពីសាសនានិងសន្តិភាព (WCRP) ហើយនិងគណៈកម្មាធិការជំនួយសូតូស៊ូជប៉ុន (JSRC) ។

យើងខ្ញុំអធិដ្ឋាន សូមឱ្យទស្សនាវដ្ដីនេះ បានជាវិភាគមានរក្សាមិត្តភាពជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិសាសនានិងវប្បធម៌របស់ប្រជាជនកម្ពុជា ។

# មាតិកាអត្ថបទ

## I. អត្ថបទរដ្ឋបាល ៖


- ប្រកាស ស្តីពីការបែងចែកភារកិច្ចជូនរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងទីប្រឹក្សាក្រសួងធម្មការ និងសាសនា ១
- សេចក្តីសំរេច ស្តីពីការចាត់តាំងអោយបំពេញការងារបន្ថែម ៤


## II. អក្សរសិល្ប៍ពុទ្ធសាសនា ៖


- ចីវររបស់ព្រះសង្ឃ (លោក ម៉ែន ប្រាង និង អាំ ឆន) ៦
- សូធ្យស្មូមទាន់ព្រះសមោធាន (លោក ជីម ពៅ) ១៦


## III. អក្សរសាស្ត្រទូទៅ ៖


- បណ្តាំក្រមង៉ុយ ១៧
- ពាក្យបណ្តាំរបស់បិតា (លោក ម៉ែន ប្រាង និង អាំ ឆន) ២៧
- ចាស់ពុំទាន់ទុំ (លោក ជីម ពៅ ) ៣៧
- បញ្ជីឈ្មោះបទភ្លេងខ្មែរ ៣៨
- សេចក្តីជូនដំណឹង អំពីលទ្ធផលនៃចម្លើយកំអាព្យប្រស្នា ៤៥
- ចម្លើយកំណាព្យប្រស្នា (លោក សរ ចន្ទរិទ្ធិ) ៤៨
-* កំណាព្យប្រស្នា ៥៤


## IV. កំណត់ និង ប្រវត្តិការណ៍ ៖


- ដំណើរទស្សនកិច្ចរបស់ឯកឧត្តម ឈន អៀម នៅប្រទេសជប៉ុន ៥៦
- ការបែងចែកគម្ពីរព្រះត្រៃបិដក ៦៩

# ព្រះរាជាណាចក្រកម្ពុជា

ក្រសួងធម្មការ និងសាសនា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ១៥៩ / ៩៥ កធស

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ១៩៩៥

## ប្រកាស

ស្តីពីការបែងចែកភារកិច្ចជូនដល់រដ្ឋលេខាធិការ

និងអនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា និងទីប្រឹក្សា

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំង ឯកឧត្តម ហៀន វណ្ណរ័ត្ន ជារដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។

- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងអនុរដ្ឋលេខាធិការ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋលេខាធិការដ្ឋាន ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។

- បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ។

- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងធម្មការ ។

- សំណូមពរការងារចាំបាច់របស់ក្រសួង ។

## សំរេច

*ប្រការ ១ :* ឯកឧត្តម ហៀន វណ្ណរ័ត្ន រដ្ឋលេខាធិការ ជាប្រធានស្ថាប័ន

មានភារកិច្ចដឹកនាំមាគ៌ានយោបាយសាសនារបស់រាជរដ្ឋាភិបាល ទទួលខុសត្រូវចំពោះសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងចំពោះរដ្ឋសភាជាតិ ក្នុងការដឹងនាំក្រសួង ។

ក្នុងតួនាទីនេះ រដ្ឋលេខាធិការទទួលបន្ថែមនូវការងារខុទ្ទកាល័យ នាយក-ដ្ឋានធម្មការ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ច និងទំនាក់ទំនងក្នុង និងក្រៅប្រទេស « ជាតិ និងអន្តរជាតិ »

*ប្រការ ២ :* ឯកឧត្តមអនុរដ្ឋលេខាធិការ ជាអ្នកជំនួយការផ្ទាល់ និងជាសហការីជិតស្និទ្ធបំផុតរបស់រដ្ឋលេខាធិការ ក្នុងកិច្ចសហការគ្នាដឹកនាំក្រសួងឱ្យបានរីកចំរើន ។ អនុរដ្ឋលេខាធិការ ត្រូវបានប្រគល់ភារកិច្ចឱ្យសម្របសម្រួលការងាររបស់នាយកដ្ឋានជំនាញមួយៗ ហើយរាយការណ៍ពីសកម្មភាពរបស់នាយកដ្ឋានទាំងនោះជូនរដ្ឋលេខាធិការ ដោយជៀសវាងចូលជ្រៅក្នុងការងារផ្ទៃក្នុងរបស់នាយក-ដ្ឋានជំនាញ ។

១ - ឯកឧត្តម ឈន អៀម អនុរដ្ឋលេខាធិការ ទទួលបន្ទុកសម្របសម្រួលការងារពុទ្ធសាសនបណ្ឌិត្យ ។

២ - ឯកឧត្តម អ៊ីស្មាឯល ឧស្មាន អនុរដ្ឋលេខាធិការ ទទួលបន្ទុកសម្របសម្រួលការងារនាយកដ្ឋានសាសនា ។

៣ - ឯកឧត្តម ដោក ណារិន អនុរដ្ឋលេខាធិការ ទទួលបន្ទុកសម្របសម្រួលការងារអគ្គាធិការពុទ្ធិកសិក្សា ។

*ប្រការ ៣ :* លោក យី ធន់ ទីប្រឹក្សាក្រសួងធម្មការ និងសាសនា ជាអ្នកជំនាញការ និងជាអ្នកជំនួយការផ្ទាល់របស់រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិ-ការ, ត្រូវទទួលភារកិច្ច ដែលរដ្ឋលេខាធិការប្រគល់ជូនផ្ទាល់ ។

*ប្រការ ៤ :* ពេលអវត្តមានរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការមួយរូបដែលទទួលការផ្ទេរសិទ្ធិ មានសិទ្ធិចុះហត្ថលេខាលើលិខិតស្នាមផ្សេងៗ ជាផ្លូវការ

របស់ក្រសួង ។

*ប្រការ ៥ :* ឯកឧត្តមដូចមានរាយនាមក្នុងប្រការ២ និង៣ នាយកខុទ្ទកា-ល័យ និងប្រធាននាយកដ្ឋានទាំងអស់នៃក្រសួងធម្មការ ទទួលបន្ទុក និង អនុវត្ត ប្រកាសនេះ តាមសមត្ថកិច្ច និងភារកិច្ចរៀងៗខ្លួន ។

*ប្រការ ៦ :* រាល់សេចក្តីសំរេចដែលពាក់ព័ន្ធនឹងការបែងចែកភារកិច្ច នេះ ដែលមានពីមុន ចាត់ទុកជានិរាករណ៍ ។

*ប្រការ ៧ :* សេចក្តីប្រកាសនេះ មានអានុភាពតតិយុត្តិចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

ហត្ថលេខា និងត្រា

**ហៀន វណ្ណារិទ្ធ**

ចម្លងជូន :

- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

«ដើម្បីជូនជ្រាប »

- ដូចក្នុងប្រកា២ និង៣ «ដើម្បីអនុវត្ត »

ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងធម្មការ និង សាសនា

លេខ ២១៦ / ៩៥ ក.ធ.ស

## សេចក្តីសំរេច
ស្តីពីការចាត់តាំងអោយបំពេញការងារបន្ថែម

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣,
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងព្រះរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ. ចុះថ្ងៃទី ៨ ខែកុម្ភៈ ១៩៩២,
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ. ចុះថ្ងៃ ៣០ មិថុនា ១៩៩២ ស្តីពីការរៀបចំ និងដំណើរប្រព្រឹត្តទៅនៃទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ,
- យោងប្រកាសលេខ ១៥៩/៩៥ ក.ធ.ស. ចុះថ្ងៃទី ៣១ កក្កដា ១៩៩៥ ស្តីពីការបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំក្រសួងធម្មការ និងសាសនា,
- អនុលោមតាមសំណូមពររបស់នាយកពុទ្ធសាសនបណ្ឌិត្យ និងអនុលោមតាមទំហំការងារនៃពុទ្ធសាសនបណ្ឌិត្យ ដែលកាន់តែកើនឡើង,
- ពិនិត្យសមត្ថភាព និងលទ្ធភាពរបស់មន្ត្រីរាជការនៅក្នុងអង្គភាព,

## សំរេច

ប្រការមួយ . គណៈកម្មការទស្សនាវដ្តីកម្ពុជសុរិយា ដែលតែងតាំងដោយសេចក្តីសំរេច

លេខ ១០/៩៤ កធស.ពប ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ ១៩៩៣ របស់ក្រសួង

ធម្មការ និងសាសនា ត្រូវទុកជាធរមានដដែល ។

ប្រការ ២ . ឯកឧត្តម យី ធន់ បច្ចុប្បន្នទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា ត្រូវចាត់

អោយទទួលបំពេញការងារបន្ថែមខាងផ្នែកដឹកនាំការស្រាវជ្រាវនៃក្រុមជំនុំទំនៀម

ទម្លាប់ខ្មែរ, ការប្រមូលចងក្រងឯកសារ និងការងារគ្រប់គ្រង

បណ្ណាល័យនៅពុទ្ធសាសនបណ្ឌិត្យ ។

ប្រការ ៣ . សេចក្តីសំរេចនេះ មានប្រសិទ្ធភាពបន្តអនុវត្ត និងអនុវត្តចាប់ពីថ្ងៃចុះហត្ថ-

លេខានេះតទៅ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៩៥

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា : ហៀង វណ្ណរ័ត្ន

ចម្លងជូន :

- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- គ្រប់នាយកដ្ឋានក្រោមឱវាទ

« ដើម្បីជ្រាបជាពតិមាន »

- ដូចក្នុងប្រការ ២ « ដើម្បីអនុវត្ត »
- ឯកសារ និងកាលប្បវត្តិ

# ចីវររបស់ព្រះសង្ឃ

ព្រះពុទ្ធទ្រង់អនុញ្ញាតបច្ច័យ គឺគ្រឿងសម្រាប់អាស្រ័យរបស់ភិក្ខុសង្ឃក្នុងសាសនមណ្ឌល មាន ៤ យ៉ាង ហៅថា ចតុប្បច្ច័យ គឺ *ចីវរប្បច្ច័យ* គ្រឿងស្លៀកដណ្តប់ ១ *បិណ្ឌបាតប្បច្ច័យ* គ្រឿងអាហារ ១ *សេនាសនប្បច្ច័យ* ទីអាស្រ័យនៅ ១ *គិលានភេសជ្ជប្បច្ច័យ* ថ្នាំព្យាបាលរោគ ១ ។ បច្ច័យទាំង ៤ នេះ ជាតម្រូវការចាំបាច់ក្នុងជីវភាពរស់នៅរបស់មនុស្សទូទៅ ក៏ដូចជារបស់ភិក្ខុសង្ឃដែរ ។

ក្នុងទីនេះ យើងសូមលើកយកតែគ្រឿងស្លៀកដណ្តប់គឺ ចីវររបស់ភិក្ខុសង្ឃមកនិយាយ តើវាមានការវិវត្តន៍យ៉ាងណាខ្លះ ?

## I. សំពត់សំរាប់ធ្វើចីវរ

កាលព្រះសម្ពុទ្ធទើបបានត្រាស់ដឹងថ្មីៗ ទ្រង់អនុញ្ញាតអោយភិក្ខុសង្ឃប្រើប្រាស់តែសំពត់ឥតម្ចាស់ គឺសំពត់បង្សុកូល ដែលខ្លួនរកបានមកពីព្រៃស្មសាន ឬ គំនរសម្រាមយកមកប៉ះប៉ុនធ្វើជាចីវរស្លៀកដណ្តប់ ។ ប៉ុន្តែ ក្រោយមក ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតអោយភិក្ខុអាចប្រើប្រាស់សំពត់មានម្ចាស់ គឺគហបតិចីវរ យកមកកាត់ដេរស្លៀកដណ្តប់ ក៏បានផងដែរ ដូចមានពុទ្ធានុញ្ញាតថា [(១)] *«អនុជានាមិ ភិក្ខវេ គហបតិចីវរំ សាទិយន្តេន បំសុកូលំបិ សាទិតុំ តទុភយេន ចាហំ ភិក្ខវេ សន្តុដ្ឋឹ វណ្ណេមិ »* ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតអោយភិក្ខុដែលត្រេកអរ

(១) ព្រះវិន័យបិដក ភាគទី ៨ ទំព័រ ១០១

នឹងគហបតិចីវរ ហើយត្រេកអរនឹងសំពត់បង្សុកូលផងក៏បាន, ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត តថាគតសរសើរសេចក្តីសន្តោសរបស់ភិក្ខុ ដោយចីវរទាំងពីរយ៉ាងនោះ ( តាមមាន តាមបាន ) ។

សំពត់ទាំងពីរបែប ដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតអោយយកមកធ្វើជាចីវរបាននោះ ត្រូវតែជាសំពត់ដែលផលិតឡើងអំពីវត្ថុ ៦ យ៉ាង គឺ សំពត់ដែលធ្វើដោយសំបកឈើ ១ សំពត់ដែលធ្វើដោយកប្បាស ១ សំពត់ដែលធ្វើដោយសូត្រ ១ សំពត់ដែលធ្វើដោយរោមសត្វ ( វៀរលែងតែសក់ ឬរោមមនុស្សចេញ ) ១ សំពត់ដែលធ្វើដោយសំបកធ្មៃ ១ សំពត់ដែលធ្វើលាយដោយវត្ថុ ៥ យ៉ាង ខាងដើម ១ ។

តើមានមូលហេតុដូចម្តេច បានជាព្រះសម្ពុទ្ធទ្រង់បន្ធូរបន្ថយដល់ពួកភិក្ខុក្នុងសាសនារបស់ព្រះអង្គ អោយអាចប្រើប្រាស់គហបតិចីវរបានរហូតមកដល់សព្វថ្ងៃ ? ឯនិទានសង្ខេបស្តីពីមូលហេតុនេះ មានដូចតទៅ :

សម័យនោះ ព្រះមានព្រះភាគ គង់នៅវត្តវេឡុវ័ន ទៀបក្រុងរាជគ្រឹះ ។ កាលនោះឯង ក្រុងវេសាលី ជាទីស្ថានស្តុកស្តម្ភមូលាយ, មានជនច្រើនមីរដេរដាស, បរិបូណ៌ដោយចំណីអាហារ, មានប្រាសាទ ៧ពាន់ ៧រយ ៧ប្រាសាទ, មានផ្ទះកំពូល ៧ពាន់ ៧រយ ៧ផ្ទះ, មានសួនច្បារ ៧ពាន់ ៧រយ ៧សួនច្បារ, មានស្រះបោក្ខរណី ៧ពាន់ ៧រយ ៧ស្រះ និងមានស្រីផ្កាមាស (ស្រីពេស្យា) ម្នាក់ឈ្មោះនាង «អម្ពបាលី» មានរូបល្អគួរជាទីពិតពិលរមិលមើល ជាទីនាំអោយកើតសេចក្តីជ្រះថ្លា ប្រកបដោយសម្បុរល្អ និងជាទីគាប់ចិត្តរបស់អ្នកផងពន់ពេក ហើយជាស្រីប្រសប់ក្នុងល្បែងរាំ-ច្រៀង-ដេញដំប្រគំ ជាស្រីដែលពួកមនុស្សត្រូវការទាំងប៉ុន្មាន តែងចូលទៅរកច្រើន, បើជនណាត្រូវការយកនាងទៅលេងសើចសប្បាយក្នុងមួយយប់ត្រូវអោយថ្លៃ ៥០ កហាបណៈដល់នាង ។ ឯក្រុងវេសាលីសោត ក៏សឹង(រកប្រាក់ចំណូលបានច្រើន) ថ្កុំថ្កើងលើសលប់ពន់ប្រមាណ ព្រោះនាងអម្ពបាលីនោះ ។

និយាយពីពួកកុដុម្ពិក៍នៅក្រុងរាជគ្រឹះ ថ្ងៃមួយបានមកធ្វើទស្សនកិច្ចនៅក្រុងវេសាលី ក៏បានឃើញការរីកចំរើន និងនាងអម្ពបាលីនោះផ្ទាល់ ។ លុះពេលត្រឡប់ទៅដល់ក្រុងរាជគ្រឹះវិញ ក៏នាំព្រឹត្តិការណ៍នេះចូលទៅក្រាបទូលព្រះបាទពិម្ពិសារ ព្រះចៅក្រុងរាជគ្រឹះ តាមការពិនិត្យជាក់ស្តែង ។ ព្រះរាជាទ្រង់ត្រាស់តបថា នែនាយ បើដូច្នោះ អ្នកទាំងឡាយចូរជ្រើសរើសនាងកុមារីណាដែលមានរូបល្អប្រហែលនាងអម្ពបាលីនោះ តាំងអោយជាស្រីផ្កាមាសឡើង ។ គ្រានោះ ពួកកុដុម្ពិក៍ក៏ជ្រើសរើសបាននាងកុមារីម្នាក់ឈ្មោះ «សាលវតី» ដែលមានលក្ខណសម្បត្តិស្មើនាងអម្ពបាលីនោះដែរ ហើយតាំងអោយជាស្រីផ្កាមាសប្រចាំក្រុងរាជគ្រឹះតទៅ, នាងនេះ បើជនណាត្រូវការសប្បាយលេងសើចក្នុងមួយយប់ ត្រូវបង់ថ្លៃឈ្នួល ១០០ កហាបណៈ (ថ្លៃលើសនាងអម្ពបាលីទៅទៀត) ។

គួរអោយអភ័ព្វណាស់ ! មិនយូរប៉ុន្មាន នាងសាលវតីក្នុងពេលដែលកំពុងតែរកស៊ីបាន កំពុងតែត្រូវបានទទួលការនិយមពីអ្នកផង នាងស្រាប់តែមានផ្ទៃពោះឡើងក្នុងពេលនោះដែរ ។ វេលានោះ នាងគិតថា ធម្មតាស្រី តែមានគភ៌ហើយ រមែងមិនជាទីគាប់ចិត្តរបស់ពួកបុរសឡើយ, ប្រសិនបើបុរសណាមួយ នឹងដឹងថាអាត្មាអញមានគភ៌ ពេលនោះ លាភសក្ការៈ (មុខរបរ) របស់អញ ប្រាកដជានឹងសាបសូន្យ (រកស៊ីលែងបាន) ។ លុះគិតបែបនេះហើយ នាងក៏បានបង្គាប់នាយទ្វារថា «នែនាយទ្វារ កុំអោយបុរសណាមួយចូលមកឡើយ ទោះជានរណាសួររកខ្ញុំក៏ដោយ, ក៏ត្រូវប្រាប់ថា «នាងសាលវតីមានជំងឺហើយ » ។ ចាប់ពីពេលនោះមក នាងសំងំនៅតែក្នុងបន្ទប់ រហូតដល់គភ៌នោះចាស់ ហើយក៏សម្រាលកូនប្រុសមួយមក ។ នាងក៏បង្គាប់អោយខ្ញុំស្រីយកទារកនោះដាក់ក្នុងចង្អេរចាស់ យកទៅចោលលើគំនរសម្រាម ។

គាប់ជួនពេលព្រឹកនោះ ព្រះរាជកុមារមួយអង្គ ព្រះនាម « អភ័យ »

បានយាងទៅក្បែរ ហើយទតឃើញទារកដែលពួកសត្វក្អែក កំពុងចោមរោមលើគំនរសម្រាមនោះ ក៏បង្គាប់អោយគេនាំយកទៅអោយមេដោះចិញ្ចឹមនៅក្នុងវាំង ហើយដាក់ឈ្មោះថា « ជីវកៈ » ព្រោះទារកនេះ មិនទំនងរស់សោះ ហើយបែរជារស់ទៅកើត ។ លុះក្រោយមក ក៏ដាក់ឈ្មោះមួយទៀតថា «កោមារភត្យ» ព្រោះជាកុមារដែលរើសយកមកចិញ្ចឹម ។

ពេលធំដឹងក្តី ជីវកកោមារភត្យ ទូលសួរបិតាចិញ្ចឹមថា បពិត្រព្រះសម្មតិ-ទេព អ្នកណាជាមាតាបិតារបស់ខ្ញុំ ? អភយរាជកុមារតបថា យើងមិនស្គាល់មាតាបិតាបង្កើតអ្នកឯងទេ ប៉ុន្តែយើងទុកដូចជាបិតារបស់អ្នកហើយ ព្រោះយើងបានរើសអ្នកមកចិញ្ចឹម ។ ជីវកកោមារភត្យ គិតថា «ពួករាជត្រកូលនេះ តែបុគ្គលណាគ្មានសិល្បសាស្ត្រហើយ មិនងាយនឹងចិញ្ចឹមជីវិតបានទេ, បើដូច្នេះមានតែអាត្មាអញរករៀនសិល្បសាស្ត្រអោយបាន ។ លុះគិតយ៉ាងនេះហើយ កុមារក៏លួចរត់ភៀសខ្លួនចេញទៅកាន់ក្រុងតក្កសិលា ដើម្បីរៀនវិជ្ជាពេទ្យក្នុងសំណាក់អាចារ្យទិសា-បាមោក្ខ ។ កាលបើបានរៀនចេះចប់វិជ្ជានេះក្នុងរយៈពេល ៧ ឆ្នាំហើយ ក៏សុំលាអាចារ្យត្រឡប់វិលទៅក្រុងរាជគ្រឹះវិញ ។

ចាប់ពីពេលនោះមក ជីវកកោមារភត្យបានព្យាបាលជំងឺសេដ្ឋី គហបតីរហូតដល់បានជាសះស្បើយជាបន្តបន្ទាប់ ហើយក្លាយខ្លួនជាគ្រូពេទ្យក្មេង មានទេព-កោសល្យខ្ពស់ ។ គ្រូពេទ្យជីវកកោមារភត្យ បានរស់នៅក្នុងភាពជាអ្នកថ្លៃថ្នូរ មានកិត្តិយស និងកិត្តិស័ព្ទល្បីរន្ទឺ ហើយនិងមានភោគទ្រព្យស្តុកស្តម្ភ ដោយសារចំណេះវិជ្ជាដ៏ខ្ពង់ខ្ពស់របស់ខ្លួន ។ សម័យមួយ ព្រះមានព្រះភាគទ្រង់មានអាពាធទល់លាមក។ ព្រះបាទពិម្ពិសារ ទ្រង់បញ្ជាអោយគ្រូពេទ្យជីវកកោមារភត្យនេះទៅព្យាបាលរោគព្រះសម្ពុទ្ធ ។ គ្រូពេទ្យនេះ ក៏បានខិតខំព្យាបាលព្រះរោគរបស់ព្រះសាស្តា រហូតដល់បានជាសះស្បើយជាស្ថាពរ ។

ខណៈនោះ ជីវកកោមារភច្ច បាននាំយកសំពត់សិវេយ្យកៈ (១) មួយគូ ចូលទៅគាល់ព្រះមានព្រះភាគ ដោយក្រាបទូលថា « សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គសូមពរមួយចំពោះព្រះអង្គ » ។ ព្រះមានព្រះភាគត្រាស់ថា « នៃជីវកៈ ព្រះតថាគតទាំងឡាយមានពរកន្លងហើយ » ។ ជីវកៈទូលថា « សូមទ្រង់ព្រះមេត្តាប្រោស អំពើណាគួរផង មិនមានទោសផង ខ្ញុំព្រះអង្គសូមចំពោះអំពើនោះ » ។ ព្រះសាស្តាត្រាស់ថា «នៃជីវកៈ ចូរអ្នកនិយាយមកចុះ » ។ ជីវកកោមារភច្ច ទូលថា សូមទ្រង់ព្រះមេត្តាប្រោស ព្រះមានព្រះភាគក្តី ភិក្ខុសង្ឃក្តី តែងតែទ្រទ្រង់សំពត់បង្សុកូល, សូមទ្រង់ព្រះមេត្តាប្រោស សំពត់សិវេយ្យកៈមួយគូនេះហើយ ដែលព្រះបាទបជ្ជោតបញ្ជូនមកអោយខ្ញុំព្រះអង្គ ជាសំពត់ល្អលើសលប់, សូមព្រះអង្គមេត្តាទទួលយកសំពត់នេះរបស់ខ្ញុំព្រះអង្គផង សូមទ្រង់អនុញ្ញាតគហបតិចីវរដល់ភិក្ខុសង្ឃផង ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ទទួលយកនូវសំពត់សិវេយ្យកៈមួយគូនោះ ។ ដោយមានសំណូមបែបនេះ ទើបព្រះសម្ពុទ្ធទ្រង់អនុញ្ញាតថា *អនុជានាមិ ភិក្ខវេ គហបតិចីវរំ យោ ឥច្ឆតិ បំសុកូលិកោ ហោតុ យោ ឥច្ឆតិ គហបតិចីវរំ សាទិយតុ*

(១) តាមអដ្ឋកថា បញ្ជាក់ថា « សំពត់សិវេយ្យកៈ » នេះ បានដល់សំពត់ដែលគេចោលនៅព្រៃខ្មោច ក្នុងឧត្តរកុរុទ្វីប ។ បានឮមកថា ពួកមនុស្សក្នុងឧត្តរកុរុទ្វីបតែងរុំសាកសពដោយសំពត់នោះឯង ហើយយកទៅចោល ។ មានសត្វបក្សីមានប្រមោយដូចដំរី វាសំគាល់នូវសំពត់នោះថាជាដុំសាច់ ហើយឆាបយកទៅតម្កល់ទុកលើកំពូលភ្នំហិមពាន្ត រួចបកសំពត់នោះចោលចេញ វាស៊ីតែសាច់សាកសពនោះ ។ វេលានោះ ពួកថ្មើរព្រៃ បានឃើញសំពត់នោះហើយក៏នាំយកមកថ្វាយស្តេច ( ព្រោះមិនហ៊ានប្រើខ្លួនឯង ដោយសំពត់នោះល្អពេក មិនដែលមានក្នុងលោកនេះទេ ) ។ សំពត់នោះហើយដែលព្រះបាទបជ្ជោត បានជូនជារង្វាន់ដល់ជីវក-កោមារភច្ច បន្ទាប់ពីពេលដែលគ្រូពេទ្យរូបនេះ បានព្យាបាលជំងឺឿងរបស់ព្រះអង្គ បានជាសះស្បើយមក ។

*ឥតរិតវេន ចាហំ ភិក្ខវេ សន្តុដ្ឋឹ វណ្ណេមិ :* ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត នូវគហបតិចីវរ ភិក្ខុណាប្រាថ្នានូវសំពត់បង្សុកូល ភិក្ខុនោះចូរទ្រទ្រង់សំពត់បង្សុកូល ចុះ, ភិក្ខុណាប្រាថ្នាគហបតិចីវរ ភិក្ខុនោះចូរត្រេកអរនឹងគហបតិចីវរចុះ, ម្នាលភិក្ខុ ទាំងឡាយ ម្យ៉ាងទៀត តថាគតពោលសរសើរសេចក្តីសន្តោសដោយបច្ច័យណា មួយ ( តាមមាន តាមបាន ) ។

ពួកមនុស្សទាំងឡាយ ទាំងនៅទីក្រុង ទាំងនៅជនបទ បានដឹងថាព្រះមាន ព្រះភាគទ្រង់អនុញ្ញាតគហបតិចីវរដល់ភិក្ខុទាំងឡាយហើយ ក៏មានចិត្តរីករាយស្រស់ ស្រាយឡើងថា យើងមុខជានឹងបានអោយទាន មុខជានឹងបានធ្វើចីវរទាន ពុំខាន ។ ចាប់ពីពេលនោះមក ចីវរច្រើនពាន់កើតមានដល់ភិក្ខុសង្ឃតែក្នុងមួយថ្ងៃក៏មាន ដោយសារទាយកទាយិកា នាំយកមកប្រគេន ។

## II. របៀបធ្វើចីវរ

ដំបូងឡើយ ភិក្ខុសង្ឃក្នុងពុទ្ធសាសនា កាលណារកបានសំពត់បង្សុកូល ក្តី សំពត់គហបតិចីវរក្តី តែងយកមកលៃលកមើល, បើតូចៗពេក ក៏ដេរភ្ជាប់គ្នា អោយល្មមស្លៀកដណ្តប់កើត, បើធំពេកក៏កាត់ហែកចេញខ្លះ ទុកអោយល្មមតែប្រើ ប្រាស់បានស្រួល, តែបើសំពត់នោះល្មមស្រាប់ហើយ ក៏បោកគក់ជ្រលក់ទឹកអម្ចត់ ស្លៀកដណ្តប់តែម្តងទៅជាការស្រេច ។ ដូច្នេះ ការច្នៃប្រឌិត កាត់ដេរ ធ្វើចីវរសំរាប់ ស្លៀកដណ្តប់របស់ភិក្ខុសង្ឃ តាមវិធីបែបនេះ ពុំមានលក្ខណៈឯកភាពគ្នាទូទាំង សាសនាទេ ។ ប៉ុន្តែក្រោយមក ចីវររបស់សង្ឃ បានឈានចូលដល់ឯកភាពមួយ ទូទាំងផ្ទៃពុទ្ធសាសនា ដូចដែលយើងរាល់គ្នាបានឃើញរហូតដល់សព្វថ្ងៃនេះ ។ តើ មានមូលហេតុដូចម្តេចខ្លះ ដែលនាំអោយព្រះសម្ពុទ្ធអនុញ្ញាតការប្រើប្រាស់ចីវរដល់

ភិក្ខុសង្ឃ មានលក្ខណៈជាឯកសណ្ឋានបែបនេះ ? ឯលំនាំសង្ខេបនៃរឿងនោះ មានដូចតទៅ :

គ្រានោះ ព្រះមានព្រះភាគគង់នៅក្រុងរាជគ្រឹះ តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ក៏ទ្រង់យាងចេញទៅកាន់ចារិកក្នុងទក្ខិណាគិរីជនបទ ។ ពេលនោះ ព្រះមានព្រះភាគទ្រង់ទតឃើញស្រែអ្នកដែនមគធៈ មានសណ្ឋានជាស្រែមានជ្រុងបួន មានសណ្ឋានជាស្រែមានភ្លឺវែងដោយបណ្ដោយផង ទទឹងផង មានសណ្ឋានជាស្រែមានភ្លឺខ្លីក្នុងចន្លោះៗ មានសណ្ឋានជាបួនជ្រុង មានភ្លឺខ្លីៗបាញ់រត់គ្នា ។ លុះទ្រង់ទតឃើញហើយ ក៏ត្រាស់ហៅអានន្ទដ៏មានអាយុថា « នែអានន្ទ អ្នកឃើញស្រែអ្នកដែនមគធៈ មានលក្ខណៈ (ល្អ) បែបនេះទេ ? » ព្រះអានន្ទ ក្រាបបង្គំទូលថា « ព្រះករុណាព្រះអង្គ» ។ ព្រះសាស្ដាត្រាស់សួរថា «នែអានន្ទ អ្នកអាចចាត់ចែងចីវរ (ដែលមានលក្ខណៈដូចស្រែអ្នកដែនមគធៈ) បែបនេះដល់ភិក្ខុទាំងឡាយបានឬទេ ? » ព្រះអានន្ទ ក្រាបទូលថា « បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គអាចធ្វើបាន » ។ វេលានោះ ព្រះមានព្រះភាគទ្រង់គង់ក្នុងទក្ខិណាគិរីជនបទគួរដល់ពុទ្ធអធ្យាស្រ័យហើយ ក៏ទ្រង់យាងត្រឡប់មកក្រុងរាជគ្រឹះវិញ ។ ខណៈនោះ ព្រះអានន្ទមានអាយុ ក៏បានចាត់ចែងចីវរដល់ភិក្ខុទាំងឡាយជាច្រើនរូប រួចហើយចូលគាល់ព្រះមានព្រះភាគ ។ លុះចូលទៅដល់ហើយ ក៏ក្រាបទូលព្រះសាស្ដាថា « បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គទ្រង់ទតចីវរដែលខ្ញុំព្រះអង្គបានចាត់ចែងហើយនេះចុះ » ។ ព្រះមានព្រះភាគក៏ទ្រង់ធ្វើធម្មីកថាក្នុងវេលានោះ ត្រាស់ហៅភិក្ខុទាំងឡាយមកថា « ម្នាលភិក្ខុទាំងឡាយ អានន្ទជាបណ្ឌិត មានប្រាជ្ញាច្រើន ព្រោះពាក្យដែលតថាគតពោលហើយដោយសង្ខេប អានន្ទអាចដឹងសេចក្ដីដោយពិស្ដារបាន ហើយចេះធ្វើសំពត់ឈ្មោះ «កុសិ-អឌ្ឍកុសិ-មណ្ឌលៈ-អឌ្ឍមណ្ឌលៈ-វិវដ្ដៈ-អនុវិវដ្ដៈ-គីវេយ្យកៈ-ជង្ឃេយ្យកៈ-ពាហន្តៈ ហើយសំពត់ទាំងនោះ អានន្ទក៏បានកាត់ដាច់អោយសៅហ្មងដោយមុខកាំបិត អោយ

សមគួរដល់សមណៈ អោយជារបស់មិនគួរប្រាថ្នាដល់ពួកចោរជាសត្រូវ, ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសង្ឃាដីកាត់ ចីពរកាត់ ស្បង់កាត់ដល់ភិក្ខុទាំងឡាយ = *អនុជានាមិ ភិក្ខវេ ឆិន្នកំ សង្ឃាដី ឆិន្នកំ ឧត្តរាសង្គំ ឆិន្នកំ អន្តរវាសកំ* ។

ចំពោះសង្ឃាដី ព្រះសម្ពុទ្ធទ្រង់អនុញ្ញាតអោយមានពីរជាន់ ព្រោះសម្រាប់ការពារពេលត្រជាក់ខ្លាំង ដូចមាននិទានដំណាលថា សម័យមួយ ព្រះសាស្តាទ្រង់យាងទៅកាន់ផ្លូវឆ្ងាយ ជាចន្លោះក្រុងរាជគ្រឹះ និងចន្លោះក្រុងវេសាលី ក៏បានទតឃើញភិក្ខុច្រើនរូបទូលចីវរផង លីចីវរផង កណ្ដៀតចីវរផង ដើរមក ។

លុះទតឃើញហើយ ព្រះអង្គទ្រង់ព្រះតម្រិះថា ភិក្ខុទាំងនេះ ល្មោភចីវរណាស់ គួរតថាគតកំណត់ព្រំដែនក្នុងការប្រើប្រាស់ចីវរដល់ភិក្ខុទាំងឡាយទើបបាន ។ ព្រះមានព្រះភាគ ក៏បន្តព្រះដំណើរទៅដល់ក្រុងវេសាលី ហើយទ្រង់គង់នៅក្នុងគោតមចេតិយ ។ សម័យនោះឯង ព្រះអង្គទ្រង់ចីវរតែមួយ (ស្បង់) គង់នៅក្នុងទីវាល ពេលយប់មានទឹកសន្សើមធ្លាក់ចុះនាហេមន្តរដូវ ។ ក្នុងបឋមយាម ព្រះអង្គមិនរងាសោះ, លុះមជ្ឈិមយាមទើបទ្រង់រងា ហើយក៏ទ្រង់ចីវរជាគម្រប់ពីរ (ចីពរ) ទើបបាត់រងា, លុះដល់បច្ឆិមយាម ទើបទ្រង់រងា ហើយព្រះអង្គក៏ទ្រង់ចីវរជាគម្រប់បី ( សង្ឃាដី ១ ជាន់ ) ទើបបាត់រងា, លុះពេលអរុណរះព្រាងៗ ព្រះអង្គក៏រងាទៀត ទើបទ្រង់ចីវរគម្រប់ ៤ (សង្ឃាដី ១ ជាន់ទៀត) ទើបបាត់រងា ។ ព្រះសាស្តាទ្រង់ព្រះតម្រិះថា « គួរតថាគត ក៏រិតព្រំដែនចីវរអោយភិក្ខុក្នុងធម្មវិន័យនេះអោយបានសមស្រប » ។ ដូចមានពុទ្ធានុញ្ញាតថា « *អនុជានាមិ ភិក្ខវេ តិចីវរំ ទ្វិគុណំ សង្ឃាដី ឯកច្ចិយំ ឧត្តរាសង្គំ ឯកច្ចិយំ អន្តរវាសកំ* =ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតចីវរបី (ត្រៃចីវរ) គឺសង្ឃាដី ២ ជាន់ ចីពរ ១ ជាន់ ស្បង់ ១ ជាន់ ដល់ភិក្ខុទាំងឡាយ ។

## III. ពណ៌សំរាប់ជ្រលក់ចីវរ

គ្រាដំបូង ភិក្ខុទាំងឡាយជ្រលក់ចីវរដោយអាចម៍គោខ្លះ ដោយដីស្អិតពណ៌លឿងខ្លះ ។ ចីវរនោះ ក៏មានពណ៌អាក្រក់ពេក ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនេះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គត្រាស់ថា « *អនុជានាមិ ភិក្ខវេ ឆ រជនានិ មូលរជនំ ខន្ធរជនំ តចរជនំ បត្តរជនំ បុប្ផរជនំ ផលរជនំ* =ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកជ្រលក់ ៦ យ៉ាងគឺ ទឹកជ្រលក់កើតពីមើម ១ ទឹកជ្រលក់កើតពីដើម ១ ទឹកជ្រលក់កើតពីសំបក ១ ទឹកជ្រលក់កើតពីស្លឹក ១ ទឹកជ្រលក់កើតពីផ្កា ១ ទឹកជ្រលក់កើតពីផ្លែ ១ ( មានលក្ខណៈដូចដើមខ្នុរជាដើម ) គឺជ្រលក់ជាមួយទឹកក្តៅ ។ ព្រះអង្គទ្រង់ហាមមិនអោយប្រើពណ៌ខ្មៅសុទ្ធ ខៀវសុទ្ធ ក្រហមសុទ្ធ ពណ៌ដូចភ្លុក ... ទោះបីកើតអំពីវត្ថុ ៦ យ៉ាងនោះក៏ដោយ ។

## IV. ចីវរបន្ទាប់បន្សំ

ក្រៅពីត្រៃចីវរទាំងបីនេះ ព្រះសម្ពុទ្ធទ្រង់អនុញ្ញាតចីវរបន្ទាប់បន្សំមួយចំនួនទៀត សំរាប់តម្រូវការប្រើប្រាស់របស់ភិក្ខុដែរ ដូចជា :

- វស្សិកសាដកៈ សំពត់ងូត សំរាប់ស្រង់ទឹក
- និសីទនៈ សំពត់សំរាប់ទ្រាប់អង្គុយ
- អង្សៈ សំពត់សំរាប់ពាក់ឆៀងស្មា ទុកដូចជាអាវទ្រនាប់
- កន្សែងជូតមុខ
- កន្សែងសំរាប់រុំរបួស កម បូស

- វត្តពន្ធចង្កេះ វត្តពន្ធទ្រូង
- តម្រងទឹក

ចំពោះចីវរលើសពីសេចក្តីត្រូវការ ដែលហៅថាអតិរេកចីវរ ( គឺចីវរលើសពីមួយសំរាប់ទៅ ព្រះពុទ្ធទ្រង់អនុញ្ញាតអោយភិក្ខុវិកប្បទុក គឺត្រូវធ្វើជាមួយអ្នកដទៃ ។ បានសេចក្តីថា ភិក្ខុមិនត្រូវល្មោភចីវរលើសពីមួយសម្រាប់ឡើយ ។

រៀបរៀងដោយ

**ម៉ែន ប្រាជ** និង **អាំ ឆន**

ពិនិត្យកែសម្រួលដោយ ឱម ខែម

*ត្រុកៗអ្នកស្រុកមើលងាយ រលាស់គូថខ្លាយ មានឱដ្ឋមានភ័ន្ត*

*ឃើញខ្លាក្រាបកុំថាខ្លាសំពះ ឃើញខ្លាលោតទះ កុំថាខ្លាបន្លែង*

# សូធ្យសូមទាន់ព្រះសមោធាន

( បទកាកគតិ )

ភន្តេ ភគវា នៅនាសាសនា គំរប់ប្រាំពាន់
សូមកងកុសល ជួយផ្តល់ឱ្យទាន់ ព្រះធាតុភគវន្ត
ពេលសមោធាន ។
បានថ្វាយបង្គំ នូវព្រះគោតម ស្តាប់ទេសន៍ទូន្មាន
សវនានិសង្ស បញ្ចង់ឱ្យបាន សំរេចញ្ញេយ្យញាណ
ជាអរិយសាវ័ក ។
បើមានបាបកម្ម សូមបុណ្យឧបត្ថម្ភ រារាំងបង្អាក់
បង្អួសអបាំ ឱ្យខ្លាំងដល់ថ្នាក់ ជាមនុស្ស-ទេវៈ
ធម្មាភិសម័យ ។
បើគ្មានវាសនា ជាអរិយសាវកា សូមមាននិស្ស័យ
ទាន់ព្រះសិរី អារ្យមេត្រី ស្តាប់ធម៌ជិនស្រី
លុះមគ្គផលបោង ។

រៀបរៀងដោយ
**ជឹម ពៅ** គរុនិវត្តជន
នៅភូមិជំទាវ ឃុំច្រែស ស្រុកកំពង់តឡាច
ខេត្តកំពង់ឆ្នាំង

# បណ្ដាំក្រមង៉ុយ

## LES RECOMMANDATIONS DE KRAM NGOY

ឆ្នាំនេះជាខួប ១៣០ ឆ្នាំ នៃកំណើតរបស់កវីអ្នកភិរម្យភាសា អ៊ូ ហៅ ង៉ុយ ។ ក្នុងឱកាសដ៏ប្រពៃនេះ ទស្សនាវដ្ដីកម្ពុជសុរិយា មានកិត្ដិយសចុះផ្សាយស្នាដៃមួយទៀតរបស់អ្នកកវីប្រជាប្រិយដ៏ឆ្នើមរបស់យើងនេះ ដែលមានចំណងជើងថាជាបណ្ដាំក្រមង៉ុយ ។

ពាក្យបណ្ដាំនេះ ប្រជាជនខ្មែរពីស្រុករមុន គឺក្នុងរវាងបណ្ដាឆ្នាំ ៤០ និង ៥០ បានចេះចាំស្ទើរគ្រប់មាត់ ។ រហូតដល់សព្វថ្ងៃ ក៏នៅមានចាស់ទុំខ្លះអាចសូត្រ ឬច្រៀងបណ្ដាំនេះបានយ៉ាងក្បោះក្បាយ ។ ការចុះផ្សាយអត្ថបទបណ្ដាំក្រមង៉ុយនេះមានបំណងម្យ៉ាងទៀត គឺចង់ជម្រាបប្រជារាស្ត្រខ្មែរអោយបានដឹងអំពីប្រវត្តិសាស្ត្រសង្គមសម័យដើមផង និងមានបំណងរក្សាទុកស្នាដៃអក្សរសិល្ប៍ដ៏កម្រមាននេះអោយកូនចៅខ្មែរជំនាន់ក្រោយបានសិក្សារៀនសូត្រផង ។

ខាងក្រោមនេះ គឺអត្ថបទបណ្ដាំក្រមង៉ុយទាំងស្រុង ដែលមាន ៩១ ល្បះ ត្រូវជា ២០០២ ពាក្យ ។

១. នេះបទព្រហ្មប្រាជ្ញប្រែ ប្រាយប្រាប់ខ្មែរទាំងប្រុសស្រី
ឱយប្រិតប្រុងស្មារតី គួរគប្បីឱយឧស្សាហ៍ ។
២. កុំខ្ជិលកុំល្ងង់ពេក ខំរៀនលេខរៀនអក្ខរា
រៀនគ្រប់សព្វធម៌អាថ៌ ប្រាជ្ញាផ្សំនឹងគំនិត ។

៣. កំណើតកើតជាមនុស្ស មើលឱ្យធ្លុះទោះឆ្ងាយជិត
ចេះស្ទាត់ប្រាកដពិត គិតការអ្វីបានគ្រប់យ៉ាង ។
៤. មនុស្សល្ងង់មិនផ្ចើលភ្ញាក់ ដូចភ្នែកខ្វាក់ទាំងសងខាង
មានរូបគ្មានអ្វីអាង សាងទាបថោកកើតមកខ្លៅ ។
៥. ពូជមនុស្សទោះខ្ពស់ទាប កាត់តាមភាពត្រកូលផៅ
អាក្រក់ល្អសខ្មៅ កាត់កូនចៅដូចដូនតា ។
៦. ពូជល្ងង់មិនបានបួស ទុកជាទោសនឹងសាសនា
អ្នកបួសចេះធម៌អាថ៌ កូនសិក្សាខំរៀនសូត្រ ។
៧. ពូជខ្លៅមិនសូវប្រាជ្ញ ពូជកោងកាចមិនសូវស្លូត
ពូជត្រង់១រហូត ពូជភរភូតមិនផុតផៅ ។
៨. ឪពុកម្តាយស្លូតត្រង់ ចិត្តមិនចង់ឱ្យកូនខ្លៅ
ជេរវាយស្តីប្រដៅ ឱ្យកូនចៅបានចេះដឹង ។
៩. ឪពុកគ្មានតិរិះ ឃើញកូនចេះមិនដែលខឹង
ឃើញកូនខំប្រិតប្រឹង ឪពុកដឹងតែងត្រេកអរ ។
១០. ដាស់តឿនគ្រើនរំលឹក ជេរល្ងាចព្រឹកខ្លាចកូនក្រ
ចង់ឱ្យតែកូនល្អ លោមអង្វរឱ្យកូនខំ ។
១១. កូនកាចបំពេញទុក្ខ ម្តាយឪពុកមានបារម្ភ
កូនស្លូតដឹងគួរសម មេបាថ្កុំថ្កើងកេរ្តិ៍ឈ្មោះ ។
១២. ឪពុកម្តាយខ្សត់ខ្សោយ កុំបណ្តោយឱ្យអាប់យស
ខំរៀនឱ្យបានខ្ពស់ គ្រាន់សង្គ្រោះដល់មេបា ។
១៣. អ្នកល្ងង់ហេតុពីខ្ជិល ឥតមន្ទិលរៀនធម៌អាថ៌
គួរកូនចៅសិក្សា រៀនអក្ខរាទាំងប្រុសស្រី ។

១៤. កាលអង្គព្រះសាស្ដា មានថេរាមានថេរី
ភិក្ខុភិក្ខុនី ធម៌បាលីចេះចាំស្ទាត់ ។
១៥. លោកសង្ឃខ្លះចេះស្ទើរ ចេះភ្លើៗធ្វើឱយភ្លាត់
ព្រះអង្គទ្រង់សន្មត សិក្ខាបទដល់ឥឡូវ ។
១៦. ទំលាប់ទំនៀមខ្មែរ ខំធ្វើស្រែចង់បានស្រូវ
អ្នករៀនច្បាប់ខុសត្រូវ ទុកជាផ្លូវភ្លឺប្រាជ្ញា ។
១៧. ស្រុកសៀមលាវបារាំង ចេះតតាំងពីដូនតា
ចេះលេខចេះអក្ខរា សរសេរចារទាំងប្រុសស្រី
១៨. ជាតិខ្មែរមិនចេះខ្មាស នាំពីចាស់គំនិតខ្លី
ល្ងង់ដប់ចេះពីរបី ចេះជួញក្ដីមិនចេះច្បាប់ ។
១៩. មិនចេះលេខអក្សរ មុខមាត់ល្អប្រាជ្ញារាប
ឈ្មោះខ្លួនភ្នែកខ្លួនស្រាប់ គេស្ញូត្រប្រាប់ទើបបានដឹង ។
២០. ភ្នែកជាភ្លឺក្រឡៀត ល្ងង់ព្រោះហេតុមិនខំប្រឹង
កើតទាស់មានចិត្តខឹង ពឹងរកគេសរសេរឱយ ។
២១. មនុស្សក្រហេតុពីខ្ជិល មិនរមិលមើលមុខក្រោយ
ម្យ៉ាងខ្សត់ពីព្រោះខ្សោយ ញឹកខាងឱយរង្វើលរក ។
២២. ម្យ៉ាងក្រពីព្រោះល្ងង់ ជួញលិចលង់មិនលៃលក
ទិញថ្លៃទៅលក់ថោក ចេះតែយកមិនគិតយល់ ។
២៣. អ្នកមាន១គំនិត ដេកដើរគិតកើតរវល់
ប្រាជ្ញាជាឫសគល់ កើតអំពល់អំពីទ្រព្យ ។
២៤. អ្នកល្ងង់នឹងអ្នកចេះ បើនឹងរិះរាយរៀបរាប់
អ្នកចេះប្រសើរគាប់ ល្ងង់ឥតភ័ព្វអាប់រាសី ។

២៥. មានរូបមានជីវិត មិនចេះគិតចង់ដឹងអ្វី
រូបប្រុសឬកដូចស្រី នឹងប៉ានស្តីគ្មានគេស្តាប់ ។
២៦. ល្ងង់ម្យ៉ាងមានអំណាច ល្ងង់កោងកាចរអួតចាក់កាប់
ឆាប់ខឹងមិនដឹងច្បាប់ កាលណាស្លាប់គេត្រេកអរ ។
២៧. អ្នកចេះតិរិះដល់ អ្នកល្ងង់ឆ្ងល់មិនសល់ក្រ
ចេះល្អិតចិត្តជាល្អ ស្ងួយអាករចូលមិនខ្វះ ។
២៨. ចេះម្យ៉ាងមានអំណាច អ្នកខ្លៅខ្លាចឱនសំពះ
គេខុសជេរដៀលត្មះ អ្នកខ្លៅខ្លះគេលបខឹង ។
២៩. ប្រាជ្ញម្យ៉ាងចេះសព្វសុស ប្រព្រឹត្តខុសនោះមិនដឹង
មិនគិតពិនិត្យថ្លឹង ប្រាជ្ញប្រិតប្រឹងប្រដៅគេ ។
៣០. កូនចៅទោះធំតូច ខុសខិលខូចខឹងវាយជេរ
មារយាទខ្លួនខុសគេ មិនគ្មាន់គ្មេរកិរិយាឯង ។
៣១. កូនចៅទាំងស្រីប្រុស ការត្រូវខុសគួរគិតក្រែង
គិតគ្រប់សព្វកន្លែង តែងនឹងមានរាល់រូបកាយ ។
៣២. ភ្នែកបើកភ្លឺមែនពិត មើលឃើញជិត១វៀងអាយ
ភ្នែកធ្មេចមើលឃើញឆ្ងាយ សព្វសុសសាយមិនសេសសល់ ។
៣៣. រៀនរកស៊ីលក់ទិញ ខាតចំណេញគិតឱយដល់
ឱយដឹងការកិច្ចកល ទើបកើតផលប្រយោជន៍ខ្លួន ។
៣៤. ឱយរៀនលេខនព្វន្ត បូកហាគុណឱយមាំមួន
ដីសនឹងក្តារឆ្នួន ក្រែងចិនយួនបំបាត់បាន ។
៣៥. ជញ្ជីងភ្នែកមានល្បាក់ មើលឱយជាក់កុំប្រមាណ
ក្រែងខុសខាតមិនខាន ធ្លាប់រាប់អានកុំទុកចិត្ត ។

៣៦. ភ្នែកមនុស្សធំរលីង ភ្នែកជញ្ជីញគេចុចល្មិត
អ្នកល្អថ្លឹងប្រឹងប្រិត ព្រោះអាណិតខ្មែរល្ងង់ខ្លៅ ។
៣៧. ចិនមានពីដួរលក់ ស្រូវកន្ទក់កន្ទាំងតៅ
របស់ទោះឆ្អិនឆៅ សំពត់អាវខោខ្មៅស ។
៣៨. ខ្មែរអាងស្រូវក្នុងដោក ដួរថ្លៃថោកអាក្រក់ល្អ
អស់ស្រូវទៅជាក្រ អង្វរចិនជឿស្រូវឯង ។
៣៩. ធ្វើស្រែនឿយហត់ណាស់ ចិននៅផ្ទះដេកចំខែង
ផ្ទះចិនពីរបីល្វែង មានកន្លែងជង្រុកស្រូវ ។
៤០. ជាតិខ្មែរឥតគំនិត ស៊ីមិនគិតមើលខុសត្រូវ
ជឿចិនរាល់រដូវ កេរ្តិ៍(*) ម៉ែឪចិនអូសអស់ ។
៤១. ចិនមកពីស្រុកនាយ មានសំពាយជារបស់
មិនទាន់ចេះខ្មែរសោះ គ្មានកេរ្តិ៍(*) កោះស្រែចំការ ។
៤២. កវែកចង្ក្រានឆ្នាំង ផ្សំកំលាំងនឹងប្រាជ្ញា
អម្រែកជិះលើស្មា មានមូស្លាជាដើមទុន ។
៤៣. ទំនិញមានគ្រប់មុខ ផ្ទាល់ផ្ទេរទុកដាក់ដោយធុន
ចិនរើកមិនដែលពុន ស្រូវជោរជន់ពេញជង្រុក ។
៤៤. ឈប់រែកដេកអង្គុយ រាប់កាក់លុយប្រមូលទុក
ឪចិនស្រាពីមុខ ទុកជាផ្ទាក់ទាក់កខ្មែរ ។
៤៥. ចិនច្រើនខ្លាំងចិត្តខ្មៅ កន្ទាំងតៅធ្វើជាស្រែ
គ្មានត្បាល់គ្មានអង្រែ អង្ករខ្មែរចូលបាវចិន ។

(*) កេរ

៤៦. ជាតិខ្មែរច្រើនឥតខ្មាស | ស្រេកស្រាណាស់ផឹកជឿសិន
គំនិតគិតមិនឆ្អិន | ផឹកបង្ហិនតែទ្រព្យឯង ។
៤៧. កំណើតអ្នកផឹកស្រា | បែកប្រាជ្ញាច្រើនកន្លែង
អ្នកម្យ៉ាងបែកខាងល្បែង | មិនគិតក្រែងខ្លាចខ្លួនក្រ ។
៤៨. អាម្យ៉ាងបែកល្ងចឆក់ | មារយាទអាក្រក់មិនបានល្អ
ផឹកចោលការរបរ | ចិនទាក់កធ្វើខ្ញុំបាន ។
៤៩. មិនដឹងខ្លួនជាឆ្កួត | និយាយអួតប្រាប់សន្ដាន
ថាចិនធ្លាប់រាប់អាន | ផឹកថ្មើម៉ានចិនមិនគិត ។
៥០. ថាចិនមិនចេះកាញ់ | ប្រាប់សំឡាញ់ពួកម៉ាកមិត្ត
គួកនទោះឆ្ងាយជិត | រឹតប្រមូលលុយឱយចិន ។
៥១. ត្រូវស្រាចង់ស៊ីឆ្ងាញ់ | ធុំឆាខ្លាញ់បក់ឆ្ងលក្លិន
ឃើញបាយសម្លឆ្អិន | ផ្ដាប់ចិត្តចិនយកបាយស៊ី ។
៥២. ផឹកទឹកបោយត្រឡោក | មារយាទទាបថោកឫកសៀវធី
ចិនប្រើសែងរែកឈើ | ស៊ីញយ។ចិនមើលងាយ ។
៥៣. ជាតិចិនកំណាញ់ស្វិត | នឹកក្នុងចិត្តមិននិយាយ
មារយាទខ្មែរច្រើនរាយមាយ | រលាយទ្រព្យអភ័ព្វខ្លួន ។
៥៤. ស៊ីឆ្ងាញ់ឆ្អែតស្កប់ស្កល់ | ទាបថោកដល់ប្រពន្ធកូន
អាប់យសទាំងបងប្អូន | ដល់តាដូនពូជពង្សខ្មែរ ។
៥៥. ជាតិចិនសុទ្ធសឹងស | មានចំលក្រខ្សត់ខ្លះដែរ
ស៊ីផឹកស្និទ្ធតាមសៃ | តមបាយខ្មែរមិនស៊ីសោះ ។
៥៦. មានផ្ទះមានដំណាំ | កាប់ដីដាំដោយក្បៀនកោះ
ដំឡូងត្រាវចេកម្នាស់ | ស៊ីមិនអស់ទុកលក់ដូរ ។

| | |
|---|---|
| ៥៧. ខ្មែរច្រើនខ្ជិលប្រមឹក | កែងកោងឫកអួតអំប្ញូរ |
| ខ្វះលុយអង្គុយថ្ងូរ | កើបបង្ហូរស្រូវជង្រុក ។ |
| ៥៨. កូនអើយរឿងដីណាំ | គួរតែដាំឱយគ្រប់មុខ |
| ដីកេរ្តិ៍(*) ម្តាយឪពុក | មិនត្រូវទុកចោលទំនេរ ។ |
| ៥៩. រាជការវាស់មានថ្លៃ | ផ្ចិតមេដៃផ្ដាច់ជាកេរ្តិ៍(*) |
| មិនវាស់លេងទទេ | រើះយកពន្ធរាល់ឆ្នាំ ។ |
| ៦០. ដូងស្វាយអំពៅចេក | កុំខ្ជិលពេកដេកប្រចាំ |
| ម្លូស្លាម្រេចខ្ទឹមថ្នាំ | ត្រូវតែដាំកុំឱយខ្វះ ។ |
| ៦១. ទេសឯកសំពត់ស | ដីវាលល្អដាំកប្បាស |
| កុំខ្ជិល តាមចាស់ៗ | មនុស្សនៀយណាស់មិនដែលក្រ ។ |
| ៦២. បន្លែដាំគ្រប់មុខ | យកគ្រាប់ទុកដាំបន្ត |
| ចាក់ដីជាតិល្អៗ | បង្ការស្លពេលល្ងាចព្រឹក ។ |
| ៦៣. ម្លូស្លាថ្នាំខ្ទឹមម្រេច | ល្វតលាស់លេចពីស្រោចទឹក |
| បានផលថ្លៃឬស្លឹក | កុំឆ្មើងឫកវាក្រខ្លួន ។ |
| ៦៤. ត្រីងៀតផ្អកប្រហុក | ខ្មែរគ្រប់ស្រុកទិញដូរយួន |
| អំបិលធូបក្រមួន | ពីតាដូនតែងដូរទិញ ។ |
| ៦៥. ដូរទុកដាក់ដីកល់ | ស៊ីឱយដល់ខួបខែវិញ |
| ឱយបរិបូណ៌ពោរពេញ | ខាតចំណេញកុំទិញតិច ។ |
| ៦៦. អំបិលទិញមួយចុង | ច្រកពេញអុងអាងខាងលិច |
| កុំទិញក្តោបខ្ចប់វេច | អស់រំពេចគេចទិញទៀត ។ |

(*) កេរ

៦៧. អំបិលមួយស្រូវបី វាល់នឹងល្អីទូលកណ្ដៀត
ខ្លួនក្រព្រដរឆ្អៀត មារយាទយ៉ាងហ្នឹងកុំប្រព្រឹត្ត ។

៦៨. កូនចៅទាំងប្រុសស្រី គួរគប្បីប្រុងគំនិត
ចិញ្ចឹមជន្មជីវិត គិតឱយវែងកុំគិតខ្លី ។

៦៩. ទំនេរល្ហែធ្វើការ ស្ងួត្រធមិនអាថិទាំងប្រុសស្រី
ឱយត្រឹមត្រូវបាលី ដូចស្រដីខាងដើមស្រាប់ ។

៧០. វាល់រូបទាំងប្រុសស្រី កាលចេះស្ដីព្រោះចេះស្ដាប់
ម៉ែឪតម្រូវប្រាប់ កូនចៅត្រាប់តាមដូនតា ។

៧១. ចាស់ម្យ៉ាងសាងសីលទាន មិនបំពានខុសពុទ្ធដីកា
កូនកាត់តាមមេបា មិនទៅណាឆ្ងាយពីផ្លូវ ។

៧២. ចាស់ម្យ៉ាងសាងផលកម្ម ស្អប់សីលប្រាំដូចសត្រូវ
កូនកាត់តាមម៉ែឪ អាស្រូវភាសវិនាសខ្លួន ។

៧៣. មិនជឿមគ្គជឿផល ធ្លាក់ទៅដល់អបាយបួន
កងកម្មចាំគុំគួន គេចវេះពួនមិនកំបាំង ។

៧៤. ព្រះអង្គមានពុទ្ធដីកា ប្រៀបឧបមាជាទីតាំង
ដូចគោមានកំលាំង សំរាំងទុកទីមរទេះ ។

៧៥. នឹងបរផ្លូវវៀចត្រង់ ឬនឹងចង់បរគេចវេះ
កងវិលមិនរបេះ ជិះជើងគោមិនឃ្លាតឃ្លា ។

៧៦. វាល់រូបទាំងតូចធំ ចូលរូងភ្នំរូងគុហា
យកថ្មផ្ទាំងរាំងទ្វារ កម្មវេរាពោងតាមបាន ។

៧៧. កងសីលមានអង្គប្រាំ វេរាកម្មជិតដោយដាន
នរកប្រេតតិរច្ឆាន ខានឃាត់ខាំងបាំងមគ្គផល ។

៧៨. គួរខំសាងសីលទាន យកនិព្វានជាត្រើយផ្សល
យូរឆាប់គង់តែដល់ កុសលជួយចាកសង្សារ ។

៧៩. កូនចៅវេរិះគិត មើលគំនិតចិត្តដូនតា
ប្រព្រឹត្តខុសសាសនា គេចកិរិយាកុំធ្វើគ្រាប់ ។

៨០. មើលចាស់ណាត្រឹមត្រូវ ចុះក្នុងផ្លូវគន្លងច្បាប់
ចាស់ស្ដីគប្បីស្ដាប់ ប្រិតប្រៀងប្រាប់ឱយប្រុងចាំ ។

៨១. គោរពគុណទាំងបី សូត្របាលីតាមចំណាំ
រក្សាអង្គសីលប្រាំ កម្មវេរាតាមមិនទាន់ ។

៨២. សាសនានៅវែងឆ្ងាយ កន្លងប្លាយជាងពីរពាន់
សព្វថ្ងៃលៃគ្មេរគ្មាន់ មិនទាន់គ្រប់ជាប្រាំរយ ។

៨៣. ឥឡូវចិត្តប្រាំបី នៅម្ដែមួយខាងក្រោយ
កូនចៅកុំបណ្ដោយ ឱយលិចលង់ក្នុងសង្សារ ។

៨៤. មានពាក្យចាស់ដំណាល ថាកណ្ដាលព្រះសាសនា
ទំនាយក្បួនតម្រា ថានឹងរៀវហើយរីកវិញ ។

៨៥. ហេតុនេះអស់កូនចៅ ទោះល្ងង់ខ្លៅយ៉ាងណាមិញ
ខំឧស្សាហ៍ទន្ទេញ បំពេញពាក្យពុទ្ធទំនាយ ។

៨៦. តំណាពីថ្ងៃនេះ រៀនពីរះកុំវាយមាយ
កូនណាមិនស្វាធ្យាយ មិនរលាយរលត់ទុក្ខ ។

៨៧. ដល់សាសនាគ្រប់គ្រាន់ ជួបប្រាំពាន់ទៅខាងមុខ
ទំនាយវាយទំនុក ថាឪពុកម្ដាយស្អប់កូន ។

៨៨. ថាកើតអន្តរកប្ប គុំសម្លាប់គ្នាបងប្អូន
មិនដឹងតាដឹងដូន សូន្យសីលទានមិនមានសល់ ។

៨៩. គួរគិតកុំសាងកម្ម កាន់សីលប្រាំចាំដឹកល់
ខំសាងមគ្គសាងផល នឹងបានដល់ឋានសាន្តសុខ ។
៩០. នឹងរួចពីកាប់ចាក់ មិនបានធ្លាក់ទៅនរក
ព្រះសិអារ្យត្រាស់ខាងមុខ រសាយទុក្ខសោករាល់ថ្ងៃ ។
៩១. នេះហៅច្បាប់បណ្តាំ ជាពាក្យប្រាំមួយផ្គូន
បទព្រហ្មគ្រប់ឃ្លាប្អូន ជូនថែងចប់ម្ល៉េះហើយហោង ។

អ្នកព្រះភិរម្យភាសា " អ៊ូ "
ហៅ ង៉ុយ

***

*ផ្កាញ់មនុស្សកំណាញ់ ដោយអោយធនធាន*
*ផ្កាញ់ប្រាជ្ញកល្យាណ ដោយពោលពាក្យពិត*
*ផ្កាញ់មនុស្សឆ្មើងឆ្មៃ ដោយក្តីប្រណិបតន៍*
*ផ្កាញ់មនុស្សល្ងង់ក្តាត់ ដោយបណ្តោយតាម*

# ពាក្យបណ្តាំរបស់បិតា

ស្ទើរតែគ្រប់គ្រួសារ គ្រប់ជនជាតិក្នុងលោក តែងតែគោរព ជឿ ធ្វើតាមពាក្យបណ្តាំដំបូន្មានរបស់មាតាបិតា ជីដូនជីតា បុព្វបុរសរបស់ខ្លួន ។

ចំពោះគ្រួសារខ្មែរយើង ក៏តែងយកចិត្តទុកដាក់ប្រតិបត្តិតាមពាក្យបណ្តាំចុងក្រោយរបស់មាតាបិតាខ្លួនដែរ ។ ជាក់ស្តែង ទោះបីគេចេញទៅធ្វើការងារឆ្ងាយៗពីស្រុកកំណើតក៏ដោយ តែកាលណាគេបានដឹងថា មាតាបិតារបស់គេឈឺធ្ងន់ហើយ គេតែងតែប្រញាប់ប្រញាល់ ស្ទុះស្ទា ស្រូតរូតជាបន្ទាន់មកជួបជុំគ្នា ដើម្បីជួយព្យាបាលលោកផង ដោយខ្លាចក្រែងពុំបានទាន់ដង្ហើមគាត់ផង ព្រោះគេធ្លាប់មានជំនឿថា « កូនចៅណាដែលពុំបានទាន់ដង្ហើមមាតាបិតា ជីដូនជីតា កូនចៅនោះជាមនុស្សអភ័ព្វ ឬកូនចៅនោះជាអ្នកគ្មាននិស្ស័យនឹងលោកទៅជាតិមុខទៀតទេ » ។

តាមធម្មតា មាតាបិតា នៅពេលណាដែលបានដឹងច្បាស់ក្នុងខ្លួនថា ខ្លួនចុះខ្សោយកម្លាំងច្រើន, ខ្លួនពុំអាចទ្រាំទ្រនឹងជំងឺ តទៅទៀត, ខ្លួនប្រាកដជានឹងស្លាប់ក្នុងពេលដ៏ខ្លីខាងមុខ លោកតែងតែបន្តផ្តត់គំនិតជួញចិត្តគិតអំពីសុខទុក្ខអនាគតជីវិតរបស់បុត្រធីតាជានិច្ច ម្ល៉ោះហើយមុននឹងដាច់ខ្យល់ស្លាប់លាកូនចៅ លាលោកនេះទៅ លោកតែងតែនឹកនារកគំនិតប្រមូលផ្តុំសំខាន់ៗ ដែលផ្តើមចេញពីបទពិសោធន៍ជាក់ស្តែងក្នុងជីវិតកន្លងទៅរបស់លោក បង្កើតបានជាពាក្យផ្តាំផ្ញើ . ពាក្យបណ្តាំខ្លីៗតែមានន័យទូលំទូលាយ ដើម្បីជាត្រីវិស័យក្នុងជីវិតរបស់កូនចៅ ។

ពាក្យបណ្តាំ ឬ មតកសាសន៍នេះ ត្រូវបានបុត្រធីតាចងចាំ គោរពតាមអស់មួយជីវិត ។ កូនចៅណាដែលមិនគោរពធ្វើតាមពាក្យបណ្តាំនេះ គេតែងថ្កោល

ទោសថា កូនចៅនោះជាកូនចៅអកតញ្ញូ ល្មើសគុណមាតាបិតា ។ មតកសាសន៍នេះជាមូលដ្ឋានមួយក្នុងការវិនិច្ឆ័យបែងចែកមរតករបស់មាតាបិតាអោយដល់កូនចៅ ជាទាយាទ ( អ្នកត្រូវទទួលមរតក ) នៅពេលណាដែលពុំចុះសម្រុងគ្នា ។

រីឯព្រះសម្ពុទ្ធ ក៏ទ្រង់បានប្រតិស្ឋាននូវបណ្តាំរបស់ព្រះអង្គទុកសំរាប់ពុទ្ធ-សាសនិកដែរ ដែលឱ្យឈ្មោះថា *បច្ឆិមពុទ្ធវចនៈ* គឺជាពាក្យប្រៀនប្រដៅចុងក្រោយបង្អស់ ដោយមានបទថា *អប្បមាទេន សម្បាទេថ ...* = អ្នកទាំងឡាយ ចូរញ៉ាំងការងារឱ្យសំរេច ដោយការមិនប្រមាទចុះ .... ដូច្នេះជាដើម ។

ក្នុងទីនេះ យើងសូមលើកយកបណ្តាំរបស់ព្រះរាជាមួយអង្គដែលបានផ្តាំចំពោះបុត្រទោលតែមួយគត់របស់ខ្លួន នៅពេលហៀបត្រូវផ្លែដាវពេជ្ឈឃាតប្រ-ល័យប្រាណជាបូនកំណាត់ ។ ឯលំនាំសង្ខេបនៃរឿង [១] នេះ មានដូចតទៅ :

កាលពីដើម មានស្តេចក្នុងដែនកាសី ក្រុងពារាណសី ទ្រង់ព្រះនាមព្រហ្ម-ទត្ត ជាស្តេចស្តុកស្តម្ភមាំមួន មានទ្រព្យសម្បត្តិច្រើន មានពលច្រើន ពាហនៈច្រើន ដែនច្រើន មានកម្លាំងនិងជង្រុកបរិបូណ៌ ។ គ្រានោះ មានស្តេចក្នុងដែនកោសល ទ្រង់ព្រះនាមទីឃីតិ ជាស្តេចកំសត់ មានទ្រព្យសម្បត្តិតិច មានពលតិច ពាហនៈតិច មានដែនតិច មានកម្លាំងនិងជង្រុកមិនបរិបូណ៌ ។ វេលានោះ ស្តេចដែនកាសី បានរៀបចំពួកសេនាប្រកបដោយអង្គ ៤ ( ចតុរង្គសេនា ) លើកចេញទៅច្បាំងនឹងស្តេចដែនកោសល ។ ព្រះបាទទីឃីតិ ទ្រង់បានដឹងថា ព្រះបាទព្រហ្មទត្តទ្រង់លើកទ័ពមកច្បាំងនឹងខ្លួន ក៏គិតថា ស្តេចដែនកាសីនេះខ្លាំងពូកែណាស់ ទោះជាអញតទល់ក៏ពុំឈ្នះដែរ ។ ស្តេចដែនកោសល ក៏នាំមហេសីរត់ចេញទៅពីក្រុងជាមុន ។ ព្រះបាទព្រហ្មទត្ត ដណ្តើមយកពួកពល ពាហនៈ ជនបទ ឃ្លាំង ជង្រុករបស់ព្រះបាទទីឃីតិ ហើយគ្រប់គ្រងរក្សាតទៅ ។

---

(១) រឿងនេះ មានសំដែងពិស្តារនៅក្នុងគម្ពីរព្រះត្រៃបិដក ភាគទី ៨ ។

ឯស្តេចដែនកោសល ព្រមទាំងមហេសី យាងចេញទៅក្រុងពារាណសី ដោយក្លែងភេទជាបរិព្វាជក (អ្នកបួសក្រៅពុទ្ធសាសនា) ហើយក៏នៅអាស្រ័យក្នុងផ្ទះស្មូនឆ្នាំងជាយក្រុងនោះ ។ មិនយូរប៉ុន្មាន មហេសីរបស់ស្តេចទីឃីតិ ទ្រង់មានគភ៌ ។ ព្រះមហេសីនោះ ក៏កើតមានចំណង់ពីរយ៉ាងគឺ ចង់ឃើញពួកចតុរង្គសេនាស្អិតស្អាងគ្រឿងប្រដាប់ពាក់អាវក្រោះ ហើយឈរនៅក្នុងទីមានផែនដីរាបស្អាតក្នុងវេលាដែលព្រះអាទិត្យរះឡើង ១ ចង់សោយទឹកដែលគេលាងព្រះខ័ន ១ ។ មហេសីនោះក្រាបទូលព្រះរាជស្វាមីថា « បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់មានគភ៌ហើយ គឺខ្ញុំម្ចាស់មានចំណង់ដូច្នេះឯង » ។ ព្រះបាទទីឃីតិ តបថា « នែនាងទេវី បើយើងជាអ្នកកំសត់ម្លេះ តើយើងទៅរកពីណាបាន » ។ ព្រះនាងទេវីទូលតបថា « បពិត្រព្រះសម្មតិទេព បើខ្ញុំមិនបានគ្រឿងទាំងនោះទេ ខ្ញុំម្ចាស់មុខជានឹងស្លាប់មិនខាន » ។

គ្រានោះ ស្តេចដែនកោសលក៏សំរេចព្រះទ័យចូលទៅជួបនឹងព្រាហ្មណ៍ម្នាក់ធ្លាប់ជាសម្លាញ់ ជាបុរោហិតរបស់ស្តេចដែនកាសី ហើយប្រាប់ថា « នែសម្លាញ់ ឥឡូវស្រីជាសម្លាញ់របស់អ្នកមានគភ៌ ហើយចង់តែឃើញពួកសេនាប្រកបដោយអង្គ ៤ ស្អិតស្អាងគ្រឿងប្រដាប់ពាក់អាវក្រោះ ហើយឈរនៅក្នុងទីមានផែនដីរាបស្អាតក្នុងវេលាព្រះអាទិត្យរះឡើង និងចង់ផឹកទឹកដែលគេលាងព្រះខ័ន » ។ ឯព្រាហ្មណ៍ជាបុរោហិតទូលតបវិញថា « សូមទ្រង់ព្រះមេត្តាប្រោស បើដូច្នោះទូលបង្គំចង់ឃើញព្រះនាងទេវីផង » ។ ពេលនោះ ព្រះនាងមហេសីក៏ចូលទៅរកព្រាហ្មណ៍បុរោហិត ។ ឯព្រាហ្មណ៍បុរោហិត គ្រាន់តែបានឃើញព្រះនាងពីចម្ងាយ ក៏ក្រោកចាកអាសនៈ ពានាសំពត់ឆៀងស្មាម្ខាង ប្រណម្យអញ្ជលីឡើងចំពោះព្រះនាងហើយបន្លឺនូវឧទានបីដងថា « អើហ្ន៎ ស្តេចក្នុងដែនកោសល បានមកស្ថិតនៅក្នុងផ្ទៃហើយ, បពិត្រព្រះនាងទេវី ព្រះនាងកុំព្រួយព្រះទ័យឡើយ ព្រះនាងប្រាកដជានឹងបាននូវចំណង់នោះមិនខានឡើយ » ។

បុរោហិតនោះ ចូលទៅគាល់ព្រះបាទព្រហ្មទត្ត ទូលថា « បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំនិមិត្តឃើញដូច្នេះថា (១) កាលបើព្រះអាទិត្យរះឡើងក្នុងថ្ងៃស្អែក សូមឱ្យពួកសេនាប្រកបដោយអង្គ ៤ ស្អិតស្អាងគ្រឿងប្រដាប់ ពាក់អាវក្រោះ ហើយឈរនៅលើទីមានផែនដីរាបល្អផង សូមឱ្យជនទាំងឡាយលាងនូវព្រះខ័នផង » ។ គ្រានោះ ស្តេចដែនកាសីទ្រង់ឯកភាព ហើយត្រាស់បង្គាប់ថា នៃនាយទាំងឡាយ ព្រាហ្មណ៍ជាបុរោហិតបង្គាប់យ៉ាងណា ចូរនាំគ្នាធ្វើយ៉ាងនោះកុំខាន ។ កាលបើព្រះអាទិត្យរះឡើងហើយ ព្រះមហេសី ក៏បានឃើញពួកសេនាប្រកបដោយអង្គ ៤ ស្អិតស្អាងគ្រឿងប្រដាប់ ពាក់អាវក្រោះ ហើយឈរនៅលើទីមានផែនដីរាបល្អផង បានសោយទឹកដែលគេលាងព្រះខ័នផង ។ មិនយូរប៉ុន្មាន ព្រះមហេសី ក៏ទ្រង់ប្រសូតព្រះរាជបុត្រមួយអង្គ ហើយទ្រង់ប្រទាននាមថា ទីឃាវុ ។

ព្រះបាទ ទីឃីតិ ទ្រង់រិះគិតថា « ព្រះបាទព្រហ្មទត្តបានរឹបយករាជសម្បត្តិអាត្មាអញ ហើយប្រសិនបើស្តេចនេះជ្រាបដំណឹងថា យើងទាំងបីនាក់ ឪពុក ម្តាយ កូន រស់នៅទីនេះ មុខជានឹងឱ្យមនុស្សសម្លាប់មិនខានឡើយ, បើដូច្នេះ គួរអាត្មាអញឱ្យទីឃាវុកុមារចេញទៅនៅក្រៅក្រុងវិញ » ។ វេលានោះ ទីឃាវុកុមារក៏លាមាតាបិតាចេញទៅក្រៅក្រុង រៀនសូត្របានចេះដឹងនូវសិល្បសាស្ត្រសព្វគ្រប់ ។

គួរឱ្យអនិច្ចា ! ថ្ងៃមួយ នាយខ្មាន់ព្រះកេសរបស់ស្តេចទីឃីតិពីដើម តែឥឡូវមករស់នៅក្នុងសំណាក់ស្តេចព្រហ្មទត្ត បានឃើញស្តេចដែនកោសល ព្រមទាំងមហេសីទ្រង់ក្លែងភេទជាបរិព្វាជក អាស្រ័យនៅក្នុងផ្ទះស្មូនឆ្នាំងនោះ ក៏បានចូលទៅទូលពិតព្រះបាទព្រហ្មទត្ត ។ ស្តេចដែនកាសី ក៏បញ្ជាឱ្យគេចាប់ព្រះបាទទីឃីតិ ព្រមទាំងមហេសី កោរក្បាល ចងស្លាបសេក បណ្តើរអាក្រោសទូងស្គរលាន់ឮខ្ទរខ្ទារ នាំ

(១) គឺនិមិត្តឃើញហេតុ ( អាក្រក់ )

បណ្ដើរជុំវិញសព្វច្រកល្ហក សព្វផ្លូវត្រឡែងកែង រួចនាំចេញទៅទ្វារខាងត្បូង ។

និយាយពីទីឃាវុកុមារ ត្រិះរិះថា « អាត្មាអញខានឃើញមាតាបិតាយូរណាស់ហើយ បើដូច្នោះ គួរតែអាត្មាអញទៅមើលមាតាបិតាបានម្ដងសិន » ។ វេលានោះ ទីឃាវុកុមារ ក៏ចូលទៅក្រុងពារាណសី បានឃើញមាតាបិតាដែលគេកំពុងតែធ្វើមារុណកម្ម ។ ឯព្រះបាទទីឃីតិជាបិតា គ្រាន់តែទតឃើញទីឃាវុកុមារជាកូនមកអំពីចម្ងាយ ក៏មានព្រះរាជឱង្ការថា «*មា ខោ ត្វំ ទីឃាវុ ទីឃំ បស្ស មា រស្សំ ន ហិ តាត ទីឃាវុ វេរេន វេរា សម្មន្តិ អវេរេន ហិ តាត ទីឃាវុ វេរា សម្មន្តិ* =នែទី-ឃាវុកូន អ្នកឯងកុំឃើញកាលវែង, កុំឃើញកាលខ្លី, នែទីឃាវុកូន ធម្មតាពៀរ មិនដែលរម្ងាប់ដោយការចងពៀរទេ, នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ » ។ ពួកមនុស្សទាំងឡាយឮដូច្នោះ ក៏ពោលថា « ព្រះបាទទីឃីតិនេះ ពិតជាឆ្កួតនិយាយផ្ដេសផ្ដាស, នរណាឈ្មោះទីឃាវុ ជាកូនរបស់ខ្លួន » ។ ស្ដេចកោសល ក៏តបវិញថា « នែនាយ យើងមិនមែនឆ្កួតទេ យើងមិននិយាយផ្ដេសផ្ដាសទេ, តែបើអ្នកណាជាអ្នកប្រាជ្ញ អ្នកនោះទើបយល់សេចក្ដីបាន » ។ ព្រះបាទទីឃីតិទ្រង់និយាយពាក្យនេះអស់វារៈបីដង ទើបពួកពេជ្ឈឃាតកាប់ខ្លួនជា ៤ កំណាត់ រួចកប់ក្នុងរណ្ដៅគ្រប់ទិសទាំង ៤ នាខាងត្បូងក្រុង ហើយទុកពួកពលឱ្យនៅមើល រួចថយចេញទៅ ។ វេលានោះ ទីឃាវុកុមារចូលទៅក្នុងក្រុង យកស្រាមកបំផឹកពួកពលទាំងនោះ ។ លុះពួកពលទាំងនោះស្រវឹងដួលដេកទៅកាលណា ទីឃាវុកុមារ ក៏ប្រមូលកំណាត់ឈើហើយលើកសរីរៈមាតាបិតាដាក់លើជើងថ្ករ រួចបូជាភ្លើង ផ្គងអញ្ជលីដើរប្រទក្សិណបីជុំ ។ ជួនជាពេលនោះ ស្ដេចព្រហ្មទត្តកំពុងគង់នៅប្រាសាទជាន់ខាងលើបង្អស់ បានទតទៅឃើញទីឃាវុកុមារកំពុងតែធ្វើឈាបនកិច្ចសពមាតាបិតាខ្លួន ក៏ទ្រង់ព្រះតម្រិះថា « មនុស្សនោះច្បាស់ជាញាតិសាច់សាលោហិតរបស់ស្ដេចទីឃីតិហើយ, ឱហ្ន៎ ! សេចក្ដីវិនាសព្រោះបុរសនោះ គង់នឹងមានដល់អាត្មាអញមិនខានឡើយ, មិនសមបើ

គ្មាននរណាមួយប្រាប់អាត្មាអញសោះ » ។ គ្រានោះ ទីឃាវុកុមារគេចខ្លួនទៅនៅព្រៃ ខ្សឹកខ្សួល ទ្រាំញញឹមអស់ចិត្ត ក៏ជូតទឹកភ្នែកត្រឡប់ចូលទៅក្នុងពារាណសីវិញ ហើយបានចូលទៅឯរោងដំរីទៀបព្រះរាជវាំង ហើយនិយាយនឹងហ្មដំរីថា « បពិត្រអ្នកហ្មដំរី ខ្ញុំចង់រៀនសិល្ប៍អំពីអ្នក តើបានឬទេ ? » ។ ហ្មដំរី តបថា « នែនាយមាណព[១] បើដូច្នោះ ចូរអ្នករៀនចុះ » ។ ឯទីឃាវុកុមារ តែងតែក្រោកឡើងពីដំណេកក្នុងបច្ចូសសម័យ[២] នៃរាត្រី ហើយស្រែកច្រៀងដ៏ពិរោះ អមដោយសំឡេងពិណផងក្នុងរោងដំរី ។

ស្តេចព្រហ្មទត្ត បានទ្រង់ព្រះសណ្ដាប់ចម្រៀង និងពិណរបស់ទីឃាវុកុមារនោះ ក៏ត្រាស់សួរទៅរាជអាមាត្យៗ ក្រាបទូលថា « សូមទ្រង់ព្រះមេត្តាប្រោស មាណពជាកូនសិស្សរបស់ហ្មដំរីឯណោះ » ។ ស្តេចដែនកាសី ក៏ត្រាស់ឱ្យទីឃាវុកុមារមកនៅបំរើព្រះអង្គ ។ ទីឃាវុកុមារ ក៏ខិតខំយកចិត្តទុកដាក់បំរើព្រះរាជាមិនឱ្យមោះហ្មង តែងក្រោកមុន ដេកក្រោយ ទទួលស្ដាប់បង្គាប់ការអ្វីៗ ប្រព្រឹត្តគួរជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ ... ។ មិនយូរប៉ុន្មាន ស្តេចព្រហ្មទត្តក៏ទ្រង់សព្វព្រះទ័យតែងតាំងទីឃាវុកុមារក្នុងទីជាអ្នកស្និទ្ធស្នាលខាងក្នុង ( អព្ភន្តរិកៈជំនិត ) ។ ថ្ងៃមួយ ស្តេចកាសីទ្រង់ចង់យាងទៅប្រពាតម្រឹគ ( ប្រពាតព្រៃ ) ហើយបញ្ជាឱ្យទីឃាវុកុមារបររាជរថទៅ ។ ពួកសេនាដើរទៅតាមផ្លូវឯទៀត ទីឃាវុ ក៏បររាជរថទៅតាមផ្លូវឯទៀត បែកផ្សេងពីគ្នា ។ គ្រានោះ ស្តេចព្រហ្មទត្ត យាងទៅដល់ទីឆ្ងាយ ហើយទ្រង់មានព្រះឱង្ការនឹងទីឃាវុកុមារថា « នែនាយមាណព បើដូច្នោះ ចូរអ្នកឯងដោះរាជរថសិន ដ្បិតយើងនឿយព្រួយលំបាក យើងនឹងផ្ទំសម្រាកបន្តិចសិន » ។ វេលានោះ ស្តេចដែនកាសី ក៏ផ្ទំកើយព្រះសិរ[៣] លើភ្លៅទីឃាវុកុមារដែលអង្គុយពែនភ្នែនលើដី ។ ពេលដែលស្តេចអង្គនេះកំពុងផ្ទំលក់ ទីឃាវុកុមារ ត្រិះរិះថា

(១) មាណព អ្នកកម្លោះ ។ (២) បច្ចូសសម័យ ពេលជិតភ្លឺ ។ (៣) សិរ ក្បាល ។

« ស្តេចព្រហ្មទត្តនេះឈ្លានពានរឹបយករាជសម្បត្តិ ហើយថែមទាំងសម្លាប់មាតាបិតាអញផង, វេលានេះ ជាឱកាសល្អ ត្រូវតែរាង្គារអញសងពៀរដល់ស្តេចនេះវិញ » ហើយក៏ហូតព្រះខ័នចេញពីស្រោម ។ ស្រាប់តែភ្លាមនោះ ទីឃាវុកុមារបាននឹកឃើញទាន់ថា « បិតាបានផ្តាំរាង្គារអញក្នុងពេលដែលទៀបចូលទិវង្គតថា នែទីឃាវុកូន អ្នកឯងកុំឃើញកាលវែង, កុំឃើញកាលខ្លី, នែទីឃាវុកូន ធម្មតាពៀរ មិនដែលរម្ងាប់ដោយការចងពៀរទេ, នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ, បើអាត្មាអញកន្លងពាក្យបិតា, អំពើនេះឈ្មោះថា មិនសមគួរដល់អាត្មាអញឡើយ » ហើយក៏ស៊កព្រះខ័នទៅក្នុងស្រោមវិញ អស់វារៈបីដង ដោយអល់អែក រារែក មិនអស់មិនហើយ មិនដាច់ចិត្តសោះ ។ រំពេចនោះ ស្តេចព្រហ្មទត្តទ្រង់ភិតភ័យ ភ្ញាក់ផ្អើល ស្ទើតស្លក់ តក់ស្លុត ហើយក៏តើនឡើងភ្លាម ។ ខណៈនោះ ទីឃាវុ ទូលសួរថា « សូមទ្រង់ព្រះមេត្តាប្រោស ហេតុអ្វីបានជាដូច្នោះ ? » ។ ព្រះរាជាតបថា «នែនាយមាណព ព្រោះយើងយល់សប្តឃើញ ដូចជាទីឃាវុកុមារ ជាកូនស្តេចដែនកោសល ព្រះនាមទីឃីតិ លើកព្រះខ័នឡើងគម្រាមយើងក្នុងទីនេះ » ។ លំដាប់នោះ ទីឃាវុកុមារ យកដៃឆ្វេងចាប់សង្កត់ព្រះសិរស្តេចព្រហ្មទត្ត ហើយយកដៃស្តាំហូតព្រះខ័ននិយាយថា « នែព្រះអង្គ ខ្លួនខ្ញុំហ្នឹងឯងហើយឈ្មោះទីឃាវុកុមារ ជាកូនស្តេចក្នុងដែនកោសល ព្រះនាមទីឃីតិ, ព្រះអង្គបានធ្វើសេចក្តីវិនាសជាច្រើនដល់ខ្ញុំ ទាំងពលពាហនៈ ជនបទ ឃ្លាំង ជង្រុករបស់ខ្ញុំ ក៏ព្រះអង្គរឹបយកអស់, ទាំងមាតាបិតារបស់ខ្ញុំក៏ព្រះអង្គសម្លាប់ចោលអស់, វេលានេះ គួរខ្ញុំសងពៀរដល់ព្រះអង្គវិញ » ។ ស្តេចដែនកាសី ក៏ឱនព្រះសិរក្រាបទៀបជើងទីឃាវុកុមារ ហើយនិយាយថា « នែទីឃាវុកូន សូមអ្នករាណិតឱ្យជីវិតដល់យើងផង » ។ ទីឃាវុកុមារតបថា « ខ្ញុំនឹងអាចឱ្យជីវិតដល់ព្រះអង្គដូចម្តេចបាន គួរតែព្រះអង្គប្រទានជីវិតមកខ្ញុំវិញ» ។ ស្តេចនោះទ្រង់ត្រាស់ថា «នែទីឃាវុកូន បើដូច្នោះ អ្នកឯងចូរឱ្យជីវិតដល់យើងចុះ, យើងក៏ឱ្យជីវិត

ដល់អ្នកឯងវិញ » ។ គ្រានោះ ស្តេចព្រហ្មទត្ត និងទីឃាវុកុមារបានឱ្យជីវិតគ្នាទៅវិញទៅមក ហើយបានចាប់ដៃគ្នានឹងគ្នាផង ធ្វើសម្បថផង ដើម្បីមិនឱ្យមានរឿងប្រទូស្តគ្នាតទៅទៀត ។

ស្តេចដែនកាសី និងទីឃាវុកុមារ ក៏និវត្តទៅព្រះរាជវាំងវិញ ហើយស្តេចទ្រង់ប្រជុំពួកអាមាត្យមន្ត្រីគ្រប់ជាន់ថ្នាក់ ដោយត្រាស់សួរថា « នែនាយទាំងឡាយ ប្រសិនបើអ្នកបានឃើញទីឃាវុកុមារ ជាកូនស្តេចដែនកោសលនោះ តើគួរធ្វើដូចម្តេច ? » ។ ពួកអាមាត្យទាំងឡាយ ក៏ក្រាបទូលថា « សូមទ្រង់ព្រះមេត្តាប្រោសយើងខ្ញុំគួរតែកាត់ជើង កាត់ដៃ កាត់ទាំងជើងទាំងដៃ កាត់ច្រមុះ កាត់ត្រចៀក កាត់ទាំងច្រមុះ ទាំងត្រចៀក កាត់ក្បាលទីឃាវុកុមារនោះ » ។ ស្តេចនោះ ទ្រង់ប្រាប់ថា នែនាយទាំងឡាយ បុរសនេះឯងហើយដែលឈ្មោះទីឃាវុកុមារ ជាកូនស្តេចដែនកោសល ព្រះនាមទីឃីតិនោះ, អ្នកទាំងឡាយមិនត្រូវធ្វើទោសកុមារនេះ សូម្បីតិចតួចឡើយ ព្រោះកុមារនេះបានឱ្យជីវិដល់យើង ហើយយើងក៏បានឱ្យជីវិតដល់កុមារនេះដែរ » ។ ស្តេចព្រហ្មទត្ត ទ្រង់មានព្រះឱង្ការទៅនឹងទីឃាវុកុមារថា « នែទីឃាវុកូន កាលដែលបិតារបស់អ្នកជិតនឹងធ្វើមរណភាពនោះ តើបានផ្តាំចំពោះអ្នកយ៉ាងណាខ្លះ ? តើបណ្តាំនោះមានន័យយ៉ាងណាដែរ ? » ។ ទីឃាវុកុមារ ក្រាបទូលថា « បពិត្រព្រះសម្មតិទេព បិតារបស់ទូលបង្គំបានផ្តាំយ៉ាងនេះ :

១. នែទីឃាវុកូន « អ្នកឯងកុំឃើញកាលវែង » គឺមានន័យថា អ្នកឯងកុំធ្វើពៀរឱ្យយូរអង្វែងឡើយ ។

២. នែទីឃាវុកូន « អ្នកឯងកុំឃើញកាលខ្លី » គឺមានន័យថា អ្នកឯងកុំប្រញាប់បែកចាកពួកមិត្តសម្លាញ់ឡើយ ។

៣. នែទីឃាវុកូន « ធម្មតាពៀរ មិនដែលរម្ងាប់ដោយការចងពៀរទេ » គឺមានន័យថា មាតាបិតារបស់ទូលបង្គំ ត្រូវព្រះអង្គសម្លាប់ចោលអស់, បើទូលបង្គំ

នឹងបំផ្លាញព្រះអង្គឱ្យដាច់ចាកជីវិតនោះ ក៏គង់មានពួកជនដែលប្រាថ្នាប្រយោជន៍ចំពោះព្រះអង្គ នឹងបំផ្លាញទូលបង្គំឱ្យដាច់ចាកជីវិតវិញ, ហើយពួកជនដែលប្រាថ្នាប្រយោជន៍ដល់ទូលបង្គំ មុខជានឹងបំផ្លាញជនទាំងនោះឱ្យដាច់ចាកជីវិតមិនខានឡើយ, ដូច្នេះ ពៀរនោះមិនបានរម្ងាប់ដោយការចងពៀរទេ ។

៤. នែទីឃាវុកុមារ « ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ » គឺមានន័យថា ដូចជាឥឡូវនេះ « ព្រះអង្គទ្រង់ប្រទានជីវិតដល់ទូលបង្គំហើយ ឯទូលបង្គំក៏ថ្វាយជីវិតចំពោះព្រះអង្គវិញ, ដូចនេះ ពៀរនោះឈ្មោះថាបានរម្ងាប់ដោយការមិនចងពៀរយ៉ាងពិតប្រាកដ ។

គ្រានោះ ស្តេចព្រហ្មទត្តទ្រង់ស្ងើចថា « អើហ្ន៎ ! នេះហៅថាពេញជាអស្ចារ្យណាស់, អើហ្ន៎ ! នេះហៅពេញជាចម្លែកណាស់, ទីឃាវុកុមារនេះ ពេញជាអ្នកប្រាជ្ញមែន ព្រោះអាចដឹងន័យសេចក្តីដែលបិតាខ្លួនពោលដោយសង្ខេប ដោយពិស្តារបាន » ហើយក៏ទ្រង់ត្រឡប់ប្រគល់ពល ពាហនៈ ជនបទ ឃ្លាំង ជង្រុក ជាកេរដំណែលបិតាទៅឱ្យទីឃាវុកុមារវិញ ថែមទាំងបានប្រទានធីតាមួយថែមទៀត ។ ក្រោយមក ព្រះបាទទីឃាវុ ក៏ទ្រង់បានជាព្រះមហាក្សត្រ សោយរាជសម្បត្តិលើដែនកោសល និងដែនកាសី ជាបរមសុខក្សេមក្សាន្តវែងឆ្ងាយតរៀងទៅ ។

*សេចក្តីសន្និដ្ឋាន* ៖ ពាក្យបណ្តាំ ជាកម្រងសំរាំងបទពិសោធវិជ្ជមានរបស់ជីវិតមនុស្សម្នាក់ៗ និងសង្គមនីមួយៗ ឬជាចម្លើយវិជ្ជមាននៃជីវិតក្នុងជីវភាពជាក់ស្តែង ។ អ្នកដើរមុន អាចដឹងថាផ្លូវនេះមានបន្លា មានឧបសគ្គ ហើយត្រូវដើរយ៉ាងណាកុំឱ្យមុតបន្លា ឱ្យមានសុវត្ថិភាព យ៉ាងណាមិញ ស្តេចព្រះនាមទីឃីតិនៃដែនកោសល ជាស្តេចដែលធ្លាប់គ្រប់គ្រងរាជសម្បត្តិ ធ្លាប់ប្រឡូកក្នុងជីវភាពសង្គមជីវភាពនយោបាយ អាចទទួលបាននូវបទពិសោធមួយចំនួនក្នុងការរស់នៅ ក៏ដូចជា

ក្នុងការដឹកនាំសង្គម ។ ដូច្នេះហើយបានជាស្ដេចអង្គនេះ បានលើកយកសំរាំងគំនិតរបស់ខ្លួនមកផ្ដាំឱ្យបុត្រទោលបណ្ដូលចិត្តតែមួយចងចាំជានិច្ច ទុកជាគតិក្នុងដំណើរជីវិត ដើម្បីសេចក្ដីចំរើន ( អត្ថាយៈ ) ដើម្បីជាប្រយោជន៍ ( ហិតាយៈ ) ដើម្បីសេចក្ដីសុខ ( សុខាយៈ ) ដល់ខ្លួនផង ដល់សង្គមផង អស់កាលជាអង្វែងតទៅ ។

រៀបរៀងដោយ

**ម៉ែន ប្រាជ និង អាំ ឆន**

**ពិនិត្យនិងកែសំរួលដោយ ឱមខែម**

---

*ខ្លែងហើរដ្បិតខ្យល់ នាយថ្កើងដ្បិតពល រក្សាអោយសុខ*

*ទ្រព្យគង់ដ្បិតស្រីចេះសំចៃទុក ផ្ទះធំស្រណុកដ្បិតភរិយាជា*

# ចាស់ពុំធានធំ ?

( បទកាកគតិ )

ភ្លេងក៏ពិរោះ ចំរៀងក៏ស្រស់ ស្រណោះម្លេះទេ
កាលបឋមវ័យ ធ្លាប់ស្ដាប់ហួរហែ ខ្លួនចាស់មិនប្រែ
នៅតែជាប់ចិត្ត ។
ឱខ្លួនអើយខ្លួន ខ្លួនចាស់អស់មួន ជរាជុំជិត
ព្យាធីរឹតរួត ទើបឃើញមរណ៍ពិត ចិត្តបែរទៅនិត្យ
នៃបស្អិតនឹងធម៌ ។
ព្រះធម៌នេះឯង លោកជួយជ្រោមជ្រែង អ្នកប្រព្រឹត្តល្អ
ដល់ពេលស្លាប់ស្បាន់ អាត្មានោះក៏ ជាប់នឹងព្រះធម៌
ទៅឋានសុខសម ។
ព្រះធម៌ត្រជាក់ ប្រោះព្រំចិត្តអ្នក- ជឿបាត់ក្រៀមក្រំ
ធម៌ជាឱសថ ស័ក្តិសិទ្ធិឧត្តម អ្នកជឿជាក់ចំ
ធម៌ចាំជួយអ្នក ។

រៀបរៀងដោយ
**ជីម ពៅ** គរុនិវត្តជន
នៅភូមិជំទាវ ឃុំច្រេស ស្រុកកំពង់ត្រឡាច
ខេត្តកំពង់ឆ្នាំង

# បញ្ជីឈ្មោះបទភ្លេងខ្មែរ

( តចប់ )

ស្រាវជ្រាវដោយ **យី ធន់**

| ឈ្មោះថ្មី ឬឈ្មោះហៅ តាមភាសាខ្មែរទំនើប | | ឈ្មោះចាស់ ឬឈ្មោះហៅ តាមភាសាបរទេស |
|---|---|---|
| ១៧២- ភ្លូងចំរុះ ៤ ពណ៌ | : | - សយសុនភ្លូងរ៉យ |
| ១៧៣- ពណិលឿងខ្ចី | : | - ស៊ុន្ទូន |
| ១៧៤- មើលនោម | : | - អ៊ុំឆ្មម |
| ១៧៥- លោម | : | - លោម |
| ១៧៦- កង្កែប | : | - កុបតឹក |
| ១៧៧- យានី | : | - យានី |
| ១៧៨- ទំនួញពិលាភ | : | - អូភីលៀប |
| ១៧៩- ទំនួញវ៉ាយ | : | - អូវ៉ាយ |
| ១៨០- ទំនួញប្រជាជន | : | - អូប៉ាឆាឝុន |
| ១៨១- ទំនួញលាវ | : | - អូឡាវ |
| ១៨២- ឃ្លាតឆ្ងាយ | : | - អូណាយ |
| ១៨៣- ដំណើរយឺត | : | - ឆាពី |
| ១៨៤- ភ្លេងរាំក្រោយ | : | - ឆាត្រី |
| ១៨៥- ដំណើរសម្ងាត់ | : | - រោយ៉យ |

| | | |
|---|---|---|
| ១៨៦. ដំណើរស្តេចហង្ស | : | . តាយ៉យហង្សា |
| ១៨៧. ដំណើរចេញក្រៅ | : | . តាយ៉យណាក |
| ១៨៨. កំសត់ | : | . តាយ៉ៃ |
| ១៨៩. ប៉ាន់រូប | : | . គយរូប |
| ១៩០. តាយសភ្នំពេញ | : | . តាយសភ្នំពេញ |
| ១៩១. ដីរលេងភ្លុក | : | . ឆាងព្រះសាំងង៉ា |
| ១៩២. តាយ៉ងយំថ្ងូរ | : | . តាយ៉យយួន |
| ១៩៣. សម្តេចឡាវ | : | . ឡាវសម្តេច |
| ១៩៤. ចង្កេះរៀវ | : | . អេវបាង |
| ១៩៥. ក្រសាលសួនស្ថានសួគ៌ | : | . ឆ៉ុសួនសុវណ្ណ |
| ១៩៦. សារថីបររថ | : | . សារធីខាំរថ |
| ១៩៧. បុប្ផាផ្លែង | : | . បុប្ផាផ្លែង |
| ១៩៨. សង្សារ | : | . សង្សារ |
| ១៩៩. សម័យ | : | . សម័យ |
| ២០០. សុវណ្ណមយូរ៉ា | : | . សយម្យូរ៉ា |
| ២០១. ស្តាយល្អ | : | . សៀវដាយង៉ាម |
| ២០២. ស៊ីរីឡៃ | : | . តាណៃ |
| ២០៣. ស៊ីរិល័យក្រៅ | : | . តាណៃណាក |
| ២០៤. សារីយាំង | : | . សារីយាំង |
| ២០៥. អាយុយីនយូរ | : | . ងៃរ៉េត |
| ២០៦. សុបិននិម្មិត | : | . សូបាកសូបិន |
| ២០៧. ស្លឹកភ្លាំង | : | . បៃផ្លាំង |

២០៨- សត្វល្ងាចេក : - ណុកមីន

២០៩- សត្វកលវែក : - កលវែក

២១០- .................... : - ឆាំសួនសំអាង

២១១- ភូមា ៥ ថត : - ភូម៉ាហាថន

២១២- លាវរួមចិត្ត : - ឡាវមួយសំផាន់

២១៣- ស្រីលាវល្អ : - ឡាវសួយសាធ

២១៤- ដីរបោសលាន : - ឡាវឡាងសាង

២១៥- ជាតិលាវ : - សាត់ឡាវ

២១៦- សំរើបចិត្តលាវ : - ឡឺនថៃឡាវ

២១៧- កូនជាតិលាវ : - ល្ងូកសើយឡាវ

២១៨- ទាហានជាតិលាវ : - សាធថ៉ះហានឡាវ

២១៩- និស្ស័យលាវ : - និស្ស័យឡាវ

២២០- ផ្កាកូឡាបរោយ : - កូឡាបរ្វង

២២១- ផ្កាចំប៉ា : - ដួងចំប៉ា

២២២- ផ្ការបេះទង : - ឌីតដុកហាក់

២២៣- ក្តៅរំដួល : - ទាន់សាណោ

២២៤- កូឡាបបាក់សេ : - កូឡាបបាក់សេ

២២៥- ផ្កាណាត្រី : - ដួងរ៉ាទ្រី

២២៦- ផ្ការំដួលព្រៃ : - ដករំដួលដុង

២២៧- រាត្រីស្ងាត់ : - រ៉ាត្រីស្ងវត្តិ

២២៨- ព្រះចន្ទពេញបូរណ៍ : - ដឿនង៉ាមញ៉ាមណាម

២២៩- ព្រះចន្ទភ្លឺត្រចះ : - ត្រចះព្រះចន្ទ

| | | |
|---|---|---|
| ២៣០- ខ្យល់រំភើយ | : | - លំសួយ |
| ២៣១- រស្មីព្រះច័ន្ទ | : | - ច័ន្ទចៅខា |
| ២៣២- ផ្កាបេះស្លឹកឈើ | : | - ខែកសែ |
| ២៣៣- ចំរើនជីវិត | : | - សីនស៊ីវិត |
| ២៣៤- របាំលាវ | : | - ឡាវឡាំប៉ាង |
| ២៣៥- អញ្ជើញផឹក | : | - សីនឪម |
| ២៣៦- ..................... | : | - ដាំង៉ាន |
| ២៣៧- បាំងស្លឹក | : | - បាំងបៃ |
| ២៣៨- សោយសោកា | : | - សុផាកនៃ្សង |
| ២៣៩- ចាមចាស់ | : | - ប៊ិចាម |
| ២៤០- ស្រីតូចលេងទឹក | : | - សាវណាយលិនណាម |
| ២៤១- ឈូកស្លឹកខ្ចី | : | - បួបាំងបៃ |
| ២៤២- ត្រជាក់ក្នុងចិត្ត | : | - វ៉ាន់ថៃ |
| ២៤៣- ភូមាទាស់ចិត្ត | : | - អ៊ុកខេនភូម៉ា |
| ២៤៤- នឹកអាល័យ | : | - ភ្ជួងអាល័យ |
| ២៤៥- បុប្ផាអារ៉ាប់ | : | - បូង៉ាអារ៉ាប់ |
| ២៤៦- សូរសម្លេងអារ៉ាប់ | : | - សះង្ហួនសៀងអារ៉ាប់ |
| ២៤៧- របាំម៉ាឡាយូ | : | |
| ២៤៨- រលកទប់ប្រាំង | : | |
| ២៤៩- របាំបំបៃ | : | |
| ២៥០- អាលីបាបា | : | |
| ២៥១- ស្នេហាពេញចិត្ត | : | |

២៥២. ស្នេហាពុំមានសង្ឃឹម :

២៥៣. ស្នេហាហើយឃ្លាត :

២៥៤. នាងកម្រើ :

២៥៥. សុរិនរាហ៊្វូ :

២៥៦. បុប្ផាលោកិយ :

២៥៧. នារីជាជួរ :

២៥៨. ពន្លឺលីង :

... ភ្លេងហ៊ុំរោង ...

២៥៩. សាធុការ : - សាធុ់កាន

២៦០. ត្រាក់ : - ត្រាក់

២៦១. យោម៉ាន់ : - យោម៉ាន់

២៦២. បាធំ : - បាធំ

២៦៣. ណា : - ណា

២៦៤. ស្មីររូ : - ស្មីររូ

២៦៥. ជើតពីរជាន់ : - ជើតពីរជាន់

២៦៦. ថ្លី : - ថ្លី

២៦៧. ចំណាន : - ចំណាន

២៦៨. ក្រៅណៃ : - ក្រៅណៃ

... ភ្លេងសំពះគ្រូធំ ...

២៦៩. ត្រាក់ធំ : - ត្រាក់ធំ

២៧០. ដំបងកាន់ : - ដំបងកាន់
២៧១. ស្នីខាំស្មុត : - ស្នីខាំស្មុត
២៧២. ផ្សាដីន : - ផ្សាដីន
២៧៣. ហក់ : - ហក់
២៧៤. ឈោ : - ឈោ
២៧៥. ភ្លុកតុនម៉ាយ : - ភ្លុកតុនម៉ាយ
២៧៦. ផៃវៀ : - ផៃវៀ
២៧៧. រ៉ុករ៉ុន : - រ៉ុករ៉ុន
២៧៨. ប្រក់ប៉ែន : - ប្រក់ប៉ែន
២៧៩. ត្រោកសន្និបាត : - ត្រោកសន្និបាត
២៨០. មហាជ័យ : - មហាជ័យ
២៨១. ឃុតខាត : - ឃុតខាត
២៨២. រូសាមឡា - រូសាមឡា
២៨៣. ព្រាហ្មរីសចិញ្ចៀន : - ព្រាហ្មកិបរីន
២៨៤. ឡុងសុង : - ឡុងសុង
២៨៥. ប្រយខាវតក : - ប្រយខាវតក
២៨៦. សែនឡាវ : - សែនឡាវ
២៨៧. ដើតឆាន : - ដើតឆាន
២៨៨. ផ្លូ : - ផ្លូ
២៨៩. មហារីក : - មហារីក
២៩០. បងរាប់រង : - ភីរាប៉រ៉ង
២៩១. ដើតសុង : - ដើតសុង

| | | | |
|---|---|---|---|
| ២៩២. ត្រាវរាំ | : | : | . ត្រាវរាំ |
| ២៩៣. ជើតឈើង | : | : | . ជើតឈើង |
| ២៩៤. ជើតចាប់ | : | : | . ជើតចាប់ |
| ២៩៥. ខែកវរធឹត | : | : | . ខែកវរធឹត |
| ២៩៦. ព្រះបាទសមុនី | : | : | . ព្រះបាទសមុនី |
| ២៩៧. ក្រៅលំ | : | : | . ក្រៅលំ |

. ចប់ដោយសង្ខេប .

ភ្នំពេញ, ថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៧២

---

*គប់ប្រាជ្ញនាំប្រាណអោយបានសុខ គប់ពាលនាំស្លុកចិត្តមួយឮង*
*គប់ប្រាជ្ញនាំឃ្លាតចាកបាបផង គប់ពាលសៅហ្មងជាប្រក្រតី*

# សេចក្ដីជូនដំណឹង

## អំពីលទ្ធផលនៃចម្លើយ " កំណាព្យប្រស្នា "

## ដែលបានចុះផ្សាយក្នុងទស្សនាវដ្ដី កម្ពុជសុរិយា លេខ ២ ឆ្នាំ ១៩៩៥

គណៈកម្មការនិពន្ធនៃទស្សនាវដ្ដីកម្ពុជសុរិយា មានកិត្តិយស សូមប្រគេន និងជូនដំណឹងចំពោះព្រះតេជព្រះគុណ និងអស់លោកអ្នក នាងកញ្ញា ព្រមទាំងមិត្តអ្នកអានជាទីគោរពថា លិខិតដែលឆ្លើយត្រូវនឹងខ្លឹមសាររបស់ប្រស្នាលើកនេះ មានចំនួន ១៥ ច្បាប់ ។ លិខិតទាំង ១៥ ច្បាប់នេះ សុទ្ធតែសរសេរជាពាក្យកាព្យទាំងអស់ និងមានសម្ផស្សល្អប្រហាក់ប្រហែលគ្នា ។ ចំណែកខាងខ្លឹមសារវិញ អត្ថបទទាំង ១៥ ឆ្លើយត្រូវដូចគ្នា ខុសគ្នាតែត្រង់អត្ថបទខ្លះឆ្លើយសង្ខេប អត្ថបទខ្លះបរិយាយល្អិតល្អន់សព្វគ្រប់ជាង តែប៉ុណ្ណោះ ។ ចំពោះការរៀបចំណាត់ថ្នាក់វិញ គណៈកម្មការបានផ្អែកទៅលើលក្ខណៈវិនិច្ឆ័យ ៣ ប្រការ : ទី១គឺ អត្ថបទណាឆ្លើយត្រូវផ្អែកខ្លឹមសារល្អជាងគេ, ទី២គឺ សម្ផស្សកាព្យល្អជាងគេ និងទី៣គឺ កាលបរិច្ឆេទទទួលអត្ថបទ, អត្ថបទណាទៅដល់មុន អត្ថបទនោះមានអាទិភាព ។

ដោយផ្អែកលើគោលការណ៍ខាងលើនេះ គណៈកម្មការបានសម្រេចបែងចែកចម្លើយទាំងនោះជាបីថ្នាក់ ដោយថ្នាក់នីមួយៗ មានចម្លើយប្រហាក់ប្រហែលគ្នា និងត្រូវទទួលរង្វាន់ដូចគ្នាគឺ :

*ក/ . រង្វាន់លេខ ១ ត្រូវបានប្រាក់ចំនួន ២០.០០០ រៀល ចំនួន ៥ រង្វាន់ ត្រូវប្រគល់ជូនជ័យលាភី ដូចខាងក្រោម :*

១. ភិក្ខុ រតនសុវណ្ណោ សាន សុម៉ែន សមណសិស្សពុទ្ធិកវិទ្យាល័យព្រះសុរាមម្រឹត, ( ចម្លើយមកដល់ថ្ងៃ ០៤ . ៩ . ១៩៩៥ ) ។

២. លោក សរ ច័ន្ទរិទ្ធី ធ្វើការនៅព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ, ( ចម្លើយមកដល់ថ្ងៃ ០៦ . ៩ . ១៩៩៥ ) ។

៣. ភិក្ខុ រិន ចន្ទោ កោសលបញ្ញោ គង់នៅវត្តព្រៃតាត្រាវ ឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ, ( ចម្លើយមកដល់ថ្ងៃ ០៧ . ៩ . ១៩៩៥ ) ។

៤. លោក មៀច ប៉ុណ្ណ នៅពុទ្ធសាសនបណ្ឌិត្យ, ( ចម្លើយមកដល់ថ្ងៃ ០៧ . ៩ . ១៩៩៥ ) ។

៥. លោក កែវ ជន មន្ទីរពតិមានខេត្តពោធិសាត់, ( ចម្លើយមកដល់ថ្ងៃ ០៦ . ១០ . ១៩៩៥ ) ។

*ខ/ . រង្វាន់លេខ ២ ត្រូវបានប្រាក់ចំនួន ១៥.០០០ រៀល មាន ៦ រង្វាន់ ត្រូវប្រគល់ជូនជ័យលាភី ដូចខាងក្រោម :*

១. ភិក្ខុ ធម្មធរោ ឡាក់ សុភ័ក្រ្ត សមណសិស្សពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ស្នាក់នៅវត្តឧណ្ណាលោម កុដិលេខ ១១, (ចម្លើយមកដល់ថ្ងៃ ០៥ . ៩ . ១៩៩៥ ) ។

២. ភិក្ខុ (បទុមវង្សា ) សេង មុនី សមណសិស្សពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ស្នាក់នៅវត្តឧណ្ណាលោម កុដិលេខ ១១, ( ចម្លើយមកដល់ថ្ងៃ ០៩ . ៩ . ១៩៩៥ ) ។

៣. ភិក្ខុ តាំង សុភា រៀននៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត គង់នៅវត្តទួលទំពូង, ( ចម្លើយមកដល់ថ្ងៃ ១២ . ៩ . ១៩៩៥ ) ។

៤. ភិក្ខុ ប៉ាត សុផល សមណសិស្សពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត គង់នៅវត្តទួលទំពូង, ( ចម្លើយមកដល់ថ្ងៃ ១២ . ៩ . ១៩៩៥ ) ។

៥. ភិក្ខុ ពុធ ពឿន សមណសិស្សពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត គង់នៅវត្តឧណ្ណាលោម កុដិលេខ ២៩, ( ចម្លើយមកដល់ថ្ងៃ ១២ . ៩ . ១៩៩៥ ) ។

៦. ភិក្ខុ សេង ចន្ទ្រា គង់នៅវត្តស្លា ឃុំកំពង់ឫស្សី ស្រុកពារាំង ខេត្តព្រៃវែង, ( ចម្លើយមកដល់ថ្ងៃ ២០ . ១០ . ១៩៩៥ ) ។

*គ/ . រង្វាន់លេខ ៣ ត្រូវបានប្រាក់ចំនួន ១០.០០០ រៀល មាន ៤ រង្វាន់ ត្រូវប្រគល់ជូនជ័យលាភី ដូចខាងក្រោម ៖*

១. លោក ជា សុភឿន និស្សិតសាកលវិទ្យាល័យ ភ្នំពេញ ស្នាក់នៅកុដិលេខ ១០ វត្តមហាមន្ត្រី, ( ចម្លើយមកដល់ថ្ងៃ ២៤ . ៨ . ១៩៩៥ ) ។

២. ភិក្ខុ ប៊ុច សុផាត សមណសិស្សពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត, ( ចម្លើយមកដល់ថ្ងៃ ០៤ . ៩ . ១៩៩៥ ) ។

៣. ភិក្ខុ សុន យ៉ែស សមណសិស្សពុទ្ធិកបឋមសិក្សាវត្តទួលទំពូង, ( ចម្លើយមកដល់ថ្ងៃ ១២ . ៩ . ១៩៩៥ ) ។

៤. ភិក្ខុ អគ្គចិត្តោ ព្រហ្ម សុជាតិ គង់នៅវត្តមហាមន្ត្រី, ( ចម្លើយមកដល់ថ្ងៃ ០៩ . ១០ . ១៩៩៥ ) ។

គណៈកម្មការនិពន្ធ សូមនិមន្ត និងអញ្ជើញជ័យលាភីទាំងប៉ុន្មាន ដូចមានរាយព្រះនាម និងនាមខាងលើ ទៅបើករង្វាន់ នៅផ្នែកទស្សនាវដ្ដី នៃពុទ្ធសាសនបណ្ឌិត្យ ដែលមានទីចាត់ការបណ្ដោះអាសន្ន នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ នៅរាល់ម៉ោងធ្វើការ ។

គណៈកម្មការនិពន្ធ សូមឆ្លៀតឱកាសនេះដែរ ដើម្បីសម្ដែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះឯកឧត្តម វណ្ណ ស៊ុនហេង អ្នកតំណាងរាស្ត្រ មណ្ឌលព្រៃវែង ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន សំរាប់ឧបត្ថម្ភចំពោះរង្វាន់ជ័យលាភីខាងលើនេះ ។

កម្ពុជសុរិយា

# ចម្លើយកំណាព្យប្រស្នា

ដែលចុះផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយា លេខ ២ - ១៩៩៥

គណៈកម្មការនិពន្ធ មានកិត្តិយសសូមជម្រាបលោកអ្នកអាន ជាទីគោរព ថា ឯកឧត្តម វណ្ណ ស៊ុនហេង ដែលជាម្ចាស់ប្រស្នា លោកមិនឆ្លើយនឹងប្រស្នា ដែលលោកចោទនោះទេ ព្រោះថា លោកអ្នកអានបានឆ្លើយត្រូវល្អច្រើនហើយ តែលោកសុំអោយគណៈកម្មការនិពន្ធ ចុះអត្ថបទរបស់លោក សរ ច័ន្ទរិទ្ធី ធ្វើការ នៅព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ ដែលទទួលបានចំណាត់ថ្នាក់លេខ ១ ជា ជំនួសអត្ថបទចម្លើយរបស់លោកតែម្ដង ។

ម្យ៉ាងវិញទៀត គណៈកម្មការនិពន្ធ សូមសម្ដែងនូវសេចក្ដីស្ដាយជាពន់ ពេក ដោយមិនអាចចុះផ្សាយអត្ថបទចម្លើយរបស់អស់លោកអ្នក ដែលបានទទួល ចំណាត់ថ្នាក់ទាំងអស់បាន ដោយមូលហេតុបច្ចេកទេសបោះពុម្ព ។ គណៈកម្មការ និពន្ធ សង្ឃឹមទុកជាមុនថា អស់លោកអ្នកអាន នឹងអធ្យាស្រ័យចំពោះកង្វះខាតខាង លើនេះ ។ ខាងក្រោមនេះគឺ អត្ថបទចម្លើយប្រស្នា ដែលទទួលបានចំណាត់ថ្នាក់ លេខ ១ ។

ចម្លើយកំណាព្យប្រស្នា

ក្នុងកម្ពុជសុរិយា ឆ្នាំ៤៩ លេខ២ ឆ្នាំ ១៩៩៥

ខ្ញុំលើកហត្ថា ចាប់កាន់ប៉ាកា ចារជាអក្សរ

តែងជាកំណាព្យ កាព្យឃ្លោងយ៉ា១ ឆ្លើយដោយស្មោះស

កំណាព្យប្រស្នា ។

ពូជស្រូវស្រុកខ្មែរ មានច្រើនហូរហែ ទាំងស្រែចំការ
មានធ្ងន់មានស្រាល ត្រូកាលពេកណា ជួយទ្រទ្រង់ជីវា
ផ្ទែកខាងរាងកាយ ។

ពូជស្រូវខុសគេ មានពីបុព្វេ តាំងពីវៀងអាយ
ពូកែសក្តិសិទ្ធិ គំនិតប្រាជ្ញប្រាយ ភោគ្គារឿយៗ
ជួយមនសិការ ។

ពូជនេះល្អល្អះ សំរាំងយូរណាស់ ដោយព្រះសម្មា
សមណគោតម បរមសាស្តា បង្កធ្វើជា
បានបីកន្តាំង ។

ស្រូវកន្តាំងបី គ្រប់ទ្វីបលោកីយ៍ រស្មីចែងចាំង
ទោះមានឬក្រ មិនមានខាយាំង បានធីភ្លឺស្វាង
មិនគិតវណ្ណៈ ។

ស្រូវកន្តាំងបី នោះគឺព្រះត្រៃ- បិកដជាក់លាក់
ដែលជាព្រះធម៌ បវរឥតអាក់ ចែកគ្រប់ជាតិសាសន៍
ធ្វើការចម្លង ។

នៅឯលង្កា ព្រះពុទ្ធឃោសា ប្រាជ្ញាចម្បង
ប្រែសំនៀងជាក់ មគធៈហ្មត់ហ្មង ពីសីហឡៈ
មកជាបាលី ។

ព្រះធម៌ឧត្តម ផ្សព្វផ្សាយទូលំ វាយពាសពេញដី
ចូលមកកម្ពុជា តាំងពីព្រេងនាយ ជាតិខ្មែររីករាយ
ទទួលសិក្សា ។

ដោយព្រះឧបត្ថម្ភ មហាឧត្តម ពីព្រះករុណា

ព្រះមុនីវង្ស រាជាក្សត្រា បង្កើតបានជា
ក្រុមជំនុំបក* ។

ឆ្នាំម្ភៃប្រាំបួន ខ្មែរចាប់រៀបក្បួន អក្ខរាបែបបទ
ដល់ហុកប្រាំបី ចប់ដោយសន្មត សាមប្រាំបួនគត់
ជាឆ្នាំអស់កាល ។

ព្រះត្រៃបិដក ក្រុមជំនុំបក- ប្រែពីស្រុកអាយ
ខាងឆ្វេងបាលី ខាងស្តាំសំរាយ សំរាប់ចែកចាយ
គ្រប់វត្តនិគម ។

ភាគដើមដប់បី មានទាំងបាលី មានធម៌ឧត្តម
ចំនួនហុកបួន ក្បួនព្រះសុត្តន្ត ឯអភិធម្ម
មានសាបសិបបី ។

សរុបទាំងអស់ ព្រះត្រៃបិដក ដែលបានស្រដី
មានមួយរយដប់ រាប់ទាំងបីល្អី សូមរាយសេចក្តី
តាមល្អីមួយៗ ។

ភាគដើមដប់បី មានទាំងបាលី សំរាយជំនួយ
សំរាប់អប់រំ សន្សំជាមួយ និស្ស័យជាត្រួយ
លើកស្ទួយព្រះធម្ម ។

ក្នុងព្រះវិន័យ រៀបរាប់សេចក្តី ពីច្បាប់ក្រឹត្យក្រម
ដែលអង្គព្រះពុទ្ធ លោកបានរៀបចំ ជាក្បួនឧត្តម
ទុកប្រតិបត្តិ ។

---
* បកប្រែ

វិន័យបិដក គឺជាកញ្ចក់ ឆ្លុះមើលប្រវត្តិ
អង្គព្រះសម្ពុទ្ធ គង់នៅប្រាកដ ទំនៀមទំលាប់
រឿងរ៉ាវហេតុការណ៍ ។

ភាគទាំងដប់បី ក្នុងព្រះវិន័យ មានប្រាំឈ្មោះថា
*អាទិកម្មមួយ* នោះមានន័យថា ទោសធ្ងន់អស្ចារ្យ
*មហាវិភង្គ* ។

*បាចិត្តិយៈ* ជាទោសស្រាលជាក់ មិនសូវជាខ្លាំង
នៅវៀងទី២ នៃធម៌វិភង្គ ទីបីសំរាំង
គឺ*មហាវគ្គ* ។

ប្រែថាវគ្គធំ មានច្រើនគួរសម រាប់សិបធម្មកៈ[1]
*ចុល្លវគ្គតូច* *បរិវារៈ* បាលីប្រែច្បាស់
ជាបទរាយរង ។

ចប់ព្រះវិន័យ នេះនឹងស្រដី ពីល្អិសុត្តន្ត
គម្ពីរព្រះសូត្រ នៃព្រះពុទ្ធអង្គ ដែលលោកផ្ចិតផ្ចង់
សំរាប់សាសនា ។

*ទីឃនិកាយ* បើប្រែសំរាយ សេចក្ដីពិស្ដារ
មានធម៌មធ្យម មជ្ឈិមនោះណា បាលីអានថា
*មជ្ឈិមនិកាយ* ។

ព្រះសូត្របីទៀត ខ្ញុំសូមរាប់រៀប *សំយុត្តនិកាយ*
បើប្រែឱ្យចំ សេចក្ដីមិនឆ្ងាយ នៅក្បែរៗរាយ
ន័យប្រហែលគ្នា ។

(១) មានន័យធម្មកណ្ឌ សូមអានធម្មកៈ

ស្ងូត្រជាក្រុមពួក *អង្គុត្តរៈ* *មានវគ្គមានឃ្លា*
ស្ងូត្រសេចក្តីខ្លី បាលីប្រែជា *ខុទ្ទកៈណា*
សារសព្ទខ្លីៗ ។

វគ្គតូចច្រើនទៀត ខ្ញុំមិនបានរៀប រាប់អស់សេចក្តី
គ្រាន់តែដឹងថា មាននិទានស្តី *ប្រេតអវិថី*
និង*ទសជាតក* ។

ព្រះអភិធម្ម គម្ពីរសុខុម ល្អិតល្អន់ហ្មត់ចត់
ព្រះពុទ្ធលោកចារ ដីកាសន្ទត ជាវិជ្ជាពិត
ផ្នែកទស្សនៈ ។

*ធម្មសង្គណី* ធម៌ចែងពីន័យ ការរៀបចំដាក់
ចែករំលែកធម៌ ដល់ពុទ្ធបរិស័ទ *វិភង្គ*ចាំស្ទាត់
ដោយពិចារណា ។

ធម៌ផ្ទុយសេចក្តី ភាសាបាលី *វត្ថុកថា*
*បុគ្គលបញ្ញត្តិ* ចាត់ជារូបា ឯ*ធាតុកថា*
ការវែកញែកធាតុ ។

ធម៌តូចៗគ្នា បាលីអានជា *យមកៈ*ធម៌
ហេតុផលទាំងឡាយ មិនសុទ្ធតែល្អ *បដ្ឋាន*ធម៌
បច្ច័យប្រាកដ ។

ព្រះអភិធម្ម មានធម៌ចំរើន ដល់ការបាត់ពត់
ទាំងចិត្តទាំងកាយ ក្រាបថ្វាយសីលដប់ លើកហត្ថគោរព
ឱវាទសីលប្រាំ ។

សេចក្តីខាងលើ ខ្ញុំសាកលមើល អ្វីដែលបានចាំ
ចេះដឹងតិចតួច ល្មួចកត់ចំណាំ សំដីគ្រូផ្តាំ
កាលនៅសិក្សា ។

ខ្ញុំសូមជូនពរ ពូជពីអង្គរ ខ្មែរគ្រប់អាត្មា
សូមជួបក្តីសុខ ប្រកបគ្រប់គ្នា សូមមានសុខា
ទិវារាត្រី ។

កម្ពុជសុរិយា សូមថ្កើងថ្លៃថ្លា រុងរឿងរាល់ថ្ងៃ
រក្សាវប្បធម៌ ជាតិមិនឱ្យក្ស័យ អនាគតប្រពៃ
កម្ពុជាក្សេមក្សាន្ត ។

ភ្នំពេញ, ថ្ងៃទី ៥ កញ្ញា ១៩៩៥

**សរ ចំនួរិទ្ធ**

*ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ*

*ការមានប្រយោជន៍គួរខំធ្វើ វិជ្ជាចេះស្ទើរគួរបំពេញ*
*អកុសលមាននៅគួរលះចេញ ជួញមានចំណេញគួរខំជួញ*

# កំណាព្យប្រស្នា

គណៈកម្មការនិពន្ធ មានកិត្តិយសចុះផ្សាយ កំណាព្យប្រស្នាមួយទៀតរបស់ ឯកឧត្តម វណ្ណ ស៊ុនហេង អ្នកតំណាងរាស្ត្រមណ្ឌលព្រៃវែង នៅក្នុងទស្សនាវដ្តី កម្ពុជសុរិយា លេខ ៣ / ១៩៩៥ នេះ ។

ចម្លើយទាំងឡាយណា ដែលត្រូវនឹងខ្លឹមសាររបស់ប្រស្នា នឹងបានទទួលរង្វាន់តាមកិរិតនៃចំណាត់ថ្នាក់ ។

គណៈកម្មការនិពន្ធ សូមអញ្ជើញលោកអ្នកអានទាំងឡាយ ដែលស្រឡាញ់អក្សរសាស្ត្រខ្មែរ មេត្តាចូលរួមសាកល្បងឆ្លើយ អោយបានច្រើនជាអតិបរមា ។

## បទកាកគតិ

មនុស្សលើលោកា ប្រើច្រើនភាសា ចរចាទាក់ទង
បារាំង អង់គ្លេស អារ៉ាប់ ហុល្លង់ រុស្ស៊ី អាល្លឺម៉ង់
ចិន ចាម ឡាវ ខ្មែរ ។

រយពាន់ភាសា ទោះរៀនយ៉ាងណា ក៏ពុំអស់ដែរ
ចេះដប់ភាសា ចាត់ជាពូកែ ថ្នេះត្រូវបកប្រែ
ទើបយើងយល់បាន ។

ប្រស្នាអារកាត់ មានពាក្យពីរម៉ាត់ ប្រើគ្រប់ទីស្ថាន
មិនអាចប្រែប្រាប់ អាចស្តាប់យល់បាន សូមសួរសន្តាន
ពាក្យនោះជាអ្វី ?

សូមទាញអារម្មណ៍ ប្រស្នាបន្ទំ ល្បែងល្បោយកវី
ភាសាពីរម៉ាត់ ប្រើពេញផែនដី ក្មេងចាស់ប្រុសស្រី
យល់បានគ្រប់គ្នា ។
ពាក្យនោះថាម៉េច ? លើកកាព្យកលកិច្ច ល្បោយល្បិចឃ្លោងឃ្លា
ប្រើបទប្លែកៗ បំបែកន័យវា ជូនដល់ជនា-
នុជនដឹងផង ។

២៧ - ១១- ១៩៩៥
**ខណ្ឌ ស៊ុនហេខ**

*ប្រាំប្អូនទ័លដប់ទ័ល កុំអោយទ័លគំនិត*
*ប្រាំប្អូនគិតដប់គិត កុំគិតមេឃដី*
*ប្រាំប្អូនធ្វើដប់ធ្វើ កុំធ្វើការអប្រិយ៍*
*ប្រាំប្អូនស្តីដប់ស្តី កុំស្តីពាក្យអសុរស*

# ដំណើរទស្សនកិច្ច

របស់ឯកឧត្តម ឈិន អៀម អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា
និងលោក យី ធន់ ទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា
នៅទីក្រុងតូក្យូ ប្រទេសជប៉ុន និងទីក្រុងបាងកក ព្រះរាជាណាចក្រថៃឡង់
ពីថ្ងៃទី ២៥-១០-៩៥ ដល់ថ្ងៃទី ០៩-១១-៩៥

តាមសេចក្ដីអញ្ជើញរបស់សកលវិទ្យាល័យ ត្សឹគូបា ប្រទេសជប៉ុន និងដោយបានទទួលការអនុញ្ញាតពីព្រះរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងធម្មការ និងសាសនា បានចាត់បញ្ជូនគណៈប្រតិភូមួយ ដឹកនាំដោយ ឯកឧត្តម ឈិន អៀម អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ឱ្យទៅបំពេញបេសកកម្មនៅទីក្រុងតូក្យូ ប្រទេសជប៉ុន ដើម្បីស្វែងរកជំនួយបន្ថែមទៀត ក្នុងការស្ដារវិស័យពុទ្ធសាសនានៅកម្ពុជាឡើងវិញ ជាអាទិ៍គឺសុំជំនួយឧបត្ថម្ភចំពោះការបោះពុម្ពសៀវភៅធម៌ និងអក្សរសាស្ត្រ ដែលជាស្នាដៃរបស់ពុទ្ធសាសនបណ្ឌិត្យពីបុរាណ, ការសាងសង់អគារពុទ្ធសាសនបណ្ឌិត្យថ្មី និងការស្រាវជ្រាវរកស្នាដៃថ្មីៗ ខាងផ្នែកទំនៀមទម្លាប់ ប្រពៃណី និងសិល្បៈ វប្បធម៌ខ្មែរ និងជនជាតិ ។

គណៈប្រតិភូបានចេញដំណើរពីរាជធានីភ្នំពេញ នៅថ្ងៃទី ២៤.១០.៩៥ ហើយបានទៅដល់ទីក្រុងតូក្យូ នៅថ្ងៃទី ២៥.១០.៩៥ វេលាម៉ោង ០៧ ព្រឹក ។ នៅព្រឹកថ្ងៃ ២៥.១០.៩៥ ប្រតិភូបានទៅទស្សនាទីក្រុង ត្សឹគូបា ដែលជាមជ្ឈមណ្ឌលវប្បធម៌ វិទ្យាសាស្ត្រសង្គមដ៏ទំនើបបំផុតរបស់ប្រទេសជប៉ុន ស្ថិតនៅចម្ងាយ ៦០ គ.ម ពីទីក្រុងតូក្យូ ។ នៅវេលារសៀលថ្ងៃដដែល គណៈប្រតិភូបានទៅធ្វើបាឋកថា ស្ដីអំពីព្រះពុទ្ធសាសនានៅកម្ពុជា នៅមហាវិទ្យាល័យប្រវត្តិវិទ្យា និងនរវិទ្យា នៃសកលវិទ្យាល័យ និងបានចូលរួមសំណេះសំណាលជាមួយសាស្ត្រាចារ្យ

និងនិស្សិតថ្នាក់បណ្ឌិតជាច្រើនរូប ។ ការធ្វើបាឋកថាលើកនេះ គឺជាជំហានទីមួយនៃទំនាក់ទំនងក្នុងការផ្លាស់ប្តូរវប្បធម៌ទៅវិញទៅមក រវាងពុទ្ធសាសនបណ្ឌិត្យ និងមហាវិទ្យាល័យប្រវត្តិវិទ្យា និងនរវិទ្យា នៃសកលវិទ្យាល័យត្សឹគូបា ជប៉ុន ។ អស់លោកសាស្ត្រាចារ្យ និងនិស្សិតជប៉ុន បានវាយតម្លៃខ្ពស់ចំពោះបាឋកថានេះ ព្រមទាំងមានបំណងពង្រីកទំនាក់ទំនងខាងផ្នែកស្រាវជ្រាវ អំពីវប្បធម៌សង្គមឱ្យកាន់តែជិតស្និទ្ធ និងទូលំទូលាយថែមទៀត ។ ក្នុងឱកាសនោះដែរ សកលវិទ្យាល័យត្សឹគូបា បានធ្វើសំណូមពរឱ្យភាគីកម្ពុជាយើង ជួយសម្រួល និងជួយឧបត្ថម្ភដល់និស្សិតថ្នាក់អនុបណ្ឌិត និងថ្នាក់បណ្ឌិតជប៉ុន ដែលត្រូវមកធ្វើការសិក្សាស្រាវជ្រាវនៅប្រទេសកម្ពុជាយើងនាពេលខាងមុខ ដូចជាសម្រួលផ្នែកទិដ្ឋាការ និងជួយណែនាំក្នុងការស្រាវជ្រាវនៅតាមមូលដ្ឋាននានា ក្នុងប្រទេសកម្ពុជាយើង ។ គណៈប្រតិភូបានសម្តែងស្វាគមន៍ចំពោះនិស្សិតជប៉ុនដែលត្រូវមកធ្វើកម្មសិក្សាស្រាវជ្រាវ នៅប្រទេសខ្មែរ និងត្រៀមរួមសហការគ្រប់យ៉ាង ដើម្បីសម្រួលដល់កិច្ចការស្រាវជ្រាវនេះ ។

នៅថ្ងៃទី ២៦.១០.៩៥ ដោយមានលោកសាស្ត្រាចារ្យ បណ្ឌិតម៉ាសាគី អូណូហ្សាវ៉ា សាស្ត្រាចារ្យបំរុងនៃសកលវិទ្យាល័យ ត្សឹគូបា ជូនដំណើរផង គណៈប្រតិភូបានអញ្ជើញទៅសម្តែងការគួរសម និងសំណេះសំណាលជាមួយអ្នកដឹកនាំមូលនិធិតូយ៉ូតា ។ ចូលរួមក្នុងឱកាសនោះ មានលោក ស៊ីម៉ាគី គូរ៉ូកាវ៉ា នាយកនៃអង្គការមូលនិធិតូយ៉ូតា លោក តូអ៊ីជិ ម៉ាគីតា មន្ត្រីផ្នែកកម្មវិធីនៃនាយកដ្ឋានអន្តរ-ជាតិរបស់មូលនិធិ និងលោក ណូដា មន្ត្រីរបស់អង្គការ ជី អេស អ ស៊ី នៅតូក្យូ ។ ក្នុងកិច្ចពិភាក្សាគ្នា ឯកឧត្តម ឈន អៀម បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅក្នុងនាមក្រសួងធម្មការ និងសាសនា ចំពោះការដែលមូលនិធិតូយ៉ូតា បានជួយឧបត្ថម្ភចំពោះការបោះពុម្ពផ្សាយឡើងវិញនូវ បទានុក្រមធម្មបទទាំងពីរលើក ដែលជាជំនួយ

ប្រកបដោយអត្ថប្រយោជន៍យ៉ាងសំខាន់ចំពោះការសិក្សារៀនសូត្ររបស់ភិក្ខុ សា-មណេរ និងគ្រហស្ថ អ្នកសិក្សាស្រាវជ្រាវអំពីពុទ្ធសាសនា ។ ឯកឧត្តម ឈាន អៀម បានធ្វើសំណូមពរឱ្យមូលនិធិនេះ បន្តជួយឧបត្ថម្ភដល់ការងាររបស់ពុទ្ធសាសនបណ្ឌិត្យតទៅទៀត ទៅអនាគត ។ ឆ្លើយតបនឹងសំណូមពររបស់គណៈប្រតិភូលោក គូរ៉ូកាវ៉ា បានមានប្រសាសន៍ថា លោកនឹងពិនិត្យលទ្ធភាពជួយផ្ដល់ថវិកាខ្លះ សំរាប់ការងារបោះពុម្ពផ្សាយ និងស្រាវជ្រាវណាដែលមូលនិធិពិនិត្យទៅឃើញថាមានប្រយោជន៍ចំពោះប្រទេសកម្ពុជា ក្នុងការស្តារ និងថែរក្សាមរតកវប្បធម៌ជាតិ ។ លោក គូរ៉ូកាវ៉ា បានសំណូមពរឱ្យពុទ្ធសាសនបណ្ឌិត្យបង្កើតគណៈកម្មការស្រាវជ្រាវមួយ ដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំស្រាវជ្រាវ និងវាយតម្លៃស្នាដៃដែលត្រូវបោះពុម្ពផ្សាយ ។ ចំពោះសំណូមពរនេះ ឯកឧត្តម ឈាន អៀម សន្យាថានឹងរៀបចំឱ្យបានក្នុងពេលខាងមុខ ។

នៅវេលាថ្ងៃត្រង់ គណៈប្រតិភូបានជួបសំណេះសំណាល និងពិសាភោជនាហារជាមួយព្រះតេជគុណ ហ្សិនជូ ម៉ាត្សិណាហ្គា ប្រធាននៃអង្គការ ជីអេស អ ស៊ី ជប៉ុន ។ ក្នុងឱកាសនោះ ឯកឧត្តម ឈាន អៀម បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការ JSRC ដែលបានជួយឧបត្ថម្ភដោយឥតសំចៃចំពោះពុទ្ធសាសនបណ្ឌិត្យកន្លងមក រហូតដល់ទទួលបានជោគជ័យយ៉ាងធំធេង ជាពិសេសក្នុងការបោះពុម្ពគម្ពីរព្រះត្រៃបិដក នាពេលថ្មីៗនេះ ។

នៅវេលារសៀលថ្ងៃ ២៦.១០.៩៥ ដដែល គណៈប្រតិភូបានទៅទស្សនាបណ្ណាល័យរបស់សភាជាតិជប៉ុន ។ នៅទីនោះ គណៈប្រតិភូត្រូវបានលោក យ៉ាម៉ាគូជិ ទទួលស្វាគមន៍យ៉ាងកក់ក្ដៅរាក់ទាក់ ។ គណៈប្រតិភូបានទស្សនាគ្រប់ផ្នែកទាំងអស់នៃបណ្ណាល័យដ៏ធំ ដែលមានសៀវភៅ និងឯកសាររាប់លានក្បាល ។ លោក យ៉ាម៉ាគូជិ បានបង្ហាញគណៈប្រតិភូយើងនូវរោងជាងជួសជុលសៀវភៅចាស់ៗ របៀបថែ

ទាំ ទុកដាក់សៀវភៅក្រុមៗ របៀបធ្វើបញ្ជីសៀវភៅ .... ។ ល ។ បន្ទាប់ពីបានស្ដាប់របាយការណ៍ និងបំណងប្រាថ្នារបស់គណៈប្រតិភូយើងមក លោក តាការ៉ូ មុរ៉ាយ៉ាម៉ា នាយកផ្នែកសហប្រតិបត្តិការអន្តរជាតិរបស់បណ្ណាល័យសភាជាតិជប៉ុន បានសន្យាថា នឹងខិតខំរកគ្រប់មធ្យោបាយ ដើម្បីជួយដល់ប្រទេសកម្ពុជា ខាងផ្នែកបណ្ណាល័យ ដូចជាការផ្លាស់ប្ដូរពិសោធន៍ទៅវិញទៅមក ការបណ្ដុះបណ្ដាលបុគ្គលិកជំនាញៗ និងការជួសជុលសៀវភៅជាដើម ។ លោក តា ការ៉ូ បានបញ្ជាក់ទៀតថា លោកមានបំណងធ្វើការផ្លាស់ប្ដូរសៀវភៅ រវាងបណ្ណាល័យរបស់ពុទ្ធសាសនៈបណ្ឌិត្យ និងបណ្ណាល័យរបស់សភា ទៅអនាគតផងដែរ ។ ការពិភាក្សានេះ បានប្រព្រឹត្តទៅក្នុងស្មារតីយោគយល់គ្នាយ៉ាងស្និទ្ធស្នាលក្រៃលែង ។

នៅថ្ងៃទី ២៧.១០.៩៥ គណៈប្រតិភូបានអញ្ជើញទៅជួបពិភាក្សាការងារជាមួយលោក កាត់ស៊ុហ៊ីរ៉ូ ស៊ីណូហារ៉ា អ្នកសម្របសម្រួលតាមតំបន់ នៃក្រសួងការបរទេសជប៉ុន ដោយមានអ្នកស្រី មិជិកុ កាវ៉ា នៃនាយកដ្ឋានកិច្ចការវប្បធម៌របស់ក្រសួងការបរទេស លោកសាស្ត្រាចារ្យ អ៊ូណូហារ៉ា និងលោក ណូដា នៃអង្គការ JSRC ចូលរួមផង ។ នៅក្នុងឱកាសនោះ គណៈប្រតិភូយើងបានសំណូមពរចំពោះលោក ស៊ីណូហារ៉ា ជួយផ្ដល់យោបល់ដើម្បីស្វែងរកវិធីសុំជំនួយពីរាជរដ្ឋាភិបាលជប៉ុន ចំពោះពុទ្ធសាសនបណ្ឌិត្យដែលជាមជ្ឈមណ្ឌលវប្បធម៌ខ្មែរដ៏ធំមួយ នៃប្រទេសកម្ពុជា ពីព្រោះបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលជប៉ុនមាននយោបាយមួយគឺមិនប៉ះពាល់ដល់កិច្ចការសាសនាឡើយ ។ ដើម្បីឆ្លើយបំភ្លឺ ឯកឧត្ដម ឈេន អៀម បានបញ្ជាក់ថា ចំពោះប្រទេសកម្ពុជា ពុទ្ធសាសនាជាវប្បធម៌ខ្មែរ ពុទ្ធសាសនបណ្ឌិត្យជាមជ្ឈមណ្ឌលនៃវប្បធម៌ខ្មែរ ។ ឆ្លើយតបនឹងសំណូមពររបស់គណៈប្រតិភូ លោកស៊ីណូហារ៉ា ដែលចេះភាសាខ្មែរយ៉ាងស្ទាត់ ទាំងបានធ្លាប់ធ្វើការនៅប្រទេសខ្មែរ ជាច្រើនឆ្នាំ បានជម្រាបថា វិធានការតែមួយ ដើម្បីអាចមានលទ្ធភាពទទួលជំនួយបាន

មានតែផ្លាស់ប្តូរឈ្មោះវិជ្ជាស្ថានរបស់យើង សុំកុំឱ្យជាប់ពាក្យពុទ្ធសាសនបណ្ឌិត្យ ដែលជាឈ្មោះសាសនាមួយ ឬក៏ម្យ៉ាង ត្រូវបង្កើតសមាគម ឬគណៈកម្មការចំរុះមួយ ដែលមានក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងអប់រំសិក្សាធិការ កីឡា និងយុវជន ហើយនិងពុទ្ធសសនបណ្ឌិត្យចូលរួម ។ ចំពោះបញ្ហានេះទៀត លោក ស៊ីណូហារ៉ា បានសុំអោយគណៈប្រតិភូយើង ពិភាក្សាជាមួយស្ថានទូតជប៉ុន នៅភ្នំពេញផងដែរ ។ ដោយធ្លាប់បានរៀនសូត្រនៅវត្តឧណ្ណាលោម និងធ្លាប់បានអានសៀវភៅនៅក្នុងបណ្ណាល័យរបស់ពុទ្ធសាសនបណ្ឌិត្យ លោក ស៊ីណូហារ៉ា បានសន្យាថា លោកនឹងខិតខំប្រឹងប្រែងជួយពុទ្ធសាសនបណ្ឌិត្យឱ្យអស់ពីសមត្ថភាព និងលទ្ធភាពរបស់លោក ។

នៅវេលារសៀលថ្ងៃ ២៧-១០-៩៥ គណៈប្រតិភូ បានអញ្ជើញទៅសំដែងការគួរសមចំពោះអង្គការ JSRC នៅទីស្នាក់ការកណ្តាល នាទីក្រុងតូក្យូ ។ នៅក្នុងឱកាសនោះ គណៈប្រតិភូបានទទួលស្វាគមន៍ដោយលោក ជីត្សុ ជោ អារីម៉ា អគ្គ-លេខាធិការ នៃអង្គការ JSRC ព្រមទាំងបុគ្គលិកជាច្រើនរូបទៀត ។ បន្ទាប់ពីបានស្តាប់របាយការណ៍ត្រួសៗ ស្តីអំពីរចនាសម្ព័ន្ធចាត់តាំងរបស់អង្គការ JSRC នៅប្រទេសនានា នៅអាស៊ីអាគ្នេយ៍ មានប្រទេសថៃ ឡាវ កម្ពុជា ដែលរៀបរាប់ដោយលោក អារីម៉ា មក ឯកឧត្តម ឈន អៀម ក៏បានរាយការណ៍អំពីសកម្មភាពការងារដែលពុទ្ធសាសនបណ្ឌិត្យ សហការជាមួយអង្គការ JSRC នៅភ្នំពេញ បានបំពេញប្រកបដោយផ្លែផ្កាជាទីសង្ឃឹម និងជាទីទំនុកទុកចិត្តទៅអនាគត ។ ឯកឧត្តម ឈន អៀម បានសំណូមពរដល់អង្គការ JSRCឱ្យបន្តជួយឧបត្ថម្ភដល់ពុទ្ធសាសនបណ្ឌិត្យតទៅទៀត ទំរាំមានលទ្ធភាពដំណើរការដោយខ្លួនឯងបាន ។ ជាមួយគ្នានេះដែរ ឯកឧត្តម ឈន អៀម បានធ្វើបាឋកថាដោយសង្ខេប ស្តីអំពីពុទ្ធសាសនបណ្ឌិត្យនៅកម្ពុជា ដើម្បីជាទីសណ្តាប់ចំពោះបុគ្គលិករបស់ JSRC ដែលមានបំណងចង់ស្វែង

យល់អំពីពុទ្ធសាសនានៅកម្ពុជា ។ អង្គការ JSRC បានសំដែងនូវការសរសើរលើកទឹកចិត្តចំពោះពុទ្ធសាសនបណ្ឌិត្យ និងសន្យាថាបន្តជួយឧបត្ថម្ភជ្រោមជ្រែងដល់ការស្តារ និងអភិវឌ្ឍន៍ពុទ្ធសាសនានៅកម្ពុជាឡើងវិញ តាមលទ្ធភាពដែលអាចធ្វើទៅបាន ។

នៅល្ងាចថ្ងៃទី ២៧-១០-៩៥ គណៈប្រតិភូបានជួបពិភាក្សាការងារ និងពិសាភោជនាហារ ជាមួយលោកខូណូ អគ្គលេខាធិការនៃអង្គការ រីស្សូ កូសី-កៃ ។ កិច្ចពិភាក្សាក្នុងពេលនោះ ផ្តោតទៅលើកម្មវិធីសាងសង់ពុទ្ធសាសនបណ្ឌិត្យថ្មី នៅក្នុងឆ្នាំ ១៩៩៦ និងកម្មវិធីជួបជាមួយអ្នកបង្កើតអង្គការ រីស្សូ កូសី-កៃ ព្រមទាំងសមាជិកនៃអង្គការនេះរាប់ម៉ឺននាក់នៅថ្ងៃទី ២៨-១០-៩៥ ។

នៅព្រឹកថ្ងៃ ២៨-១០-៩៥ គណៈប្រតិភូបានអញ្ជើញទៅសំដែងការគួរសមចំពោះអ្នកដឹកនាំនៃអង្គការ រីស្សូកូសីកៃ (RKK) ដែលមានព្រះតេជព្រះគុណនីវ៉ាណូ ជាស្ថាបនិក ។ អង្គការរីស្សូ កូសី-កៃ ជាអង្គការពុទ្ធសាសនា ដែលមានសុទ្ធតែគ្រហស្ថ បង្កើតដោយព្រះតេជព្រះគុណ នីវ៉ាណូ ។ នៅក្នុងឆ្នាំ ១៩៩៥ នេះ ព្រះតេជព្រះគុណ នីវ៉ាណូ ដែលជាស្ថាបនិកនៃអង្គការ RKK មានព្រះជន្មគម្រប់ ៩០ ឆ្នាំ ។ ដើម្បីជាកិច្ចរំលឹកដល់ខួបកំណើតទី ៩០ នៃស្ថាបនិកជាទីគោរពរបស់អង្គការ RKK នេះ ទើបអង្គការនេះ សម្រេចជួយសាងសង់អគារមួយខ្នង ជូនចំពោះពុទ្ធសាសន-បណ្ឌិត្យយើង ។ នៅក្នុងឱកាសនោះ ឯកឧត្តម ឈន អៀម បានថ្លែងសុន្ទរកថាស្វាគមន៍ និងអរគុណ ចំពោះមុខអង្គប្រជុំនៃពុទ្ធិកសមាគម RKK ដែលមានមហាជនចំនួនប្រមាណ ៣.០០០ នាក់ ។ គណៈប្រតិភូ បានទទួលកិត្តិយសយ៉ាងធំធេងមួយទៀត ពីអង្គការ RKK ដោយបានទទួលការអនុញ្ញាតអោយចូលជួបព្រះតេជព្រះគុណ និវ៉ាណូ ដែលអ្នកបង្កើតអង្គការ RKK និងព្រះតេជព្រះគុណ និវ៉ាណូប្រធានរបស់អង្គការ RKK ដោយផ្ទាល់ ដើម្បីសំដែងអំណរស្វាគមន៍ និងរាយ-

ការណ៍បន្ថែមអំពីដំណើរការសាងសង់ពុទ្ធសាសនបណ្ឌិត្យ នៅនាឆ្នាំខាងមុខ ។ ថ្នាក់ដឹកនាំជាន់ខ្ពស់នៃអង្គការ RKK ទាំងអស់ក៏បានចូលរួមក្នុងឱកាសដ៏កម្រនោះដែរ ។ ព្រះតេជព្រះគុណ (ស្ថាបនិក) នីវ៉ាណូ បានសំដែងនូវសេចក្តីសោមនស្សរីករាយក្រៃលែងចំពោះគណៈប្រតិភូ ដែលអញ្ជើញទៅធ្វើទស្សកិច្ចនៅទីស្នាក់ការកណ្តាលរបស់អង្គការ រីស្សូ កូ សី.កៃ ព្រមទាំងសំដែងការពេញចិត្តចំពោះគម្រោងរួមនៃសំណង់របស់ពុទ្ធសាសនបណ្ឌិត្យ ។ អង្គការ RKK បានសុំអោយលោក យី ធន់ ទីប្រឹក្សាក្រសួងធម្មការ និងសាសនា ជួយជំរុញការងារសាងសង់អោយបានឆាប់ ដើម្បីបញ្ចប់ដំណាក់កាលទីមួយ នៅក្នុងខែ ១០ ឆ្នាំ ១៩៩៦ ។ ដំណើរទស្សនកិច្ចនៅទីស្នាក់ការកណ្តាលនៃអង្គការ RKK បានបញ្ចប់នៅម៉ោង ១៣:៣០ នៃថ្ងៃ២៨. ១០.៩៥ ដដែល បន្ទាប់ពីពិធីពិសាភោជនាហារថ្ងៃត្រង់ ដែលរៀបចំឡើងដោយអង្គការ RKK ដើម្បីជាកិត្តិយសចំពោះគណៈប្រតិភូយើង ។

នៅម៉ោង ១៤:០០ រសៀលថ្ងៃដដែល គណៈប្រតិភូបានអញ្ជើញទៅសំដែងការគួរសមចំពោះអង្គការ WCRP ( អង្គការពិភពលោកខាងសាសនា និងសន្តិភាព ) ។ នៅក្នុងឱកាសនោះ លោក ណូប៊ូតុស៊ី ម៉ាស៊ុដា អគ្គលេខាធិការរងនៃអង្គការ WCRP និងលោក យោស៊ីហ្គា មន្ត្រីរបស់ WCRP បានសម្តែងអំណរស្វាគមន៍ចំពោះគណៈប្រតិភូយ៉ាងរាក់ទាក់កក់ក្តៅ ។ ជាកិច្ចឆ្លើយតប ឯកឧត្តម ឈន អៀម បានរៀបរាប់អំពីប្រវត្តិនៃទំនាក់ទំនងរវាងពុទ្ធសាសនបណ្ឌិត្យ និងអង្គការ WCRP ជាពិសេសអំពីអំណោយដ៏មានសារសំខាន់ ដែល WCRP បានផ្តល់អោយពុទ្ធសាសនបណ្ឌិត្យកន្លងមក មានម៉ាស៊ីន កុំព្យូទ័រ . រថយន្តដឹកសៀវភៅ និង បោះពុទ្ធផ្សាយទស្សនាវដ្តីកម្ពុជសុរិយាជាដើម ធ្វើអោយពុទ្ធសាសនបណ្ឌិត្យមានលទ្ធភាពដំណើរការបានជាប្រក្រតី ជារៀងរហូតមកដល់សព្វថ្ងៃ ។

លោកអគ្គលេខាធិការរង ម៉ាស៊ុដា បានសម្តែងនូវសេចក្តីសប្បាយរីករាយ

ចំពោះជោគជ័យ ដែលកើតបានពីកិច្ចសហប្រតិបត្តិការរវាងអង្គភាពទាំងពីរ ហើយសង្ឃឹមថាទៅអនាគត នឹងមានរីកចំរើនកាន់តែល្អជាងទៀត ។

នៅវេលាម៉ោង ១៦:០០ ល្ងាច គណៈប្រតិភូបានអញ្ជើញទៅសម្តែងការគួរសម ចំពោះឯកឧត្តមឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសជប៉ុន ។ ចូលរួមក្នុងឱកាសនោះ មានឯកឧត្តម ទ្រឿង មាលី ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសជប៉ុន ឯកឧត្តម ធាម ឈុនអ៊ី រដ្ឋមន្ត្រីទីប្រឹក្សាអមស្ថានឯកអគ្គរាជទូត ឯកឧត្តម តាំ កុសល លេខាធិការទី២ទទួលបន្ទុកកិច្ចការវប្បធម៌ ឃោសនាការ និងពត៌មាន ប្រចាំស្ថានឯកអគ្គរាជទូត ។ ខាងភាគីជប៉ុន មានលោកសាស្ត្រាចារ្យ អ្វូណូហារ៉ាវ៉ា នៃសកលវិទ្យាល័យឥស៊ីគូបា និងលោក ណូដា មន្ត្រីនៃអង្គការ JSRC ចូលរួមផងដែរ ។ ខណៈនោះឯកឧត្តម ឈន រៀម បានធ្វើរបាយការណ៍ជូនឯកឧត្តមឯកអគ្គរាជទូត អំពីគោលបំណងនៃទស្សនកិច្ចរបស់លោក នៅទីក្រុងតូក្យូលើកនេះ ព្រមទាំងបានរាយការណ៍ត្រួសៗ អំពីទល្ធផលដែលគណៈប្រតិភូទទួលបានក្នុងរយៈបីថ្ងៃកន្លងមក ។ ឯកឧត្តមឯកអគ្គរាជទូត បានសម្តែងសេចក្តីសោមនស្សរីករាយចំពោះលទ្ធផលដែលគណៈប្រតិភូទទួលបាន ហើយសន្យាថានឹងជួយពន្យល់ភាគីជប៉ុនអោយយល់អំពីសេចក្តីត្រូវការចាំបាច់នៃពុទ្ធសាសនានៅកម្ពុជា ដែលប្រជាជនខ្មែរចាត់ទុកជាព្រលឹងរបស់វប្បធម៌ អក្សរសាស្ត្រជាតិ ។

នៅថ្ងៃទី២៩.១០.៩៥ គណៈប្រតិភូបានអញ្ជើញទៅជួបសំណេះសំណាលជាមួយជនភៀសខ្លួនខ្មែរ នៅទីក្រុងយោគោហាម៉ា ។ នៅវេលាយប់ថ្ងៃដដែលនោះ គណៈប្រតិភូបានចូលរួមក្នុងពិធីបើកអង្គប្រជុំមួយ ដែលចាត់ចែងឡើងដោយអង្គការ JSRC នៅក្នុងវត្ត បាអ៊ិកូអេន នៅទីក្រុងតូក្យូ ។

នៅថ្ងៃទី ៣០.១០.៩៥ គណៈប្រតិភូបានជួបសំណេះសំណាលជាមួយ

លោកសាស្ត្រាចារ្យ ក្លូម៉ៃ នៃសកលវិទ្យាល័យ ត្សឹគូបា និងបានទៅទស្សនាស្រាវជ្រាវក្នុងបណ្ណាល័យរបស់មហាវិទ្យាល័យប្រវត្តិវិទ្យា និងនរវិទ្យា នៃសកលវិទ្យាល័យ ត្សឹគូបា ។

នៅវេលារសៀលថ្ងៃ ៣០.១០.៩៥ គណៈប្រតិភូបានត្រឡប់ទៅទីក្រុងតូក្យូវិញ ដើម្បីត្រៀមចូលរួមក្នុងសន្និសីទអន្តរជាតិលើកទី១៧ នៃសហភាពសាសនាពិភពលោក ។

នៅថ្ងៃ ៣១.១០.៩៥ អង្គសន្និសីទបានប្រព្រឹត្តទៅនៅក្នុងសាលប្រជុំរបស់វត្ត សិងហ្គុន និកាយប៊ូហ្សាន អស់រយៈពេលពេញមួយថ្ងៃ ។ ចូលរួមក្នុងអង្គសន្និសីទនោះ ក្រៅពីគណៈប្រតិភូមកពីនិកាយផ្សេងៗ និងអង្គការសាសនាផ្សេងៗរបស់ជប៉ុន មានគណៈប្រតិភូពីព្រះរាជាណាចក្រកម្ពុជា ដែលមានព្រះតេជព្រះគុណ ហេង មណីចិន្តា ជាតំណាង ឯកឧត្តម ឈន អៀម និងលោក យី ធន់ ជាសមាជិកសង្កេតការណ៍, គណៈប្រតិភូទៅពីប្រទេសភូមា មានព្រះសង្ឃបីអង្គដែលដឹកនាំដោយព្រះតេជព្រះគុណ អ៊ូ ខេ មិនដា គណៈប្រតិភូមូស្លីមនៃប្រទេសឥណ្ឌូនេស៊ី គណៈប្រតិភូគ្រីស្តសាសនាពីប្រទេសហ្វីលីពីន និងតំណាងសម្តេចដាឡៃឡាម៉ា ។ នៅក្នុងពិធីលៀងសាយភោជន៍ ដែលចាត់ចែងជាកិត្តិយសចំពោះភ្ញៀវកិត្តិយសដែលបានចូលរួមក្នុងសន្និសីទលើកទី ១៧ របស់សហភាពសាសនាពិភពលោក ឯកឧត្តម ឈន អៀម ត្រូវបានគេអញ្ជើញឱ្យឡើងថ្លែងចាប់អារម្មណ៍ និងរៀបរាប់អំពីស្ថានភាពព្រះពុទ្ធសាសនានៅកម្ពុជា ដែលធ្វើឱ្យភ្ញៀវទាំងអស់ចាប់អារម្មណ៍យ៉ាងខ្លាំង ។

នៅថ្ងៃទី ០១ វិច្ឆិកា ១៩៩៥ គណៈប្រតិភូយើងបានចូលរួមក្នុងដំណើរទស្សនកិច្ចតាមវត្តធំៗ នៅក្នុងទីក្រុងតូក្យូ រៀបចំឡើងដោយពុទ្ធិកសមាគមជប៉ុន ដែលមានព្រះតេជព្រះគុណ គេនស៊ី យ៉ាម៉ាគុជី ជាអគ្គលេខាធិការរង ជាអ្នកជូន

ដំណើរ ។ គណៈកម្មការទ្រទ្រង់វត្ត និងព្រះតេជព្រះគុណចៅអធិការគ្រប់វត្ត សុទ្ធតែបានសម្ដែងនូវមនោសញ្ចេតនារាក់ទាក់ និងលើកទឹកចិត្តចំពោះគណៈប្រតិភូក្នុងការស្ដារឡើងវិញនូវព្រះពុទ្ធសាសនានៅកម្ពុជា ។ ជាមួយគ្នានោះដែរ គណៈប្រតិភូយើងក៏បានទៅទស្សនាទីស្នាក់ការរបស់គណៈកម្មការខាងសាសនាជប៉ុន ដើម្បីសហភាពពិភពលោក ជាមួយគណៈប្រតិភូដែលអញ្ជើញមកពីប្រទេសភូមា ។

នៅថ្ងៃទី ០៣-១១-៩៥ គណៈប្រតិភូបានទៅធ្វើទស្សនកិច្ចនៅសារមន្ទីរជាតិខាងប្រវត្តិសាស្ត្រ នៅទីក្រុងតូក្យូ ។

នៅថ្ងៃទី ០៤-១១-៩៥ គណៈប្រតិភូបានធ្វើបាឋកថាម្ដងទៀតជូនចំពោះអង្គការក្រៅរដ្ឋាភិបាល និងអង្គការសារពត៌មាននានា ដែលចង់ដឹងអំពីប្រវត្តិពុទ្ធ-សាសនា និងស្ថានភាពបច្ចុប្បន្ន នៃពុទ្ធសាសនានៅកម្ពុជា ។ ចូលរួមក្នុងឱកាសនោះមានលោកសាស្ត្រាចារ្យ អ៊ី ស៊ីហ្សាវ៉ា ដែលជាអ្នកជំនាញការខាងបុរាណវិទ្យាផងដែរ ។ ក្រៅពីនោះ មានអង្គការ និងតំណាងស្ថាប័នរដ្ឋធំៗបានចូលរួម ជាអាទិ៍មានអង្គការ RKK អង្គការមូលនិធិតូយ៉ូតា អង្គការមូលនិធិជប៉ុន, តំណាងបណ្ណាល័យរបស់សភាជាតិជប៉ុន, តំណាងសកលវិទ្យាល័យ និងអ្នកសារពត៌មានជាច្រើនរូបទៀត ។ បាឋកថា បានប្រព្រឹត្តទៅនៅក្នុងសាលប្រជុំនៃមហាវិទ្យាល័យ វ៉ាសេដា-ហ្វូសៀន នាទីក្រុងតូក្យូ ។

នៅថ្ងៃទី ០៥-១១-៩៥ គណៈប្រតិភូបានបន្តដំណើរទៅទស្សនាសាខាអង្គការ JSRC នៅក្រុងជីបា ដែលស្ថិតនៅចម្ងាយប្រមាណ ៧០ គ.ម ពីទីក្រុងតូក្យូ ។ នៅទីនោះ គណៈប្រតិភូបានទទួលស្វាគមន៍ពីព្រះតេជព្រះគុណ សីក្យូ មូចាតូ ចៅអធិការវត្ត សូតូស៊្យូ ហ្វូតូ សេនជិ និងជាប្រធានគណៈកម្មការបោះពុម្ពគម្ពីរព្រះត្រៃបិដកឡើងវិញ ព្រមទាំងសមាជិកនៃគណៈកម្មការនេះជាច្រើនរូបទៀត ដូចជាលោកឧបាសិកា តូគិ មូចាតូ លោក ហិសាអូ កាសាហារ៉ា ព្រះតេជព្រះគុណ អេអិជិ

ស៊ីណូហារ៉ា និងលោក យ៉ាបិ ជាដើម ។ នៅក្នុងឱកាសទស្សនកិច្ចសាខាអង្គការ JSRC នៅជីបានេះ គណៈប្រតិភូបានចូលរួមក្នុងពិធីសមោសរប្រជាកសិករជប៉ុន ដើម្បីសង្គ្រោះដល់កុមារពិការ ដែលចាត់ចែងដោយព្រះតេជព្រះគុណ ស៊ីណូហារ៉ា និងព្រះតេជព្រះគុណម៉ូចាត្សូ ។

គណៈប្រតិភូយើងបានសំរាកមួយយប់នៅក្នុងវត្ត សូត្តស្សឹ ហ្វុត្តសេនជិ ដើម្បីបានសំណេះសំណាលជាមួយពុទ្ធបរិសទ័ជើងវត្ត ដែលភាគច្រើនជាកសិករ ។

នៅព្រឹកថ្ងៃទី ០៦.១១.៩៥ គណៈប្រតិភូបានធ្វើដំណើរទៅទស្សនាវត្តមួយនៅជនបទ ដែលជាអាវាសរបស់ព្រះតេជព្រះគុណ អេអ៊ីជិ ស៊ីណូហារ៉ា ។ ព្រះតេជព្រះគុណអង្គនេះ ជាសមាជិកដ៏សកម្មបំផុតរបស់អង្គការ JSRC ក្នុងការជួយបោះពុម្ពគម្ពីរព្រះត្រៃបិដកខ្មែរឡើងវិញ ។

នៅពេលរសៀលថ្ងៃ ០៦.១១.៩៥ គណៈប្រតិភូបានត្រឡប់ទៅទីក្រុងតូក្យូវិញ ដើម្បីជួបពិភាក្សាជាមួយមូលនិធិជប៉ុន សម្រាប់អាស៊ី ។ ក្នុងឱកាសនោះ គណៈប្រតិភូយើង បានលើកសំណើសុំអោយមូលនិធិនេះជួយផ្តល់ថវិកាខ្លះសម្រាប់ការស្រាវជ្រាវ និងបោះពុម្ពផ្សាយ ។ លោក ស៊ុយ ស៊ុយគី ត្សុត្តមុ នៃនាយកដ្ឋានផ្លាស់ប្តូរខាងបញ្ញា ១ និងលោក គុប្ហូ កាហ្សឹអាគិ នាយកផ្នែកផ្លាស់ប្តូរខាងបញ្ញា ១របស់មូលនិធិ បានសន្យាថានឹងជួយពិនិត្យគម្រោងដែលភាគីកម្ពុជា នឹងលើកសំណើទៅមូលនិធិ នាពេលខាងមុខ ។

បន្ទាប់មកទៀត នៅម៉ោង ១៦:០០ នៃថ្ងៃទី ០៦.១១.៩៥ ដដែល គណៈប្រតិភូបានអញ្ជើញទៅជួបសំណេះសំណាលជាមួយលោកសាស្ត្រាចារ្យ អ៊ីស៊ីហ្សាវ៉ា នៃសកលវិទ្យាល័យ សូហ្វីយ៉ា នាទីក្រុងតូក្យូ ។ ក្នុងឱកាសនោះ គណៈប្រតិភូយើង បានទៅទស្សនាបណ្ណាល័យរបស់សកលវិទ្យាល័យ និងកន្លែងរក្សាទុកឯកសារកម្រៗរបស់បណ្ណាល័យ ។ គណៈប្រតិភូក៏បានចូលរួមផងដែរ នៅក្នុងការពិភាក្សាអំពី

គម្រោងរៀបចំភូមិមួយនៅស្រះស្រង់ សៀមរាប អង្គរ របស់សកលវិទ្យាល័យ សូហ្វីយ៉ា ដែលរៀបចំឡើងដោយលោកសាស្ត្រាចារ្យ អិនដូ ណូប៊ូអូ ។ ចូលរួមក្នុងឱកាសនោះដែរ មានលោកសាស្ត្រាចារ្យ អុគីរ៉ា សាដាអូ នៃសកលវិទ្យាល័យ ស៊្វីរី លោកបណ្ឌិត វិសូករ ឡៅ គឹមលាង និងនិស្សិតខ្មែរ-ជប៉ុន ជាច្រើនរូបទៀត ។

បន្ទាប់ពីពិធីលៀងសាយភោជន៍ ដែលចាត់ចែងដោយលោកសាស្ត្រាចារ្យ អ៊ីស៊ីហ្សាវ៉ា ដើម្បីជាកិត្តិយសដល់គណៈប្រតិភូយើងមក គណៈប្រតិភូក៏បានលាម្ចាស់ផ្ទះត្រឡប់ទៅព្រលានយន្តហោះណារីតា ដើម្បីរៀបដំណើរត្រឡប់មកប្រទេសកម្ពុជាវិញ ។

នៅព្រឹកថ្ងៃទី ០៧-១១-៩៥ គណៈប្រតិភូយើងបានចេញដំណើរពីទីក្រុងតូក្យូ ឆ្ពោះមកទីក្រុងបាងកក ។

នៅថ្ងៃទី ០៨-១១-៩៥ ដោយបានទទួលការឧបត្ថម្ភពីអង្គការ JSRC នៅបាងកក គណៈប្រតិភូយើងបានទៅធ្វើទស្សនកិច្ចស្រាវជ្រាវ នៅពុទ្ធិកមហាវិទ្យាល័យពីរគឺ មហាចុល្លាឡុងកន ពុទ្ធិកមហាវិទ្យាល័យនៃ វត្តមហាធាតុ ផ្នែកមហានិកាយ និងព្រះមហាមង្កុដ ពុទ្ធិកមហាវិទ្យាល័យនៃវត្តបវរនិវាត ផ្នែកធម្មយុត្តិកនិកាយ ។ នៅក្នុងពិធីសំណេះសំណាលជាមួយថ្នាក់ដឹកនាំមហាវិទ្យាល័យទាំងពីរ ឯកឧត្តម ឈន អៀម បានលើកឡើងអំពីការលំបាកខ្វះខាតខាងផ្នែកពុទ្ធិកសិក្សានៅកម្ពុជា នាបច្ចុប្បន្នកាលនេះ ។ នៅក្នុងកិច្ចសំណេះសំណាលទាំងពីរកន្លែងនេះ គណៈប្រតិភូ សុទ្ធតែបានទទួលស្វាគមន៍ដោយរាក់ទាក់កក់ក្ដៅពីថ្នាក់ដឹកនាំមហាវិទ្យាល័យ ។ ថ្នាក់ដឹកនាំមហាវិទ្យាល័យទាំងពីរ សុទ្ធតែបានត្រៀមទទួលសមណសិស្សរបស់ខ្មែរ ដែលចង់ទៅបន្តការសិក្សានៅមហាវិទ្យាល័យទាំងពីរ ប៉ុន្តែសុំអោយភាគីកម្ពុជាធ្វើទំនាក់ទំនងជាផ្លូវការ តាមរយៈព្រះរាជរដ្ឋាភិបាល ។ ក្រោយពីនោះ គណៈប្រតិភូបានទទួលសៀវភៅ ឯកសារមួយចំនួន សំរាប់តំកល់ទុកនៅក្នុងបណ្ណាល័យ

របស់ពុទ្ធសាសនបណ្ឌិត្យផងដែរ ។

ថ្ងៃទី ០៩-១១-៩៥ គណៈប្រតិភូបានអញ្ជើញទៅទស្សនាទីស្នាក់ការរបស់ពុទ្ធិកសមាគមពិភពលោក ដែលប្រទេសកម្ពុជាយើងពីមុន ក៏ធ្លាប់ជាសមាជិក របស់សមាគមនេះដែរ ។ នៅក្នុងកិច្ចសំណេះសំណាលជាមួយថ្នាក់ដឹកនាំរបស់សមាគម ឯកឧត្តម ឈន អៀម បានជំរាបអំពីបំណងរបស់ពុទ្ធិកសមាគមកម្ពុជរដ្ឋ ដែលចង់ភ្ជាប់សមាជិកភាពជាមួយពុទ្ធិកសមាគមពិភពលោកឡើងវិញ ។ ឆ្លើយតបនឹងសំណូមពររបស់គណៈប្រតិភូយើង ម្ចាស់ផ្ទះបានសំដែងអំណរស្វាគមន៍ចំពោះការភ្ជាប់សមាជិកភាពឡើងវិញរបស់ពុទ្ធិកសមាគមកម្ពុជរដ្ឋ ដោយគ្រាន់តែដាក់ពាក្យសុំចូលជាថ្មី និងបង់វិភាគទានប្រចាំឆ្នាំតែប៉ុណ្ណោះ ។ លោកប្រាងសង ប៊ុនចឹម អនុប្រធាន និងហេរញ្ញិកកិត្តិយសរបស់ពុទ្ធិកសមាគមពិភពលោក បានមានប្រសាសន៍ថា លោកមានបំណងប្រាថ្នាចង់ឃើញកម្ពុជា បានចូលជាសមាជិកនៃពុទ្ធិកសមាគមពិភពលោក ក្នុងពេលឆាប់ៗ ខាងមុខនេះ ។

បន្ទាប់ពីបានបំពេញទស្សនកិច្ចដោយជោគជ័យ នៅទីក្រុងតូក្យូ និងនៅទីក្រុងបាងកក អស់រយៈពេល ១៦ ថ្ងៃមក គណៈប្រតិភូនៃក្រសួងធម្មការ និងសាសនា ដែលដឹកនាំដោយឯកឧត្តម ឈន អៀម បានវិលត្រឡប់មកដល់មាតុភូមិវិញ នៅថ្ងៃ សុក្រ ទី ១០ ខែវិច្ឆិកា ១៩៩៥ ដោយសុវត្ថិភាព ។

ភ្នំពេញ, ថ្ងៃទី ១២ វិច្ឆិកា ឆ្នាំ ១៩៩៥

**យី ធន់**

ទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា

# ការបែងចែកគម្ពីរព្រះត្រៃបិដក

គម្ពីរព្រះត្រៃបិដកខ្មែរ ១១០ ភាគ (ព្រះវិន័យ ១៣ ភាគ, ព្រះសូត្រ ៦៤ ភាគ និងព្រះអភិធម្ម ៣៣ ភាគ) ត្រូវបានបោះពុម្ពឡើងវិញ តាមសំណូមពររបស់ពុទ្ធសាសនបណ្ឌិត្យ នៃក្រសួងធម្មការ និងសាសនា ដោយបានទទួលការឧបត្ថម្ភដ៏ឧត្តុង្គឧត្តមពីអង្គការជំនួយសូត្តូស៊ូជប៉ុន និងអង្គការពុទ្ធសាសនាជប៉ុន ដែលមានព្រះតេជព្រះគុណ សីក្យូ មូចាត្សូ ជាប្រធាន ។គណៈកម្មការបោះពុម្ពព្រះត្រៃបិដកជប៉ុន និងអង្គការជំនួយសូតស៊ូជប៉ុន បានប្រគល់គម្ពីរព្រះត្រៃបិដកចំនួន ១.០០០ ចប់ ចំពោះក្រសួងធម្មការ និងសាសនា ។ ក្រោយធ្វើពិធីប្រគល់ដ៏មហោឡារិក នៅថ្ងៃទី ២០ មិថុនា ១៩៩៥ នៅរាជធានីភ្នំពេញ រួចមក, ក្រសួងធម្មការនិងសាសនា បានធ្វើការបែងចែកគម្ពីរព្រះត្រៃបិដកទាំង ១.០០០ ចប់នោះ ទៅតាមវត្តអារាម នានា និងស្ថាប័នរដ្ឋមួយចំនួន ក្នុងប្រទេស ។

ចំនួនវត្ត ដែលបានទទួលគម្ពីរព្រះត្រៃបិដករួចមកហើយ គឺ :

*ក/ នៅក្នុងរាជធានីភ្នំពេញ វត្តចំនួន ៣៤ បានទទួល ១ ចប់ ក្នុង ១ វត្ត ត្រូវជា ៣៤ ចប់ (សេចក្តីសំរេចលេខ ១៦៣_៩៥ កធស_០៥/០៨/៩៥) :*

១. វត្ត បទុមវតី
២. វត្ត ឧណ្ណាលោម
៣. វត្ត មហាមន្ត្រី
៤. វត្ត ព្រះពុទ្ធមានបុណ្យ
៥. វត្ត នាគវ័ន
៦. វត្ត ទួលសង្កែ
២៨. វត្ត ខ្នារ
២៩. វត្ត អង្គតាម៉ិញ
៣០. វត្ត សំបួរមាស
៣១. វត្ត ញាណរង្សី
៣២. វត្ត ឫស្សីស្រស់
៣៣. វត្ត អរុណវតី

៧. វត្ត សន្សំកុសល
៨. វត្ត ជម្ពូវ័ន
៩. វត្ត ទួលទំពូង
១០. វត្ត ឧត្តរាវតី
១១. វត្ត ពោធិសត្ថារាម
១២. វត្ត សំរោងអណ្តែត
១៣. វត្ត ក្រាំងធ្នង់
១៤. វត្ត សារាវ័នតេជោ
១៥. វត្ត កោះ
១៦. វត្ត មង្គលវ័ន
១៧. វត្ត ទឹកថ្លា (ឃុំទឹកថ្លា)
២៤. វត្ត នួនមណី
២៥. វត្ត ស្វាយពពៃ
២៦. វត្ត សំពៅមាស
២៧. វត្ត និរោធរង្សី
២៨. វត្ត តាព្រហ្មមានជ័យ
២៩. វត្ត តាំងក្រសាំងខាងជើង
៣០. វត្ត សំរោងផលអណ្តែត
៣១. វត្ត ធម្មត្រ័យ
៣២. វត្ត លង្កា
៣៣. វត្ត ប្រជុំសាគរ
៣៤. វត្ត ទឹកថ្លា (ភ្លើងឆេះរទេះ)

*ខ/ នៅក្នុងខេត្តកណ្តាល វត្តចំនួន ៥៤ បានទទួល ១ ចប់ ក្នុង ១ វត្ត ត្រូវជា ៥៤ ចប់ (សេចក្តីសំរេចលេខ ១៧០_៩៥ កធស / ១៦/០៨/៩៥) ដូចមាន ខាងក្រោម :*

១. វត្ត តាខ្មៅ ( មេគណខេត្ត )
២. វត្ត ជ្រោយអំពិល ( អនុគណ )
៣. វត្ត កំពង់សំបួរ ( អនុគណ )
៤. វត្ត ព្រៃកអំពិល ( អនុគណ )
៥. វត្ត ប្រជុំនទី ( អនុគណ )
៦. វត្ត សុវណ្ណសាគរ ( អនុគណ )
៧. វត្ត កោកកាក ( អនុគណ )
២៩. វត្ត វិចិត្តការាម
៣០. វត្ត ជ្រៃមាសសាគរ
៣១. វត្ត កែវមណីជោត
៣២. វត្ត សុវណ្ណារី
៣៣. វត្ត ឈ្មូងលៀប
៣៤. វត្ត នាគវនារាម
៣៥. វត្ត ប្រាសាទ

៨. វត្ត ភូមិថ្មី ( អនុគណ )
៩. វត្ត សង្ខ ( អនុគណ )
១០. វត្ត សិរីមង្គល ( អនុគណ )
១១. វត្ត ព្រែកទម្លាប់ ( អនុគណ )
១២. វត្ត វិហារសួគ៌ ( អនុគណ )
១៣. វត្ត មុនីប្រសិទ្ធិវង្ស
១៤. វត្ត កំពង់ភ្នំក្នុង
១៥. វត្ត ទឹកឃ្លាំង
១៦. វត្ត សិរីបន្ទាយដែក
១៧. វត្ត ជេដ្ឋាឧត្តម
១៨. វត្ត ស្លាកែត
១៩. វត្ត កៀនស្វាយក្នុង
២០. វត្ត ជ័យឧត្តម
២១. វត្ត ព្រែកស្តី
២២. វត្ត កោះធំ
២៣. វត្ត បទុមរង្សី
២៤. វត្ត ឧទុម្ពរ
២៥. វត្ត ល្វា-ស
២៦. វត្ត ទេពប្រណម្យ
២៧. វត្ត ទឹកវិល
២៨. វត្ត ខ្ពប

៣៦. វត្ត ស្រះស្រង់
៣៧. វត្ត សុវណ្ណវតី
៣៨. វត្ត កោះសុក្រ
៣៩. វត្ត ចតុមុខារាម
៤០. វត្ត ពាមមង្គល
៤១. វត្ត កោះសម្ផារាម
៤២. វត្ត ស្អាងភ្នំ
៤៣. វត្ត អណ្តែត
៤៤. វត្ត សាឡុង
៤៥. វត្ត ស៊ីសុវត្ថិរតនារាម
៤៦. វត្ត សណ្តារ
៤៧. វត្ត មាត់ក្រសាស់ក្នុង
៤៩. វត្ត វិហារហ្លួង
៥០. វត្ត អន្លង់រមៀត
៥១. វត្ត ដូនស
៥២. វត្ត ដីណាក់អំពិល
៥៣. វត្ត មជ្ឈិមសរារាម
៥៤. វត្ត សុភានុវង្ស

---

*( នៅមានតទៅខេត្តផ្សេងទៀត )*

សាធុជន ស្រឡាញ់បុណ្យ ងាយធ្វើបុណ្យ
ឯទុរជន ចិត្តទំរន់ ធ្វើពុំកើត
បើបាបវិញ គេងាយធ្វើ ពុំញញើត
អ្នកប្រាជ្ញឆើត ធ្វើពុំកើត ព្រោះខ្ពើមបាប ។

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



ប្រាសាទបន្ទាយក្ដី . ( សិល្បៈពុទ្ធសាសនា ចុងសតវត្សទី ១២ )

ឆ្នាំទី ៤៩ លេខ ៤ ខែ តុលា - វិច្ឆិកា - ធ្នូ

ព.ស ២៥៣៩ គ.ស ១៩៩៥

ភ្នំពេញ



# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

ទីប្រឹក្សា : **ហៀន ចណ្ណរក្ខ**

នាយកការផ្សាយ : **ឈន អៀម**

និពន្ធនាយក : **យី ធន់**

និពន្ធនាយករង : **ឱម ខែម**

គណៈកម្មការនិពន្ធ

សម្ដេចព្រះធម្មលិខិត **លាស់ ឡាយ**, ព្រះមហាព្រហ្មមុនី **ហេង លាងហោ**,

លោក **ម៉ែន ប្រាង**, លោក **អាំ ឆន**,

## ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました.

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの宗教と文化の発展に貢献できれば幸いです。

## ACKNOWLEDGEMENT

The Kampuja Surya Magazine is specially printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC).

We pray that this magazine would contribute to the Friendship with Cambodian people and their religious and cultural preservation.

## និវេទនកថា

ទស្សនាវដ្តីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគម្រោងការងារ របស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោកស្តីពីសាសនានិងសន្តិភាព (WCRP) ហើយនិងគណៈកម្មាធិការជំនួយសូតូស៊ូជប៉ុន (JSRC) ។

យើងខ្ញុំអធិដ្ឋាន សូមឱ្យទស្សនាវដ្តីនេះ បានជាវិភាគទានរក្សាមិត្តភាពជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិសាសនានិងវប្បធម៌របស់ប្រជាជនកម្ពុជា ។

# មាតិកាអត្ថបទ

## I. អក្សរសិល្ប៍ពុទ្ធសាសនា

- ការថ្វាយព្រះភ្លើង និង ការចែកព្រះសារីរិកធាតុ
ព្រះសម្ពុទ្ធ ( លោក ម៉ែន ប្រាង និង អាំ ឆន ) ១
- ឧបស្សយានិសង្ស ( សម្ដេចព្រះសង្ឃរាជ ជួន ណាត ) ៧
- មយមាណវត្ថុ ( សម្ដេចព្រះសង្ឃរាជ ជួន ណាត ) ១៣
- អំពីភិក្ខុនីសង្ឃ ( លោក ឈន អៀម ) ២៤

## II. អក្សរសាស្ត្រទូទៅ

- វត្តអារាមជាមជ្ឈមណ្ឌលវប្បធម៌ របស់
ប្រជារាស្ត្រខ្មែរ ( លោក ឃី ធន់ ) ៤០
- បុណ្យមហាអំបុក ( លោក មៀច ប៉ុណ្ណ ) ៦៩
- ពុទ្ធកិច្ច ៥ យ៉ាង ( លោក វ៉ាយ វិបុល ) ៧៧
- ឆ្លូត ៨ យ៉ាង ( លោក នួច ជឹម ) ៧៨
- សេចក្ដីជូនដំណឹងពីចម្លើយកំណាព្យប្រស្នា និង
* កំណាព្យប្រស្នា ៨១

## III. កំណត់ និង ប្រវត្តិកាណ៍

- ការបែងចែកគម្ពីរព្រះត្រៃបិដក ( ត ) ៨៣
- កាលប្បវត្តិនៃសកម្មភាពសំខាន់ៗ របស់ពុទ្ធសាសនបណ្ឌិត្យ
ឆ្នាំ ១៩៩៥ ៨៧

# ការថ្វាយព្រះភ្លើង
# និង
# ការចែកព្រះសារីរិកធាតុព្រះសម្ពុទ្ធ

ថ្ងៃអង្គារ ១៥ កើតខែពិសាខ ឆ្នាំម្សាញ់ បញ្ចស័ក វេលាទៀបភ្លឺ ព្រះសម្ពុទ្ធទ្រង់និព្វាន [(១)] នៅក្រោមដើមរាំងភ្នំ ឧទ្យាននៃមល្លក្សត្រ ក្រុងកុសិនារា ដោយមានព្រះអនុរុទ្ធត្ថេរនិងព្រះអានន្ទត្ថេរ ព្រមទាំងភិក្ខុមួយចំនួនបានគង់នៅក្នុងទីនោះដែរ ។

ពួកភិក្ខុទាំងឡាយ ដែលមិនទាន់ប្រាសចាករាគៈ ក៏ផ្គងកំភួនដៃ កន្ទក់កន្ទេញ ផ្តួលខ្លួនបម្រះននៀលទៅមក ហាក់ដូចជាមានជើងដាច់ហើយថា ព្រះមានព្រះភាគទ្រង់ប្រញាប់បរិនិព្វានពេកណាស់ ។ ឯពួកភិក្ខុដែលប្រាសចាករាគៈហើយ មានសតិ និងសម្បជញ្ញៈ អត់សង្កត់ ដោយគិតថា សង្ខារទាំងឡាយមិនទៀងពិត ព្រោះហេតុនេះ បុគ្គលគប្បីបានសេចក្តីទៀងទាត់ ក្នុងខន្ធប្បវត្តិនេះអំពីណា ។ ពពួកទេវតា ក៏មានការសោកស្តាយ ខ្សឹកខ្សួល ដូចពួកភិក្ខុដែរ ។

ព្រះអនុរុទ្ធត្ថេរ បានឱ្យអានន្ទត្ថេរ និមន្តទៅថ្វាយដំណឹងនេះចំពោះពួកមល្លក្សត្រ ។ គ្រានោះ ពួកមល្លក្សត្រ អ្នកក្រុងកុសិនារា បាននាំយកគ្រឿងក្រអូប កម្រងផ្កា តូរ្យតន្ត្រី និងសំពត់ស ៥០០ គូ ចូលទៅគាល់ព្រះសរីរៈនៃព្រះមានព្រះភាគ ធ្វើពិតានសំពត់ ពាក់តែងរោង បារាំ អស់មួយថ្ងៃ ។ ពួកមល្លក្សត្រ និងអ្នកក្រុងកុសិនារា បាននាំគ្នាធ្វើសក្ការៈគោរពបូជាព្រះសរីរៈនៃព្រះមានព្រះភាគអស់រយៈពេល ៦ ថ្ងៃ ។ លុះដល់ថ្ងៃទី ៧ ទើបពួកមល្លក្សត្រ និងអ្នកក្រុងកុសិនារា គិតគ្នាថា យើង

---

(១) ព្រះអង្គផ្ទំលើគ្រែ យកព្រះកេសទៅទិសខាងជើង ក្នុងចន្លោះដើមសាលព្រឹក្សទាំងគូ ទ្រង់ផ្ទៀងទៅខាងស្តាំ យកព្រះបាទឆ្វេងតម្រួតលើព្រះបាទស្តាំ ។

និងដង្ហែព្រះសរីរៈព្រះសម្ពុទ្ធ ទៅតាមទិសខាងត្បូងក្រៅក្រុង ហើយថ្វាយព្រះភ្លើងនៅទិសខាងត្បូងនៃក្រុង ។

ពេលនោះ ពួកមល្លក្សត្រ ៨ អង្គ ដែលជាប្រធានបានជម្រះសីសៈ[១] ទ្រង់សំពត់ថ្មី ហើយនាំគ្នាលើកព្រះសរីរៈនៃព្រះមានព្រះភាគ តែមិនអាចនឹងលើករួចបាន ។ ពួកមល្លក្សត្រ និងអ្នកក្រុងកុសិនារា កើតមានការសង្ស័យណាស់ ចំពោះអព្ភូតហេតុដ៏ចំឡែកនេះ ហើយបានទូលសួរព្រះអនុរុទ្ធ ។ ព្រះអនុរុទ្ធតបថា បំណងរបស់ពួកទេវតាផ្សេងពីបំណងរបស់ពួកទ្រង់ គឺពួកទេវតាមានបំណងឱ្យយើងដង្ហែព្រះសរីរៈព្រះមានព្រះភាគទៅខាងជើង តាមទិសខាងជើងនៃក្រុង ហើយចូលទៅកាន់ក្រុងតាមទ្វារខាងជើង ហើយដង្ហែទៅត្រង់កណ្ដាល តាមទីកណ្ដាលនៃក្រុង ហើយចេញទៅតាមទ្វារខាងកើត ហើយថ្វាយព្រះភ្លើងក្នុងមកុដពន្ធនចេតិយ[២] របស់ពួកមល្លក្សត្រ ខាងកើតនៃក្រុង ។

លំដាប់នោះ ពួកមល្លក្សត្រក៏ទ្រង់ធ្វើតាមបំណងរបស់ពួកទេវតា ។ លុះដង្ហែព្រះសរីរៈនៃព្រះមានព្រះភាគទៅដល់មកុដពន្ធនចេតិយហើយ ពួកមល្លក្សត្រទូលសួរព្រះអានន្ទត្ថេរថា បពិត្រអានន្ទដ៏ចំរើន យើងទាំងឡាយនឹងប្រតិបត្តិក្នុងព្រះសរីរៈនៃព្រះមានព្រះភាគដូចម្ដេច ? ព្រះអានន្ទតបថា បពិត្រមហារាជ ពួកឥស្សរជនប្រតិបត្តិក្នុងសរីរៈស្ដេចចក្រពត្តិយ៉ាងណា ពួកមហាបពិត្រគប្បីប្រតិបត្តិក្នុងព្រះសរីរៈនៃព្រះមានព្រះភាគ យ៉ាងនោះចុះ ។

គ្រានោះ ពួកមល្លក្សត្រនាំគ្នារុំព្រះសរីរៈ នៃព្រះមានព្រះភាគដោយសំពត់ថ្មី លុះរុំដោយសំពត់ថ្មីហើយ ទើបរុំដោយសំឡី លុះរុំដោយសំឡីហើយ ក៏រុំដោយសំពត់ថ្មីថែមទៀត គឺរុំព្រះសរីរៈព្រះមានព្រះភាគ ដោយសំពត់ ៥០០ គូ ដោយទំនង

(១) កោរសក់ ។ (២) អដ្ឋកថា ថា សាលរាជាមង្គលសម្រាប់តែងព្រះអង្គរបស់ពួកមល្លរាជ ដែលគេធ្វើ វិចិត្រ រចនាក្បូរក្បាច់វិសេសណាស់ ។

នេះ ហើយតម្កល់ក្នុងមឈូសមាសដែលដាក់ប្រេង ហើយគ្របដោយមឈូសដទៃ ហើយធ្វើជើងថ្ករ ទើបថ្វាយព្រះភ្លើងនូវព្រះសរីរៈនៃព្រះមានព្រះភាគ ដោយមានគ្រឿងក្រអូបគ្រប់យ៉ាង(១) ។

ពួកមល្លក្សត្រ ៤ អង្គ ដែលជាប្រធានទ្រង់ជម្រះសីសៈ ហើយទ្រង់សំពត់ថ្មី គិតគ្នាថាយើងនឹងឆួលនូវជើងថ្ករ តែមិនអាចនឹងឆួលឱ្យឆេះបាន ។ ពួកមល្លក្សត្រមានចម្ងល់ណាស់ ក៏ទូលសួរព្រះអនុរុទ្ធត្ថេរ ។ ព្រះអនុរុទ្ធត្ថេរតបថា បពិត្រមហារាជ បំណងរបស់ពួកទេវតាថា មហាកស្សបដ៏មានអាយុ ជាមួយភិក្ខុសង្ឃ ប្រមាណ ៥០០ អង្គ កំពុងនិមន្តតាមផ្លូវឆ្ងាយចេញពីក្រុងបាវា មកកាន់ក្រុងកុសិនារា មិនទាន់បានថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគដោយដៃរបស់ខ្លួនដរាបណា ជើងថ្ករក៏មិនទាន់ឆេះដរាបនោះ ។

លុះព្រះមហាកស្សប និងភិក្ខុ ៥០០ អង្គ និមន្តមកដល់ហើយ ក៏ទ្រង់ចីវរប្រណម្យអញ្ជលី ធ្វើប្រទក្សិណជើងថ្ករ ៣ ជុំ ហើយថ្វាយបង្គំព្រះបាទាព្រះមានព្រះភាគដោយសិរ្ស ( ក្បាល )(២) ។ បន្ទាប់ពីនេះភ្លាម ជើងថ្ករក៏ឆេះឯង(៣) ។ ព្រះសរីរៈរបស់ព្រះមានព្រះភាគដែលភ្លើងឆេះហើយ អាការៈណា ទោះបីព្រះឆវី (ស្បែក

(១) តាមចំនៀម គេធ្វើព្រះស្តូបសំរាប់តម្កល់ព្រះអដ្ឋិធាតុស្តេចចក្រពត្តិក្នុងផ្លូវធំបែកជា ៤ ។ (២) អដ្ឋកថា ថាព្រះមហាកស្សបចូលចតុត្ថជ្ឈាន ចេញចាកចតុត្ថជ្ឈាន ហើយអធិដ្ឋានថា សូមឱ្យព្រះបាទទាំងគូរ ទម្លាយសំពត់ទាំង ៥០០ គូ ព្រមទាំងសំឡី និងព្រះមឈូសមាស និងជើងថ្ករធ្វើដោយខ្លឹមចន្ទន៍ ហើយលៀនចេញមកប្រតិស្ឋានលើក្បាលរបស់ខ្ញុំ ។ គ្រានោះ ព្រះបាទទាំងគូរ ក៏ទម្លាយសំពត់ទាំង ៥០០ គូជាដើម លៀនចេញមកដំណាលគ្នានឹងការអធិដ្ឋានចិត្តរបស់ព្រះមហាកស្សប ប្រៀបដូចព្រះចន្ទពេញវង់ចេញមកអំពីចន្លោះពពក ។ ព្រះមហាកស្សប ក៏លាដៃឡើងចាប់ព្រះបាទាលើកដាក់លើព្រះសិរ្សរបស់លោក ។ (៣) អដ្ឋកថា ថាជើងថ្ករនោះឆេះឡើង ដោយអានុភាពទេវតា ។

ក្រៅ ) ក្តី ព្រះចម្មៈ ( ស្បែក ) ក្តី ព្រះមំសៈ ( សាច់ ) ក្តី ព្រះន្ហារូ ( សរសៃ ) ក្តី ព្រះលសិកា ( ទឹករំអិល ) ក្តី អាការៈនោះ ក៏ឆេះអស់មិនមានផេះ និងកំញ៉ែម សល់នៅតែព្រះអដ្ឋិធាតុសុទ្ធ[១] ធារទឹកក៏បង្អុរចុះពីអាកាស និង មានទឹកខ្ចួរចេញអំពីដើមសាលព្រឹក្សរំលត់ជើងថ្ករ ។ រួចទើបពួកមល្លក្សត្ររំលត់ជើងថ្ករ ដោយទឹកក្រអូបទាំងពួង ។

គ្រានោះ ពួកមល្លក្សត្រ ក៏ធ្វើនូវការបញ្ឈរលំពែង[២] រួចព័ទ្ធដោយកំពែងធ្នូ[៣] ហើយធ្វើសក្ការបូជាព្រះសារីរិកធាតុរបស់ព្រះមានព្រះភាគ ដោយរបាំ ចម្រៀង ភ្លេង - ប្រគំ ផ្កាកម្រង និងគ្រឿងក្រអូបទាំងឡាយអស់ ៧ ថ្ងៃ ក្នុងសណ្ឋាគារដ្ឋាន ។

ពួកព្រះរាជានៃក្រុងនានា គឺព្រះបាទអជាតសត្រូវ ក្រុងរាជគ្រឹះ ពួកក្សត្រលិច្ឆវី ក្រុងវេសាលី, ពួកក្សត្រសក្យៈ ក្រុងកបិលភ័ស្តុ, ពួកក្សត្រថូលិ ក្រុងអល្ល-កប្បៈ ពួកក្សត្រកោឡិយៈ ក្រុងរាមគ្រាម, ពួកព្រាហ្មណ៍ក្នុងដែនវេដ្ឋទីបៈ ពួកមល្ល-ក្សត្រក្រុងបាវា លុះបានដឹងថា ព្រះមានព្រះភាគទ្រង់ចូលបរិនិព្វានហើយ ក៏បញ្ជូនរាជទូត និងទូតទៅកាន់សំណាក់នៃពួកមល្លក្សត្រក្រុងកុសិនារាថា យើងគួរបានចំណែកនៃព្រះសារីរិកធាតុ នៃព្រះមានព្រះភាគដែរ យើងនឹងធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសារីរិកធាតុនៃព្រះមានព្រះភាគ ។

លុះពួកក្សត្រ និង ព្រាហ្មណ៍ទាំងនោះ បានចាត់បញ្ជូនទូតទៅស្នើសុំព្រះ

---

(១) អដ្ឋកថា ថានៅសល់តែព្រះអដ្ឋិធាតុប្រៀបដូចផ្កាម្លិះក្រពុំខ្លះ ដូចកែវមុក្តាដ៏ស្អាតខ្លះ ដូចកម្ទេចមាសខ្លះ ។ (២) អដ្ឋកថា ថា ញុំាងបុរសអ្នកកាន់លំពែងឱ្យឈរព័ទ្ធជុំវិញព្រះសារីរិក-ធាតុ ។ (៣) ញុំាងពួកដំរី ពួកសេះ ពួករថ ពួកយោធា ឱ្យឈរព័ទ្ធជុំវិញព្រះសារីរិកធាតុធ្នូក៏ច្រុះព័ទ្ធជុំវិញខាងក្រៅបង្អស់ ។

សារីរិកធាតុយ៉ាងនេះ ពួកមល្លក្សត្រក្រុងកុសិនារា បានពោលទៅនឹងពួកគណៈទូត ទាំងនោះថា « ព្រះមានព្រះភាគទ្រង់បរិនិព្វានហើយក្នុងគាមក្ខេត្ត[(១)] របស់យើង យើងនឹងមិនឱ្យនូវចំណែកព្រះសារីរិកធាតុនៃព្រះមានព្រះភាគឡើយ ។ កាលបើពួកក្សត្រ និងពួកព្រាហ្មណ៍ពោលទំនាស់គ្នាយ៉ាងនេះហើយ ទើបទោណព្រាហ្មណ៍ និយាយទៅនឹងគណៈទូតទាំងនោះថា អ្នកទាំងឡាយដ៏ចំរើន សូមស្តាប់ពាក្យរបស់ខ្ញុំមួយម៉ាត់សិន ព្រះពុទ្ធជាម្ចាស់នៃយើង ព្រះអង្គជាខន្តិវាទ ( អ្នកពោលសរសើរគុណនៃខន្តិ ) មែនពិត ការប្រហារគ្នា ( ច្បាំងគ្នា ) ព្រោះតែចំណែកនៃសារីរិកធាតុរបស់ឧត្តមបុគ្គលនេះមិនប្រពៃឡើយ ។ បពិត្រលោកទាំងឡាយដ៏ចំរើន យើងទាំងអស់គ្នា គួរតែស្រុះស្រួលគ្នា ព្រមព្រៀងគ្នា រីករាយរកគ្នា ចែកព្រះសារីរិកធាតុឱ្យជា ៨ ចំណែកស្មើ ព្រះស្តូបទាំងឡាយ សូមផ្សាយទៅក្នុងទិសទាំងឡាយចុះ ពួកជនច្រើនគង់ជ្រះថ្លាចំពោះព្រះសម្ពុទ្ធមានចក្ខុមិនលែង ។

ពួកក្សត្រ និងព្រាហ្មណ៍ក៏បានទទួលព្រះសារីរិធាតុស្មើគ្នា នាំយកទៅធ្វើព្រះស្តូបតម្កល់គោរពបូជារៀង១ ខ្លួន ។ រីឯពួកក្សត្រមោរិយៈ ក្រុងបិប្ផលីវន ទើបតែបានឮដំណឹងក្រោយគេ ក៏បញ្ជូនរាជទូតទៅកាន់សំណាក់នៃពួកមល្លក្សត្រ ក្រុងកុសិនារា ដើម្បីសុំចំណែកព្រះសារីរិកធាតុព្រះមានព្រះភាគ ។ ពួកមល្លក្សត្រ ឆ្លើយថា ចំណែកព្រះសារីរិកធាតុព្រះមានព្រះភាគមិនមានទេ យើងចែកគ្នាអស់ហើយ ចូរអ្នកទាំងឡាយនាំយកព្រះអង្គារ ( ធ្យូង ) អំពីកន្លែងដែលថ្វាយព្រះភ្លើងនេះទៅចុះ ។ ពួកក្សត្រមោរិយៈទាំងនោះ ក៏នាំយកព្រះអង្គារអំពីកន្លែង ដែលថ្វាយព្រះភ្លើងនោះទៅ ។

ព្រះសារីរិកធាតុរបស់ព្រះមានព្រះភាគ មាន ៨ ទោណៈ[(២)] គឺព្រះសារី-

---

(១) គាមក្ខេត្ត ទឹកដី ស្រុកទេស ។ (២) ៤ ក្តាប់ ត្រូវជា ១ កុឌវៈ, ៤ កុឌវៈ ត្រូវជា ១ បត្ថៈ ( នាឡិ ) ៤ បត្ថៈ ត្រូវជា ១ អាឡ្ហកៈ ៤ អាឡ្ហកៈ ត្រូវជា ១ ទោណៈ ( ១៦ នាឡិតូច ) ។

វិកធាតុ ៧ ទោណៈ ជនទាំងឡាយធ្វើសក្ការបូជាក្នុងជម្ពូទ្វីប ព្រះសារីរិកធាតុ ១ ទោណៈ ពួកនាគរាជធ្វើសក្ការបូជាក្នុងរាមគ្រាម ។ ឯព្រះទាឋា ( ចង្កូម ) ១ ពួកទេវតានាំយកទៅបូជា, ព្រះទាឋា ១ ពួកជនធ្វើសក្ការបូជាក្នុងគន្ធារបុរី, ព្រះទាឋា ១ ពួកជនធ្វើសក្ការបូជាក្នុងដែនកាលិង្គ និងព្រះទាឋា ១ ទៀត ពួកនាគរាជនាំយកទៅធ្វើសក្ការបូជា ។

រៀបរៀងដោយ

**ម៉ែន ប្រាជ, អាំ ឆន**

ពិនិត្យសម្រួលដោយ ឱម ខែម

---

* យប់យូរ ចំពោះអ្នកដែលដេកមិនលក់ ។

* ផ្លូវឆ្ងាយ ចំពោះអ្នកដើរដែលនឿយហត់ ។

* សង្សារ ( ការអន្ទោលកើតស្លាប់ ) សែនវែងឆ្ងាយ ចំពោះអ្នកដែលមិនយល់ព្រះធម៌ ។

( ចាកធម្មបទ . ពាលវគ្គ )

# ឧបស្សយានិសង្ស

## « អានិសង្សនៃសាលាសំណាក់ »

សម្តេចព្រះមហាសុមេធាធិបតី ជ.ណ ជោតញ្ញាណោ
ព្រះសង្ឃរាជថ្នាក់ទី១ នៃគណៈមហានិកាយ
ប្រែ - រៀបរៀង

ក្នុងព្រះសុត្តន្តបិដក សំយុត្តនិកាយ ទេវតាសំយុត្ត សគាថវគ្គ ត្រង់សត្តម-សូត្រ ក្នុងអាទិត្តវគ្គ មានសេចក្តីថែងថា មានទេវតាក្រាបទូលសួរព្រះភគវ័ត អរហន្ត សម្មាសម្ពុទ្ធថា :

**កេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ**
**ធម្មដ្ឋា សីលសម្បន្នា កេ ជនា សគ្គគាមិនោ ។**

" ( សូមទ្រង់ព្រះមេត្តាប្រោស ), បុណ្យរមែងចំរើនជានិច្ចទាំងថ្ងៃ ទាំងយប់ ដល់ជនទាំងឡាយណាខ្លះ ? ជនទាំងឡាយណាខ្លះ ជាអ្នកឋិតនៅក្នុងធម៌ ជាអ្នកបរិបូណ៌ដោយសីល ហើយគេបានទៅកើតឯឋានសួគ៌ ? "

ព្រះសព្វញ្ញុពុទ្ធទ្រង់ត្រាស់ឆ្លើយដោះស្រាយបញ្ហានេះថា :

**អារាមរោបា វនរោបា យេ ជនា សេតុការកា**
**បបញ្ច ឧទបានញ្ច យេ ទទន្តិ ឧបស្សយំ**
**តេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ**
**ធម្មដ្ឋា សីលសម្បន្នា តេ ជនា សគ្គគាមិនោ ។**

« ជនទាំងឡាយណា បានដាំសួនមានផ្កាមានផ្លែក្តី បានដាំឈើជាឧទ្យានមានម្លប់ត្រឈឹងត្រឈៃក្តី បានសង់ស្ពានក្តី បានដងទឹកដាក់តំកល់ទុកឱ្យទានក្តី បាន

ជីកអណ្ដូងឬជីកស្រះក្ដី បានសាងសង់ឧបស្សយដ្ឋាន គឺសាលាសំណាក់ជាដើមក្ដី បុណ្យរមែងចំរើនកើតកើនជានិច្ចទាំងថ្ងៃទាំងយប់ដល់ជនទាំងឡាយនោះ ។ ជនទាំងឡាយណាជាអ្នកឋិតនៅក្នុងកុសលធម៌ ជាអ្នកបរិបូណ៌ដោយសីល, ជនទាំងឡាយនោះជាអ្នកបានទៅកើតឯឋានសួគ៌ » ។

## អធិប្បាយ

តាមលំអាននៃគម្ពីរសារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ សគាថវគ្គ ត្រង់ទេវតាសំយុត្តវណ្ណនា ព្រមទាំងការពង្រីកសេចក្ដីឱ្យទូលំទូលាយខ្លះផង តាមមតិនៃខ្ញុំជាអ្នករៀបរៀងធម៌នេះ ។

ត្រង់ដែលទេវតាក្រាបទូលសួរព្រះភគវ័ត អរហន្តសម្មាសម្ពុទ្ធថា : **កេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ** បុណ្យរមែងចំរើនទាំងថ្ងៃទាំងយប់ដល់ជនទាំងឡាយណាខ្លះ ? នោះព្រះភគវ័តទ្រង់ឆ្លើយដោះស្រាយថា **អារាម-រោបា** អ្នកណាបានដាំបុប្ផារាម និងផលារាម គឺបានដាំឈើដែលមានផ្កា ដូចជាម្លិះ, ន្លួនស្រី, មាលតី, ដកខិម, ចំប៉ីជាដើម ឬបានដាំឈើមានផ្លែ ដូចជាត្របែក, ពុទ្រា, ត្រប់, ម្ទេសជាដើម ដែលជាឈើតូចៗ ទាបៗ ក្នុងវត្តអារាមជាទីនៅនៃភិក្ខុសង្ឃ ឬដាំនៅទីណាមួយ ឱ្យជាសាធារណប្រយោជន៍ដល់ជនទាំងពួង, យ៉ាងនេះហៅថា *អារាមរោបា* អ្នកដាំសួនមានផ្កាមានផ្លែ ។ **វនរោបា** បានធ្វើរបងព័ទ្ធទីដីដែលមានឈើជាព្រៃដុះឯងស្រាប់ ឥតមានអ្នកណាមួយដាំទេ ជាទីដីទំនេរឥតមានអ្នកណាមួយហួងហែងថែរក្សាទេ ឬជាទីដីរបស់ខ្លួន បានកសាងចេតិយ, បានដាំដើមពោធិ៍, បានធ្វើផ្លូវជាទីចង្ក្រមន៍ ឬបានសង់មណ្ឌប, សង់សាលា, តូប, អាស្រម, លេណដ្ឋានសម្រាប់ជ្រក អាស្រ័យនៃយោគី, តាបស អាចប្រើប្រាស់បានក្នុងវេលាថ្ងៃ ឬយប់តាមត្រូវការ, យ៉ាងនេះហៅថា *វនរោបា* អ្នកដាំឈើឧទ្យានមានម្លប់ត្រឈឹង

ត្រៃយេ ។ ពុំនោះសោត បានដាំឈើជាម្លប់ឱ្យគេជ្រក ទោះដាំនៅទីជិតសាលាសំ-ណាក់ក្តី នៅទីក្បែរថ្នល់ ក្បែរផ្លូវក្តី នៅទីដីក្នុងវត្តអារាមក្តី ដាំធ្វើជាឧទ្យានមានម្លប់ត្រឈើងត្រឈៃក្តី ឱ្យជាម្លប់ជាជម្រកជាទីពេញចិត្តខ្លួនឯង និងសាធារណជនទាំងពួង, យ៉ាងនេះក៏ហៅថា *វនរោបា* អ្នកដាំឧទ្យានមានម្លប់ត្រឈើងត្រឈៃដែរ ។

**យេ ជនា សេតុការកា** ជនទាំងឡាយណាបានសង់ស្ពាន, **ឧទកេ នាវំ បដិយាទេន្តិ** ឬបានចាត់ចែងឱ្យមានទូកសម្រាប់ចម្លងដោយឥតយកថ្លៃឈ្នួលឱ្យសាធារណជនបានឆ្លងទឹកដោយងាយស្រួល, អ្នកដែលមានចិត្តជាកុសលបានលើកថ្នល់ ឬជីរះស្មៅ ចូកចាំងពង្រាបផ្លូវ ឬក៏បានលុបថ្លុកជង្ហុកធ្វើជាផ្លូវ ជាថ្នល់ឱ្យមានផ្ទៃរាបស្មើ ស្រួលដើរ ស្រួលធ្វើគមនាគមន៍ ទោះថ្ងៃទោះយប់មិនចំពប់ មិនរឥល ឬពុំនោះ កាលបើបានឃើញមានមែកឈើ ឬបន្លាជាដើម រាត់រាយនៅក្នុងផ្លូវមិនដើរបង្ហួសទៅ ក៏បានទាត់ចោល ឬបានចាប់រើសបោះចោលដោយស្រួលទៅក្រៅផ្លូវ, មានចបនៅនឹងដៃ កាលបើបានឃើញផ្លូវ ឬថ្នល់វិកលខូចខាត ក៏ឆ្លៀតលើកដីបំពេញដោយចិត្តជ្រះថ្លា, យ៉ាងនេះក៏សុទ្ធសឹងតែជាបុណ្យ ជាកុសល មានផលល្អប្រពៃទាំងអស់ ។

**បបញ្ច ឧទបានញ្ច** ជាអ្នកមានចិត្តជាកុសល បានធ្វើរោងតូចដាក់ក្អម ឬពាងទឹក ព្រមទាំងផ្តិល ឬបោយត្រឡោកសម្រាប់ដួសដងផង ឱ្យជាទានដល់សាធារណជន នៅទីប្រសព្វផ្លូវតូចធំ ក្នុងរដូវដែលក្រទឹក ។ បានជីកស្រះ ជីកត្រពាំង ជីកអណ្តូង ឬលើកទំនប់ទប់បង្ខាំងទឹកឱ្យដក់នៅជានិច្ចកាល ជាប្រយោជន៍ដល់មនុស្ស និងសត្វតិរច្ឆានទូទៅ ។ ពុំនោះសោត បានធ្វើប៉ប៉ា.[១] គឺឃ្លាំងសម្រាប់ទទួលទឹកភ្លៀងដែលហូរធ្លាក់ចុះចាកដំបូលសាលាធំៗ ជាដើម ទុកជាប្រយោជន៍ដល់ភិក្ខុ

(១) អានថា ប៉ះប៉ា ។

សាមណេរ និងសាធារណជន ដួសដងយោងយកមកប្រើប្រាស់បានដោយងាយ, ការទាំងនេះក៏សុទ្ធសឹងតែជាបុណ្យកុសល អាចនឹងផ្តល់នូវសេចក្តីសុខចំរើនឱ្យដល់អ្នកកសាងនោះវិញ ពុំមែនតូចតាចស្តួចស្តើងឡើយ ។

**យេ ធនន្តិ ឧបស្សយំ** (១) ជនទាំងឡាយណា បានសាងសង់នូវ *ឧបស្ស័យ* ឬ *វាសាគារ* គឺសាលាសម្រាប់ជ្រក សម្រាប់សំណាក់ នៃសាធារណជនទូទៅពុំរើសមុខ ឬក៏បានសាងសង់កុដិ, តូប, ឧបដ្ឋានសាលា, មន្ទីរពេទ្យជាដើម ក្នុងវត្តអារាម របស់ភិក្ខុសង្ឃ, ពុំនោះ បានសង់តូប, អាស្រម សម្រាប់យោគី តាបស ឥសីនៅជ្រកអាស្រ័យធ្វើភាវនាជាដើម, រួមសេចក្តីខ្លីទៅថា បានសាងសង់ បានឱ្យនូវឧបស្ស័យ ឬវាសាគារជាទាន, នេះក៏ជាបុណ្យកុសលជាទីជ្រះថ្លាទាំងអស់ ។

**តេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ** ជនទាំងឡាយណាបានកសាងសន្សំនូវបុណ្យកុសលខាងលើនេះ, កាលបើជនទាំងឡាយនោះ នឹកឃើញការកុសលរបស់ខ្លួននោះនៅវេលាណា ទោះនៅវេលាដើរ ឈរ អង្គុយ ឬដេកក្តី វេលានោះឯង បុណ្យក៏ចេះតែល្ហូតលាស់ចំរើនកើនឡើងជានិច្ចជាងពីមុនថែមទៀត ទាំងថ្ងៃទាំងយប់ ព្រោះជនទាំងនោះមានអំណរជ្រះថ្លារីករាយពេញចិត្ត មានសង្ឃឹម កក់ក្តៅរឿយៗ ក្នុងវេលាដែលខ្លួននឹកឃើញបុណ្យនុ៎ះឯង ។ ប៉ុន្តែ ផ្ទុយទៅវិញ, ក្នុងពេលខ្លះ, បើជនអ្នកកសាងកុសលនោះ មិនភ្នកនឹកដល់កុសលដែលខ្លួនបានកសាងសន្សំហើយនោះទេ បែរជាមានចិត្តវិបល្លាសភ្លាសនឹកទៅរក *អកុសលវិតក្កៈ* ណាមួយទៅវិញ គឺត្រិះរិះនឹករាំងស្ទួងទៅរក *កាមវិតក្កៈ* ត្រិះរិះទៅរកកាមគុណទាំង ៥ ណាមួយក្តី, *ព្យាបាទវិតក្កៈ* ត្រិះរិះទៅរកការព្យាបាទផ្តន្ទាគេ ចងគំនុំគុំ

---

(១) បាលីនេះប្រើជា ឧបាសយំ វិញក៏បាន មានន័យត្រូវគ្នានឹង ឧបស្សយំ នេះដែរ គឺវាសាគារ « អគារជាទីសំណាក់អាស្រ័យ ឬជាលំនៅ » ។

គួនគេក្តី, *វិបដីសារិតក្កៈ* ត្រិះរិះទៅរកការបៀតបៀនគេក្តី ឬនឹកទៅរកអកុសលកម្ម ណាមួយផ្សេងដែលខ្លួនបានជ្រុលធ្វើទៅហើយនោះក្តី, បុណ្យកុសលពុំមែនល្វត លាស់ចំរើន កើនឡើងជានិច្ចរាល់ថ្ងៃរាល់យប់ ដូចបានពោលហើយនោះទេ, បើជន នោះធ្លាប់បានធ្វើបាបណា កាលបើនឹកឃើញបាបនោះ ក៏ស្រាប់តែមាន *វិប្បដិសារៈ* ក្តៅក្រហាយ ស្តាយក្រោយ ព្រោះបាបនោះ, យ៉ាងនេះបែរទៅជាបាបនោះល្វត លាស់ចំរើនកើនថែម១ ឡើងទៀតលើសជាងមុនទៅវិញ ។ ដោយហេតុនេះ បុគ្គល ពុំគួរនឹកទៅរកបាបចាស់នោះទេ ត្រូវតែបំភ្លេចបាប ត្រូវតាំងចិត្តឱ្យត្រេកអរ ទាំងត្រូវ សង្ឃឹមយ៉ាងមាំផង ទៅរកបុណ្យដែលខ្លួនបានធ្វើរួចហើយនោះ ឬត្រូវផ្តង់ចិត្តឱ្យមាំ ស៊ប់ផ្តោតចំពោះត្រង់បុណ្យដែលខ្លួនកំពុងធ្វើ ឱ្យចិត្តមានអំណររីករាយថែម១ឡើង ឬក៏ត្រូវផ្តងចិត្តឱ្យមុតមាំទៅរកការកុសលដែលខ្លួនបំរុងនឹងធ្វើរឿយ១ ត១ទៅទៀត នោះវិញ, យ៉ាងនេះហៅថានឹកបុណ្យ នាំឱ្យបានបុណ្យថែមឡើងទៀត ឬហៅថា *នឹកបុណ្យបំភ្លេចបាប* ដូច្នេះវិញក៏សឹងថាបាន ។ ព្រះអរហន្តសម្មាសម្ពុទ្ធជាបរមគ្រូ ពុំដែលប្រទានព្រះឱវាទថា *ធ្វើបុណ្យលាងបាបទេ*, ព្រះពុទ្ធសាសនា *គ្មានពិធីលាង បាបឡើយ*, មានត្រឹមតែថា **សុខោ បុញ្ញស្ស ឧច្ចយោ** ការសន្សំបុណ្យនាំឱ្យ បានសេចក្តីសុខ ។ **ទុក្ខោ បាបស្ស ឧច្ចយោ** ការសន្សំបាបនាំឱ្យបានសេចក្តី ទុក្ខ ។ **តមោ ជោតិ បរាយនោ** បុគ្គលចេញពីទីងងឹតមកកាន់ទីភ្លឺ ហៅថា ងងឹតខាងដើម ភ្លឺខាងចុង ។ បុគ្គលណា កាលពីមុន មានគំនិតងងឹតងងល់លង់ស្លុង ទៅខាងបាប លុះដល់មកខាងក្រោយ ភ្ញាក់គំនិតបានប្រព្រឹត្តត្រឹមត្រង់ល្អតាមគន្លង ធម៌ពិត, បុគ្គលនោះក៏ភ្លឺរុងរឿងដោយសារបុណ្យកុសល **អព្ភា មុត្តោវ ចន្ទិមា** ដូចជាព្រះចន្ទចេញផុតពីពពកបាំង ។ គួរយល់ថា បុណ្យជាកុសលបំភ្លេចបាប, ឯបាប ជាអកុសលបំភ្លេចបុណ្យ ឬបង្អាក់បង្អាប់បុណ្យ, ត្រេកអរចំពោះបុណ្យ បុណ្យឱ្យ ផលជាសុខ ឱ្យមានចិត្តរីករាយ, ត្រេកអរចំពោះបាប បាបឱ្យផលជាទុក្ខ ឱ្យមាន

សេចក្ដីក្ដៅក្រហាយស្ដាយក្រោយ ។ នេះជាលទ្ធិនៃព្រះពុទ្ធសាសនា ចង្អុលប្រាប់ការណ៍ពិត ឥតមានល្បៀងឡើយ ។ ដោយហេតុនេះហើយបានជាព្រះសព្វញ្ញុ ពុទ្ធវិសេសវិសុទ្ធបរមសាស្ដា ទ្រង់ឆ្លើយតបបញ្ហាដែលទេវតាក្រាបទូលសួរនោះថា **កេសំ ឆិទា ច វគ្គោ ច សទា បុញ្ញំ បវឌ្ឍតិ** ( ដែលបានប្រែ ព្រមទាំងបានអធិប្បាយផងរួចហើយនោះ ) ។

**ធម្មដ្ឋា សីលសម្បន្នា តេ ជនា សគ្គគាមិនោ** ជនទាំងឡាយណាឋិតនៅក្នុងកុសលធម៌ផង បរិបូណ៌ដោយសីលផង ជនទាំងឡាយនោះ តែងតែបានទៅកើតឯឋានសួគ៌ ។ ពាក្យថា *ឋិតនៅក្នុងកុសលធម៌* គឺប្រព្រឹត្តត្រឹមត្រូវតាមគន្លងធម៌ មានសុចរិត ១០ ប្រការជាដើម ។ ពាក្យថា *បរិបូណ៌ដោយសីល* គឺកាន់សីល តាំងពីសីល ៥ ជាដើមទៅ ដោយប្រយ័ត្នជានិច្ចមិនឱ្យសៅហ្មង ។

ចប់សត្តមសូត្រទី ៧ ក្នុងអាទិត្តវគ្គតែប៉ុណ្ណេះ ។

# មឃមាណវវត្ថុ

## « រឿងនិទានមឃមាណពទៅកើតជាព្រះឥន្ទ »

សម្ដេចព្រះមហាសុមេធាធិបតី ជ.ណ ជោតញ្ញាណោ
ព្រះសង្ឃរាជថ្នាក់ទី ១ នៃគណៈមហានិកាយ
ប្រែ - រៀបរៀង

ក្នុងគម្ពីរធម្មបទដ្ឋកថា ត្រង់អប្បមាទវគ្គវណ្ណនា មានដំណាលអំពីរឿងមឃមាណព(១) និងមិត្រ ៣៣ នាក់ ដែលបានរួបរួមគ្នាបំពេញការកុសល ក្នុងពុទ្ធន្តរ-កាល គឺក្នុងកាលលង្វែកឥតមានព្រះពុទ្ធសាសនា ។ មឃមាណព និងមិត្រទាំង ៣៣ នាក់នោះមានចិត្តជ្រះថ្លា បានសាងសន្សំកុសល មានការជំរះស្មៅ ចូកចាំងប្រាបពង្រាបផ្លូវ លើកថ្នល់ សង់ស្ពាន សង់សាលាសំណាក់ជាដើម ជាប្រយោជន៍ដល់សាធារណជន, លុះអស់ជីវិតបានទៅកើតជាព្រះឥន្ទ ជាទេវបុត្ត ជាទេវតាទាំងអស់គ្នានៅឋានត្រ័យត្រឹង្សសួគ៌ ។ និទាននោះ មានសេចក្ដីពិស្ដារ ប៉ុន្តែ, ខ្ញុំដកស្រង់ត្រឹមតែគោលខ្លីៗ យកមករៀបរៀង ដូចតទៅនេះ ៖

ព្រះសក្យមុនីសម្មាសម្ពុទ្ធ ទ្រង់គង់នៅនា *កូដាគារសាលា មហាវ័ន* ជិតក្រុងវេសាលី ក្នុងដែនវជ្ជី ។ ព្រះរាជាទ្រង់ព្រះនាម*មហាលិ* ក្នុងពួក *លិច្ឆវីក្សត្រិយ៍* នៃក្រុងវេសាលី ដែនវជ្ជី ក្នុងជម្ពូទ្វីប, ដោយព្រះអង្គបានទ្រង់ព្រះសណ្ដាប់នូវ*សក្កបញ្ហសូត្រ* ដែលព្រះបរមសាស្ដាទ្រង់សំដែងអំពីរឿងព្រះឥន្ទ, ព្រះមហាលិរាជ

(១) ពុទ្ធសាសនិកជនខ្មែរយើងច្រើនតែហៅថា មាឃមាណព ប៉ុន្តែតាមពិត មឃមាណពវិញទេ ទើបត្រឹមត្រូវ, ដល់បានទៅកើតជាព្រះឥន្ទៗ ក៏មានព្រះនាមពិសេសមួយថា មឃទេវរាជដែរ ពុំមែន មាឃទេវរាជ ទេ ។

មានសេចក្ដីឆ្ងល់ថាមានព្រះឥន្ទពិតមែន, ព្រះភគវ័តទ្រង់បានទតព្រះនេត្រឃើញព្រះឥន្ទពិតមែន ឬព្រះអង្គទ្រង់សំដែងតាមតែរឿងព្រេងដែលគេឆ្លាក់ គេគូរជារូបព្រះឥន្ទ ថា ព្រះឥន្ទៗនោះទៅទេ ? ឬក៏យ៉ាងណាអីចេះ ? ពីព្រោះឥតអ្នកណាអាចបានឃើញ បានស្គាល់ព្រះឥន្ទនោះដោយងាយៗ ទេ !

លុះព្រះបាទមហាលិបានចូលមកគាល់ទូលសួរព្រះអង្គអំពីរឿងនេះ, ព្រះបរមគ្រូក៏បានឆ្លើយដោះស្រាយតាមការណ៍ពិតថា មានព្រះឥន្ទពិតមែន, តថាគត បានឃើញ បានស្គាល់ព្រះឥន្ទនោះពិតៗ តថាគតស្គាល់ទាំងធម៌ និងវត្តប្រតិបត្តិដែលធ្វើឱ្យអ្នកប្រតិបត្តិបានផលានិសង្ស នាំអ្នកនោះទៅកើតជាព្រះឥន្ទផងទៀត, ពុំមែនតថាគតចេះតែថាៗទៅ ដោយពុំឃើញ ពុំស្គាល់ច្បាស់នោះទេ ។ ទើបព្រះបរមគ្រូទ្រង់សំដែងរឿងពិតនោះថា :

**អតីតេ មគធរដ្ឋេ អចលគាមេ មឃោ នាម មាណវោ** ក្នុងអតីត-កាលកន្លងរំលងទៅយូរហើយ មានមាណពម្នាក់ឈ្មោះ **មឃៈ** នៅក្នុងអចលគ្រាមក្នុងមគធរដ្ឋ, មឃមាណពនោះបានធ្វើបុណ្យកុសល រួមជាមួយនឹងបុរស ៣៣ នាក់ជាមិត្ររបស់ខ្លួន, បានរួបរួមគ្នាធ្វើការកុសលផ្សេងៗ មានការជំរះ ស្មៅ ចូកចាំងប្រាបពង្រាប សំអាតផ្លូវ លើកថ្នល់ សង់ស្ពាន សង់សាលាសំណាក់ជាដើម ជាប្រយោជន៍ដល់សាធារណជន ។ មឃមាណពនោះ ពុំមែនត្រឹមតែមានសទ្ធាជ្រះថ្លាធ្វើការកុសលទាំងនេះប៉ុណ្ណោះទេ ថែមទាំងបានប្រព្រឹត្តកាន់ធម៌ជាកុសលឯទៀតដែលទេវតា និងមនុស្សជាបណ្ឌិតទាំងឡាយ ពេញចិត្តស្ងើចសរសើរនោះផងទៀត ។ ធម៌ដែលមឃមាណពកាន់ខ្ជាប់ជានិច្ចនោះ ហៅថា*វត្តបទ* មាន ៧ ប្រការគឺ :

១. *មាតាបេតិភរណៈ* ការចិញ្ចឹមបីបាច់រក្សាមាតាបិតា,

២. *កុលេជេដ្ឋាបចាយនៈ* ការគោរពកោតក្រែងចាស់ព្រឹទ្ធាចារ្យ ត្រកូលវៀមច្បង,

៣. *សច្ចវាចា* ការពោលពាក្យសច្ចៈ,

៤. *អផរុសវាចា* ការមិនពោលផរុសវាទ,

៥. *អបិសុណវាចា* ការមិនពោលពាក្យញុះញង់,

៦. *មច្ឆេរវិនយៈ* ការនាំសេចក្ដីកំណាញ់ចេញ គឺការបណ្ដុះសទ្ធាជ្រះថ្លា ចំណាយទ្រព្យធ្វើបុណ្យឱ្យទាន,

៧. *អក្កោធនៈ* ការចេះអត់ ចេះទប់សេចក្ដីក្រោធ ។

កាលដែលមឃមាណព និងមិត្រទាំង ៣៣ នាក់ កំពុងធ្វើការកុសល មានការប្រាបពង្រាបផ្លូវ និងការលើកថ្មល់ពីទីមួយភ្ជាប់គ្នាទៅទីមួយដូច្នោះ, *គាមភោជក*[(១)] បានរករឿងចាប់ទោសកំហុសថា ជនទាំងនោះជាចោរប្រមូលផ្ដុំគ្នាជាពួក, ក៏បានក្រាបទូលព្រះរាជាមគធរដ្ឋ ដោយអាងលេសផ្សេងៗ ជាអយុត្តិធម៌ ។ ព្រះរាជាពុំបានពិចារណាដោយហ្មត់ចត់, ព្រះអង្គជឿសំដីគាមភោជក, ក៏មានព្រះរាជបញ្ជាឱ្យចាប់ជនទាំង ៣៤ នាក់នោះមក ហើយឱ្យយកដំរីសឹកទៅបំព្រេចសម្លាប់ ។ មឃមាណព និងមិត្រទាំង ៣៣ នាក់ បានតាំងចិត្តប្រកបដោយមេត្តាធម៌ដ៏មុតមាំឥតតក់ស្លុត រន្ធត់ ព្រោះជឿស៊ប់ចំពោះសុចរិតធម៌ ព្រមទាំងកុសលកម្មដែលបានកសាងសន្សំមកហើយនោះផង ជឿទុកចិត្តលើមេត្តាធម៌ដែលខ្លួនកំពុងកាន់នោះផង គឺរំលឹកគ្នា មិនឱ្យខឹងប្រកាន់ទៅលើគាមភោជក, ទៅលើព្រះរាជា, ទៅលើដំរីសឹក និងជនឯទៀតៗ សូម្បីបន្តិចបន្តួចសោះឡើយ ។ ទោះបីគេឱ្យជនទាំង ៣៤ នាក់នោះទៅនៅក្នុងរនាំងកន្ទេលផែង ឱ្យវាងាយនឹងព្រេចសម្លាប់, ដំរីសឹកនោះក៏បែរជាញ័រ

---

(១) គាមភោជក ប្រែថា " មន្ត្រីអ្នកបរិភោគនូវសួយអាករដែលមានក្នុងស្រុក " លោកអ្នកចេះបាលីខ្លះប្រែស័ព្ទនេះថា ចៅហ្វាយស្រុក, ខ្លះប្រែថា មេស្រុក ។ ក្នុងសម័យបុរាណព្រេងនាយ គាមភោជកនេះ ឥតមានបៀវត្សទេ មានត្រឹមតែសួយអាករក្នុងស្រុកនោះឯងជាប្រយោជន៍បានមកខ្លួន តាមស្រុកធំ ស្រុកតូច ។

ចំប្រប់ ពុំបានព្រេចជនទាំងនោះឡើយ ។ ព្រះមហាក្សត្រិយ៍ទ្រង់បានជ្រាបហេតុដ៏អស្ចារ្យចំឡែកនេះ, ព្រះអង្គក៏មានព្រះរាជបញ្ជាឱ្យហៅជនទាំងនោះចូលមកគាល់ ។ លុះទ្រង់ជ្រាបការណ៍ពិតសព្វគ្រប់ហើយ ក៏ភ្ញាក់ព្រះសតិ មានព្រះរាជហឫទ័យជ្រះថ្លាចំពោះជនទាំង ៣៤ នាក់, ទ្រង់ព្រះរាជទានគាមភោជក ព្រមទាំងប្រពន្ធ កូនឱ្យជាទាសាទាសីនៃមឃមាណព និងមិត្រទាំង ៣៣ នាក់ ។ ដំរីសឹកនោះក៏ព្រះអង្គប្រទានឱ្យជាជំនិះនៃជនទាំងនោះដែរ ។ ស្រុកដែលគាមភោជកចិត្តបាបអាក្រក់កាន់កាប់មកនោះ ព្រះមហាក្សត្រិយ៍ក៏ប្រោសប្រទានឱ្យជាស្រុកសួយនៃជនទាំង ៣៤ នាក់នោះផងទៀត ។

មឃមាណព និងមិត្រទាំង ៣៣ នាក់ កាលបើបានឃើញផលបុណ្យជាទិដ្ឋធម្មវេទនីយឱ្យផលដ៏អស្ចារ្យ ឃើញជាក់ស្ដែងទាន់ភ្នែកដូច្នេះ ក៏និយាយគ្នាថា **ឥទានិ អម្ហេហិ អតិរេកតរំ បុញ្ញំ កាតព្វំ** " ឥឡូវ, យើងត្រូវតែធ្វើបុណ្យឱ្យច្រើនក្រៃលែងជាងពីមុនទៅទៀត " ។ ក៏មូលមតិគ្នាថា យើងត្រូវសង់សាលាសំណាក់មួយ ។ ក៏បានហៅជាងឈើឱ្យមកផ្ដើមសង់សាលាសំណាក់ លើទីដីដែលគួរសង់ត្រង់ប្រជុំផ្លូវបែកបួន, ប៉ុន្តែមិនត្រូវឱ្យស្ត្រីមានសិទ្ធិចូលធ្វើសាលានេះជាមួយនឹងយើងផងទេ ( ព្រោះមិនចង់កើតជួបនឹងស្ត្រីទៅជាតិមុខទៀត ) ។

មឃមាណពមានប្រពន្ធ ៤ នាក់គឺ នាង *សុធម្មា* ១ នាង *សុនន្ទា* ១ នាង *សុចិត្តា* ១ នាង *សុជាតា* ១ ។ បណ្ដាប្រពន្ធទាំង ៤ នាក់នោះ, នាង *សុធម្មា* មានគំនិតឈ្លាសវៃ គិតថាអញនឹងធ្វើបុណ្យរួបរួមចូលជាមួយនឹងប្ដីឱ្យត្រាតែបាន, ក៏បានលបនិយាយត្រូវមាត់ត្រូវពាក្យគ្នាជាមួយនឹងជាងឈើ, បានឱ្យជាងឈើលបធ្វើ *ហោជាង* ឱ្យត្រូវនឹងខ្នាតសាលានោះ, បានឱ្យឆ្លាក់អក្សរនៅហោជាងថា **សាលាសុធម្មា** ។ លុះដល់ថ្ងៃត្រូវលើកហោជាង, ស្រាប់តែជាងឈើធ្វើអាការដូចជាភ្ញាក់ថា " ឱ, វរតែម្ដង ! ខ្ញុំពុំបានគិតធ្វើហោជាងទុកជាមុន, ឥឡូវបើនឹងធ្វើឱ្យបានទាន់ការប្រញាប់ក៏ពុំ

កើត, ដ្បិតនឹងយកឈើស្រស់ៗ មកធ្វើពុំកើតទេ, បើអីចឹង តើធ្វើម៉េចទៅហ៎ ! , ខ្ញុំបានឃើញមានហោជាងគេធ្វើហើយស្រេច ទុកនៅផ្ទះគេឯណោះ, ប្រហែលជាត្រូវខ្នាតនឹងសាលាយើងនេះ, បើយើងទិញគេ ប្រហែលជាគេលក់ទេដឹង " ។ ជនទាំង ៣៤ នាក់ ក៏យល់ព្រម ហើយនាំគ្នាទៅទិញ ដោយឱ្យថ្លៃដល់មួយពាន់កហាបណៈ ។ នាង *សុធម្មា* មិនព្រមលក់ឱ្យ, ព្រមតែចូលបុណ្យជាមួយផង ។ មឃមាណព និងមិត្រទាំង ៣៣ នាក់មិនព្រមឱ្យស្ត្រីធ្វើបុណ្យជាមួយ ។ ជាងឈើប្រើឧបាយនិយាយពន្យល់ថា " ក្រៅពីឋានព្រហ្ម គ្មានឋានណាឥតស្ត្រីទេ, យើងប្រញាប់ចង់ឱ្យសាលាយើងហើយស្រេច, ណ្ហើយ, យកហោជាងហ្នឹងទៅ ! ... " ។ ជនទាំង ៣៤ នាក់ ទាល់គំនិត ក៏ព្រមយកហោជាងរបស់នាងសុធម្មានោះមកលើកដាក់ជាហោជាងសាលាសំណាក់នោះ ដោយឥតរង្កៀសអ្វីឡើយ ។ ជនទាំងពួងដែលមកកាន់ទីនេះ អានអក្សរជាឈ្មោះសាលានៅហោជាងថា **សាលាសុធម្មា** , គេស្គាល់រាល់គ្នាថា *សាលាសុធម្មា*, ឯជនទាំង ៣៤ នាក់ ក៏ឥតមានការអាក់អន់ស្រពន់ចិត្តអ្វីព្រោះឈ្មោះសាលានេះទេ ។

មឃមាណពបានដាំដើម *កោវិឡារព្រឹក្ស* គឺដើមរលួសផ្កុងមួយដើមឱ្យជាម្លប់ក្បែរសាលានោះ ; បានយក *ថ្មដា* មួយផ្ទាំងធំមកដាក់ក្រោមដើមរលួសផ្កុងសម្រាប់ឱ្យគេអង្គុយសម្រាកក្នុងម្លប់ឈើនេះ ។

នាង *សុនន្ទា* ក៏មានយោបល់ឈ្លាសវៃណាស់ដែរ, បានចាត់ការឱ្យជីក *ស្រះបោក្ខរណី* គឺស្រះឈូកមួយនៅទីមិនឆ្ងាយប៉ុន្មានពីសាលាសុធម្មានោះ, ស្រះនេះមានទឹកដក់នៅជានិច្ច ជាទីពេញចិត្តនៃនាង និងជនទាំងពួង, ជាសាធារណៈប្រយោជន៍រាល់ទិវារាត្រី ។

នាង *សុចិត្តា* ក៏ជាស្ត្រីឈ្លាសវៃណាស់ដែរ, បានចាត់ការឱ្យដាំសួន នៅទីមិនឆ្ងាយពីសាលាសុធម្មានោះប៉ុន្មាន, សួនច្បារនោះមានសុទ្ធសឹងតែឈើមានផ្កាមាន

ផ្លែ ជាទីពេញចិត្តនៃខ្លួន និងជនទាំងពួង ។ ជនទាំងពួងដែលចូលមកកាន់ទីនេះ ក៏តែងតែមានចិត្តរីករាយសប្បាយត្រេកអរក្សាន្ត បានកែអផ្សុកធូរចិត្តគំនិតទាំងអស់គ្នា ។

រីឯនាង *សុជាតា* ប្រពន្ធទី៤ ត្រូវជាប្អូនជីដូនមួយខាងម្តាយនៃមឃមាណពផង បានមកជាប្រពន្ធនៃមាណពនោះផង ។ នាងនេះជាស្ត្រីមិនឈ្លាសវៃ, មិនអាចញ៉ាំងចិត្តឱ្យជ្រះថ្លាចំពោះការកុសល, នាងនេះយល់ខុសទាំងស្រុងថា " អញជាប្អូនជីដូនមួយនៃមឃៈផង ជាប្រពន្ធគាត់ទៀតផង, ការអ្វីដែលប្តីអញគាត់បានធ្វើ ក៏ជាការរបស់អញដែរ, ប្តីអញធ្វើបុណ្យ អញក៏ត្រូវតែបានបុណ្យដូចជាគាត់ដែរ ព្រោះអញ និងប្តីអញមានអំពើកិច្ចការរួមគ្នាតែមួយ " ។ នាងសុជាតាគិតខុសយ៉ាងនេះក៏ឥតបើរើពើ ឥតមានសទ្ធាជ្រះថ្លា ឥតមានការលៃលកធ្វើបុណ្យអ្វីដូចជានាងទាំង ៣ នាក់នោះសោះឡើយ, គិតមួយតែពីខាងតាក់តែងស្អិតស្អាងខ្លួនឱ្យតែគាប់ចិត្តប្តីប៉ុណ្ណោះ ។ នាងនេះ ជាស្ត្រីមោឃាឃៃតចាកកុសលកម្ម ព្រោះខ្លួនជាស្ត្រីល្ងង់វង្វេងឃ្លាតចាកមនុស្សធម៌ ក្លាយទៅជាស្ត្រីអភ័ព្វ ។

លុះចំណេរកាលមកខាងមុខ, ជនទាំងនោះក៏រំលាងខន្ធអស់ជីពជន្មតាមលំដាប់កាលរៀងខ្លួន, សុទ្ធតែបានទៅកើតឋានត្រ័យត្រឹង្សស្ហួគ៌ (១) ទាំងអស់គ្នា ។

មឃមាណព បានទៅកើតជាព្រះឥន្ទ្រ នៅឋានត្រ័យត្រឹង្សស្ហួគ៌ ជាស្តេចទេពតា មាននាមពិសេសមួយយ៉ាងថា *មឃវា* ឬ *មឃទេវរាជ* តាមនាមដើមកាលនៅជាមនុស្សឈ្មោះ *មឃៈ* ។

អានិសង្សនៃ *សាលាសំណាក់* បានកើតជាប្រាសាទទិព្វឈ្មោះ *វេជយ័ន្ត* ជាវិមានសម្រាប់ព្រះឥន្ទ្រ ។

អានិសង្សនៃការដាំ*កោវិឡារព្រឹក្ស* គឺដើមរលួសផ្អុង ជាម្លប់ឱ្យគេជ្រកនោះ បានកើតជាដើមឈើទិព្វមួយដើមហៅថា*បារិច្ឆត្តកព្រឹក្ស* ឬហៅថា*បារិជាតក*.

---

(១) បណ្តាឋានស្ហួគ៌ទាំង ៦ ជាន់, ត្រៃត្រឹង្ស ជាឋានស្ហួគ៌ជាន់ទី ២ ។

ព្រឹក្ស ក៏បាន នៅឋានត្រ័យត្រឹង្ស ។

អានិសង្សនៃ *ថ្មជា* មួយផ្ទាំងធំ ដែលមឃមាណពបានដាក់តម្កល់ក្រោមដើមរលួសផ្គងសម្រាប់ឱ្យគេអង្គុយកំសាន្តនោះ បានកើតជាថ្មទិព្វឈ្មោះ*បណ្ឌុកម្ពលសិលា* ជាថ្មមានសម្បុរដូចជាសំពត់កម្ពលក្រហម ប្រតិស្ឋាននៅក្រោមដើមបារិច្ឆត្តកព្រឹក្សនៅឋានត្រ័យត្រឹង្ស ជាអាសនៈសម្រាប់ព្រះឥន្ទគង់កំសាន្តមួយដងមួយកាល ឬ គង់រំពឹងមើលហេតុការណ៍អ្វីមួយ ដែលប្លែកគួរឱ្យព្រងើយកន្តើយពុំកើត ។

ជនទាំង ៣៣ នាក់ជាមិត្រនៃមឃមាណព លុះអស់ជីវិត ក៏បានទៅកើតជាទេវបុត្រនៅឋានត្រ័យត្រឹង្សសួគ៌ សុទ្ធសឹងតែមានប្រាសាទវិមានទិព្វទីទៃៗរៀងខ្លួន ។ ដោយហេតុនេះ បានជាឋានសួគ៌នោះ, ដែលពីដើមជាឋានរបស់ពួកអសុរ មាន*វេបចិត្តិអសុរិន្ទ* ជាប្រមុខ, ក៏ត្រឡប់មកជាឋានរបស់ព្រះឥន្ទ និងពួកទេវតាថ្មីនោះទៅវិញ, មានឈ្មោះថាឋាន *ត្រ័យត្រឹង្ស* ឬ *តាវត្តិង្ស* ពីព្រោះមុនដំបូង ទេវតាពួកនេះ មានគ្នា ៣៣ រូប ដោយមានព្រះឥន្ទជាស្ដេចគ្រប់គ្រង ។ ព្រះឥន្ទថែមទាំងមានអំណាចត្រួតត្រាលើពួកលោកបាលទេវរាជទាំង ៤ នៅឋាន *ចាតុម្មហារាជិកាសួគ៌* ផងទៀត ។ ឋានត្រ័យត្រឹង្ស នៅលើផ្ទៃកំពូលនៃ*ភ្នំសុមេរុ* ។ ឯឋាន*ចាតុម្មហារាជិកា* នៅលើកំពូល *ភ្នំបរិភណ្ឌ* (១) ក្នុងទិសធំទាំង ៤ ជិត *ភ្នំសុមេរុ* ។

*ជាងឈើ* ទៅកើតជា *វិស្សុកម្មទេវបុត្ត* ក្នុងត្រ័យត្រឹង្សសួគ៌ដែរ ។

---

(១) ភ្នំបរិភណ្ឌនេះមាន ៧ មានឈ្មោះថា យុគន្ធរ, នេមិន្ធរ, ឥសធរ ឬឥសន្ធរ,ករវីក, សុទស្សន, វិនតក, អស្សកណ្ណ, ហៅថា ភ្នំសត្តបរិភណ្ឌ ។ ភ្នំបរិភណ្ឌទាំង ៧ នេះ នៅព័ទ្ធជុំវិញភ្នំសុមេរុ ។ ភ្នំសុមេរុនេះ មានឈ្មោះហៅបាន ៥ យ៉ាងគឺ សុមេរុ, មេរុ, នេរុ, សិនេរុ, តិទិវាធរ ។ បណ្ដាឈ្មោះទាំង ៥ យ៉ាងនេះ តិទិវាធរ ជាឈ្មោះបញ្ជាក់ឱ្យឃើញថា ភ្នំទ្រទ្រង់នូវឋាន តិទិវៈ គឺឋានត្រ័យត្រឹង្ស ដ្បិតឋានត្រ័យត្រឹង្សឋិតនៅលើកំពូលភ្នំនេះ ។

*ដំរីសឹក* ដែលព្រះរាជាមគធរដ្ឋទ្រង់ប្រោសប្រទានឱ្យជាជំនិះនៃមឃ-មាណព និងមិត្រ ៣៣ នាក់នោះ លុះអស់ជីវិត ក៏បានទៅកើតជា *ឯរាវណទេវបុត្ត* នៅឋានត្រ័យត្រឹង្ស ។ ក្នុងឋានសួគ៌ មិនមានសត្វតិរច្ឆានមែនទែនទេ ប៉ុន្តែ កាលបើព្រះឥន្ទ និងទេវបុត្តជាមិត្រទាំង ៣៣ រូបនោះត្រូវការឱ្យមានដំរីទិព្វជាជំនិះមួយដងមួយកាល, *ឯរាវណទេវបុត្ត* ក៏និម្មិតឱ្យខ្លួនក្លាយទៅជាដំរីទិព្វមួយធំ មានក្បាលចំនួន ៣៤, ក្បាលមួយធំកណ្តាលជាជំនិះរបស់ព្រះឥន្ទ និងក្បាល ៣៣ ឯទៀត ជាជំនិះទេវបុត្តទាំង ៣៣ រូប ។ ដំរីនិម្មិតនោះឈ្មោះថា *ឯរាវ័ណ*, កាលបើបានបំពេញកិច្ចរបស់ខ្លួនរួចហើយ ក៏ក្លាយខ្លួនទៅជាទេវបុត្តដូចដើមវិញដដែល, ឯប្រាសាទវិមានរបស់ខ្លួន មានស្រេចស្រាប់ជាធម្មតា ។

នាង *សុធម្មា* បានទៅកើតជាស្ត្រីសួគ៌ មានឈ្មោះថា *សុធម្មា* ដដែល, ជាជាយានៃព្រះឥន្ទ ។ អានិសង្សនៃ *រោងជាង* ដែលនាងបានចូលបុណ្យជាមួយនឹងមឃមាណពជាប្តីនោះ បានកើតជាសាលាទិព្វមួយធំទូលំទូលាយ នៅឋានត្រ័យត្រឹង្ស, សាលាទិព្វនេះឈ្មោះ *សុធម្មាទេវសភា* ជាសាលាទិព្វដែលទេវតាទាំងឡាយតែងមកប្រជុំគ្នា តាមពេលដែលត្រូវប្រជុំ មានថ្ងៃ ៨ កើតនៃមនុស្សលោកជាដើម ។

នាង *សុនន្ទា* បានទៅកើតជាស្ត្រីសួគ៌ដែរ មានឈ្មោះថា *សុនន្ទា* ដដែល, ជាជាយានៃព្រះឥន្ទ ។ អានិសង្សនៃ *ស្រះបោក្ខរណី* គឺស្រះឈូករបស់នាងនោះ បានកើតជាស្រះបោក្ខរណីទិព្វមួយធំទូលាយ នៅឋានត្រ័យត្រឹង្ស មានឈ្មោះថា *ស្រះនន្ទា* ជាទីកំសាន្តសប្បាយនៃពួកទេវតា ។

នាង *សុចិត្តា* បានទៅកើតជាស្ត្រីសួគ៌ ជាជាយានៃព្រះឥន្ទដែរ មាននាមថា *សុចិត្តា* ដូចដើមដដែល ។ អានិសង្សនៃ *សួន* របស់នាងនោះបានកើតជាសួនទិព្វធំមួយ នៅឋានត្រ័យត្រឹង្ស មានឈ្មោះថាសួន *ចិត្តលតាវ័ន* ជាទីកំសាន្តនៃទេវតាទាំងឡាយ ។ កាលបើទេពតាណាជិតនឹងច្យុត តែងតែមានបុព្វនិមិត្តទាំង ៥ ណាមួយ

កើតប្រាកដឡើង, ជួនកាលទេពតាឯទៀតគេបានដឹង គេតែងនាំទេពតាដែលជិតនឹងច្យុតនោះឱ្យទៅកំសាន្តនៅសួនទិព្វឈ្មោះចិត្តលតាវ័ននេះ ដើម្បីបន្ធូរចិត្តកុំឱ្យតក់ស្លុត ។

**សុជាតា ចន ការំ កត្វា ឯកិស្សា គិរិកន្ទរាយ ពក-សកុណិកា ហុត្វា និព្វត្តិ** ប្លែកពីគេតែនាង *សុជាតា* ដែលជាស្ត្រីល្ងង់ យល់ខុស, លុះធ្វើមរណកាលស្លាប់ទៅ កើតជា កុកញី នៅទីជិតញកភ្នំមួយ, ចេះតែសញ្ជរភ្ញើកចុះភ្ញើកឡើងរកមច្ឆជាតិជាចំណីអាហារតាមធម្មតារបស់សត្វកុក ។

ព្រះឥន្ទ *មឃទេវរាជ* រំពឹងឃើញថា " នាងសុធម្មា, សុនន្ទា, សុចិត្តាបានមកកើតនាឋានត្រ័យត្រឹង្សជាមួយនឹងអញដែរហើយ, ចុះនាងសុជាតា តើស្លាប់ទៅកើតនៅទីណា ? " ទ្រង់ជ្រាបច្បាស់ដោយញាណទិព្វថា " ឱ ! សុជាតាអើយ ! ហេតុតែវាល្ងង់ វាយល់ខុស, វាឥតមានសទ្ធាជ្រះថ្លា ឥតបានធ្វើបុណ្យអ្វីបន្តិចបន្តួចសោះ ឥឡូវវាទៅកើតជាសត្វតិរច្ឆាន ! ឱ, គួរអាណិតវាណាស់ ! ឥឡូវអញគួរតែទៅណែនាំវាឱ្យធ្វើបុណ្យ ហើយនឹងនាំយកវាមកក្នុងឋានត្រ័យត្រឹង្សនេះ ឱ្យវាបានជាភរិយាអញដូចពីដើមតទៅទៀត ! " ។

លំដាប់នោះ, ព្រះឥន្ទក៏ចុះមកកាន់ឋានមនុស្ស, បាននិម្មិតព្រះអង្គជាសត្វកុក, បាននាំកុកញីនោះទៅឱ្យឃើញឋានត្រ័យត្រឹង្ស, រួចហើយនាំយកមកកាន់កន្លែងដើមវិញ, បានពន្យល់ណែនាំឱ្យកាន់សីល ៥ ខ្ជាប់ ។ តពីនោះមក, ព្រះឥន្ទបានចុះមកពិសោធ ៣ ដង ដោយនិម្មិតធ្វើជាត្រីងាប់ លុះកុកញីឃើញត្រីងាប់ ក៏ចាប់ដោយចំពុះបំរុងនឹងលេប, ត្រីងាប់នោះក៏កម្រើកចុងកន្ទុយខ្ញើក១ ឱ្យដឹងថាជាត្រីរស់ទេ, កុកញីក៏លែងហ៊ានស៊ីទៅវិញ ។ កុកញីអត់អាហារដោយរកត្រីងាប់ស៊ីពុំបាន ព្រោះខ្លាចដាច់សីល ក៏ចេះតែស្គមទៅ១, ពុំយូរថ្ងៃប៉ុន្មាន ក៏ងាប់ទៅ ទៅកើតជាកូនស្រីនៃស្មូនឆ្នាំងនៅស្រុកពារាណសី ដែនកាសី ។ ព្រះឥន្ទក៏និម្មិតព្រះអង្គជាឈ្មួញម្នាក់បររទេះពពាយ

នាយលក់ផ្លែល្ពៅ ដែលសុទ្ធតែជុំមាសសោះទេ, បានឱ្យផ្លែល្ពៅទាំងអស់នោះទៅនាង ឱ្យជាស្រីមានទ្រព្យសម្បត្តិបរិបូណ៌, បានណែនាំឱ្យធីតានោះកាន់សីល ៥ រឹតតែខ្ជាប់ខ្ជួនថែមទៀត ។ លុះធីតានៃស្មួនផ្លាំងអស់ជីពជន្ម ក៏បានទៅកើតជាបុត្រីនៃ *វេបចិត្តិ-អសុរិន្ទ* ជាវេរិបុគ្គលនៃព្រះឥន្ទ ព្រោះអសុរនេះជាសត្រូវនឹងព្រះឥន្ទ តាំងពីកាលដែលបរាជ័យចាញ់អំណាចព្រះឥន្ទ ហើយបានចងគំនុំគុំគួនចំពោះព្រះឥន្ទ និងទេពតាជាមិត្តរបស់ព្រះឥន្ទ, ក៏ជាប់មានគំនុំរៀងមក, បុត្រីនៃអសុរនេះ មាននាមថា *សុជាតា* ដូចនាមដើមជាអសុរកញ្ញា ហៅថា *សុជាតា - អសុរកញ្ញា* ។ ដោយអំណាចផលានិសង្សនៃ *សីល៥* ដែលនាងនេះរក្សាហ្មត់ចត់តាំងពីនៅជាកុកញីរៀងមក, អសុរកញ្ញានេះមានរូបឆោមលោមព័ណ៌ល្អស្អាតឥតខ្ចោះ ។ នាងនេះចេះតែប្រកែកពុំព្រមទទួលយកបុរសអសុរណាមួយ ជាគូស្រករសោះ, ទើបវេបចិត្តិអសុរិន្ទជាបិតាអនុញ្ញាតឱ្យជ្រើសរើសគូស្រករតាមចិត្តខ្លួនចុះ ។ នៅពេលដែលពួកអសុរ កំលោះៗកំពុងជួបជុំកុះករ ដើម្បីបង្ហាញខ្លួនឱ្យនាងនេះជ្រើសរើសគូស្រករ, ព្រះឥន្ទបានជ្រាបការណ៍នេះ ក៏ស្តេចយាងមកនិម្មិតព្រះអង្គជាអសុរចាស់ម្នាក់ ឈរត្រង់ទីបំផុតនៃពួកអសុរជាបរិស័ទដែលកំពុងឈរត្រៀបត្រា ។ នាងសុជាតា គ្រាន់តែក្រឡេកទៅឃើញ ក៏មានចិត្តស្នេហាប្រតិព័ទ្ធដ៏ខ្លាំងក្លា ព្រោះនាង និងព្រះឥន្ទមានបុព្វេសន្និវាសជាគូព្រេងគ្នាមក ក៏ស្រែកប្រាប់គេថា " អ្នកនុ៎ះជាប្តីខ្ញុំ ! ហើយក៏បោះកម្រងផ្កាទៅលើអសុរចាស់ ជាឥន្ទនិម្មិតនោះភ្លាម ។ អសុរចាស់ក៏ចាប់ដៃនាងសុជាតាអសុរកញ្ញាស្រែកឮខ្លាំងប្រាប់ពួកអសុរថា " អញជាព្រះឥន្ទ !" ហើយហោះទៅ ។ មឃទេវរាជចាប់ដើមតាំងពីបាននាងសុជាតានេះមកជាជាយា ក៏មានព្រះនាមពិសេសមួយទៀតថា *សុជម្បតិ* ប្រែថា " ប្តីនាងសុជាតា " ។

លុះព្រះសក្យមុនីសម្ពុទ្ធទ្រង់សម្តែងរឿងនេះដោយពិស្តារចប់ហើយ, ព្រះអង្គទ្រង់ប្រទានព្រះធម៌ទេសនាថា ៖

**អប្បមាទេន មឃវា ទេវានំ សេដ្ឋតំ គតោ**
**អប្បមាទំ បសំសន្តិ បមាទោ គរហិតោ សទា ។**

" មឃមាណពដែលឥឡូវបានទៅកើតជាព្រះឥន្ទ្រ មាននាមពិសេសថា *មឃវា* តាមនាមដើមកាលនៅជាមនុស្សថា **មឃៈ** , បានដល់នូវសេដ្ឋភាព គឺសេចក្ដីស្ញើចសរសើររបស់ពួកទេវតា, ក៏ដោយសារតែមឃមាណពនោះមិនប្រមាទ; អ្នកប្រាជ្ញទាំងឡាយ តែងតែស្ញើចសរសើរនូវសេចក្ដីមិនប្រមាទ និងបុគ្គលមិនប្រមាទ, តែងតែរិះគន់និន្ទាសេចក្ដីប្រមាទ និងបុគ្គលអ្នកប្រមាទ ( ព្រោះ *អប្បមាទៈ* ជាមូលជាប្រភពនៃកុសលធម៌, *បមាទៈ* ជាមូល ជាប្រភពនៃអកុសលធម៌ ) " ។

លុះចប់ព្រះធម៌ទេសនានេះហើយ *មហាលិ-លិច្ឆវីរាជ* ក៏បានសម្រេចសោតាបត្តិផល ។ ពុទ្ធបរិស័ទមានចំនួនច្រើនដែលបានស្ដាប់ព្រះធម៌ទេសនានេះដែរក៏បានសម្រេចលោកុត្តរផល មានសោតាបត្តិផលជាដើម ។

( គម្ពីរព្រះពុទ្ធសាសនា ដែលថ្លែងរឿងនិទានពីជនអ្នកមានចិត្តជាកុសល បានសាងសន្សំបុណ្យមានការសង់សាលាសំណាក់, លើកថ្នល់, សង់ស្ពាន, ជីកស្រះ, ជីកអណ្ដូងជាដើម ជាប្រយោជន៍ដល់សាធារណជន ដូចមឃមាណពដែរនោះ នៅមានច្រើនទៅទៀត, អស់លោកអ្នកដែលធ្លាប់បានរៀន ធ្លាប់បានស្ដាប់ធម៌ទេសនា ក៏សឹងបានជ្រាបស្រាប់ហើយ, គួរពិចារណាឱ្យត្រាតែឃើញការណ៍ពិតទៀតផងចុះ ។ បើអស់លោកអ្នកខ្លះ ដែលជឿកម្ម និងផលនៃកម្មពុំទាន់ស៊ប់នៅឡើយទេ ក៏គួរកុំអាលបដិសេធចោលថាពុំពិត, គួររិះរេពិចារ-ណារឿយៗ ឱ្យល្អិតល្អន់ចត់ទៅទៀត កុំប្រញាប់យកហេតុដទៃ ក្រៅពីព្រះពុទ្ធភាសិតមកលុបលាងភ្លាមៗ នូវរឿងពិតឡើយ ។ គួរយល់មួយយ៉ាងទៀតថា កម្មជារបស់អ្នកធ្វើ ពុំមែនជារបស់អ្នកឯទៀតទេ, កម្មរមែងឱ្យផលតាមពូជដើម, ដូចពូជឈើនិងដំណាំទាំងពួងដូច្នោះដែរ, ព្រះពុទ្ធព្រះអង្គគ្រាន់តែបានជ្រាប ហើយទ្រង់ប្រាប់ផ្លូវប៉ុណ្ណោះ, ព្រះអង្គពុំមែនសាងកម្មឱ្យយើងរាល់គ្នាទេ, កម្មដែលអ្នកណាធ្វើក៏ជារបស់អ្នកនោះឯង ) ។

**រឿងនិទានមឃមាណព ចប់ដោយសង្ខេប**

# អំពីភិក្ខុនីសង្ឃ

រៀបរៀងដោយ : **ឈន អៀម**

នៅក្នុងអត្ថបទមុន យើងបានពិនិត្យមើលអំពីភិក្ខុសង្ឃរួចហើយ ។ នៅក្នុងអត្ថបទនេះវិញ យើងនឹងពិនិត្យមើលអំពីភិក្ខុនីសង្ឃ នៅក្នុងប្រវត្តិពុទ្ធសាសនាកន្លងទៅ ដើម្បីមានជាគំនិតជួយបំភ្លឺទៅលើនិន្នាការថ្មីបច្ចុប្បន្ននេះ . ក្រោមការជំរុញនៃអង្គការសិទ្ធិមនុស្ស . ក្នុងការប៉ុនប៉ងពង្រីកពង្រឹងសិទ្ធិស្ត្រី ឈានទៅដល់ការចាត់តាំងអង្គការដូនជី ហើយឆ្ងាយជាងនេះទៀត ឈោងទៅរកការចាត់តាំងឱ្យមានឡើងវិញ នូវគណៈភិក្ខុនី ឬភិក្ខុនីសង្ឃ (The Order of Nuns) ។

ភិក្ខុនី គឺជាសមាជិកភេទស្រីនៃគណៈសង្ឃពុទ្ធសាសនិក ដែលបានឧទ្ទិសជីវិតចំពោះសាសនា, រស់នៅក្នុងអាស្រម ឬកុដិ ក្នុងភាពក្រីក្រ និង រក្សាព្រហ្មចរិយធម៌ជាអចិន្ត្រៃយ៍ ។ ឈ្មោះភិក្ខុនី ត្រូវបានគេស្គាល់ដូចនេះ ដោយសារទម្លាប់របស់គេដើរសុំទានអាហារ ឬហៅតាមភាសាខ្មែរយើងថា បិណ្ឌបាតចង្ហាន់ ។ ពាក្យភិក្ខុនីនេះក្លាយពីកិរិយាស័ព្ទបាលីថា ភិក្ខតិ (សំ.ភិក្សតិ) ដែលមានន័យថា «សុំ» (ទាន) ។ មាននិយមន័យជាច្រើនរបស់ពាក្យភិក្ខុ, ក៏ត្រូវបានគេយកមកអនុវត្តចំពោះពាក្យភិក្ខុនីដែរ, គេឃើញមានប្រើពាក្យនេះជាញឹកញយនៅក្នុងអដ្ឋកថា ។ សមាជិកស្ត្រីភេទនៃគណៈសាសនាជេន ក៏ដូចគ្នាដែរ ត្រូវបានគេស្គាល់ដោយស័ព្ទ «ភិក្ខុនី», ទោះបីមានស័ព្ទផ្សេងទៀតត្រូវបានប្រើដែរក៏ដោយ ដូចជា និគ្គណ្ឋី, សាហុណី, និងអជ្ជា ។ ជាងនេះទៀត, អក្សរសាស្ត្រសាសនារបស់ជេនបង្ហាញថា ស្ត្រីទាំងឡាយដែលបោះបង់ជីវភាពជាគ្រហស្ថ ដើម្បីក្លាយទៅជាភិក្ខុនីនោះ ពុំមែនជាគំនិតថ្មីមាននៅតែក្នុងពុទ្ធសាសនា ក្នុងសម័យកាលដែលព្រះពុទ្ធសាសនាបានកើតមានឡើងនៅក្នុងប្រទេសឥណ្ឌានោះប៉ុណ្ណោះទេ ។ ដោយសារមានស្ត្រីទាំងឡាយកាន់តែច្រើនឡើងៗ

ចាកចោលជីវភាពជាគ្រហស្ថដើម្បីក្លាយខ្លួនទៅជាភិក្ខុនីក្នុងអំឡុងសម័យកាលព្រះពុទ្ធ និងព្រះមហាវីរៈមានព្រះជន្មគង់នៅ, ដោយប្រព័ន្ធសាសនាទាំងពីរ ត្រូវបានស្ថាបនាឡើងដោយព្រះពុទ្ធ និងព្រះមហាវីរៈនោះ, ទើបកើតមាន *ភិក្ខុនីសង្ឃ* ដែលមានប្រព័ន្ធគ្រប់គ្រងប្រហាក់ប្រហែលគ្នា ។

ស្ត្រីដំបូងគេ ដែលបានបួសក្នុងពុទ្ធសាសនា, ហើយដែលបានក្លាយជាភិក្ខុនី គឺព្រះមហាបជាបតិគោតមី, ជាព្រះមាតុច្ឆា (ម្ដាយមីង) និងជាព្រះមាតាចិញ្ចឹមរបស់ព្រះពុទ្ធ ។ ក្រោយផ្នួសរបស់ព្រះនាងគោតមី និងក្រោយផ្នួសរបស់ស្រីស្នំទាំងប្រាំរយរបស់ព្រះនាងផងដែរ, ដែលទាំងអស់ជាស្ត្រីសាក្យត្រកូល, ទើបមានស្ត្រីដទៃទៀតចូលមកបួស, ដោយហេតុនេះ បង្កើតបានទៅជា*ភិក្ខុនីសង្ឃ* ។ យោងតាមដំណើររឿងនៅក្នុងចុល្លវគ្គនៃវិន័យបិដក បានថែងថា ក្រោយការសោយព្រះទិវង្គតនៃព្រះស្វាមីព្រះនាង គឺព្រះបាទសុទ្ធោទនៈ, ព្រះនាងមហាបជាបតិគោតមី បានចូលទៅថ្វាយបង្គំព្រះពុទ្ធ កាលព្រះអង្គគង់នៅកបិលវត្ថុ ហើយបានទូលសុំព្រះអង្គអនុញ្ញាតឱ្យស្ត្រីទាំងឡាយ បានបួសនៅក្នុងសំណាក់សាសនាព្រះអង្គផង ។ ព្រះពុទ្ធបដិសេធសំណូមពរនេះ ជាបន្តបន្ទាប់ ។ ចំណោរកាលជាខាងក្រោយមក, នៅពេលព្រះពុទ្ធបានយាងពីកបិលវត្ថុទៅគង់នៅវេសាលី, ព្រះនាងគោតមីក៏បានយាងទៅតាមព្រះពុទ្ធក្នុងទីនោះដែរ ជាមួយនឹងស្ត្រីជាសាក្យត្រកូលដទៃទៀត ដោយមានសក់កាត់ចោល និងស្លៀកដណ្ដប់សំពត់ពណ៌លឿង ។ ស្ត្រីទាំងឡាយនោះឈរនៅខាងក្រៅប្រឋច្រកផ្លូវចូលទៅកាន់វត្ត ដោយមានជើងហើមប៉ោងប្រលាក់ដោយធូលី, មានទឹកមុខស្រពាប់ស្រពោន, ក្រៀមក្រំ, ទួញយំ និងពោរពេញដោយជលនេត្រ ( ទឹកភ្នែក ) ។ ព្រះអានន្ទ ដែលបានឃើញព្រះនាងគោតមី និងបានស្ដាប់ព្រះនាងរៀបរាប់រឿងរបស់ព្រះនាងរួចហើយ ក៏មានចិត្តអាណិតអាសូរ រួចចូលទៅក្រាបបង្គំទូលព្រះពុទ្ធ, ហើយអង្វរព្រះអង្គឱ្យព្រមទទួលសំណូមពររបស់ព្រះនាង ។ សូម្បីនៅលើក

ទីបីនេះទៀត ព្រះពុទ្ធក៏ទ្រង់នៅតែបដិសេធសំណូមពររបស់ព្រះនាង ។ បន្ទាប់មក, ព្រះអានន្ទ, ដោយបានគិតឃើញផែនការមួយផ្សេង, ទើបទូលសួរចំពោះព្រះពុទ្ធថា " បពិតព្រះអង្គ, ស្ត្រីទាំងឡាយ កាលបើគេលះបង់ផ្ទះសម្បែង ហើយចូលមកបួសជាអនាគារិក (អ្នកគ្មានផ្ទះសម្បែង) ឋិតនៅក្រោមព្រះធម៌ និងវិន័យរបស់ព្រះដ៏មានជោគ, តើគេអាចសម្រេចសោតាបត្តិផល, ឬសកទាគាមិផល ឬក៏អនាគាមិផលបានឬទេ ? " ។ នៅពេលនោះ ព្រះពុទ្ធទ្រង់បានឆ្លើយតបជាវិជ្ជមានចំពោះសំណួរនេះ, ព្រះអានន្ទក៏ធ្វើការអង្វរករម្តងទៀត ។ នៅទីបំផុត, ព្រះពុទ្ធបានយល់ព្រមឱ្យព្រះនាងបជាបតិគោតមីបានបួស ក្រោយការសន្យារបស់ព្រះនាងព្រមទទួលប្រតិបត្តិគរុធម៌ប្រាំបីយ៉ាង ដើម្បីបំពេញលក្ខណសម្បត្តិឱ្យបានទទួល *បព្វជ្ជា* ក៏ដូចជាសម្រាប់ *ឧបសម្បទា* ដែរ ។ សូម្បីតែក្រោយពេលព្រះពុទ្ធបានផ្តល់ការអនុញ្ញាតដូច្នេះក៏ដោយ, ក៏គេបាននិយាយថា ព្រះពុទ្ធបានមានបន្ទូលប្រាប់ព្រះអានន្ទថា ៖ ដោយសារស្ត្រីចូលរួមនៅក្នុងជួរសង្ឃ, ព្រះធម៌និងព្រះវិន័យដែលព្រះតថាគតបានប្រកាស ហើយនេះដែលអាចឋិតថេរតាំងនៅបានមួយពាន់ឆ្នាំ, ឥឡូវនេះ នឹងឋិតថេរតាំងនៅបានតែប្រាំរយឆ្នាំប៉ុណ្ណោះទេ ។ ដោយគិតតាមតួលេខនេះ ជាប្រមាណវិធី, គេអាចសង្កេតថា ព្រះពុទ្ធទ្រង់បានឃើញមុននូវការស្រុតចុះដ៏ឆាប់នៃព្រះធម៌ និងព្រះវិន័យដែលព្រះអង្គបានប្រកាស ដោយសារតែស្ត្រីបានទទួលការអនុញ្ញាតឱ្យចូលក្នុង ជួរសង្ឃ ។ ទោះបីជាសេចក្តីរៀបរាប់របស់វិន័យបិដក មិនបានផ្តល់ហេតុផលសម្រាប់ការទស្សន៍ទាយរបស់ព្រះពុទ្ធក៏ដោយ, ក៏ស្នាដៃអក្សរសាស្ត្រក្រោយមក ដូចជា *បូជាវលិយ* (ស្នាដៃជាភាសាសីហឡ្សះរបស់មយូរបាទថេរ) សន្និដ្ឋានថា ការស្ទាក់ស្ទើរព្រះទ័យនិងការទស្សន៍ទាយរបស់ព្រះពុទ្ធ ចេញមកតែពីធម្មជាតិមិននឹងនរបស់ស្ត្រី ។ គរុធម៌ទាំងប្រាំបីប្រការ ដែលព្រះនាងបជាបតិគោតមីត្រូវប្រតិបត្តិតាម ដើម្បីអាចទទួលផ្នួសបាន ហើយដែលក្រោយមក ស្ត្រីទាំងអស់ត្រូវអនុវត្តតាម ទុកដូចជា

ល័ក្ខខ័ណ្ឌ ដើម្បីបានបួសចូលក្នុងជួរសង្ឃនោះ គឺមានដូចតទៅនេះ :

១. ភិក្ខុនីមួយរូប សូម្បីតែមានអាយុផ្នួសមួយរយឆ្នាំក៏ដោយ ក៏ត្រូវតែគោរពភិក្ខុ ទោះបីជាមានវ័យផ្នួសទើបបានមួយថ្ងៃក៏ដោយ ។

២. ភិក្ខុនី មិនត្រូវគង់ចាំវស្សា (រដូវភ្លៀង) នៅក្នុងជនបទណាមួយ ដែលគ្មានភិក្ខុទាំងឡាយគង់នៅទេ ។

៣. រៀងរាល់កន្លះខែម្តង ភិក្ខុនីត្រូវបំពេញកិច្ចការពីរយ៉ាងគឺ : សុំអំពីភិក្ខុសង្ឃ នូវឧបោសថសីល និងសុំឱ្យភិក្ខុសង្ឃផ្តល់ឱវាទ - ទូន្មាន ។

៤. នៅទីបញ្ចប់នៃការចាំវស្សា ភិក្ខុនីត្រូវចូលរួមក្នុងពិធីបវារណា ដឹកនាំដោយគណៈសង្ឃទាំងពីរ ( ភិក្ខុសង្ឃ និងភិក្ខុនីសង្ឃ ) ហើយនៅក្នុងពិធីនីមួយៗ ភិក្ខុនីត្រូវសុំខមាទោសចំពោះកំហុសឯណានីមួយ ដែលសង្ឃបានឃើញ, ឮ ឬសង្ស័យ ។

៥. ភិក្ខុនីណាមួយប្រព្រឹត្តបំពានលើសិក្ខាបទសង្ឃាទិសេស ត្រូវដាក់ខ្លួនទទួលវិន័យពិសេស (បក្ខមានត្ត) អស់រយៈពេលកន្លះខែ នៅចំពោះមុខក្រុមនីមួយៗនៃគណៈសង្ឃទាំងពីរ ។

៦. សាមណេរីត្រូវហ្វឹកហ្វឺនខ្លួននៅក្នុងសិក្ខាបទទាំង ៦ (បញ្ចសីល រួមនិងសិក្ខាបទវិកាលភោជនា) អស់រយៈពេលពីរឆ្នាំ ហើយបន្ទាប់មក ត្រូវសុំ *ឧបសម្បទា* ជាភិក្ខុនី អំពីក្រុមជំនុំគណៈសង្ឃទាំងពីរ ។

៧. ភិក្ខុនី មិនត្រូវជេរបញ្ចោរ ឬប្រមាថមាក់ងាយភិក្ខុដោយប្រការណាមួយទេ, សូម្បីតែដោយវិធីបញ្ឆិតបញ្ឆៀង ក៏ពុំបានដែរ ។

៨. ភិក្ខុអាចទូន្មានប្រៀនប្រដៅភិក្ខុនីបាន, ប៉ុន្តែ ភិក្ខុនី មិនត្រូវបានអនុញ្ញាតឱ្យទូន្មានប្រៀនប្រដៅភិក្ខុទេ ។

រយៈកាលហ្វឹកហ្វឺនពីរឆ្នាំ មិនតម្រូវទៅលើព្រះនាងបជាបតិគោតមី ដូចដែលបានកំណត់នៅក្នុងសិក្ខាបទទីប្រាំមួយទេ ពីព្រោះ ព្រះពុទ្ធទ្រង់បានប្រកាសថា

ការទទួលព្រមប្រតិបត្តិតាមគរុធម៌ទាំងប្រាំបីដោយព្រះនាងផ្ទាល់ សន្មតស្មើនឹងផ្នួសរបស់ព្រះនាងជាសាមណេរី អស់រយៈកាលពីរឆ្នាំរួចទៅហើយ ។ បុព្វសិទ្ធិនេះ ក៏ត្រូវបានប្រទានទៅឱ្យស្ត្រីសាក្យត្រកូលទាំងប្រាំរយផងដែរ ដែលបានដង្ហែព្រះនាងមក ។ ប៉ុន្តែតាមធម្មតា ស្ត្រីអ្នកសាកល្បងដើម្បីផ្នួស (A probationer) មុនគេ ចាប់ផ្ដើមហ្វឹកហ្វឺនរយៈពេលពីរឆ្នាំ នៅក្នុងសិក្ខាបទទាំងប្រាំមួយ ត្រូវតែបានសេចក្ដីយល់ព្រមឱ្យហ្វឹកហ្វឺនអំពីសង្ឃ ( សិក្ខាសម្មតិ ) ជាមុនសិន ។ កាលបើបានសេចក្ដីយល់ព្រមពីសង្ឃហើយ, គេត្រូវសន្យាដោយជាក់ស្ដែងថា : "នាងខ្ញុំប្រកាសទុកជាសំណូមពរមិនអាចបំពារបំពានបាន, នៅក្នុងអំឡុងពេលពីរឆ្នាំ, គឺវៀរចាកការសម្លាប់សត្វមានជីវិត, មិនលួច, មិនប្រព្រឹត្តខុសព្រហ្មចរិយធម៌, មិននិយាយកុហក, មិនផឹកទឹកស្រវឹង និងមិនបរិភោគអាហារក្នុងពេលម៉ោងហាមឃាត់ ពោលគឺ រវាងពេលថ្ងៃត្រង់និងពេលថ្ងៃរះនៃថ្ងៃបន្ទាប់" ។ គេមិនតម្រូវឱ្យអ្នកសាកល្បងដើម្បីផ្នួស ផ្ដាច់ចំណងរបស់ខ្លួនពីជីវភាពគ្រហាវាសនៅក្នុងដំណាក់កាលសាកល្បងនោះទេ ទោះបីភាគច្រើនគេបានផ្ដាច់ ។ ជាទូទៅ អ្នកសាកល្បងដើម្បីផ្នួស រស់នៅក្នុងលំនៅសម្រាប់ក្រុមរបស់ខ្លួន ក្នុងអំឡុងកាលឋិតក្រោមការថែទាំរបស់ដូនជីដ៏មានពិសោធម្នាក់ជួយថែរក្សា និងហ្វឹកហ្វឺនខ្លួនឯងក្នុងសិក្ខាបទទាំងប្រាំមួយ ។ អ្នកសាកល្បងដើម្បីផ្នួសតាមធម្មតា ត្រូវបានគេហៅថា *សិក្ខមានា* ។ នៅទីបញ្ចប់នៃការសាកល្បងពីរឆ្នាំ, សិក្ខមានាបានក្លាយជាភិក្ខុនី ក្រោយបានទទួលឧបសម្បទារួចហើយ ។

មានតែក្រោយពេលបានទទួលការបួសថ្នាក់ខ្ពស់គឺ ឧបសម្បទាប៉ុណ្ណោះទេ, ទើបសាមណេរីបានក្លាយទៅជាភិក្ខុនីដ៏ពេញលក្ខណៈ ។ ដោយបានទទួលការបួសថ្នាក់ខ្ពស់នេះ ភិក្ខុនីត្រូវបានគេចាត់ទុកជាថេរីមួយរូប ជួយទ្រោលភារកិច្ចបង្ហាត់-បង្រៀនបន្ថែម ។ ចាប់ពីពេលនោះទៅ លោកផ្ដើមយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាក្នុងការប្រតិបត្តិធ្វើសមាធិ ។ ដោយប្រការយ៉ាងនេះ, សាមណេរី ដែលសុំ

ផ្នួសថ្នាក់ខ្ពស់ ( ឧបសម្បទា ) ត្រូវឆ្លើយតបសំណួរម្ភៃបួន, ទាល់តែគណៈសង្ឃទាំងពីរគាប់អធ្យាស្រ័យជាមុនរួចហើយ, ទើបផ្នួសថ្នាក់ខ្ពស់ត្រូវបានអនុញ្ញាត ។ ក្នុងបណ្ដាសំណួរទាំងម្ភៃបួន មានសំណួរដប់មួយនិយាយអំពីរូបភាពនៃរោគស្ត្រីភេទ (Gynaecological deformities) និងប្រាំសំណួរស្ដីពីជំងឺ ជាអាទិ៍ ៖ ឃ្លង់, បូស, ត្រអក, របេង, ឆ្កួតជ្រូក ។ សំណួរក្រៅពីនេះ មានដូចតទៅនេះ ៖ . អ្នកជាមនុស្សមែនឬ ? . អ្នកជាស្ត្រីឬ ? . អ្នកជាស្ត្រីអ្នកជាទេឬ ? . អ្នកគ្មានជំពាក់បំណុលគេទេឬ ? តើអ្នកមិនជាប់ជំពាក់នឹងព្រះរាជបំរើទេឬ ? . តើអ្នកបានទទួលការយល់ព្រមពីឪពុកម្ដាយ និងប្ដីរបស់អ្នកហើយឬ ?. តើអ្នកមានអាយុម្ភៃឆ្នាំពេញហើយឬ ? . តើអ្នកមានបាត្រ និងស្បង់ចីពរឬទេ ? *អ្នកឈ្មោះអ្វី ? តើស្ត្រីអ្នកស្នើផ្នួសឱ្យអ្នកឈ្មោះអ្វី ?* ៈ

ដំបូងឡើយ, បុព្វសិទ្ធិសាកសួរសាមណេរី និងការផ្ដល់ផ្នួសជាន់ខ្ពស់អោយសាមណេរីនោះ គឺឋិតនៅក្នុងកណ្ដាប់ដៃនៃភិក្ខុ ; ប៉ុន្តែក្រោយមក ដោយសារមានការស្មុគស្មាញខ្លះកើតមានឡើង, បុព្វសិទ្ធិក៏ត្រូវបានផ្ទេរទៅឱ្យភិក្ខុនីទាំងឡាយដែលមានបទពិសោធន៍ និងមានសមត្ថភាពធ្វើកិច្ចការនេះវិញ នៅចំពោះមុខគណៈសង្ឃទាំងពីរដោយឡែក១ពីគ្នា ។ វិធីធ្វើប្រព្រឹត្តទៅយ៉ាងម៉ត់ចត់ណាស់ ។ ដោយបានប្រាប់ដំណឹងឱ្យដឹងមុនតាមរយៈភិក្ខុនីមួយអង្គដ៏មានបទពិសោធន៍ និងមានសមត្ថភាព, សាមណេរីបានមកកាន់ទីចំពោះមុខសង្ឃ ដោយមានចីពរពាក់លើស្មា ។ បន្ទាប់មក សាមណេរីនោះក្រាបថ្វាយបង្គំទៀបបាទានៃភិក្ខុនីទាំងឡាយ ហើយអង្គុយចុះបត់ជើងដោយមានដៃទាំងពីរប្រណម្យ ហើយសុំផ្នួសដោយពោលពាក្យថា" ខ្ញុំព្រះករុណាសុំសង្ឃអនុញ្ញាតឧបសម្បទា ។ សូមសង្ឃលើកស្ទួយខ្ញុំព្រះករុណា ដោយសេចក្តីអាណិតអាសូរផងចុះ" ។ ពាក្យនេះត្រូវថាឡើងវិញបីដង។ បន្ទាប់មក ភិក្ខុនីដ៏មានពិសោធន៍ និង មានសមត្ថកិច្ចចោទសួរសំណួរទាំងម្ភៃបួន ចំពោះសាមណេរី

ជាឧបសម្បទាបេក្ខៈនៅចំពោះមុខភិក្ខុនីសង្ឃ ។ កាលបើសំណួរទាំងឡាយត្រូវបានឆ្លើយដោយពេញចិត្តរួចហើយ ភិក្ខុនីជាថេរៈសួរភិក្ខុនីសង្ឃបីដងថា តើសង្ឃព្រមឱ្យសាមណេរីនេះបានឧបសម្បទាឬទេ ហើយប្រសិនបើព្រម ត្រូវនៅស្ងៀម, ប៉ុន្តែប្រសិនបើភិក្ខុនីណាមិនយល់ព្រម នោះត្រូវមានពុទ្ធដីកា ។ ប្រសិនបើទាំងអស់អង្គស្ងៀម, សាមណេរិត្រូវបានប្រកាសថាបានអនុញ្ញាតឱ្យទទួលឧបសម្បទាអំពីគណៈ-ភិក្ខុនិហើយ ។ សាមណេរីនោះ ត្រូវបានគេនាំភ្លាមទៅកាន់ទីចំពោះមុខភិក្ខុសង្ឃដែលគ្រងស្បង់ចីពរតាមបែបដូចៗគ្នា ហើយវិធីធ្វើដូចគ្នាត្រូវបានថាឡើងវិញ ។ ភិក្ខុជាថេរៈផ្តល់ពតិមានដល់ជំនុំសង្ឃថា សាមណេរីប្រាថ្នាសុំឧបសម្បទា, ថានាងបានឆ្លើយច្បាស់លាស់ហើយទាក់ទងនឹងសំណួរទាំងម្ភៃបួន និងថានាងបានបំបួសរួចហើយនៅខាងគណៈភិក្ខុនី ។ បន្ទាប់មក, ភិក្ខុទាំងឡាយក៏ត្រូវបានព្រះថេរៈស្នើសួរថាតើលោកទាំងឡាយយល់ព្រមឱ្យនាងបួស ឬមិនព្រម ។ ប្រសិនបើទាំងអស់អង្គនៅស្ងៀម នាងត្រូវបានប្រកាសយល់ព្រមឱ្យបួសដោយភិក្ខុសង្ឃ, ហើយក្លាយជាភិក្ខុនីពេញលក្ខណៈ ក្រោយពេលបានទទួលផ្នូសថ្នាក់ខ្ពស់អំពីផ្នែកទាំងពីរនៃសង្ឃ ។ បន្ទាប់មក ល័ក្ខខ័ណ្ឌបី ក្នុងចំណោមល័ក្ខខ័ណ្ឌទាំងបួន ត្រូវបានគេពន្យល់ចំពោះនវភិក្ខុនីជាអាទិ៍, អាហារ, សម្លៀកបំពាក់ និងថ្នាំព្យាបាលរោគ ។ ល័ក្ខខ័ណ្ឌដទៃផ្សេងទៀតត្រូវបានអនុញ្ញាតឱ្យភិក្ខុ ជាអាទិ៍ ការស្នាក់អាស្រ័យនៅក្នុងព្រៃ, ប៉ុន្តែ មិនអនុញ្ញាតឱ្យភិក្ខុនីទាំងឡាយទេ ប្រហែលជាបណ្តាលមកពីការមិនមានសន្តិសុខសម្រាប់ភិក្ខុនីដើម្បីរស់នៅម្នាក់ឯងក្នុងព្រៃ ដូចជាករណីជាក់ស្តែងនៃឧប្បលវណ្ណាថេរី ។ ជាងនេះទៀត, គេហាមមិនឱ្យភិក្ខុនីបំពារបំពានសិក្ខាបទប្រាំបីយ៉ាង ។ ការបណ្តែតបណ្តោយខ្លួនឱ្យល្មើសលើសិក្ខាបទទាំងប្រាំបីយ៉ាងនេះ គឺជាកំហុសយ៉ាងធ្ងន់ធ្ងរ ។ សិក្ខាបទទាំងប្រាំយ៉ាងនោះគឺ ការបណ្តែតបណ្តោយខ្លួនក្នុងមេថុនកម្ម, ការលួច, ការសម្លាប់, ការអួតអាងថាបានសម្រេចឈាន ( ឧត្តរិមនុស្សធម៌ ), ការព្រមព្រៀងសេពកាមជា

មួយបុរស, ការលាក់បាំងកំហុសធ្ងន់ធ្ងររបស់ភិក្ខុនីដទៃ, ការទទួលយកការណែនាំរបស់ភិក្ខុដែលត្រូវសង្ឃព្យួរទោស, និងការរំលោភបំពានដោយចេតនាលើសិក្ខាបទទាំងឡាយ ដោយមានបំណងអាក្រក់ ។

ក្នុងពេលវេលាកន្លងទៅ មានសិក្ខាបទដទៃទៀត ត្រូវបានកំណត់ឡើងសម្រាប់ជាក្រឹត្យវិន័យ និងការណែនាំដល់ភិក្ខុនីទាំងឡាយ ។ កាលមួយនោះ ក្នុងការឆ្លើយតបបញ្ហា ដែលព្រះនាងមហាបជាបតិគោតមីចោទសួរ, ព្រះពុទ្ធទ្រង់មានព្រះបន្ទូលថា កាលណាសិក្ខាបទសម្រាប់ភិក្ខុនីមានខ្លឹមសារដូចគ្នានឹងសិក្ខាបទកំណត់ឡើងសម្រាប់ភិក្ខុ, ភិក្ខុនីគប្បីប្រតិបត្តិតាមសិក្ខាបទទាំងនោះ ក្នុងបែបបទដូចជាភិក្ខុប្រតិបត្តិដែរ, ហើយកាលណាសិក្ខាបទទាំងឡាយនោះមិនដូចគ្នាទេ, ភិក្ខុនីគប្បីប្រព្រឹត្តឱ្យត្រូវទៅតាមខ្លឹមសារដែលបានដាក់ចុះ ។ វិន័យបិដកបានបំភ្លឺច្បាស់ថាសិក្ខាបទខ្លះដែលកំណត់សម្រាប់ភិក្ខុនី ដូចគ្នាសុទ្ធសាធទៅនឹងសិក្ខាបទកំណត់ឡើងសម្រាប់ភិក្ខុ ។ សិក្ខាបទខ្លះដែលកំណត់សម្រាប់ភិក្ខុនី ដូចដែលមានចែងនៅក្នុងវិន័យបិដក ដូចតទៅនេះថា : _ ភិក្ខុនីមួយអង្គ មិនត្រូវមានបាត្រលើសពីមួយ នៅក្នុងវិហារមួយ ; វត្ថុណាមួយផ្តល់ឱ្យភិក្ខុនីសម្រាប់គោលដៅណាមួយ គប្បីប្រើប្រាស់វត្ថុនោះ សម្រាប់តែគោលដៅនោះប៉ុណ្ណោះ; ភិក្ខុនីមិនត្រូវទទួលយកស្រូវ; មិនត្រូវបោះវត្ថុសៅហ្មងទាំងឡាយទៅលើផ្លូវ និងលើចំការ_ស្រែ តាមបង្អួច; មិនត្រូវចូលរួមក្នុងការរាំ, ការច្រៀង និងតន្ត្រីមានឧបករណ៍; មិនត្រូវនិយាយជាមួយមនុស្សណាម្នាក់ក្នុងទីងងឹត ឬកន្លែងកៀន ឬក្រោមពន្លឺព្រះចន្ទ ឬក្នុងផ្លូវសាធារណៈ ឬនៅតាមផ្លូវបំបែក; ភិក្ខុនីមិនត្រូវងូតទឹកស្រាត ។ ភិក្ខុនីពីរអង្គមិនត្រូវសឹង (ដេក) លើគ្រែជាមួយគ្នា ហើយគ្របដណ្តប់ខ្លួនដោយកម្រាល (ភួយ) មួយជាមួយគ្នា ។ ប្រសិនបើភិក្ខុនីមួយអង្គមានអាពាធ, សហធម្មិករបស់លោកគប្បីថែទាំលោក ឬក៏ជួយយកចិត្តទុកដាក់ឱ្យអ្នកដទៃទៀតជួយថែទាំលោក ។ ភិក្ខុនីមិនគប្បីបណ្តេញភិក្ខុនីដទៃ

ទៀត ដែលលោកបានផ្តល់ជម្រកឱ្យស្នាក់អាស្រ័យនោះទេ ។ ភិក្ខុនីមិនគប្បីសេពគប់ជាមួយមេផ្ទះ ឬកូនប្រុសរបស់មេផ្ទះទេ ។ ក្នុងអំឡុងរដូវភ្លៀង ភិក្ខុនីមិនត្រូវធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយទេ ។ ភិក្ខុនីមិនត្រូវទៅមើលវាំង, រាជឧទ្យាន, ថែវមានរូបភាព, ឧទ្យានកំសាន្ត ឬជលដ្ឋាន ឬអាងទឹក ដែលមានផ្កាល្អៗ ។ល។ ភិក្ខុនីមិនត្រូវរៀនសិល្បៈណាមួយសម្រាប់ចិញ្ចឹមជីវិតខ្លួនទេ ។ លោកមិនត្រូវចូលទៅក្នុងកុដិរបស់ភិក្ខុ ដោយគ្មានការអនុញ្ញាតនោះឡើយ ។ លោកមិនត្រូវភ្ជាប់ខ្លួនទៅនឹងគ្រួសារពិសេសណាមួយឡើយ ។ លោកមិនត្រូវពាក់គ្រឿងអលង្ការ ឬស្រង់ទឹកមានលាយទឹកអប់ឡើយ ។ លោកមិនត្រូវអង្គុយនៅចំពោះមុខភិក្ខុដោយគ្មានការអនុញ្ញាតពីភិក្ខុនោះទេ ។ លោកមិនត្រូវចេញទៅក្រៅនៅពេលយប់ ។ បើមនុស្សណាមួយបញ្ជូនអំណោយមកឱ្យភិក្ខុនីណាមួយ ដោយមានមូលហេតុអាក្រក់ ហើយបើលោកទទួលអំណោយទាំងនោះដោយដឹងច្បាស់នូវមូលហេតុនោះ, ភិក្ខុនីនោះនឹងត្រូវអាបត្តិសង្ឃាទិសេស ។

មានសិក្ខាបទទាំងឡាយផ្សេងទៀតកំណត់ឡើង ដោយមានបំណងរក្សាភិក្ខុ និងភិក្ខុនីដោយឡែកពីគ្នា, ដាក់បង្ខំការហាមឃាត់ជាច្រើនស្តីពីការប្តូរអាហារ, ស្បង់ចីពរ (សម្លៀកបំពាក់) និងវត្ថុទាំងឡាយផ្សេងទៀត រវាងគ្នានិងគ្នា ។ ដូចគ្នានឹងករណីភិក្ខុទាំងឡាយដែរ, វាមានគំរូករណីយកិច្ចដ៏ទៀងទាត់មួយនៅក្នុងជីវភាពរាល់ថ្ងៃរបស់ភិក្ខុនី ។ នៅពេលព្រឹក, លោកត្រូវចេញទៅបិណ្ឌបាត ហើយឆាន់អាហារមុនថ្ងៃត្រង់ ។ បន្ទាប់មក, លោកថយខ្លួនទៅធ្វើសមាធិ និងសូត្រធម៌ និងរៀនធម៌ ហើយស្តាប់ធម៌ទេសនានៅពេលល្ងាច ។ ភិក្ខុនីទាំងឡាយក៏ត្រូវចូលរួមក្នុងពិធី ទាំងឡាយដែលទាក់ទងនឹងរដូវវស្សាដែរ, ដូចជា ឧបោសថ បវារណា និងកឋិន ។ ភិក្ខុនីទាំងឡាយមិនមានកិច្ចការផ្ទះដូចគ្រហស្ថទេ ហើយគេរស់រានភាគច្រើនដោយ សារអំណោយសប្បុរសរបស់គ្រហស្ថ ។ កុដិ ឬអាស្រមទាំងឡាយ

(Nunneries) ត្រូវបានសាងសង់ឡើងសម្រាប់ភិក្ខុនី ដោយព្រះរាជាជាពិសេសផងដែរ ពីព្រោះ ភិក្ខុនីទាំងឡាយមិនត្រូវបានទទួលការអនុញ្ញាតឱ្យស្នាក់នៅក្នុងព្រៃទេ ។ គ្រហស្ថផ្តល់ដល់ភិក្ខុនីនូវសំពត់ដែលមានចីវរ, ឧត្តរាសង្គៈ ( សំពត់ស្លៀកខាងក្រៅ ), អន្តរវាសកៈ ( សំពត់ស្លៀកក្នុង ) និងសំកច្ឆិកៈ ( អាវទ្រនាប់ ) ។

សិក្ខាបទដ៏សំខាន់ទាំងប្រាំបីដែលនិយាយខាងលើ បង្ហាញយ៉ាងច្បាស់ថាភិក្ខុនីសង្ឃត្រូវបានរក្សាឱ្យនៅចំណុះភិក្ខុសង្ឃ ។ ជាងនេះទៀត, គេកត់សម្គាល់ឃើញថា ការបួសថ្នាក់ខ្ពស់ (ឧបសម្បទា) របស់ភិក្ខុនី ត្រូវឡើងពេញលេញបានតែកាលណាភិក្ខុនីនោះបានទទួលការបញ្ជាក់អះអាងអំពីភិក្ខុសង្ឃប៉ុណ្ណោះ ។ ប៉ុន្តែថា វាហាក់ដូចជាមិនឃើញមានការផ្សេងគ្នាណាមួយ រវាងភិក្ខុនី និងភិក្ខុ ក្នុងសមត្ថភាពដើម្បីសំរេចបានខាងគុណធម៌បញ្ញាស្មារតីនោះទេ ។ ថេរីគាថានិងអបទានមានឧទានកថានិយាយអំពីថេរីជាច្រើន ដែលបានក្លាយជាព្រះអរហន្តនៅក្នុងសម័យកាលព្រះពុទ្ធ ។ ថេរីទាំងឡាយនោះ រួមមានស្ត្រីទាំងឡាយមកពីគ្រប់ថ្នាក់នៃសង្គម, ពីរាជត្រកូល, ពីត្រកូលអភិជន, ពីត្រកូលពាណិជ្ជករ, ពីត្រកូលព្រាហ្មណ៍ និងពីវណ្ណៈទាំងឡាយដទៃទៀត ហើយរហូតដល់ពួកស្ត្រីខិលខូចមួយចំនួនផង ។

ប្រវត្តិនៃភិក្ខុនីសង្ឃនៅក្នុងប្រទេសទាំងឡាយផ្សេងៗ នឹងមាននិយាយនៅក្នុងអត្ថបទដោយឡែក ។ ប៉ុន្តែការកត់សម្គាល់ខ្លះៗ ត្រូវបានលើកយកមកនិយាយក្នុងទីនេះ ដោយកាត់ខ្លីជាសេចក្តីសង្ខេបដូចតទៅ ។

នៅប្រទេសស្រីលង្កា ភិក្ខុនីសង្ឃត្រូវបានបង្កើតឡើង ដូចដែលបានកត់ត្រាទុកនៅក្នុងកាលប្បវត្តិទាំងឡាយ ដូចជានៅក្នុងគម្ពីរទីបវង្ស និងមហាវង្ស ក្នុងរជ្ជកាលព្រះបាទទេវានម្បិយតិស្សៈ (២៥០ - ២១០ មុនគ្រីស្តសករាជ) ។ គឺនៅក្នុងរជ្ជកាលព្រះរាជានេះហើយ ដែលពុទ្ធសាសនាត្រូវបាននាំចូលទៅស្រីលង្កា ដោយព្រះមហិន្ទត្ថេរ ។ ពុទ្ធសាសនាបានចាប់ផ្តើមដោយការបំបួស (បព្វជ្ជា) ព្រះរាជនីអនុលា

និងស្ត្រីទាំងឡាយដទៃទៀតចំនួនមួយពាន់នាក់ ។ ព្រះនាងអនុលា និងស្ត្រីជាបរិវារបស់ព្រះនាងបានទទួលសីលដប់ ក្រោមការណែនាំរបស់ព្រះមហិន្ទត្ថេរ ។ ស្ត្រីទាំងឡាយនោះស្លៀកដណ្ដប់សំពត់ពណ៌លឿង, ស្នាក់អាស្រ័យនៅក្នុងកុដិ ឬអាស្រមដែលព្រះរាជាសង់ឡើងសម្រាប់ស្ត្រីទាំងនោះ រង់ចាំការនិមន្តមកដល់នៃព្រះសង្ឃមិត្តាថេរី ដែលត្រូវជាប្អូនស្រីរបស់ព្រះមហិន្ទត្ថេរ ដើម្បីបានទទួលឧបសម្បទា ក្លាយទៅជាភិក្ខុនី ។ អាស្រមមួយទៀត ដែលត្រូវបានគេស្គាល់ថា « ហត្ថាឡ្ហកវិហារៈ » ក៏ត្រូវបានព្រះរាជាទេវានម្បិយតិស្សៈកសាងឡើងដែរ សម្រាប់ការប្រើប្រាស់របស់ព្រះថេរីសង្ឃមិត្តា ។ ការសង់អាស្រមដ៏ច្រើនទៀតនៅប្រទេសស្រីលង្កា ក្នុងកាលជាខាងក្រោយមក, ឧទាហរណ៍ ក្នុងរាជ្យព្រះបាទមោគ្គល្លាន I (គ.ស ៤៩៧-៥០៨), ព្រះបាទអគ្គពោធិ IV ( គ.ស. ៦៦៧ - ៦៨៣ ) និងព្រះបាទកស្សបៈIV ( គ.ស.៨៩៨ - ៩១៤ ) ត្រូវបានគេកត់ត្រាទុកនៅក្នុងគម្ពីរមហាវង្ស ។ គម្ពីរទីបវង្ស បានផ្ដល់បញ្ជីឈ្មោះភិក្ខុនីទាំងឡាយដែលបានមកពីប្រទេសឥណ្ឌា ទៅកាន់ប្រទេសស្រីលង្កា និងឈ្មោះភិក្ខុនីដទៃទៀតក្នុងប្រទេសស្រីលង្កា ដែលបានបង្រៀនវិន័យ ។ គម្ពីរមហាវង្ស ក៏បាននិយាយផងដែរថា ភិក្ខុនីមួយរយពាន់បានចូលរួមក្នុងពិធីបុណ្យឆ្លងមរិចវដ្ដិវិហារ ។ ទោះជាយ៉ាងនេះក្ដី, ចំនួនភិក្ខុនីនៅក្នុងប្រទេសស្រីលង្កា នៅតែមានតិចជាងចំនួនភិក្ខុ, ហើយតួនាទីរបស់ភិក្ខុនីនៅក្នុងសង្គម ក៏មានសារសំខាន់តិចតួចដែរ ។ យោងតាមសំណង់នៃអាស្រមទាំងឡាយ ដែលព្រះរាជាទាំងឡាយបានកសាងឡើង, បង្ហាញថា ស្ថាប័នភិក្ខុនីនៅក្នុងប្រទេសស្រីលង្កា បានបន្តមកអស់ពេលមួយយ៉ាងវែងបង្គួរ ។ ចាប់តាំងពីពេលនោះមក គណៈភិក្ខុនីបានក្លាយទៅជារលត់សាបសូន្យ, ទោះបីជាគ្មានកាលបរិច្ឆេទជាក់លាក់ណាមួយបញ្ជាក់ថា ចាប់ត្រឹមពីពេលណាមកទើបហេតុការណ៍នេះបានកើតឡើងក៏ដោយ ។ គណៈសង្ឃភិក្ខុនី មិនត្រូវបានគេកសាងឡើងវិញទេ, សូម្បីនៅពេលដែលឧបសម្បទារបស់ភិក្ខុទាំងឡាយ ត្រូវបាន

គេកសាងឡើងវិញនៅក្នុងកាលជាខាងក្រោយមកក៏ដោយ ។ សព្វថ្ងៃនៅមានស្ត្រីមួយចំនួនប្រព្រឹត្តកាន់ផ្នួសជាអ្នកសាកល្បងដែលទទួលកាន់សីលដប់ ។ តាមពិតសីលដប់នេះគឺ សម្រាប់អ្នកសាកល្បងភេទប្រុសទេ ( Male probationers ) ដែលគេហៅថា សាមណេរ, មានតែសិក្ខាបទប្រាំមួយខាងដើមប៉ុណ្ណោះទេ ទើបសម្រាប់ស្ត្រីអ្នកសាកល្បង (Female probationers) ដែលមានឈ្មោះថា សិក្ខ-មានា ហើយស្ត្រីអ្នកសាកល្បងទាំងឡាយនោះ ស្នាក់នៅក្នុងអាស្រម ឬកុដិ ។ ស្ត្រីអ្នកសាកល្បង ឬសិក្ខមានា ពាក់អាវពណ៌សដៃវែង ហើយស្លៀកសំពត់ពណ៌លឿងព្រលាតចាស់ ។ ថ្មីៗនេះ មានការប៉ុនប៉ងធ្វើឱ្យភិក្ខុនីសង្ឃរស់ឡើងវិញ, ប៉ុន្តែពុំទទួលបានជោគជ័យទេ ។

គេពិបាកនឹងនិយាយណាស់ថា ពេលណា គណៈភិក្ខុនីត្រូវបានស្ថាបនាឡើងវិញនៅក្នុងប្រទេសកាន់ពុទ្ធសាសនាដទៃទៀត ។ លោក ស្ពេន ហារឌី (Spence Hardy) បានកត់សំគាល់នៅក្នុងសៀវភៅរបស់លោកឈ្មោះ « Eastern Monachism », Partridge & Oakey, ១៨៥០, pp. ១៦១ - ថា : ភិក្ខុនី[១] នៅក្នុងប្រទេសភូមា ដែលគេហៅថា ថិលសេន ( Thilashen ), មានចំនួនតិចតួចពេកណាស់ បើប្រៀបនឹងចំនួនភិក្ខុ ។ ភាគច្រើននៃភិក្ខុនី គឺជាស្ត្រីចាស់ៗ ។ គេកោរក្បាល ហើយស្លៀកពាក់សំពត់-អាវពណ៌ស ។ គេរស់នៅក្នុងលំនៅសមរម្យជិតវត្ត ហើយតាំងចិត្តរស់នៅក្នុងព្រហ្មចរិយភាព ដរាបណាគេឋិតនៅក្នុងគណៈ-សង្ឃ ( ឬគណៈដូនជី ) ។ ភិក្ខុនី ( ឬដូនជី ) នៅក្នុងប្រទេសថៃ កាន់តែតិចតួចជាងនៅក្នុងប្រទេសភូមាទៅទៀត ។ នៅអារ៉ាកាន ( Arakan ), ភិក្ខុនី (ឬដូនជី) មានដូចជាភិក្ខុទាំងឡាយដែរ ។ គេរស់នៅក្នុងអាស្រម ឬមួយក្នុងខ្ទមមួយៗ ដោយឡែក,

---

(១) តាមដឹង, នៅពេលបច្ចុប្បន្ន ក្នុងប្រទេសកាន់ពុទ្ធសាសនាថេរវាទ, ពុំមានភិក្ខុនីទេ, គឺមានតែដូនជី ឬ សីលវតី ។ នៅក្នុងប្រទេសកាន់ពុទ្ធសាសនាមហាយាន, ទើបមានភិក្ខុនី ។

ដឹកនាំជីវិតជាអ្នកកាន់សាសនា ។ សម្លៀកបំពាក់របស់គេ ប្រហាក់ប្រហែលនឹងស្បង់ចីពររបស់ភិក្ខុសង្ឃដែរ ។ នៅក្នុងប្រទេសចិន, គេឃើញភិក្ខុនី រហូតមកដល់ពេលថ្មីៗនេះ មានចំនួនច្រើនបង្គួរ ។ គេទាំងនោះ កោរក្បាល, ស្លៀកពាក់សំពត់ដូចជាភិក្ខុដែរ ។

គេពុំមានមូលហេតុច្បាស់លាស់ណាមួយ ដើម្បីបញ្ជាក់ពីការរលាយរលត់នៃគណៈភិក្ខុនីដែលបានទទួលផ្នួសជាន់ខ្ពស់ ( ឧបសម្បទា ) នោះទេ ។ លោក ហ៊ន័រ ( I.B. Horner ) យល់ថា ទោះបីជានៅពេលបដិសន្ធិ នៃគណៈភិក្ខុនី, ស្ត្រីទាំងឡាយចេញពីត្រកូលអភិជនបានបោះបង់ជីវភាពជាគ្រហស្ថ ( មេផ្ទះ ) ចូលទៅបួសក្នុងគណៈភិក្ខុនីសង្ឃក៏ដោយ, ក៏ក្រោយមកគណៈសង្ឃនេះ បានបាត់បង់បន្តិចម្តងៗនូវចរិតដើមរបស់ខ្លួន ហើយបានក្លាយទៅជាជំរកសម្រាប់ស្ត្រីក្រីក្រ, ស្ត្រីអភ័ព្វ, ស្ត្រីគ្មានគូស្រករ, និងស្ត្រីមេម៉ាយខ្វះទីពឹង ។ ការសង្កេតរបស់លោក ស្ពេន ហារឌី អំពីស្ថានភាពនៃគណៈភិក្ខុនី ឬគណៈដូនជី នៅក្នុងប្រទេសកាន់ពុទ្ធសាសនានានា អាចផ្តល់នូវសញ្ញាប្រាប់ផ្លូវគួរទទួលយកបាន, ជាអាទិ៍គឺគណៈភិក្ខុនី ក្នុងកាលជាខាងក្រោយមក បានបាត់បង់នូវការគាំទ្រអំពីត្រកូលអភិជន ហើយធ្លាក់ក្នុងស្ថានភាពត្រូវគេបំភ្លេចចោល ។

នៅក្នុងប្រទេសកម្ពុជា ពុទ្ធសាសនាបានរីករាលដាលចូលមកសណ្ឋិតនៅជាងពីរពាន់ឆ្នាំកន្លងទៅហើយ ដោយមាននិកាយ (មហាយាន, ហីនយាន ឬថេរវាទ) និងការរីកចំរើនខុសៗគ្នា ទៅតាមកាលៈទេសៈ ។ នៅក្នុងប្រវត្តិដ៏វែងនេះ យើងពុំដែលបានឃើញ បានឮ នៅក្នុងប្រវត្តិពុទ្ធសាសនាថា មានអ្នកបួសភេទស្រីជាភិក្ខុនី ឬក៏ជាសាមណេរី ពិតប្រាកដនោះទេ ។ ប្រសិនបើអាចមានវិញនោះ គឺអ្នកបួសភេទស្រី ដែលគេហៅថា ដូនជី ហើយមានចំនួនតិចតួចពេកណាស់ បើប្រៀបផ្ទឹមទៅនឹងអ្នកបួសភេទប្រុសជាសាមណេរ ឬជាភិក្ខុនៅក្នុងគ្រប់កាលៈទេសៈ ។ លោក

ហ្វ្រង់ស្វា ម៉ារទីនី នៅក្នុងអត្ថបទរបស់លោកស្តីអំពីលោកសង្ឃខ្មែរ ចុះផ្សាយក្នុង France Asie លេខពិសេស ៣៧-៣៨ ក្នុងឆ្នាំ ១៩៤៩ បានសរសេរថា ៖ « គេអាចមើលឃើញផងដែរ, ជាពិសេស នៅក្នុងបណ្តាវត្តអារាមតាមខេត្រ, នូវមនុស្សប្រុសស្រី ដែលច្រើនតែជាចាស់ៗ ស្លៀកពាក់ស ។ នោះគឺជាអ្នកកាន់សីលភេទជាគ្រហស្ថ ដែលមានប្រាថ្នាកាន់សិក្ខាបទពុទ្ធសាសនាយ៉ាងតឹងរ៉ឹង ដោយមិនចាំបាច់បួស » ។

« ប៉ុន្តែ គេអាចប្រដូចស្ត្រី ដែលគេហៅថាដូនជី ទៅនឹងអ្នកបួសភេទស្រីបាន ។ ដូនជីគឺជាអ្នកជឿស៊ប់ក្នុងសាសនា ដែលស្លៀកពាក់ស រស់នៅកាន់សីល និងប្រព្រឹត្តតបកម្មតឹងរ៉ឹង ដូចជាការរស់នៅរបស់លោកសង្ឃដែរ ។ ដូនជី តែងនៅវត្តជាប់លាប់ ជួយបំពេញការងារតូចតាចសម្រាប់ព្រះសង្ឃ, ដូចជាតុបតែងអាសនៈព្រះពុទ្ធរូប, ដេរប៉ះជាដើម ។ ប៉ុន្តែថា ដូនជីស្នាក់អាស្រ័យនៅក្រៅវត្តទេ » ។

ស្ថានភាពភិក្ខុសង្ឃពុទ្ធសាសនិក និងដូនជី ដែលធ្លាប់កើតមានជាច្រើនតំណមនុស្សមកហើយនៅប្រទេសកម្ពុជា ត្រូវរលត់រលាយបាត់រូបបាត់ឈ្មោះពីក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ។ ចាប់ពីពេលនោះមក, ស្ថាប័នពុទ្ធសាសនា ត្រូវបានរៀបចំ កសាងបន្តិចម្តងៗ ជាបណ្តើរៗឡើងវិញ ហើយដូនជី ( តាជីផងដែរ ) ក៏កើតមានឡើងវិញយ៉ាងច្រើន បើប្រៀបធៀបចំនួនដូនជី ( និងតាជី ) ទៅនឹងចំនួនដែលមានមុនឆ្នាំ ១៩៧៥ ។ មូលហេតុនៃការកើនចំនួនដូនជី ( និងតាជី ) កើតចេញពីរបបដ៏មហាអសោចិ៍ ដ៏មហាឧក្រិដ្ឋ នៃបនប្រល័យពូជសាសន៍ខ្មែរក្រហម ក្នុងអំឡុងឆ្នាំ ១៩៧៥ - ១៩៧៩ ដែលបានសាបព្រោះមហាវិនាសកម្មដ៏ឈឺចាប់ ខ្លោចផ្សារ មកលើគ្រួសារប្រជាពលរដ្ឋកម្ពុជាទាំងអស់ ។ ម្ល៉ោះហើយ ភាពអស់សង្ឃឹម ភាពឈឺចាប់ខ្លោចផ្សារក្នុងចិត្ត ភាពអស់ជំនឿលើជីវិតរបស់ខ្លួន ភាពធុញទ្រាន់នឹងការរស់នៅ ភាពខ្វះទីពឹងពំនាក់ ទាំងផ្លូវកាយផ្លូវចិត្ត ទុគ៌តភាពជាទូទៅគ្របដណ្តប់មកលើសង្គម ។ ល ។ បានរុញប្រជាពលរដ្ឋយើងមួយចំនួន ជាពិសេស ស្ត្រីភេទ ហើយ

ច្រើនជាស្ត្រីវ័យចាស់ឱ្យទៅស្វែងរកសេចក្តីសុខ ឬសេចក្តីស្ងប់ ឬក៏ស្វែងរកការទ្រទ្រង់ជីវិតតាមរយៈពុទ្ធសាសនា ពោលគឺការបួសជាដូនជី (ឬជាតាជី) ដែលយកទីវត្តអារាមធ្វើជាកន្លែងស្នាក់អាស្រ័យនៅដោយសង់ជាខ្ទម - ផ្ទះ ឬ យកកុដិ សាលាឆាន់របស់វត្ត រហូតដល់ព្រះវិហារធ្វើជាលំនៅឋានរបស់ខ្លួន ។

ចាប់តាំងពីឆ្នាំ ១៩៧៩ រៀងមក ដូនជី (ឬជាតាជី) បានក្លាយទៅជាសមាសភាពសង្គមមួយ ដែលគេនិយមហៅថា ស្រទាប់មហាជន ។ នៅរាល់ពិធីផ្លូវការ ឬពិធីសាសនាធំៗ គេតែងឃើញដូនជី (តាជី) ស្លៀកស ពាក់ស ត្រូវបានគេដឹកជញ្ជូនតាមរថយន្តអំពីវត្តអារាមនានាយកទៅឱ្យចូលរួមក្នុងពិធី ដើម្បីផ្តល់កិត្តិយសដល់គណៈអធិបតីក្នុងពិធី ។ ជាញឹកញយ, ក្រោយពិធីបានប្រព្រឹត្តទៅចប់, ដូនជី ( ហើយក៏មានតាជីផងដែរ ) តែងបានទទួលរង្វាន់ខាន់ខៅពុំសូវដែលខាន ក្នុងនាមជាសីលវន្តបុគ្គល ឬក្នុងនាមជាអ្នកខ្វះខាត ។ វិធានការណ៍នេះ ហាក់ដូចជាបានលើកទឹកចិត្តឱ្យចំនួនដូនជី ( និងតាជីផង ) កាន់តែមានកំណើនឡើង រស់នៅក្នុងវត្តអារាម ។

ដោយសារមានកំណើននៃចំនួនដូនជី ដ៏គួរឱ្យចាប់អារម្មណ៍នេះហើយ ទើបមានអង្គការក្រៅរដ្ឋាភិបាលខ្លះ អង្គការមនុស្សធម៌អន្តរជាតិខ្លះ បានយកចិត្តគិតគូរការពារសិទ្ធិស្ត្រី ( ដើម្បីស្មើភាពនឹងបុរស ? ) និងដើម្បីទាញយកលទ្ធភាពរួមចំណែករបស់ស្ត្រីវ័យចាស់ ក្នុងការអភិវឌ្ឍន៍សង្គមជាតិខ្មែរ ។ ជាការណ៍ពិត គេពុំគប្បីមើលស្រាលសមាសភាពនេះ នៃសង្គមខ្មែរយើងទេ ។ ក្រុមដូនជី គឺជាស្ថាប័នសង្គមដែលប្រវត្តិសាស្ត្របានបង្កើតឡើង, ដោយហេតុនេះ គេគួរតែសិក្សាឱ្យបានម៉ត់ចត់អំពីតថភាពនៃការកើតឡើងនៃក្រុមដូនជី ហើយរៀបចំលក្ខន្តិកៈមួយដ៏សមស្របដើម្បីជួយក្រុមដូនជី ឱ្យអាចរស់រានក្នុងកិត្តិយស, ក្នុងសិទ្ធិ, ក្នុងសេរីភាព, និងក្នុងជំនឿរបស់ខ្លួន ហើយបើកច្រក ឬក្រាលផ្លូវឱ្យក្រុមដូនជីអាចយកសមត្ថភាព

និងលទ្ធភាពចុងក្រោយនៃវ័យចាស់របស់ខ្លួនរួមចំណែកក្នុងការជួយអភិវឌ្ឍសង្គមក្នុងវិស័យណាមួយដែលសមស្រប ។

កាលពីដើមខែឧសភា ១៩៩៥ កន្លងទៅនេះ, សិក្ខាសាលាមួយស្តីពី ដូនជីនិងឧបាសិកាខ្មែរ ដែលផ្តើមគំនិត និងឧបត្ថម្ភដោយមូលនិធិ ហ៊ានរិចបូល, ប្រទេសអាល្លឺម៉ង់ បានប្រព្រឹត្តទៅចំនួនបីថ្ងៃ នៅក្នុងវិជ្ជាស្ថានវិបស្សនា គ្រប់គ្រងដោយលោកព្រឹទ្ធាចារ្យ ឆេង ផុន នៅព្រែកហូរ - ខេត្តកណ្តាល ។ នៅក្នុងសិក្ខាសាលានោះ មានវាគ្មិនជាតិ និងអន្តរជាតិជាច្រើនបានលើកយកបញ្ហានានា ដែលទាក់ទងនឹងដូនជីមកពិភាក្សារហូតឈានដល់ធ្វើសេចក្តីសំរេចបង្កើតឱ្យមានគណៈដូនជីឬភិក្ខុនីសង្ឃនៅកម្ពុជា ។ លទ្ធផលនៃការអនុវត្តន៍សេចក្តីសំរេចនោះយ៉ាងណា នៅមិនទាន់ក្តាប់បាននៅឡើយ ។ មតិមួយចំនួនក្រៅវេទិកានៃសិក្ខាសាលា បានសម្តែងការព្រួយបារម្ភចំពោះសេចក្តីសំរេចនោះ ដែលអាចនឹងបណ្តាលឱ្យមានបញ្ហាថ្មីៗកើតបន្ថែមមកលើបញ្ហាចាស់ដ៏ច្រើន ដែលមិនទាន់នឹងដោះស្រាយបានផងនៅឡើយ ។ បញ្ហាទាំងនោះ មានជាអាទិ៍ ភាពក្រីក្រនៃសង្គមកម្ពុជាមិនទាន់ស្តាររួច, កំណើនមនុស្សឥតការងារធ្វើ ទន្ទឹមនឹងកំណើនមនុស្សត្រូវចិញ្ចឹម, ចំណាយធនធានសង្គមយ៉ាងច្រើនលើផ្នែកមិនផលិត ទន្ទឹមនឹងគ្រោះធម្មជាតិ បង្កអន្តរាយដល់ផលិតផលសង្គមជាញឹកញយ, . . . ។

ក្រៅពីនេះ ភាពច្របូកច្របល់ និងភាពសៅហ្មងក៏អាចបណ្តាលមកពីការរស់នៅរបស់ភិក្ខុ - សមណេរ ដូនជី និងតាជី ក្នុងបរិវេណវត្តតែមួយ ដែលកាន់តែបាត់បង់ផ្ទៃដីនៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ ជម្លោះដណ្តើមកាន់កាប់កុដិ ឬលំនៅឋាន រវាងវត្ត និងដូនជី - តាជី តែងកើតមានជាញឹកញយ ជាពិសេសនៅទីក្រុងភ្នំពេញ ។ នេះមិនទាន់និយាយដល់ការដណ្តើមយកដីគរុភ័ណ្ឌវត្ត ធ្វើជាទីតាំងសាងសង់លំនៅឋានផ្ទាល់ខ្លួនជាអចិន្ត្រៃយ៍ផងនោះទេ ។

# វត្តអារាម
## ជាមជ្ឈមណ្ឌលវប្បធម៌របស់ប្រជារាស្ត្រខ្មែរ [១]

## I. ពុទ្ធសាសនានៅកម្ពុជា

ប្រជារាស្ត្រខ្មែរ ជាង ៩៥% ជាអ្នកកាន់ពុទ្ធសាសនា ។ ជីវិតរបស់គេបានផ្សារភ្ជាប់ទៅនឹងវត្តអារាម តាំងពីកើតរហូតដល់ស្លាប់ ។ ដោយសារប្រជារាស្ត្រខ្មែរទាំងអស់គ្នាផ្តោតចិត្តគំនិត និងសកម្មភាពទៅលើតែចំណុចរួមមួយ គឺវត្តអារាម ដូច្នេះ ទើបវត្តបានក្លាយទៅមជ្ឈមណ្ឌលវប្បធម៌របស់គេ ។

*តើពុទ្ធសាសនាចូលមកដល់ប្រទេសកម្ពុជា តាំងពីពេលណាមក ?*

តាមរយៈឯកសាររបស់ឥណ្ឌា ចិន និងការស្រាវជ្រាវខាងបុរាណវិទ្យា បញ្ជាក់ថា មនុស្សខ្មែរបានរស់លើទឹកដីសុវណ្ណភូមិនេះ តាំងតែពីរាប់ពាន់ឆ្នាំមកហើយ ។ គឺជាប្រជាជាតិដែលមានចំណាស់ជាងគេមួយ ក្នុងចំណោមប្រជាជាតិនៅអាស៊ីភាគអាគ្នេយ៍នេះ ។ ប្រជាជាតិខ្មែរបានស្ថាបនាប្រព័ន្ធគ្រប់គ្រងប្រទេសរបស់ខ្លួន មានការរីកចំរើនគ្រប់វិស័យ តាំងពីមុនពេលដែលពុទ្ធសាសនា និងសាសនាព្រាហ្មណ៍ចូលមកដល់ ។ ខ្មែរមានភាសាដោយឡែករបស់ខ្លួន មានជំនឿសំរាប់គោរព

---

(១) អត្ថបទនេះ ខ្ញុំបានសរសេរដើម្បីចូលរួមនៅក្នុងវគ្គបំពាក់បំប៉នព្រះតេជព្រះគុណ មេគណគ្រប់ខេត្ត - ក្រុង ដែលចាត់ចែងឡើងដោយពុទ្ធិកសមាគមខ្មែរ នៅវត្តឧណ្ណាលោម នៅថ្ងៃទីទី២៣ ខែ សីហា ឆ្នាំ ១៩៩៤ ។ លោក អ៊ូ ប៊ុនឡុង ប្រធានសមាគមនេះ បានយកអត្ថបទនេះទៅបោះពុម្ពផ្សាយម្តងរួចហើយ កាលពីឆ្នាំ១៩៩៤ នៅក្នុងសៀវភៅឈ្មោះធម្មទេសនា ។

បូជារបស់ខ្លួន ។ រីឯវប្បធម៌ដែលចូលមកពីក្រៅ មានវប្បធម៌ឥណ្ឌា និងចិន គឺគ្រាន់តែជាការផ្តល់កម្លាំង, ឬជាពន្លឺជួយជំរុញឱ្យវប្បធម៌ខ្មែររីកចំរើន និងអភិវឌ្ឍន៍បានយ៉ាងឆាប់រហ័សតែប៉ុណ្ណោះ ។ ដោយហេតុភាពរលាយនៃវប្បធម៌បរទេសមកជាវប្បធម៌ខ្មែរនេះហើយ ទើបប្រទេសដែលជាម្ចាស់ដើមនៃវប្បធម៌នោះ ពុំអាចរកភស្តុតាងនៃវប្បធម៌របស់ខ្លួនឃើញនៅប្រទេសខ្មែរយើង ។ ដូនតាខ្មែរ ជាអ្នកមានទេពកោសល្យខាងច្នៃប្រឌិត មានកម្លាំងខាងបញ្ញាដ៏អស្ចារ្យណាស់ខាងការបង្កើតថ្មី ។ ការណ៍ដែលលោកមិនចេះចម្លងតាមគ្នានេះហើយបានជា វិស័យសិល្បៈវប្បធម៌ខ្មែរមានខ្លឹមសារ និងរូបភាពយ៉ាងសម្បូរបែប ។ សិល្បៈ វប្បធម៌ដ៏សម្បូរនោះ មានមជ្ឈមណ្ឌលដោយឡែកពីគ្នា ប៉ុន្តែទាំងអស់គ្នាដើរតាមក្បួនខ្នាតជាមូលដ្ឋានរួមមួយ ដែលជាអត្តសញ្ញាណរបស់ជាតិ ។

ក្នុងពេលដែលសាសនាព្រាហ្មណ៍ ជាសាសនារបស់ប្រទេសនោះ ព្រះមហាក្សត្រ និងរាជបណ្ឌិតបានកសាងប្រាសាទជាច្រើន ( រាប់ពាន់ប្រាសាទ ) ។ ប្រាសាទទាំងអស់នោះ ទោះបីស្ថិតក្នុងរចនាបថជាមួយគ្នា ក៏លក្ខណៈពិសេសពុំដូចគ្នាទេ ទំហំ កំពស់ ទីតាំង តុបតែងលំអ ក្បូរក្បាច់ខុសគ្នា ។ ប៉ុន្តែ ដែលដូចគ្នានោះគឺប្រាសាទទាំងអស់នោះ ជាទីគោរពសក្ការបូជា និងជាកន្លែងរក្សាទុកឯកសារដូចគ្នា ។

លុះដល់ពេលដែលពុទ្ធសាសនាមហាយាន មកជំនួសសាសនាព្រាហ្មណ៍វិញ ប្រាសាទទាំងឡាយនោះ មិនគ្រាន់តែជាទីសក្ការបូជា ជាបណ្ណាល័យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាសាលារៀន ជាមហាវិទ្យាល័យរបស់ជាតិទៀតផង ។

ឧទាហរណ៍, ប្រាសាទព្រះខ័ន ប្រាសាទតាព្រហ្ម ជាដើម ។ សិលាចារឹក ( តាព្រហ្ម សៀមរាប អង្គរ ) ឬ "បុរីរាជវិហារ" បញ្ជាក់ថា បុរីរាជវិហារនេះ មានការជួយឧបត្ថម្ភដោយស្រុក ចំនួន ៣.១៤០ សំរាប់ឧបត្ថម្ភចំពោះបុរស ៤០០ នាក់ មានអធិការ ( មហាថេរ ) ១៨ អង្គ មានអធិការរង ( អនុថេរ ) ២.៧៤០ អង្គ

អ្នកបំរើ ២.២៣២ នាក់ រួមទាំងបរិចារិកា ( ស្រីរបាំ ) ៦១៥ នាក់ រួមទាំងអ្នកសំណាក់នៅក្នុងនោះផង មានចំនួន ១២.៦៤០ នាក់ ។ រីឯអ្នកបំរើ មាន ៦៦.៦២៥ សរុបទាំងអស់មាន ៧៩.២៦៥ នាក់ រួមទាំងជាតិភូមា និងចាមផង ។

នៅទីនោះមាន :

- លំនៅថ្ម ៥៦៦ កន្លែង
- លំនៅឥដ្ឋ ២៨៨ កន្លែង
- ស្រះ ទទឹង ៧៦ ព្យាម x បណ្តោយ ១១៥០ ព្យាម ។
- ភិក្ខុសង្ឃ ៤៣៩ អង្គ ទទួលភត្តរាល់ថ្ងៃ ក្នុងព្រះរាជមន្ទីរ ។ សិស្សមាន ៩៧០ នាក់ ។ សរុបទាំងអស់មាន ១.៤០៩ នាក់ ។

នៅក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី ៧ ដែលជាព្រះរាជាគោរពពុទ្ធសាសនា ព្រះអង្គបានកសាងអរោគ្យសាលា (មន្ទីរពេទ្យ) ចំនួន ១០២ កន្លែង - មានទេវរូប ៧៩៨ អង្គ តម្កល់នៅទូទាំងប្រទេស ។ ដើម្បីព្យាបាលអ្នកជំងឺនៅគ្រប់មន្ទីរពេទ្យទាំងនោះ គេត្រូវចំណាយអង្ករចំនួន ១១៧.២០០ ខារិកា ។ អង្ករនោះបានមកពីស្រុកចំនួន ៨៣៨ ។ បុគ្គលិកអ្នកបំរើនៅមន្ទីរពេទ្យមាន ៨១.៦៤០ នាក់ ។

ដល់មកក្រោយសម័យអង្គរ ពុទ្ធសាសនាហីនយានបានចូលមកជំនួសពុទ្ធ-សាសនាមហាយាន ពេលនោះវត្តអារាម ក៏មានតួនាទីដូចប្រាសាទសិលាពីបុរាណដូច្នេះដែរ ។

តាមពិតទៅ ពុទ្ធសាសនា និង សាសនាព្រាហ្មណ៍ មកដល់ប្រទេសខ្មែរក្នុងពេលប្រហាក់ប្រហែលគ្នា ។ គម្ពីរពុទ្ធសាសនា បានផ្តល់ពត៌មានថា ក្រោយពេលធ្វើតតិយសង្គាយនារួច ក្នុងរង្វង់ពុទ្ធសតវត្សទី៣ ព្រះមហាថេរមួយអង្គព្រះនាមមហាមោគ្គល្លីបុត្តតិស្សៈ បានចាត់ចែងបញ្ជូនព្រះថេរ ២ អង្គ គឺ ព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរ ឱ្យចេញពីជម្ពូទ្វីប " ឥណ្ឌា " មកផ្សាយពុទ្ធសាសនា នៅសុវណ្ណភូមិ

យើងនេះ ។

តាមប្រភពឯកសារចិនថា ប្រទេសខ្មែរ និងចិន មានទំនាក់ទំនងជាមួយគ្នា តាំងពីមុនគ្រិស្តសករាជច្រើនរយឆ្នាំ ។ ប៉ុន្តែ ឯកសារដែលជាភស្តុតាង រាប់ទុកជាផ្លូវការនោះគឺ រាប់ពីគ្រិស្តសតវត្សទី៣ រហូតមក ។ តាមរយៈឯកសាររបស់ចិនដដែលនោះ យើងអាចដឹងបានថា ៖ ចិនមកដល់ប្រទេសខ្មែរយើង ( ដែលកាលនោះមានឈ្មោះថាហ្វូណន (Founan) តាំងពីមុនឆ្នាំ២៣១ នៃគ.ស បន្តិច និងមានទំនាក់ទំនងជាមួយគ្នាពីឆ្នាំ ២៤៣ គ.ស ដល់ ៤៣៤ គ.ស ។ នៅក្នុងរជ្ជកាលព្រះចៅក្រុងចិននាម វូ ( ២២០ - ២៨០ គ.ស ) ចិនបានបញ្ជូនទូត ២ រូប មកកម្ពុជា គឺ កាំង ថៃ និង ជូ យីង ។ ទូតទាំងពីររូបនេះ បានជួបទូតមកពីប្រទេសឥណ្ឌា នៅក្នុងស្រុកខ្មែរយើង ។ ទូតឥណ្ឌាឈ្មោះចិន ស៊ុន ។

តាមឯកសារដែលទូតចិនឈ្មោះ ជូ យីង សរសេរ គេអាចដឹងថា ព្រះរាជានៅនគរភ្នំ ព្រះនាម ហ្វានម័ន ឬ ហ្វាន់ចេម៉ុន ( ស្រីមារៈ ? ) ។ ព្រះអង្គជាព្រះរាជាកាន់ពុទ្ធសាសនា មានកិត្យានុភាព ដ៏ល្បីល្បាញ ។

ជូ យីង រៀបរាប់ថា ប្រជាជននៅនគរភ្នំ មានសម្បុរខ្មៅ សក់រួញ នៅក្នុងប្រជុំភូមិមួយមានអណ្តូងមួយ គេរកស៊ីធ្វើស្រែចំការ ចេះត្បាញរវៃអម្បោះ សូត្រ, ចេះសិល្បៈ ឆ្លាក់ក្បាច់រចនា - ធ្វើចិញ្ចៀន, កងដៃ, កងជើង, កងក, ប្រើចានប្រាក់ យកពន្ធដារជាមាស ប្រាក់ គុជ និងមានក្បួនតម្រា - មានមន្ទីរឯកសារ - អក្សរសរសេរតាមអក្សរឥណ្ឌា - ទំនៀមការកូនចៅ - បុណ្យខ្មោចដូចនៅប្រទេសចាមដែរ ។ ប្រជាជនកាន់សាសនាព្រាហ្មណ៍ និងកាន់ពុទ្ធសាសនា ។

ឯកសារចិនបានបញ្ជាក់ថា ៖ ក្នុង ព.ស ១០៤៦ ( គ.ស ៥០៣ ) ព្រះបាទកោណ្ឌិន្យជ័យវរ្ម័ន បានបញ្ជូនរាជទូតម្នាក់ទៅប្រទេសចិន ។ នៅចុងគ្រិស្តសតវត្សទី៥ ដើមគ្រិស្តសតវត្សទី៦ ព្រះបាទកោណ្ឌិន្យជ័យវរ្ម័ន បានបញ្ជូនព្រះថេរ ១

អង្គ នាម សេងគា ប៉ូឡូ ( សង្ឃបាលោ ) ដែលចេះច្រើនភាសា ឱ្យទៅជួយបកប្រែគម្ពីរព្រះត្រៃបិដក អស់ ១៦ ឆ្នាំ នៅការិយាល័យនគរភ្នំ ឯប្រទេសចិន ។ ព្រះថេរៈនេះបានសុគតនៅទីនោះ ក្នុង គ.ស ៥២៤ ។

ព្រះថេរៈ ១ អង្គទៀត នាម ម៉ុនតូឡូ ( មន្ទ្រសេនៈ ) និមន្តទៅដល់ប្រទេសចិន ក្នុងឆ្នាំ គ.ស ៥០៣ ក៏បានទៅជួយបកប្រែគម្ពីរព្រះត្រៃបិដកដែរ ។ ព្រះនាមនៃព្រះថេរៈទាំងពីរអង្គ ចារក្នុងឯកសារនោះរហូតដល់សព្វថ្ងៃ ។ កាលពីឆ្នាំ ១៩៥៦ ពេលព្រះករុណាព្រះបាទសម្តេចព្រះ ន. សីហនុវរ្ម័ន ស្តេចយាងទៅប្រទេសចិន គេបានថ្វាយព្រះអង្គទតនូវស្នាដៃនោះ ។

ចំពោះភស្តុតាងនៅក្នុងប្រទេសយើងវិញ គេបានរកឃើញសិលាចារឹកមួយផ្ទាំង នៅវ៉ូកាញ នៅតំបន់ញ៉ាត្រាង ( សព្វថ្ងៃនៅក្នុងប្រទេសវៀតណាម ) ចារជាអក្សរខ្មែរបុរាណដ៏មានចំណាស់បំផុត សរសេរជាភាសាសំស្ក្រឹត ដែលក្នុងនោះមានពាក្យ " គតាគតិ " និងពាក្យ " ប្រជានំ ករុណា " ដែលជាពាក្យឧទ្ទិសរបស់ព្រះបាទស្រីមារៈ ដែលសោយរាជ្យនៅនគរភ្នំ ក្នុងសតវត្សទី៣ នៃមហាសករាជ ( គ្រឹស្តសតវត្សទី២ ) ។

អត្ថបទសិលាចារឹកបានឱ្យដឹងថា ៖ ព្រះរាជវង្សស្រីមារៈ បានត្រាស់បង្គាប់ឱ្យចារឹកទុកដើម្បីជាអនុស្សាវរីយ៍ ចំពោះព្រះបាទស្រីមារៈថា ៖ រាជកុលៈ គឺបឋមវង្សជ្រះថ្លាចំពោះពុទ្ធសាសនា ដោយត្រាស់យល់ច្បាស់នូវគតាគតិដំណើរអន្ទោល ស្លាប់កើតនៃសត្វលោក ក្នុងវាលវដ្តសង្សារ ទ្រង់ប្រកបដោយមេត្តា ករុណា ដល់សព្វសត្វហើយទ្រង់ត្រាស់បង្គាប់ឱ្យបរិច្ចាគព្រះរាជទ្រព្យព្រះអង្គធ្វើជាទាន ទុកជាសាធារណៈប្រយោជន៍ ។ ទ្រង់ផ្តាំឱ្យព្រះរាជាសោយរាជ្យជាតំណទៅអនាគត ឱ្យប្រតិបត្តិតាមព្រះរាជប្រកាសនេះ ដើម្បីជាប្រយោជន៍ដល់សត្វលោក ..... ។

សិលាចារឹកប្រាសាទតាព្រហ្ម ទន្លេបាទី ( គ្រឹស្តសតវត្សទី៦ ) ថា ព្រះបាទ

រុទ្រវរ្ម័ន ជាព្រះរាជបុត្រព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន ទ្រង់កាន់ពុទ្ធសាសនា ហើយគោរពព្រះបរមសារីរិកធាតុ នៃអង្គព្រះសម្មាសម្ពុទ្ធ ។

ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី ១ ( ព.ស ១២០០-១២២៤ ) ( គ.ស ៦៥៧ - ៦៨១ ) មានសិលាចារឹក ១ នៅវត្តព្រៃវៀរ រៀបរាប់ថា មានភិក្ខុពីរអង្គ ជាបងប្អូនបង្កើត ជាតិជាក្សត្រ ចេញទៅបួស ហើយគង់នៅវត្តព្រៃវៀរ ។ ទាំងពីរអង្គមានសីលជាពហុស្សូត្រ សុភាព ខន្តី មានករុណា មានសមាធិជាអរិយទ្រព្យ នាមខាងដើមដូចគ្នាថា " រតនៈ " គឺ រតនភាណុ និង រតនសិង្ហ ។ ព្រះថេរៈទាំងពីរអង្គនេះបានហាមប្រាមមិនឱ្យគេកាប់ព្រៃក្នុងវត្ត ទើបមានឈ្មោះថា វត្តព្រៃវៀររហូតមក ។

តាមពតិមានឥណ្ឌា - ចិន និងខ្មែរ យើងឃើញមានចំណុចត្រូវគ្នាច្រើនល្មមសន្និដ្ឋានបានថា ព្រះពុទ្ធសាសនា បានចូលដល់ប្រទេសកម្ពុជាយើង តាំងពីមុនគ្រឹស្តសករាជ ព្រមទាំងមានការរីកចំរើនយ៉ាងខ្លាំង តាំងពីសម័យនគរភ្នំមកម្ល៉េះ ។

ភស្តុតាងខាងលើនេះបញ្ជាក់ថា ពុទ្ធសាសនាត្រូវបានគេគោរពនៅកម្ពុជាតាំងពីរាប់ពាន់ឆ្នាំមកហើយ ។

ទន្ទឹមនឹងការគោរពពុទ្ធសាសនា គេក៏គោរពសាសនាព្រាហ្មណ៍ដែរ ។ ការគោរពសាសនាធំពីរទន្ទឹមគ្នាយ៉ាងនេះ បង្កើតបានជាចរន្តធំៗរបស់វប្បធម៌ ។ ចរន្តមួយចេញពីសាសនាព្រាហ្មណ៍ ដែលជាសាសនារបស់ស្រទាប់វណ្ណៈខ្ពស់ នៅសម័យនោះ និងចរន្តមួយទៀត ចេញពីវត្តអារាមនៃពុទ្ធសាសនា ។ ចរន្តទាំពីរនេះ មិនដែលប្រឆាំងគ្នាទេ ផ្ទុយទៅវិញ បានរស់នៅជាសហវិជ្ជមានជាមួយគ្នា និងបង្កើតបានជាផ្លូងពីរនៃវប្បធម៌របស់ជាតិ ។ ឯផ្លូងចរន្តទីបីនោះ គឺគតិបណ្ឌិតប្រជាប្រិយ និងជំនឿអ្នកស្រុកដើម ។

ក្នុងប្រវត្តិសាស្ត្ររបស់ខ្មែរ គេមិនដែលឃើញមានសង្គ្រាមសាសនារវាងពុទ្ធសាសនា និងសាសនាដទៃទៀតទេ ។ ផ្ទុយទៅវិញ គេឃើញមានការរួមរស់ជា

មួយយ៉ាងសុខសាន្ត រវាងសាសនាទាំងឡាយទៅវិញ ។ ពិតមែនហើយ ពេលដែលផ្លាស់ប្តូរការគោរពសាសនាម្តង តែងតែមានការកែច្នៃខ្លះ មិនខានឡើយ ។ ប៉ុន្តែគួរឱ្យស្តាយ សង្គ្រាមពីខាងក្រៅ និងការបែកបាក់សាមគ្គីផ្ទៃក្នុង បានធ្វើឱ្យខូចខាតដល់សមិទ្ធិខាងវប្បធម៌យ៉ាងសម្បើមឥតគណនា ។

ប៉ុន្តែ ទោះបីយ៉ាងណា ក៏យើងនៅតែឃើញមាននិរន្តរភាពរបស់ចរន្តវប្បធម៌នេះបន្តរហូត តាំងពីបុរាណ ដល់សព្វថ្ងៃ ។ យើងបានសង្កេតឃើញថា វត្តអារាម និងប្រាសាទបុរាណ នៅតែមានទំនាក់ទំនងគ្នាជានិច្ច ។ វត្តអារាមដែលសង់ថ្មីច្រើននៅក្បែរបុរាណដ្ឋានចាស់ ឬនៅចំពីលើកន្លែងដែលបាក់បែកអស់ទៅ ។ ដូចជា វត្តនៅទន្លេបាទី ជាឧទាហរណ៍ស្រាប់ ។

ការសង់បែបនេះ គឺជាបំណងរបស់ប្រជារាស្ត្រខ្មែរ ដែលចង់រក្សាកេរដំណែលបុរាណឱ្យគង់វង្ស ចង់បន្តការគោរពបូជាចំពោះបុព្វបុរសរបស់ខ្លួន ចាប់ពីឪពុកម្តាយឡើងទៅ ។ ដូច្នេះហើយបានជាយើងឃើញថា វត្តអារាមយើងសព្វថ្ងៃមានឈ្មោះតាមប្រាសាទ ឬទីតាំងបុរាណ ដូចជា វត្តអង្គរ, វត្តព្រះធាតុ, វត្តអង្គតាសូរ, វត្តអង្គស្នួល ជាដើម ។ រីឯវត្តជាច្រើនទៀត ពិតមែនតែដាក់ឈ្មោះថ្មី ប៉ុន្តែសង់ក្បែរបុរាណដ្ឋានដដែល ដូចជា វត្តបាទី វត្តភ្នំជីសូរ វត្តអាធ្វារ វត្តបាគង ..... ។

ត្រង់នេះបញ្ជាក់ថា ប្រាសាទក្តី វត្តក្តី សុទ្ធតែមានតួនាទីជាមជ្ឈមណ្ឌលវប្បធម៌ដូចគ្នា ។ ដូច្នេះ វត្តបានបន្តតួនាទីវប្បធម៌ តាំងពីសម័យបុរាណ ពិសេសពីសម័យអង្គរមក ។

## II. ពុទ្ធសាសនា និងប្រជាជនខ្មែរ

ដូចបានបញ្ជាក់ពីខាងដើមមកហើយ ប្រជារាស្ត្រខ្មែរ ៩៩% ជាអ្នកកាន់ពុទ្ធសាសនា ។ ការគោរពពុទ្ធសាសនានេះ មានតាំងពីសម័យបុរាណ គឺតាំងពីមុន

សម័យអង្គរទៅទៀត ។ ការគោរពពុទ្ធសាសនាតៗគ្នារាប់សតវត្សបែបនេះ បានធ្វើឱ្យទស្សនវិជ្ជាពុទ្ធសាសនា ជ្រួតជ្រាប ជិតជាប់ក្នុងផ្នត់ ចិត្តគំនិតរបស់ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស ។ ផ្នត់ ចិត្តគំនិតនេះ បានក្លាយទៅជា " ទស្សនៈរួមរបស់ជាតិ " ដែលមនុស្សខ្មែរសព្វថ្ងៃមានពីកំណើត ។ ទោះអ្នកនោះ មិនបានទៅវត្តរៀនធម៌អាថ៌ក៏ដោយ ក៏ទស្សនៈព្រះពុទ្ធដែលបន្តពីឪពុកម្តាយ បានជ្រាបចូលទៅដល់បុត្រធីតារួចស្រេចទៅហើយ ហើយដែលមិនអាចធ្វើឱ្យប្តូរផ្លាស់បានដោយងាយៗឡើយ ។ ជាពិសេស ប្រជាពលរដ្ឋជាកសិកររស់នៅតាមជនបទ រមែងផ្សារភ្ជាប់ខ្លួនគេទៅនឹងវត្តអារាម និងជួយទ្រទ្រង់វត្តឱ្យមានជីវិតជានិច្ចនិរន្តរ៍រហូតមក ។ ទីណាមានប្រជារាស្ត្រខ្មែររស់នៅ ទីនោះមានវត្ត ។ តាមតួលេខក្នុងឆ្នាំ ១៩១៦ នៅក្នុងទូទាំងប្រទេសមានវត្តអារាមចំនួន២.៥០៥ វត្ត ដែលក្នុងនោះមាន ២១វត្ត នៅក្នុងរាជធានីភ្នំពេញ ។ ព្រះសង្ឃមានចំនួន ៣០.០០០ អង្គ ។ បើប្រៀបទៅនឹងប្រជាពលរដ្ឋ ប្រហែល ២ លាននាក់ គឺថា វត្តមួយសំរាប់ប្រជាជនខ្មែរចំនួន ៨០០ នាក់ និងក្នុងចំណោមមនុស្ស ៦៦ នាក់ មានព្រះសង្ឃ ១ អង្គ ។ ដល់មកឆ្នាំ ១៩៦៩ វត្តបានកើនដល់ ៣.៣៦៩ ក្នុងនោះ វត្តធម្មយុត្តិកនិកាយមាន ១៣៩ វត្ត ។ ព្រះសង្ឃមានចំនួន ៦៥.០៦២ អង្គ ក្នុងនោះ ព្រះសង្ឃធម្មយុត្តមាន ២.៣៨៤ អង្គ ។ បើធៀបនឹងចំនួនប្រជាជនប្រហែល ៧ លាននាក់ ឃើញថា វត្តមួយសំរាប់ប្រជាជន ១.៧៨០ នាក់ និងព្រះសង្ឃមួយអង្គសំរាប់ប្រជាជន ៩២ នាក់ ។ បច្ចុប្បន្ននេះ នៅទូទាំងប្រទេសមានវត្តចំនួន ៣.០៨៧ វត្ត ព្រះសង្ឃមាន ២៧.៩៣៩ អង្គ ( ស្ថិតិ ១៩៩៤ ) បើធៀបនឹងប្រជាជន ឃើញថា វត្តមួយសំរាប់ប្រជាជន ២.២៦៧ នាក់, ព្រះសង្ឃ ១ អង្គសំរាប់ប្រជាជន ២៥៤ នាក់ ។ គិតតាមចំនួនប្រជាជន ៧.០០០.០០០ នាក់ ។ ដូច្នេះបានជាគេនិយមពោលថា វត្តជាជីវិតរបស់ខ្មែរ និងតំណាងនៃអត្ថិភាពរបស់ខ្មែរ ។

*តើគេច្រើនសង់វត្តអារាម នៅកន្លែងណា ?*

វត្តអារាម ទោះបីជាកន្លែងស្ងប់ សំរាប់អ្នកបួសសំងំបន្ទំចិត្តជំរះកិលេស តណ្ហា កាត់ផ្តាច់ការជាប់ជំពាក់នឹងជីវភាពរស់នៅសាមញ្ញរបស់មនុស្សក៏ដោយ ក៏វត្ត នៅតែមានទំនាក់ទំនងជាប្រចាំជាមួយសង្គម ផ្សារភ្ជាប់នឹងសង្គមជានិច្ចកាល ។ ដូច្នេះបានជាគេឃើញវត្តអារាម ច្រើនស្ថិតនៅកណ្តាលចំណោមភូមិ ។

វត្តទាំងឡាយ ច្រើនសង់លើទីទួលខ្ពស់ មិនលិចទឹកនៅរដូវវស្សា ឬនៅ លើកំពូលភ្នំ ។ នេះជាលក្ខណៈមួយបង្ហាញថា វត្តជាទីគោរពសក្ការៈ ត្រូវស្ថិតនៅ ខ្ពស់ជាងលំនៅរបស់ប្រជារាស្ត្រ ប្រហាក់ប្រហែលនឹងបុរាណប្រាសាទ ដែលគេ សាងនៅលើកំពូលភ្នំ ដូច្នេះដែរ ។

- វត្តសង់លើភ្នំណា យកឈ្មោះតាមភ្នំនោះ ដូចជា ភ្នំស្រង់, ភ្នំសន្ទុក, ភ្នំជិល, ភ្នំបាឆាយ, ភ្នំស្អាង, ភ្នំធន់មន់, ភ្នំសំពៅ, ភ្នំតាម៉ៅ ។ ល ។

- វត្តសង់លើទួលណា គេដាក់ឈ្មោះតាមទួលនោះ,

ឧទាហរណ៍ វត្តទួលព្រេច វត្តទួលរកា វត្តទួលស្ពឺ ជាដើម ។

- វត្តមួយចំនួនសង់លើទីតាំងរបស់អង្គចាស់ៗពីបុរាណ ដូចបានរៀបរាប់ ខាងលើ ហើយយកឈ្មោះតាមអង្គនោះ ឬព្រះធាតុនោះ ឬតាំងនោះ,

ឧទាហរណ៍ វត្តអង្គប្រូច, វត្តអង្គតាសូរ, វត្តព្រះធាតុ, វត្តត្រឡែងកែង, វត្តទន្លេបាទី ។ ល ។

- វត្តតាំងក្រសាំង, វត្តតាំងផ្លោច ។ ល ។

** *តាំង* គឺទួលក្នុងដងព្រៃ ដែលគេកាប់ឆ្ការកសាងជាភូមិ ឬកសាងជា វត្ត ។ ក្រៅពីទួល - អង្គ - ព្រះធាតុ - តាំង វត្តអារាមត្រូវបានគេកសាងនៅកន្លែង ផ្សេងៗទៀត ជិតៗភូមិ ដូចជា កន្លែងមានរំលិច ។ *រំលិច* ជាអន្លង់ទឹក មានសណ្ឋាន ទ្រវែង ទាល់ចុងដើម គ្មានផ្លូវទឹកហូរចេញចូល ច្រើននៅជិតស្ទឹង ជិតព្រែក ។ នៅ

ខាងខ្ពស់ គេហៅក្បាលរំលិច ខាងទាប គេហៅចុងរំលិច ។ រំលិចជាប្រភពទឹកមួយដែរ ។

- វត្តសង់នៅកន្លែងមានក្រាំង មានខ្នារ មានព្នៀត មានរលាំង . . . ។ ឧទាហរណ៍ វត្តក្រាំងយ៉ូវ វត្តខ្នារ វត្តរលាំងកែន ឬឃុំរលាំងកែន ។

***ក្រាំង* គឺជាទួលដែលមានទីវាល គេដាក់ឈ្មោះក្រាំងទៅតាមដើមឈើដែលដុះនៅលើដីក្រាំងនោះ ដូចជា :

ក្រាំងធ្នង់ ក្រាំងធ្នោ ក្រាំងចេក . . . ។

** *ខ្នារ* : គឺដីទួលខ្ពស់ព័ទ្ធជុំវិញត្រពាំង ឬស្រះដែលកើតឯងដោយធម្មជាតិ ឥតមានអ្នកណាជីក ។ បើគេកសាងវត្តនៅលើទីទួលនោះ គេក៏យកឈ្មោះតាមទីនោះ ។ ឧទាហរណ៍ វត្តខ្នារ នៅឃុំស្រឡប់ជាដើម ។ រីឯត្រពាំងដែលនៅជិតនោះ ក៏ឱ្យឈ្មោះហៅថា ត្រពាំងខ្នារ ក៏មាន ។

** *ព្នៀត* : គឺដីទួលទាបៗ នៅជាប់ពីមាត់បឹងប៉ាចហាច ឬមាត់បឹងមានស្រែ មានព្រៃរបោះ ។ ជួនកាល គេកសាងភូមិ កសាងវត្ត នៅលើទួលនោះ ហើយគេឱ្យឈ្មោះថា វត្តព្នៀត ឬ ភូមិព្នៀត . . . ។ ល ។

** *រលាំង* : គឺទួលប៉ែកខាងខ្ពស់ជិតរំលិច ឬក្បាលរំលិច ពេលគេកសាងជាវត្ត ជាភូមិនៅទីនោះ គេឱ្យឈ្មោះភូមិ វត្តតាមឈ្មោះរលាំងនោះដែរ ។ ឧទាហរណ៍ រលាំងគ្រើល រលាំងចក រលាំងឈ្វូក ជាដើម ។

** *គោក* : គឺទួលកណ្ដាលវាល ឬកណ្ដាលវាលស្រែ ឬក៏នៅកណ្ដាលទីដែលមានទឹកលិច បើគេកសាងភូមិ ឬវត្តនៅទីនោះ គេក៏ដាក់ឈ្មោះតាមឈ្មោះគោកនោះទៅ ។ ឧទាហរណ៍ វត្តគោកព្រីង - គោកសណ្ដែក - គោកត្រប់ - គោកគង់ ។ ល ។ គេកសាងវត្តនៅកន្លែងផ្សេងទៀត ដែលមានប្រភពទឹក ដូចជាលំហាច, របោល, បារាយណ៍, ស្តុក ជាដើម ។

*ហេតុអ្វីបានជាគេនិយមកសាងវត្ត នៅទីទាំងឡាយនោះ ?*

- ប្រទេសកម្ពុជាយើង ជាប្រទេសទំនាប ភ្លៀងច្រើន មានទឹកលិចច្រើន នៅរដូវវស្សា ។ ភូមិសាស្ត្របែបនេះ តម្រូវឱ្យគេជ្រើសរើសរកកន្លែងខ្ពស់ មិនលិចទឹក កសាងវត្តអារាម ដើម្បីងាយដល់ការធ្វើបុណ្យសុន្ទរ៍ទានផងទាំងឡាយ ។ គេអាចធ្វើដំណើរទៅកាន់ទីនោះបាន តាមទូកនៅរដូវទឹកលិច តាមផ្លូវគោក នៅរដូវប្រាំង ។

- ទីពីរ ទីកន្លែងនោះ ច្រើនមានប្រភពទឹកនៅក្បែរ ជាទីប្រជុំនៃមនុស្សសត្វផងទាំងឡាយនៅរដូវរាំងស្ងួត ។ គេនាំគ្នាទៅទីនោះបានផលប្រយោជន៍យ៉ាងច្រើនគឺ ទៅវត្តផង យកសត្វទៅឱ្យទឹកផង ងូតខ្លួនឯងផង ដងទឹកយកទៅបរិភោគផង បេះបន្លែវារិជាតិ មានឈូក ព្រលិត លំចង់ ស្បង្ក៏ជ ទៅបរិភោគផង ។

- ទីបី គឺជាកន្លែងដែលគេធ្លាប់គោរពបូជា តាំងពីបុរាណកាលតៗមក ។ យើងសង្កេតឃើញថា មានវត្តជាច្រើនដែលកសាងឡើងលើដំណៃលចាស់ពីបុរាណ ឬនៅលើកំពូលភ្នំតូចៗ ដែលជាកន្លែងពិសិដ្ឋខ្ពស់ជាងលំនៅរបស់ប្រជារាស្ត្រ ដែលធម្មតា ចូលចិត្តរស់នៅតាមវាលទំនាប ។

ឧទាហរណ៍ វត្តនៅទន្លេបាទី វត្តនៅក្នុងបរិវេណប្រាសាទអង្គរវត្ត ។ ល ។ វត្តភ្នំ ជីសូ - ភ្នំស្រង់ - ភ្នំបាសិត - ភ្នំសំពៅ - ភ្នំអណ្តើក . . . . ។ ល ។

- ទីបួន វត្តជាកន្លែងស្ងប់ ស្ងាត់ ត្រជាក់ត្រជុំ មានព្រៃឈើ ដែលគេហៅថាអារាម - ដូច្នេះ ទីទួលដែលមានព្រៃស្រោប់ នោះជាកន្លែងសមស្របមុនគេ ។

ទីប្រាំ វត្តអារាម ជាកន្លែងដែលមានបារមីនៃព្រះពុទ្ធជាព្រះបរមគ្រូ ជាឃ្លាំងនៃធម៌វិន័យ ដែលប្រជាជនខ្មែរមានជំនឿថាអាចកំចាត់បិសាច ខ្មោច ព្រាយ អសុរកាយបាន ។

រីឯទីទួលព្រៃស្មសាន ច្រើនជាកន្លែងដែលប្រជាជនខ្លាចរអែង ធ្វើឱ្យ

អារម្មណ៍របស់ប្រជាជនមិនស្ងប់ ។ ដូច្នេះ ព្រះសង្ឃដែលជាតំណាងនៃសេចក្ដីលះបង់ . តំណាងសេចក្ដីពិតសច្ចធម៌ . ដែលមិនចេះខ្លាចខ្មោច ព្រាយ បិសាចលោកតែងទៅតាំងទីធ្វើសំណាក់កម្មដ្ឋាន ធុតង្គ រុក្ខមូល ដើម្បីកំចាត់ពួកព្រាយអសុរកាយទាំងនោះ ។ ក្រោយមក គេក៏នាំគ្នាកសាងវត្តនៅទីនោះទៅ ។ វត្តបានក្លាយទៅជាការធានារ៉ាប់រង ជាទីពំនាក់ខាងសតិអារម្មណ៍ខាងផ្លូវចិត្តរបស់ប្រជាជន ។

*តើអ្នកណាជាអ្នកកសាងវត្តអារាម ?*

ដូចបានបញ្ជាក់ស្រាប់រួចមកហើយថា ប្រជាជនខ្មែរបានផ្សារភ្ជាប់ខ្លួនទៅនឹងវត្តអារាមតាំងពីកំណើត ។ ទំនាក់ទំនងរវាងវត្តអារាម និងជីវភាពរស់នៅរបស់ប្រជាជនខ្មែរ មានភាពរឹងមាំណាស់ មិនអាចកាត់ផ្ដាច់បានឡើយ ។

ដូច្នេះ បើមានការតាំងទីលំនៅថ្មីនៅកន្លែងណាមួយហើយ គេតែងនិមន្តព្រះសង្ឃ ១ អង្គ ពីវត្តណាមួយ ឱ្យទៅគង់នៅកន្លែងតាំងលំនៅថ្មីនោះ ដើម្បីបង្កើតជាវត្ត ។

វត្តជារបស់ឧបាសកពុទ្ធបរិស័ទ ពោលគឺ ប្រជាជនក្នុងភូមិស្រុកនៅជុំវិញវត្តនោះ ។ ប្រជាជនជាអ្នកកសាងវត្ត គេចាត់ទុកវត្តជាសម្បត្តិរួមរបស់គេ ។ ព្រះសង្ឃជាអ្នកទ្រទ្រង់ថែរក្សាវត្តអារាម ។

នៅសម័យបុរាណ ពេលដែលដីធ្លីនៅទូលាយ គេនាំគ្នាជ្រើសរើសរកដីទួលខ្ពស់ មានព្រៃឈើ មានទឹកនៅជិតធ្វើជាវត្ត ឬក៏គេតាំងវត្តនៅកន្លែងដែលប្រជាជនជឿថាមានខ្មោច ព្រាយ បិសាច ដែលតែងតែមកយាយីដល់ជីវភាពរស់នៅរបស់ប្រជាជន ។

ប៉ុន្តែក្រោយមក ពេលដែលដីធ្លីកាន់តែចង្អៀត ប្រជាជនកាន់តែច្រើន វត្តអារាមក៏បំបែកខ្លួនទៅតាមកំណើនរបស់ប្រជាជនដែរ ។ គឺប្រជាជនដែលចង់

បាននវត្តសំរាប់គោរពប្រតិបត្តិនៅជិតផ្ទះខ្លួន នាំគ្នាកសាងវត្តថ្មីឡើង ។

គេអាចកសាងវត្ត ដោយសារមានសប្បុរសជនធ្វើអំណោយដីធ្លី ឬប្រាក់កាស ឬក៏ទ្រព្យសម្បត្តិ ដើម្បីទិញដីធ្លី ទិញសម្ភារៈសំណង់ផ្សេងៗ ។

ជួនកាល អំណោយរបស់សប្បុរសជនម្នាក់ ក៏ល្មមអាចសង់វត្តមួយបាន ជួនកាលគេនាំគ្នាកាត់ដីធ្លី ដែលនៅជាប់គ្នា ឬផ្លាស់ប្តូរដីគ្នា រួមបញ្ចូលគ្នាឱ្យបានធំល្មមនឹងកសាងវត្តបាន ។

ចំពោះការសាងសង់កុដិ វិហារ សាលាបុណ្យ សាលាបាលី .... និយាយរួមគឺសំណង់ស្ថាបត្យកម្មក្នុងវត្តទាំងមូល គឺពុទ្ធបរិស័ទចំណុះជើងវត្តជាអ្នកជួយឧបត្ថម្ភ និងរ៉ាប់រង ។

ពេលសង់បានអគាររហើយ គឺប្រជាជនជាអ្នកសំរេចថា ត្រូវនិមន្តព្រះសង្ឃណាមកធ្វើជាចៅអធិការ ។ គណៈកម្មការ អាចារ្យវត្ត ក៏ត្រូវបង្កើតឡើងដែរ ដើម្បីបន្តទ្រទ្រង់វត្ត ជួយមើលដំណើរការរបស់វត្ត និងការដឹកនាំវត្តរបស់ចៅ-អធិការ ។ ភារកិច្ចរបស់អាចារ្យ និងគណៈកម្មការវត្ត គឺបន្តជួយសាងសង់សំណង់ទាំងឡាយរបស់វត្ត - កែលំអ - ជួសជុលសំណង់ចាស់ - សាងសង់សំណង់ថ្មី ។

ភារកិច្ចទីពីរ របស់ឧបាសកជើងវត្ត គឺការឃ្លាំមើលការគោរពប្រតិបត្តិធម៌វិន័យរបស់សង្ឃក្នុងវត្ត - របស់ចៅអធិការ ៖

- តើមានភាពបរិសុទ្ធល្អ ឬទេ ?
- តើត្រឹមត្រូវតាមធម្មវិន័យ និងសិក្ខាបទ ឬទេ ?
- តើការដឹកនាំរបស់គណៈសង្ឃ បានត្រឹមត្រូវល្អដែរ ឬទេ ?
- តើវត្តបំរើផលប្រយោជន៍រួមរបស់ពុទ្ធបរិស័ទជើងវត្តបាន សមតាមសេចក្តីប្រាថ្នាដែរ ឬទេ ?

ប្រសិនបើមានរឿងអាស្រូវណាមួយកើតឡើងនោះ មិនអាចកំបាំងនឹង

ភ្នែករបស់ប្រជាជនបានទេ ។ ព្រោះវត្តជាវត្តរបស់គេ គេមានសិទ្ធិ និងភារកិច្ចនឹងរក្សាភាពថ្លៃថ្នូរ និងកិត្យានុភាពរបស់វត្តគេ ។

ដើម្បីឱ្យវត្តនៅក្នុងភូមិរបស់គេរស់រាន រីកចំរើន ស្ថិតស្ថេរ ប្រជាជនតែងបរិច្ចាគកូនចៅរបស់គេឱ្យបួសជាសង្ឃ ដើម្បីបន្តដឹកនាំវត្តពីជំនាន់មួយ ទៅជំនាន់មួយ ។

*តើវត្តអារាមផ្តល់អ្វីខ្លះឱ្យប្រជាជនវិញ ?*

ក) វត្តអារាមជាទីតាំងនៃព្រះពុទ្ធសាសនា ដែលជាទីពឹងពំនាក់របស់ប្រជាជនគ្រប់ៗរូប ។

- ព្រះសង្ឃជួយប្រជាជនឱ្យរំដោះផុតពីការភ័យខ្លាច - តាមរយះការសូត្រមន្តផ្សេងៗ,

- ព្រះធម៌ធ្វើឱ្យបរិស័ទស្ងប់រំងាប់ - រំដោះខ្លួនពីសេចក្តីទុក្ខសោកទាំងឡាយ,

- ព្រះធម៌នាំបរិស័ទឱ្យដើរតាមផ្លូវត្រូវ - មជ្ឈិមប្បដិបទា - មានសីល ( មានទាន ) - បញ្ញា - សមាធិ មានអដ្ឋង្គិកមគ្គ ជាអាទិ៍ ។

- វត្តអារាម ជាកន្លែងស្ងប់រំងាប់ចិត្ត ឱ្យផុតកង្វល់ក្នុងជីវិត ដែលពោរពេញទៅដោយអរិជ្ជា តណ្ហា សេចក្តីលោភ ហឹង្សា សេចក្តីច្រណែនឈ្នានីស អំពើពាល អំពើឃោរឃៅ ការជិះជាន់ កេងប្រវញ្ចន៍ កាប់សម្លាប់ ពោលតី សង្គ្រាម និងអសន្តិសុខ ។ មនុស្សយើង ដើម្បីរស់នៅត្រូវតែតស៊ូក្នុងជីវិតរបស់ខ្លួន ។ ការតស៊ូតែងប៉ះទង្គិច ការប៉ះទង្គិចនាំឱ្យមានទំនាស់មិនចេះចប់ ។ ទំនាស់នេះនាំឱ្យមានវិបត្តិទាំងខាងផ្លូវកាយ ទាំងខាងផ្លូវចិត្ត ។ ម្យ៉ាងទៀត មនុស្សកើតមកមាន " កម្ម " មកជាមួយ កម្មនេះអាចផ្តល់សេចក្តីសុខ ឬទុក្ខ ។ ប៉ុន្តែសេចក្តីទុក្ខ ជាមរតក

ជាសច្ចធម៌ ដែលមនុស្សគ្រប់រូបត្រូវទទួល ពិសេសគឺ ទុក្ខដែលកើតមកពីសេចក្ដីកើតស្លាប់ ។ មនុស្សភ័យខ្លាចសេចក្ដីស្លាប់ណាស់ តែមនុស្សមិនខ្លាចប្រព្រឹត្តអំពើដែលនាំឱ្យទៅរកសេចក្ដីស្លាប់ទេ ។

អ្នកភ័យខ្លាចនឹងសេចក្ដីស្លាប់ អ្នកស្អប់ខ្ពើមអំពើបាប អ្នកចង់សាងអំពើល្អ តែងតែទៅពឹងវត្ត ។

*ខ) វត្តអារាមជាមន្ទីរពេទ្យខាងផ្លូវចិត្ត របស់បរិស័ទជើងវត្ត ។*

- ព្រះសង្ឃនិងព្រះធម៌អាចជួយព្យាបាល ជួយពន្យល់ឱ្យបរិស័ទអ្នកមានទុក្ខ មានកង្វល់ រំលត់ទុក្ខព្រួយបាន ។ ពេលមានកើតហេតុមិនល្អ នៅតាមគ្រួសារក្ដី នៅភូមិក្ដី - គេតែងនិមន្តព្រះសង្ឃទៅជួយដោះស្រាយ ។

- គ្រប់ពិធីទាំងអស់នៅក្នុងគ្រួសារ តាំងពីកើតរហូតដល់ស្លាប់ គេមិនដែលចោលព្រះសង្ឃទេ ។

- ព្រះសង្ឃជួយអប់រំជនពាល ជនប្រមឹកឱ្យស្គាល់ផ្លូវត្រូវវិញបាន ។

*គ) វត្តជាកន្លែងជ្រកកោនរបស់អ្នកកំសត់ទុរគត ។*

គ្រប់វត្តអារាម តែងទទួលចិញ្ចឹមកុមារកំព្រាឥតទីពឹង ព្រមទាំងសិស្សានុសិស្សជាកូនចៅរបស់ប្រជាជនដែលនៅទីឆ្ងាយ ខ្វះជម្រក ខ្វះទីសំណាក់ ដើម្បីបន្តការសិក្សា ។

ជនពនេចរ - ចាស់ជរា - ជនអភ័ព្វឥតសំណាង គ្មានកូនចៅជួយទំនុកបំរុង តែងទៅជ្រកនៅក្នុងវត្ត ដើម្បីរៀនធម៌អាថ៌ នៅក្នុងដំណាក់ចុងក្រោយនៃជីវិតរបស់ខ្លួន ។

*ឃ) វត្តជាជម្រកនិរភ័យរបស់សត្វម្រឹគីម្រឹគា បក្សាបក្សី និងមច្ឆជាតិ និងជាកន្លែងរក្សា ការពារពូជឈើ ព្រៃ ឱ្យគង់វង្ស ។ វត្តជាសួនច្បារ ជាអារាម ជារមណីយដ្ឋាន អាចលំហែអារម្មណ៍បាន ។*

ការបំផ្លាញព្រៃឈើរបស់វត្តអារាម ធ្វើឱ្យបក្សាបក្សីបាត់ជម្រក ហើយក៏ហើរទៅកន្លែងផ្សេងៗ ។ ការបំផ្លាញវត្ត ធ្វើឱ្យមច្ឆជាតិ ព្រៃឈើ និងបក្សាបក្សី ដែលជាសម្បត្តិធម្មជាតិមានតំលៃសំរាប់ទ្រទ្រង់ជីវិតមនុស្ស វិនាសសាបសូន្យ ឬក៏ផុតពូជតែម្តង ។

*ង) វត្តជារណ្តៅដែលគេកប់ចោលនូវទំនាស់ទាស់ទែងគ្នា ជាកន្លែងដែលមនុស្សទាំងអស់មានភាពស្មើគ្នា ។*

ពេលចូលទៅដល់ក្នុងវត្ត ទាំងអស់គ្នាមានឈ្មោះថាឧបាសក ឧបាសិកា ពេលនោះ ទោះបីជាមន្ត្រីរាជការមានឋានៈណាក៏ដោយ ក៏ត្រូវថ្វាយបង្គំព្រះពុទ្ធ.បដិមា ថ្វាយបង្គំព្រះសង្ឃដូចគ្នា ។ ហើយបើចូលបព្វជ្ជាជាសង្ឃ ក៏រឹតតែមានសមភាព នឹងគ្នាទៅទៀត ។ វត្តជាកន្លែងដែលឋានៈសង្គមទាំងឡាយ ត្រូវរលាយចូលគ្នា ។ វត្តជាកន្លែងដែលធ្វើឱ្យមនុស្សគ្រប់ស្រទាប់ខិតចូលជិតគ្នា យល់អធ្យា.ស្រ័យគ្នា អនុគ្រោះឱ្យគ្នា ដោយអំណាចនៃព្រះធម៌ នៃធម៌អហឹង្សា វិរិយៈ ខន្តី និងភាពទន់ភ្លន់ ... ។

ហេតុនេះ ព្រះសង្ឃត្រូវប្រកាន់ទសពិធរាជធម៌ និងព្រហ្មវិហារធម៌ឱ្យបាន ដើម្បីជួយពុទ្ធបរិស័ទឱ្យបានស្មើៗគ្នា ដោយឥតរើសអើង ឥតប្រកាន់បក្ស ពួក ឥតប្រកាន់និន្នាការនយោបាយ ប្រកាន់ពណ៌សម្បុរ ប្រកាន់វណ្ណភាពឡើយ ។

*ច) វត្តជាចំណុចកណ្តាលនៃផ្លូវសាមគ្គីភាពជាតិ និងប្រជាធិបតេយ្យ*

គ្មានកន្លែងដែលនាំប្រជាជនខ្មែរទៅរកសាមគ្គីភាព និងប្រជាធិបតេយ្យបានល្អ ដូចវត្តអារាមទេ ។ ព្រះសង្ឃ បានធ្វើគំរូមុនគេក្នុងការរក្សាសាមគ្គីភាព និងប្រជាធិបតេយ្យ ។ រីឯប្រជាជន ក៏រៀនសូត្រធម៌ទាំងពីរនេះ ពីវត្តអារាមដែរ ។

*ឆ) វត្ត ក៏ជាកន្លែងការពារសិទ្ធិរបស់ប្រជាជនដែរ ។*

នៅសម័យអាណានិគមបារាំង វត្តបានជួយលាក់បំពួនជនអ្នកស្នេហាជាតិ

ដែលបះបោរប្រឆាំងបារាំង និងមនុស្សដែលត្រូវរដ្ឋការបារាំងចោទថា ជាអ្នកមានទោស ។

ក្រោយមក ចៅអធិការវត្ត អាចមានសិទ្ធិបិណ្ឌបាតយកអ្នកមានទោសទៅអប់រំឱ្យកែប្រែអត្តចរិតសីលធម៌អ្នកទោសទាំងនោះបាន ។ ដូច្នេះ វត្តក្លាយទៅជាមណ្ឌលកែប្រែ និងអប់រំឡើងវិញរបស់ប្រជាជន ។

គេតែងយកជនខិលខូច ជនប្រមឹក ជនពាលអាវ៉ាសែ ទៅប្រគេនព្រះសង្ឃជួយអប់រំ ។

*ជ) វត្តជាមជ្ឈមណ្ឌលវប្បធម៌របស់ប្រជាជន ។*

១ . វត្តជាសាលារៀនខាងលេខនព្វន្ត និងអក្សរសាស្ត្ររបស់ប្រជាជន ។ រហូតមកដល់ចុងសតវត្សរ៍ទី១៩ ឬដើមសតវត្សរ៍ទី ២០ វត្តជាមជ្ឈមណ្ឌលតែមួយគត់នៃការអប់រំ និងការសិក្សានៅជនបទ ។

បុរសស្ទើរតែ ១០០% សុទ្ធតែបានបួសរៀននៅក្នុងវត្ត យ៉ាងហោចណាស់ក៏មួយវស្សាដែរ ។ ចំណុចនេះបញ្ជាក់ថា មនុស្សប្រុសទាំងអស់ សុទ្ធតែបានឆ្លងផុតគ្រោះមិនចេះអក្សរ ។ រីឯផ្នែកនារីវិញ ទោះបីមិនបានរៀនសូត្រនៅវត្ត ប៉ុន្តែក៏មានស្ត្រីចេះអក្សរដោយសាររៀនពីឪពុក និងបងៗ ដែលធ្លាប់បានបួសរៀនអក្សរនៅវត្តដែរ យ៉ាងហោចណាស់ក៏កូនស្រីបានទទួលការអប់រំខាងច្បាប់សីលធម៌ ក្នុងពេលចូលម្លប់ដែរ ។

២. វត្តជាកន្លែងអប់រំសីលធម៌របស់ខ្មែរ ។

វត្តជាកន្លែងទ្រទ្រង់សីលធម៌សង្គម ធ្វើឱ្យសង្គមខ្មែរមានរបៀបរបបខាងសីលធម៌មួយ ដែលមានច្បាប់ជាមូលដ្ឋាន ។ អ្នកដែលបានបួសរៀននៅវត្តគេចាត់ទុកថាជាអ្នកចេះដឹងខាងសីលធម៌ . មានកិត្តិយស . មានឋានៈ មុខមាត់ស្មើគេឯងនៅក្នុងភូមិ . ក្នុងសង្គម ។ ពុទ្ធសាសនា ជាលទ្ធិ "សង្គ្រោះខ្លួនឯង" ឱ្យមាន

តម្លៃគួរដល់ការគោរព និងចេះគោរពអ្នកដទៃ ។

ក្បួនខ្នាត ទំនៀមទម្លាប់ ប្រពៃណី ពិធីការផ្សេងៗ ត្រូវគេបង្រៀននៅក្នុងវត្ត ។ ដូចជាសាស្ត្រាច្បាប់ប្រុស ច្បាប់ស្រី ច្បាប់កេរកាល ច្បាប់ត្រីនេតិ៍ ច្បាប់ក្រម ច្បាប់ពាក្យចាស់ ។ល។ នេះជាច្បាប់សំរាប់គ្រហស្ថ ហៅថា អគារិយ-វិន័យ ។ ឯអានាគារិយវិន័យ ក៏វត្តរឹតតែយកចិត្តទុកដាក់បង្ហាត់បង្រៀន ថែបំប៉នណាស់ទៅទៀត ។ គឺលោកមេវត្ត ជាអ្នកបង្ខំឱ្យព្រះសង្ឃរៀនច្បាប់ទាំងនេះ ។ ច្បាប់ - សីលធម៌ - វិន័យរបស់ពុទ្ធសាសនានេះហើយ ដែលជាគ្រឹះមូលដ្ឋាន នៃសីលធម៌ខ្មែរ ។

៣- វត្តជាកន្លែងអប់រំវិជ្ជាជីវៈ ។

មុខវិជ្ជាជាច្រើន ត្រូវបានគេបង្រៀននៅក្នុងវត្ត គឺការបង្រៀនដោយអនុវត្តផ្ទាល់ ដូចជាមុខរបរជំនាងចម្លាក់ សិល្បៈ សិប្បកម្មសម្រាប់បំរើជីវភាពរស់នៅរបស់ប្រជាជន ។

ការទៅវត្តបួសរៀនសំរាប់កូនចៅប្រជាជនខ្មែរ មិនមែនដើម្បីស្វែងរកសួគ៌និព្វានទេ គឺគ្រាន់តែបំពេញលក្ខណសម្បត្តិជាមនុស្សប្រុស ដែលសមល្មមអាចប្រកបរបរចិញ្ចឹមជីវិត និងរស់នៅក្នុងសង្គមដោយសេចក្ដីថ្លៃថ្នូរ ស្មើមុខ ស្មើមាត់នឹងគេ ពេលដែលខ្លួនលាចាកសិក្ខាបទមកជាគ្រហស្ថវិញតែប៉ុណ្ណោះ ។ នៅវត្តគេមិនគ្រាន់តែរៀនវិជ្ជាខាងជំនាង ដូចជាជាងទង ជាងឈើ ជាងសំណង់ធ្វើផ្ទះសម្បែងប៉ុណ្ណោះទេ ។ ប៉ុន្តែ គេអាចរៀនខាងវិជ្ជាផ្សំថ្នាំបុរាណ វិជ្ជាខាងតន្ត្រីបុរាណដូចភ្លេងពិណពាទ្យ និងល្បែងប្រជាប្រិយផ្សេងៗទៀត ដូចជា ធ្វើខ្លែង ធ្វើកាំជ្រួចធ្វើទូកង ធ្វើគោមបង្ហោះ ព្រមទាំងរៀនដឹកនាំពិធីការផ្សេងៗ ក្នុងពេលបុណ្យទានផ្សេងៗ ពេលរៀបពិធីជាមង្គលធំៗ ដូចជាពិធីរៀបការ ពិធីបូជាសព ការធ្វើមេរុការធ្វើមឈូស ការរក្សាសពទុកឱ្យបានយូរ ។ល។

៤. វត្តជាបណ្ណាល័យរបស់ប្រជាជន ។

គ្រប់វត្តពីបុរាណ សុទ្ធតែមានបណ្ណាល័យ មានរក្សាទុកគម្ពីរក្បួនខ្នាត និង គម្ពីរដីកា សាស្ត្រាស្លឹករឹត ។ ពេលត្រូវការផ្ទៀងផ្ទាត់អំពីព្រឹត្តិការណ៍ ឬក្បួនខ្នាតអ្វីមួយ គេតែងទៅបើកមើលក្បួននៅតាមវត្ត ដូចជាក្បួនហោរា ក្បួនទំនាយផ្សេងៗ មានទំនាយព្រហ្មជាតិសំរាប់ជ្រើសរើសគូស្រករ ឬក្បួនល្អសំរាប់ប្រារព្ធពិធីផ្សេងៗ ។ ល ។

ព្រះសង្ឃជាអ្នកចារចម្លងសាស្ត្រា គម្ពីរនានា ទាំងខាងធម៌អាថ៌ ទាំងខាងអក្សរសាស្ត្រ ប្រវត្តិសាស្ត្រ និង ជាអ្នកថែរក្សាសម្បត្តិវប្បធម៌ អក្សរសាស្ត្រ និង សិល្បៈរបស់ជាតិ ។

៥. វត្តជាកន្លែងបង្កើតស្នាដៃនិពន្ធ ។

ព្រះសង្ឃ មិនគ្រាន់តែជាអ្នកថែរក្សាក្បួនខ្នាត ខាងអក្សរសាស្ត្រ សីលធម៌ ធម៌អាថ៌ របស់ព្រះពុទ្ធប៉ុណ្ណោះទេ ។ ប៉ុន្តែ លោកជាអ្នកបង្កើតស្នាដៃដោយផ្ទាល់ផង ជាអ្នកបណ្តុះបណ្តាលកវីនិពន្ធខ្មែរផង ។ ព្រះសង្ឃដែលបានរៀនសូត្រភាសាបាលីជ្រៅជ្រះ បានបកប្រែគម្ពីរពីភាសាបាលីមកជាភាសាខ្មែរ និងបាននិពន្ធសៀវភៅធម៌អាថ៌ ជាច្រើនសំរាប់ព្រះសង្ឃក្មេងៗ និងពុទ្ធបរិសទ័រៀនសូត្រ ។ ព្រះសង្ឃអង្គខ្លះទៀត មានថ្វីមាត់អាចនិយាយជាកាព្យ សរសេរជាកាព្យ អាចនិពន្ធទាំងរឿងបែបអក្សរសិល្ប៍ទៀតផង ។ បើនៅពេលគង់ក្នុងផ្នួស លោកមិនបានតែងនិពន្ធ ក៏ដល់ពេលលោកចាកសិក្ខាបទមកវិញ ក៏លោកក្លាយទៅជាអ្នកនិពន្ធដែរ ។

អ្នកនិពន្ធ និងអ្នកកវីខ្មែរ សុទ្ធតែចេញមកពីវត្តអារាមទាំងអស់, ដូចជាព្រះនាងឥន្ទ្រទេវី នៅសម័យអង្គ ( សតវត្សរ៍ទី ១២ )

១/ បណ្ឌិត ជ័យនន្ទ - សិលាចារឹកនគរវត្ត

២/ អ្នកប៉ាង - ល្បើកអង្គរវត្ត

៣/ ព្រះឃ្លាំងនង - លោកនេយ្យជាតក

៤/ ម៉ឺនភក្តីអក្សរតន់ - រឿងសព្វសិទ្ធ

៥/ ព្រះអរិយគាមនី ហ៊ីង - រឿងព្រះជិនវង្ស

៦/ សន្ធរម៉ុក - រឿងទេវន្ទ

៧/ ព្រះបទុមថេរ សោម - រឿងទុំទាវ

៨/ សុត្តន្តប្រីជា ឥន្ទ - គតិលោក, និរាសនគរវត្ត

៩/ អ្នកព្រះភិរម្យភាសា អ៊ូ - ច្បាប់ល្បើកថ្មី

១០/ សម្តេចព្រះសង្ឃរាជជួនណាត - វចនានុក្រមខ្មែរ ។ល។

ដូច្នេះ យើងឃើញថា វត្តអារាមនេះហើយជាកន្លែងថែរក្សា ទ្រទ្រង់វប្បធម៌ខ្មែរឱ្យគង់វង្ស និងរីកចំរើនរៀងរហូតមកដល់សតវត្សរ៍ទី ២០ នេះ ។

៦. វត្តអារាមជាមណ្ឌលផ្សព្វផ្សាយវប្បធម៌ខ្មែរ និងផ្តល់ពត៌មានដល់ប្រជារាស្ត្រ ។

ពុទ្ធសាសនានៅកម្ពុជា មានប្រព័ន្ធគ្រប់គ្រងដឹកនាំជាឋានានុក្រម ពីថ្នាក់កំពូល រហូតដល់ជនបទគឺ វត្តអារាមនេះឯង ។ នៅថ្នាក់កំពូល មានសម្តេចព្រះសង្ឃ-រាជ និងមន្ត្រីសង្ឃថ្នាក់រាជាគណៈ និងឋានានុក្រម ។ នៅថ្នាក់ខេត្រមាន មេគណខេត្រ, នៅថ្នាក់ស្រុក មានអនុគណស្រុក, នៅវត្ត មានចៅអធិការ និងលោកគ្រូសូត្រឆ្វេង - ស្តាំ ជាជំនួយ ។ នៅមុនឆ្នាំ ១៨៦៤ ពុទ្ធសាសនានៅកម្ពុជា មានតែ ១ គណៈទេ គឺគណៈមហានិកាយ ។ គណៈធម្មយុត្តិកនិកាយ មានកំណើតនៅប្រទេសថៃនៅក្នុងឆ្នាំ ឆ្លូវ ឯកស័ក ច.ស ១១៩១ ត្រូវនឹងគ.ស.១៨២៩ ។ នៅសម័យឧដុង្គ (សម្តេចព្រះសុគន្ធាធិបតី) មហាប៉ាន បាននិមន្តទៅរៀននៅប្រទេសថៃ ហើយបាននិមន្តទៅគង់នៅវត្តបវ៉ននិវ៉ាត ដែលជាវត្តធម្មយុត្តដំបូងបំផុត កសាងឡើងដោយព្រះចោមក្លាវ ។ ដល់ពេលត្រឡប់មកប្រទេសវិញ លោកបានសុំព្រះរាជានុញ្ញាតបង្កើត

គណៈធម្មយុត្តិកនិកាយនៅកម្ពុជា ទើបបានជាមានគណៈធម្មយុត្តតាំងពីពេលនោះមក ។

ចំពោះសមណស័ក្តិ តាមបវេណីក្នុងរដ្ឋកម្ពុជាពីបុរាណមក មាន :

- ទីសម្តេចសង្ឃ
- ទីសង្ឃនាយក
- ទីរាជាគណៈ
- ទីឋានានុក្រម
- ទីមហា

ហើយចែកជាបួនថ្នាក់ គឺ ឯក - ទោ - ត្រី - ចត្វា ។ សមណស័ក្តិទីរាជាគណៈ មាន ៣២ គឺ :

- ថ្នាក់ឯក មាន ១១ ( ផ្ចិតពណ៌ក្រហម )
- ថ្នាក់ទោ មាន ៧ ( ផ្ចិតពណ៌បៃតង )
- ថ្នាក់ត្រី មាន ៧ ( ផ្ចិតពណ៌ស្វាយ )
- ថ្នាក់ចត្វា មាន ៧ ( ផ្ចិតពណ៌ខៀវ )

ដល់មក គ.ស ១៩៤៣ មានការកែប្រែបន្ថែមបន្ថយខ្លះ ហើយដល់មក គ.ស ១៩៤៨ បានកែប្រែម្តងទៀត ដោយចែកជាពីរ គឺ :

| មហានិកាយ | ធម្មយុត្តិកនិកាយ |
|---|---|
| * ព្រះសង្ឃនាយកគណៈមហានិកាយ | * ព្រះសង្ឃនាយកគណៈធម្មយុត្តិកនិកាយ |
| ព្រះមហាសុមេធាធិបតី | ព្រះសុគន្ធាធិបតី |
| (សម្តេចព្រះសង្ឃរាជ) | ( សម្តេចព្រះសង្ឃរាជ ) |
| ទីរាជាគណៈ មាន ៣៥ គឺ | ទីរាជាគណៈ មាន ២១ គឺ |
| ថ្នាក់ឯក មាន ៣ | ថ្នាក់ឯក មាន ២ |

| | |
|---|---|
| ថ្នាក់ទោ មាន ៦ | ថ្នាក់ទោ មាន ៣ |
| ថ្នាក់ត្រី មាន ៦ | ថ្នាក់ត្រី មាន ៤ |
| ថ្នាក់ចត្វា មាន ២០ | ថ្នាក់ចត្វា មាន ១២ |

រាជាគណៈទាំងអស់ មាន ៥៦ អង្គ

ព្រះសង្ឃនាយក ( សម្តេច ) ទាំងពីរព្រះអង្គ និងរាជាគណៈទាំង ៥៦ អង្គនេះ សុទ្ធតែព្រះមហាក្សត្រទ្រង់ប្រោសព្រះរាជទានតែងតាំងដោយព្រះរាជក្រឹត្យ ។

ព្រះសង្ឃទាំង ៥៦ អង្គ ព្រមទាំងព្រះឋានានុក្រម រហូតដល់ព្រះចៅអធិការមានឥទ្ធិពលខ្លាំងណាស់ក្នុងការឃោសនា ផ្សព្វផ្សាយ អប់រំ ខាងទ្រឹស្តីពុទ្ធសាសនា ខាងធម៌អាថ៌ ក៏ដូចជាពតិមានផ្សេងៗ ។ ដូច្នេះហើយបានជារឿងរ៉ាវ ច្បាប់ ទម្លាប់ក្បួនខ្នាត និងពតិមានផ្សេងៗ បានរីកសាយយ៉ាងឆាប់រហ័ស ចូលទៅដល់ភូមិ ដល់ផ្ទះប្រជាជន ។

ការចារចម្លង . គម្ពីរ ពីវត្តមួយទៅវត្តមួយ ពីភូមិមួយទៅភូមិមួយ ការទេសនាពីផ្ទះមួយទៅផ្ទះមួយ គឺជាការផ្ទេរមរតកវប្បធម៌របស់ជាតិ ពីជំនាន់មួយ ទៅឱ្យជំនាន់មួយទៀត ។

ឧទាហរណ៍ ដូចជានៅសម័យបុរាណ យើងមានសិលាចារឹកជិត ២.០០០ ផ្ទាំង ( ទាំងភាសាខ្មែរ ទាំងភាសាសំស្ក្រឹត ) ។

. នៅសម័យកណ្តាល មានសាស្ត្រាស្លឹករឹត រាប់ពាន់ច្បាប់ មានក្រាំងមានគម្ពីរ រាប់ពាន់ច្បាប់ ។

. នៅសម័យទំនើប មានសៀវភៅរាប់ម៉ឺនក្បាល ដែលត្រូវចារចម្លងផ្សាយ ។

ព្រះសង្ឃជាអ្នកអាន អ្នកទេសនា និងអ្នកស្មូត្រកាព្យ យ៉ាងពិរោះទៀត

ផង ។

ខ្មែរមានក្បួនតែងកាព្យជាង ៤០ និង មានរបៀបសូត្រកាព្យជាង ៦០ បែប ហើយមានតែព្រះសង្ឃទេ ដែលមានទេពកោសល្យក្នុងការតែងនិពន្ធ និងសូត្រកាព្យ ។

នៅសម័យបុរាណ គ្រប់វត្ត សុទ្ធតែមានស្គរធំសម្រាប់ផ្តល់សញ្ញាល្អ ឬសញ្ញាអាសន្នដល់ប្រជាជន ។ ដូចជា ពេលមានចោរកម្ម ពេលមានភ្លើងឆេះផ្ទះ ពេលមានបុណ្យមានត្រូវប្រមូលផ្តុំមនុស្ស ជាដើម ។

៧. វត្តជាកន្លែងសម្រាប់ផ្តល់នូវបុណ្យកុសលគ្រប់យ៉ាងដល់ប្រជាពលរដ្ឋ ដើម្បីឱ្យពុទ្ធបរិស័ទកើតសទ្ធា ជ្រះថ្លា កសាងបុណ្យ រក្សាសីល ធ្វើទាន ដើម្បីសេចក្តីសុខចំរើន ។ វត្តជួយកសាងកិច្ចការសង្គមជាកុសលច្រើនទៀត ដូចជា អណ្តូងទឹក ថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យ ។ល។

៨. វត្តអារាមជាទីប៉ាឆា សម្រាប់បូជាសពនៃប្រជាពលរដ្ឋ ។

តាមទម្លាប់ខ្មែរ ពេលស្លាប់ គេតែងតែចង់ទៅជួបព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។ ហេតុនេះបានជា គេតែងយកសពទៅបូជានៅវត្ត រួចគេបញ្ចុះធាតុ ឬតម្កល់ធាតុនៅក្នុងវត្តនោះតែម្តង ។

ដោយសារធាតុរបស់មាតាបិតា ញាតិសន្តានរបស់គេនៅឯវត្តជាមួយគ្នាដូច្នេះហើយបានជា វត្តក្លាយទៅជាទីជួបជុំគ្នារវាងប្រជាជនក្នុងភូមិទាំងអស់ ជាពិសេស ពេលបុណ្យចូលឆ្នាំ បុណ្យភ្ជុំបិណ្ឌ ជាដើម ។

តាមប្រពៃណីរបស់ខ្មែរ ការគោរពដឹងគុណចំពោះមាតាបិតា និងគ្រូឧបជ្ឈាយាចារ្យ ឬគ្រូបាធ្យាយ ជាអំពើប្រកបដោយកតញ្ញូកតវេទី ដែលកុលបុត្រកុលធីតាត្រូវធ្វើវត្តប្រត្តិបត្តិជាចាំបាច់ ដោយខានពុំបានឡើយ ។ ឱ្យតែដល់រដូវទាំងពីរនេះ ទោះបីគេទៅរស់នៅទីឆ្ងាយដល់ណាក៏ដោយ ក៏គេតែងតែឆ្លៀតពេល

ត្រឡប់ទៅកាន់ភូមិកំណើត វត្តកំណើតរបស់គេ ដើម្បីធ្វើកិច្ចតបស្នងសងគុណរំឭកគុណដល់បុព្វការីជនរបស់គេ មានការជូនជំនូនជាសំពត់ អាវ សម្លៀកបំពាក់ និចំណីប្រាក់កាស ការបោសសំអាតធាតុចេតិយ ដែលជាកន្លែងបញ្ចុះធាតុ ការបង្សុកូលជូនអ្នកដែលលាចាកលោកនេះទៅហើយ ជាដើម ។

ចំពោះអ្នកដែលបានបួសជាព្រះសង្ឃវិញ ការគោរពគ្រូឧបជ្ឈាយ៍ និងចៅអធិការ មានជម្រៅធំធេងជាងការគោរពឪពុកម្ដាយបង្កើតទៅទៀត ។ ទោះបីសឹកមកជាគ្រហស្ថវិញហើយក៏ដោយ ក៏លោកគ្រូចៅអធិការ និងគ្រូឧបជ្ឈាយ៍ នៅតែមានឥទ្ធិពលដដែល ។ រីឯសិស្សានុសិស្សវិញ ក៏ខិតខំថែរក្សាលើកតម្កើងកេរ្តិ៍ឈ្មោះរបស់លោកគ្រូ របស់ខ្លួនគេដែរ ។

ទម្លាប់ល្អនេះ បានសាបរលាបបន្តិចម្ដងៗ នៅពេលដែលសាលារៀនរៀបរយសាធារណៈកើតឡើង គឺក្នុងរវាងឆ្នាំ ១៩១០ ។ ពេលដែលសិស្ស ១ ភាគបានឃ្លាតចេញពីវត្ត មករៀននៅសាលាបារាំង ដោយឆ្លងកាត់ថ្នាក់កាន់តែច្រើនចំណេះដឹងខាងវិទ្យាសាស្ត្រសង្គមកាន់តែខ្ពស់ អរិយធម៌ និងស៊ីវិល័យសកល ក៏ចូលមកលាយឡំក្នុងការអប់រំ លោកគ្រូ សាស្ត្រាចារ្យ កាន់តែច្រើន ដូច្នេះសិស្សម្នាក់ៗគោរពកោតខ្លាចគ្រូតែពេលរៀនក្នុងថ្នាក់ទាប ឬក្នុងឆ្នាំដែលខ្លួនរៀនតែប៉ុណ្ណោះ នឹងគោរពកោតខ្លាចដូចសិស្សដែលរៀនក្នុងសំណាក់តែគ្រូមួយអង្គពុំបាន ។ ម្យ៉ាងទៀត លោកគ្រូ សាស្ត្រាចារ្យ នៅសាលាសាធារណៈ លោកមានប្រាក់បៀវត្សដែលរដ្ឋផ្ដត់ផ្គង់ មានគ្រួសារ បុត្រ ភរិយា ជាអ្នកជួយទំនុកបំរុងរួចហើយ ដូច្នេះបានជាកម្រមានសិស្សនៅរក្សាសេចក្ដីដឹងគុណដូចព្រះសង្ឃណាស់ ។

៩. វត្តអារាមជាកន្លែងប្រមូលផ្ដុំ នៃជំនឿរបស់ប្រជាជន ។

ដោយសារវត្តជាទីប្រជុំនៃឧបាសកបរិស័ទជើងវត្ត ដែលមានជំនឿ ទម្លាប់ដូចគ្នាខ្លះ ខុសគ្នាខ្លះ ដូច្នេះ ដើម្បីឱ្យសមស្របទៅនឹងចំណង់ចំណូលចិត្តរបស់ពុទ្ធ-

បរិស័ទដែលជាម្ចាស់របស់វត្ត គេឃើញមានលទ្ធិសាសនា និងជំនឿជាច្រើន រលាយចូលគ្នានៅក្នុងវត្តអារាម ។ ដូចជាមានអ្នកតា មានយាយទេព តាមោក មានការគោរពលឹង្គ ព្រះសីវៈ ។ ល ។

ការរលាយខាងជំនឿបែបនេះ គឺជាលក្ខណៈនៃវប្បធម៌ខ្មែរ ដែលជាវប្បធម៌កកើត និងធំធាត់ រីកចំរើន ដោយសារការរលាយចូលគ្នានៃវប្បធម៌ពីក្រៅ និងវប្បធម៌របស់ខ្មែរ ។ *ប៉ុន្តែ ចំណុចសំខាន់ដែលត្រូវកត់សម្គាល់ គឺធាតុពីក្រៅ ត្រូវតែចំណុះក្នុងក្បួនខ្នាតរបស់វប្បធម៌ខ្មែរ ហើយរលាយបាត់រូបទៅក្នុងវប្បធម៌ខ្មែរ* ។ ការរលាយទៅតាមក្បួនខ្នាតខ្មែរនេះ មិនមែនមានតែក្នុងជំនឿសាសនាទេ នៅក្នុងភាសា អក្សរសាស្ត្រ សិល្បៈតូច ធំ មានភ្លេង របាំ ស្ថាបត្យកម្ម ក៏ដូចគ្នាដែរ ។

១០. វត្តអារាមជាសារមន្ទីរនៃស្ថាបត្យកម្មខ្មែរ ។

សំណង់ក្នុងវត្ត ទោះបីសង់ក្នុងសម័យទំនើបហើយក្តី ក៏នៅតែរក្សាលក្ខណៈជាតិដែរ ។ គេគ្រាន់តែក្រឡេកមើលពីចម្ងាយ ក៏អាចស្គាល់បានភ្លាមថា នោះជាវត្តអារាម ដោយកំពូលដំបូលវិហារប្រកបដោយក្បូរក្បាច់រចនា មានជហ្វាដងក្តារ បែរកា ហោជាង ។ ល ។ ដោយសារស្ថាបត្យកម្មនោះជារបស់ខ្មែរ បានជាខ្មែរមានពាក្យសំរាប់សម្គាល់ចំណែកផ្សេងៗទាំងអស់នៃស្ថាបត្យកម្មនោះ ។ ពាក្យទាំងអស់នោះ ក៏រលុបបាត់ទៅដែរ នៅពេលដែលយើងលែងសង់សំណង់បែបបុរាណនោះ ។ មកដល់ពេលនេះ មានតែចាស់ៗដែលធ្លាប់បួសរៀននៅវត្តទេ ដែលអាចស្គាល់ពាក្យសម្គាល់ចំណែកផ្សេងៗនៃសំណង់ទាំងនោះ ។

ក្រៅពីព្រះវិហារ នៅមានសំណង់សំខាន់ៗដទៃទៀត ដែលប្រកបដោយលក្ខណៈជាតិដែរ ដូចជា ចេតិយ ប្រាង្គ ពុទ្ធបដិមា មេរុបូជាសព ជាដើម ។

ចំណុចទាំងអស់ខាងលើនេះ គឺជាធាតុនៃវប្បធម៌ខ្មែរ ។ ដោយសារវត្ត

មានលក្ខណៈជាច្រើនទាក់ទងដល់វប្បធម៌ជាតិ ដល់ចរិតលក្ខណៈរបស់ជាតិ ទើបវត្តមានតួនាទីមួយទៀតគឺ ជាតំណាងអត្តសញ្ញាណរបស់ជាតិ និងជាព្រលឹងនៃវប្បធម៌ជាតិ ។ មានវត្តអារាមនៅកន្លែងណា បញ្ជាក់ថា នៅកន្លែងនោះមានមនុស្សខ្មែរធ្លាប់រស់នៅ ។ ព្រោះវត្តអារាម ជារបស់ប្រជាជនខ្មែរ មានលក្ខណៈពិសេសរបស់ខ្លួនខុសប្លែកពីវត្តអារាមរបស់ជនជាតិដទៃ ។ វត្តជាភស្តុតាងបញ្ជាក់អំពីវត្តមាននៃប្រជាជនខ្មែរនៅកន្លែងជិតៗនោះ ។

នៅសម័យមហានគរ យើងមានប្រាសាទបុរាណ មានអង្គ មានព្រះធាតុ មានសិលាចារឹកដែលជាភស្តុតាងបញ្ជាក់ថា ប្រជាជនខ្មែរធ្លាប់បានរស់នៅលើទីណាខ្លះ ក្នុងឧបទ្វីបអាស៊ីអាគ្នេយ៍នេះ ។ ចាប់ពីសម័យកណ្តាល គឺវត្តអារាមដែលអាចបញ្ជាក់បន្ថែមទៀតទៅលើប្រាសាទបុរាណទាំងនោះ ។

វត្តអារាមជារបស់ប្រជារាស្ត្រខ្មែរ កសាងដោយប្រជារាស្ត្រខ្លួនឯង និងដើម្បីបំរើផលប្រយោជន៍របស់ប្រជារាស្ត្រខ្លួនឯង ។ ដូច្នេះ មានតែប្រជារាស្ត្រខ្មែរទេ ដែលជាអ្នកកំណត់ជោគវាសនារបស់វត្តអារាម ។

ក្នុងរយៈពេលពីរទសវត្សកន្លងទៅនេះ បុរាណស្ថាន ប្រាសាទបុរាណ និងវត្តអារាមស្ទើរតែទាំងអស់ ត្រូវទទួលរងគ្រោះមហន្តរាយដោយសារសង្គ្រាម និងរបបប្រល័យពូជសាសន៍ ធ្វើឱ្យបាត់អស់នូវភស្តុតាង ជាកេរដំណែលដូនតារបស់យើង ។ ការបំផ្លិចបំផ្លាញ គាស់កកាយ ជីករំលើងបុរាណស្ថាន ក៏បានន័យថា ជាការសម្លាប់ព្រលឹងជាតិ ។ ការបំផ្លាញវត្តអារាម ការដុតកំទេចគម្ពីរ ក្បួនខ្នាត ការប្រើប្រាស់ពាក្យពេចន៍ខុសក្បួនច្បាប់ ក៏ចាត់ថាជាការសម្លាប់ព្រលឹងជាតិដែរ ។

ឥឡូវនេះ ទោះបីសង្គ្រាម និងរបបប្រល័យពូជសាសន៍ បានកន្លងផុតទៅហើយក៏ដោយ តែផលវិបាករបស់វា នៅតែមានយ៉ាងធ្ងន់ធ្ងរមកលើវប្បធម៌ មកលើសតិបញ្ញាស្មារតី ធ្វើឱ្យជនជាតិខ្មែរគ្រប់រូប មានរបួសខាងផ្លូវចិត្តមិនអាចព្យាបាលឱ្យ

ជាសះស្បើយវិញក្នុងរយៈពេលដ៏ខ្លីបានឡើយ ដែលជាហេតុធ្វើឱ្យខ្មែរមានវិបល្លាសខាងសតិបញ្ញា វង្វេងនៅក្នុងភាពស្មុកស្មាញ ទន់ខ្សោយ, បាត់ជំនឿលើខ្លួនឯង ។ ប្រជាជនខ្មែរឥឡូវ មិនទាន់ចាប់យកព្រលឹងរបស់ខ្លួនដែលលស់ទៅនោះបានមកវិញនៅឡើយ ពោលគឺ កំពុងស្ថិតក្នុងភាព " លស់ព្រលឹងនៅឡើយ " ។

គួរឱ្យខ្មាសខ្លួនឯងណាស់ ដែលខ្មែរយើងពីបុរាណ ដូនតាយើងធ្លាប់តែជាគ្រូ គេធ្លាប់តែដាក់ទានឱ្យគេ ឥឡូវខ្មែរទ្រុឌទ្រោមក្លាយជាអ្នកសុំទានគេត្រូវទទួលឱវាទពីគេ ត្រូវគេមើលងាយ ព្រោះខ្មែរខ្សោយ ខ្មែរមិនខ្លាំងដូចពីបុរាណ ។

## III យើងធ្វើឱ្យវត្តអារាមក្លាយជាមជ្ឈមណ្ឌលវប្បធម៌ឡើងវិញ

ហេតុនេះ ដើម្បីឱ្យព្រលឹងខ្មែរ ( រស់មកវិញ ) ចូលមកសណ្ឋិតក្នុងរូបរាងកាយរបស់ខ្មែរវិញ ប្រជាជាតិខ្មែរ ត្រូវរួមចំណែកស្វែងរកព្រលឹងនោះគ្រប់ៗគ្នា ។ ជាមួយនឹងការកសាងវត្តអារាមខាងសម្ភារះរបស់ពុទ្ធបរិស័ទ ព្រះសង្ឃក៏មានភារកិច្ចយ៉ាងសំខាន់ដែរ នោះគឺការថែរក្សាវប្បធម៌ខ្មែរ ការបំប៉នពូនជ្រំឱ្យវប្បធម៌រីកចំរើនល្អូតលាស់ឡើងវិញ ឱ្យស្មារតីជាតិ ស្មារតីច្នៃប្រឌិតរបស់ខ្មែររស់ឡើងវិញទប់ទល់នឹងអប្បិយជំនឿ ទប់ទល់នឹងការឈ្លានពាន និងឥទ្ធិពលនៃវប្បធម៌បរទេសឱ្យបាន ។ ត្រូវខិតខំលើកតម្កើង និងឱ្យតម្លៃ ឱ្យសារសំខាន់ដល់វប្បធម៌ខ្មែរ ។ ចំពោះមុខ វត្តអារាមណាដែលបានស្តារឡើងវិញរួច គប្បីប្រែក្លាយឱ្យទៅមជ្ឈ-មណ្ឌលវប្បធម៌ជាតិ ឱ្យបានដូចពីបុរាណកាល ។

ក្នុងការអនុវត្តន៍ជាក់ស្តែង ការស្តារតួនាទីរបស់វត្តឱ្យដូចពីបុរាណត្រូវធ្វើទៅតាមលទ្ធភាព និងស្ថានភាពជាក់ស្តែងរបស់មូលដ្ឋាននីមួយៗផង ព្រមទាំងសមស្រប ទៅនឹងការរីកចំរើនរបស់សង្គមផង ។

ប៉ុន្តែ វត្តគប្បីចាប់អារម្មណ៍ដល់ការងារសំខាន់ ដូចខាងក្រោម :

១. ការសាងសង់សំណង់ថ្មី ត្រូវតែរក្សាឱ្យបាននូវលក្ខណៈចរិតវប្បធម៌ខ្មែរខាងស្ថាបត្យកម្ម ។ ការតុបតែងលំអរ ក៏ត្រូវតែគោរពតាមក្បួនខ្នាតនៃសិល្បៈខ្មែរ ។

២ . ស្ថាបត្យកម្មសំណង់ចាស់ក្នុងវត្តអារាម ត្រូវតែខំរក្សាទុកឱ្យបានល្អ ។ ការជួសជុលត្រូវធ្វើដោយប្រយ័ត្នប្រយែង កុំឱ្យប៉ះពាល់ដល់សោភ័ណសិល្បៈស្ថាបត្យកម្មបុរាណ ។ បើចាំបាច់ត្រូវរុះរើនោះ គប្បីរក្សាបំណែកសិល្បៈទាំងឡាយទុកធ្វើជាគំរូ ។

៣ . ត្រូវខិតខំដាំដើមឈើល្អៗ ឈើកម្រៗ ឈើប្រើជាថ្នាំសង្កូវ ឈើហូបផ្លែ ឈើលំអរសួន ឈើយកស្លឹក ( ម្លប់ ) ។

៤ . ត្រូវជីកស្រះធំៗ យកទឹកប្រើប្រាស់ ស្រោចស្រពដំណាំ យកទឹកជាជម្រកមច្ឆជាតិ ។ បក្សាបក្សីខ្លះ រស់ដោយសារមច្ឆជាតិ ក៏អាចវិលមកនៅក្នុងវត្តវិញ ។

៥ . ខិតខំបង្កើតសាលារៀន ឬខិតខំបង្រៀនសង្ឃខ្ចីវស្សា ឱ្យចេះធម៌អាថ៌ ចេះភាសាខ្មែរ ភាសាបាលី ចេះសរសេរ ចេះលេខនព្វន្ត ។

៦ . បង្កើតឱ្យមានទូសៀវភៅ បណ្ណាល័យ សំរាប់ព្រះសង្ឃផង និងសំរាប់ប្រជាជនរៀនសូត្រផង ។

៧ . វត្តនីមួយៗ គប្បីបង្រៀនមុខវិជ្ជាជំនាញ ត្រូវមានរោងជាងរបស់វត្ត ដូចជា ជាងឈើ តុ កៅអី ទ្រែ ឬ សិប្បកម្ម ល្អី កញ្ជើ ... ខ្សែវល្លិ ឬសិល្បៈសូន្យរូប មានចម្លាក់ គំនូរបុរាណជាដើម ។ វត្តរួមចំណែកអប់រំកូនចៅខ្មែរឱ្យមានលក្ខណៈពេញលេញជាពលរដ្ឋដ៏ល្អ ដែលអាចប្រកបមុខរបរចិញ្ចឹមជីវិតដោយខ្លួនឯងបាន ។ វត្តក៏អាចមានលទ្ធភាពធ្វើឱ្យអ្នកដែលរៀននៅសាលាវត្ត មានសមត្ថភាព ដូចជាសាលារៀនរយសាធារណៈដែរ ។ លើសពីនេះទៀត អ្នករៀនសាលាវត្ត អាចមាន

សមត្ថភាពខ្ពស់ជាងការអប់រំសីលធម៌ និងអក្សរសាស្ត្រ ។ ដូច្នេះ សិស្សសាលាវត្ត ជាមនុស្សដែលមានគុណភាពខាងសីលធម៌ផង មានសមត្ថភាពខាងវិជ្ជាជីវៈផង និងខាងវប្បធម៌ អក្សរសាស្ត្រផង ។

បើធ្វើបានយ៉ាងនេះ នោះវត្តអារាមរបស់យើង ប្រាកដជាបំពេញបាន នូវភារកិច្ចដែលវត្តធ្លាប់មានពីបុរាណមក ជាមិនខានឡើយ ។

ស្រាវជ្រាវដោយ **ឃី ធន់**
ភ្នំពេញ, ថ្ងៃទី ២០ ខែសីហា ឆ្នាំ ១៩៩៤

មនុស្សពាលដែលដឹងខ្លួនថាពាល ចាត់ទុកថាជាបណ្ឌិត
ប៉ុន្តែ មនុស្សពាលដែលសំគាល់ខ្លួនថាជាបណ្ឌិត
មនុស្សពាលបែបនេះ លោកហៅថា ពាលពិត ។

(ចាកធម្មបទ . ពាលវគ្គ )

# បុណ្យមហាអំបុក
## ( តាមទំនៀមរបស់ប្រជាជន នៅខេត្តតាកែវ )

ពិតមែនតែបុណ្យមហាអំបុកនេះ មិនត្រូវបានមហាជនខ្មែរអនុវត្តនៅទូទាំងប្រទេសក៏ពិតមែន ក៏ប៉ុន្តែបុណ្យនេះមានសភាពអធិកអធម គគ្រឹកគគ្រេងណាស់ នៅខេត្តខ្លះៗ ប៉ែកខាងត្បូងនៃប្រទេសយើង មានខេត្តតាកែវ ជាដើម ។ ទោះបីយ៉ាងណាក៏ដោយ ក៏បងប្អូនខ្មែរដែលបានបង្កើតបុណ្យនេះឡើង គឺដើម្បីញ៉ាំងពិធីបុណ្យអកអំបុកឱ្យកាន់តែមានលក្ខណៈពិសេសឡើងតែប៉ុណ្ណោះ ព្រោះគេធ្វើបុណ្យមហាអំបុកនៅចំថ្ងៃ ១៥ កើត ខែកត្តិក ( ពេញបូណ៌ ) គឺជាកាលបរិច្ឆេទរួមជាមួយគ្នានឹងថ្ងៃបុណ្យអកអំបុក សំពះព្រះខែផងដែរ ។ ប្រការដែលគួរកត់សំគាល់នោះ គឺគេមិនចាត់ចែងធ្វើបុណ្យនេះគ្រប់ៗវត្ត ដែលស្ថិតនៅជិតខាងគ្នាទេ គឺថា បើឆ្នាំនេះវត្ត « ក » ធ្វើ វត្ត « ខ - គ - ឃ » ដែលនៅជិតខាងនោះត្រូវផ្អាក ដើម្បីប្រមូលមនុស្សឱ្យចូលរួមជួបជុំគ្នាបានច្រើនកុះករ ជាហេតុធ្វើឱ្យពិធីបុណ្យមានភាពឧឡារិក អធិកអធមផង និងផ្តល់កិត្តិយសដល់វត្ត ដល់អ្នកដឹកនាំ និងអ្នកចូលរួមអនុវត្តផង ។ ហើយនៅឆ្នាំក្រោយៗ វត្តផ្សេងៗទៀត នឹងផ្លាស់វេនគ្នាធ្វើបុណ្យនេះទាល់តែបានគ្រប់ៗវត្ត ទើបសារដើមមកវិញ ។ តាមការផ្តល់ពត៌មានរបស់ចាស់ៗ នៅតំបន់នោះបានឱ្យដឹងថា ពិធីបុណ្យមហាអំបុកនេះធ្លាប់បានធ្វើតៗគ្នាមកជាច្រើនជំនាន់មនុស្សមកហើយ ។ យើងឆ្ងល់ដែរថា ហេតុអ្វីក៏មានពិធីបុណ្យមហាអំបុកនេះ នៅចំពេលជាមួយគ្នានឹងបុណ្យអកអំបុក និងសំពះព្រះខែ ? ឆ្លើយតបនឹងចម្ងល់នេះ ចាស់ៗ នៅខេត្តតាកែវ [១] ភាគខាងត្បូងមួយចំនួន

(១) បណ្តាវត្តនានា ក្នុងឃុំព្រៃអំពក ឃុំតាអូន ស្រុកគីរីវង្ស ខេត្តតាកែវ

បានឆ្លើយឱ្យការណ៍ថា ៖ បុណ្យអកអំបុក ឬពិធីអកអំបុក គឺជាពិធីមួយដែលធ្វើឡើងក្រោយពីគេមានអំបុកសំរាប់អករួចហើយ ។ ចាស់បុរាណមិនចូលចិត្តបង្ហាញនូវឆាកអ្វី, ទស្សនីយភាពអ្វី ឬសកម្មភាពអ្វី នៅកណ្តាលរឿង ឬចុងរឿងឡើយ ។ បំណងគាត់ គឺចង់បង្ហាញឱ្យដឹងអំពីដើមរឿងផង ដើម្បីឱ្យសាច់រឿងវាជាប់គ្នាជាខ្សែសង្វាក់តាំងពីដើមដល់ចប់ ។ ដូច្នេះ ក្នុងពិធីបុណ្យមហាអំបុកនេះ ចាស់បុរាណលោកចង់បង្ហាញឱ្យយើងឃើញថា ៖ តើគេបានអំបុកពីណាយកមកអក ? ហើយតើគេដាល់អំបុកដូចម្តេចខ្លះ ? ខ្មែរទូទាំងប្រទេសធ្លាប់ស្គាល់អំបុកគ្រប់ៗ គ្នា មិនដឹងជាប៉ុន្មានពាន់ ឬប៉ុន្មានរយឆ្នាំមកហើយទេ ។ បើគេស្គាល់អំបុក វាច្បាស់ណាស់ថា គេចេះដាល់អំបុកហើយ ។ ក្មេងៗខ្មែរប្រុស ស្រី ធ្លាប់បានចូលរួមក្នុងការដាល់អំបុកនេះ ជាលក្ខណៈគ្រួសារ ឬឯកជនដោយចាប់ផ្តើមដើរតួនាទីជាអ្នកលីងអំបុក ។ ការដាល់អំបុកជាលក្ខណៈឯកជន ឬជាលក្ខណៈគ្រួសារនោះ វាសាមញ្ញពេកណាស់ហើយក៏គ្មានអ្វីគួរចាប់អារម្មណ៍ផងទេ ។ គំនិតផ្តួចផ្តើមថ្មីមួយទៀតរបស់ចាស់ៗ ជំនាន់មុន គឺលោកបានគិតកែច្នៃការដាល់អំបុកនេះឱ្យមានលក្ខណៈជាទស្សនីភាពមួយ ជាទម្រង់សិល្បៈមួយគួរជាទីចាប់អារម្មណ៍ និងគួរឱ្យចង់ទស្សនា ដែលខ្ញុំនឹងពណ៌នាជូនដូចតទៅនេះ ។ ប៉ុន្មានថ្ងៃមុនពិធីមហាអំបុក អាចារ្យវត្ត និងចាស់ព្រឹទ្ធាចារ្យក្នុងស្រុកមានការយ៉ាងមមាញឹក ដើម្បីត្រៀមលក្ខណៈឱ្យបានល្អ ។ គេត្រូវចាត់តាំងអ្នកដាល់, ដោយមានកម្លាំងត្រៀមជំនួយ ៤ ឬ ៥ នាក់, អ្នកលីងដែលអាចមាន ២ ឬ ៣ នាក់ ក្នុងមួយក្រុមៗ ។ គេចាត់តាំងអ្នកដើរប្រមូលត្បាល់ អង្រែ ដើររកអំបែងធ្វើឈើឆ្កៀលត្រៀមទុកជាមុនឱ្យស្រេច ។ ធម្មតាបុណ្យមហាអំបុក គេត្រូវមានត្បាល់ពី ៣០ ទៅ ៥០ ដើម្បីញ៉ាំងពិធីនេះឱ្យមានភាពឧឡារិក ។ ដូច្នេះ គេក៏ត្រៀមមនុស្ស ៣០ ឬ ៥០ ក្រុមដើម្បីចូលរួមក្នុងពិធីនេះដែរ ។ នៅថ្ងៃបុណ្យ

សម្ភារៈគ្រប់ប្រភេទ [១] ដែលត្រូវការចាំបាច់ក្នុងពិធី ត្រូវបានដឹកជញ្ជូនយកទៅដាក់ឯវត្តជាស្រេចតាំងពីថ្ងៃរសៀលម្ល៉េះ ។ នៅពេលព្រលប់ប្រមាណម៉ោង ៦ កន្លះ អ្នកចាត់ចែងបុណ្យបានបង្គាប់ឱ្យក្រុមដាល់អំបុកនីមួយៗ តម្រៀបត្បាល់ ចង្រ្កានជាជួរយ៉ាងត្រង់ ហើយវែង ទៅតាមចំនួនត្បាល់ដែលអាចមាន ។ ដំបូងឡើងអ្នកបញ្ជាការ បានបង្គាប់ឱ្យគ្រប់ក្រុមបង្កាត់ភ្លើង ដាំអំបែងឱ្យបានក្តៅស្មើៗគ្នាមុនចាប់ផ្តើមពិធី ។ នៅពេលពិធីមហាអំបុកចាប់ផ្តើមសកម្មភាព, គេសន្មតគ្នាយកសំឡេងគងជាសញ្ញាបញ្ជា ។ លុះឃើញថា អំបែងគ្រប់ក្រុមមានកំដៅល្មមហើយ គេគោះគងមួយអន្លូងជាសញ្ញា ប្រាប់ឱ្យចាក់ស្រូវទៅក្នុងអំបែង ។ អ្នកលីងបានវាសវីឈើលីងទៅលើគ្រាប់ស្រូវក្នុងអំបែងទៅតាមបច្ចេកទេស ឬបទពិសោធន៍របស់ខ្លួន ។ លុះប៉ាន់ស្មានដឹងថា ស្រូវលីងនោះឆ្អិន ( ដោយគ្រាប់ស្រូវចាប់ផ្ទុះប្រែសៗ ជាបន្តបន្ទាប់ ) ហើយនោះ, ស្គរគងអន្លូងទីពីរបានបន្លឺឡើងជាសញ្ញា ប្រាប់ថា ឱ្យអ្នកលីងលើកអំបែងចាក់ស្រូវលីងឆ្អិនល្មមនោះទៅក្នុងត្បាល់ [២] ព្រមគ្នា ។ បន្ទាប់ពីនោះភ្លាម, ស្គរអង្រៃបានបញ្ចេញសន្ធឹកយ៉ាងកក្រើកដី ។ អ្នកដាល់អំបុកគ្រប់ក្រុមបានបុក និងឆ្កៀលយ៉ាងញាប់ដៃ ដើម្បីលៃយ៉ាងណាឱ្យអំបុករបស់ខ្លួនមានគុណភាពល្អ ។ នៅពេលនេះ ទស្សនិកជនរាប់ពាន់នាក់មកឈរចោមរោមមើលទស្សនីយ-

---

(១) សម្ភារៈសំរាប់ដាល់អំបុកមាន ៖ ត្បាល់, អង្រែ, អំបែង, ឈើឆ្កៀល (ឆ្កៀល) ឧសចង្ក្រាន ស្រូវដំណើបទុំស្ទើរ ឈើលីង ( ឈើលីងនេះគេច្រើនយកឫស្សី ១ កំណាត់ សំរួចហើយដោតស្លួលពោតទុំនៅខាងចុង, គេលីងអំបុក ដោយយកឈើលីងដែលដោតស្លួលពោតនេះ គ្រវីគ្រវាសទៅលើគ្រាប់ស្រូវក្នុងអំបែង ដើម្បីឱ្យឆ្អិនសព្វ ។ ក្នុងករណីទាល់ច្រក គេយកធាងល្ហុងធ្វើជាឈើលីងក៏បាន ។ (២) អ្នកចាត់ចែងពិធី ចង់បានសកម្មភាពនីមួយៗ នៃការដាល់អំបុក ( ជាទ្រង់ទ្រាយធំនេះ ) ប្រព្រឹត្តទៅឱ្យបានស្រុះៗគ្នា ចៀសវាងភាពរកេតរក្លូតមុនក្រោយ ។

ភាពនេះយ៉ាងសប្បាយព្រឺព្រួច ដោយឃើញត្បាល់ អំបែង ចង្ក្រានតម្រៀបគ្នា យ៉ាងត្រង់, ដោយឃើញចង្កៀងគោម ឬចង្កៀងម៉ាំងសុងជះពន្លឺព្រោងព្រាត ដើម្បីបំភ្លឺអ្នកដាល់អំបុក និងទស្សនិកជន ។ គេរំភើបរីករាយដោយឃើញចលនាស្ត្រីអ្នកដាល់អំបុក (១) មានរូបរាងស្អាតបាត ប្រដាប់ដោយសម្លៀកបំពាក់សំរាប់ថ្ងៃបុណ្យ ធ្វើកាយវិការលើកអង្រែបុកអំបុកយ៉ាងទន់ភ្លន់ ..... ។ មិនយូរប៉ុន្មាន ស្នូរគងទី៣ បានបន្លឺឡើង ( ម្នូង ! ) ជាសញ្ញាប្រាប់ឱ្យអ្នកដាល់អំបុកកាយអំបុកដាក់កញ្ជើ ។ រួចសំឡេងគង ក៏បានបន្លឺជាសញ្ញាឱ្យចាក់ស្រូវទៅក្នុងអំបែង ដើម្បីលីងជាបន្តទៀត ។ សកម្មភាពនេះ ប្រព្រឹត្តឡើងក្នុងចលនាដដែលៗ (២) ទាល់តែអស់ស្រូវមួយតៅ ទើបត្រូវបញ្ចប់ការដាល់អំបុកជាសមូហភាពនេះ ។ គេអាចប៉ាន់ស្មានបានថា តាំងពីពេលចាប់ផ្ដើមរហូតដល់ពេលបញ្ចប់នៃពិធីដាល់អំបុក អាចមានថេរះវេលា ពី ៤ ទៅ ៥ ម៉ោង ។ អ្នកផងធ្លាប់បានដឹងហើយថា ពិធីអកអំបុកត្រូវប្រព្រឹត្តធ្វើនៅពេលខែត្រង់ គឺពេលដែលព្រះច័ន្ទគោចរមកចំពីលើក្បាល ។ ដូច្នេះ នៅពេលដាល់អំបុកបានចប់ហើយ គេចាត់ចែងអុំអំបុកជាបន្ទាន់ ដោយគេបានត្រៀមចង្អេរ ៣ ឬ ៤ ក្នុងមួយក្រុមៗ សំរាប់អុំអំបុកឱ្យបានឆាប់ទាន់ពេលវេលាដែលលោកអាចារ្យបានគ្រោងទុកក្នុងកម្មវិធី ។

សូមជំរាបផងដែរថា ការអុំអំបុកនេះ ពុំមានធ្វើឡើងតាមសង្វាក់ស្នូរគង

---

(១) ជ្រើសរើសយកតែស្រីក្រមុំដែលមានរូបស្អាតៗ ហើយស្ទាត់ជំនាញខាងការដាល់អំបុក ។

(២) សំឡេងគងជាសញ្ញាបញ្ជានោះ គឺ : ស្នូរទី ១ ឱ្យចាក់ស្រូវទៅក្នុងអំបែង, ស្នូរទី២ ឱ្យលើកស្រូវពីអំបែងចាក់ទៅក្នុងត្បាល់, ស្នូរទី ៣ ឱ្យកាយអំបុកពីត្បាល់ដាក់កញ្ជើ រួចវិលមកស្នូរគងជាបន្តបន្ទាប់ឱ្យចាក់ស្រូវលីង ឱ្យចាក់ស្រូវទៅក្នុងត្បាល់ ឱ្យកាយអំបុក វិលទៅវិលមកយ៉ាងនេះរហូតដល់ឈប់ដាល់ ។

ដូចជាការចាក់ស្រូវក្នុងអំបែង ការចាក់ស្រូវក្នុងត្បាល់ ឬការបញ្ឈប់ការបុកអំបុកនោះឡើយ គឺគេអុំដោយសេរី ធ្វើយ៉ាងណាឱ្យក្រុមរបស់ខ្លួនផលិតបានអំបុក ដែលមានគុណភាពល្អ (១) ។ ការអុំអំបុកនេះ អាចធ្វើហើយស្រេចតែក្នុងរយៈពេលកន្លះម៉ោងប៉ុណ្ណោះ ។ តាមការប្រកាសរបស់លោកអាចារ្យ, អំបុកអុំស្រេចត្រូវបានដាក់ក្នុងកញ្ជើ ហើយត្រូវបានបែងចែកជាពីរផ្នែក :

- មួយផ្នែក សំរាប់ទុកប្រគេនលោក នៅព្រឹកថ្ងៃស្អែក,
- មួយផ្នែកទៀត សំរាប់បំរើដល់ការអកអំបុក (២) ។

ការដាល់អំបុកដោយគោរពយ៉ាងម៉ឺងម៉ាត់ទៅតាមសង្វាក់ តាមបញ្ជាបែបនេះ ពិតជាពុំសូវមានគុណភាពល្អឥតខ្ចោះដូចគេដាល់អំបុកឯកជន ដែលគេមានពេលលើង បុកអំបុកដោយសេរី និងដោយការប្រិតប្រៀង ផ្ចិតផ្ចង់ត្រឹមត្រូវនោះឡើយ ព្រោះក្រុមខ្លះ អំបុកមិនទាន់ឆ្អិនស្រួលបួលផង តែត្រូវគោរពតាមសំឡេងគងបញ្ជាក៏ត្រូវលើកចាក់ទៅក្នុងត្បាល់ឱ្យគេបុក ។ ជួនកាលក្រុមខ្លះទៀត ស្រូវក្នុងអំបែងផ្ទុះអស់ជិត ៥០ % ទៅហើយ ទើបត្រូវលើកអំបែងចាក់ទៅក្នុងត្បាល់ឱ្យគេបុក ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ប្រសិនបើយើងមិនបានគុណភាពអំបុក ១០០ % ក៏យើងបានល្បែងកំសាន្តមួយ បានទស្សនីយភាពមួយ បានចលនារួមមួយស្រុះស្រៀចរំភើបរីករាយ តាំងពីក្បាលព្រលប់រហូតដល់ខែត្រង់ ។ នេះក៏ជាឱកាសមួយ ដែលក្រមុំស្រុកស្រែ ពិសេសនៅភាគខាងត្បូងនៃខេត្រតាកែវ មានឱកាសបានបង្ហាញ

---

(១) អំបុកដែលមានគុណភាពល្អ គឺគ្មានលាយស្រូវ, សំប៉ែតស្តើង, ឥតមានក្តាំង ។

(២) អក = ច្រកចំណីអ្វីដែលស្ងួត ដែលម៉ដ្ឋទៅក្នុងមាត់ ឧ. អកអំបុក, អកប្រហុល, អកអង្ករលីង, អកពោតលីង ជាធម្មតា អំបុកសំរាប់អក មិនសូវជាមានគុណភាពល្អប៉ុន្មានទេ ព្រោះគេលៃឱ្យតែត្រូវតាមចង្វាក់សញ្ញាបញ្ជារបស់គង ម្ល៉ោះហើយអំបុកអាចឆៅ អាចលាយស្រូវ ឬអាចមានក្តាំង ។

រូបរាង បានបង្ហាញកាយវិការ បានបង្ហាញភាពប៉ិនប្រសប់របស់ខ្លួនចំពោះកម្លោះៗស្រុកស្រែដែរ ។ ហើយនេះជាឱកាសមួយដ៏ល្អផងដែរ ចំពោះកម្លោះៗ ដែលចង់ជ្រើសរើសប្រពន្ធមួយមានរូបរាងស្រស់បស់ស្អាតប្រិមប្រិយ, ទន់ភ្លន់, រវៀសរវៃ, ប៉ិនប្រសប់ក្នុងការងារ, ចូលចុះក្នុងជំនុំចំណោម ។ ដូច្នេះ ជាមួយនឹងពិធីមួយដែលធ្វើតាមដំណែលចាស់បុរាណ តជាប្រពៃណីនេះ ក៏ជាឱកាសមួយបង្កលក្ខណៈឱ្យយុវជន យុវនារីខ្មែរនៅជនបទ មាននឱកាសនឹងជួបប្រាស្រ័យទាក់ទងគ្នា ស្វែងយល់ចិត្តគ្នាទៅវិញទៅមក បន្ទាប់ពីបានបញ្ចប់ការងារធ្វើស្រែចំការអស់មួយរដូវរួចមក ។

## ពិធីអកអំបុក

មហាអំបុកត្រូវបញ្ចប់ត្រឹមអុំអំបុកដាក់ក្នុងកញ្ជើ ត្រៀមមួយផ្នែកទុកប្រគេនលោកនៅព្រឹកស្អែក និងមួយផ្នែកទៀត ទុកសំរាប់ចាត់ចែងក្នុងពិធីអកអំបុក ។ គេបានយកអំបុក ដែលបានត្រៀមទុកនោះដាក់ក្នុងកញ្ជើមួយដោយឡែកតម្កល់លើតុតាមក្រុមដាល់អំបុក ដែលបានធ្វើសមយុទ្ធហើយថ្មីៗមកនេះ ។ នៅលើតុនេះដែរ ហើយនៅក្បែរៗកញ្ជើអំបុក ចេកទុំច្រើនប្រភេទ និងច្រើនស្និត បានត្រូវត្រៀមទុកជាស្រេចដែរ ។ លោកអាចារ្យ បានប្រកូកប្រកាសឱ្យប្រុសៗ កម្លោះៗចូលមកអកអំបុកនៅតាមតុ តាមក្រុមដែលបានតម្រៀបគ្នាហូរហែជាជួរ បំភ្លឺដោយចង្កៀងគោម ឬម៉ាំងសុងដ៏គួរឱ្យសប្បាយរីករាយ ។ ស្រីម្នាក់ចាប់សក់បុរសភ្ញើយហើយបង្គាប់ឱ្យប្រុសនោះហាមាត់ឱ្យធំ ។ ស្រីម្នាក់ទៀតក្តាប់អំបុក ហើយបង្ហូរអំបុក[១] ទៅក្នុងមាត់ប្រុសនោះ ។ គេបង្អកដូច្នេះ ម្តងហើយម្តងទៀត ដោយសួរថា « ពេញឬនៅ ? » អ្នកត្រូវគេបង្អក មិនទាន់ឆ្លើយស្រួលបួលផង ក៏ត្រូវគេបង្អក

(១) បង្អក ឬបញ្ច្រកអំបុកទៅក្នុងមាត់

បន្ថែមទៀត ទាល់តែឆ្លើយចេញមកទាំងឡូល១ មិនច្បាស់ថា « ពេញហើយ ! » ។ បន្ទាប់ពីបង្អកអំបុកហើយ គេបង្អកចេកទៀត ដោយចាប់ញាត់ឱ្យតែខាងឈ្នះដៃ ។ ប្រុសអ្នកអកអំបុក មើលពីខាងក្រៅ ហាក់ដូចបានទទួលនូវទារុណកម្មមួយ ព្រោះត្រូវគេបង្អកអំបុកពេញមាត់ហើយ ត្រូវគេញាត់ចេកទាំងមូលថែមទៀត ធ្វើឱ្យមាត់គេពេញហួសពីពេញ គឺដល់ថ្នាក់ « ហៀរ » ។ និយាយក៏មិនរួច ទំពារក៏មិនកើតយ៉ាងនេះហើយនៅត្រូវគេគក់ខ្នងឮស្ទូ « ឱប១ » ដោយសួរថា «ពេញឬនៅ ?» ។ លុះឆ្លើយដោយមិនច្បាស់ថា « ពេញហើយ ! » ស្រី១ ក៏សួរទៀតថា ៖ ឆ្នាំក្រោយភ្លៀងល្អ ឬទេ ? ឬសួរសង្ខេបខ្លីថា ៖ «ភ្លៀង ឬមិនភ្លៀង» អ្នកអកឆ្លើយមិនច្បាស់ « ឡូល១ » ថា « ភ្លៀង ! » ។ ក្រុមណាក៏អកតាមរបៀបនេះ គឺស្រី១បង្អកអំបុកប្រុស១ ។ ព្រមជាមួយចលនាអកអំបុកជាទ្រង់ទ្រាយធំ ដូចមហាអំបុកដែរនេះគេឃើញសកម្មភាពមួយ គឺ ៖ កសិករខ្មែរនៅស្រុកស្រែ បានឱកាសជួបគ្នា កម្លោះជួបក្រមុំ ។ គេបានសម្តែងការស្និទ្ធស្នាលជាមួយគ្នា តាមការអនុគ្រោះរបស់ប្រពៃណី នៅក្រោមក្រសែភ្នែកចាស់១ ជាឪពុកម្តាយរបស់កម្លោះ និងក្រមុំ ។ អត្ថន័យម្យ៉ាងទៀត គឺក្នុងពិធីមហាអំបុក អកអំបុកនេះ ទាំងអស់គ្នាបានបង្ហាញអំពីសាមគ្គីភាពជិតស្និទ្ធក្រោមការដឹកនាំរបស់បញ្ញាការម្នាក់ គឺចាស់ស្រុក ។ អ្នកអនុវត្តគោរពបទបញ្ជារបស់មេកោយយ៉ាងសស្រាក់សស្រាំ ធ្វើឱ្យពិធីនេះទទួលបានជោគជ័យ ។ ពេលអកអំបុកទៀតសោត គេឃើញអំបុកពេញ១កញ្ជើ ចេកគ្រប់មុខរៀបចំពោរពាសឈើតុ ។ គេឃើញម្យ៉ាងទៀត នៅពេលបង្អក និងពេលអកអំបុកនិងចេកកំពប់(១) ធ្លាក់រពោងរពាយមកលើដី ជាការបកស្រាយនូវភាពសម្បូរ

(១) ក្នុងពេលនោះ, គេមិនអាចចៀសផុតពីការកំពប់ខ្ចាយខ្លះបានឡើយ ។ ត្រង់នេះមិនបញ្ជាក់ថា ខ្មែរមិនចេះសន្សំសំចៃទេ ប៉ុន្តែគ្រាន់តែបង្ហាញថា ជីវភាពរបស់ប្រជារាស្ត្រខ្មែរពីបុរាណ សម្បូរសប្បាយណាស់ ។

ហូរហៀរបស់ស្រុកទេសយើងពីបុរាណ ។

និយាយរឿងមហាអំបុក អកអំបុកក្នុងពេលនោះ ហាក់បីដូចជានិយាយពីសុបិនមួយដូច្នេះឯង ។ ព្រោះសព្វថ្ងៃនេះ ពិធីមហាអំបុកក្តី - អកអំបុកក្តី មានតែនៅលើឯកសារ ដែលចាស់ៗជំនាន់មុនធ្លាប់បានធ្លងកាត់ ហើយបានសរសេរចងក្រងទុកកុំឱ្យបាត់ដំណែល ចំណែកឯការអនុវត្តវិញ មិនសូវមានដូចកាលពីបុរាណទេ ។ សម្រាប់ក្មេងៗជំនាន់នេះវិញ ជួនកាលគេស្តាប់ឮរឿងនេះ ដូចជារឿងព្រេងនិទានដែលគេចង់ជឿបន្តិច សង្ស័យបន្តិច ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ចាស់ៗដែលមានអាយុលើសពី ៦០ ឆ្នាំ នៅខេត្តតាកែវ បានដឹង បានឮ ហើយអាចបញ្ជាក់ច្បាស់ថា នេះគឺជារឿងពិត នឹងជាប្រពៃណីមួយរបស់ប្រជាជនខ្មែរ តាំងពីបុរាណមក ។

ដោយ **មៀច ប៉ុណ្ណ**
ប្រធានការិយាល័យក្រុមជំនុំទំនៀមទម្លាប់ខ្មែរ
នៃ ពុទ្ធសាសនបណ្ឌិត្យ

# ពុទ្ធកិច្ច ៥ យ៉ាង

( បទព្រហ្មគីតិ )

ព្រះពុទ្ធទ្រង់សម្រេច កិច្ចចាំបាច់ទាំងប្រាំយ៉ាង
មួយពេលព្រឹកភ្លឺស្វាង ស្ដេចទ្រង់យាងបិណ្ឌបាត ។
ពីរទ្រង់សម្ដែងធម៌ ជ្រាបរវរខំសង្វាត
ពេលល្ងាចមិនឱ្យខាត សម្ដែងធម៌ពិរោះក្រៃ ។
បីនៅពេលព្រលប់ ព្រះចោមភពសម្ពុទ្ធថ្លៃ
ប្រទានឱវាទនៃ ដល់ភិក្ខុផងទាំងឡាយ ។
បួនក្នុងពេលអធ្រាត្រ ព្រះលោកនាថទ្រង់បកស្រាយ
ដោះប្រស្នាទាំងឡាយ នៃទេវតាដែលជំពាក់ ។
ប្រាំទ្រង់ពិចារណា មើលសត្តាគ្រប់ជាន់ថ្នាក់
ឧបនិស្ស័យជាក់ នៃសត្វដែលគួរត្រាស់ដឹង ។
និងសត្វដែលមិនគួរ សត្វអួរមួរគ្មានពំនឹង
មិនគួរនឹងត្រាស់ដឹង ក្នុងវេលាគ្រាជិតភ្លឺ ។

ចងជាកាព្យដោយ

**ង៉ាយ ចិបុល**

# កំណាព្យ

បទពាក្យ ៧

# ឆ្កួត ៨ យ៉ាង

លោកិយយើងនេះពិបាកណាស់
ទោះក្មេងឬចាស់កើតរោគា
ជួនភ្លេចសតិស្មើរលេលា
មិនសូវមានជាច្រើនគគោក ។
* ខ្លះជា *កម្មុម្មត្តកោ*
ចិត្តចើងធំប៉ោដោយរាគរោគ
កើតឆ្កួតព្រោះអំពើស្មោកគ្រោក
ដ្បិតអីសត្វលោកនេះមានកម្ម ។
កម្មទាញឱ្យឈ្លក់ក្នុងកាមា
វក់តាមតណ្ហាជាប្រចាំ
ស្រវឹងក្នុងកាមគុណទាំងប្រាំ
គឺកម្មនាំឱ្យឆ្កួតលេលា ។
ប្រុសខ្លះឆ្កួតស្រីកើតក្បត់ចិត្ត
ហ៊ានប្រព្រឹត្តផិតនឹងភរិយា
ត្រូវវ៉ូវស្រីស្នេហ៍កាត់រកគ្នា
នេះហៅលេលាគឺឆ្កួតស្រី ។
ឯស្រី១ខ្លះក៏ហ៊ានផិត
ប្រព្រឹត្តក្បត់ចិត្តនឹងស្វាមី
ជួបប្រុសពេញចិត្តល្បួងបេតី
ផិតឆ្កួតក្បត់ប្តីដោយរាគា ។
* *កោធុម្មត្តកោ* ឆ្កួតទីពីរ
ឆ្កួតវិលវកវីព្រោះក្រោធា
បណ្តោយឱ្យចិត្តឆ្កួតឥតជា
ខឹងគេគ្រប់គ្នាជេរមិនឈប់ ។
ទាស់ចិត្តប្រពន្ធជេរបញ្ចោរ
ដោយក្តីទោសោស្រវឹងជ្រប់
ពៃទើសមុខហើយឥតធមិទប់
ខន្តីទំនប់មិនកាន់យក ។
បណ្តោយឱ្យចិត្តអសុរ[១] ចូល
ជេរដៀលត្រកូលឥតគិតភ្នក
ខឹងកូនខឹងចៅជេរតំហាក
ញាតិមិនរាប់រកព្រោះគេខ្លាច ។

(១) អានថា អសុល ។

ដ្បិតអីអ្នកឆ្កួតដោយកំហឹង ឱ្យតែកើតខឹងប្រើអំណាច
ជនឆ្កួតពួកនេះចិត្តកោងកាច នាំឱ្យគេខ្លាចគ្រប់អាត្មា ។
* ទីបី *មោហុម្មត្តកោ* ឆ្កួតព្រោះមោហោខ្វះបញ្ញា
វង្វេងមិនស្គាល់ព្រះធម្មា អ្នកផងគេរៀវមិនហ៊ានគប់ ។
ជួនឆ្កួតភ្លេចជាតិភ្លេចត្រកូល ដ្បិតមោហៈចូលពេញខ្លួនស៊ប់
អាប់ឥតបញ្ញាងងឹតជ្រប់ ឆ្កួតឥតធមិទប់មិនស្គាល់បុណ្យ ។
ភ្នែកភ្លឺដូចខ្វាក់មិនស្គាល់ផ្លូវ យល់ខុសជាត្រូវឆ្កួតនេះកុន
ពួកនេះបើបានជាដើរមុន នាំគេឱ្យស៊ុនឆ្កួតតាមដែរ ។
បើដឹកនាំគេក្នុងជំនុំ អាចមានគ្រោះធំដោយសារតែ
នាំគេឱ្យខុសដូចខ្លួនដែរ មោហោបង្វែរឱ្យលេលា ។
* *ទិដ្ឋុម្មត្តកោ* ឆ្កួតទីបួន ឆ្កួតនេះឆ្កួតមួនមើលមិនជា
ប្រកាន់ទិដ្ឋិផ្ទុយធម្មា ទាញគេគ្រប់គ្នាឱ្យតាមខ្លួន ។
* *យក្ខុម្មត្តកោ* ឆ្កួតទីប្រាំ អាក្រក់សាំញ៉ាំពេញចំនួន
ឆ្កួតព្រោះយក្សចូលនៅពេញខ្លួន សំដីខុសផួនប្លែកធម្មតា ។
ពាក្យយក្សនេះគឺបិសាចព្រាយ ចូលមកទម្លាយឱ្យមោហា
ចេញសំដីខ្មោចឬអ្នកតា ដែលយើងហៅថាខ្មោចព្រាយចូល ។
ខ្មោចយក្សចូលខ្លួនក្លែងនិយាយ ហាក់មានប្រេតព្រាយមកមីរមួល
ឆ្លើយឆ្លងញ័រញ៉ាក់ខ្មោចចេញចូល អ្នកស្រុកបបួលគ្នាបន់ស្រន់ ។
* ប្រាំមួយ *បិត្តុម្មត្តកោ* ជួនដោះអាវខោឆ្កួតអាប់អន់
កម្រើកប្រមាត់វិលឥតស្រន់ ឆ្កួតមិនអាចបន់ស្រន់ជាបាន ។
គឺឆ្កួតមែនទែនហៅរិកល ឆ្កួតលែងដឹងខ្យល់យល់ដើមដាន
សរសៃប្រាសាទភ្លេចវិញ្ញាណ ជួនព្យាបាលបានជួនដូចសត្វ ។

* ប្រាំពីរ *សុរម្មត្តកោ*
ឆ្កួតព្រោះសុរាអាក្រក់ក្តាត់
គឺឆ្កួតប្រមឹកគ្រប់វេលា
បើស្រវឹងហើយរលាតែ
ដំណើរទ្រេតទ្រោតសំដីខ្មោច
សតិបញ្ញាខ្សោយខិនអន់
* ឯ *ព្យសនុម្មត្តកោ*
ឆ្កួតព្រោះវិនាសព្រាត់គ្រួសារ
ឬក៏វិនាសទ្រព្យសម្បត្តិ
ទ្រព្យពេញស្រទ្បាញ់ឥតបីគណ-
ទៅជាវិកលឆ្កួតស្រែកយំ
សង្រេងខ្សឹកខ្សួលមិនងាយបាត់

អាឡេអាឡោស្មារតីបាត់
ដូចខ្ទួចប្រមាត់មិនអាចកែ ។
មិនសួរដែលជារាល់ថ្ងៃ-ខែ
ជេរឪជេរម៉ែកូនប្រពន្ធ ។
ក្លិនខ្លួនអសោចិ៍កើតមោហន្ធ
ផឹកឆ្កួតមិនស្រន់ហៅឆ្កួតស្រា ។
មិនចេះបញ្ឈោរជេរអ្នកណា
មាតាបិតាកូនប្រពន្ធ ។
សោយសោកពេកក្តាត់បោកខ្លួនទន់
នាត្រូវអាសន្នមកពង្រាត់ ។
សោកសៅក្តៅងំថ្លើមប្រមាត់
នេះចាត់ថាឆ្កួតទីប្រាំបី ។

**នួច . ជឹម**
ការិយាល័យគរុកោសល្យពុទ្ធិកសិក្សា
ក្រសួងធម្មការ និងសាសនា

## សេចក្តីជូនដំណឹង

អំពីលទ្ធផលនៃចម្លើយ " កំណាព្យ ប្រស្នា "

គណៈកម្មការនិពន្ធទស្សនាវដ្ដីកម្ពុជសុរិយា មានកិត្តិយសសូមប្រគេន និងជូនដំណឹងចំពោះព្រះតេជព្រះគុណ និងចំពោះអស់លោក អ្នកនាងកញ្ញា ព្រមទាំងមិត្តអ្នកអានជាទីគោរពថា គណៈកម្មការនិពន្ធ សូមអភ័យទោស ដោយមិនបានចុះចម្លើយប្រស្នាដែលបានចុះក្នុងទស្សនាវដ្ដី លេខ ៣ . ១៩៩៥ ។ គណៈកម្មការនឹងចុះផ្សាយចម្លើយប្រស្នានោះ នៅលេខក្រោយ ។

ក្នុងលេខនេះ គណៈកម្មការនិពន្ធ មានកិត្តិយសសូមចុះផ្សាយ " កំណាព្យប្រស្នា " មួយទៀត របស់ឯកឧត្តម វណ្ណ ស៊ុនហេង អ្នកតំណាងរាស្ត្រ មណ្ឌលព្រៃវែង ។ គណៈកម្មការនិពន្ធ សូមជម្រាបថា ចម្លើយទាំងឡាយដែលត្រូវនឹងខ្លឹមសាររបស់ប្រស្នា នឹងបានទទួលរង្វាន់តាមក៏រិតនៃចំណាត់ថ្នាក់ ។ សូមអញ្ជើញលោកអ្នកអានទាំងឡាយ ដែលស្រឡាញ់អក្សរសាស្ត្រខ្មែរ មេត្តាចូលរួមសាកល្បងឆ្លើយឱ្យបានច្រើនជាអតិបរមា ។

## កំណាព្យប្រស្នា

** នេះនឹងថ្លាថ្លែងតែងសេចក្ដី ពីតាឥសីលោកប្លែងសារ*
*ផ្ញើទៅស្រីម្នាក់ដោយលាក់ការណ៍ មិនឱ្យនរណាមើលយល់បាន ។*
** ជូនខ្ញុំប្រទះសារសម្ងាត់ មើលកាត់ខ្លឹមសារថាស្មានៗ*
*ក្រែងពុំប្រាកដស្ទួរសន្តាន ក្រែងចេះចំណានជាងខ្ញុំបាទ ។*

*« (៣) ធំរងេមីធរលងលីភ្នំកែ (១០) ទីកសាលលមមីលោកេរយ*
*(១០) ដីន្លៃលះអមីដុងដើរយ (៤) សេចមេឆ្នាឆ្នាមីយយយលខ្ពដ្ឋស្រី » ។*

** សូមប្រែសេចក្ដីន័យបង្កប់ ពិនិត្យឱ្យសព្វលេខ អក្ខរា*
*នេះឯងជាក្បួនខ្មែរប្លែងសារ បុរាណាចារ្យតែងកំសាន្ត ។*

** បើរកឃើញស័ព្ទសារសេចក្ដី សូមស្ដីបញ្ជាក់ពីដើមដាន*
*តើកាព្យឃ្លានេះឥសីបាន ស្រង់តាមលំអានរឿងឈ្មោះអ្វី ? ។*

**ខណ្ឌ ស៊ុនហេង**

***

មនុស្សពាល ទោះបីរស់នៅជាមួយបណ្ឌិតអស់មួយជីវិត
ក៏នៅតែមិនស្គាល់ព្រះធម៌ ដូចវែកមិនដឹងរសជាតិសម្ល ។

( ចាកធម្មបទ - ពាលវគ្គ )

# ការបែងចែកគម្ពីរព្រះត្រៃបិដក

## ( ត )

ចំនួនវត្តដែលបានទទួលគម្ពីរព្រះត្រៃបិដករួចមកហើយគឺ :

*គ) នៅក្នុងខេត្ត កោះកុង វត្តចំនួន ១៤ បានទទួល ១ ចប់ ក្នុង ១ វត្ត ត្រូវជា ១៤ ចប់ ( សេចក្ដីសំរេចលេខ ២៧០ / ៩៥ កធស / ២៨ . ១១ . ៩៥ ) ដូចមានខាងក្រោម :*

១. វត្ត ជោតញាណ

២. វត្ត អំពីរទិយារាម

៣. វត្ត មណ្ឌលសីមារាម

៤. វត្ត សមុទ្រនារាម

៥. វត្ត កែវមរកត

៦. វត្ត សុវណ្ណពិសី

៧. វត្ត សុវណ្ណបពិត

៨. វត្ត កោះស្រឡៅ

៩. វត្ត មាតាគីរី

១០. វត្ត សាលាម្នាង

១១. វត្ត ឧត្តមមុនី

១២. វត្ត អង្គសិលាមុនី

១៣. វត្ត បទុមសាគរ

១៤. វត្ត ពោធិគីរី

*ឃ) នៅក្នុងខេត្ត បន្ទាយមានជ័យ វត្តចំនួន ៥១ បានទទួល ១ ចប់ ក្នុង ១ វត្ត ត្រូវជា ៥១ ចប់ ( សេចក្ដីសំរេចលេខ ២០៨ / ៩៥ កធស / ៤ . ១១ . ១៩៩៥ ) ដូចខាងក្រោម :*

១. វត្ត ចមសុទ្ធាវាស (មេគណ)

២. វត្ត សមាធិផល (អនុគណ)

៣. វត្ត ឫស្សីក្រោក (អនុគណ)

៤. វត្ត ជប់វារី (អនុគណ)

៥. វត្ត កណ្ដាល (អនុគណ)

៦. វត្ត ស្វាយចេក (អនុគណ)

| | |
|---|---|
| ៧. វត្ត និមិត្ត (អនុគណ) | ២៩. វត្ត អូរស្វ៉ូត |
| ៨. វត្ត ព្រះពន្លា | ៣០. វត្ត សុវណ្ណគិរី |
| ៩. វត្ត សុភមង្គល | ៣១. វត្ត គោកធ្នង់ |
| ១០. វត្ត ភ្នំជញ្ជាំង | ៣២. វត្ត បន្ទាយនាង |
| ១១. វត្ត ភ្នំបាក់ | ៣៣. វត្ត ពោធិកែវ |
| ១២. វត្ត មុនីសោភ័ណ | ៣៤. វត្ត គិរីសាគរ |
| ១៣. វត្ត ធម្មសាមគ្គី | ៣៥. វត្ត ភ្នំលៀប |
| ១៤. វត្ត បរមនិវេសន៍ | ៣៦. វត្ត តាប៉ុន |
| ១៥. វត្ត ឯករង្សី | ៣៧. វត្ត អំពិល |
| ១៦. វត្ត សេនាប្រជុំពល | ៣៨. វត្ត ទន្លាប់ |
| ១៧. វត្ត កោះពងសត្វ | ៣៩. វត្ត ទានកម្ម |
| ១៨. វត្ត អង្គាបុស្ស | ៤០. វត្ត ឈ្មោះមានជ័យ |
| ១៩. វត្ត ល្វង | ៤១. វត្ត ត្រពាំងថ្ម |
| ២០. វត្ត អញ្ចាញ | ៤២. វត្ត ស្វាយសរ |
| ២១. វត្ត គយម៉ែង | ៤៣. វត្ត ណាំតៅ |
| ២២. វត្ត និវេសន៍ | ៤៤. វត្ត តាបែន |
| ២៣. វត្ត អន្លង់ថ្ងាន់ | ៤៥. វត្ត ស្រះចែង |
| ២៤. វត្ត បឹងត្រាវ | ៤៦. វត្ត ទ្រាស |
| ២៥. វត្ត សឿ | ៤៧. វត្ត ពោធិវាល |
| ២៦. វត្ត ចំណោម | ៤៨. វត្ត បន្ទាយឆ្មា |
| ២៧. វត្ត សង់ប្រាសាទ | ៤៩. វត្ត សិង្ហ |
| ២៨. វត្ត គិរីប្រាសាទ | ៥០. វត្ត ដុងអារញ្ញ |

៩១. វត្ត បាលិលេយ្យ

ង) នៅក្នុងខេត្ត ក្រចេះ វត្តចំនួន ១៤ បានទទួល ១ ចប់ ក្នុង ១ វត្ត ត្រូវជា ១៤ ចប់ ( សេចក្ដីសំរេចលេខ ២០៥ / ៩៥ កធស / ៤ . ១០ . ១៩៩៥ ) ដូចខាងក្រោម :

| | | |
|---|---|---|
| ១. វត្ត សិរីសន្ធរវង្ស | (មេគណ) | ៨. វត្ត រដ្ឋបាណារាម " ប៉ាឆា " |
| ២. វត្ត តបសុខារាម | (អនុគណ) | ៩. វត្ត សិលោនទី |
| ៣. វត្ត ភូមិថ្មី | (អនុគណ) | ១០. វត្ត ឌីដុះ |
| ៤. វត្ត វិហារធំ | (អនុគណ) | ១១. វត្ត ក្រគរ |
| ៥. វត្ត សំបុក | (អនុគណ) | ១២. វត្ត រការកណ្ដាល |
| ៦. វត្ត ផ្សារស្នួល | (អនុគណ) | ១៣. វត្ត វេឡុការាម |
| ៧. វត្ត ភ្នំសុពណ៌គិរី | | ១៤. វត្ត សិរីបុណ្ណារាម |

ច) នៅក្នុងខេត្ត កំពង់ឆ្នាំង វត្តចំនួន ៤១ បានទទួល ១ ចប់ ក្នុង ១ វត្ត ត្រូវជា ៤១ ចប់ ( សេចក្ដីសំរេចលេខ ២២៨ / ៩៥ កធស / ២៥ . ១០ . ៩៥ ) ដូចមានខាងក្រោម :

| | | | |
|---|---|---|---|
| ១. វត្ត ខេមរ័ន្ត | (មេគណ) | ៧. វត្ត ចន្ទសុរិយា | (អនុគណ) |
| ២. វត្ត ទេពធិតារាម | (អនុគណ) | ៨. វត្ត អម្ពវ័ន | (អនុគណ) |
| ៣. វត្ត សន្ទៃ | (អនុគណ) | ៩. វត្ត សេដ្ឋី | (អនុគណ) |
| ៤. វត្ត ព្រះឥន្ទទេព | (អនុគណ) | ១០. វត្ត កាសេមរតនារាម | |
| ៥. វត្ត គង្គា | (អនុគណ) | ១១. វត្ត អារញ្ញិការាម | |
| ៦. វត្ត សុវណ្ណមយូរា | (អនុគណ) | ១២. វត្ត ពន្លៃ | |

១៣. វត្ត កុលម្ចាវ័ន
១៤. វត្ត ក្រាំងល្វា
១៥. វត្ត សាមគ្គីសុខារាម
១៦. វត្ត អង្គមេត្រី
១៧. វត្ត ភ្នំសន្ទូច
១៨. វត្ត ទួលមេត្រី
១៩. វត្ត សំបួរមាស
២០. វត្ត ប្រាសាទស្គាំ
២១. វត្ត ត្រពាំងស្នោរ
២២. វត្ត សំប៉ាន
២៣. វត្ត ព្រះចន្ទរង្សី
២៤. វត្ត ដីរស
២៥. វត្ត នទីមូលារាម
២៦. វត្ត ថ្មស
២៧. វត្ត ពោធិសត្ថារាម
២៨. វត្ត ទេពអប្សរ
២៩. វត្ត សំរោងរង្សី
៣០. វត្ត ត្រពាំងជុំ
៣១. វត្ត អង្គសិរី
៣២. វត្ត ស្នោរ
៣៣. វត្ត សិរីបណ្ឌប
៣៤. វត្ត ចំបក់រង្សី
៣៥. វត្ត រវៀងជុំ
៣៦. វត្ត អង្គ
៣៧. វត្ត រាជាយតនារាម
៣៨. វត្ត ព្រះបាទក្រុងល័ក្ខណ៍
៣៩. វត្ត បល្ល័ង្ក
៤០. វត្ត រតនមណីសាគរ
៤១. វត្ត ទឹកជុំ

---

*( នៅមានតទៅខេត្តផ្សេងទៀត )*

# កាលប្បវត្តិ

## នៃសកម្មភាពសំខាន់ៗ របស់ពុទ្ធសាសនបណ្ឌិត្យ
## នៃក្រសួងធម្មការ និងសាសនា នៅក្នុងឆ្នាំ ១៩៩៥

### ខែ មករា

ថ្ងៃ ០៩ - លោកសាស្ត្រាចារ្យ អូណូហ្សាវ៉ា នៃមហាវិទ្យាល័យ ត្សឹគូបា បានអញ្ជើញមកពុទ្ធសាសនបណ្ឌិត្យ ដើម្បីពិភាក្សាអំពីលទ្ធភាពធ្វើកិច្ចសហប្រតិបត្តិការ ក្នុងការស្រាវជ្រាវកម្ពុជា - ជប៉ុន ។

ថ្ងៃ ១៦ - គណៈប្រតិភូរបស់អង្គការពុទ្ធសាសនាគ្រហស្ថ រីស្សូ កូសិ-កៃ ដឹកនាំដោយព្រះតេជគុណ ខូណូ និងមានសមាជិក ២ រូបទៀតគឺ លោកតេរុហ៊ីសា ណាបាតា និងលោក វ៉ាអ៊ិជិ ហ្វូស៊ីណា បានអញ្ជើញមកពុទ្ធសាសនបណ្ឌិត្យ ដើម្បីពិភាក្សាបញ្ហាគម្រោងសាងសង់អគារពុទ្ធសាសនបណ្ឌិត្យ ជាមួយឯកឧត្តម ឈឹម អៀម អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា, លោក យី ធន់ ទីប្រឹក្សាអមក្រសួងធម្មការ និង សាសនា ដែលជាអ្នករៀបចំគម្រោងសាងសង់ និងលោក ឱម ខែម នាយកពុទ្ធសាសនបណ្ឌិត្យ ។

ថ្ងៃ ១៩.២០ - ក្រសួងធម្មការនិងសាសនា បានចាត់ឯកឧត្តម ឈន អៀម និងលោក យី ធន់ ឱ្យចុះទៅដោះស្រាយទំនាស់ រវាងបរិស័ទធម្មយុត្តនិងមហានិកាយ នៅវត្តពាលញែក ខេត្តពោធិសាត់ ជាមួយគណៈកម្មការទី ៧ របស់សភាជាតិ ដែលដឹកនាំដឹកនាំដោយឯកឧត្តមជៀម យាប ។

## ខែ មីនា

ថ្ងៃ ២៨ - លោកបណ្ឌិត អ វ៉ាលណ៍ នៃសកលវិទ្យាល័យ វីយែន ប្រទេសអូទ្រីស បានអញ្ជើញមកធ្វើទស្សនកិច្ច នៅពុទ្ធសាសនបណ្ឌិត្យ ។

## ខែ មេសា

ថ្ងៃ ០៤ - គណៈប្រតិភូរបស់អង្គការ JSRC ដឹកនាំដោយព្រះតេជគុណ មូចាគូ បាននិមន្ត និងអញ្ជើញដល់ភ្នំពេញ ដើម្បីពិភាក្សាអំពីការប្រគល់គម្ពីរព្រះត្រៃបិដក ចំនួន ១.០០០ ចប់ ។ សមាសភាពនៃគណៈប្រតិភូមាន ៖ ព្រះតេជព្រះគុណ ស៊ីណូហារ៉ា កូអិជី, អ្នកស្រី តូគី មូចាគូ និងលោក កាសាហារ៉ា កាសាអូ ។

ថ្ងៃ ០៥ - លោក ជីនី ឡុមបា ចាងហ្វាងសាលាបារាំងចុងបូព៌ា បានអញ្ជើញមកទស្សនាបណ្ណាល័យ របស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ដោយមានលោក អូលីវិយេ ដឺបៃណុង នាយកមូលនិធិស្រាវជ្រាវអំពីឯកសារសរសេរដៃ នៅព្រះរាជាណាចក្រកម្ពុជា ជូនដំណើរផង ។ ក្នុងឱកាសនោះ លោក យី ធន់ បានធ្វើរបាយការណ៍ជូនភ្ញៀវ អំពីស្ថានភាពរបស់ពុទ្ធសាសនបណ្ឌិត្យនាបច្ចុប្បន្ន និងគម្រោងការស្តារបណ្ណាល័យទៅអនាគត ព្រមទាំងបានស្នើសុំឱ្យសាលាបារាំងចុងបូព៌ាជួយផ្តល់ឯកសារសំខាន់ៗខ្លះ ដល់បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ។

ថ្ងៃ២១.២២ - មន្ត្រីរាជការ នៃក្រសួងធម្មការ និងសាសនា ទាំងអស់ រួមទាំងមន្ត្រីរាជការ មកពីខេត្ត - ក្រុងនានា ទូទាំងប្រទេស បានចូលរួមក្នុងអនុសំវច្ឆរមហាសន្និបាតសង្ឃ លើកទី ៤ ដែលបានប្រព្រឹត្តទៅនៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ក្រោមព្រះរាជាធិបតីភាព ដ៏ខ្ពង់

ខ្ពស់របស់សម្តេចព្រះមហាសុមេធាធិបតី ទេព វង្ស ព្រះសង្ឃរាជគណៈមហានិកាយ ។

ថ្ងៃ ២៣ . ពិធីបញ្ចុះបឋមសិលា នៅវិទ្យាស្ថានព្រះពុទ្ធសាសនាព្រះសីហនុ-ធម្មាធិរាជ នៅកំពង់ស្ពឺ ក្រោមព្រះរាជាធិបតីភាពរបស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ។

ថ្ងៃ ២៦ . លោក យី ធន់ ចេញដំណើរទៅធ្វើទស្សនកិច្ចតាមវត្តខ្មែរនានា នៅសហរដ្ឋអាមេរិក ។

## ខែ មិថុនា

ថ្ងៃ ១៨ . គណៈប្រតិភូអ្នកឧបត្ថម្ភការបោះពុម្ពឡើងវិញ នៃគម្ពីរព្រះត្រៃបិដកជប៉ុន ដឹកនាំដោយព្រះតេជព្រះគុណ មូចាតូ បានមកដល់ភ្នំពេញដើម្បីចូលរួមក្នុងពិធីប្រគល់គម្ពីរព្រះត្រៃបិដក ចំពោះក្រសួងធម្មការ និង សាសនា ។

ថ្ងៃ ២០ . ពិធីប្រគល់គម្ពីរព្រះត្រៃបិដក ចំនួន ១.០០០ ចប់ ចំពោះក្រសួងធម្មការ និងសាសនា នៅសាលសន្និសីទចតុមុខ ក្រោមព្រះរាជា-ធិបតីភាពរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហេសី មុនីនាថ សីហនុ ។

ថ្ងៃ ២២ . គណៈប្រតិភូអ្នកឧបត្ថម្ភការបោះពុម្ពគម្ពីរព្រះត្រៃបិដកឡើងវិញ ចំនួន ៧៩ រូប បានអញ្ជើញត្រឡប់វិញ ។

ថ្ងៃ ២៤ . ពុទ្ធសាសនបណ្ឌិត្យបានទទួលសៀវភៅ បីចំណងជើងគឺ វិជ្ជាប្រាំបី

ប្រការ ភាណវារបាលី និងសប្តបរិត្ត-ទ្វាទសបរិត្ត សរុបទាំងអស់ចំនួន ១២.០០០ក្បាល ដែលបោះពុម្ពឡើងវិញដោយជំនួយឧបត្ថម្ភរបស់អង្គការពុទ្ធសាសនា តៃវ៉ាន់ ។

ថ្ងៃ ២៨ - អង្គការ អាស៊ីរ៉ា របស់ប្រទេសជប៉ុន បានប្រគល់សៀវភៅបីមុខខាងផ្នែកវេយ្យាករណ៍បាលី ដែលអង្គការនេះបានជួយឧបត្ថម្ភក្នុងការបោះពុម្ពឡើងវិញ ចំពោះពុទ្ធសាសនបណ្ឌិត្យ ។

## ខែ កក្កដា

ថ្ងៃ ០៣ - មន្ត្រីរាជការ នៃក្រសួងធម្មការ និងសាសនា ដឹកនាំដោយឯកឧត្តម ហៀង វណ្ណារ័ត្ន បានអញ្ជើញទៅចូលរួមក្នុងសិក្ខាសាលា ស្តីពីពុទ្ធ-សាសនា និងកិច្ចអភិវឌ្ឍន៍ ដែលរៀបចំឡើងដោយព្រះតេជព្រះគុណ ញ៉ែម គីមតេង នាយកអង្គការសន្តិសេនា នៅខេត្តស្វាយរៀង ។ សិក្ខាសាលានេះ ឧបត្ថម្ភដោយអង្គការមូលនិធិ ខុនរ៉ាដ អាដិនណៅ-អ៊ែរ របស់ប្រទេសអាល្លឺម៉ង់ ។

ថ្ងៃ ១០ - ឯកឧត្តម ឈន អៀម - លោក យី ធន់ និងលោក តេបញ្ញីកា នាយកអង្គការ ជី អេស អ ស៊ី, ជប៉ុន នៅភ្នំពេញ បានអញ្ជើញទៅសុំយោបល់ពី ឯកឧត្តម វណ្ណ មូលីវណ្ណ អំពីគម្រោងសាងសង់អគារពុទ្ធសាសនបណ្ឌិត្យថ្មី ។

ថ្ងៃ ១១ - ឯកឧត្តម ឈន អៀម - លោក យី ធន់ និងលោក តេបញ្ញីកា បានអញ្ជើញទៅសាលាក្រុងភ្នំពេញ ដើម្បីពិភាក្សាការងារបច្ចេក-ទេសសំណង់ និងធ្វើប្លង់អគារសាជាថ្មី ជាមួយស្ថាបត្យករ លី ជិនធង ។

ថ្ងៃ ១២ - ពិធីសម្ពោធសាលាពុទ្ធិកបឋមសិក្សា ដែលឧបត្ថម្ភឡើងដោយព្រះតេជព្រះគុណ ស៊ីប៊ូយ និងព្រះសង្ឃជប៉ុន នៅវត្តឧណ្ណាលោម ក្រោមព្រះរាជាធិបតីភាព របស់សម្តេចព្រះសង្ឃរាជ គណៈមហានិកាយ ព្រះមហាសុមេធាធិបតី ទេព វង្ស ។

ថ្ងៃ ២០ - គណៈប្រតិភូរបស់អង្គការ រីស្សូ កូសី-កៃ ដែលមានព្រះតេជព្រះគុណ យាស៊ុហ៊ីកូសៃតូ និងលោក ខូណូ បានអញ្ជើញមកដល់រាជធានីភ្នំពេញ ដើម្បីចូលរួមក្នុងពិធីចុះហត្ថលេខាផ្តល់ថវិកា ចំពោះពុទ្ធសាសនបណ្ឌិត្យ ដើម្បីសង់អគារថ្មី ។

ថ្ងៃ ២១ - ពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ថវិកា ចំនួន ៤៩២.៥៣២ ដុល្លារអាមេរិក សំរាប់សង់អគារពុទ្ធសាសនបណ្ឌិត្យថ្មី រវាងព្រះតេជព្រះគុណ យ៉ាស៊ុហ៊ីកូ សៃតូ ដែលតំណាងរបស់ព្រះតេជព្រះគុណ អាគីរ៉ា អ៊ីុឈិដា ប្រធានគណៈកម្មាធិការនាយក នៃអង្គការ រីស្សូ កូសី-កៃ និងឯកឧត្តម ឈន អៀម អនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា តំណាងឱ្យពុទ្ធសាសនបណ្ឌិត្យ ។

## ខែ សីហា

ថ្ងៃ ០៨ - លោកសាស្ត្រាចារ្យ កូម៉ែ នៃសកលវិទ្យាល័យត្សឹគូបា, តូក្យូ បានអញ្ជើញមកធ្វើទស្សនកិច្ច នៅពុទ្ធសាសនបណ្ឌិត្យ និងពិភាក្សាអំពីការស្រាវជ្រាវ របស់និស្សិតជប៉ុន នៅខេត្តតាកែវ ។

ថ្ងៃ ០៩ - លោក យី ធន់ ជួបពិភាក្សាការងារបោះពុម្ពសៀវភៅ និងសិទ្ធិអ្នកនិពន្ធ ជាមួយនាងកញ្ញា រ៉ូហ្សាមារីយ៉ា ខ្វរ៉ង់ តំណាងអង្គការ យូណេស្កូ ខាងផ្នែកសៀវភៅ ។

ថ្ងៃ ១០ - ជួបពិភាក្សាការងារ និងស្តាប់របាយការណ៍របស់និស្សិតជប៉ុន ឈ្មោះ យ៉ាអូរី ម៉ារិកុ អំពីលទ្ធផលនៃការស្រាវជ្រាវអំពីភូមិខ្មែរ នៅខេត្តតាកែវ ។

ថ្ងៃ ១១ - ក្រសួងធម្មការ និងសាសនា បានប្រគល់គម្ពីរព្រះត្រៃបិដក ចំនួន ៣៤ ចប់ ចំពោះវត្តទាំងឡាយ នៅក្នុងរាជធានី ភ្នំពេញ ។ ពិធីប្រគល់បានប្រព្រឹត្តទៅ នៅក្នុងវត្តបទុមវតី ក្រុងភ្នំពេញ ក្រោមអធិបតីភាពសម្តេចព្រះសង្ឃរាជ គណៈមហានិកាយ ទេព វង្ស និងឯកឧត្តម ហៀន វណ្ណារ័ត្ន រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ។

ថ្ងៃ ២៦ - ពិធីប្រគល់គម្ពីរព្រះត្រៃបិដក ចំនួន ៤៧ ចប់ ចំពោះវត្ត និងព្រះសង្ឃក្នុងខេត្តកណ្តាល ក្រោមអធិបតីភាព ឯកឧត្តម ហៀន វណ្ណារ័ត្ន នៅក្នុងបរិវេណវត្តជ្រោយអំពិល ខេត្តកណ្តាល ។

## ខែ កញ្ញា

ថ្ងៃ ១២ - នាយកគម្រោងអង្គការហិនរិចប៊ូល រាយការណ៍អំពីលទ្ធផលការងារ និងផែនការការងារ សំរាប់ឆ្នាំ ១៩៩៦ ដែលអង្គការនេះ បានសហ-ការជាមួយពុទ្ធសាសនបណ្ឌិត្យ ក្នុងការស្តារនូវវិស័យវប្បធម៌ខ្មែរ ។

ថ្ងៃ ២៧ - លោក យី ធន់ - បណ្ឌិត ពៅ ធនវឌ្ឍន៍ និងបណ្ឌិត ហ៊ែរ ឡុសម៉ាន់ បានអញ្ជើញទៅធ្វើទស្សនកិច្ច នៅទីក្រុងហូជីមិញ ដើម្បីស្វែងរកឯកសារខ្មែរ ដែលមានតំកល់ទុកនៅក្នុងបណ្ណាល័យនានា នៃទីក្រុងហូជីមិញ ។

## ខែ តុលា

ថ្ងៃ ០២ - ពិធីប្រគល់គម្ពីរព្រះត្រៃបិដក ចំនួន ១១៩ ចប់ ចំពោះព្រះសង្ឃ និងវត្តនានា ក្នុងខេត្តកំពង់ចាម ក្រោមអធិបតីភាព សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១ នៃព្រះរាជរដ្ឋាភិបាល ។

ថ្ងៃ ២៤ - ឯកឧត្តម ឈិន អៀម អនុរដ្ឋលេខាធិការ នៃក្រសួងធម្មការ និង សាសនា បានដឹកនាំគណៈប្រតិភូព្រះសង្ឃ ចំនួន ៤ អង្គ ទៅចូលរួម ក្នុងពិធីសម្ពោធឆ្លងព្រះពុទ្ធរូប នៅទីក្រុង ហ្វូគូអូកា ប្រទេសជប៉ុន ។

ថ្ងៃ ០៧ - ក្រសួងធម្មការ និងសាសនា បាននាំយកគម្ពីរព្រះត្រៃបិដក ចំនួន ៨៧ ចប់ ទៅប្រគេនព្រះសង្ឃ និងវត្តនានា ក្នុងខេត្តព្រៃវែង ។

ថ្ងៃ ០៨ - ក្រសួងធម្មការ និងសាសនា បាននាំយកគម្ពីរព្រះត្រៃបិដក ចំនួន ៨៦ ចប់ ទៅប្រគេនព្រះសង្ឃ និងវត្តនានា ក្នុងខេត្តតាកែវ ។

ថ្ងៃ ១២ - ព្រះតេជព្រះគុណ ណូដា បុគ្គលិកថ្មីរបស់អង្គការ ជី អេស អ ស៊ី ទទួលបន្ទុកផ្នែកវប្បធម៌ និងអភិវឌ្ឍន៍ បានអញ្ជើញទៅសម្តែងការ គួរសម និងពិភាក្សាការងារជាមួយលោក យី ធន់ ទីប្រឹក្សារបស់ ក្រសួងធម្មការ និងជានិពន្ធនាយកទស្សនាវដ្តី កម្ពុជសុរិយា និងលោក ឱម ខែម នាយកពុទ្ធសាសនបណ្ឌិត្យ នៅទីស្នាក់ការបណ្តោះអាសន្ន របស់ពុទ្ធសាសនបណ្ឌិត្យ នាវត្តឧណ្ណាលោម ។

ថ្ងៃ ១៣ - ព្រះតេជគុណ ណូដា ដែលមានលោក តេហ៊្សូកា នាយកអង្គការ ជី អេស អ ស៊ី នៅភ្នំពេញ និងលោក យី ធន់ ជូនដំណើរផង បានអញ្ជើញទៅសម្តែងការគួរសម ចំពោះឯកឧត្តម ហៀង វណ្ណរឹទ្ធ រដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា នៅទីស្តីការរបស់ ក្រសួង ។

ថ្ងៃ ១៧ - ក្រសួងធម្មការ និងសាសនា បាននាំយកគម្ពីរព្រះត្រៃបិដក ចំនួន ៧ ចប់ ទៅប្រគេនព្រះសង្ឃ និងវត្តនានា នៅក្រុងព្រះសីហនុ ។ ពិធីប្រគល់ត្រូវបានគេប្រារព្ធធ្វើនៅវត្តឥន្ទញាណ ក្រោមអធិបតីភាព របស់ឯកឧត្តម ហៀន វណ្ណារ័ត្ន រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា និងឯកឧត្តម ឃីម បូ អភិបាលរង ក្រុងព្រះសីហនុ ។

ថ្ងៃ ២០ - ក្រសួងធម្មការ និងសាសនា បានរៀបចំធ្វើពិធីប្រគល់គម្ពីរព្រះ-ត្រៃបិដក ចំនួន ៤៩ ចប់ ទៅខេត្តកំពត និងក្រុងកែប ក្រោម អធិបតីភាព ឯកឧត្តម ហៀន វណ្ណារត្ន ។

- នៅថ្ងៃដដែលនោះដែរ គណៈប្រតិភូមួយទៀត ដឹកនាំដោយ ឯកឧត្តម ដោក ណារិន អនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា បាននាំយកគម្ពីរព្រះត្រៃបិដក ចំនួន ៤២ ចប់ ទៅប្រគេនព្រះសង្ឃ និងវត្តនានា នៅក្នុងខេត្តស្វាយរៀង ។

ថ្ងៃ ២៤ - ឯកឧត្តម ឈន អៀម និងលោក យី ធន់ បានអញ្ជើញទៅប្រទេសជប៉ុន ដើម្បីធ្វើបាឋកថារំពីពុទ្ធសាសនានៅកម្ពុជា នៅតាមមហា-វិទ្យាល័យនានា នាទីក្រុង តូក្យូ ។

## ខែ វិច្ឆិកា

ថ្ងៃ ០៨ - ឯកឧត្តម ឈន អៀម និងលោក យី ធន់ បានអញ្ជើញទៅធ្វើទស្សនកិច្ច នៅពុទ្ធិកមហាវិទ្យាល័យ មហាចុឡា នៅវត្តមហាធាតុ និងពុទ្ធិកមហាវិទ្យាល័យ មហាមកុដ នៅវត្ត បវរនិវេសន៍ ព្រមទាំងពុទ្ធិកសមាគមពិភពលោក នាទីក្រុងបាងកក ព្រះរាជាណាចក្រថៃឡង់ ។

ថ្ងៃ ២១ - មន្ត្រីរាជការជាន់ខ្ពស់ នៃក្រសួងធម្មការ និងសាសនា និងមន្ត្រីជាន់ខ្ពស់សង្ឃទាំងអស់ បានអញ្ជើញ - និមន្ត ទៅចូលរួមក្នុងសិក្ខាសាលា ស្តីអំពីព្រះពុទ្ធសាសនា និងកិច្ចអភិវឌ្ឍន៍សង្គមខ្មែរ ដែលឧបត្ថម្ភដោយមូលនិធិអង្គការ ខុនរ៉ាដ អាដិនណៅអ៊ែរ នៅវត្តអន្លង់វិល ខេត្តបាត់ដំបង ។

ថ្ងៃ ២៦ - ពិធីចែកគម្ពីរព្រះត្រៃបិដក ចំនួន ៦៥ ចប់ នៅខេត្តបាត់ដំបង ។

## ខែ ធ្នូ

ថ្ងៃ ០៩ - លោកសាស្ត្រាចារ្យ អូណ៊ីហ្សាវ៉ា បានអញ្ជើញមកពិភាក្សាអំពីគម្រោងផែនការសហប្រតិបត្តិការ រវាងពុទ្ធសាសនបណ្ឌិត្យ និងសកលវិទ្យាល័យ ត្សឹគូបា, តូក្យូ សំរាប់ឆ្នាំ ១៩៩៦ - ១៩៩៧ ។ កិច្ចសហប្រតិបត្តិការលើកនេះ ផ្តោតទៅលើការទិញសៀវភៅ ដើម្បីតំកល់ទុកក្នុងបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ។

ថ្ងៃ ១២ - ព្រះតេជព្រះគុណ មូចាគូ ដឹកនាំប្រតិភូមួយក្រុមមកធ្វើទស្សនកិច្ចនៅកម្ពុជា និងដើម្បីចូលរួមក្នុងពិធីចែកគម្ពីរព្រះត្រៃបិដក នៅខេត្តកំពង់ស្ពឺ ។

ថ្ងៃ ១៤ - ពិធីចែកគម្ពីរព្រះត្រៃបិដក ចំនួន ៥៦ ចប់ នៅខេត្តកំពង់ស្ពឺ ក្រោមព្រះរាជាធិបតីភាពសម្តេចព្រះសង្ឃរាជ គណៈមហានិកាយ ទេព វង្ស ។ គណៈប្រតិភូជប៉ុន ដែលដឹកនាំដោយព្រះតេជព្រះគុណ មូចាគូ ក៏បានចូលរួមក្នុងពិធីនោះដែរ ។

- នៅថ្ងៃដដែលនោះដែរ គណៈប្រតិភូជប៉ុនដែលដឹកនាំដោយព្រះតេជព្រះគុណ មូចាគូ និងដោយមានលោក យី ធន់ ជូនដំណើរផងនោះ

បានបន្តដំណើរទៅពិនិត្យគម្រោងសាងសង់បណ្ណាល័យមួយ នៅក្រុងព្រះសីហនុ ។

ថ្ងៃ ១៥ - គណៈប្រតិភូរបស់ព្រះតេជព្រះគុណ ម្ចាស់គុ បានអញ្ជើញទៅពិនិត្យសាលារៀនមួយខ្នង នៅក្នុងភូមិតាពុល ស្រុកជុំគិរី ខេត្តកំពត ។

ថ្ងៃ ២៥ - ក្រសួងធម្មការ និងសាសនា បាននាំយកគម្ពីរព្រះត្រៃបិដក ចំនួន ៤៥ ចប់ ទៅប្រគេនព្រះសង្ឃ និងវត្តនានា នៅខេត្តកំពង់ធំ ។ ពិធីនេះបានប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម ហៀង វណ្ណារ័ត្ន ឯកឧត្តម ជៀង អំ អភិបាលខេត្តកំពង់ធំ ព្រះតេជព្រះគុណមេគណខេត្តកំពង់ធំ និងមន្ត្រីរាជការ ក្រសួងធម្មការ និងសាសនា និងមន្ត្រីរាជការខេត្តជាច្រើនរូបទៀត ។